# គម្ពីរ
# សារត្ថសង្គហៈ
# ភាគទី ២

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ១៥កើត ខែផល្គុន ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត

# គម្ពីរ
# សារត្ថសង្គហៈ
# ភាគទី ២

ដឹកនាំបកប្រែដោយ
ខ្ញុំព្រះករុណា
អាត្មាភាព យង់ សុផាត

ថ្ងៃ ១៥កើត ខែផល្គុន ព.ស. ២៥៥៥

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ : ២២៥ [illegible]

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា
## ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។

សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***ចម្លងជូន :***

- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

ខ្ញុំព្រះករុណា យើងខ្ញុំទាំងឡាយជាក្រុមគ្រួសារ មានសេចក្ដីជ្រះថ្លាលះបង់ នូវមច្ឆរិយៈ គឺសេចក្ដីកំណាញ់រួមគ្នាកសាងបោះពុម្ពសៀវភៅគម្ពីរសារត្ថសង្គហៈភាគ ២ នេះឡើងដើម្បីប្រគេន ចែកជូនលោកអ្នកសប្បុរសជាធម្មទាន តម្កល់ទុកនៅក្នុងព្រះពុទ្ធ-សាសនា ។

ដូច្នេះ ខ្ញុំព្រះករុណា យើងខ្ញុំទាំងឡាយ សូមលើកនូវមហា-កុសលធម្មទាននេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** លោកគ្រូវិនយាចារ្យ **គាំ អ៊ីវ** សូមលោកបានទទួលនូវបុញ្ញធម្មទានដូចយើងខ្ញុំផងដែរ ។

ម្យ៉ាងទៀត យើងខ្ញុំទាំងឡាយ សូមឧទ្ទិសបុញ្ញធម្មទាននេះដល់មាតា បិតា ជីដូន និងជីតា គ្រូឧបជ្ឈាយាចារ្យ ញាតកាក្នុងសង្សារវដ្ដ ដល់សក្កទេវរាជ ដល់ស្ដេចចតុលោកបាល ដល់យមរាជ និងសូមឧទ្ទិសប្រគេននូវមហាកុសលនេះ ដល់លោកម្ចាស់គ្រូ អគ្គ-បណ្ឌិតោ **យង់ សុផាត** ដែលជាប្រធានសមាគមធម្មទានអរិយវង្ស

*យង់សុផាត សូមលោកទាំងអស់ត្រេកអរអនុមោទនា នូវកុសល-ធម្មទាននេះ ដោយសេចក្តីជ្រះថ្លា សូមឲ្យបានសម្រេចនូវសម្បត្តិណាមួយ តាមសេចក្តីប្រាថ្នា កុំបីអាក់ខានឡើយ ។*

**យាវតិដ្ឋតិ សេលេន្ទោ** *ស្តេចភ្នំតាំងនៅដរាបណា* **យាវចន្ទោ វិរោចតិ** *ព្រះចន្ទនៅភ្លឺដរាបណា* **តាវតិដ្ឋតុ សទ្ធម្មោ ភគវន្តស្ស យសស្សិនោ** *សូមព្រះសទ្ធម្ម របស់ព្រះភគវន្តដ៏មានយស តាំងនៅដរាបនោះ* **ធម្មា ភិរតោ សទា** *សូមសត្វលោកត្រេកអរក្នុងធម៌សព្វកាល* **និច្ចំ ខេម សុភិក្ខាទិ សម្បទា ជនបទា ហោន្តុ** *សូមជនបទទាំងឡាយដល់ព្រមដោយសេចក្តីក្សេមក្សាន្ត មានអាហាររកបានងាយអស់កាលជានិច្ចហោង ។*

# អារម្ភកថា

*គម្ពីរសារត្ថសង្គហៈភាគ ២ នេះ ជាភាគបញ្ចប់ ដែលជាគម្ពីរព្រះនន្ទាចារ្យបានដកស្រង់មកពី* ***គម្ពីរអដ្ឋកថា និងគម្ពីរផ្សេងៗ*** *ជាច្រើនទៀត មើលគម្ពីរសារត្ថសង្គហៈនេះហើយ ធ្វើឲ្យកើតសេចក្តីជ្រះថ្លាក្នុងការមើលគម្ពីរផ្សេងៗ ទៀត អាស្រ័យហេតុដូច្នេះ ខ្ញុំ និងក្រុមការងារទាំងអស់ បាននាំគ្នាប្រែមកជាភាសាខ្មែរ ដើម្បីបូជាចំពោះគុណព្រះរតនត្រ័យផង ដើម្បីបុណ្យកុសលផង ដើម្បីរក្សាព្រះពុទ្ធសាសនាឲ្យបានគ្រប់ ៥០០០ ព្រះវស្សាផង ដើម្បីឲ្យជនានិកជនយល់អំពីតម្លៃព្រះពុទ្ធវចនៈផង ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់សព្វសត្វអស់កាលជាអង្វែងតទៅផង ។*

*ខ្ញុំសង្ឃឹមថា* ***គម្ពីរសារត្ថសង្គហៈនេះ*** *នឹងបានជាប្រយោជន៍ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែងក៏ប្រសើរជាងអត់ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយក៏គង់នៅមានខុសមិនខាន ជួនដោយចេះមិនដល់ ជួនដោយការភ្លេចភ្លាំង*

ជាពិសេសនោះ គឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិត ជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

សូមអស់មិត្តអ្នកអាន បានទទួលនូវការចេះដឹង ជាក្តើមតិកផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់ព្រះនិព្វាន ដែលជាបរិយោសាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណាអាត្មាភាព បានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ ៦៤៥ ដុល្លារសហរដ្ឋអាមេរិក ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទនៅ**

ប្រមាណ ៦៥ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ១០ ព្រះអង្គផងដែរ ដែលមានលោកគ្រូអគ្គបណ្ឌិត ម៊ុត សាចខ្ស្យ ជាប្រធាន ក្នុងការដឹកនាំ គណៈធម្មយាត្រានោះ ដោយទៅ ថ្វាយបង្គំបាន ៥១ កន្លែង បានការ ឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសិកា ឱម លក្ខណា នៅក្នុង ព.ស. ២៥៥០ ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស.២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែង ព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស.

**២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល )** និង **ប្រាក់ដុល្លារ ៤៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសស្រីលង្កា** ដែលមានលោកគ្រូអគ្គបណ្ឌិត **ម៉ុត សាខឿ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១២១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៤ ព្រះអង្គផងដែរ** ដោយទៅថ្វាយបង្គំបាន **១៩ កន្លែង** បានការឧបត្ថម្ភមកអំពីឧបាសក **ឡាយ សុខុម** និងឧបាសក **សោម រតនៈ** ឧបាសិកា **ស៊ិម ចណ្ណា** នៅក្នុង **ព.ស. ២៥៥១** ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

នឹកឃើញលង្កា នឹកឃើញកាលណា ជ្រះថ្លាក្រៃលែង
នៅពុទ្ធស្ថាន ១៩ កន្លែង ដែលខ្ញុំបានស្វែង
ទៅថ្វាយបង្គំ ។

១២១ អង្គា គាល់ព្រះបាទា នាស្ថានមនោរម
លើសុមនកូដ ជេស្ឋាឧត្តម ជាកំពូលភ្នំ
ក្នុងប្រវត្តិពុទ្ធ ។

### ង

ទឹកដីលង្កា ទឹកដីអស្ចារ្យ ពេញពោរដោយឫទ្ធិ
ទឹកឃើញកាលណា ជ្រះថ្លាក្រៃពិត ធម្មយាត្រាប្រណីត
ក្នុង ព.ស.២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥១ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល ) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទី ២** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គផងដែរ**បានការឧបត្ថម្ភអំពីឧបាសក **យឹត សុឃុណារ៉ា**ឧបាសិកា **ហ៊ីន ម៉ារ៉ាវលី** M. SU SOKUNORA et MmeINN VISAL + NARITA et RAKSA ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **អ៊ឹម រិទ្ធារី** ឧបាសិកា **សួន គល្យាណ**

ឧបាសិកា ស្ងួន ចរណៃ នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង

ច្រើនពុទ្ធសកពជ សាសនាអង្វែង ល្អហួសការថ្លែង

ឱ! ព្រះសាសនា ។

នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នាមសក្ការ

១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ

ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៣៦ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៣ ព្រះអង្គផងដែរ** បានការឧបត្ថម្ភអំពីឧបាសក **ឆាយ អ៊ិចស៊ាង** ឧបាសិកា **ហ្វាង គីមសែ**

ក្រោមការជ្រោមជ្រែងរបស់ឧបាសក **យន្ត សួន** នៅក្នុង **ព.ស. ២៥៥២** ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៣** ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង **ព.ស. ២៥៥២** ដែរ ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥៣ ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល** ( **១៣ លាន ០ សែន ៨ ម៉ឺន**) **និងប្រាក់ដុល្លារ ២០៨ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងពីឧបាសក **ឡាយ ស៊ុខុម** នៅក្នុង **ព.ស. ២៥៥៣** ( ២៥.០១.២០១០ ) ។

## ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ញប់ស្ញែងអស្ចារ្យ

ជ

ឱះឱ! ពុទ្ធស្ថាន ។

នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន

១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន

២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន ) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទប្រមាណ ២៧៧ នាក់ ក្នុងនោះក៏មាន ព្រះសង្ឃ ៤០ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១២ កន្លែងធំៗ បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

# គួរឱ្យសង្វេគ

*គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន*
*ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាន*
*ប្រៀបបានព្រៃស្ងាត់ ។*

*២៧៧ អង្គា ប្រណាមវន្ទា បង្គំថ្វាយថ្វាត់*
*បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ជម្ងឺយាត្រាកំណត់*
*ក្នុងពុទ្ធសករាជ ២៥៥៤ ។*

*ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស* **យង់ ស្វុខ** *( ស្លាប់ ) និងញោមស្រី* **ឈឹម ហាយ** *( ស្លាប់ ) ម្យ៉ាងទៀត ញាតកានៅក្នុងសង្សារវដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ* **ប៊ុត សាវង្ស** *លោកគ្រូធម្មបណ្ឌិត* **រស់ ស្ងួនតាត** *និងលោកគ្រូធម្មាចារ្យ* **គាំ អ៊ីវខ** *ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ* **សូមអនុមោទនា !!!**

*សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។*

*ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនូវអាសវក្កិលេស នាកាលជាអនាគតកុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណាទីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១ ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះសក្យមុនីទ្រង់ត្រាស់ថា* **នត្ថិ សន្តិ បរំ សុខំ** *ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។*

*អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែផល្គុន ព.ស.២៥៥៥*

**ដោយប្រធានសមាគមធម្មទានអរិយធន្យយ៉ង់ស្វាត**

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម្ទី សាលួន វាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង គុសល វាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គឹម ម៉ានិត ប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ម៉ូរ៉ា វាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ុម សុជាន ប្រែ

លោកអ្នកដ៏មានអាយុ មាន ចន្ថនា វាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្ដម វាយកុំព្យូទ័រ

ឧបាសក អ៊ុម វ៉ៃយ៉ា ជាទីប្រឹក្សាក្នុងកិច្ចការងារធម្មទាន

ឧបាសក សន ឈៀត ប្រែ

ឧបាសក ឡាន សុខុម ប្រែ

លោកគ្រូធម្មាចារ្យ គាំ អ៊ុច ពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឌិម ជំនិត ពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រឹម សុមេធ ពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ម្ជូ ស៊ីផូ ពិនិត្យអក្ខរាវិរុទ្ធ

ឋ

# សមាជិកសមាគមធម្មទានអរិយវង្សយ៉ង់ស្វធាត

សម្តេចព្រះសង្ឃរាជគណមហានិកាយ **នន្ទ ង៉ែត** ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ **យ៉ង់ ស្វធាត** ជាប្រធានសមាគម

លោកអភិបាលស្រុក ស្រេង ស្រាង ជាទីប្រឹក្សាសមាគម

ឧបាសក អ៊ឹម អ៊ៃយ៉ា ជាអនុប្រធានសមាគម

ឧបាសិកា ង៉ែត យូអេង ជាអនុប្រធានសមាគម

សាមណេរ ម៉ី សាលួន ជាលេខាធិការ

ឧបាសក ឡាន សុខុម ជាលេខាធិការរង

ឧបាសិកា តាំង ប៉ោងជីង ជាហេរញ្ញិក

ឧបាសិកា ជា នាង ជាបេឡា

លោកគ្រូធម្មបណ្ឌិត អឿ សៅ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ឡាយ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា អ៊ឹង រិទ្ធារី សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោ ភាព សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា គួ ម៉ីនគាង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឈុំ គីមឃួយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ប៉ែន រម្មណិយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ុង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ប៊ួរ ម៉ាឡួា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហោង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោង ស្រីដា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោង ស្រីច័ន្ទ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោង ស្រីនាង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ហោង សុភ័ត្រ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា តែង ភល្យណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហោង ច័ន្ទបុញ្ញាចន្ទី ជាសមាជិកសកម្ម

ឧបាសក ហុង សុខណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហុង សុខណ្ណារ៉ែត ជាសមាជិកសកម្ម

# មាតិការឿង

ល.រ ទំព័រ

០១ អនន្តរិយកម្មកថា ........................................ ១

កថាពោលអំពីអនន្តរិយកម្ម

០២ មិច្ឆាទិដ្ឋិវិភាវនកថា ..................................... ៤៧

កថាពោលអំពីលទ្ធិរបស់មិច្ឆាទិដ្ឋិ

០៣ អរិយូបវាទកម្មកថា ...................................... ៧១

កថាពោលអំពីការតិះដៀលព្រះអរិយៈ

០៤ កោហញ្ញាទីនវកថា ........................................ ៧៨

កថាពោលអំពីទោសក្នុងអនាគត

០៥ មច្ឆេរប្បភេទកថា ........................................ ៨៦

កថាពោលអំពីការកំណាញ់

០៦ តិវិធគ្គិកថា .................................................. ៩៣

កថាពោលអំពីភ្លើង ៣ កង

០៧ ទានាទិបុញ្ញកម្មកថា .................................... ១១៩

កថាពោលអំពីបុញ្ញកម្មផ្សេងៗ មានទានជាដើម

០៨ សត្តាហារវិវេចនកថា .................................. ១៨០

កថាពោលអំពីអាហារ

០៩ សត្តានំយោនិបភេទកថា ................................ ២១៧

កថាពោលអំពីប្រភេទនៃកំណើតរបស់សត្វ

១០ បុមិត្ថីបរិវត្តនកថា .......................................... ២៧៨

កថាពោលអំពីការប្តូរភេទ

១១ ឥត្ថីវិការនកថា ............................................. ២៩៣

កថាពោលអំពីអធ្យាស្រ័យរបស់ស្ត្រីភេទ

១២ បណ្ឌកានំវិការនកថា .................................... ៣១០

កថាពោលអំពីបណ្ឌកៈ

១៣ នាគានំវិការនកថា ....................................... ៣១៥

កថាពោលអំពីនាគ

១៤ សុបណ្ណានំវិការនកថា ................................... ៣២៥

កថាពោលអំពីប្រភេទផ្សេងៗ របស់គ្រុឌទាំងឡាយ

១៥ បេតានំវិការនកថា ........................................ ៣២៩

កថាពោលអំពីពពួកប្រេត

១៦ អសុរានំវិការនកថា ...................................... ៣៣៨

កថាពោលអំពីពពួកអសុរកាយ

១៧ ទេវានំវិការនកថា .......................................... ៣៣៩

កថាពោលអំពីពពួកទេវតា

១៨ បឋវីវឡ្ឌនវិការនកថា ................................... ៣៥០

កថាពោលអំពីផែនដីចម្រើន

១៩ មហីកម្បនវិការនកថា .................................... ៣៥៧

កថាពោលអំពីផែនដីកក្រើក

២០ វុដ្ឋិវាតាទិកថា .............................................. ៣៧៤

កថាពោលអំពីអាការកើតឡើងនៃភ្លៀង និងខ្យល់ជាដើម

២១ បកិណ្ណកកថា .............................................. ៣៩៦

កថាពោលអំពីបកិណ្ណកកថា

២២ ឥទ្ធិកថា .............................................. ៤៥០

កថាពោលអំពីឫទ្ធិទាំងឡាយផ្សេងៗ

២៣ លោកសណ្ឋានកថា .............................................. ៥០៦

កថាពោលអំពីលោកសណ្ឋាន

# អនន្តរិយកម្មកថា

បន្ទាប់អំពីនេះ នឹងវិសជ្ជនាក្នុងអនន្តរិយកម្ម ៥ ប្រការ គឺ មាតុឃាត ១ បិតុឃាត ១ អរហន្តឃាត ១ លោហិតុប្បាទ ១ សង្ឃភេទ ១ នោះបន្តទៅដូច្នោះថា ៈ-

ព្រះនន្ទាចារ្យបាននាំយក អដ្ឋានសូត្រ ក្នុង គម្ពីរអង្គុត្តរ-និកាយ ឯកនិបាត មកវិសជ្ជនាថា **អដ្ឋានមេតំ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ អ្នកឃើញភ័យក្នុងវដ្តសង្សារ បុគ្គលអ្នកមានអភិនីហារពិចារណាឃើញព្រះនិព្វាន បានសម្រេចមគ្គ និងផល ជាអរិយសាវកក្នុងព្រះពុទ្ធសាសនានេះ មិនមានទីកន្លែង មិនមានឋានៈ មិនមានហេតុមិនមានបច្ច័យដែលនឹងកាត់ផ្តាច់ជីវិតមាតាបិតា ព្រះអរហន្ត មិនមានហេតុ មិនមានបច្ច័យ ដែលនឹងប្រទូស្តចំពោះព្រះសម្មាសម្ពុទ្ធ រហូតដល់ធ្វើលោហិតុប្បាទឲ្យពុរពង មិនមែនហេតុ មិនមែនបច្ច័យ ដែលនឹងធ្វើសង្ឃភេទ ជាទោសធ្ងន់ជាងអនន្តរិយកម្មខាងដើម ៤ ប្រការនោះទៀត ។

ម្នាលភិក្ខុទាំងឡាយ កិរិយាដែលទាបថោកល្មើសបំពាន ធ្វើ

នូវអនន្តរិយកម្ម ៥ ប្រការនេះ ជាវិស័យនៃបុថុជ្ជនដែលក្រាស់ទៅដោយកិលេស គឺរាគៈ ទោសៈ មោហៈ ធ្វើឲ្យងងឹតងងល់វង្វេង មិនឲ្យភ្ញាក់រឭកស្វែងរកកុសល បុថុជ្ជនដូច្នេះ នឹងសម្លាប់ឪពុកម្តាយ សម្លាប់ព្រះអរហន្ត ញុំាងលោហិតុប្បាទឲ្យពុះពេញ ធ្វើនូវសង្ឃភេទ ។ កិរិយា ដែលធ្លាក់នៅក្នុងវិស័យរបស់បុថុជ្ជន ឆ្ងាយពីមគ្គផល ឆ្ងាយពីព្រះនិព្វាន ឆ្ងាយពីត្រៃលក្ខណ៍ មិនបានឃើញអនិច្ចំ ទុក្ខំ អនត្តា នេះឯងជាហេតុ ជាបច្ច័យឲ្យធ្វើនូវអនន្តរិយកម្ម អធិប្បាយសេចក្តីព្រះបាលីក្នុង **អដ្ឋានសូត្រ** ក៏ចប់តែប៉ុណ្ណេះ ។

ព្រះអដ្ឋកថាចារ្យប្រាថ្នានឹងសម្តែងសេចក្តីឲ្យឃើញថា ធម្មតាអរិយសាវកនោះ ចិត្តរបស់លោកនឹងធឹង មិនឡេះឡោះដូចចិត្តបុថុជ្ជន ប្រាថ្នានឹងសម្តែងសេចក្តីដូច្នេះ ទើបតាំងសំណួរខាងដើមថា **កិំ បន អរិយសាវកោ អញ្ញំបិ ជីវិតា វោបេយ្យ** ព្រះអរិយសាវកដែលជាព្រះអរហន្តនោះលើកទុកសិនចុះ មិនបានយកមកសម្តែងទេ នឹងសួរក្នុងទីនេះ ត្រឹមតែព្រះសោតា និងព្រះសកទាគាមី ។ អរិយ-សាវកដែលបានជាសោតា និងជាសកទាគាមីនោះ នៅផ្តាច់បង់ជីវិតរបស់សត្វដទៃខ្លះ ឬដោយប្រការដូចម្តេច ? **ឯតំបិ អដ្ឋានំ** មាន

ពាក្យវិសជ្ជនាថា កិរិយាដែលសោតា សកទាគាមី នឹងផ្តាច់បង់ជីវិតរបស់សត្វដទៃនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ។ អរិយសាវកដែលជាសោតា សកទាគាមីនោះ **ភវន្តរគតំ** បើទៅកើតក្នុងភពណា មិនដឹងខ្លួនថា ខ្លួននោះជាសោតា ជាសកទាគាមី **ឃរំបិ វេទេយ្យ** បើលោកអ្នកមានឫទ្ធិច្រើនបង្គាប់បញ្ជាថា ចូរអ្នកសម្លាប់ស្រមោចខ្មៅ ស្រមោចក្រហមមួយនេះចុះ យើងនឹងឲ្យសម្បត្តិស្តេចចក្រដល់អ្នក **សកលចក្កវាឡគព្ភេ** យើងនឹងឲ្យភាពជាធំក្នុងចក្រវាលទាំងឡាយ មិនមានអ្នកដទៃប្រៀបបាន ។ កាលលោកអ្នកដែលមានឫទ្ធិបញ្ជាដូច្នេះ ព្រះសោតា ព្រះសកទាគាមី ក៏មិនបានប្រាថ្នានឹងសម្លាប់ស្រមោច ឃើញដល់សម្បត្តិជាស្តេចចក្រពត្តិ នឹងសម្លាប់ជីវិតសត្វមានកំណត់ត្រឹមតែស្រមោចនោះ មិនមានចំពោះព្រះសោតា ព្រះសកទាគាមីជាដាច់ខាត ។ ទោះបីលោកអ្នកដែលមានឫទ្ធិនឹងកាត់ទោសថា អ្នកមិនសម្លាប់ស្រមោច មិនធ្វើតាមពាក្យបង្គាប់បញ្ជារបស់យើង **សីសំ តេ ឆិន្ទិស្សាមិ** យើងនឹងកាត់ក្បាលរបស់អ្នកចោល ទោះកាត់ទោសដូច្នេះក្តី កាត់ក្បាលចោលក្តី ព្រះសោតា ព្រះសកទាគាមីនោះ ក៏ព្រួរស្លាប់ ដែលនឹងរក្សាកាយ រក្សា

ជីវិតរបស់ខ្លួន ហើយទៅសម្លាប់ស្រមោចខ្មៅ ស្រមោចក្រហម សូម្បីតែមួយនោះមិនមាន ព្រោះថា ចិត្តរបស់ព្រះអរិយសាវកនេះ រឹងប៉ឹង មាំមួនក្រៃលែង មិនញាប់ញ័រដូចចិត្តបុថុជ្ជនឡើយ ។ ចិត្តបុថុជ្ជននេះ ត្រឡប់ត្រឡិន ឃ្លេងឃ្លោង ម្តងយ៉ាងនេះ ម្តងយ៉ាងនោះ មិនស្ថិតស្ថេរ មិនពិតប្រាកដ ឈ្មោះថា បុថុជ្ជននេះមានដោយច្រើន ចិត្តរបស់បុថុជ្ជននេះ រមែងវៀចវេរប្រែប្រួល និងមិនមាំមួនដូចជាចិត្តព្រះអរិយៈនោះឡើយ ចិត្តរបស់អរិយៈមានសភាពរឹងមាំ ដោយអំណាចអរិយមគ្គ ព្រោះហេតុដូច្នោះ ព្រះសម្ពុទ្ធមានព្រះពុទ្ធដីកាថា កិរិយាដែលធ្វើនូវអនន្តរិយកម្ម ហៅថា អនន្តរិយកម្ម ព្រោះហេតុឲ្យផលក្នុងជាតិទី ២ ( ភពបន្ទាប់ ) ។ បុគ្គលដែលធ្វើអនន្តរិយកម្មនោះ បើបែកធ្លាយរាងកាយទៅហើយ ទៀងនឹងទៅកើតក្នុងនរក នឹងមិនផុតអំពីនរកនោះឡើយ នឹងធ្លាក់ទៅនរកក្នុងជាតិទី ២ ជាប្រាកដ ហេតុដូច្នោះ ទើបកម្ម ៥ ប្រការ គឺមាតុឃាត បិតុឃាត អរហន្តឃាត លោហិតុប្បាទ សង្ឃភេទនោះ ប្រាកដឈ្មោះថា អនន្តរិយកម្ម និងកិរិយាដែលសម្លាប់មាតា ជាអនន្តរិយកម្មនោះ សម្លាប់ចំពោះតែមាតាបង្កើត បើសម្លាប់ម្តាយចិញ្ចឹម ម្តាយមីង ម្តាយធំ ជីដូន មិនជា

អនន្តរិយកម្មទេ សូម្បីបិតាក៏ដូចគ្នា សម្លាប់បិតាបង្កើតប៉ុណ្ណោះ បើសម្លាប់ឪពុកចិញ្ចឹម ឪពុកមា ឪពុកធំ ជីតា ក៏មិនជាអនន្តរិយកម្មដូចគ្នាដែរ ។ សូម្បីមិនដឹងសោះ ថាជាបិតា បើសម្លាប់ក៏ជាអនន្តរិយកម្មសមដូចព្រះបាលីថា **សចេ ហិ វេសិយា បុត្តោ ហោតិ អយំ មេ បិតា ន ជានាតិ យស្ស សម្ភវេន និព្វត្តោ សោចេតេន ឃាដិតោ បិតុឃាតោត្វេ សង្ខ្យំ គច្ឆតិ អនន្តរិយញ្ច ផុសតិ** អធិប្បាយថា បុត្ររបស់ស្ត្រីពេស្យាមិនដឹងថា បុរសនោះ ជាបិតារបស់ខ្លួនសូម្បីមិនដឹងថាជាបិតាក្តី បើខ្លួនកើតដោយសម្ភវៈរបស់បុរសណាបើសម្លាប់បុរសនោះ ជាបិតុឃាត គឺត្រូវអនន្តរិយកម្ម ។

**យោ បន សយំ មនុស្សភូតោ** ន័យម្យ៉ាងទៀត បើកូនណាជាមនុស្ស ប៉ុន្តែមាតាបិតាជាសត្វតិរច្ឆាន កូនជាមនុស្សសម្លាប់មាតាបិតាដែលជាសត្វតិរច្ឆានយ៉ាងនេះ មិនជាអនន្តរិយកម្ម ។

**សយំ វា តិរច្ឆានភូតោ** ម្យ៉ាងទៀត កូននោះ ជាសត្វតិរច្ឆាន ប៉ុន្តែមាតាបិតាជាមនុស្ស កូនដែលជាសត្វតិរច្ឆានសម្លាប់មាតាបិតាដែលជាមនុស្សយ៉ាងនេះ ក៏មិនជាអនន្តរិយកម្មដែរ ។

**តិរច្ឆានោ យេវ វា តិរច្ឆានភូតំ** ន័យម្យ៉ាងទៀតថា កូន

នោះជាសត្វតិរច្ឆាន មាតាបិតាជាសត្វតិរច្ឆាន កូនដែលជាសត្វតិរច្ឆាន នោះ សម្លាប់ឪពុក សម្លាប់ម្តាយដែលជាសត្វតិរច្ឆានយ៉ាងនេះ ក៏មិនជាអនន្តរិយកម្ម គឺមិនកំណត់ទៀងថា នឹងធ្លាក់ទៅនរកក្នុងជាតិទីពីរ បន្ទាប់ពីបច្ចុប្បន្នជាតិឡើយ កាលបើកុសលខ្លាំងក្លា ក៏អាចកើតក្នុងសុគតិភពបាន ក្រោយមក ទើបធ្លាក់ទៅសោយទុក្ខក្នុងនរក សោយទុក្ខវេទនាប៉ុនគ្នា ស្មើគ្នានឹងអនន្តរិយកម្ម គឺថា នឹងជាមាតុឃាត បិតុឃាត ត្រូវអនន្តរិយកម្មនោះ ចំពោះមាតាបិតាជាមនុស្ស កូនដែលសម្លាប់នោះ ក៏ជាមនុស្សដូចគ្នា បើជាសត្វតិរច្ឆានដូចគ្នាសម្លាប់គ្នាតាមវិស័យនៃសត្វ ក៏មិនជាអនន្តរិយកម្ម ។

មួយទៀត ជាអរហន្តឃាតនោះ ចំពោះបុគ្គលដែលសម្លាប់ព្រះអរហន្តជាមនុស្ស សមដូចបទថា **មនុស្សភូតោ ខីណាសវោ អរហាតិ អធិប្បេតោ** អធិប្បាយថា ព្រះខីណាស្រពដែលកើតក្នុងមនុស្ស ជាជាតិមនុស្សនោះសោត លោកអាចារ្យសំដៅហៅថា ព្រះអរហន្ត បុគ្គលដែលសម្លាប់ព្រះអរហន្តដែលមានជាតិជាមនុស្សនោះឯង ហៅថា អរហន្តឃាត គឺត្រូវអនន្តរិយកម្ម បើសម្លាប់ព្រះអរហន្តដែលជាទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មយក្ខនោះ បាបក៏ធ្ងន់ តែមិន

ជាអនន្តរិយកម្មឡើយ ។

ក្នុងលោហិតុប្បាទនោះ ក៏សំដៅយកតែបុគ្គលដែលប្រកប ដោយទោសចិត្ត គិតនឹងផ្តាច់បង់នូវព្រះជន្មរបស់ព្រះមានព្រះភាគ ធ្វើនូវការប្រទូស្ត ញ៉ាំងព្រះលោហិតឲ្យពុរពងក្នុងព្រះវរកាយរបស់ព្រះពុទ្ធ ដូចទេវទត្តភិក្ខុធ្វើ ទើបជាលោហិតុប្បាទ បុគ្គលដែលបំផ្លាញព្រះពុទ្ធរូប ព្រះស្តូប ចេតិយ និងដើមពោធិព្រឹក្ស ជាទោសធ្ងន់ បាបក៏ច្រើន ប៉ុន្តែមិនជាអនន្តរិយកម្ម មិនជាលោហិតុប្បាទទេ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ព្រះវរកាយរបស់ព្រះសាស្តា ជាអភេទកាយ បុគ្គលណាម្នាក់ មិនអាចធ្វើឲ្យបែកធ្លាយបានឡើយ ប្រការដែលធ្វើលោហិតុប្បាទនោះ គឺធ្វើលោហិតឲ្យពុរពងក្នុងព្រះវរកាយរបស់ព្រះលោកនាយក សូម្បីធ្វើមិនច្រើន ត្រឹមតែបន្តិចបន្តួច ព្រះលោហិតពុរពងត្រឹមតែមួយចំអែតសត្វរុយ ក៏ជាលោហិតុប្បាទ គឺត្រូវអនន្តរិយកម្ម ។

ចំណែកសង្ឃភេទនោះ ចំពោះភិក្ខុធ្វើទើបជាសង្ឃភេទ អ្នកដទៃក្រៅអំពីភិក្ខុ សូម្បីញុះញង់ភិក្ខុទាំងឡាយឲ្យពិរោធ-ក្រោធ-ជេរ វាយគ្នាបែកចេញឈាម ដោយប្រការណាក្តី ក៏បានបាបច្រើន មិនជាសង្ឃ-

ភេទ មិនត្រូវអនន្តរិយកម្មឡើយ ជាសង្ឃភេទនោះ សំដៅយកតែភិក្ខុធ្វើប៉ុណ្ណោះ ។

មួយទៀត កិរិយាដែលធ្វើប្រកបព្រមដោយហេតុ ៥ ប្រការ ទើបជាសង្ឃភេទ ប្រសិនបើធ្វើយ៉ាងដទៃក្រៅអំពីហេតុ ៥ ប្រការ សូម្បីភិក្ខុទាំងឡាយវិវាទ ប្រមាថគ្នា វាយតប់ជេរគ្នា មិនពេញចិត្ត យកមុខយកមាត់បែកបាក់គ្នាមួយរូបក្តី ពីររូបក្តី ទៅជាពួកៗក្តី ក៏ត្រូវអាបត្តិច្រើននោះឯង មិនជាសង្ឃភេទ មិនត្រូវអនន្តរិយកម្មឡើយ ។ កាលភិក្ខុធ្វើដោយហេតុ ៥ ប្រការ សង្ឃបែកគ្នាដោយហេតុ ៥ ប្រការ ម្នាងៗ តាំងពី ៤ រូបឡើងទៅក្តី ទើបភិក្ខុអ្នកធ្វើជាសង្ឃភេទ ត្រូវអនន្តរិយកម្ម ហេតុ ៥ ប្រការនោះគឺ **កម្មេន** បំបែកភិក្ខុដែលវង្វេងជឿស្តាប់ពាក្យរបស់ខ្លួនចេញជាផ្នែក ធ្វើឲ្យសង្ឃនោះជាផ្នែកផ្សេងៗ ដោយឡែក ១ ។

**ឧទ្ទេសេន** បំបែកភិក្ខុដែលវង្វេងជឿពាក្យរបស់ខ្លួនចេញជាផ្នែក ឲ្យសូធ្យបាតិមោក្ខជាផ្នែកផ្សេងដោយឡែក ១ ។

**វោហារន្តោ** ពោលភេទករវត្ថុ ១៨ គឺជាធម៌ត្រឡប់ថាមិនមែនជាធម៌ មិនជាអាបត្តិត្រឡប់ថាជាអាបត្តិ ជាកប្បិយ ត្រឡប់ថាជា អកប្បិយ

ព្រះពុទ្ធត្រាស់ទេសនា ត្រឡប់ថា ព្រះពុទ្ធមិនបានទេសនាទេ ពោលមួលបង្កាច់ព្រះពុទ្ធវចនៈដូច្នេះឯង ហៅថា ពោលភេទករវត្ថុ ចាត់ជាហេតុក្នុងការធ្វើសង្ឃភេទ ១ ។

**អនុសាវនេន** ពោលខ្សឹបៗ ខ្សាវៗ ពោលជិតត្រចៀកថា **តុម្ហេ ឆាថ** លោកម្ចាស់ទាំងឡាយក៏ដឹងថា ខ្ញុំព្រះករុណាមានជាតិមានត្រកូលខ្ពង់ខ្ពស់ លះបង់ទ្រព្យសម្បត្តិចេញបព្វជ្ជា មួយទៀតសោតខ្ញុំព្រះករុណាក៏ជាពហូសូត បានស្តាប់មកច្រើន **មាទិសោ** ភិក្ខុដូចខ្ញុំព្រះករុណានេះឬ នឹងមកកាន់ឲ្យខុសពីធម៌ និងវិន័យ ដែលលោកម្ចាស់ទាំងឡាយសង្ស័យក្នុងពាក្យរបស់ខ្ញុំព្រះករុណានេះមិនគួរទេ អវីចីនរកនោះធំ ខ្ញុំព្រះករុណាភ័យខ្លាចក្នុងនរក ឬនឹងមកបង្រៀនឲ្យលោកម្ចាស់ទាំងឡាយប្រកាន់ខុសពីវិន័យ លោកម្ចាស់ទាំងឡាយកុំនឹកសង្ស័យក្នុងពាក្យរបស់ខ្ញុំព្រះករុណាឡើយ ស្តាប់ពាក្យរបស់ខ្ញុំព្រះករុណាថាចូរបដិបត្តិតាមឱវាទានុសាសនីរបស់ខ្ញុំព្រះករុណាចុះ កិរិយាពោលលួងលោមឲ្យភិក្ខុជទៃឈ្ងក់វង្វេង ជឿពាក្យរបស់ខ្លួន ឲ្យប្រកាន់ខុសចំពោះព្រះពុទ្ធវចនៈតាមលទ្ធិរបស់ខ្លួនយ៉ាងនេះ ក៏ចាត់ជាហេតុដែលធ្វើនូវសង្ឃភេទ ១ ។

**សលាកគ្គាហេន** សរសេរស្លាកឲ្យចាប់ បំណងមិនឲ្យភិក្ខុ ដែលចូលពួកជាមួយខ្លួននោះត្រឡប់ត្រឡិន នឹងឲ្យប្រកាន់មាំនៅក្នុងឱវាទរបស់ខ្លួន ដែលមួលបង្កាច់ព្រះពុទ្ធវចនៈនោះ អាការដែលឲ្យចាប់ស្លាកនោះ ជាល្បិចកលបោកបញ្ឆោតឲ្យចាប់ត្រូវស្លាកដែលខ្លួនកំណត់ឲ្យចាប់ ដែលខ្លួនបំណងឧបត្ថម្ភគាំទ្រចិត្តរបស់ភិក្ខុទាំងឡាយដែលចូលជាពួករបស់ខ្លួននោះ មិនឲ្យក្រឡះដោយកិរិយា ដែលចាប់ស្លាក នេះក៏ជាហេតុដែលធ្វើសង្ឃភេទ ១ រួមជា ៥ ប្រការ ដូចពោលមកនេះឯង ។

**កម្មេន ឧទ្ទេសេន វា បមាណំ** នឹងយកតែទីជាប្រមាណគឺនឹងចាត់យកជាសង្ឃភេទដោយពិតនោះ ក្នុងកាលបំបែកធ្វើសង្ឃកម្មផ្សេងដោយឡែក បំបែកសូធ្យបាតិមោក្ខផ្សេងដោយឡែក **វោហារានុសាវន សលាកគ្គាហា បុព្វភាគា** កិរិយាដែលពោលភេទករវត្ថុ មួលបង្កាច់ព្រះពុទ្ធវចនៈ និងពាក្យខ្សឹបលួងលោមយកចិត្ត និងសរសេរស្លាកឲ្យចាប់នោះ ប្រព្រឹត្តទៅជាបុព្វភាគ គឺជាចំណែកខាងដើមរបស់សង្ឃភេទ អធិប្បាយថា ភិក្ខុធ្វើនូវសេចក្តីព្យាយាមដើម្បីឲ្យសម្រេចនូវកិច្ចជាសង្ឃភេទនោះ កាលបើពោលមួលបង្កាច់

ព្រះពុទ្ធវចនៈដែលគួរថាមិនគួរ ដែលមិនជាអាបត្តិថាជាអាបត្តិ សម្តែងទោសភេទករវត្ថុ ឲ្យភិក្ខុដែលល្ងង់ខ្លៅជឿពាក្យណែនាំដដែលៗ ឲ្យភិក្ខុដែលបញ្ញាទន់ខ្ទី អប្បបញ្ញា គោរពរាប់អានមាំក្នុងពាក្យដែលពោលមួលបង្កាច់ព្រះពុទ្ធវចនៈ មិនឲ្យមាននូវសន្ទិះសង្ស័យណាមួយឡើយ ឃើញថា វង្វេងដោយសារខ្លួន ជឿក្នុងពាក្យរបស់ខ្លួន ប្រាថ្នាមិនឲ្យត្រឡប់ក្រោយ ទើបសរសេរស្ងាកឲ្យចាប់ឧបត្ថម្ភគាំទ្រចិត្ត មិនឲ្យប្រែប្រួល ត្រឹមនោះហើយក្តី បើមិនទាន់បែកចេញធ្វើនូវសង្ឃកម្មផ្សេងដោយឡែកទេ នៅមិនទាន់បែកសូធ្យបាតិមោក្ខដរាបណា **អភិជ្ជោ ហោតិ សង្ឃោ** ក៏ឈ្មោះថា សង្ឃនៅមិនទាន់បានបែក នៅមិនទាន់ជាសង្ឃភេទដរាបនោះ **យទា បន ឯវំ ចត្តារោ វា អតិរេកា វា** កាលណា ភិក្ខុពួកដែលប្រកាន់ខុស មួលបង្កាច់ព្រះពុទ្ធវចនៈនោះព្រមព្រៀងគ្នា បែកចេញជាពួក ៤ រូបក្តី ច្រើនជាង ៤ រូបក្តី កាលបើបែកចេញជាផ្នែកដូច្នេះហើយ ធ្វើសង្ឃកម្មផ្សេងដោយឡែក សូធ្យបាតិមោក្ខផ្សេងដោយឡែក តាមពួករបស់ខ្លួន ដែលមួលបង្កាច់ព្រះពុទ្ធវចនៈនោះ យ៉ាងនេះទើបឈ្មោះថា បំបែកសង្ឃ ឬ ធ្វើឲ្យបែកគ្នា ជាសង្ឃភេទ ជាអនន្តរិយកម្មក្នុងខណៈនោះ ។

សេចក្តីថា មួលបង្កាច់ព្រះពុទ្ធវចនៈ ហើយដឹកនាំភិក្ខុដទៃៗ ឲ្យចូលពួករបស់ខ្លួន ឲ្យពេញចិត្តក្នុងពាក្យមួលបង្កាច់ព្រះពុទ្ធវចនៈដូចគ្នានឹងខ្លួន កាលបានពួកច្រើនហើយ បែកចេញធ្វើសង្ឃកម្ម ពួកដែលមួលបង្កាច់ព្រះពុទ្ធវចនៈដូចគ្នា បែកធ្វើឧបោសថសូធ្យបាតិមោក្ខតាមពួកដែលមួលបង្កាច់ព្រះពុទ្ធវចនៈដូចគ្នា យ៉ាងនេះ ទើបជាសង្ឃភេទ គឺត្រូវអនន្តរិយកម្ម ។ បើមិនមួលបង្កាច់ព្រះពុទ្ធវចនៈទេ បដិបត្តិតាមព្រះពុទ្ធបញ្ញត្តិ ប៉ុន្តែកើតជម្លោះវិវាទទាស់ទែងគ្នាដោយហេតុណានីមួយ ក៏បែកពួករបស់ខ្លួនចេញទៅទីដទៃ ទៅធ្វើឧបោសថកម្មដទៃដាក់ឧបោសថកម្មដទៃផ្សេងៗ យ៉ាងនេះក៏មិនមែនជាសង្ឃភេទដែរ ព្រោះហេតុដែលមិនបានមួលបង្កាច់ព្រះពុទ្ធវចនៈ **តេសំ អាវិភាវត្ថំ** ព្រះនន្ទាចារ្យប្រាថ្នានឹងសម្តែងអនន្តរិយកម្មឲ្យច្បាស់ដោយវិសេស ទើបពោលវិនិច្ឆ័យ ៤ ប្រការ គឺវិនិច្ឆ័យដោយកម្ម ១ វិនិច្ឆ័យដោយទ្វារ ១ វិនិច្ឆ័យដោយកប្បដ្ឋិតិកាល ១ វិនិច្ឆ័យដោយវិបាកសាធារណៈជាដើម ១ ជាប្រភេទនៃការវិនិច្ឆ័យ ៤ ប្រការ ដូច្នេះ ។

**កម្មតោ តាវ** នឹងវិនិច្ឆ័យដោយកម្មជាមុន **ឯត្ថ ហិ មនុស្ស-ភូតស្សេវ មនុស្សភូតំ មាតរំ វា បិតរំ វា អបរិវត្តលិង្គំ ជីវិតា-**

**ឋោរោបេន្តស្ស កម្មំ អនន្តរិយំ ហោតិ** *អធិប្បាយថា បុគ្គលដែលសម្លាប់មាតាបិតានោះ មានជាតិជាមនុស្ស មាតាបិតាក៏ជាមនុស្ស កាលកូនប្រទូស្ត គឺសម្លាប់ឲ្យស្លាប់នោះ ភេទមាតាបិតាជាមនុស្សតាំងនៅជាធម្មតា មាតាបិតាមិនបានក្លាយជាសត្វតិរច្ឆាន យ៉ាងនេះទើបកម្មនោះ ជាអនន្តរិយកម្ម បើមាតាបិតានោះក្លាយជាសត្វតិរច្ឆាន កាលកូនសម្លាប់ឲ្យស្លាប់នោះ ភេទមាតាបិតាជាសត្វតិរច្ឆានយ៉ាងនេះ មិនជាអនន្តរិយកម្ម តែទោសនោះធ្ងន់ ធ្លាក់ទៅក្នុងនរកប្រហែលគ្នានឹងអនន្តរិយកម្មដែរ ប្លែកគ្នាត្រង់មិនធ្លាក់នរកក្នុងជាតិទីពីរ បន្ទាប់ពីបច្ចុប្បន្នជាតិប៉ុណ្ណោះ ។ កម្មដែលជាអនន្តរិយកម្ម ទៀងតែនឹងធ្លាក់នរកក្នុងជាតិទី ២ បន្ទាប់ពីបច្ចុប្បន្នជាតិ ។ កាលខ្លួនប្រមាទធ្វើកម្មជាអនន្តរិយកម្មហើយ សូម្បីសាងព្រះស្តូបប្រកបដោយមាសមានប្រមាណប៉ុនមហាចេតិយ ក្នុងលង្កាទ្វីប ឲ្យពេញក្នុងផ្ទៃនៃចក្រវាលក្តី ថ្វាយមហាទានចំពោះភិក្ខុសង្ឃ ដែលប្រជុំគ្នាពេញក្នុងផ្ទៃនៃចក្រវាលក្តី នឹងចាប់នូវជាយចីវរជាប់តាមព្រះពុទ្ធជានិច្ចក្តី នឹងរារាំងផលរបស់អនន្តរិយកម្ម ទុកឲ្យយូរនោះមិនបានឡើយ ដល់ពេលដែលបែកធ្លាយរាងកាយទៅហើយ ក៏ទៀងនឹងធ្លាក់ទៅនរកក្នុងជាតិទីពីរ បន្ទាប់*

ពីបច្ចុប្បន្នជាតិ មិនឃ្លៀងឃ្លាត ហេតុនោះ ទើបបាននាមបញ្ញត្តិថា **អនន្តរិយកម្ម** ដោយប្រការដូច្នេះ ។

**ឯឡកចតុក្កំ សង្គាមចតុក្កំ ចោរចតុក្កញ្ច កថេតព្វំ** ក្នុងទីនេះ អ្នកប្រាជ្ញគប្បីនាំយកឯឡកចតុក្កៈ សង្គាមចតុក្កៈ និងចោរ-ចតុក្កៈមកសម្តែងឲ្យពិស្តារ ។

ក្នុងឯឡកចតុក្កៈ **ឃាតកោ ច ហោតិ** បុគ្គលអ្នកសម្លាប់នោះក៏ត្រូវមាតុឃាត បិតុឃាត អរហន្តឃាត សមគួរដល់ការស្លាប់ចុងក្រោយ បើសម្លាប់ត្រូវមាតាៗ ស្លាប់ ក៏ជាមាតុឃាត ត្រូវអនន្តរិយកម្ម បើសម្លាប់ត្រូវបិតាៗ ស្លាប់ ក៏ជាបិតុឃាត ត្រូវអនន្តរិយកម្ម បើសម្លាប់ត្រូវព្រះអរហន្តៗ រំលត់ខន្ធបរិនិព្វាន ក៏ជាអរហន្តឃាត ត្រូវអនន្តរិយកម្ម ចិត្តដែលមិនដឹងថា ជាមាតាបិតា មិនដឹងថាជាព្រះអរហន្ត សម្គាល់ថាជាពពែនោះ មិនអាចការពារបាប ការពារទោសបានឡើយ លើកយកវធកចេតនាឡើងជាធំសំដៅវធកចេតនាជាគោល ជាប្រធាន កាលលើកសស្ត្រាវុធឡើងដើម្បីសម្លាប់នោះ ប៉ុនប៉ងថានឹងសម្លាប់រាងកាយណា កាលសម្លាប់ក៏ត្រូវរាងកាយនោះ សមតាមវធកចេតនាដែលប៉ុនប៉ង កាលដែល

សម្លាប់ត្រូវរាងកាយតាមចិត្តដែលប៉ុនប៉ងដូច្នោះហើយ ជាមាតុឃាត បិតុឃាត អរហន្តឃាត ចិត្តដែលមិនដឹងថាជាមាតាបិតា មិនដឹងថាជាព្រះអរហន្ត សម្គាល់ថាជាពពែនោះ មិនអាចនឹងគ្រប់គ្រងបាប គ្រប់គ្រងកម្មបាន ព្រោះហេតុ (ដែលលើកយក) វធកចេតនាក្នុងកាលដែលលើកសស្ត្រាវុធឡើងសម្លាប់នោះជាប្រធាន អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា បើបុគ្គលអ្នកសម្លាប់នោះជាភិក្ខុ អ្នកស្លាប់នោះជាមាតាបិតារបស់ភិក្ខុអ្នកសម្លាប់ ភិក្ខុអ្នកសម្លាប់នោះក៏ត្រូវអាបត្តិបារាជិក ត្រូវអនន្តរិយកម្ម បើអ្នកស្លាប់នោះជាព្រះអរហន្ត ភិក្ខុអ្នកសម្លាប់ក៏ត្រូវដាច់ចាកសិក្ខាបទត្រូវអាបត្តិមនុស្សវិគ្គហបារាជិក បើអ្នកស្លាប់នោះជាយក្ខ ឬជាប្រេត ភិក្ខុអ្នកសម្លាប់ ត្រូវអាបត្តិថុល្លច្ច័យ បើសត្វដែលស្លាប់ជាសត្វតិរច្ឆាន ភិក្ខុដែលសម្លាប់នោះក៏ត្រូវអាបត្តិបាចិត្តិយ សម្តែងឯឡកបតុក្កៈមានប្រមាណប៉ុណ្ណោះ ។

ក្នុងសង្គាមចតុក្កៈនោះថា **បរសេនាយ អញ្ញញ្ញ យោធំ បិត-រញ្ញ កម្មំ ករោន្តោ ឥស្សា យោធស្ស ឧសុំ ខិបតិ ឯកំ វិជ្ឈិត្វា មម បិតរំ វិជ្ឈិស្សតិ** បុគ្គលដែលចូលសមរភូមិធ្វើសង្គ្រាមផ្ចាញ់ពួកបច្ចាមិត្រនោះ កាលបើឃើញយោធាដទៃដែលជាបច្ចាមិត្រ តម្រង់មក

ចំពោះមុខ ហើយក៏ឃើញបិតារបស់ខ្លួន ចូលមកជាមួយនឹងយោធានោះ លុះឃើញបិតានៅក្នុងពួកបច្ចាមិត្រ គាំទ្រឲ្យកម្លាំងយោធាដល់បច្ចាមិត្រ ក៏ទាស់ចិត្ត លែងសរសំដៅទៅ ឲ្យត្រូវកាយយោធា ហើយនឹងឲ្យត្រូវបិតា ប្រាថ្នានឹងសម្លាប់ចោលទាំងពីរនាក់ **យថា–ធិប្បាយំ គតោ** បើសរនោះត្រូវទាំងពីរនាក់ សមតាមអធ្យាស្រ័យដែលប៉ុនប៉ងសម្លាប់បិតានោះ បុគ្គលដែលបាញ់ក៏ត្រូវអនន្តរិយកម្មជាបិតុឃាត ប្រសិនបើកាលដែលបាញ់នោះ មិនគិតឲ្យត្រូវបិតាទេ ប្រាថ្នាឲ្យត្រូវតែយោធា ចំណែកបិតានោះ ធ្វើឲ្យគ្រាន់តែភ័យ ឲ្យបិតារត់ទៅ កាលបើគិតដូច្នេះហើយ ក៏បាញ់ទៅ សរនោះមិនបានទៅដូចការគិត ត្រឡប់ជាទៅត្រូវបិតាស្លាប់ យ៉ាងនេះ មិនជាអនន្តរិយកម្មទេ ព្រោះហេតុដែលវធកចេតនានោះបំណងឲ្យត្រូវតែយោធា មិនប្រាថ្នាឲ្យត្រូវបិតាឡើយ វធកចេតនានោះឯងជាធំ កាលបើមិនមានវធក–ចេតនាហើយ ក៏មិនគួរពិភាក្សាយកជាបិតុឃាតទេ ព្រោះហេតុដូច្នោះ កាលសរនោះទៅមិនដូចចិត្តប៉ង ភ្លាត់ទៅត្រូវបិតាស្លាប់ ទើបបុគ្គលដែលបាញ់មិនត្រូវអនន្តរិយកម្ម បើសរនោះទៅត្រូវយោធាដូចចិត្តនឹកសំដៅ យោធានោះស្លាប់ បើអ្នកបាញ់នោះជាភិក្ខុ ត្រូវមនុស្សវិគ្គហ–

បារាជិកបើជាយក្ខ ឬប្រេតកាន់ភេទជាយោធាមកជាមួយនឹងបិតារបស់ភិក្ខុៗ សម្គាល់ថាជាយោធា បាញ់យក្ខ និងប្រេតនោះស្លាប់ ភិក្ខុក៏ត្រូវអាបត្តិថុល្លច្ច័យ ប្រសិនបើសត្វតិរច្ឆាន ក្លែងកាយជាយោធាមកជាមួយនឹងបិតារបស់ភិក្ខុៗ សម្គាល់ថាជាយោធា បាញ់សត្វតិរច្ឆាននោះស្លាប់ភិក្ខុក៏ត្រូវអាបត្តិបាចិត្តិយ សម្តែងក្នុងសង្គាមចតុក្កៈចប់ ។

ក្នុងចោរចតុក្កៈថា **យោ បិ ចោរំ មារេស្សាមីតិ ចោរវេសេន គច្ឆន្តំ បិតរំ មារេតិ អនន្តរិយំ ផុសតិ** កាលបុគ្គលឃើញបិតាក្លែងភេទមក សម្គាល់ថាចោរ មិនដឹងថាជាបិតា ក៏សម្លាប់បិតា ដោយសម្គាល់ថាសម្លាប់ចោរ បុគ្គលនោះក៏ត្រូវអនន្តរិយកម្ម ជាបិតុឃាត បើចោរនោះរូបរាងដូចបិតា បុគ្គលអ្នកសម្លាប់នោះ សម្គាល់ថាបិតា មាននូវទោសចិត្តសម្លាប់ចោរ ដោយសម្គាល់ថាសម្លាប់បិតា មិនជាបិតុឃាត មិនជាអនន្តរិយកម្មឡើយ បើអ្នកសម្លាប់នោះជាភិក្ខុ ត្រូវមនុស្សវិគ្គហបារាជិក ម្យ៉ាងទៀត បើយក្ខ ឬប្រេត ដែលក្លែងភេទជាបិតាមកប្រទូស្តដល់ខ្លួន កើតទោសចិត្តសម្លាប់យក្ខ សម្លាប់ប្រេតនោះស្លាប់ សម្គាល់ថាជាបិតា មិនដឹងថាជាយក្ខ ជាប្រេតក្លែងភេទមកទេ ភិក្ខុសម្លាប់យក្ខ សម្លាប់ប្រេតដោយសម្គាល់ថាជាបិតានោះ

មិនត្រូវអនន្តរិយកម្ម មិនត្រូវអាបត្តិបារាជិកឡើយ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ បើសត្វតិរច្ឆានដែលក្លែងកាយបាន មាននាគ និងគ្រុឌជាដើម កាឡាខ្លួនដូចបិតារបស់ភិក្ខុមក ហើយបៀតបៀនធ្វើឲ្យភិក្ខុនោះកើតទោសចិត្ត ភិក្ខុនោះសម្គាល់ជាបិតា ប៉ុន្តែទប់ទល់ទោស-ចិត្តមិនបាន ក៏សម្លាប់ឲ្យស្លាប់ កាលដែលសម្លាប់នោះ ក៏យល់ថាសម្លាប់បិតា ការសម្គាល់យ៉ាងមុតមាំត្រឹមតែប៉ុណ្ណោះ ក៏មិនត្រូវអនន្តរិយកម្មដែរ អាបត្តិបារាជិកក៏មិនត្រូវ អាបត្តិថុល្លច្ច័យក៏មិនត្រូវ ត្រូវត្រឹមតែអាបត្តិបាចិត្តិយ តាមទោសដែលសម្លាប់សត្វតិរច្ឆាន អ្នកប្រាជ្ញគប្បីយល់ថា បុគ្គលអ្នកសម្លាប់នោះ បើនៅក្នុងនាទី ឬក៏តំណែងដែលខ្ពស់ គឺជាមាតាបិតា ជាព្រះអរហន្តហើយ សូម្បីអ្នកសម្លាប់សម្គាល់ថា ជាពពែ ជ្រូក ក៏គង់ជាបិតុឃាត មាតុឃាត អរហន្តឃាតនោះឯង ទោសនឹងមិនបានថយស្រាលចុះឡើយ អ្នកប្រាជ្ញគប្បីយល់ចូលចិត្តក្នុងការដែលមានអ្នកបង្គាប់បញ្ជាថា មនុស្សម្នាក់ជាអ្នកសម្លាប់ បើអ្នកស្លាប់នោះ ជាមាតាបិតារបស់អ្នកប្រើ អ្នកប្រើក៏ត្រូវអនន្តរិយកម្ម អ្នកសម្លាប់នោះ បានបាបតាមនាទីសម្លាប់មនុស្ស មិនត្រូវអនន្តរិយកម្មទេ បើអ្នកស្លាប់នោះជាបិតារបស់អ្នក

សម្លាប់ៗ នោះក៏ត្រូវអនន្តរិយកម្ម អ្នកប្រើនោះបានបាបតាមនាទី ដែលសម្លាប់មនុស្ស មិនត្រូវអនន្តរិយកម្មទេ **សចេ អរហា ហោតិ** ប្រសិនបើអ្នកស្លាប់នោះជាព្រះអរហន្ត ក៏ត្រូវអនន្តរិយកម្ម ទាំងអ្នកប្រើ ទាំងអ្នកសម្លាប់ បើអ្នកសម្លាប់នោះ ទៅសម្លាប់អ្នកដទៃវិញ មិនត្រូវបុគ្គលដែលកំណត់ឲ្យសម្លាប់ យ៉ាងនេះ ជាបាបតែអ្នកសម្លាប់ អ្នកប្រើគ្មានបាប គ្មានទោសទេ **បលាសបុញ្ជាទីនិ វត្ថូនិ** អាចារ្យប្រាថ្នាសម្តែងសេចក្តីនេះឲ្យច្បាស់ ទើបនាំយករឿងរ៉ាវមកសម្តែងថា **លោហិតកំ អសឹ វា សត្ថំ វា បុញ្ជិស្សាសីតិ បលាសបុញ្ជេ បវេសន្តោ តត្ថ និបន្នំ មាតរំ វា បិតរំ វា អរហន្តំ វា** បុគ្គលដែលឃើញលំពែង ឃើញដាវប្រឡាក់ដោយឈាម គិតថា អញនឹងជូតឈាមដែលជាប់លំពែង ជាប់ដាវនេះចេញ គិតរួចហើយ ក៏ចាប់យកលំពែង និងដាវនោះ ចាក់ចូលទៅត្រង់គំនរចំបើង និងគំនរស្លឹកឈើ បើមាតា និងបិតារបស់ខ្លួន ឬព្រះអរហន្តដេកនៅក្នុងគំនរចំបើង ឬគំនរស្លឹកឈើ ត្រូវលំពែង ត្រូវដាវដល់នូវសេចក្តីស្លាប់ក្តី បុគ្គលដែលចាក់គំនរចំបើង ឬគំនរស្លឹកឈើដោយដាវ និងលំពែងនោះ **នេវ កម្មំ ផុសតិ** មិនជាបាប មិនជាកម្មទេ **វធក–**

**ចេតនាយ អភាវតោ** ហេតុថា មិនមានវធកចេតនា ចិត្តនោះប៉ុនប៉ងទៅក្នុងការជូតឈាមតែម្យ៉ាង ប្រាសចាកវធកចេតនា ទើបមិនជាបាប បើប្រាថ្នានឹងជូតឈាមដែលជាប់លំពែង និងជាប់ដាវនោះ កាលដែលចាក់គំនរចំបើង ឬគំនរស្ទឹកឈើ ក៏ដឹងច្បាស់ថា ត្រូវសត្វ ចិត្តប្រព្រឹត្តទៅក្នុងបាបចេតនាដ៏ថោកទាប កើតឡើងក្នុងខណៈណាថា **សត្តោ មញ្ញោ អព្ភន្តរតោ មរតុ** ខាងក្នុងគំនរចំបើង ឬគំនរស្ទឹកឈើនេះមានសត្វ កាលបើអញចាក់ទៅត្រូវសត្វ ក៏ចូរស្លាប់ចុះ កាលបើវធកចេតនាកើតឡើងដូច្នេះ ក៏មានបាប មានកម្ម តាមនាទីខ្ពស់និងទាប បើអ្នកស្លាប់នោះជាមាតាបិតា ជាព្រះអរហន្ត អ្នកចាក់ក៏ត្រូវអនន្តរិយកម្ម បើជាមនុស្សដទៃ ក៏មានបាបតាមនាទីដែលសម្លាប់មនុស្ស បើសត្វដែលស្លាប់ជាយក្ខ ជាប្រេត ជាសត្វតិរច្ឆាន ក៏មានបាបសមគួរដល់វត្ថុ ដែលសម្តែងមកហើយនេះ **ឯសេវ នយោ តត្ថ និបាតនត្ថំ បវេសេន្តស្សាបិ វនគុម្ពាទីសុ ខិបន្តស្សាបិ** កាលបើបុគ្គលប្រាថ្នានឹងលាក់លំពែង លាក់ដាវ ហើយពួយលំពែង ពួយដាវចូលទៅក្នុងគំនរចំបើង ឬគំនរស្ទឹកឈើនោះក្តី ពួយលំពែង ពួយដាវតម្រង់ចូលទៅក្នុងជុបគុម្ពោតជាដើមនោះក្តី អ្នកប្រាជ្ញគប្បីយល់សេចក្តីក្នុងទីនេះ

ថា បើមិនមានវធកចេតនា មិនប្រាថ្នានឹងឲ្យត្រូវសត្វណានីមួយទេ ក៏ពួយលំពែង ពួយដាវចូលទៅក្នុងគំនរចំបើង ឬស្ទីកឈើនោះ ពួយចូលទៅក្នុងជុបគុម្ពោតព្រៃ ដើម្បីនឹងលាក់ទុកនោះ សូម្បីនឹងត្រូវសត្វស្លាប់ក្តី កាលបើប្រាសចាកវធកចេតនាហើយ ក៏មិនមានបាបមានកម្មតាមសមគួរដល់វត្ថុ សូម្បីអនន្តរិយកម្ម ក៏មិនត្រូវអនន្តរិ-យកម្ម សូម្បីមនុស្សវិគ្គហៈក៏មិនត្រូវមនុស្សវិគ្គហៈ បារាជិកក៏មិនត្រូវបារាជិក បើជាថុល្លច្ច័យក៏មិនត្រូវថុល្លច្ច័យ បើជាបាចិត្តិយក៏មិនត្រូវបាចិត្តិយ ។ កិរិយាដែលសម្លាប់សត្វតិរច្ឆាននោះ ជាបាចិត្តិយសម្លាប់យក្ខ សម្លាប់ប្រេតនោះជាថុល្លច្ច័យ សម្លាប់មនុស្សក៏ជាបារាជិកសម្លាប់មាតាបិតា ព្រះអរហន្តជាអនន្តរិយកម្ម **អបព្វជិតម្បិ មនុស្សំ អរហន្តមេវ មារេត្វា អនន្តរិយំ ផុសតិ ន យក្ខភូតំ** អ្នកដែលជាមនុស្ស បានជាព្រះអរហន្តហើយនោះ សូម្បីនៅមិនទាន់បានបួសក្តី អ្នកណាសម្លាប់លោកនោះ ក៏ជាអរហន្តឃាត ត្រូវអនន្តរិយកម្ម ប្រសិនបើសម្លាប់ព្រះអរហន្តដែលជាជាតិទេវតានោះ បានបាបធ្ងន់ ប៉ុន្តែមិនជាអនន្តរិយកម្មទេ **មនុស្សអរហន្តស្ស ច បុថុជ្ជនកាលេ យេវ សត្ថប្បហារេ វា វិសេ វា ទិន្នេបិ យទិ សោ អរហន្តំ បត្វា**

**តេនេវ មរតិ អរហន្តឃាដកោ ហោតិ យេវ** បុគ្គលដែលជាបុថុជ្ជន ចម្រើននូវកម្មដ្ឋាន មានមនុស្សចង់ពៀរមកប្រហារដោយអាវុធក្ដី យកថ្នាំពិសមកលបដាក់ក្នុងខាទនីយភោជនីយាហារឲ្យបរិភោគក្ដី កាលបើទុក្ខវេទនាកើតខ្លាំងក្លា ដោយហេតុត្រូវប្រហារ និងបរិភោគថ្នាំពិសនោះ លោកមិនលះបង់ មិនដាក់ចុះនូវកម្មដ្ឋាន តាំងនូវសេចក្ដីព្យាយាមក្នុងវិបស្សនា ក៏បានជាព្រះអរហន្ត កាត់នូវកិលេសជាសមុច្ឆេទប្បហាន ជីវិតនៅមិនទាន់អស់ ចូលកាន់ព្រះនិព្វាន ព្រោះហេតុដែលត្រូវប្រហារ និងផឹកនូវថ្នាំពិសនោះ បើយ៉ាងនេះ បុគ្គលដែលប្រហារ ដែលឲ្យថ្នាំពិស ជាអរហន្តឃាត ត្រូវអនន្តរិយកម្ម ។

បិណ្ឌបាតទានដែលបុគ្គលប្រគេនដល់លោក ដែលជាបុថុជ្ជនមានវិបស្សនាចាស់ក្លា ជិតនឹងបានមគ្គ និងផលនោះ បើលោកទទួលបិណ្ឌបាតទៅហើយ លោកយកទៅតម្កល់ទុក នៅមិនទាន់បានឆាន់ទេ ចម្រើនវិបស្សនាសម្រេចជាព្រះអរហន្ត ហើយទើបឆាន់បិណ្ឌបាតទាននោះ ប្រសិនបើយ៉ាងនេះ អ្នកដែលប្រគេនបិណ្ឌបាតទាននោះ បានឈ្មោះថា ប្រគេនដល់បុថុជ្ជន មិនបានឈ្មោះថា ប្រគេនដល់ព្រះអរហន្តទេ ប្រសិនបើលោកទទួលបិណ្ឌបាតទានហើយ លោកមិនបាន

តម្កល់ទុកសិនទេ លោករៀបចំឆាន់មុនស្រេចហើយ ទើបចូលកន្លែងចម្រើនវិបស្សនាក្នុងពេលជាខាងក្រោយ កាលឆាន់រួចហើយ ទើបទៅចម្រើនវិបស្សនា បើបានសម្រេចជាព្រះអរហន្ត បុគ្គលដែលបានប្រគេនបិណ្ឌបាតទាន ឈ្មោះថា ប្រគេនដល់ព្រះអរហន្ត មិនឈ្មោះថាប្រគេនចំពោះបុថុជ្ជនទេ សេចក្ដីថា កាលដែលប្រគេនបិណ្ឌបាតទាននោះ លោកអ្នកទទួលនៅជាបុថុជ្ជនដូចគ្នា ប្លែកគ្នាត្រង់តែឆាន់មុន ជួនកាលទទួលរួចហើយ ក៏យកទៅតម្កល់ទុកមិនទាន់ឆាន់ទេ បានសម្រេចជាព្រះអរហន្តហើយ ទើបឆាន់ជាខាងក្រោយអ្នកប្រគេនឈ្មោះថា ប្រគេនដល់បុថុជ្ជន អ្នកដែលទទួលរួចហើយ ឆាន់ជាមុនទើបទៅធ្វើសមណ-ធម៌ បានជាព្រះអរហន្តក្នុងពេលខាងក្រោយ អ្នកប្រគេនបានឈ្មោះថាប្រគេនចំពោះព្រះអរហន្ត សំខាន់នៅត្រង់ឆាន់ចង្ហាន់ចូលទៅក្នុងកាយកិរិយាដែលបិណ្ឌបាតចូលទៅប្រតិស្ឋាននៅក្នុងកាយនេះ នាំឲ្យប្រាកដផលច្រើន សូម្បីដែលជាអរហន្តឃាត ដូចផលដែលត្រូវប្រហារនិងដាក់ថ្នាំពិសចូលទៅក្នុងកាយ នាំបាបឲ្យខ្លាំងក្លា ឲ្យមានកម្លាំងខ្លាំងឡើង អ្នកដែលប្រហារ អ្នកដែលឲ្យថ្នាំពិស ត្រូវអនន្តរិយកម្ម ជាអរ-ហន្តឃាត ដោយន័យដែលសម្ដែងមកហើយនោះ ។ **សេសអរិយ-**

**បុគ្គលេ មារេន្តស្ស អនន្តរិយំ នត្ថិ** បុគ្គលដែលសម្លាប់នូវអរិយ-បុគ្គលដ៏វិសេស គឺសម្លាប់ព្រះសោតា ព្រះសកទា ព្រះអនាគាមី មិនត្រូវអនន្តរិយកម្មទេ **កម្មំ បន ភារិយំ អនន្តរិយសទិសំ** ប៉ុន្តែកម្មនោះធ្ងន់ សោយទុក្ខវេទនាប្រហាក់ប្រហែលនឹងអនន្តរិយ-កម្ម ។ មួយទៀតសត្វតិរច្ឆានដែលសម្លាប់ព្រះអរហន្ត មានជាតិជាមនុស្ស មិនត្រូវអនន្តរិយកម្មទេ ប៉ុន្តែ កម្មនោះ ធ្ងន់ប្រហែលនឹងអនន្តរិយកម្មដែរ ។

វារៈនេះនឹងពោលដោយលោហិតុប្បាទកម្ម ដែលទេវទត្តភិក្ខុធ្វើដូចតទៅថា **ទេវទត្តេន បវិទ្ធសិលាតោ ភិជ្ជិត្វា គតា សក្ខលិកា** ដុំថ្មដែលទេវទត្តប្រមៀលចុះមក ដើម្បីផ្តាច់ព្រះជន្មព្រះសាស្តា កាលធ្លាក់ចុះមកជិតដល់ព្រះសម្ពុទ្ធ មានដុំថ្មដ៏ធំពីរដុំផុសឡើងអំពីផែនដីព្រមគ្នាបង្អោនកំពូលចូលរកគ្នា មានអាការហាក់ដូចមានជើងសម្រាប់ទទួលដុំថ្ម ដែលទេវទត្តប្រមៀលចុះមកនោះ មិនឲ្យធ្លាក់ទៅត្រូវព្រះវរកាយរបស់ព្រះភគវា គួរអស្ចារ្យ ដុំថ្មដែលទេវទត្តទម្លាក់នោះ ប៉ះទង្គិចយ៉ាងខ្លាំងលើកំពូលថ្មទាំងពីរ ដែលផុសឡើងសម្រាប់ទទួល ក៏បែកចេញជាបំណែកៗ ប៉ើងខ្ចាយចេញទៅ ត្រូវចុងម្រាមព្រះបាទៗ

ហាក់បីដូចត្រូវប្រហារដោយពូថៅ ព្រះលោហិតក៏បានពុះពង់ឡើងជាំមិនបែកចេញឈាមទេ ព្រោះហេតុថា ព្រះវរកាយនោះជាអភេជ្ជ-កាយ សូម្បីតែរោមមួយក៏មិនដាច់ **ជីវកោ បន តថាគតស្ស រុចិយា សត្ថកេន ចម្មំ ឆិន្ទិត្វា** ពេទ្យជីវកកោមារភច្ចវះរបួសដែលត្រូវបំណែកថ្មចេញដោយកាំបិត ប្របាច់ឲ្យឈាមខ្មៅចេញអំពីព្រះបាទ វះរបួសបាននោះ ព្រោះហេតុដែលទ្រង់អនុញ្ញាតឲ្យធ្វើ ទើបអាចវះបាន **តថា ករោន្តស្ស** ជីវកកោមារភច្ចធ្វើនោះដើម្បីនឹងព្យាបាលព្រះសម្មាសម្ពុទ្ធ ឲ្យបាននូវសេចក្តីសុខ កើតគំនរបុណ្យជាអនេក ។

សួរថា **តថាគតេ បរិនិព្វុតេ** កាលព្រះពុទ្ធទ្រង់បរិនិព្វានទៅហើយ បុគ្គលដែលបំផ្លាញព្រះចេតិយ កាប់ដើមពោធិព្រឹក្ស វាយព្រះសារីរិកធាតុ នឹងមានបាបកម្មដូចម្តេច ?

ឆ្លើយថា **ភារិយំ កម្មំ អនន្តរិយសទិសំ** កម្មនោះធ្ងន់ប្រហែលនឹងអនន្តរិយកម្ម គឺឲ្យបានសោយទុក្ខក្នុងនរកជានិច្ច ប្រហែលនឹងអនន្តរិយកម្ម ប្លែកតែកាលឲ្យផល ។ ចំណែកអនន្តរិយកម្មនោះមានកំណត់ទៀង ដែលត្រូវឲ្យផលក្នុងជាតិទី ២ បន្ទាប់ពីបច្ចុប្បន្នជាតិ កម្មដែលប្រហែលនឹងអនន្តរិយកម្មនោះ មិនកំណត់ពេលឲ្យ

ផលឡើយ ប្លែកគ្នាត្រឹមតែប៉ុណ្ណោះឯង ។

អដ្ឋកថាវិសុទ្ធិមគ្គថា **សធាតុកំ បន ថូបំ វា បដិមំ វា ពាធិយមានំ ពោធិសាខំ ឆិន្ទិតុំ វដ្ដតិ** ព្រះស្តូប រូបបដិមាដែលបញ្ចុះព្រះបរមធាតុ បើមែកពោធិព្រឹក្សទោរសង្កត់ព្រះស្តូប និងព្រះបដិមា នាំឲ្យអន្តរាយ និងបាក់បែកព្រោះមែកព្រះពោធិព្រឹក្សទោរសង្កត់នោះ ក៏ត្រូវកាត់មែកពោធិព្រឹក្សចេញ ដោយចេតនារក្សាព្រះស្តូបព្រះបដិមាដែលបញ្ចុះព្រះបរមធាតុនោះក៏គួរ មិនមានទោសទេ ។

**សចេ បិ តត្ថ និសិន្នា សកុណា ចេតិយេ វច្ចំ ចាតេន្តិ ឆិន្ទិតុំ វដ្ដតិ យេវ** មែកពោធិព្រឹក្សដែលទោរទៅខាងលើព្រះស្តូប និងព្រះបដិមា សកុណជាតិទំនៅលើមែកព្រះពោធិព្រឹក្ស បន្ទោបង់មូត្រលាមកធ្លាក់មកត្រូវព្រះស្តូប និងរូបព្រះបដិមា ដែលបញ្ចុះព្រះបរមធាតុនោះ បើដូច្នេះ ត្រូវកាត់មែកពោធិព្រឹក្សក៏គួរ មិនមានទោសទេ ។

**បរិភោគចេតិយតោ ហិ សរីរចេតិយំ មហន្តតរំ** ការពិតដើមពោធិព្រឹក្សនោះ ជាកន្លែងព្រះអង្គបានស្នាក់អាស្រ័យ ក្នុងកាលបានសម្រេចនូវសម្ពោធិញ្ញាណ តាំងនៅក្នុងឋានៈ ដែលជាបរិភោគចេតិយ ព្រះស្តូប និងព្រះបដិមាដែលបញ្ចុះព្រះធាតុនៃព្រះលោក-

នាយកនោះ តាំងនៅក្នុងឋានៈដែលជាសរីរចេតិយ ធំជាងបរិភោគចេតិយ ។

**ចេតិយវត្ថុំ ភិន្ទិត្វា គច្ឆន្តំ ពោធិមូលំបិ ឆិន្ទិត្វា នីហរិតុំ វដ្ដតិ** ឫសពោធិព្រឹក្សដែលដុះជ្រៀតចូលទៅ ធ្វើឲ្យប្រេះព្រះចេតិយដែលបញ្ចុះព្រះបរមធាតុនោះ ក៏សមគួរនឹងកាត់ចោលបាន មិនជាបាបជាទោសទេ ឯមែកពោធិព្រឹក្ស ដែលទោរសង្កត់សសរខឿន ដែលលោកសន្មតថា ផ្ទះរបស់ព្រះពោធិព្រឹក្សនោះ ប្រសិនបើយល់ថា ផ្ទះរបស់ព្រះពោធិព្រឹក្សបាក់បែក ដោយមែកពោធិព្រឹក្សដែលទោរសង្កត់នោះ ក៏កាត់មែកព្រះពោធិព្រឹក្សចេញ ព្រោះហេតុថា នឹងរក្សាផ្ទះព្រះពោធិព្រឹក្សនោះមិនគួរទេ ព្រោះថា ដើមពោធិព្រឹក្សនោះជាធំ ផ្ទះនោះគេធ្វើបូជាព្រះពោធិព្រឹក្ស គេថ្វាយព្រះពោធិព្រឹក្ស ជាផ្ទះរបស់ព្រះពោធិព្រឹក្ស មិនមែនព្រះពោធិព្រឹក្សជារបស់គ្រាន់តែជាផ្ទះៗ ជាធំជាងព្រះពោធិព្រឹក្សនោះមិនមាន ។

**អាសនឃរេបិ ឯសេវ នយោ** សូម្បីសាលាឆាន់ក៏ដូចគ្នា ឃើញថា មែកព្រះពោធិព្រឹក្សទោរសង្កត់សាលាឆាន់ នឹងកាត់មែកព្រះពោធិព្រឹក្សចេញនោះក៏មិនគួរ ។

**អាសនឃរេ ធាតុនិទហិតា ហោតិ** ប្រសិនបើសាលាឆាន់នោះ ជាកន្លែងប្រតិស្ឋាននៃព្រះបរមធាតុ ជាកន្លែងប្រតិស្ឋានព្រះបដិមាដែលបញ្ចុះព្រះបរមធាតុ មែកព្រះពោធិព្រឹក្សទោរសង្កត់សាលាឆាន់ ដូច្នេះ ទើបគួរកាប់មែកពោធិព្រឹក្សចេញបាន ។

**ពោធិជគ្គនត្ថំ ឱតរនសាខំ វា បតិដ្ឋានំ វា ឆិន្ទិតុំ វដ្ដតិយេវ** បើមែកពោធិព្រឹក្សនោះទន់ទោរចុះមក នាំឲ្យដើមបាក់ ឬរលំដួល កាត់មែកពោធិព្រឹក្សចេញ ដោយចេតនានឹងរក្សាដើមព្រះ-ពោធិព្រឹក្សទុកមិនឲ្យរលំនោះ បានបុណ្យច្រើន ដូចគ្នានឹងបុណ្យដែលពេទ្យកោមារភច្ចរក្សាព្រះកាយរបស់ព្រះពុទ្ធអង្គ ។

មួយទៀត ដើម មែករបស់ព្រះពោធិព្រឹក្សនោះ កន្លែងណាពុកផុយ ដួងស៊ី ដង្កូវស៊ី ទុកយូរទៅនាំឲ្យមានអន្តរាយដល់ព្រះពោធិព្រឹក្ស កាលឃើញថាមិនល្អ ក៏ស្មោះយកកន្លែងដែលពុកផុយដួងស៊ី ដង្កូវស៊ីនោះចេញ ដើម្បីនឹងរក្សាព្រះពោធិព្រឹក្សនោះទុក មិនឲ្យមានអន្តរាយ ក៏បានបុណ្យច្រើនដូចគ្នា ដូចរក្សារោគក្នុងព្រះកាយរបស់ព្រះពុទ្ធអង្គ ។

ទីនេះនឹងសម្ដែងក្នុងសង្ឃភេទកម្មនោះ មិនមែនមានកំណត់

សង្ឃដែលនៅក្នុងសីមាប្រជុំគ្នា ដើម្បីនឹងធ្វើសង្ឃភេទណាមួយ ភិក្ខុដែលធ្វើសង្ឃភេទនោះ ទៅបបួលយកភិក្ខុ ប្រជុំបំបែកពួកចេញ ធ្វើសង្ឃកម្មផ្សេងដោយឡែក ទើបជាសង្ឃភេទ នឹងមិនបានកំណត់ដូចនោះ សូម្បីសង្ឃនៅក្នុងសីមាមិនបានប្រជុំគ្នាទេ ភិក្ខុអ្នកធ្វើនូវសង្ឃភេទនោះ ធ្វើនូវសេចក្ដីព្យាយាម ពោលភេទករវត្ថុ គឺពោលមួលបង្កាច់ព្រះពុទ្ធវចនៈ ដែលព្រះអង្គមិនបានបញ្ញត្តប្រាប់ថា បញ្ញត្ត ដែលព្រះអង្គត្រាស់ថា គួរនោះ និយាយត្រឡប់ថា មិនគួរ ទីបំផុតនឹងបែកពោលឲ្យខុសអំពីព្រះពុទ្ធដីកា ញ៉ាំងភិក្ខុដែលប្រាសចាកបញ្ញាឲ្យរាប់អានជឿពាក្យរបស់ខ្លួន និយាយវង្វេងវង្វាន់ៗ ត្រចៀក ឧបត្ថម្ភគាំទ្រទឹកចិត្តរបស់ភិក្ខុដែលប្រាសចាកបញ្ញានោះ ឲ្យស្រឡាញ់ពេញចិត្តក្នុងពាក្យរបស់ខ្លួន ដែលពោលមួលបង្កាច់ព្រះពុទ្ធវចនៈ សរសេរស្ងាកឲ្យចាប់ ធ្វើភិក្ខុដែលប្រាសចាកបញ្ញានោះ ឲ្យប្រកាន់មាំ មិនឲ្យត្រឡប់ត្រឡិន មិនឲ្យឃ្លេងឃ្លោង លុះបានពួកដូច្នេះច្រើនរូប សូម្បីមិនច្រើន ត្រឹមតែ ៤ រូប ក៏បំបែកចេញធ្វើសង្ឃកម្មផ្សេងដោយឡែក សូធ្យបាតិមោក្ខផ្សេងដោយឡែកក្នុងកាលណា ក៏ជាសង្ឃភេទ ត្រូវអនន្តរិយកម្មក្នុងកាលនោះ ប៉ុន្តែបើជាសង្ឃភេទនោះ អាស្រ័យមានភិក្ខុនៅក្នុងសីមាតាំងអំពី

៤ រូបឡើងទៅ បើនៅក្នុងសីមានោះ មានភិក្ខុតិចជាង ៥ រូបហើយ ទោះបីធ្វើការបំបែកសង្ឃ ក៏មិនជាសង្ឃភេទដែរ ។ ក្នុងសីមាដែលមានភិក្ខុច្រើនជាង៩រូប ភិក្ខុធ្វើសង្ឃភេទ ក៏សម្រេចបានជាសង្ឃភេទ ។ សូមពោលចំពោះតែសីមាដែលមានភិក្ខុរស់នៅ ៩ រូបនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា សីមាដែលមានភិក្ខុនៅ ៩ រូបនោះ ភិក្ខុមួយរូបព្យាយាមធ្វើសង្ឃភេទ ភិក្ខុនោះបបួលភិក្ខុដែលប្រាសចាកបញ្ញាឲ្យចូលពួករបស់ខ្លួន ឲ្យនៅក្នុងឱវាទរបស់ខ្លួនបាន ៤ រូប ឲ្យចាប់ស្លាកហើយ ទាំង ៤ រូបនោះ ៤ រូបទៀតមានបញ្ញា លោកមិនចូលពួកខ្លួន ដោយលោកឡើងជាធម្មវាទី ៤ រូប លោកជាអ្នកបំបែកមួយរូបជា ៥ រូប ។ ភិក្ខុដែលជាអ្នកបំបែកនោះ ប្រសិនបើបំបែកភិក្ខុ ៤រូបដែលវង្វេងចូលពួករបស់ខ្លួន ចេញធ្វើសង្ឃកម្មផ្សេងដោយឡែក សូធ្យបាតិមោក្ខផ្សេងដោយឡែកកាលណា ក៏ជាសង្ឃភេទ ត្រូវអនន្តរិយកម្មក្នុងកាលនោះ ។ បើនៅក្នុងសីមាតិចជាង ៩ រូប គឺមានតែ ៨ រូប លើកយកអ្នកបំបែកចេញមួយហើយ នៅតែ ៧ រូប សូម្បីបំបែកចេញក៏មិនជាសង្ឃភេទ ម្ខាងៗ មិនគ្រប់ ៤ រូប មិនជាសង្ឃភេទ ទាំងពីរផ្នែកខ្វះមួយរូប ក៏មិនជាសង្ឃភេទដែរ កាលបើគ្រប់ ៤ រូបទាំងពីរផ្នែក

គ្រប់សង្ឃទាំងពីរផ្នែក ភិក្ខុអ្នកបំបែកធ្វើសង្ឃកម្មផ្សេងដោយឡែក ទើបជាសង្ឃភេទ កាលបើជាសង្ឃភេទហើយ ភិក្ខុអ្នកបំបែកនោះត្រូវអនន្តរិយកម្ម ភិក្ខុដែលវង្វេងជឿពាក្យបដិបត្តិតាមភិក្ខុអ្នកធ្វើ សង្ឃភេទនោះ បានបាប បានទោសច្រើន ភិក្ខុជាធម្មវាទី មានទូវបញ្ញា លោកមិនបានបដិបត្តិតាមភិក្ខុដែលធ្វើសង្ឃភេទនោះ **អនវជ្ជា** លោកមិនបានទទួលបាប មិនបានទទួលកម្ម ប្រាសចាកបាប ជាអ្នកគ្មានទោស ។

ព្រះនន្ទាចារ្យនាំយកសូត្រ ដែលព្រះពុទ្ធអង្គត្រាស់សម្ដែងដល់ព្រះឧបលិត្ថេរមកជាសាធកៈថា **ឯកតោ ឧបាលិ ចត្តារោ ហោន្តិ ឯកតោ ចត្តារោ នវមោ អនុសាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ គណ្ហាថ ឥទំ រោចេថាតិ ឯវំ ខោ ឧបាលិ សង្ឃរាជី ចេវ ហោតិ សង្ឃភេទោ ចាតិ** អធិប្បាយថា ម្នាលឧបាលី លក្ខណៈដែលជាសង្ឃភេទនោះ អាស្រ័យហេតុដែលគ្រប់ ៤ រូបទាំងពីរផ្នែក ចំណែកធម្មវាទី ៤ រូប ចំណែកអធម្មវាទី ៤ រូប គ្រប់សង្ឃទាំងពីរចំណែក រួមទាំងភិក្ខុអ្នកបំបែកនោះ មានគម្រប់ ៩ រូប ។ ភិក្ខុអ្នកបំបែកនោះពោលខ្សឹបជិតត្រចៀក ពោលមួលបង្កាច់ព្រះពុទ្ធវចនៈ នាំយកលទ្ធិរបស់ខ្លួនមកសម្ដែងតាមអធ្យាស្រ័យហើយ

ក៏បំភ្លាត់ថា នេះឯងជាធម្មវាទី និងជាវិន័យ នេះឯងជាពាក្យប្រៀនប្រដៅរបស់ព្រះបរមគ្រូ ចូរលោកកាន់យកយ៉ាងនេះចុះ ចូរលោកពេញចិត្តបដិបត្តិយ៉ាងនេះចុះ ពោលរួចហើយ ក៏ឲ្យចាប់ស្លាក ។ ចំណែកភិក្ខុគ្មានបញ្ញា មិនបានយល់ទៅតាមសេចក្តីពិត ចាប់ស្លាកមកបដិបត្តិតាមពាក្យរបស់ភិក្ខុអ្នកបំបែកៗ ក៏ញែកពួកចេញជា ៤ រូប គឺជា ៥ រូបជាមួយគ្នានឹងខ្លួនបំបែកចេញ ធ្វើសង្ឃកម្មផ្សេងដោយឡែក សូធ្យបាតិមោក្ខផ្សេងដោយឡែក ។ ពួកធម្មវាទី ៤ រូបនោះ លោកក៏ប្រជុំគ្នា ធ្វើសង្ឃកម្មផ្សេងដោយឡែក សូធ្យបាតិមោក្ខផ្សេងដោយឡែក យ៉ាងនេះ កាលណា ក៏ឈ្មោះថា សង្ឃបែកគ្នាក្នុងកាលនោះ ។ ម្នាលឧបាលិ ភិក្ខុដែលច្រើនជាង ៤ រូប ម្ខាងៗ ឡើងទៅ ដល់រយពាន់រូប ប៉ុនណាៗ ក្តី ភិក្ខុអ្នកបំបែកខ្វល់ខ្វាយណែនាំឲ្យជឿពាក្យ ដែលមួលបង្កាច់ព្រះពុទ្ធវចនៈ ឲ្យចាប់ស្លាកគាំទ្រ មិនឲ្យប្រែប្រួលត្រឡប់ត្រឡិន បានសម្រេចដូចបំណងរបស់ខ្លួនហើយ នឹងបំបែកពួកដែលវង្វេងជឿពាក្យ ចេញធ្វើសង្ឃកម្មផ្សេងដោយឡែក សូធ្យបាតិមោក្ខផ្សេងដោយឡែក ចំណែកពួកធម្មវាទីដែលមិនវង្វេងនោះ ក៏ប្រជុំគ្នាធ្វើសង្ឃកម្មផ្សេងដោយឡែក សូធ្យបាតិ-មោក្ខផ្សេងដោយឡែក យ៉ាងនោះ ក្នុងកាលណា ក៏បានឈ្មោះថា ធ្វើ

សង្ឃភេទក្នុងកាលនោះ ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា សង្ឃភេទកម្មមានទោសច្រើន បាបច្រើននោះ ព្រោះហេតុព្រះពុទ្ធវចនៈសម្តែងភេទករវត្ថុ ១៨ ប្រការ ។ ភេទករវត្ថុ ១៨ ព្រះសម្ពុទ្ធទ្រង់ទេសនាទុកក្នុងសង្ឃភេទក្ខន្ធកៈ ក្នុងគម្ពីរចុល្លវគ្គថា **អធម្មំ ធម្មោតិ ទីបេន្តិ** អធម៌ ភិក្ខុអ្នកបំបែកសង្ឃពោលថា ជាធម៌ ១ **ធម្មំ អធម្មោតិ ទីបេន្តិ** ធម៌ ភិក្ខុបំបែកសង្ឃពោលថា អធម៌ ១ **អវិនយំ វិនយោតិ ទីបេន្តិ** មិនមែនវិន័យ ភិក្ខុអ្នកបំបែកសង្ឃ ពោលថា ជាវិន័យ ១ **វិនយំ វិនយោតិ ទីបេន្តិ** វិន័យ ភិក្ខុអ្នកបំបែកសង្ឃ ពោលថា មិនមែនវិន័យ ១ **អភាសិតំ អលបិតំ តថាគតេន ភាសិតំ បលិតំ តថាគតេនាតិ ទីបេន្តិ** ធម៌ដែលព្រះសម្ពុទ្ធមិនបានសម្តែង ភិក្ខុអ្នកបំបែកសង្ឃ ពោលថា ព្រះពុទ្ធបានសម្តែង ១ **ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ** ព្រះពុទ្ធបានសម្តែង ភិក្ខុអ្នកបំបែកសង្ឃ ពោលថា មិនបានសម្តែង ១ **អនាចិណ្ណំ តថាគតេន អចិណ្ណំ តថាគតេនាតិ ទីបេន្តិ** វត្តដែលព្រះពុទ្ធមិនបានសន្សំ ប្រព្រឹត្តជាប្រពៃណីរបស់ព្រះសម្មាសម្ពុទ្ធ ភិក្ខុបំបែកសង្ឃ ពោលថា ព្រះពុទ្ធ

បានសន្សំជាប្រពៃណីរបស់ព្រះពុទ្ធ ១ **អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ** វត្តដែលព្រះសម្ពុទ្ធបានសន្សំជាប្រពៃណីរបស់ព្រះលោកនាថនោះ ត្រឡប់ពោលលើកឡើងថា ព្រះ-ពុទ្ធមិនបានសន្សំជាប្រពៃណីរបស់ព្រះអង្គ ១ **អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ** សិក្ខាបទដែលព្រះពុទ្ធអង្គមិនបានបញ្ញត្ត ពោលថា ព្រះពុទ្ធបានបញ្ញត្ត ១ **បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន** សិក្ខាបទដែលព្រះពុទ្ធបញ្ញត្ត ពោលថា ព្រះពុទ្ធមិនបានបញ្ញត្ត ១ **អនាបត្តឹ អាបត្តីតិ ទីបេន្តិ** មិនជាអាបត្តិ ត្រឡប់ពោលថា ជាអាបត្តិ ១ **អាបត្តឹ អនាបត្តីតិ ទីបេន្តិ** ជាអាបត្តិ ត្រឡប់ពោលថា ជាអនាបត្តិ ១ **លហុកំ អាបត្តឹ គរុកា អាបត្តីតិ ទីបេន្តិ** អាបត្តិស្រាលៗ ត្រឡប់ពោលថា ជាអាបត្តិធ្ងន់ ១ **គរុកំ អាបត្តឹ លហុកា អាបត្តីតិ ទីបេន្តិ** អាបត្តិដែលធ្ងន់ ត្រឡប់ពោលថា ជាអាបត្តិស្រាល ១ **សាវសេសំ អាបត្តឹ អនវសេសា អាបត្តីតិ ទីបេន្តិ** អាបត្តិដែលជាសាវសេសបត្តិ គឺអាចកែខៃរក្សាបាន ពោលថា ជាអនវសេសបត្តិ ១ **អនវសេសំ អាបត្តឹ សាវ-**

**សេសា អាបត្តីតិ ធីបេន្តិ** *អនវសេសាបត្តិ គឺអាបត្តិដែលកែខៃមិនបាន ត្រឡប់ពោលថា ជាសាវសេសបត្តិ ១* **ទុដ្ឋុល្លំ អាបត្តី អទុដ្ឋុល្លា អាបត្តីតិ ធីបេន្តិ** *អាបត្តិគ្រោតគ្រាត ត្រឡប់ពោលថា ជាអាបត្តិគ្រោតគ្រាត ១* **អទុដ្ឋុល្លំ អាបត្តី ទុដ្ឋុល្លា អាបត្តីតិ ធីបេន្តិ** *អាបត្តិដែលមិនគ្រោតគ្រាត ត្រឡប់ពោលថា ជាអាបត្តិគ្រោតគ្រាត ១ ។*

*ក្នុងគម្ពីរបតុត្តសមន្តប្បាសាទិកា អដ្ឋកថាចុល្លវគ្គវិសជ្ជនាថា កុសលកម្មបថ ១០ ប្រការនោះ បានឈ្មោះថា ជាធម៌ដោយពិត ឯអកុសលកម្មបថ បានឈ្មោះថា មិនជាធម៌ទៅតាមសេចក្តីពិតទេ ។ ភិក្ខុដែលធ្វើសង្ឃភេទនោះ កាលបើពោលឲ្យជាជំទាស់ ត្រឡប់សេចក្តីថា កុសលកម្មបថនោះ ហៅថា អកុសលកម្មបថ ។ ពោលត្រឡប់ត្រឹមតែប៉ុណ្ណោះ ឈ្មោះថា ពោលបង្អាច់ព្រះពុទ្ធវចនៈ សម្តែងថា ធម៌មិនមែនជាធម៌ មិនមែនជាធម៌សម្តែងថា ជាធម៌ ។*

*មិនត្រឹមតែប៉ុណ្ណោះទេ ភិក្ខុដែលធ្វើសង្ឃភេទនោះ ព្រោះហេតុដែលប្រាថ្នាឲ្យខ្លួនមានមុខមានមាត់ប្រាកដនោះ កាលបើពោលជំទាស់ចំពោះព្រះពុទ្ធដីកា ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤*

នោះ តិះដៀលថាខុស សតិប្បដ្ឋាន ៣ សម្មប្បធាន ៣ ឥទ្ធិបាទ ៣ នោះ ពោលយ៉ាងនេះទើបត្រូវ ។ ប្រការដែលពោលថា ឥទ្ធិបាទ ៤ ពល ៥ ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គ ៨ នោះមិនត្រូវទេ ។ ឥទ្ធិបាទ ៥ ពល ៦ ពោជ្ឈង្គ ៨ អដ្ឋង្គិកមគ្គ ៩ ពោលយ៉ាងនេះទើបត្រូវ ភិក្ខុពោលមួលបង្កាច់ព្រះពុទ្ធវចនៈដូច្នេះ ឈ្មោះថា សម្ដែងធម៌ ថាជាអធម៌ សម្ដែងអធម៌ ថាជាអធម៌ ដូច្នេះ ។

មិនត្រឹមតែប៉ុណ្ណេះទេ ពាក្យដែលពោលជំទាស់ ចំពោះព្រះពុទ្ធដីកាថា ឧបាទាន ៤ នីវរណៈ ៥ អនុស័យ ៧ មិច្ឆត្តនិយត ៧៨ ដែលព្រះមានជោគត្រាស់សម្ដែងនោះ ធ្វើឲ្យឃ្លៀងឃ្លាតទៅបន្តិច ។ សម្ដែងដូចពោលមកនេះ ជាសុត្តន្តបរិយាយ បើសម្ដែងដោយវិនយបរិយាយសោត ធម្មតាវិនយធរប្រាថ្នានឹងរម្ងាប់អធិករណ៍នោះ ចូរសួរដើមចោទ ឯចុងចោទចូរត្រូវទៅតាមសេចក្ដីពិត ចូរពិភាក្សាតាមពាក្យដើមចោទ និងចុងចោទឲ្យស្របគ្នា យ៉ាងនេះ ជាធម្មតារបស់វិនយធរក្នុងព្រះពុទ្ធសាសនា ។ ឯភិក្ខុធ្វើសង្ឃភេទនោះតិះដៀលថា ប្រយោជន៍អ្វីដោយការសាកសួរដេញដោលដើមចោទ និងចុងចោទឲ្យស្របគ្នា ឃើញយ៉ាងណា ក៏កាត់ក្ដីយ៉ាងនោះឯង ទើបល្អ

**អក្ខរេន វត្តុនា អប្បដិញ្ញាយ** សូម្បីវត្ថុមិនពិត ចម្លើយមិនស្របគ្នា ក៏គួរពិភាក្សាបាន ភិក្ខុអ្នកធ្វើសង្ឃភេទពោលដូច្នេះ ក៏បានឈ្មោះថា សម្តែងជាធម៌ថាជាអធម៌ សម្តែងអធម៌ ថាជាធម៌ ។

ទាំងនេះពោលដោយលក្ខណៈនៃវិន័យ ដោយសុត្តន្តបរិយាយមុន **រាគវិនយោ ទោសវិនយោ មោហវិនយោ សំវរោ បហានំ បតិសង្ខាតិ អយំ វិនយោ នាម** អធិប្បាយតាមសុត្តន្តបរិយាយនោះថា ដោយលក្ខណៈកិរិយាដែលបន្ទោបង់នូវរាគៈ បន្ទោបង់នូវទោសៈ បន្ទោបង់នូវមោហៈ ប្រព្រឹត្តសង្រួមនូវឥន្ទ្រិយ លះបង់នូវកាយទុច្ចិត វចីទុច្ចរិត មនោទុច្ចរិត មានបញ្ញាពិចារណាខុស និងត្រូវ គួរ និងមិនគួរនោះ ឈ្មោះថា វិន័យ ដោយអត្ថថា នាំខ្លួនឲ្យផុតចាកសង្សារទុក្ខ និងអបាយភូមិទាំងឡាយ លក្ខណៈរបស់វិន័យដែលសម្តែងដោយសុត្តន្តបរិយាយ ដូច្នេះ ភិក្ខុធ្វើនូវសង្ឃភេទនោះហាមឃាត់ថា កិរិយាដែលបន្ទោបង់រាគៈ ទោសៈ មោហៈនោះក្តី កិរិយាដែលសង្រួមនូវឥន្ទ្រិយនោះក្តី លះបង់នូវកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតនោះក្តី កិរិយាដែលពិចារណាខុស និងត្រូវ គួរមិនគួរនោះក្តី អាការដែលបដិបត្តិយ៉ាងនេះក្តី មិនមែនជាវិន័យទេ មិនឈ្មោះថា

វិន័យទេ កិរិយាដែលបដិបត្តិតាមសមគួរដល់អធ្យាស្រ័យ មិនបន្ទោបង់រាគៈ ទោសៈ មោហៈ មិនសង្រួមឥន្ទ្រិយ មិនលះបង់នូវកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ប្រាសចាកការពិចារណាខុស និងត្រូវគួរ និងមិនគួរ នេះឯងជាវិន័យ ភិក្ខុឯទៀតពោលដូច្នេះឯង ឈ្មោះថាសម្តែងនូវវត្ថុដែលជាវិន័យ ថាមិនមែនជាវិន័យ មិនមែនជាវិន័យ ថាជាវិន័យ លក្ខណៈរបស់វិន័យនោះ សម្តែងដោយវិនយបរិយាយថា **វត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុសាវនសម្បត្តិ សីមាសម្បត្តិ បរិស-សម្បត្តិ អយំ វិនយោ នាម** អធិប្បាយតាមវិនយបរិយាយនោះថា សង្ឃកម្មសម្រេចជាការល្អ ឈ្មោះថា សង្ឃធ្វើល្អនោះ អាស្រ័យដោយភាពបរិបូណ៌នូវសម្បត្តិ ៥ ប្រការ គឺវត្ថុសម្បត្តិ ១ ញត្តិសម្បត្តិ ១ អនុសាវនាសម្បត្តិ ១ សីមាសម្បត្តិ ១ បរិស័ទសម្បត្តិ ១ ។

**វត្ថុសម្បត្តិ** បានដល់ បុគ្គលដែលជាហេតុ ឲ្យសង្ឃធ្វើសង្ឃកម្ម ប្រសិនបើពោលដោយឧបសម្បទាកម្មនោះ បុគ្គលអ្នកឧបសម្បទានោះជាវត្ថុ ប្រសិនបើពោលដោយកឋិនកម្មនោះ លោកអ្នកក្រាលកឋិនជាវត្ថុ បើពោលដោយបរិវាសកម្ម មានត្ត និងអព្ភាននោះ លោកអ្នកសូមបរិវាស សូមមានត្ត សូមអព្ភានជាវត្ថុ បើពោលសមនុភាសនកម្ម

តជ្ជនីយកម្ម និយសកម្ម បដិសារាណីយកម្ម បព្វាជនីយកម្ម ឧក្ខេ-បនីយកម្ម និងមោហាកម្មជាដើមនោះ មានភិក្ខុអ្នកធ្វើខុសជាវត្ថុ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា បុគ្គលអ្នកឧបសម្បទានោះ គប្បីមិនជាមនុស្សខ្ទើយ គប្បីមិនជាមនុស្សឧភតោព្យញ្ជនកៈ គប្បីមិនជាមនុស្សថេយ្យសង្វាស មិនមែនជាតិរ្ថិយបក្កន្ត មិនត្រូវអន្តិមវត្ថុ មិនជាបុគ្គលធ្វើអនន្តរិយកម្ម មានវស្សាគម្រប់ ២០ បរិបូណ៌ គួរនឹងឧប-សម្បទាឡើងបាន នេះឯងហៅថា វត្ថុសម្បត្តិក្នុងឧបសម្បទាកម្ម ។

**ញត្តិសម្បត្តិ** គឺសូធ្យញត្តិត្រឹមត្រូវតាមសមគួរដល់អក្ខរៈ ទីឃៈ រស្សៈ សិថិល ធនិត គរុ លហុ ប្រកបដោយសំយោគ ប្រាសចាកសំយោគ ប្រកបនិគ្គហិត មិនបានប្ដូរបទ និងមិនបាន បែកបទ ។

**អនុសាវនាសម្បត្តិ** គឺសូធ្យអនុសាវនាត្រឹមត្រូវតាមសម-គួរ មានទីឃៈ រស្សៈជាដើម ។

**សីមាសម្បត្តិ** គឺសីមាសម្បត្តិសមគួរដល់សង្ឃកម្ម ប្រាស ចាកទោស ជាវិបត្តិដោយហេតុណានីមួយ ។

**បរិសសម្បត្តិ** គឺភិក្ខុទាំងឡាយប្រជុំព្រមគ្នា ធ្វើសង្ឃកម្ម

ដែលប្រាសចាកមន្ទិល គឺភាពទ្រុស្តសីល អង្គុយក្នុងហត្ថបាស ទើបជាការល្អ ដូចសម្បត្តិទាំង ៥ ប្រការដូច្នេះ ជាប្រពៃណីរបស់សាវកក្នុងព្រះពុទ្ធសាសនា ។

ភិក្ខុដែលព្យាយាមធ្វើសង្ឃភេទនោះ ពោលតិះដៀលថា ប្រយោជន៍អ្វីដោយសម្បត្តិ ៥ ប្រការ សង្ឃកម្មទាំងឡាយមិនសម្រេចដោយសម្បត្តិ ៥ ប្រការនោះទេ វិបត្តិ ៥ ប្រការ គឺវត្ថុវិបត្តិ ១ ញត្តិវិបត្តិ ១ អនុសាវនាវិបត្តិ ១ សីមាវិបត្តិ ១ បរិស័ទវិបត្តិ ១ នោះឲ្យសម្រេចជាសង្ឃកម្មបាន ។

ភិក្ខុអ្នកព្យាយាមធ្វើសង្ឃភេទពោលដូច្នេះ ក៏បានឈ្មោះថាសម្តែងនូវអវិន័យ ថាជាវិន័យ ដែលជាវិន័យ សម្តែងថាជាអវិន័យ អ្នកប្រាជ្ញគប្បីជ្រាវកថាសង្ខេបដូច្នេះចុះ ។

ភិក្ខុអ្នកព្យាយាមធ្វើសង្ឃភេទនោះ ជួនកាលក៏ពោលភេទករវត្ថុថាបារាជិក ៤ សង្ឃាទិសេស ១៣ អនិយត ២ និស្សគ្គិយបាចិត្តិយ ៣០ ព្រះពុទ្ធមិនបានបញ្ញត្តទេ ។ ព្រះពុទ្ធបញ្ញត្តតែបារាជិក ៥ សង្ឃាទិសេស ១៤ អនិយត ៣ និស្សគ្គិយបាចិត្តយ ៣១ ទេតើ ។ មួយទៀត អាបត្តិបារាជិក និងអាបត្តិសង្ឃាទិសេសនោះ ជាលហុកាបត្តិ មិនជាគរុកាបត្តិទេ អាបត្តិថុល្លច្ច័យ អាបត្តិបាចិត្តិយ បាជិ-

ទេសនីយ ទុព្ភាសិតនោះ ជាគរុកាបត្តិ អាបត្តិបារាជិកនោះ ជាសាវសេស ( កែខៃបាន ) អាបត្តិដទៃៗ ជាអនវសេស ( កែខៃមិនបាន ) ។ ភិក្ខុអ្នកព្យាយាមធ្វើសង្ឃភេទនោះ សម្តែងភេទករវត្ថុ ពោលមួលបង្កាច់ព្រះពុទ្ធវចនៈជាដើមដូច្នេះ ព្រោះហេតុដូច្នោះ ទើបសង្ឃភេទជាបាបធ្ងន់ជាងអនន្តរិយកម្មទាំង ៤ ប្រការ ។ ប្រសិនបើចាត់ដោយកម្មនោះ អនន្តរិយកម្ម ៤ ប្រការ ជាកាយកម្ម សង្ឃភេទនេះជាវចីកម្ម បើចាត់ដោយទ្វារនោះ អនន្តរិយកម្ម ៤ ជាកាយកម្ម-កាយទ្វារខ្លះ ជាកាយកម្មវចីទ្វារខ្លះ ។ កាលបើសម្លាប់មាតាបិតា ព្រះអរហន្ត ញ៉ាំងលោហិតព្រះលោកនាយក ឲ្យពុរពងទៅដោយដៃរបស់ខ្លួន ជាកាយកម្មកាយទ្វារ កាលប្រើអ្នកដទៃឲ្យធ្វើនោះ ជាកាយកម្មវចីទ្វារ ប៉ុន្តែសង្ឃភេទនោះ សូម្បីធ្វើដោយដៃ បំបែកភិក្ខុដែលជឿពាក្យរបស់ខ្លួនចេញអំពីទីប្រជុំសង្ឃ ដោយកិរិយាដែលធ្វើដោយដៃ ដោយជន្ទន់ជាសម្គាល់នោះក្តី សូម្បីកាលដែលនឹងជាសង្ឃភេទក៏ដោយ វចីទ្វារសម្រេចដោយញត្តិ និងអនុសាវនា សូធ្យបាតិមោក្ខដោយវិន័យដែលសម្តែងមកហើយនោះ ។ បើពោលដោយកប្បដ្ឋិតិនោះ ជាកប្បដ្ឋិតិសង្ឃភេទតែមួយ អនន្តរិយកម្មទាំង ៤ នោះមិនបានជាកប្បដ្ឋិតិទេ សង្ឃភេទនេះមានកំណត់ដែលនឹងរួចចាកនរក

ក្នុងកាលដែលលោកវិនាស បើកប្បនៅមិនទាន់វិនាសដរាបណា អ្នកដែលធ្វើសង្ឃភេទក៏នៅមិនទាន់ផុតពីនរកដរាបនោះ ។ សង្ឃភេទកម្មនោះមានកំណត់ផុតអំពីទុក្ខ ឡើងមកពីនរកក្នុងកាលដែលលោកវិនាស **សេវ កប្បោ វិនស្សតិ** ប្រសិនបើស្អែកនេះ កប្បនឹងត្រូវវិនាស អ្នកធ្វើសង្ឃភេទក្នុងថ្ងៃនេះ ភិក្ខុនោះធ្លាក់ទៅឆេះក្នុងនរកមួយថ្ងៃក៏ផុតចាកទុក្ខ ពោលដូច្នេះ គ្រាន់តែបញ្ជាក់ឲ្យឃើញថា សង្ឃភេទនោះមានកំណត់អស់ក្នុងកាលដែលលោកវិនាស **ឯវំ បន ការណំ នត្ថិ** បុគ្គលធ្វើសង្ឃភេទ ក្នុងកាលដែលកប្បវិនាសដូចពោលនោះមិនមានបើនឹងពោលដោយកិរិយាឲ្យផលនោះថា **យេ បញ្ច បេតានិ កម្មានិ កតានិ ហោន្តិ តស្ស សង្ឃភេទោ យេវ បដិសន្ធិវសេន វិបច្ចតិ សេសានិ អហោសិកម្មំ នាហោសិ កម្មវិបាកោតិ ឯវមាទីសុ សង្ខ្យំ គច្ឆន្តិ** អនន្តរិយកម្ម ៥ នេះ ប្រសិនបើអ្នកណាធ្វើព្រមទាំង ៥ ប្រការ លុះអ្នកនោះបែកធ្លាយរាងកាយទៅ ទោសនៃសង្ឃភេទដែលជាតួនាទីតាក់តែងបដិសន្ធិ ឲ្យកើតក្នុងអវិចីនរកអស់កាលដ៏យូរដរាបអស់វិវដ្តដ្ឋាយីអសង្ខេយ្យកប្ប កម្មដែលបុគ្គលធ្វើលោហិតុប្បាទសម្លាប់ព្រះអរហន្ត សម្លាប់មាតាបិតានោះក៏ជាអហោសិកម្ម នឹងមិន

បានឲ្យផលបន្ទាប់ទេ សូម្បីកាលរាប់ចូលក្នុងអតីតថា **អហោសិកម្មំ នាហោសិ កម្មវិបាកោ** អធិប្បាយថា កម្មនៅមាន ប៉ុន្តែមិនឲ្យផលក្នុងអតីតទេ មានតែកម្មមិនបានមានផលក្នុងកាលអនាគត និងបុគ្គលដែលមិនបានធ្វើសង្ឃភេទ បានធ្វើតែ ៤ ប្រការ គឺមាតុឃាត បិតុឃាត អរហន្តឃាត លោហិតុប្បាទ លុះបែកធ្លាយរាងកាយទៅ លោហិតុប្បាទក៏នាំបដិសន្ធិឲ្យកើតក្នុងនរក រងទុក្ខវេទនាយ៉ាងក្រៃលែង ។ លុះអស់បាបអស់ទោសលោហិតុប្បាទហើយ បាបកម្មដែលសម្លាប់ព្រះអរហន្តសម្លាប់មាតាបិតាក៏អស់សូន្យ ជាអហោសិកម្ម មិនបានឲ្យផលបន្តទៅក្នុងជាតិខាងមុខ និងបុគ្គលដែលបានធ្វើអនន្តរិយកម្ម ៣ ប្រការ គឺអរហន្តឃាត មាតុឃាត បិតុឃាត លុះបែកធ្លាយរាងកាយទៅហើយ អរហន្តឃាតក៏នាំបដិសន្ធិឲ្យទៅកើតក្នុងនរក រងទុក្ខវេទនាដ៏ក្រៃលែង លុះអស់បាបអស់កម្ម អស់ទោសអរហន្តឃាតហើយ បាបមាតុឃាត បាបបិតុឃាតក៏ជាអហោសិកម្ម មិនបានឲ្យផលបន្តទៅក្នុងជាតិខាងមុខទៀតឡើយ និងបុគ្គលដែលបានធ្វើអនន្តរិយកម្មតែពីរ គឺមាតុឃាត និងបិតុឃាត លុះបែកធ្លាយរាងកាយទៅ ជួនកាលបិតុឃាតនាំបដិសន្ធិ ជួនកាលមាតុឃាតនាំបដិសន្ធិ ។

**សចេ បិតា សីលវា ហោតិ មាតា ទុស្សីលវា ឆោ វា តថា សីលវតី** *អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា បើបិតាមានសីល រក្សាសីលបានល្អ មាតានោះរក្សាសីលមិនបានល្អ ធ្វើឲ្យដាច់សីល បើមិនដូច្នោះ មាតាជាមនុស្សគ្មានសីល បើយ៉ាងនេះ បិតុឃាតក៏នាំបដិសន្ធិឲ្យទៅកើតក្នុងនរក រងទុក្ខវេទនាដ៏ក្រៃលែង បើមាតាបិតា មានសីលដូចគ្នាក្តី មាតាបិតាមិនមានសីលដូចគ្នាក្តី បើដូច្នេះ មាតុឃាតកម្មក៏នាំបដិសន្ធិក្នុងនរក រងទុក្ខវេទនាដ៏ក្រៃលែង ។*

*ពិតណាស់ មាតា និងបិតានោះ សូម្បីជាមនុស្សអាក្រក់ជាមនុស្សទ្រុស្តសីលស្មើគ្នាក្តី បាបដែលសម្លាប់មាតានោះមានច្រើនជាងបាបសម្លាប់បិតា ព្រោះហេតុថា មាតានោះ មានគុណច្រើនជាងក្នុងការចិញ្ចឹមកូនប្រុសស្រី មានសេចក្តីលំបាកជាងបិតា ចាប់ផ្តើមតាំងអំពីកូនមកចុះចាប់បដិសន្ធិនៅក្នុងផ្ទៃ មាតាបានសេចក្តីលំបាកជាច្រើន សោយទុក្ខវេទនាជានិច្ចកាល គ្រប់ប្រការដែលមាតាសង្គ្រោះកូនប្រុសស្រី អ្នកដទៃមិនអាចធ្វើបាន មាតានោះមានគុណច្រើនជាងបិតា ដូច្នេះ កាលមាតាបិតាជាអ្នកទ្រុស្តសីលស្មើគ្នា ទើបបាបដែលសម្លាប់មាតានោះច្រើនជាងសម្លាប់បិតា បាបដែលសម្លាប់មាតានោះនាំបដិសន្ធិក្នុងនរក រងទុក្ខវេទនាដ៏ក្រៃលែង លុះអស់បាប អស់កម្ម អស់*

*ទោសមាតុឃាតហើយ បាបបិតុឃាតក៏អស់សូន្យ ជាអហោសិកម្ម មិនបានឲ្យផលបន្តទៅក្នុងជាតិខាងមុខ* **ចាកតោបិ វិញ្ញាតព្វោ** *អ្នកប្រាជ្ញគប្បីជ្រាបនូវសេចក្តីវិនិច្ឆ័យក្នុងផល របស់បញ្ចានន្តរិយកម្ម ដោយប្រការដូច្នេះ ។*

*ទីនេះពោលដោយសាធារណៈ និងអសាធារណៈ* **បុរិមានិ ចត្តារិ សព្វេសំបិ គហដ្ឋបព្វជិតានំបិ សាធារណានិ** *អនន្តរិយកម្ម ៤ ប្រការខាងដើម គឺមាតុឃាត បិតុឃាត អរហន្តឃាត លោហិ- តុប្បាទនោះ ជាសាធារណៈទូទៅដល់គ្រហស្ថ និងបព្វជិត អធិប្បាយថា គ្រហស្ថក៏ធ្វើបាន បព្វជិតក៏ធ្វើបាន ប៉ុន្តែចំពោះសង្ឃភេទវិញនោះជាអសាធារណៈ មិនទូទៅដល់អ្នកដទៃក្រៅអំពីភិក្ខុ សង្ឃភេទនេះធ្វើបានចំពោះតែភិក្ខុ ក្រៅអំពីភិក្ខុ អ្នកដទៃមិនអាចធ្វើសង្ឃភេទបាន ហេតុមានព្រះពុទ្ធដីកា ត្រាស់ដល់ព្រះឧបាលីដ៏មានអាយុថា* **ន ខោ ឧបាលិ ភិក្ខុនី សង្ឃំ ភិន្ទតិ ន សិក្ខមានា ន សាមណេរី ន សាមណេរោ ន ឧបាសកោ ន ឧបាសិកា សង្ឃំ ភិន្ទតិ ភិក្ខុ ខោ ឧបាលិ បកត្តត្តោ សមានសំវាសោ សមានសីមំ ឋិតោ សង្ឃំ ភិន្ទតិ** *អធិប្បាយថា ម្នាលឧបាលី សង្ឃភេទនេះ ភិក្ខុនីមិនអាចធ្វើបាន សិក្ខមានា សាមណេរ សាមណេរី ឧបាសក ឧបាសិកាក៏មិនអាច*

ធ្វើសង្ឃភេទបាន អាស្រ័យហេតុ ដែលមានព្រះពុទ្ធដីកាត្រាស់ដូច្នេះ ទើបសង្ឃភេទនេះ ជាអសាធារណៈ មិនទូទៅដល់អ្នកដទៃក្រៅអំពីភិក្ខុទេ ។

**ឯតេ្ថក ចតុក្កាទីនំ វិភាគោ វិនយដ្ឋកថាយំ វុត្តោ** អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ប្រការដែលចែកចេញនូវឯឡកចតុក្កៈក្តី សង្គាមចតុក្កៈក្តី ចោរចតុក្កៈក្តី អដ្ឋកថាចារ្យពោលទុកក្នុង **គម្ពីរសមន្តប្បាសាទិកា** អដ្ឋកថាព្រះវិន័យ **សេសំ វចនំ** សេចក្តីដ៏សេស បណ្តាសេចក្តីដែលពោលទុកក្នុងអនន្តរិយកម្មនិទ្ទេសនេះ ព្រះអដ្ឋកថាចារ្យសម្តែងទុកក្នុងអដ្ឋកថា ក្នុង **គម្ពីរមជ្ឈិមនិកាយ** មិនតែប៉ុណ្ណោះទេ សម្តែងទុកក្នុង **អដ្ឋកថាអង្គុត្តរនិកាយ** និង **អដ្ឋកថាគម្ពីរវិភង្គ** មានដល់ ៣ កន្លែង ។ សម្តែងអនន្តរិយកម្មតាមលំដាប់នៃបទមាតិកាដែលតម្កល់ទុកខាង ដើមនៃគម្ពីរចប់ត្រឹមតែប៉ុណ្ណោះ ។

អនន្តរិយកម្មកថា ចប់

# មិច្ឆាទិដ្ឋិវិភាវនកថា

*ជាបន្តទៅនេះ នឹងសម្តែងនូវលទ្ធិរបស់មិច្ឆាទិដ្ឋិតាមលំដាប់នៃបទមាតិកាដែលផ្តើមថា មិច្ឆាទិដ្ឋិនោះមានទោសធ្ងន់ជាងអនន្តរិយកម្ម ព្រះបាលីដែលសម្តែងទោសមិច្ឆាទិដ្ឋិនោះ ព្រះទសពលត្រាស់ដល់ភិក្ខុទាំងឡាយថា* **នាហំ ភិក្ខវេ អញ្ញំ ឯកំ ធម្មំ បិ សមនុបស្សាមិ យំ ឯវំ មហាសាវជ្ជតរំ យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិបរមានិ ភិក្ខវេ សាវជ្ជានីតិ** *ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃសូម្បីតែធម៌ ១ ដែលមានទោសធំយ៉ាងនេះ ដូចមិច្ឆាទិដ្ឋិនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិ ជាទោសក្រៃលែង ។ អនន្តរិយកម្ម ៥ ប្រការនោះ ជាគរុកម្ម មានទោសច្រើនផង មានទោសធ្ងន់ផង ក៏នៅមានកំណត់ថា កន្លងទៅបានប៉ុណ្ណេះៗ នឹងផុតទុក្ខ នឹងអស់កម្ម ឯមិច្ឆាទិដ្ឋិនេះ មិនមានកំណត់ទីបំផុតនៃទុក្ខ* **សង្ឃភេទកម្មម្បិ និរយេ កប្បដ្ឋិតិកាមេវ** *សង្ឃភេទកម្មនោះ សម្តែងថា ទោសធ្ងន់ជាងអនន្តរិយកម្មទាំង ៤ ប្រការ ក៏មានកំណត់ធ្លាក់នរកត្រឹមតែកប្បវិនាសៗ ក្នុងកាលណា អស់បាប អស់ទោសនៃសង្ឃភេទ*

ក្នុងកាលនោះ ឯមិច្ឆាទិដ្ឋិនេះមិនមានកំណត់ឡើយ បុគ្គលដែលជាមិច្ឆាទិដ្ឋិនោះ មិនអាចទៅកើតជាមនុស្ស ឬសុគតិសួគ៌បានទេ មានតែវិលកើត វិលស្លាប់ សោយទុក្ខយ៉ាងច្រើនក្នុងអបាយទាំង ៤ មិនមានកំណត់ទីបំផុតនៃទុក្ខ ជាការកាត់ផ្តាច់នូវសុគតិភព មិនអាចទៅកាន់សុគតិភពបានឡើយ នឹងពោលថ្វីដល់មគ្គ ផល និងព្រះនិព្វាន ។ បើមិនលះបង់នូវទិដ្ឋិដរាបណា បុគ្គលនោះប្រៀបដូចសសរគោល ឬដង្គត់ក្នុងសង្សារវដ្ត មិនមានថ្ងៃនឹងផុតទុក្ខឡើយ **យេ តស្ស សោតព្វំ មញ្ញន្តិ តេ វិប្បដិចាទេន្តិ** បុគ្គលដែលជឿពាក្យបុគ្គលដែលប្រកបដោយមិច្ឆាទិដ្ឋិនោះ បុគ្គលដែលជាទិមិច្ឆាទិដ្ឋិនោះ នឹងនាំឲ្យអ្នកបដិបត្តិតាមលទ្ធិមិច្ឆាទិដ្ឋិនោះ វិនាស ដល់នូវសេចក្តីលំបាក មិនអាចរួចខ្លួនបាន ឆ្ងាយអំពីស្ថានសួគ៌ ឆ្ងាយអំពីមគ្គផលផងដែរ ។ **កប្បវិនាសេ មហាជនេ ព្រហ្មលោកេ និព្វត្តន្តេបិ** កាលកប្បជិតវិនាស បណ្តាមហាជនទាំងឡាយដែលបដិបត្តិប្រពៃ បដិបត្តិក្នុងកងការកុសលនោះ គេនាំគ្នាទៅកើតក្នុងស្ថានសួគ៌ គេបបួលគ្នាចម្រើនឈាន យកវាយោកសិណជាអារម្មណ៍ គេទៅកើតក្នុងព្រហ្មលោកអស់ហើយ ពួកដែលជាមិច្ឆាទិដ្ឋិនោះ មិនអាចនឹងទៅកាន់ស្ថានសួគ៌បាន លុះផែនដីវិនាស

សូន្យទៅដោយភ្លើងប្រល័យកប្ប ទឹកប្រល័យកប្ប ខ្យល់ប្រល័យកប្ប ពួកមិច្ឆាទិដ្ឋិក៏ទៅកើតក្នុងចក្រវាលដទៃ ទៅឆេះនៅក្នុងនរក ដែលមាននៅក្នុងចក្រវាលដទៃ បិដ្ឋិចក្កវាឡេ ឈាយមានេបិ កាលភ្លើងប្រល័យកប្បឆេះចក្រវាលដទៃ មិច្ឆាទិដ្ឋិក៏ទៅនៅទីកន្លែងមួយនាអាកាស អណ្តែតនៅក្នុងអាកាស ភ្លើងឆេះដូចនៅក្នុងនរក មិច្ឆាទិដ្ឋិនេះមានទោសធ្ងន់ក្រៃលែង ។ មិច្ឆាទិដ្ឋិនោះកើតអាស្រ័យដោយអយោនិសោមនិការ កិរិយាមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ចិត្តនេះឯង បានឈ្មោះថាអយោនិសោមនសិការ ។ អយោនិសោមនសិការនោះ នៅក្នុងដីកាវិសុទ្ធិមគ្គបានវែសេចក្តីថា កំណត់ អធិប្បាយថា កិរិយាដែលគ្មានបញ្ញា ប្រាសចាកការពិនិត្យពិចារណាត្រិះរិះរឿងរ៉ាវដែលខុសមកកំណត់ទុកក្នុងចិត្តនេះឯង បានឈ្មោះថា អយោនិសោមនសិការជាហេតុប្បច្ច័យដែលនាំឲ្យកើតមិច្ឆាទិដ្ឋិ ។ អធិប្បាយដូច្នេះ សមគួរដល់ព្រះបាលីនៃព្រះពុទ្ធដីកា ត្រាស់ប្រោសប្រទានព្រះធម៌ទេសនាដល់ភិក្ខុទាំងឡាយថា ឆាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យេន អនុប្បន្នា វា មិច្ឆាទិដ្ឋិ ឧប្បជ្ជតិ ឧប្បន្នា វា មិច្ឆាទិដ្ឋិ បវឌ្ឍតិ យថយិទំ ភិក្ខវេ អយោនិសោមនសិការោ ។ ម្នាល

ភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែ ១ ដែលជាហេតុនាំឲ្យមិច្ឆាទិដ្ឋិ ដែលមិនទាន់កើត ឲ្យកើតឡើង ឬ មិច្ឆាទិដ្ឋិដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនឡើង ដូចគំនិត ដែលត្រិះរិះមិនត្រូវផ្លូវនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិដែល មិនទាន់កើតកកើតឡើង មិច្ឆាទិដ្ឋិដែលកើតឡើងហើយ ក៏រមែងរឹងរឹត តែចម្រើនឡើង ដល់បុគ្គលមានគំនិតត្រិះរិះមិនត្រូវផ្លូវ ។ ព្រះពុទ្ធដីកា ត្រាស់នូវសេចក្តីនេះ មានក្នុង **ព្រះអដ្ឋកថាអង្គុត្តរនិកាយ ឯកនិបាត** អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា អយោនិសោមនសិការ នេះមានកម្លាំងខ្លាំង ក្លា ។ **សត្ថុធរមានកាលេ** កាលព្រះទសពលមានព្រះជន្មនៅឡើយ ព្រះរូបឆោម ព្រះរស្មី ព្រះពុទ្ធសិរីប្រាកដប្រសើរគ្របនូវព្រះរូបឆោម និងរស្មីរបស់ព្រះឥន្ទ្រ ព្រះព្រហ្ម ទាំងពួកលោកធាតុ មិនមានអ្នក ប្រៀបបាន អានុភាពក៏ច្រើន មិនមានអ្នកប្រៀប មិនមានអ្នកស្មើ ព្រះរូបក៏ជាអចិន្តេយ្យ អានុភាពក៏ជាអចិន្តេយ្យ ជាអស្ចារ្យក្នុងលោក ទាំង ៣ សូម្បីត្រឹមតែប៉ុណ្ណោះ គ្រូទាំង ៦ ក៏ឃើញព្រះអង្គ ឃើញ អានុភាពរបស់ព្រះអង្គ ក៏នៅតែមិនជ្រះថ្លា ម្នាក់ៗ តាំងខ្លួនជាព្រះ ទាំងនេះព្រោះហេតុអ្វី ? ព្រោះហេតុអយោនិសោមនសិការនោះឯង

អយោនិសោមនសិការកើតក្នុងចិត្តៗ នោះប្រែប្រួលយល់រឿងរ៉ាវដែលខុស ថាត្រូវ ថាល្អ ថាមានសារៈ ធម៌ដែលមានខ្លឹមសារ ត្រឡប់ថាគ្មានខ្លឹមសារទៅវិញ ព្រោះអយោនិសោមនសិការនោះឯង នាំគ្នាធ្លាក់នរក នាំគ្នាវិនាស គ្មានអ្នករួចខ្លួនសូម្បីម្នាក់ឡើយ ក៏ព្រោះអយោ-និសោមនសិការនោះឯង ។ អយោនិសោមនសិការដែលមានលក្ខណៈត្រិះរិះនូវរឿងរ៉ាវដែលខុស មកកំណត់ទុកក្នុងចិត្ត ប្រាសចាកបញ្ញានោះឯងជាប្រធាន ជាមូលឲ្យកាន់យកមិច្ឆាទិដ្ឋិ មិនឲ្យជ្រះថ្លាក្នុងព្រះពុទ្ធគុណឡើយ ។

គ្រូទាំង ៦ នាក់នោះ គឺឈ្មោះបូរណកស្សបៈ ១ ឈ្មោះមក្ខលិគោសាល ១ ឈ្មោះអជិតកេសកម្ពល ១ ឈ្មោះសញ្ជយ-វេលដ្ឋបុត្រ ១ ឈ្មោះបកុធកច្ចាយនៈ ១ ឈ្មោះនិគណ្ឋនាដបុត្រ ១ ត្រូវជា ៦ នាក់ដូច្នេះ ។

ហេតុដូចម្តេច ទើបគ្រូទី ១ នោះឈ្មោះថា **បូរណកស្សបៈ** អធិប្បាយថា **បូរណៈ** ជាឈ្មោះកំណើត គ្រូនោះប្រាកដឈ្មោះថា **បូរណៈ** , **កស្សបៈ** ជាឈ្មោះនៃគោត្រ ប្រការដែលហៅថា បូរណ-កស្សបៈនោះ គឺលើកយកឈ្មោះខ្លួន និងឈ្មោះគោត្របញ្ចូលគ្នា ។

**សោ កិរ អញ្ញតរស្ស កុលស្ស ឯកូនទាសសតំ បូរិយ-មានោ ជាតោ** បានឮមកថា គ្រូម្នាក់នេះកើតមកជាទាសៈ គឺជាអ្នកបម្រើនៃត្រកូលមួយ ត្រកូលនោះមានខ្ញុំបម្រើ ៩៩ នាក់ហើយ កាលម្នាក់នេះកើតមកក៏គ្រប់ ១០០ ទើបម្ចាស់បំណុល ឲ្យគេដាក់ឈ្មោះថា បូរណៈ ប្រែថា **ពេញ** ។ ម្ចាស់បំណុលប្រាប់គ្នាគេដូច្នេះថា បូរណៈនេះ វាជាមង្គលទាសៈរបស់ខ្ញុំ ការងាររបស់ខ្ញុំនេះ វាពេញចិត្តធ្វើក៏ដោយ មិនពេញចិត្តធ្វើក៏ដោយ កុំពោលស្តីវាឡើយ ល្អអាក្រក់ ឬធ្ងន់ស្រាល ចូរកុំប្រកាន់វាឡើយ បណ្តោយទៅតាមអធ្យាស្រ័យវាចុះ ម្ចាស់បំណុលប្រាប់ដល់គ្នាគេដូច្នេះ បូរណៈក៏ទៅណាមកណាតាមអធ្យាស្រ័យ មិនមានអ្នកបង្គាប់បញ្ជា មិនមានអ្នកណាមួយពោលស្តី បូរណៈក៏ត្រិះរិះក្នុងចិត្តថា រស់នៅក្នុងទីនេះមិនមានប្រយោជន៍ទេ គិតដូច្នេះហើយ បូរណៈក៏រត់ទៅកាន់ទីដទៃ **ចោរា វត្ថានិ អច្ឆិន្ទឹសុ** ចោរទាំងឡាយវាយដោះយកសំពត់ស្លៀកដណ្តប់ បូរណៈក៏ទៅតែខ្លួនទទេ វិស័យល្ងង់ខ្លៅគ្មានបញ្ញា សូម្បីតែកាច់យកស្លឹកឈើមកបិទបាំងក៏មិនធ្វើ ដើរអាក្រាតកាយដូចប្រេត ដោយការស្រេកឃ្លានខ្លាំង គ្មានអៀនខ្មាស ដើរអាក្រាតកាយចូលទៅក្នុងស្រុក

ដើម្បីជាប្រយោជន៍សូមនូវអាហារចិញ្ចឹមជីវិត ឯមនុស្សក្នុងស្រុកក៏ប្រាសចាកបញ្ញា ឃើញមនុស្សមិនមានសំពត់ស្លៀកដណ្តប់ យល់ថាជាព្រះអរហន្ត ប្រាប់គ្នាថា លោកនេះជាសមណៈ បដិបត្តិប្រាថ្នាតិចសូម្បីតែសំពត់ស្លៀកដណ្តប់ក៏មិនស្លៀក លោកនេះជាព្រះអរហន្តពិតហើយ យើងធ្វើបុណ្យជាមួយលោកចុះ យើងនឹងបានបុណ្យច្រើននឹងរកសមណៈដទៃឲ្យស្មើនឹងសមណៈរូបនេះមិនមានឡើយ អ្នកស្រុកប្រាសចាកបញ្ញាប្រាប់គ្នាដូច្នេះហើយ **បុរភត្តាទីនិ គហេត្វា** ក៏បបួលគ្នាកាន់យកបបរ បាយ ទឹក នំ ចំណីជាដើមមកឲ្យបូរណៈៗបានឮគេសរសើរថាជាព្រះអរហន្តៗ ក៏សម្គាល់ខ្លួនថា ជាព្រះអរហន្តពិតតអំពីនោះ ក៏ប្រកាន់មាំយកជាអកិរិយទិដ្ឋិថា ធ្វើបុណ្យមិនបានបុណ្យធ្វើបាបមិនបានបាប សូម្បីធ្វើបាបប៉ុនណាៗ ក៏មិនមានបាបទេ ឬក៏ថាធ្វើបុណ្យប៉ុនណាៗ ក៏គ្មានបុណ្យដែរ ដូចជាអាត្មាអញនេះ អាត្មាអញបានធ្វើបុណ្យពីពេលណា នៅស្ងៀមៗ នៅទទេៗ ដល់ពេលក៏បានជាព្រះអរហន្ត នៅស្ងៀមៗ ក៏បានជាព្រះអរហន្តៗ ព្រោះកិរិយាដែលអាត្មាអញមិនស្លៀកដណ្តប់សំពត់ ជាបព្វជិតយ៉ាងល្អ មានមនុស្សសំពះគោរពរាប់អាន លាភសក្ការៈកើតយ៉ាងច្រើន ព្រោះហេតុដែល

មិនស្មៀកសំពត់ តអំពីនេះទៅ អាត្មាអញមិនស្មៀកសំពត់ មិនដណ្ដប់សំពត់ជាដាច់ខាត បូរណៈក៏ប្រកាន់មាំដូច្នេះ តអំពីនេះទៅ សូម្បីមានមនុស្សយកសំពត់ស្មៀក សំពត់ដណ្ដប់មកឲ្យ ក៏មិនស្មៀក មិនដណ្ដប់ កាន់ភេទអាក្រាតកាយនោះឯង ជាបព្វជ្ជារបស់ខ្លួន ពួកអ្នកស្រុកជាមនុស្សល្ងង់ខ្លៅ ប្រាសចាកបញ្ញានាំគ្នាគោរពរាប់អាន នាំគ្នាមកបួសកាន់ភេទអាក្រាតកាយ ក្នុងសម្នាក់នៃបូរណកស្សបៈ រហូតទៅដល់ ៥០០ នាក់ គោរពនាយបូរណកស្សបៈនោះថាជាគ្រូអាចារ្យ ហៅថា **គ្រូបូរណកស្សបៈ** ចាប់តាំងពីពេលនោះមក ។

មានទាសៈម្នាក់ទៀត មុនវាកើតអំពីផ្ទៃមាតា វាកើតនៅក្នុងក្រោលគោ កាលធំហើយវាជាអ្នកបម្រើគេ ថ្ងៃមួយ ម្ចាស់បំណុលប្រើឲ្យទូលក្អមប្រេងដើរខាងមុខ ម្ចាស់បំណុលដើរតាមក្រោយ ផ្លូវនោះប្រកបដោយភក់ ម្ចាស់បំណុលនោះប្រាប់បញ្ជាក់ថា **មា ខលិ មា ខលិ** ដើរឲ្យល្អ កុំឲ្យដួល កុំឲ្យភ្លាំងភ្លាត់ប្រយ័ត្នរអិលដួល ។ ម្ចាស់បំណុលប្រាប់បញ្ជាក់មិនទាន់ផុតពីមាត់ផង អ្នកបម្រើនោះក៏ដួលផ្កាប់មុខចុះ ក្អមប្រេងនោះក៏ធ្លាក់ចុះពីស្មាបែកទាំងក្អមទៅទៀត ផ្ដើមស្ទុះក្រោកឡើង ដោយការភ័យខ្លាចម្ចាស់បំណុលវាយ ក៏រត់ទៅខាងមុខ

ម្ចាស់បំណុលក៏ស្រវាចាប់ជាប់នូវជាយសំពត់ ទាសៈនោះក៏ទាញធ្លាក់ក្បិន ស្រាតសំពត់ចេញដោយរហ័ស រត់ទៅតែខ្លួនទទេ រត់គេចឆ្ងាយពីម្ចាស់បំណុលហើយ រកសំពត់ដទៃទៀតស្លៀកមិនបាន សូម្បីក្រងស្លឹកឈើបិទបាំងកាយក៏មិនចេះធ្វើ ដោយការស្រេកឃ្លានខ្លាំង ក៏អស់ការអៀនខ្មាស ដើរអាក្រាតកាយចូលទៅក្នុងស្រុកមួយ ដើម្បីនឹងសុំទាន អ្នកស្រុកក៏សម្គាល់ថាជាព្រះអរហន្ត ក៏ឲ្យអាហារ បាយ ទឹក ដោយសេចក្តីជ្រះថ្លាចំពោះមក្ខលិ ។ មក្ខលិនោះក៏សម្គាល់ថា ខ្លួនជាព្រះអរហន្តដូចគ្នានឹងគ្រូបូរណកស្សបៈ ចាប់តាំងអំពីនោះមក ក៏កាន់យកភេទអាក្រាតនោះជាបព្វជ្ជា ដូចបូរណកស្សបៈល្ងង់ខ្លៅប្រាសចាកបញ្ញា បួសអាក្រាតមានកូនសិស្សដល់ ៥០០ នាក់ តាំងខ្លួនជាគ្រូអាចារ្យ ប្រាកដឈ្មោះថា គ្រូមក្ខលិគោសាលកាន់យកពាក្យដែលម្ចាស់បំណុលប្រាប់បញ្ជាក់ថា **មា ខលិ** និងកិរិយាដែលប្រសូតនៅក្នុងក្រោលគោនោះផ្សំចូលគ្នា ជាឈ្មោះ **មក្ខលិគោសាល** ដោយប្រការដូច្នេះ ។

ក្នុងមង្គលទីបនីវិសជ្ជនាថា មក្ខលិគោសាលនោះ ប្រកាន់យកអហេតុកទិដ្ឋិ គឺបុគ្គលទាំងឡាយនឹងចង់មាន ចង់ល្អ ចង់អាក្រក់ និងបាននូវសេចក្តីសុខ មាននូវសេចក្តីទុក្ខ បានដោយធម្មតារបស់ខ្លួន

រកហេតុ រកបច្ច័យមិនមាន កុសល និងអកុសល នឹងបានជាហេតុ ជាបច្ច័យឲ្យកើតសុខ និងទុក្ខមិនមាន នឹងមានឯងៗ ទោះក្រក៏ក្រឯង ទោះសុខក៏សុខឯង ទោះទុក្ខក៏ទុក្ខឯង មក្ខលិគោសាលប្រកាន់យ៉ាងនេះ ទើបបានឈ្មោះថា **អហេតុកទិដ្ឋិ** ។

គ្រូទី ៣ ដែលប្រាកដឈ្មោះអជិតកេសកម្ពលនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា អនុត្ថិរិយនេះ មានឈ្មោះប្រាកដអជិតកេសកម្ពល អំពីកំណើត លុះចំណេរតមក ខ្លួនជាអាចារ្យមានកូនសិស្សច្រើននាក់ ហើយទើបប្រាកដឈ្មោះថា **អជិតកេសកម្ពល** ព្រោះហេតុដែលគេស្លៀកដណ្តប់សំពត់ដែលធ្វើដោយសក់មនុស្ស លំនាំដែលពោលថា សំពត់ធ្វើដោយសក់មនុស្សនេះ មានសម្ផស្សគ្រោតគ្រាត ប្រាថ្នានឹងឲ្យមនុស្សទាំងពួងយល់ថា ខ្លួននោះជាអ្នកប្រាថ្នាតិច ទើបស៊ូអត់ទ្រាំស្លៀកសំពត់ ដែលធ្វើដោយសក់មនុស្ស អជិតកេសកម្ពលនេះប្រកាន់ **នត្ថិកទិដ្ឋិ** គឺប្រកាន់ថា ផលទានមិនមាន ផលបូជាតូច-ធំ ក៏មិនមាន ស្ថានសួគ៌ក៏មិនមាន នរកក៏មិនមាន លោកនេះ និងលោកខាងមុខ ក៏មិនមាន ផលដែលបដិបត្តិចំពោះមាតាបិតាក៏មិនមាន បុគ្គលកើតមកមានត្រឹមតែជាតិនេះ លុះស្លាប់ហើយ ក៏អស់សូន្យប៉ុណ្ណោះឯង កាល

ស្លាប់ហើយ មិនកើតទៀត ធ្វើល្អប៉ុនណាៗ ធ្វើអាក្រក់ប៉ុនណាៗ ក៏មានកំណត់ត្រឹមស្លាប់ ទីបំផុតត្រឹមស្លាប់ អជិតកេសកម្ពល ប្រកាន់នត្ថិកទិដ្ឋិ ដោយប្រការដូច្នេះ ។

គ្រូទី ៤ ដែលឈ្មោះថា **សញ្ជយវេលដ្ឋបុត្រនោះ** ជាបុត្ររបស់ **វេលដ្ឋៈ** មាតាបិតារបស់គេនោះត្បាញកន្ទេលលក់ចិញ្ចឹមជីវិត ឈ្មោះកំណើតរបស់គេថា **សញ្ជ័យ** កាលបួសក្នុងលទ្ធិនៃអន្យតិរ្ថិយ មានកូនសិស្សច្រើន ទើបតាំងខ្លួនជាអាចារ្យ សម្តែងមិច្ឆាទិដ្ឋិ ប្រាកដចេញមុខ មានពួកមនុស្សល្ងង់ខ្លៅគ្មានបញ្ញា រាប់អានច្រើន ហើយញាតិមិត្ត សិស្សប្រាថ្នានឹងសម្តែងឈ្មោះឲ្យប្រាកដ ឲ្យប្លែក ចេញចាកសាមញ្ញនាម បណ្តាមនុស្សដែលឈ្មោះថា សញ្ជ័យៗ នោះ មិនឲ្យមានការភាន់ច្រឡំ ទើបលើកយកឈ្មោះរបស់ត្រកូល ដែលជាជាងផែងនោះមកប្រកបបចូលផង ហៅឈ្មោះគ្រូនោះថា សញ្ជយ-វេលដ្ឋបុត្រ ដោយប្រការដូច្នេះ ។

គ្រូទី ៥ **បកុធកច្ចាយនៈ** គោត្ររបស់គេកច្ចាយនៈ ឈ្មោះកំណើត គឺបកុធៈ ញាតិមិត្តសិស្សប្រាថ្នានឹងសម្តែងឈ្មោះឲ្យប្រាកដប្លែកចេញអំពីឈ្មោះសាមញ្ញនាម ទើបលើកយកឈ្មោះរបស់គោត្រ

និងឈ្មោះកំណើតនោះផ្សំចូលគ្នា ហៅឈ្មោះថា **បកុធកច្ចាយនៈ** ។ បកុធកច្ចាយនៈនោះ កាន់លទ្ធិគ្មានសិរី ហាមទឹកត្រជាក់ ប្រកាន់ថា ទឹកត្រជាក់នោះបាប ទឹកដែលគេដាំហើយនោះឈ្មោះថា ទឹកស្លាប់ បរិភោគប្រើប្រាស់តែទឹកក្តៅ សូម្បីបន្ទោបង់ឧច្ចារៈហើយ មិនបាន ទឹកក្តៅក៏មិនលាងជម្រះដែរ លុះត្រាតែបានទឹកក្តៅឬទឹកដាំ ទើបលាងជម្រះ បកុធកច្ចាយនៈនេះ កាលឆ្លងទឹកស្ទឹងដោយទូក ឬក្បូនក្តី លុយទឹក តាមផ្លូវក្តី កាលបើឡើងដល់ច្រាំង ឬទីគោកហើយក៏ប្រាប់ថា សីល របស់អាត្មាអញដាច់ហើយ អាត្មាអញនឹងសមាទានសីល តសីលឲ្យល្អ ទើបទៅ **វាលុកា ថូបំ កត្វា** ពោលរួចហើយក៏ប្រមូលដីខ្សាច់ចូលជា គំនរ ក-ឲ្យខ្ពស់មានកំពូលឡើង សមាទានសីលត្រង់ទីគំនរដី ខ្សាច់នោះ ហើយទើបធ្វើដំណើរតទៅ ។

គ្រូទី ៦ ដែលឈ្មោះថា **និគណ្ឋនាដបុត្រនេះ** ត្រកូលរបស់ គេជាអ្នកលេងរបាំ សម្ញាញ់របស់គេពេញចិត្តថា និគណ្ឋៈ យើងមិន មានធុរៈ កង្វល់ដោយកិលេស ដីស្រែចម្ការសួនច្បារបន្លែ ផ្ទះ កូន ប្រពន្ធអញ ក៏មិនមាន អញប្រាសចាកកង្វល់ គឺកិលេស អាស្រ័យ ហេតុដែលគេពេញចិត្តថា និគណ្ឋៈ ទើបមនុស្សទាំងឡាយយកពាក្យ

និគណ្ឋៈផ្សំចូលនឹងឈ្មោះរបស់ត្រកូលដែលជាអ្នកលេងរបាំ ហៅថា **និគណ្ឋនាដបុត្រ** ដោយប្រការដូច្នេះ ។

ប្រការដែលពោលដោយឧប្បត្តិហេតុដំបូងរបស់គ្រូទាំង ៦ នេះ មានក្នុង **អដ្ឋកថាសាមញ្ញផលសូត្រ** ក្នុង **សីលក្ខន្ធវគ្គ** **គម្ពីរទីឃនិកាយ** ថា **តិត្ថិយា ហិ អត្តនោ ទិដ្ឋឹ បញ្ញាបេន្តិ** ការពិតអន្យតិរ្ថិយទាំងឡាយ កាន់លទ្ធិខាងក្រៅព្រះពុទ្ធសាសនា តែងតែសម្តែងនូវទិដ្ឋិផ្សេងៗ ឲ្យមនុស្សប្រតិបត្តិតាមលទ្ធិរបស់ខ្លួន សម្តែងទិដ្ឋិផ្សេងៗ មិនចូលគ្នា ពួកព្រាហ្មណ៍គោរពរាប់អានព្រហ្ម ប្រាប់គ្នាឲ្យដឹងថា ព្រហ្មនេះឯង ប្រសើរបរិសុទ្ធប្រាសចាកមន្ទិលទាំងពួង នរណាបានកើតក្នុងព្រហ្មលោកហើយ ក៏ផុតទុក្ខផុតភ័យ ឧបទ្រវន្តរាយទាំងឡាយ មានសេចក្តីសុខដោយពិត ។ ពួកតាបសនោះ គោរពអាកស្សរ-ព្រហ្ម ទើបពោលថា អាកស្សរព្រហ្មប្រសើរ នរណាបានកើតក្នុងជាន់អាកស្សរព្រហ្មហើយ ក៏បរិសុទ្ធផុតចាកទុក្ខសោករោគាភ័យ ប្រាសចាកចង្រៃឧបទ្រព មិនមានភ័យ ជាបរមសុខដោយពិត ។ ពួកបរិព្វាជកដែលស្លៀកប៉ឹង គោរពសុភកិណ្ហព្រហ្មថា ប្រសើរពិត នរណាបានទៅកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនព្រហ្មហើយ ក៏

បានឈ្មោះថា ដល់ព្រះនិព្វាន ប្រាសចាកនូវទុក្ខទាំងឡាយ ពិតណាស់ ព្រាហ្មណ៍ និងពួកតាបស ពួកបរិព្វាជក អាជីវកទាំងឡាយ ពួកនេះតែងតែកាន់លទ្ធិរបស់ខ្លួន ពួកនេះច្រើនប្រភេទ មានដល់ ៦២ គឺថា ទិដ្ឋិនោះ បែកចេញទៅអំពីសម្នាក់របស់មនុស្សពួកនេះឯង ទិដ្ឋិ ៦២ នោះ គឺសស្សតទិដ្ឋិ ៤ ឯកច្ចសស្សតទិដ្ឋិ ៤ អត្តានត្តិកាទិដ្ឋិ ៤ អមរាវិក្ខេបិកាទិដ្ឋិ ៤ អធិច្ចសមុប្បត្តិកាទិដ្ឋិ ២ សោឡសសញ្ញីវាទទិដ្ឋិ ១៦ អសញ្ញីវាទទិដ្ឋិ ៨ នេវសញ្ញីនាសញ្ញីវាទទិដ្ឋិ ៨ ឧច្ឆេទវាទទិដ្ឋិ ៧ ទិដ្ឋធម្មនិព្វានវាទទិដ្ឋិ ៥ បូកបូលគ្នា ទើបជាទិដ្ឋិ ៦២ **កេចិ តិត្ថិយា អហំ នុខោស្មីតិ អត្តនោ អត្ថិភាវំ កង្ខន្តិ** ពួកអន្យតិរ្ថិយខ្លះ ត្រិះរិះទៅតាមវិស័យរបស់ខ្លួន ក៏មានការសន្ទិះសង្ស័យថា ខ្លួនរបស់យើងនេះមានឬទេ ការពិត ពួកអន្យតិរ្ថិយនោះប្រកាន់ថា ខ្លួនមាននៅក្នុងរូប ពួកខ្លះប្រកាន់ថា ខ្លួនមានរូបខ្លះ ពួកខ្លះប្រកាន់ថាខ្លួនមិនមានរូបទេ ប្រកាន់ផ្សេងៗ យ៉ាងនេះ មានសេចក្ដីសង្ស័យថា ខ្លួនរបស់អញនេះមានឬទេ សង្ស័យដូច្នេះក៏មាន ទើបព្រះនន្ទាចារ្យនាំយកនិទានបុគ្គលដែលសង្ស័យថា ខ្លួនមាន ឬមិនមាន មកវិសជ្ជនា ។

**កិរ** បានឮមកថា មានទារកពីរនាក់ ម្នាក់ជាកូនម្តាយមីង ម្នាក់ទៀតជាកូនម្តាយធំ កូនម្តាយមីងនោះក្បាលត្រងោល កូនម្តាយធំនោះក្បាលមិនត្រងោលទេ ។ ទារកទាំងពីរនោះលេងធូលី លេងដីខ្សាច់ជាមួយគ្នា ទារកក្បាលត្រងោលនោះពោលថា អញជាកូនម្តាយមីងក្បាលត្រងោល ទារកដែលក្បាលមិនត្រងោលនោះ ពោលថាអញជាកូនម្តាយធំក្បាលមិនត្រងោល កាលបើទារកទាំងពីរនាក់នោះប្រកាន់មាំថា កូនម្តាយមីងក្បាលត្រងោល កូនម្តាយធំក្បាលមិនត្រងោលប្រកាន់មាំដូច្នេះ ថ្ងៃមួយ ទារកទាំងពីរនោះដេកលក់ ទារកដែលក្បាលមិនត្រងោលដេកលក់ស៊ប់ ដោយភាពងងុយខ្លាំង ពេលដែលខ្លួនដេកលក់ស៊ប់ថ្ងៃនោះ ញាតិឃើញថា សក់វែងគេក៏លួចកោរ ទារកនោះមិនដឹងថា គេកោរសក់របស់ខ្លួនទេ លុះភ្ញាក់ឡើងយកដៃអង្អែលក្បាលមិនប៉ះសក់ ក៏មានសេចក្តីសង្ស័យថា អញនេះមិនមែនជាកូនម្តាយធំទេដឹង កូនម្តាយធំក្បាលមិនត្រងោលទេ អញជាកូនម្តាយមីងទេដឹង ទារកនោះមាននូវសន្និះសង្ស័យដូច្នេះ យ៉ាងណាមិញអន្យតិរ្ថិយដែលសង្ស័យថា ខ្លួនរបស់អញមាន ឬមិនមាន ក៏មាននូវសេចក្តីឧបមេយ្យដូចទារកដែលសង្ស័យខ្លួននោះ មិនមែនខុសមិនមែន

ប្លែកគ្នាឡើយ ទំនងដូចគ្នា ។

មិនត្រឹមតែប៉ុណ្ណោះទេ ពួកអន្យតិរ្ថិយខ្លះ ក៏សង្ស័យធ្ងន់ទៅផ្នែកខាងមិនមានខ្លួន សង្ស័យធ្ងន់នៅខាងមិនមានខ្លួន យល់ថា មិនមានខ្លួនទេដឹង សង្ស័យខាងមិនមានខ្លួនដូច្នេះ ពួកមុននោះសង្ស័យខាងមានខ្លួន យល់ថា គួរនៅខាងមានខ្លួន ពួកក្រោយនេះ សង្ស័យខាងមិនមានខ្លួន យល់ថា គួរនៅខាងមិនមានខ្លួន ប្លែកគ្នាតែប៉ុណ្ណោះ **តត្រីធំ វត្ថុ** ទើបព្រះនន្ទាចារ្យនាំយករឿងនិទានមនុស្សចាប់ត្រី និងអ្នកចាំស្រែ ដេកនៅក្បែរព្រៃខ្មោចមកសម្តែងឲ្យជាឧទាហរណ៍ ក្នុងសេចក្តីដែលអន្យតិរ្ថិយសង្ស័យថា គួរនៅខាងមិនមានខ្លួន ។

**ឯកោ កិរ មច្ឆេ គណ្ហាន្តោ ឧទកេ ចិរដ្ឋានេន** បានឮមកថា មានមនុស្សល្ងង់ខ្លៅម្នាក់ចុះចាប់ត្រីក្នុងទឹក កាលឈរនៅក្នុងទឹកយូរ ស្ពឹកជើង ដៃស្រវាចាប់ត្រូវជើងរបស់ខ្លួន ក៏មិនដឹងថាជាជើងរបស់ខ្លួនទេ យល់ថាជាត្រីហែលចូលអែបនៅត្រង់ជើងនោះ ក៏វាយជើងរបស់ខ្លួនឯង ដោយយល់ថា វាយត្រី ក៏សោយទុក្ខវេទនាដ៏ក្រៃលែង ព្រោះហេតុដែលល្ងង់ខ្លៅគ្មានសតិ ជើងរបស់ខ្លួនសម្គាល់ថា មិនមែនជើង សម្គាល់ថាជាត្រី ក៏វាយពេញទំហឹង អាការដែលបុរសល្ងង់ខ្លៅ

យកដៃស្រវាចាប់ជើងរបស់ខ្លួន កំណត់មាំថាត្រី យ៉ាងណា អនុត្តិរិយ សង្ស័យ ឃើញគួរនៅខាងមិនមានខ្លួននោះ ក៏ព្រោះវង្វេង ព្រោះល្ងង់ខ្លៅ គ្មានសតិ មានសេចក្តីឧបមេយ្យដូច្នេះ ។

មានបុរសម្នាក់ ធ្វើស្រែនៅក្បែរព្រៃខ្មោច ដេកចាំស្រែនៅក្បែរព្រៃខ្លាចខ្មោច មិនអាចសណ្តូកជើងសណ្តូកដៃចេញបាន ក៏ដេកផ្ងារ បញ្ឈរជើងទាំងពីរ ចិត្តព្រួយខ្លាចខ្មោច កាលភ្ញាក់ឡើង បើកភ្នែក ឃើញក្បាលជង្គង់របស់ខ្លួន យល់ថា ខ្មោចពីរនាក់មាននៅក្បែរខ្លួន ក៏ស្ទុតចិត្ត ស្រវាចាប់យកបានដំបង វាយជង្គង់ខ្លួនឯង ដោយយល់ថា វាយខ្មោច ដល់នូវការឈឺចាប់ ទើបដឹងថា វាយជង្គង់ បុរសល្ងង់ខ្លៅវាយជង្គង់ខ្លួនឯង ដោយយល់ថា វាយខ្មោច យ៉ាងណា អនុត្តិរិយដែលសង្ស័យឃើញធ្ងន់ទៅខាងមិនមានខ្លួន នោះ ព្រោះវង្វេង ព្រោះគ្មានបញ្ញា ឧបមេយ្យដូចបុរសអ្នកធ្វើស្រែ វង្វេងវាយជង្គង់ទាំងពីររបស់ខ្លួន ដោយសម្គាល់ថាខ្មោចពីរនាក់ ។

**តក្កី ចតុព្វិធា ហោន្តិ** អនុត្តិរិយមានការត្រិះរិះប្រកាន់ទិដ្ឋិនោះ ផ្សេងចេញជា ៤ ពួក គឺអនុស្សតិកតក្កីមួយពួក ជាតិស្សរ-តក្កីមួយពួក លាភីតក្កីមួយពួក សុទ្ធតក្កីមួយពួក រួមជា ៤ ពួក

អធិប្បាយមាននៅក្នុងទិដ្ឋិ ៦២ ហើយ ។

**អភិញ្ញាលាភីតាបសេ សន្ធាយ មាហ ឥតោ ពហិទ្ធា សមណោ នត្ថិ** អធិប្បាយថា ចំពោះសមណៈមានតែក្នុងព្រះពុទ្ធ-សាសនា ខាងក្រៅព្រះសាសនាមិនមានសមណៈឡើយ សូម្បីតាបសដែលបាននូវអភិញ្ញាសមាបត្តិ មាននៅខាងក្រៅព្រះពុទ្ធសាសនាក្តី តាបសដែលបានអភិញ្ញាសមាបត្តិនោះ មិនបានឈ្មោះថាជាសមណៈឡើយ ព្រោះហេតុនៅខាងក្រៅព្រះពុទ្ធសាសនានោះ ប្រាសចាកសមាបត្តិ ដែលជាទីតាំងនៃវិបស្សនាញាណស្រួចស្រាល់ ដែលជាវុដ្ឋានគាមិនី សម្រាប់ទៅអរិយមគ្គ និងពាក់កណ្តាលអរិយផល មគ្គនោះអ្នកប្រាជ្ញគប្បីសន្និដ្ឋានថា វុដ្ឋានគាមិនីវិបស្សនាដែលស្រួចស្រាល់ ជាទីទទួលនូវអរិយមគ្គ មានចំពោះតែក្នុងព្រះពុទ្ធសាសនា សមាបត្តិដែលជាទីតាំងនៃវុដ្ឋានគាមិនីវិបស្សនានោះ ក៏មាននៅក្នុងព្រះពុទ្ធសាសនាដូចគ្នា ប្រការដែលហៅថា សមណៈនោះ សំដៅយកបុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនា និងបុគ្គលដែលបានអរិយ-មគ្គ អរិយផល បុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនា នៅមិនទាន់បានអរិយមគ្គ អរិយផលនោះ មិនហៅថាសមណៈទេ ។ អាស្រ័យ

ហេតុដូច្នេះ ខាងក្រៅព្រះពុទ្ធសាសនានោះ សូម្បីមានកម្មវាទីតាបស បានសម្រេចអភិញ្ញាសមាបត្តិ ហោះទៅលើអាកាសបាន សម្តែងឫទ្ធិបាន កាលបើមិនបានសមាបត្តិ ដែលជាទីតាំងនៃវុដ្ឋានគាមិនីវិបស្សនា មិនបានវុដ្ឋានគាមិនីវិបស្សនាហើយ មិនហៅថាជាសមណៈទេ ។

ប្រការដែលហៅថាសមណៈនោះ សំដៅយកសមណៈ ១២ ពួក គឺបុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនា ដែលនៅបន្ទាប់សោតាបត្តិមគ្គនោះ ១ ពួក បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គនោះ ១ ពួក បុគ្គលដែលតាំងនៅក្នុងសោតាបត្តិផលនោះ ១ ពួក បុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនាដែលជាបាទនៃសកទាគាមិមគ្គនោះ ១ ពួក បុគ្គលដែលតាំងនៅក្នុងសកទាគាមិមគ្គនោះ ១ ពួក បុគ្គលដែលតាំងនៅក្នុងសកទាគាមិផលនោះ ១ ពួក បុគ្គលដែលបានវុដ្ឋាន-គាមិនីវិបស្សនាជាបាទនៃអនាគាមិនមគ្គនោះ ១ ពួក បុគ្គលដែលតាំងនៅក្នុងព្រះអនាគាមិមគ្គនោះ ១ ពួក បុគ្គលដែលតាំងនៅក្នុងអនាគាមិផលនោះ ១ ពួក បុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនាដែលជាបាទនៃអរហត្តមគ្គនោះ ១ ពួក បុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ ១ ពួក បុគ្គលដែលតាំងនៅក្នុងអរហត្តផលនោះ ១ ពួក ត្រូវជាសមណៈ

១២ ពួក ដោយពិស្តារ ។ កាលបើពោលដោយសង្ខេបនោះ បុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនាជាបាទនៃសោតាបត្តិមគ្គក្តី បុគ្គលបានសោតាបត្តិមគ្គក្តី និងបុគ្គលដែលបានសោតាបត្តិផលក្តី ៣ ពួកនេះរួមគ្នា ហៅសមណៈទី ១ ។ បុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនាដែលបាទនៃសកទាគាមិមគ្គក្តី បុគ្គលដែលបានសកទាគាមិមគ្គក្តី បុគ្គលដែលបានសកទាគាមិផលក្តី ៣ ពួកនេះ រួមចូលគ្នា ហៅថាសមណៈទី ២ ។ បុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនា ដែលជាបាទនៃអនាគាមិមគ្គក្តី បុគ្គលដែលបានអនាគាមិមគ្គក្តី បុគ្គលដែលបានអនាគាមិផលក្តី ៣ ពួកនេះ រួមគ្នាហៅថា សមណៈទី ៣ ។ បុគ្គលដែលបានវុដ្ឋានគាមិនីវិបស្សនាជាបាទនៃអរហត្តមគ្គក្តី បុគ្គលដែលបានអរហត្តមគ្គ បុគ្គលដែលបានអរហត្តផលក្តី ៣ ពួកនេះ រួមចូលគ្នាហៅថា សមណៈទី ៤ ។ សរុបសមណៈ ១២ ពួកនោះ សង្ខេបជា ៤ ពួក ដោយប្រការដូច្នេះ ។

សមណៈដែលចាត់ដោយសង្ខេប ៤ ពួក ដោយពិស្តារ ១២ ពួក ដូចសម្តែងមកនេះ មានចំពោះតែក្នុងព្រះពុទ្ធសាសនា មានព្រះពុទ្ធសាសនាជាខេត្ត ឬជាដែន លទ្ធិដទៃៗ ខាងក្រៅព្រះពុទ្ធសាសនា

ដែលបានជាខេត្ត ឬជាដែនកើតនៃសមណៈទាំងនេះមិនមាន អាស្រ័យហេតុដូច្នេះ ទើបព្រះមុនីមានព្រះពុទ្ធដីកាត្រាស់ដល់សុភទ្ទបរិព្វាជកថា **ឯកូនត្តឹសោ វយសា សុភទ្ទ យំ បព្វជ្ជំ កិំ កុសលានុ ឯសិ វស្សានិ បញ្ញាសសមាធិកានិ យតោហំ បព្វជិតោ សុភទ្ទ ញាយស្ស បទេសវត្តិ ឥតោ ពហិទ្ធា សមណោបិ នត្ថិ ទុតិយោបិ សមណោ នត្ថិ តតិយោបិ សមណោ នត្ថិ ចតុត្ថោបិ សមណោ នត្ថិ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហីតិ** ម្នាលសុភទ្ទ តថាគតមានវស្សាបាន ២៩ វស្សាហើយ ទើបតថាគតចេញបព្វជ្ជា នៅមិនទាន់បានសព្វញ្ញុតញ្ញាណទេ ប៉ុន្តែតថាគតធ្វើនូវមហាបធានវីរិយភាពអស់ ៦ វស្សា ទើបបានត្រាស់ដឹងសព្វញ្ញុតញ្ញាណ ចាប់តាំងពីបានត្រាស់ដឹងហើយ ប្រោសដល់វេនេយ្យសត្វដរាបមកដល់ឥឡូវនេះ គណនាបាន ៤៥ វស្សា បូកតាំងអំពីដើមមកគម្រប់ព្រះជន្ម ៨០ វស្សាដោយបរិបូណ៌ ។ ម្នាលសុភទ្ទ សមណៈមានតែក្នុងសាសនារបស់តថាគត **ញាយស្ស បទេសវត្តិ** បុគ្គលដែលមានវិបស្សនាដ៏ហ្មត់ចត់ ដែលជាបាទនៃមគ្គទី ១ គឺសោតាបត្តិមគ្គក្តី សោតាបត្តិផលក្តី បុគ្គលនោះចាត់ជាសមណៈទី ១ បុគ្គលដែលមានវិបស្សនា

ដ៏ហ្មត់ចត់ ដែលបាទនៃមគ្គទី ២ ក្តី សកទាគាមិមគ្គក្តី សកទាគាមិផលក្តី បុគ្គលនោះចាត់ជាសមណៈទី ២ បុគ្គលដែលបានវិបស្សនាដ៏ហ្មត់ចត់ ជាបាទនៃមគ្គទី ៣ ក្តី អនាគាមិមគ្គក្តី អនាគាមិផលក្តី បុគ្គលនោះចាត់ជាសមណៈទី ៣ បុគ្គលដែលមានវិបស្សនាដ៏ហ្មត់ចត់ ជាបាទនៃមគ្គទី ៤ ក្តី អរហត្តមគ្គក្តី អរហត្តផលក្តី បុគ្គលនោះចាត់ជាសមណៈទី ៤ ។ ម្នាលសុភទ្ទ សមណៈដូច្នេះ ក្នុងលទ្ធិដទៃមិនមានឡើយ មានតែក្នុងសាសនារបស់តថាគត លទ្ធិដទៃៗ នោះ សូន្យទទេ ប្រាសចាកសមណៈ មិនមានសមណៈទេ ។ ម្នាលសុភទ្ទ ធម៌វិន័យឯណា សម្តែងពីអដ្ឋង្គិកមគ្គដ៏ប្រសើរ ជាគន្លងផ្លូវបដិបត្តិ ទើបសមណៈមានក្នុងធម្មវិន័យនោះ ដែលបានជាសមណៈនោះ ដោយបដិបត្តិតាមគន្លងផ្លូវជាកណ្តាល គឺអដ្ឋង្គិកមគ្គ ប្រសិនបើបដិបត្តិខុសពីផ្លូវកណ្តាល គឺអដ្ឋង្គិកមគ្គហើយ មិនជាសមណៈទេ មានព្រះពុទ្ធដីកាត្រាស់សម្តែងដល់សុភទ្ទបរិព្វាជក ដោយប្រការដូច្នេះ ។

**ពុទ្ធុប្បាទេ មធុរធម្មកថំ សុត្វា បសន្នា ភគវតោ មហន្តំ សក្ការំ អភិហរន្តិ** ព្រះនន្ទាចារ្យពោលសរសើរគុណព្រះសម្ពុទ្ធថា កាលបើព្រះអង្គឧប្បត្តិត្រាស់ដឹងហើយ បណ្តាប្រជាជន អ្នកស្រុក

អ្នកនិគម អ្នកខេត្ត គ្រប់នគររាជធានី បានទទួលស្តាប់រសព្រះសទ្ធម្ម ទេសនាដ៏ពីរោះ ក៏មាននូវបសាទសទ្ធាជ្រះថ្លាត្រេកអរជឿជាក់សព្វគ្រប់ ក៏បបួលគ្នាធ្វើនូវសក្ការគោរពបូជា ចំពោះព្រះសាស្តា ហេតុដូច្នេះ ទើបលាភសក្ការៈរបស់ពួកអន្យតិរ្ថិយ សាបសូន្យទៅ ជនទាំងឡាយ តាំងចិត្តប្រកបដោយសទ្ធា នាំគ្នាបូជាព្រះពុទ្ធដ៏ក្រៃលែង ដូចលាភសក្ការៈ របស់ក្អែកក្នុងពាវេរុជាតក **អទស្សនេន មោរស្ស** អ្នកក្រុងពាវេរុនគរ នោះកាលមិនទាន់បានឃើញស្តេចក្ងោក **មញ្ជុភាណិនោ** ដែលពោល ផ្អែមល្ហែមទន់ភ្លន់ ក៏បូជាស្តេចក្អែកខ្មៅដោយត្រី និងផ្លែឈើ ។លុះបាន ស្តាប់សំឡេង ស្តេចក្ងោក (មោរជាតិ) ក៏សប្បាយចិត្ត ឈប់បូជា សត្វក្អែក នាំគ្នាបូជាស្តេចក្ងោកដ៏ក្រៃលែងជាងមុន **យាវឧប្បជ្ជតិ ពុទ្ធោ** នាកាលព្រះសម្ពុទ្ធនៅមិនទាន់ត្រាស់ដឹងដរាបណា ជនទាំងឡាយ ក៏នាំ គ្នាពពាក់ពពូនធ្វើសក្ការគោរពបូជា ចំពោះសមណព្រាហ្មណាចារ្យ និងពួកអន្យតិរ្ថិយទាំងឡាយដរាបនោះ លុះកាលព្រះពុទ្ធទ្រង់ប្រោស ប្រទាន អម្រឹតរសនៃព្រះសទ្ធម្មផ្សាយទូទៅក្នុងលោក លាភសក្ការៈ របស់ពួកអន្យតិរ្ថិយក៏សាបសូន្យថយចុះមកជាលំដាប់លំដោយ ដូច ភ្លើងរបស់សត្វអំពិលអំពែក កាលព្រះសុរិយារះមានពន្លឺឡើងនោះ

ប្រការដែលព្រះទន្ទាចារ្យបាននាំមកអំពី **អដ្ឋកថាចូឡសីហនាទសូត្រ** ក្នុង **គម្ពីរមជ្ឈិមនិកាយ** មកសម្តែងក្នុង **គម្ពីរសារត្ថសង្គហៈ** នេះ បំណងឲ្យកុលបុត្រ មានសទ្ធា មានការសង្វេគតក់ស្លុតក្នុងចិត្ត ។ សម្តែងពីមិច្ឆាទិដ្ឋិតាមលំដាប់មាតិកាបទទី ១៧ ដែលតម្កល់ទុកខាងដើមគម្ពីរចប់តែប៉ុណ្ណេះ ។

មិច្ឆាទិដ្ឋិវិការនកថា ចប់

# អរិយូបវាទកម្មកថា

តពីនេះនឹងសម្ដែងនូវអរិយូបវាទកម្មតាមលំដាប់ នៃបទមាតិកា ដែលតម្កល់ទុកនោះ អរិយូបវាទកម្មនេះ ជាអន្តរាយដល់សួគ៌ និង និព្វានបានដោយបទវិគ្រោះថា **សគ្គមោក្ខានំ អន្តរាយំ ករោន្តីតិ អន្តរាយិកា** ប្រែថា **យេ ធម្មា** រីធម៌ទាំងឡាយណា **ករោន្តិ** តែងតែ ធ្វើ **អន្តរាយំ** នូវសេចក្ដីអន្តរាយ **សគ្គមោក្ខនំ** ដល់សួគ៌ និង និព្វានទាំងឡាយ **ឥតិ** ព្រោះហេតុដូច្នោះ **តេ ធម្មា** រីធមទាំង ឡាយនោះ **អន្តរាយិកា នាម** ឈ្មោះថា អន្តរាយ **ធម្មា** រីធម៌ទាំង ឡាយ **អន្តរាយិកា** ធ្វើនូវសេចក្ដីអន្តរាយដល់សួគ៌ និងនិព្វាន ។ អធិប្បាយថា អរិយូបវាទកម្មនេះ បានដល់ បុគ្គលដែលមានចិត្ត គិតមិនឲ្យជាប្រយោជន៍ ហើយនឹងជេរតិះដៀលនូវព្រះពុទ្ធ និងព្រះ អរហន្ត កំណត់ជាទីបំផុតរហូតដល់គ្រហស្ថដែលបានសោតា លើក ទោសដាក់ដោយអន្តិមវត្ថុថា សមណធម៌របស់ជនទាំងឡាយទាំងនេះ មិនមាន ជនទាំងនេះមិនមែនជាសមណៈ ជួនកាលតិះដៀលកម្ចាត់នូវ គុណព្រះធម៌ថា ជនពួកនេះអួតខ្លួនទទេៗ ឈានក៏មិនមាន វិមោក្ខក៏

មិនមាន មគ្គផលក៏មិនមាន តិះដៀលយ៉ាងនេះ ហៅថា អរិយូបវាទ អន្តរាយិកៗ ចែកចេញជា ៥ គឺកម្មន្តរាយ ១ កិលេសន្តរាយ ១ វិបាកន្តរាយ ១ ឧបវាទន្តរាយ ១ អាណាវីតិក្កមន្តរាយ ១ ។ កម្មន្តរាយ បានដល់ អនន្តរិយកម្មទាំង ៥ ដូចបានសម្តែងរួចមកហើយពីខាងដើម ។

ភិក្ខុនីទូសកកម្ម ដែលបុគ្គលប្រទូស្តចំពោះភិក្ខុនី ដូចនន្ទមាណពប្រទូស្តចំពោះព្រះនាងឧប្បលវណ្ណាថេរី ក៏បានឈ្មោះថាជាកម្មន្តរាយ ឯភិក្ខុនីទូសកកម្មនេះ ធ្វើឲ្យមានអន្តរាយដល់មគ្គផលនិព្វាន ហាមមគ្គ ហាមផល ហាមនិព្វាន តែមិនបានហាមស្ថានសួគ៌ទេ ។ **និយតមិច្ឆាទិដ្ឋិ** មានការប្រកាន់ខុសថាជាត្រូវ ត្រូវត្រឡប់ថាជាខុស ហៅថា **កិលេសន្តរាយ** ។ កម្មដែលឲ្យបដិសន្ធិជាខ្ទើយ ជាសត្វតិរច្ឆាន ជាឧភតោព្យញ្ជនៈ ហៅថា **វិបាកន្តរាយ** ។ កម្មដែលតិះដៀលព្រះអរិយៈ ហៅថា **ឧបវាទន្តរាយ** ។ បុគ្គលដែលតិះដៀលព្រះអរិយៈ បើនៅមិនទាន់ញុំាងព្រះអរិយៈ ឲ្យអត់ទោសដរាបណា ក៏នៅមិនទាន់រួចចាកទោសដរាបនោះដែរ **សត្តអាបត្តិក្ខន្ធា** អាបត្តិទាំង ៧ កង ភិក្ខុតាំងចិត្តប្រព្រឹត្តល្មើសពុទ្ធប្បញ្ញត្តិ ( ច្បាប់ ) ហៅថា **អាណាវីតិក្កមន្តរាយ** ។ ភិក្ខុតាំងចិត្តប្រព្រឹត្តល្មើសពុទ្ធប្បញ្ញត្តិ ប្តេជ្ញាខ្លួនថាជា

ភិក្ខុក្តី នៅមិនទាន់ចេញចាកអាបត្តិនោះក្តី នៅមិនទាន់បានទេសនា-បត្តិក្តី ក៏បានឈ្មោះថា នៅមិនទាន់រួចចាកទោស អំពីអាណាវីតិក្ក-មន្តរាយ ។ប្រការដែលសម្តែងមកនេះព្រះអដ្ឋកថាចារ្យ សម្តែងទុកនៅក្នុង អលគទ្ទូបមសូត្រ ក្នុង គម្ពីរមជ្ឈិមនិកាយ ។ អន្តរាយិកធម៌ទាំងឡាយ ៥ ប្រការនេះ លើកទុកសិនចុះ ក្នុងទីនេះ បំណងនឹងពោលដោយឧបវាទន្តរាយ ។

**យោ ច ជានំ វា ឧបវទេយ្យំ អជានំ វា** បុគ្គលដែលតិះដៀលព្រះអរិយៈដូច្នោះ ដឹងក្តី មិនដឹងក្តី ហើយពោលតិះដៀលកម្មនោះធ្ងន់ ធ្ងន់ប្រហែលនឹងអនន្តរិយកម្ម ឃាត់សួគ៌ ឃាត់មគ្គឃាត់ផល ប៉ុន្តែនៅកែបាន ( នៅសង្គ្រោះបាន ) **ឥទំ វត្ថុំ វេទិតព្វំ** ដែលនាំយកនិទាននេះមកសម្តែងដើម្បីឲ្យឃើញច្បាស់ថា អាចកែខៃបាន ។

**អញ្ញតរស្មឹ កិរ គាមេ** ដូចបានឮមកថា មានភិក្ខុពីររូប គឺព្រះមហាថេរៈចាស់មួយរូប និងភិក្ខុកំលោះមួយរូប នាំគ្នាត្រាច់ទៅបិណ្ឌបាតក្នុងស្រុកមួយ បានយាគូក្តៅៗ មួយវែកអំពីផ្ទះមុនគេ ចៃជន្យព្រះមហាថេរៈចាស់ឈឺពោះ ដោយខ្យល់ក្នុងឧទរនោះដ៏ខ្លាំងក្លា ទើបព្រះមហាថេរៈចាស់ គិតក្នុងចិត្តថា យាគូនេះជាទីសប្បាយ របស់

អាត្មាអញៗ នឹងចាន់យាគូដែលនៅក្តៅៗ កុំឲ្យត្រជាក់ទាន់ ប្រហែលជាបាត់ឈើពោះ កាលបើត្រិះរិះរួចហើយ ព្រះមហាថេរៈបានគង់លើកំណាត់ឈើ ដែលអ្នកស្រុកគេលើកផ្តេកទុក បំណងដើម្បីធ្វើជាមេទ្វារ ហើយក៏ហុតយាគូនោះ **ឥតរោ តំ ជិគុច្ឆន្តោ** ចំណែកភិក្ខុកំលោះឃើញកិរិយារបស់ព្រះមហាថេរៈ ក៏ទើសចិត្ត ហើយបានពោលតិះដៀលព្រះមហាថេរៈចាស់ថា ធ្វើនូវកម្មគួរស្អប់ពិត ពោលរួចហើយក៏និមន្តបិណ្ឌបាតតទៅទៀត កាលត្រឡប់មកដល់វិហារហើយទើបព្រះមហាថេរៈចាស់មានថេរវាចាថា នែអាវុសោ ទីពឹងក្នុងព្រះសាសនានេះ លោកបានហើយ ឬនៅទេ **អាម ភន្តេ** បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាបានសោតាហើយ ។ ព្រះមហាថេរៈពោលថា **អើអាវុសោ** បើលោកបានសោតាហើយ កុំធ្វើនូវសេចក្តីព្យាយាមបន្តទៅទៀត បើលោកតាំងចេតនាថា នឹងបានមគ្គ និងផលក្នុងខាងមុខដោយមិនសង្ស័យ ហេតុអ្វី ទើបលោកពោលយ៉ាងនោះ ។ **ខីណា-សវំ ឧបវទតោ** ព្រោះកាលលោកតិះដៀលព្រះខីណាស្រពអាក្រក់ក្រៃលែងដូច្នេះ **សោ តំ ខមាបេសិ** ភិក្ខុកំលោះមានស្មារតីឡើងថាខ្លួនបានតិះដៀលព្រះមហាថេរៈចាស់ ហើយក៏អង្វរសូមខមាទោសព្រះមហាថេរៈចាស់ក៏អត់ទោសឲ្យ **តំ កម្មំ ចាកតិកំ អហោសិ**

ទោសដែលតិះដៀលព្រះអរិយៈ កាលព្រះអរិយៈលើកលែងទោសហើយ ទោសនោះក៏វិនាសសូន្យទៅ ត្រឡប់ល្អជាធម្មតា វិបាកដែលនឹងឲ្យទោសមិនមាន ឧទាហរណ៍ដូចមាននិទាននេះថា នរណាម្នាក់បានតិះដៀលព្រះអរិយៈ ក៏ឲ្យអ្នកនោះទៅអង្វរសូមទោសដែលបានធ្វើខុស កុំប្រកាន់ខ្លួនថាចាស់ជាង ក្មេងជាង **ឧក្កុដិកំ និសីទិត្វា** ចូរអង្គុយនៅចំពោះមុខលោក លើកដៃប្រណម្យថា **អហំ អាយស្មន្តំ ឥទញ្ចិទញ្ច អវចំ តំ មេ ខមាហិ** បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាបានពោលដូច្នេះៗ ចំពោះលោកម្ចាស់ ខ្ញុំព្រះករុណាបានធ្វើខុសហើយ ដោយភ្លាំងភ្លាត់នូវស្មារតី សូមលោកម្ចាស់លើកលែងទោសដល់ខ្ញុំព្រះករុណា ជាអ្នកមានកំហុសនេះផង ពោលនឹងលោកនៅចំពោះមុខមិនទាន់ទៅទីណា **សចេ ទិសា បក្កន្តោ** បើលោកមិននៅទៅកាន់ទីឆ្ងាយ ក៏ឲ្យលោកអ្នកតិះដៀលព្រះអរិយៈនោះ ខ្វល់ខ្វាយស្វែងរកនូវដំណឹង ដឹងទីនៅរបស់លោកកន្លែងណាមួយពិតហើយ ក៏គប្បីប្រើឲ្យសទ្ធិវិហារិកទៅក្តី ខ្លួនទៅក្តី អង្វរសូមទោស ទើបគួរ **សចេ នេវ គន្តុំ** ប្រសិនបើខ្លួនឯងទៅមិនបាន សិស្សក៏មិនទៅ **យេ ភិក្ខូ វសន្តិ** ភិក្ខុទាំងឡាយដែលនៅក្នុងវិហារ ដែលលោកជាព្រះអរិយៈ គប្បីឲ្យភិក្ខុអ្នកតិះដៀលព្រះអរិយៈនោះ ទៅរកភិក្ខុដែលនៅក្នុងវិហារ កុំគប្បី

ប្រកាន់ខ្លួនថា ចាស់ជាង ក្មេងជាង **វុឌ្ឍនយេមេវ បដិបជ្ជិត្វា** បដិបត្តិដូចពោលរួចមកហើយថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាបានស្តីថាដូច្នេះៗ ចំពោះលោកដ៏មានអាយុអង្គនោះ សូមលោកម្ចាស់អង្គនោះលើកលែងទោស អត់ទោសដល់ខ្ញុំព្រះករុណា ជាអ្នកខុសនេះចុះ កាលបើមិនបានឲ្យលោកអត់ទោសចំពោះមុខ ក៏គប្បីបដិបត្តិដូចពោលរួចមកហើយ ហៅថា លុបលាងនូវកម្មក៏គួរដល់អ្នកមាននូវកំហុស **សចេ ឯកចារិកភិក្ខុ** ប្រសិនបើព្រះអរិយៈលោកនិមន្តមកតែមួយព្រះអង្គមិនដឹងកន្លែងជាទីនៅ មិនស្គាល់ទីទៅថា លោកនៅទីនេះ ទីនោះមិនបានដឹងប្រាកដដូច្នេះ ក៏ឲ្យអ្នកតិះដៀលព្រះអរិយៈនោះទៅកាន់សម្នាក់ភិក្ខុជាអ្នកប្រាជ្ញ អង្វរសូមទោសថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាបានស្តីដូច្នេះៗ ចំពោះលោកម្ចាស់អង្គនោះៗ កាលបើខ្ញុំព្រះករុណារឭកដល់ពាក្យនោះហើយ ក៏ទោមនស្ស ក្តៅក្រហាយស្តាយក្រោយពន់ពេក សូមលោកម្ចាស់ជួយគិតគូររកឧបាយប្រាប់ដល់ខ្ញុំព្រះករុណាផង **មា ចិន្តយិ** ភិក្ខុជាបណ្ឌិតនោះពោលថា លោកកុំខ្វល់ខ្វាយ និងកុំទោមនស្សអ្វីឡើយ ព្រះមហាថេរៈនោះមិនបានក្រោធដល់លោកទេ លោកអត់ទោសដល់លោកហើយ ចូរលោករម្ងាប់ចិត្តចុះ ។ កាលបើភិក្ខុជាបណ្ឌិតពោលដូច្នេះ លោកដែលតិះដៀល

ព្រះអរិយៈជានោះ ក៏គប្បីបែរមុខទៅកាន់ទិសដែលព្រះអរិយៈនោះនិមន្ត ទៅ គប្បីលើកដៃប្រណម្យ ក្រាបថ្វាយបង្គំ រួចហើយក៏គប្បីបញ្ចេញវាចាថា **អាយស្មា ខមតុ** បពិត្រលោកម្ចាស់ សូមមេត្តាលើកលែងទោសដល់ខ្ញុំព្រះករុណា ដែលបានស្តីថាតិះដៀលក្នុងគ្រានោះផងចុះ **សចេ សោ បរិនិព្វុតោ** ប្រសិនបើព្រះអរិយៈលោកបរិនិព្វានទៅហើយ ក៏គប្បីទៅកាន់គ្រែដែលលោកបរិនិព្វាន ទៅរហូតដល់កន្លែងបូជាព្រះសពលោក ហើយគប្បីប្រាប់នូវអធិករណ៍ដល់លោក ធ្វើនូវកិច្ចសូមខមាទោស ដូច្នេះ ។ **នេវ សគ្គាវរណំ ន មោក្ខាវរណំ** នឹងមិនបានជាគ្រឿងហាមសុគតិ ហាមមគ្គផល ក៏ជាអហោសិកម្មទៅ ។ សេចក្តីនេះ ព្រះអដ្ឋកថាចារ្យពោលក្នុង **គម្ពីរវិសុទ្ធិមគ្គ** អ្នកប្រាជ្ញគប្បីសន្និដ្ឋានតាមវារបាលីនេះចុះ សម្តែងមកដោយអរិយូបវាទតាមមាតិកាដោយលំដាប់ ខាងដើមនៃគម្ពីរចប់តែប៉ុណ្ណេះ ។

អរិយូបវាទកម្មកថា ចប់

# កោហញ្ញានិទ្ទេសកថា

បន្តទៅនេះនឹងសម្ដែងក្នុងមាតិកាថា កោហញ្ញានិទ្ទេសកថា តទៅតាមលំដាប់ សង្គហន័យ ហៅថា កោហញ្ញៈៗ គឺនឹងឲ្យមានទោសក្នុងអនាគតដែលបុគ្គលកុហកហើយ មានតែសភាពធ្ងន់ធ្ងរ មិនបានទទួលនូវភាពភ្លឺស្វាង តែងតែធ្វើនូវកាលកិរិយាខាងក្នុងគភ៌មាតាហើយក៏តែងតែទៅវេទនាក្នុងនៅក្នុងអបាយ សកលម្បិ កប្បំ យូរហូតដល់មួយកប្ប មានតែសភាពធ្ងន់ធ្ងរនៅខាងមុខ ទោសរបស់ការកុហកតែងតែឲ្យផលមានសភាពដូច្នេះ អដ្ឋកថាគម្ពីរសំយុត្តនិកាយ ពោលយ៉ាងនេះ ព្រះនន្ទាចារ្យពោលថា ធម្មតាមនុស្សកុហក តែងតែឃើញដល់លាភសក្ការៈ ឃើញតែភាពល្បីល្បាញ ក៏ចាប់ផ្ដើមសម្ដែងចំណេះដឹង អួតចំណេះដឹងដែលមិនមាន ថាមាន ធ្វើអាកប្បកិរិយាតាក់តែងនូវឥរិយាបថទាំង ៤ ហើយក៏ធ្វើការខ្សឹបខ្សៀវ អួតខ្លួនដោយផ្លូវឧត្តរិមនុស្សធម៌ លើកឡើងពោលដោយវាចា ខ្សឹបប្រាប់ដូចកុហកភិក្ខុ ។

**កិរ** បានឮមកថា មានភិក្ខុមួយរូប កាលប្រាថ្នាចាន់កោជនទើបនិមន្តចូលទៅកាន់ស្រុក ហើយចូលទៅអង្គុយនៅក្នុងផ្ទះរបស់

ញោមឧបដ្ឋាក **យរណី អធាតុកាមា** ឯឧបាសិកាជាម្ចាស់ផ្ទះ ធុញទ្រាន់ មិនចង់ឲ្យចង្ហាន់ ក៏សម្តែងនូវអាកប្បកិរិយាមិនពេញចិត្ត ហើយពោលថា អង្ករមិនមាន ចាំខ្ញុំព្រះករុណាទៅខ្ចីគេសិន ពោលដូច្នេះហើយ ក៏ដើរទៅផ្ទះញាតិ **តស្មិំ ខណេ** ខណៈដែលឧបាសិកាដើរទៅផ្ទះញាតិ ភិក្ខុនោះក៏ចូលទៅក្នុងផ្ទះបាយ ក្រឡេកឃើញអំពៅនៅក្បែរទ្វារ ស្ករអំពៅនៅក្នុងភាជនៈ ត្រីងៀតនៅក្នុងកញ្ច្រែង អង្ករនៅក្នុងថ្នាំង ប្រេងនៅក្នុងក្អម លោកមើលសព្វគ្រប់ហើយ ក៏ចេញមកវិញ ធ្វើហាក់បីដូចមិនដឹង មិនឃើញ ។ ឧបាសិកាម្ចាស់ផ្ទះមកដល់ប្រាប់ថា លោកម្ចាស់ អង្ករមិនមានទេ ទីណាក៏មិនមានដែរ ដូចម្តេចនឹងបានចង្ហាន់ ទើបភិក្ខុនោះប្រាប់ថា **ឧបាសិកេ** នែឧបាសិកា ថ្ងៃនេះអាត្មាយល់ថា មិនគួរអត់ចង្ហាន់ទេ អាត្មាបានឃើញប្រផ្នូលប្លែកចម្លែកតាមផ្លូវ និមិត្តតាំងអំពីមិនទាន់មកម៉្លេះ ។ ឧបាសិកាសួរថា លោកម្ចាស់ឃើញអ្វី ? ភិក្ខុឆ្លើយថា នែឧបាសិកា កាលអាត្មាដើរមកតាមផ្លូវនេះ បានឃើញពស់ មើលទៅដូចជាដើមអំពៅនៅត្រង់ទ្វារ កាលអាត្មាមើលឃើញគិតនឹងចង់វាយ ក្រឡេកឃើញដុំថ្មដុំដី ដូចគ្នានឹងដុំស្ករអំពៅនៅក្នុងភាជនៈ ដែលនាង

តម្កល់ទុក អាត្មាលើកដៃឡើងនឹងគ្រវែងវាៗ ក៏បើកពពារឡើង ហាក់បីដូចជាត្រីផៀតក្នុងកញ្ច្រែង កាលពស់ហាមាត់ខាំជុំថ្ម មើលដូចជាអង្ករនៅក្នុងឆ្នាំង កាលពស់ក្រោធ ហើយព្រួសពិស មើលទៅដូចប្រេងនៅក្នុងក្អម ជាប្រផ្នូល អាត្មាបានជួបពស់ធំ នៅត្រង់ផ្លូវដូច្នេះហើយ មិនសមបើអាត្មាភាពត្រូវអត់ចង្ហាន់ទេ ។

**ឆ សក្កា មុណ្ឌំ មញ្ចេតុំ** ឧបាសិកាយល់ថា មិនអាចកុហក ឬបោកបញ្ឆោតសមណៈត្រងោលនេះបានហើយ ត្រូវតែរៀបចម្អិននូវបាយ និងម្ហូបឲ្យលោកឆាន់ កាលឆាន់រួចស្រេចហើយ ក៏ជូនដំណើរកុហកភិក្ខុនោះចេញទៅ សេចក្តីនេះព្រះអដ្ឋកថាចារ្យពោលទុកនៅក្នុងគម្ពីរ**វិសុទ្ធិមគ្គសីលនិទ្ទេស** នាំមកឲ្យឃើញថា កុហកភិក្ខុនោះប្រព្រឹត្តអាក្រក់ ដូច្នេះ ។

មិនមែនត្រឹមតែប៉ុណ្ណោះទេ កុហកភិក្ខុមួយរូបដទៃទៀត ឃើញដល់លាភសក្ការៈ ខ្លួនគ្មានសទ្ធា សម្តែងថាខ្លួនមានសទ្ធា ខ្លួនគ្មានសីល សម្តែងថាខ្លួនមានសីល ខ្លួនជាអសប្បុរសបានស្តាប់តិច អួតថាខ្លួនបានស្តាប់ច្រើន ខ្លួនជាមនុស្សខ្ជិល អួតថា ខ្លួនជាមនុស្សឧស្សាហ៍ ខ្លួនជាបុគ្គលគ្មានស្មារតី អួតថា ខ្លួនជាមនុស្សមានស្មារតី ខ្លួនមិនមានសមាធិ

គុណអួតថា ខ្លួនមានសមាធិ ខ្លួនល្អផុតអប្បប្រាជ្ញា អួតថា ខ្លួនមានប្រាជ្ញា ទីបំផុត ខ្លួនឯងល្អ អ្នកដទៃអាក្រក់ដូច្នេះឯង ។

មិនមែនត្រឹមតែប៉ុណ្ណោះទេ កុហកភិក្ខុដែលមានបញ្ញាអន់ថយ កាលគង់នៅក្នុងជំនុំបរិស័ទហើយ ក៏បញ្ចេញវាចាថា ព្រះបរិយត្តិនេះសម្រាប់ខ្លួនខ្ញុំមិនលំបាកទេ សូម្បីនឹងពោលប្រាប់ រៀនសូត្រ ក៏មិនលំបាកដែរ បុគ្គលដែលទ្រទ្រង់ទុកនូវបរិយត្តិមិនផុតទុក្ខទេ ពោលដូច្នេះហើយ ក៏សម្ដែងខ្លួនថា មានសតិបញ្ញា **សាសនស្ស បហារំ វិយ ទេតិ** ពោលដូច្នេះហាក់បីដូចថា វាយប្រហារសាសនា ហៅថាមហាចោរប្លន់សាសនា មហាចោរដែលអាក្រក់ កាចដើរប្លន់អ្នកស្រុកនោះថាជាចោរដ៏កាចក៏ពិតមែនហើយ ប៉ុន្តែមិនក្រៃលែងដូចមហាចោរនេះទេ អើ លើកយកពាក្យនេះមកពោលថា អ្នកដែលរៀនសូត្រ គឺអ្នកចេះបរិយត្តិ មិនផុតទុក្ខ ពោលទទេៗ ពោលទាំងនេះបំណងនឹងឲ្យគេជឿ តែគេមិនជឿ ។

មិនតែប៉ុណ្ណោះទេ កុហកភិក្ខុនេះតែងតែអួតលើកខ្លួន សម្ដែងលោកុត្តរធម៌ថាមានក្នុងខ្លួន ការពិតមិនមានឡើយ ដូចព្រះអរហន្តក្នុងពាង និងដូចព្រអរហន្តពួរជ្រៃ រមែងសម្ដែងគុណដែលមិនមាន

ក្នុងខ្លួនថាមាន ដូចមាននិទានតទៅនេះថា

**ឯកោ កុហកោ** មានកុហកភិក្ខុមួយរូប តម្កល់ពាងទុកក្នុងកុដិ ហើយក៏រង់ចាំមើល កាលមានមនុស្សចូលមកជិតដល់ ចូលពួនក្នុងពាងដើម្បីគេចខ្លួន កាលបើមនុស្សទាំងឡាយរកមើលមិនឃើញព្រះថេរៈ ទើបសួរសិស្សថា ព្រះមហាថេរៈរបស់លោកម្ចាស់និមន្តទៅណា ? សិស្សក៏ប្រាប់ថា លោកម្ចាស់គង់នៅទីហ្នឹងទេតើ ជនទាំងឡាយក៏ត្រឡប់ចូលទៅរកម្តងទៀត ព្រះថេរៈបានឮក៏ចេញពីពាង ហើយគង់នៅលើអាសនៈ ទើបជនទាំងឡាយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយនាំគ្នារកលោកម្ចាស់ៗ និមន្តទៅទីណា ទើបមិនឃើញ នែឧបាសកទាំងឡាយធម្មតាសមណៈ បើនឹងទៅទីណា ក៏ទៅបានតាមចិត្តប្រាថ្នារបស់ខ្លួន ថាហើយ ក៏អួតថា ជាព្រះអរហន្ត បំណងនឹងឲ្យជនទាំងឡាយជ្រះថ្លាសម្គាល់ថាល្អ ដូច្នេះក៏មានខ្វះ ។

**អបរោ កុហកោ** មានកុហកភិក្ខុមួយរូបផ្សេងទៀតអាស្រ័យនៅសាលាក្បែរភ្នំមួយ ខាងក្រោយបណ្ណសាលានោះ មានដើមជ្រៃមួយដើម មានពួរសំយុងចុះធ្លាក់មករហូតដល់ដី កាលពុទ្ធបរិស័ទ

ទាំងឡាយ គេនិមន្តទៅទទួលបិណ្ឌបាតនោះ **សោ បត្តចីវរមាទាយ** កុហកភិក្ខុនោះ កាលប្រដាប់ដោយបាត្រ និងចីវររួចហើយ ក៏សម្រូត ខ្លួនចុះតាមពួរជ្រៃ ហើយសម្តែងខ្លួនឲ្យបរិស័ទទាំងឡាយឃើញទៀប ទ្វារស្រុក **តតោ មនុស្សេហិ** កាលបរិស័ទទាំងឡាយឃើញព្រះ ថេរៈនៅត្រង់ទ្វារស្រុក ទើបសួរថា លោកម្ចាស់និមន្តមកតាមផ្លូវ ណា ទើបលឿនរហ័សដូច្នេះ ? ទើបលោកតបថា អ្នកទាំងឡាយមិន ត្រូវសួរផ្លូវទៅមករបស់សមណៈនោះទេ សមណៈនឹងមកតាមផ្លូវណា ក៏មកបាន នឹងទៅតាមផ្លូវណាក៏ទៅបាន ថាហើយ ក៏អួតខ្លួនថាជាព្រះ ខីណាស្រព លោកធ្វើដូច្នេះច្រើនដង **តំ បន កុហកំ** មានបុរសចោះ ត្រចៀកសង្ស័យក្នុងចិត្ត ហើយប្រាថ្នាចង់មើលឲ្យច្បាស់ ទើបគិតថា អញនឹងរង់ចាំមើលមួយថ្ងៃសិនចុះ កាលគិតរួចហើយ ក៏នៅឃ្លាំមើល ឃើញកុហកភិក្ខុនោះ សម្រូតខ្លួនចុះមកតាមពួរជ្រៃ កាលឃើញជាក់ ច្បាស់ក្នុងចិត្តដូច្នេះហើយ ថ្ងៃមួយ គេឡើងទៅខាងជើងភ្នំនោះ **ឆិន្ទិត្វា** កាត់ពួរជ្រៃឲ្យសល់តែបន្តិច ដល់ពេលកុហកភិក្ខុនិមន្តទៅ ក៏សម្រូតខ្លួនចុះ តាមពួរជ្រៃ លុះមកដល់ហើយ ក៏ស្រវាពួរជ្រៃសម្រូតខ្លួនចុះមក រំពេច នោះ ពួរជ្រៃក៏ដាច់របូតធ្លាក់ចុះមក បាត្រក៏បែក ក្បាលក៏ពកជាំ

**ធិក្ខមិត្វា បលាយិ** *ពោលទាំងឈើចិត្ត ទាំងឈើខ្លួនថា គេដឹងរឿង រ៉ាវអស់ហើយ នឹងនៅទីនេះដូចម្តេចកើត ស្ទុះក្រោកឡើង ប្រញាប់ ប្រញាល់រត់ចេញពីទីនោះទៅ ។ សេចក្តីនេះព្រះអដ្ឋកថាចារ្យ បាន ពោលទុកក្នុង គម្ពីរវិភង្គ អធិប្បាយដោយញាណវិភង្គ* **ឯវរូបានំ កុហកានំ** *កុហកភិក្ខុមានសភាពបែបនេះ ដែលខ្លួនលោកខ្លាចបរលោក នោះ លើកទុកសិនចុះ មនុស្សកុហកនោះ ក្នុងអត្តភាពនេះក៏ភ័យ ខ្លាច* **តត្រិទំ វត្ថុំ** *ទើបនាំយករឿងនិទានមកសម្តែងប្រាថ្នាឲ្យឃើញ សេចក្តីដែលគួរភ័យខ្លាច ។*

**កិរ** *បានឮមកថា មានភិក្ខុមួយរូបជាបិយគាមិកភិក្ខុ កាលបាន ឃើញសព្រហ្មចារីដែលសមាទានធុតង្គ លាភសក្ការៈតែងតែកើតឡើង យ៉ាងច្រើន ក៏មានគំនិតប្រាថ្នានូវលាភសក្ការៈដូចលោកដែរ ទើបបាន សមាទានសោសានិកធុតង្គ ហើយក៏និមន្តទៅកាន់ទីប៉ាឆា* **ឯកទិវសំ** *ថ្ងៃមួយ មានគោចាស់ជរាមួយ គេឈប់ប្រើ រួចផុតពីការងារហើយ ដើររកស៊ីស្មៅក្នុងពេលថ្ងៃ លុះពេលយប់ក៏ទៅដេកនៅក្បែរប៉ាឆា* **សីសំ កត្វា** *លាក់ក្បាលនៅក្បែរប៉ាឆា ត្រង់គុម្ពោតមួយ ឯគោចាស់នោះ ឈរទំពាអៀងក្នុងគុម្ពោតនោះ* **បិយគាមិកោ រត្តិំ ចង្កមានោ**

បិយគាមិកភិក្ខុកាលចេញមកចង្រ្កមក្នុងវេលារាត្រីនោះ បានឮសំឡេងគោទំពាអៀង ក៏ភ័យតក់ស្លុតចិត្ត គិតថា សក្កទេវរាជដឹងថា អាត្មាអញមានសេចក្តីត្រេកអរក្នុងលាភ ទើបចេញមកកាន់ប៉ាធា លោកក្មែងបៀតបៀនអាត្មាអញដោយពិត នឹកបណ្តើរធ្វើអញ្ជលីផ្ទោះមុខទៅរកគោចាស់នោះ ពោលអង្វរថា **ទេវរាជ** បពិត្រសក្កទេវរាជលោកជាសប្បុរស សូមលោកលើកលែងទោសដល់អាត្មាភាពតែក្នុងមួយរាត្រីនេះចុះ ចាប់តាំងអំពីថ្ងៃស្អែកទៅ អាត្មាភាពលែងធ្វើដូច្នេះទៀតហើយ គឺតាំងចិត្តអង្វរជរាបដល់ភ្លឺ មិនបានសិងឡើយ **សុរិយេ ឧដ្ឋិតេ** ក្នុងកាលព្រះអាទិត្យរះឡើងភ្លឺច្បាស់ លោកចោលភ្នែកក្រឡេកទៅក៏ឃើញគោចាស់ ក៏តូចចិត្ត ឈឺចិត្ត ទាំងក្រោធថា គោចាស់នេះគំរាមសម្លុតអញរហូតដល់ភ្លឺ ពោលរួចហើយក៏ចាប់ឈើប្រត់ដេញវាយគោរត់ចេញពីទីនោះទៅ សេចក្តីនេះមាននៅក្នុងអដ្ឋកថា **គម្ពីរមជ្ឈិមនិកាយ** សម្តែងមកដោយ **សង្គហន័យ** ក្នុង **បទមាតិកា** កោហញ្ញាទីនវកថាតាមលំដាប់ខាងដើមគម្ពីរ ក៏ចប់ត្រឹមតែប៉ុណ្ណេះ ។

កោហញ្ញាទីនវកថា ចប់

# មច្ឆេរប្បភេទកថា

*ជាបន្តទៅនេះនឹងសម្តែងនៅក្នុងបទមាតិកា មច្ឆេរានប្បភេទកថា* **បញ្ចវិធំ ហិ មច្ឆរិយំ** *ការពិតមច្ឆរិយៈ គឺការកំណាញ់មាន ៥ យ៉ាង គឺ អាវាសមច្ឆរិយៈ ១ កុលមច្ឆរិយៈ ១ លាភមច្ឆរិយៈ ១ វណ្ណមច្ឆរិយៈ ១ ធម្មមច្ឆរិយៈ ១ ជា ៥ យ៉ាង ។ ឈ្មោះថា មច្ឆរិយៈ ព្រោះមានសេចក្តីត្រិះរិះថា* **មា ឥទំ ឥស្សរិយំ អញ្ញេសំ ហោតុ** *ភាពឥស្សរិយយសនេះ កុំមានដល់អ្នកដទៃឡើយ ព្រោះត្រិះរិះដូច្នេះ ទើបឈ្មោះថា* **មច្ឆរិយៈ** *បើមិនដូច្នោះ ឃើញអ្នកដទៃមានសម្បត្តិច្រើន ទប់ចិត្តមិនបាន ក៏មានតែហួងហែងសម្បត្តិរបស់ខ្លួនទុក មិនធ្វើឲ្យជាសាធារណៈដល់អ្នកដទៃ កំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់ការសរសើរ កំណាញ់ធម៌ ហៅថា អាវាសក្តី អារាមក្តី បរិវេណទាំងឡាយក្តី បន្ទប់មួយក្តី ទីសម្រាកថ្ងៃ ទីសម្រាកយប់ក្តី ក៏ហៅថា អាវាសទាំងអស់ ទីបំផុតរហូតដល់ភិក្ខុទាំងឡាយ នៅសប្បាយក្នុងទីណា នៅទីណាបានលាភ បច្ច័យ ៤ ជាសុខហើយ ក៏ហៅថា អាវាសទាំងអស់ អាវាសដូច្នោះ បើ*

ភិក្ខុរូបណាកំណាញ់ មិនបានឲ្យដល់ភិក្ខុដែលមានវត្តបដិបត្តិល្អ និង មានសីលជាទីស្រឡាញ់ ក៏គិតថា ធ្វើម្ដេចហ្ន៎ ភិក្ខុនេះទៅដោយ រហ័ស បើឃើញភិក្ខុអាគន្តុកៈក៏ផ្ដើមរអ៊ូរទាំថា ទីនោះទុកសម្រាប់ ដាក់របស់ព្រះចេតិយ ទីនេះទុកសម្រាប់ដាក់របស់ព្រះសង្ឃ អើ ក៏នៅ ដូចម្ដេចបាន ។ កំណាញ់អាវាសជាទីនៅរបស់ព្រះសង្ឃ មិនបានឲ្យ ភិក្ខុអាគន្តុកៈនៅយ៉ាងនេះ ឈ្មោះថា **អាវាសមច្ឆរិយៈ** ។ ប្រសិនបើ ភិក្ខុមានចិត្តមិនត្រូវគ្នា ឲ្យនៅឃើញថា នឹងកើតការឈ្លោះប្រកែក គ្នា អាការដែលកំណាញ់ដូច្នោះ មិនជាអាវាសមច្ឆរិយៈឡើយ ។

កុលមច្ឆរិយៈ គឺការកំណាញ់ក្នុងត្រកូលឧបដ្ឋាកក្ដី ត្រកូល ញាតិញោមក្ដី ភិក្ខុប្រាថ្នាមិនឲ្យភិក្ខុដទៃ ចូលទៅត្រកូលឧបដ្ឋាក និងញាតិញោមទាំងឡាយ តែងតែហាមប្រាម កំណាញ់ដោយហេតុ ផ្សេងៗយ៉ាងនេះឈ្មោះថា កុលមច្ឆរិយៈ **ចាបស្ស បុគ្គលស្ស បន** បើភិក្ខុណាមានចិត្តបាបថោកទាប ចូលទៅរកត្រកូលតែងតែ ទៅពោល ឲ្យអស់នូវសទ្ធា បើដូច្នោះ សូម្បីហាម មិនឈ្មោះថា ជាកុលមច្ឆរិយៈ ឡើយ ។ កាលដែលភិក្ខុអ្នកមានសីលល្អ មានវត្តបដិបត្តិល្អ គួរជាទី ស្រឡាញ់ជ្រះថ្លារបស់ត្រកូល ភិក្ខុមានចិត្តកំណាញ់ មិនបានឲ្យភិក្ខុ

អ្នកមានសីលបរិសុទ្ធបែបនោះចូលទៅកាន់ត្រកូល ដែលប្រកបដោយសទ្ធាជ្រះថ្លា **មច្ឆរិយំ ឆាម ហោតិ** ឈ្មោះថា **កុលមច្ឆរិយៈ** ។

**លាភមច្ឆរិយៈ** គឺសេចក្តីកំណាញ់លាភនោះ បានដល់ បច្ច័យ ៤ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ ភេសជ្ជបរិក្ខារ កាលបើភិក្ខុដទៃមានសីលាចារវត្តបដិបត្តិល្អ បានបច្ច័យ ៤ បែបនេះ ភិក្ខុអ្នកមានចិត្តបាប នឹកកំណាញ់ក្នុងចិត្តថា កុំឲ្យលោកបានឡើយ កំណាញ់ហួងហែងលាភដែលជារបស់សង្ឃ **យថា អញ្ញេឆ លភន្តិ** ទីបំផុតភិក្ខុដទៃនឹងមិនបានលាភ យ៉ាងណាមិញ ក៏ប្រឹងប្រែងព្យា-យាមពោលញុះញង់ដូច្នោះឯង **៩ធំ លាភមច្ឆរិយំ ឆាម** យ៉ាងនេះ ហៅថា **លាភមច្ឆរិយៈ** ។

ភិក្ខុណាញុំាងនូវសទ្ធារបស់ទាយកឲ្យធ្លាក់ចុះ ធ្វើមិនឲ្យមាននូវរបស់ឆាន់បាន និងបរិភោគប្រើប្រាស់មិនស្រួល ឲ្យតែរបស់ជូរផ្អូមដល់ភិក្ខុដទៃ ទោះបីយ៉ាងនេះក៏ពិតមែនហើយ ចិត្តគិតថា ភិក្ខុដទៃមានសីល លោកមកហើយ នឹងបានយកទៅឆាន់ ស្លៀកដណ្តប់ ប្រើប្រាស់ ចិត្តគិតថា ទុកសម្រាប់លោកដែលមាននូវសីល ដ៏តឹងរ៉ឹងយ៉ាងនេះ ក៏មិនឈ្មោះថា លាភមច្ឆរិយៈឡើយ ។

វណ្ណមច្ឆរិយៈ គឺកំណាញ់ចំពោះការសរសើរ ការសរសើរសម្បុរនោះ គឺការសរសើរខ្លួន និងការសរសើរគុណ បានឮមនុស្សដទៃគេថា មនុស្សនោះរូបស្អាត គឺខ្លួនគេល្អ ស្តាប់ទៅទប់ចិត្តមិនកើត បិទមាត់មិនបាន ក៏ពោលចេញមកថា ស្អាតអ្វីអីចឹង គ្រាន់តែដូច្នោះក៏សរសើរថាល្អដែរ **អនេត្តុកាមោ** ចិត្តគិតថា នឹងមិនឲ្យគេសរសើរអ្នកដទៃ ឲ្យគេពោលសរសើរតែខ្លួនម្នាក់ ជួនកាលកំណាញ់រហូតដល់ការសរសើរសេចក្តីល្អ កាលបើបានឮអ្នកដទៃគេពោលថា ព្រះថេរៈរូបនោះ មានសីលល្អ និងធុតង្គវត្ត មានការបដិបត្តិ និងអាចារវត្តល្អ កាលបានស្តាប់ហើយ អត់ធន់មិនបាន ក៏លើកយកទោសដែលអាក្រក់ទៅដាក់ ក្នុងចិត្តនោះរន្ធត់ មិនចង់ឲ្យគេសរសើរអ្នកដទៃ យ៉ាងនេះហៅថា **គុណមច្ឆរិយៈ** ឬហៅថា កំណាញ់ការសរសើរ ។

**ធម្មមច្ឆរិយៈ** គឺកំណាញ់ធម៌ **ធម្មមច្ឆរិយេន សមន្នាគតោ** បុគ្គលដែលប្រកបដោយមច្ឆរិយធម៌ គម្ពីរដែលអាចិកំបាំង ក៏លាក់ចំណេះ ឬសេចក្តីអធិប្បាយក៏កំណាញ់ មិនចង់ឲ្យអ្នកណាដឹង មិនចង់ពោលប្រាប់អ្នកដទៃ ដោយសម្គាល់ក្នុងចិត្តថា អ្នកដែលរៀនចេះ

ដីង ទៅខាងមុខនឹងល្អជាងយើង គិតយ៉ាងនេះ កំណាញ់យ៉ាងនេះ ឈ្មោះថា **ធម្មមច្ឆរិយៈ** ។

**យោ បន អយំ** ភិក្ខុរូបណាគិតថា បុគ្គលនេះរៀនហើយ ក៏នឹងត្រឡប់ផ្លាស់ប្តូរនូវសេចក្តីអត្ថាធិប្បាយយ៉ាងដទៃ ធម៌របស់ព្រះសម្ពុទ្ធ ក៏នឹងវិនាសសាបសូន្យ ព្រោះការយល់ថា ព្រះធម៌នឹងវិនាសសាបសូន្យ ទើបកំណាញ់ មិនចង់នឹងប្រាប់ មួយទៀត មិនចង់ឲ្យ មិនចង់ប្រាប់នោះ ព្រោះយល់ថា បុគ្គលដូច្នេះរៀនធម៌ហើយ ក៏នឹងសង្ស័យ តម្លើងនូវមានះ នឹងសោយបាបកម្មដ៏ក្រៃលែង អនុគ្រោះដល់បុគ្គលដូច្នេះ ទើបមិនប្រាប់ នេះមិនបានឈ្មោះថា ធម្មមច្ឆរិយៈឡើយ ។

**ឥមេសុ បញ្ចសុ មច្ឆរិយេសុ** បណ្តាមច្ឆរិយៈទាំង ៥ យ៉ាងនេះ អ្នកណាកំណាញ់អាវាស អ្នកនោះស្លាប់ទៅ ក៏រមែងទៅកើតជាយក្ខ ជាប្រេត អើតក្បាលទូលនូវកាកសំណល់ ហើយដើរទៅគ្រប់វត្តអារាម ។

អ្នកដែលកំណាញ់ត្រកូល កាលឃើញមនុស្សក្នុងត្រកូល មាននូវសទ្ធា ធ្វើបុណ្យឲ្យទានជាដើមចំពោះភិក្ខុដទៃៗ ក៏អន់ចិត្តថា

គេមិនឲ្យអ្វីដល់អញ គេប្រហែលជាអន់ចិត្ត ស្អប់ខ្ពើមចំពោះអញ ហើយ ញាតិរបស់អញ នឹងជាញាតិរបស់គេ គិតទៅក៏អន់ចិត្ត រហូតដល់ក្អួតឈាម ពោះវៀនធំតូចនឹងដាច់ជាចម្រៀកតូចធំចេញមក ។

អ្នកដែលកំណាញ់លាភ កាលបើកំណាញ់លាភដែលជារបស់សង្ឃក្តី របស់គណៈក្តី បរិភោគប្រើប្រាស់ ហាក់បីដូចជារបស់បុគ្គល ។ លុះបែកធ្លាយរាងកាយទៅ ក៏តែងតែទៅកើត ជាយក្ខជាប្រេត ជាពស់ថ្លាន់ ។

អ្នកដែលកំណាញ់ការសរសើរខ្លួន កំណាញ់ការសរសើរនូវសេចក្តីល្អ កំណាញ់ធម៌នោះ កាលធ្វើនូវកាលកិរិយា **ទុព្វណ្ណោ** នឹងមានរូបអាក្រក់ ខ្លួនសម្បុរខ្មៅ ជាមនុស្ស-គ ជាមនុស្សឆ្កួត ជាមនុស្សឆ្កួតជ្រុក ។

មួយទៀតសោត អ្នកដែលកំណាញ់អាវាសនោះ រមែងទៅឆេះនៅក្នុងខ្ទះទង់ដែង ។ អ្នកដែលកំណាញ់ត្រកូល ទោសដែលនឹងឲ្យផល មានលាភសក្ការៈថយចុះ ។ អ្នកដែលកំណាញ់លាភ រមែងទៅកើតក្នុងគូថនរក ។ អ្នកដែលកំណាញ់ខ្លួន និងអ្នកដែលកំណាញ់ការសរសើរសេចក្តីល្អ លុះធ្វើកាលកិរិយាទៅហើយ ទៅកើតក្នុង

សម្បរាយិកភព មានតែគេនិន្ទា ជេរប្រទេចផ្ដាសា មិនមានអ្នកលើកតម្កើងពោលសរសើរ ទាំងសម្បុរក៏ខ្មៅ ចោតល្វង់ខ្មៅ មិនមានបញ្ញា ។ អ្នកដែលកំណាញ់ធម៌ លុះធ្វើកាលកិរិយាទៅ ក៏រមែងទៅកើតក្នុងនរកផេះក្ដៅ រងទុក្ខវេទនាអស់កាលដ៏យូរ សេចក្ដីដែលសម្ដែងមកនេះ លោកសម្ដែងប្រាកដនៅក្នុង **គម្ពីរទីឃនិកាយ** កែខ **សង្គីតិសូត្រ សក្កបញ្ហាសូត្រ** និង **អដ្ឋកថាធម្មសង្គណី** វិសជ្ជនាមកដោយ**នយសង្គហៈ មច្ឆេរកថា** ក្នុងបទមាតិកាខាងដើមគម្ពីរ ក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

មច្ឆេរប្បភេទកថា ចប់

# តិវិធគ្គិកថា

*ជាបន្តនេះនឹងសម្តែង បទមាតិកាតិវិធគ្គិកថា មានសេចក្តីជាខាងដើម ដែលនាំយកសេចក្តី សង្គីតិសូត្រ មកសម្តែងទុក បំណងនឹងបង្ហាញសេចក្តី គឺភ្លើង ៣ កងឲ្យយល់ពិតថា* **តយោ អគ្គិ** *ភ្លើង ៣ កងនោះ គឺ* **រាគគ្គិ ទោសគ្គិ មោហគ្គិ ៗ** *មាន ៣ កងទៀត គឺ* **អាហុនេយ្យគ្គិ គហបតគ្គិ ទក្ខិណេយ្យគ្គិ ៗ**

*មានបទវិគ្រោះថា* **រាគោ ច អនុឌហនដ្ឋេន អគ្គីតិ រាគគ្គិ** *ប្រែថា* **រាគោ ច** *រីរាគៈក្តី* **អគ្គិ** *ឈ្មោះថា ភ្លើង* **អនុឌហនដ្ឋេន** *ដោយអត្ថថា ដុតរឿយៗ* **ឥតិ** *ហេតុដូច្នោះ* **រាគគ្គិ** *ឈ្មោះថា រាគៈ អធិប្បាយថា* **រាគៈ** *ហៅថា ភ្លើង ព្រោះថា រាគៈនេះស្រួចស្រាល់ កាលបើកើតឡើងហើយក៏រមែងឆេះ រមែងដុតសន្តានសត្វមិនឲ្យដឹង ព្រោះយ៉ាងនោះ ទើបបានឈ្មោះថា ភ្លើងមួយកង ក្នុងបទ* **ទោស មោហ** *ក៏មានអធិប្បាយដូចគ្នា ៗ*

**ឥមានិ វត្ថូនិ** *ទើបនាំយករឿងរ៉ាវមកសម្តែងប្រាប្ថានឹងឲ្យយល់ថា ភ្លើងរាគៈនេះក្តៅខ្លាំងណាស់ មានភិក្ខុនីមួយរូប ទៅកាន់ពេង*

ឧបោសថនៅត្រង់ **ចិត្តបពិតវិហារ** ឈរសម្លឹងមើលរូបបុរសអ្នកយាមទ្វារ រាគៈខាងក្នុងរបស់ភិក្ខុនីនោះ មានកម្លាំងខ្លាំងក្លាកើតឡើង ព្រោះយ៉ាងនោះ គេជោជាតុដែលកើតពីរាគៈ ដុតបេះដូង និងសហជាតធម៌ដែលកើតព្រមដោយសភាវៈខ្លាំងក្លា ដូចគេជោជាតុខាងក្រៅដុតចេះទីជាទីកើត ទីជាទីនៅពេញកម្លាំង ព្រោះហេតុនោះ ភិក្ខុនីដែលត្រូវភ្លើងរាគៈដុតសន្តាន ក៏ធ្វើកាលកិរិយា រឿងរ៉ាវនេះនៅក្នុងអដ្ឋកថាទាំងឡាយ មានអដ្ឋកថា **សង្គីតិសូត្រ** ជាដើម ។

រឿងរ៉ាវដទៃទៀត អ្នកប្រាជ្ញគប្បីយល់ចូលចិត្តថា កើតព្រោះរាគៈដុតរោលដូចគ្នា **កិរ** បានឮមកថា ថ្ងៃមួយ ព្រះបាទសទ្ធាតិស្សៈមួយអន្ទើដោយស្រីស្នំជាបរិវារ ហែហមស្តេចយាងចេញទៅកាន់វិហារ **ឃកោ ឧបាកោ** ភិក្ខុកំលោះមួយរូប ឈរនៅត្រង់មាត់ទ្វារលោហប្រាសាទ មិនបានសង្រួមនូវឥន្ទ្រិយ ក្រឡេកឃើញស្ត្រីម្នាក់ ឯស្ត្រីក៏ចោលភ្នែកក្រឡេកមកមើលភិក្ខុកំលោះនោះវិញដែរ មើលទៅមើលមក រហូតញ៉ាំងអគ្គិរាគៈខាងក្នុងកើតឡើងដុតបេះដូងៗ ក៏រីងស្ងួត រាគៈនោះមានកម្លាំងខ្លាំងក្លា **កាលមកំសុ** ក៏ធ្វើកាលកិរិយាទាំងពីរនាក់ មានសម្តែងនៅក្នុង អដ្ឋកថាអង្គុត្តរនិកាយ ។

រឿងរ៉ាវមួយទៀត មានភិក្ខុកំលោះមួយរូប សម្តែងព្រះធម៌នៅក្នុង **មហាវិហារ** បរិស័ទទាំងឡាយក៏ប្រជុំគ្នាក្នុងវិហារ គ្រានោះព្រះបាទសទ្ធាតិស្សៈយាងមក មួយអន្ទើដោយស្រីស្នំ គង់ស្តាប់ព្រះធម៌ គ្រានោះ ព្រះរាជធីតាមានកម្លាំងរាគៈខ្លាំងក្លាកើតឡើង ព្រោះបានឃើញរូប បានស្តាប់សំឡេងភិក្ខុកំលោះសម្តែងព្រះធម៌ ។ ចំណែកភិក្ខុកំលោះសម្តែងព្រះធម៌បណ្តើរ ចៀងភ្នែកក្រឡេកមើលទៅប្រសព្វព្រះនេត្រព្រះនាង អព្ភន្តររាគៈមានកម្លាំងខ្លាំងក្លាកើតឡើងខាងក្នុងដរាបភ្លេចភ្លាំងនូវស្មារតី ព្រះមហាក្សត្រទ្រង់ទតឃើញ ព្រះអង្គកំណត់ហេតុការណ៍បានច្បាស់ **បរិក្ខិបាបេសិ** ទើបត្រាស់បញ្ជាឲ្យអមាត្យយករាំងននបាំង **តេ អញ្ញមញ្ញំ បរាមសិត្វា** ព្រះរាជធីតានិងភិក្ខុកំលោះក៏បានឱកាស ស្ទាបអង្អែល ឱបរឹតគ្នានិងគ្នា បន្ទាប់អំពីនោះមក ទើបព្រះរាជាមានព្រះរាជឱង្ការ ត្រាស់បញ្ជាឲ្យពួកអមាត្យបើករាំងននចូលទៅមើល ក៏ឃើញអ្នកទាំងពីរនាក់ធ្វើកាលកិរិយានៅក្នុងរាំងននទនោះ ។

**ឯកោ កិរ ទហរោ** នៅមានរឿងរ៉ាវមួយទៀត បានឮថាមានភិក្ខុកំលោះមួយរូប តាំងចិត្តទៅរៀនបាលី ទើបនិមន្តទៅកាន់

ទីឃវាបិវិហារ លុះទៅដល់ អាចារ្យយល់ថា អន្តរាយនឹងកើតមានដល់ភិក្ខុរូបនេះ ទើបមិនបានបង្រៀនបាលី ឯភិក្ខុរូបនោះប្រឹងប្រែងអង្វរ ទើបអាចារ្យឲ្យប្តេជ្ញាថា បើលោកមិននិមន្តចូលស្រុកដោយកិច្ចឯណានីមួយទេនោះទើបព្រមបង្រៀនឧទ្ទេស គឺបាលីដល់លោក ភិក្ខុរូបនោះទទួលពាក្យប្តេជ្ញាលោកអាចារ្យហើយ ក៏ឧស្សាហ៍រៀនសូធ្យ បានសម្រេចដូចសេចក្តីប្រាថ្នា ទើបថ្វាយបង្គំលាលោកអាចារ្យ រួចហើយដើរបណ្តើរទឹកបណ្តើរ ហេតុអ្វី លោកអាចារ្យហាមឃាត់អញមិនឲ្យចូលទៅកាន់ស្រុក ហេតុនោះនឹងមានដូចម្តេចហ្ន៎ គិតបណ្តើរ ឃ្លុំចីវរបណ្តើរ ហើយនិមន្តចូលទៅកាន់ស្រុក **ឯកា កុលធីតា** មានស្រីក្រមុំ នៅក្នុងត្រកូលមួយ ដណ្តប់សំពត់ពណ៌លឿងដូចមាសចេញមកឈរនៅក្បែរទ្វារផ្ទះ កាលបើក្រឡេកឃើញភិក្ខុកំលោះ ក៏មានចិត្តប្រតិព័ទ្ធខ្លាំងក្លា **សញ្ជាតរាគា** រាគៈកើតរួបរឹតពេញហឫទ័យព្រោះសេចក្តីស្នេហាដ៏ខ្លាំងក្លា ចំពោះភិក្ខុរូបនោះ **យាគុំ អាហរិត្វា** យកបាយ យកយាគូ មកដាក់បាត្រភិក្ខុនោះ រួចក៏ត្រឡប់ចូលទៅក្នុងបន្ទប់ ឡើងលើគ្រែដេក នឹកស្រមៃដល់ភិក្ខុរូបនោះ **អថ មាតា-បិតរោ** ពេលនោះ មាតា និងបិតាចូលទៅសាកសួរថា **អម្ម** នែកូន

ស្រីសម្លាញ់ កូនកើតអ្វី ឈឺអ្វី ? ទើបកុលធីតានោះ ប្រាប់បណ្តើរ យំបណ្តើរថា បពិត្រអ្នកម្តាយ ប្រសិនបើកូនមិនបានភិក្ខុកំលោះដែលបិណ្ឌបាតនោះមកធ្វើជាស្វាមីទេ ឃើញថា ជីវិតរបស់កូន មិនរួចពីសេចក្តីស្លាប់ឡើយ កូនសូមលាម៉ែពុកស្លាប់គ្រានេះហើយ ឯមាតាបិតាបានស្តាប់កូនពោលដូច្នោះ សម្លឹងមើលមុខគ្នាទៅវិញទៅមក ទើបប្រឹក្សាគ្នា កាលយល់ព្រមគ្នាស្រេចហើយ ក៏ចុះចាកផ្ទះម្នីម្នា រត់ទៅតាមទាន់ភិក្ខុកំលោះនោះនៅត្រង់ទ្វារស្រុក **វន្ទិត្វា** ថ្វាយបង្គំហើយ អង្វរថា សូមនិមន្តលោកម្ចាស់ត្រឡប់ទៅវិញ និមន្តទៅឆាន់ចង្ហាន់នៅផ្ទះរបស់ខ្ញុំព្រះករុណា **អលំ គច្ឆាមិ** អាត្មាមិនត្រឡប់ទៅទេ លោកម្ចាស់កុំដាច់មេត្តាកូនស្រីសម្លាញ់របស់ខ្ញុំព្រះករុណាឲ្យមក និមន្តលោកម្ចាស់ទៅ ញោមនេះមិនមែនមនុស្សក្រីក្រ អ្នកបម្រើ ភាជនៈប្រើប្រាស់មាសប្រាក់របស់ខ្ញុំមានច្រើន ឯកូនចៅរបស់ញោមសោតក៏មិនច្រើនដែរ មានកូនស្រីតែម្នាក់ ញោមនឹងចិញ្ចឹមអ្នកជាកូនច្បង រហូតមួយជីវិតមិនចាំបាច់ខ្វល់ខ្វាយលំបាកកាយឡើយ **ឥមេហិ ន មយ្ហំ** ទើបភិក្ខុកំលោះមានថេរវាចាថា នែឧបាសិកា អាត្មាភាពមិនត្រូវការ មិនពេញចិត្ត ព្រោះនេះជាបលិពោធទទេៗ មានព្រះថេរវាចាតែប៉ុណ្ណោះហើយ

ក៏មិនអើពើ ហើយក៏គេចចេញទៅ **មាតាបិតរោអាគន្ត្វា...** ។មាតាបិតាអស់សង្ឃឹម ត្រឡប់មកផ្ទះវិញ និយាយឲ្យកូនស្រីស្តាប់សព្វគ្រប់ហើយ ពោលថា **អម្ម** នែកូនសម្លាញ់ ម៉ែ និងពុក អង្វរលោកដល់ទីបំផុតហើយ លោកដាច់ខាតមិនអើពើ មិនត្រឡប់មកវិញ កូនកុំអន់ចិត្តធ្វើអ្វី ចូរកូនក្រោកឡើង បរិភោគបាយ ទឹកចុះ ម៉ែ និងពុកនឹងរកអ្នកណាឲ្យបានស្អាត តាមការពេញចិត្តរបស់កូនស្រីសព្វគ្រប់ប្រការ ។ **សា អធិច្ចន្តី** ធីតាបានស្តាប់ដូច្នោះ មិនត្រូវតាមបំណងបែរខ្នងហើយក៏ខ្សឹកខ្សួលទឹងចិត្ត អត់អាហារយូរដល់ ៧ ថ្ងៃ ភ្លើងរាគៈក៏ដុតបំផ្លាញ ពេលនោះនាងក៏អស់ជីវិតទៅ **តស្មា សរីរកិច្ចំ កត្វា** មាតាបិតាបញ្ចុះសពកូនស្រីក្រមុំរួចហើយ ទើបយកសំពត់ដណ្តប់នោះទៅប្រគេនដល់ភិក្ខុសង្ឃ ដែលនៅមិនឆ្ងាយពីទីនោះ **ខណ្ឌាខណ្ឌិកំ កត្វា** ភិក្ខុសង្ឃទាំងឡាយ ក៏កាត់សំពត់ដណ្តប់នោះជាកំណាត់ៗ រួចហើយចែកគ្នា ។ ភិក្ខុចាស់មួយរូប បានចំណែកកំណាត់សំពត់ជារបស់លោក ហើយក៏និមន្តទៅកាន់កល្យាណវិហារ **សោ តំ សុត្វា** កាលភិក្ខុកំលោះបានស្តាប់នូវព្រឹត្តិការណ៍ដូច្នោះ ទើបគិតតែក្នុងចិត្តថា អញមិនបានទៅរួមរស់ជាមួយនឹងនាងកុលធីតា ដែលប្រកបដោយចិត្តស្មោះ

ត្រង់ នាងស្មោះស្មគ្រស្រឡាញ់អញ រហូតធ្វើកាលកិរិយាដូច្នេះ មិនងាយនឹងរកបាន ។ ក្នុងខណៈនោះ ភ្លើងរាគៈដ៏ខ្លាំងក្លាកើតពីសេចក្តីស្រឡាញ់ចំពោះនាងកុលធីតាដ៏ក្រៃលែង ក៏ដុតបំផ្លាញហទយៈភិក្ខុកំលោះ រហូតធ្វើកាលកិរិយានៅក្នុងទីនោះ រឿងរ៉ាវនេះព្រះអដ្ឋកថាចារ្យនាំយកមកពី **អដ្ឋកថារថវិនីតសូត្រ** ក្នុង **គម្ពីរមជ្ឈិមនិកាយ** ដើម្បីឲ្យឃើញទោសរបស់រាគៈដោយប្រការដូច្នេះ អ្នកប្រាជ្ញគប្បីដឹងកិរិយា ដែលភ្លើងរាគៈដុតបំផ្លាញ ដូចរឿងទាំងឡាយដែលពោលមកនេះ ។

**ទោសស្ស បន អនុទហនតាយ** ប្រការមួយទៀត ទេវតាទាំងឡាយដែលជាមនោបទោសិកៈ គឺច្រើនដោយការក្រោធនោះ អ្នកប្រាជ្ញគប្បីជ្រាបក្នុងកិរិយា គឺ **ទោសោ** ដុតបំផ្លាញ **កិរ** បានឮមកថា មានទេវបុត្រមួយអង្គ ចង់ប្រពាតឧទ្យានដែលជាទីសប្បាយរីករាយ **សបរិវារោ** ជាមួយនឹងបរិវាររបស់ខ្លួន ចេញចាកវិមាន ឡើងកាន់ទិព្វរថទៅ **អថញ្ញោ និក្ខមន្តោ** ក្នុងលំដាប់នោះ មានទេវបុត្រមួយអង្គដទៃ បានចេញចាកទិព្វវិមានឡើងកាន់ទិព្វរថទៅ កាលបើក្រឡេកឃើញទេវបុត្រដែលទៅមុននោះ កើតការក្រោធឡើង ទើបពោលថា **ភោ** នៃលោកដ៏ចម្រើន ខ្លួនលោកនេះជាមនុស្សកំព្រា ឬមិនមែន

ទេ ពីមុនមកយើងក៏មិនដែលបានឃើញលោកទេ ថ្ងៃនេះ ម្ដេចក៏មកបង្ហាញខ្លួនឲ្យឃើញយ៉ាងនេះ ។ **ឧក្កុមារោវិយ** មានអាការប៉ោងឡើងដោយសេចក្ដីក្រេកអរដូច្នេះ **បុរតោ គច្ឆន្តោ** ទេវបុត្រដែលទៅមុនបែរក្រឡេកឃើញទេវបុត្រ ដែលមកក្នុងពេលខាងក្រោយ ហើយមានចិត្តក្រោធដល់ខ្លួននោះ ទើបគិតតែក្នុងចិត្តថា ឈ្មោះថាបុគ្គលអ្នកក្រោធនោះ នឹងមិនបានជាអ្នកបេះដឹងល្អអាក្រក់នោះទេ លុះដឹងថា ទេវបុត្រអង្គក្រោយនោះក្រោធនឹងខ្លួនហើយ **បដិកុជ្ឈ** ក៏ក្រោធតបវិញ ទើបមានវាចាថា **កុទ្ធោ ត្វំ មយ្ហំ កឹ ករិស្សសិ** លោកក្រោធនឹងយើងនេះ លោកនឹងធ្វើអ្វីដល់យើងបាន ក៏មិនអាចធ្វើអ្វីបានឡើយ **អយំ សម្បត្តិ** សម្បត្តិទាំងឡាយដែលយើងបាននេះយើងក៏បានដោយបុណ្យរបស់យើងអំពីកាលមុន យើងបានធ្វើទាន រក្សាសីល ទើបយើងបាននូវទិព្វសម្បត្តិដូច្នេះ យើងមិនបានដោយអំណាចបុណ្យរបស់លោកនោះទេ ។

មានពាក្យអធិប្បាយថា កាលបើទេវបុត្រមួយអង្គក្រោធទេវបុត្រមួយអង្គទៀតមិនបានក្រោធហើយ ក៏រក្សាជីវិតទុកបាន មិនចុតិព្រោះថា សេចក្ដីក្រោធរបស់ទេវបុត្រអ្នកក្រោធនោះ **អនុថានានោ**

មិនអាចជឿបាន មិនជាសេវនប្បច្ច័យ ព្រោះថា ក្រោធតែម្នាក់ឯង ក៏មិនអាចនឹងដុតបំផ្លាញឲ្យវិនាសបាន  អាការដែលមិនបានក្រោធតបនោះ នឹងរម្ងាប់រលត់នូវអាការដែលក្រោធអំពីមុនឲ្យស្ងប់ចុះ ជាការល្អ ឧទកន្តំ បត្វា អគ្គិវិយ ប្រៀបដូចភ្លើងដែលត្រូវទឹកហើយ ក៏រលត់សូន្យអស់កម្តៅ ហេតុដូច្នោះ ទេវបុត្រដែលមិនបានក្រោធតបនោះ ទើបជាបច្ច័យរក្សាជីវិតទេវបុត្រដែលក្រោធនោះមិនឲ្យចុតិ ក្នុងកាលទេវបុត្រទាំងពីរអង្គនោះក្រោធដល់គ្នានិងគ្នា  និងសេចក្តីក្រោធរបស់ទេវបុត្រមួយអង្គ  ជាបច្ច័យដល់សេចក្តីក្រោធរបស់ទេវ-បុត្រមួយអង្គទៀត  សេចក្តីក្រោធរបស់ទេវបុត្រអង្គក្រោយនោះកើតឡើងហើយ ក៏ជាបច្ច័យដល់ទេវបុត្រអង្គមុន ទើបឆេះរោលរាលអាស្រ័យមាននូវសេចក្តីក្រោធច្រើន ។

**មោហាសុ្ស បន អនុទហាន្តាយ ខិឌ្ឌាបទោសិកា ទេវា ធន្ធញ្ញា** ម្យ៉ាងទៀត ទេវតាទាំងឡាយ ដែលជាខិឌ្ឌាបទោសិកៈនោះរីករវើករាយក្នុងបញ្ចកាមគុណ ភ្លេតភ្លើនរូបហើយចុតិ ការពិត អាការដែលគ្មាននូវស្មារតីរបស់ទេវបុត្រទាំងឡាយ  ដែលជាខិឌ្ឌាបទោសិកៈនោះ តែងតែកើតរឿយៗ ដោយអំណាចនៃសេចក្តីប្រមាទ ស្រវឹងទៅ

ក្នុងបញ្ចកាមគុណ ដោយសប្បាយលេងច្រៀងរាំ ប្រគំតូរ្យតន្ត្រីជាច្រើន ព្រោះហេតុដូច្នោះ ទេវតាទាំងឡាយដែលជាខិឌ្ឌាបទោសិកៈនោះ ភ្លេចបរិភោគអាហារ ដោយអំណាចនៃកិរិយាដែលលេងបញ្ចកាមគុណ វង្វេងតែនៅក្នុងរូប សំឡេង ក្លិន រស សម្ផស្ស ទើបចុតិចាកឋានសួគ៌ អាការដែលលេងបញ្ចកាមគុណនោះ ឈ្មោះថា **ខិឌ្ឌា** អាការដែលគ្មាននូវស្មារតី ធ្វើការប្រទូស្តនោះ ឈ្មោះថា **បទោសិក** គឺរំលងពេលសោយអាហារ កាលភ្លើតភ្លើនទៅក្នុងបញ្ចកាមគុណ រហូតភ្លេចពេលសោយអាហារទិព្វហើយ ក៏រមែងចុតិ ។

**តេកិរ បុញ្ញវិសេសាធិគតេន មហន្តេន អត្តនោ សិរិវិភវេន ឆក្ខត្តុំ កីឡន្តា** បានឮមកថា ទេវតាទាំងឡាយដែលជាខិឌ្ឌាបទោ-សិកៈនោះ កាលបើលេងនក្ខត្តឫក្សជាមហោស្រពសប្បាយរីករាយនៅក្នុងឋានសួគ៌ ដែលមានតន្ត្រីប្រកបដោយអង្គ ៥ ដេញដំប្រគំកូតមានប្រការផ្សេងៗ ដោយសិរីសម្បត្តិរបស់ខ្លួន ដែលបានដោយបុញ្ញា-នុភាពវិសេសផ្សេងគ្នា ភ្លើតភ្លើន រហូតភ្លេចសោយអាហារ ព្រោះថាសិរីសម្បត្តិនោះមានច្រើន ទើបភ្លេចសតិមិនបានដឹងថា ខ្លួនបរិភោគអាហារហើយ ឬនៅមិនទាន់បានបរិភោគអាហារប្រការណា ទេវតា

ទាំងឡាយរមែងសោយនូវរសទិព្វរឿយៗ ជានិច្ច មិនចន្លោះថ្ងៃទេ ចាប់ផ្តើមពីកន្លងពេលសោយនូវអាហារទិព្វតែមួយពេលក៏ចុតិ មិនអាចទ្រទ្រង់នៅបាន **កស្មា** ព្រោះហេតុអ្វី ទេវតាទាំងឡាយតែងកន្លងពេលសោយនូវអាហារទិព្វតែមួយពេលប៉ុណ្ណោះក៏ចុតិតាំងនៅមិនបាន ? វិសជ្ជនាថា ទេវតាទាំងឡាយ មានករជកាយល្អិតក្រៃលែងណាស់ តេជោធាតុដែលកើតអំពីកម្មមានកម្លាំងខ្លាំងក្លា កាលបើទេវតាទាំងឡាយភ្លេចបរិភោគនូវអាហារទិព្វតែមួយពេលប៉ុណ្ណោះក៏ចុតិ មិនអាចតាំងនៅបានឡើយ ព្រោះថា ទេវតាទាំងឡាយមានភ្លើងធាតុខ្លាំងក្លាក្រៃលែង ដុតបំផ្លាញនូវករជកាយដ៏ល្អិតសុខុមនោះ ឲ្យជាធូលីខ្ទេចខ្ទីដល់នូវចុតិ ការពិតមនុស្សទាំងឡាយមានភ្លើងធាតុដែលកើតអំពីកម្មខ្សោយ ឯករជកាយនោះ មានកម្លាំងខ្លាំងក្លា ទោះបីមិនបានបរិភោគកន្លងទៅអស់ ៧ ថ្ងៃ ប៉ុន្តែបានបរិភោគទឹក ទឹកបាយ ទឹកបបរ ទឹកដោះថ្លាក្តី ជាដើមត្រឹមតែប៉ុណ្ណោះ ក៏អាចនឹងទ្រទ្រង់រាងកាយ និងហទយវត្ថុបានដែរ គឺមិនស្លាប់ ព្រោះហេតុថា មនុស្សទាំងឡាយមានតេជោធាតុដែលកើតអំពីកម្មទន់ខ្សោយ ឯករជកាយមានកម្លាំងខ្លាំងក្លា ទើបទ្រទ្រង់នូវរាងកាយ ទ្រទ្រង់នូវជីវិតបាន រហូតដល់អត់អាហារសូម្បីអស់ ៧ ថ្ងៃ បានត្រឹមតែ

ទទួលទានទឹក ទឹកបបរជាដើមប៉ុណ្ណោះ ក៏មិនស្លាប់ដែរ **ទេវានំ បន តេជោ ពលវា ហោតិ** ឯទេវតាមានតេជោធាតុនោះខ្លាំងក្លា ព្រោះថា តេជោធាតុនោះកើតជាទិព្វ កើតដោយអានុភាពដ៏ក្រៃលែងផង ព្រោះហេតុថា កងបុណ្យដ៏ក្រៃលែងនោះ ញុំាងទិព្វសុធាភោជនាហារឲ្យកើតឡើង បរិសុទ្ធល្អល្អិតសុខុមក្រៃលែងដោយវិសេសផង ទើបទេវតាទាំងឡាយបរិភោគនូវអាហារជារឿយៗ នឹងបានជាទីឧបត្ថម្ភគាំទ្រជីវិតបាន មួយទៀតសោត ទាំងករជកាយនោះ ក៏ជាទិព្វល្អិតសុខុមក្រៃលែង ព្រោះហេតុដូច្នោះ ទើបមាននូវសេចក្តីអធិប្បាយថា **ភគវា** រីព្រះមានព្រះភាគ កាលព្រះអង្គគង់នៅឥន្ទសាលគុហា គ្រានោះ ទ្រង់ប្រឈួនធ្លាក់ព្រះលោហិត ព្រះឥន្ទ្រាធិរាជចុះមកធ្វើជាវេយ្យាវច្ចករឧបដ្ឋាកបម្រើព្រះមានព្រះភាគ ទើបមានព្រះពុទ្ធដីកា ត្រាស់ជាស់តឿនព្រះឥន្ទ្រថា ព្រះអង្គមិនអាចនឹងនៅលើផែនដីដ៏រឹងជាប្រក្រតីបានឡើយ **ឱឡារិកាយំ អធិដ្ឋាហិ** ម្នាលទេវរាជ ព្រះអង្គចូរអធិដ្ឋាននូវករជកាយរបស់ព្រះអង្គឲ្យគ្រោតគ្រាតជាងមុន ទើបនឹងអាស្រ័យនៅលើផែនដីដ៏គ្រោតគ្រាតបាន ព្រះពុទ្ធដីកាដែលត្រាស់ដូច្នេះ ព្រោះថា ព្រះលោកនាថយល់ករជកាយរបស់ព្រះឥន្ទ្រនោះល្អិតសុខុម

ក្រៃលែង **តស្មា** ព្រោះហេតុនោះ ទេវតាទាំងឡាយដែលជាពួក ខិឌ្ឌាបទោសិកៈនោះ កាលបើភ្លើតភ្លើនក្នុងការលេងបញ្ចកាមគុណ រហូតភ្លេចពេលបរិភោគអាហារ កាលបើហួសពេលបរិភោគអាហារ ទិព្វទៅហើយ ក៏មិនអាចដើម្បីនឹងទ្រទ្រង់កាយទុកបាន មានសេចក្តី ឧបមាថា ផ្កាបទុមជាតិក្តី ផ្កាឧប្បលជាតិក្តី បុគ្គលយកទៅដាក់លើ ផ្ទាំងថ្មដ៏ក្តៅនាពេលថ្ងៃត្រង់ ក្នុងគិម្ហរដូវ ទោះបីបុគ្គលយកទឹកទៅ ស្រោចស្រូបមួយរយឆ្នាំងក្តី មួយពាន់ឆ្នាំងក្តី ក៏មិនបានស្រស់ឡើងវិញ ដូចប្រក្រតីដើម គង់នឹងវិនាសទៅដោយពិត ។ **យថា ឆាម** មានឧបមា យ៉ាងណា កាលទេវតាទាំងឡាយកន្លងពេលសោយអាហារហើយ ខាងក្រោយមក សូម្បីទេវតានោះសោយ ១០០ ដង ១០០០ ដង គ្មានចន្លោះក្តី ក៏គង់តែចុតិដោយពិត មិនអាចតាំងនៅបានឡើយ មាន ឧបមេយ្យដូច្នោះ ។

មានពាក្យសួរថា វត្ថុដូចម្តេច ដែលជាអាហាររបស់ទេវតា ទាំងឡាយ ការសោយអាហារនោះនៅពេលណា ?

មានចម្លើយថា *សុធាភោជនាហារ* ដែលជារបស់ទិព្វបរិសុទ្ធ ពិត ជាអាហាររបស់ទេវតាទាំងឡាយ ដែលនៅក្នុងឆកាមាវចរសួគ៌

*ទាំង ៦ ជាន់ ទិព្វសុធាភោជនាហាររបស់ទេវតាទាំងឡាយដែលនៅជាន់លើៗ* **បណីតុត្តមា** *ប្រណីតឧត្តមក្រៃលែងជាងទិព្វសុធាភោជ-នាហាររបស់ទេវតាទាំងឡាយ ដែលនៅក្នុងស្ថានសួគ៌ជាន់ទាបៗ ទេវតាទាំងឡាយនោះបរិភោគអាហារទិព្វរាល់ថ្ងៃ ដោយអំណាចថ្ងៃក្នុងស្ថានសួគ៌របស់ខ្លួន មិនបានដាច់សូម្បីមួយពេលឡើយ ។*

*ព្រះអដ្ឋកថាសម្ដែងទុកក្នុង ព្រហ្មជាលសូត្រ ថា* **កេចិ បន វិឡារបនប្បមាណំ សុធាហារំ បរិភុញ្ជន្តិ** *ទេវតាទាំងឡាយពួកខ្លះបរិភោគនូវសុធាភោជនាហារបន្តិចបន្តួច ប្រមាណប៉ុនដានជើងឆ្មាក៏មាន ប្រមាណប៉ុនឆ្មាស៊ីអាហារម្ដងក៏មាន* **សោ ជិវ្ហាយ ឋបិតមត្តោ** *អាហារទិព្វ គ្រាន់តែដាក់ចុះលើអណ្ដាតក៏ផ្សាយជ្រួតជ្រាបសព្វកាយ រហូតដល់ទីបំផុតចុងសក់ចុងក្រចក ។ ទេវតាទាំងឡាយដែលជាពួកខិឌ្ឌា-បទោសិកៈនោះនៅជាន់ចាតុម្មហារាជិកា ទេវតាទាំងឡាយដែលជាពួកខិឌ្ឌាបទោសិកៈនោះ ចិញ្ចឹមជីវិតដោយកពឡិង្ការាហារបរិភោគជាពំនូតៗ ដូចមនុស្សបរិភោគអាហារដូច្នោះ អ្នកប្រាជ្ញគប្បីជ្រាបចុះថា ទេវតាទាំងឡាយនោះ រមែងធ្វើនូវកិច្ចយ៉ាងនេះ សេចក្ដីទាំងនេះព្រះ-ននូាចារ្យសម្ដែងទុកក្នុងដីកានៃព្រះវិន័យ រឿងរ៉ាវដែលសម្ដែងអំពីទេវតា*

ទាំងឡាយដែលជាទិដ្ឋាបទោសិកៈនោះ ដើម្បីនឹងឲ្យឃើញនូវមោហៈ ដែលកើតជាភ្លើងមួយកង ក្នុងកិរិយាដុតបំផ្លាញករជកាយរបស់ទេវតាទាំងឡាយឲ្យដល់នូវសេចក្ដីវិនាសហើយ ចុតិចាកស្ថានសួគ៌ ។

**អាហុណេយ្យគ្គីតិ អាទីសុ** ពេលនេះនឹងវិនិច្ឆ័យនៅក្នុងបទទាំងឡាយជាដើមថា **អាហុណេយ្យគ្គិ** នោះ **អាហុណំ វុច្ចតិ** គ្រឿងសក្ការបូជារបស់របរវិសេសៗ ផ្សេងៗ គឺបាយ ទឹក នំ ចំណីបរិភោគនោះ អ្នកប្រាជ្ញគប្បីពោលថា **អាហុន អាហុន** នោះ បានដល់របស់របរគ្រឿងសក្ការគោរពបូជាទាំងឡាយ មានបទវិគ្រោះថា **យេ ជនា** វីជនទាំងឡាយណា **អរហន្តិ** សមគួរទទួល **តំ អាហុនំ** នូវគ្រឿងបូជានោះ **ឥតិ** ព្រោះហេតុដូច្នេះ **តេ ជនា** វីជនទាំងឡាយនោះ **អាហុនេយ្យា** ឈ្មោះថា អាហុនេយ្យ **ជនា** វីជនទាំងឡាយ **អាហុនេយ្យា** សមគួរទទួលនូវគ្រឿងសក្ការបូជា អធិប្បាយថា មាតានិងបិតាទាំងឡាយ សមគួរទទួលនូវគ្រឿងសក្ការបូជា របស់បុត្រទាំងឡាយ ព្រោះថា មាតា និងបិតាទាំងឡាយនោះ មានឧបការៈដល់បុត្រទាំងឡាយយ៉ាងច្រើន កាលបុត្រទាំងឡាយបដិបត្តិខុសចំពោះមាតាបិតាទាំងឡាយហើយ ក៏នឹងទៅកើតក្នុងអបាយភូមិទាំង ៤ មាន

នរកជាដើម **តស្មា** ព្រោះហេតុនោះ មាតា និងបិតាទាំងឡាយ នឹងមិនបានដុតបំផ្លាញនូវកូនទាំងឡាយឲ្យក្តៅឆេះជារឿយៗ នោះទេ ប៉ុន្តែគឺមាតាបិតាទាំងឡាយ កើតជាបច្ច័យដល់កិរិយាដ៏ក្តៅឆេះជារឿយៗ មាតាបិតាទាំងឡាយ ទើបអ្នកប្រាជ្ញពោលថា **អាហុនេយ្យគ្គិ** ដោយសភាវៈជាកិរិយាដែលដុតឲ្យក្តៅជារឿយៗ ដោយប្រការដូច្នេះ ។

**សោ អយំ អត្ថោ** សេចក្តីនេះអ្នកប្រាជ្ញគប្បីជ្រាបដោយរឿងមិត្តវិន្ទុកនោះចុះ មានសេចក្តីអធិប្បាយថា មិត្តវិន្ទុកនោះជាបុត្រអ្នកមានត្រកូលមួយ មាតាបានពោលប្រៀនប្រដៅថា **តាត** ហៃ កូនសម្លាញ់ ថ្ងៃនេះជាថ្ងៃឧបោសថ ចូរកូនរក្សាឧបោសថសីលចុះ យប់នេះចូរទៅស្តាប់ព្រះធម៌ទេសនាក្នុងវិហារ កាលជិតភ្លឺហើយត្រឡប់មកផ្ទះវិញ ម្តាយនឹងឲ្យទ្រព្យមួយពាន់ដល់អ្នក **ធនលោភេន** មិត្ត-វិន្ទុកឃើញទ្រព្យមួយពាន់ **ឧបោសថំ សមាទាយ** ទើបសមាទានឧបោសថសីល រួចហើយក៏ទៅកាន់វិហារ ពិចារណាថា កន្លែងខាងក្រោមធម្មាសនៈនេះ ជាកន្លែងប្រាសចាកភ័យ ក៏ចូលទៅដេកនៅខាងក្រោមធម្មាសនៈនោះ **សព្វរត្តឹ និទ្ទាយិត្វា** ដេកលក់ទល់ភ្លឺហើយក៏ត្រឡប់មកកាន់ផ្ទះតាំងអំពីព្រឹកព្រលឹមមាតាក៏រៀបចំដាំបាយ-បបរឆ្អិន

ហើយក៏លើកយកមកឲ្យ មិត្តវិន្ទុកនិយាយថា សូមម៉ែឲ្យទ្រព្យមួយពាន់ជាមុនសិន ទើបខ្ញុំបរិភោគ បើមិនបានទ្រព្យមួយពាន់ជាមុនទេ ខ្ញុំក៏មិនបរិភោគនេះដែរ ពោលបញ្ជាក់ប្រាប់ម្តាយដូច្នេះ ម្តាយក៏ឲ្យទ្រព្យមួយពាន់ ។ មិត្តវិន្ទុកបានទ្រព្យមួយពាន់ ទើបគិតថា ទ្រព្យរបស់អញនេះក៏មានហើយ សមគួរអញទៅធ្វើជំនួញប្រមូលទ្រព្យមកឲ្យច្រើន មិត្តវិន្ទុកមានសេចក្តីប្រាថ្នា ដើម្បីនឹងទៅជំនួញតាមសំពៅជាមួយពួកនាយពាណិជទាំងឡាយ ។

**អថ នំ មាតា** លំដាប់នោះ ទើបមាតាហាមឃាត់ថា **តាត** ហៃកូនសម្លាញ់ ក្នុងត្រកូលរបស់យើងនេះមានទ្រព្យដល់ ៤០ កោដិហើយ ក៏កូនឯងទៅជួញតាមសំពៅនោះត្រូវការអ្វីទៀត កូនកុំទៅអីម៉ែមិនឲ្យកូនទៅទេ **សោ តស្សា វចនម្បិ អនាទយិត្វា** មិត្តវិន្ទុកមិនបានស្តាប់ពាក្យមាតាហាម ទៅជួញតាមសំពៅទាល់តែបាន គ្រានោះមាតាស្ទាក់ផ្លូវពីមុខ ក៏មានចិត្តក្រោធចំពោះមាតា ពោលថា ម៉ែមករាំងពីមុខកូនធ្វើអ្វី រំពេចនោះ មិត្តវិន្ទុកជាក់ម្តាយខ្ទេចឯងឲ្យដួលហើយក៏លោតកន្លងម្តាយទៅ **ឧដ្ឋហិត្វា** កាលមាតាក្រោកឡើងនិយាយថា កូនមកជាក់ម៉ែឲ្យដួលដូច្នេះ កូនទៅធ្វើជំនួញតាមសំពៅ

នោះ  កូនមាននូវសេចក្ដីសុខក្នុងកិរិយាដែលនឹងទៅជួញតាមសំពៅនោះបានដូចម្ដេច បើកូនធ្វើចំពោះម៉ែដូច្នេះទៅហើយ  កូនកុំសម្គាល់ថានឹងបានសេចក្ដីសុខ  កូនទៅពេលនេះ  មិនមានសេចក្ដីសុខឡើយ  ។ កាលមិត្តវិន្ទុកឡើងសំពៅទៅបាន ៧ ថ្ងៃ សំពៅក៏កឿងមិនទៅមុខ  ។

**អថ តេ មនុស្សា** គ្រានោះ មនុស្សទាំងឡាយក៏តក់ស្លុតចិត្តទើបប្រឹក្សាគ្នាថា ក្នុងសំពៅប្រហែលជាមានមនុស្សចង្រៃ កាឡកណ្ណីពិតប្រាកដហើយពួកយើងទាំងអស់គ្នាចូរចែកស្លាកឲ្យគ្រប់គ្នា **សលាកំ និយមានោ** កាលពួកពាណិជទាំងឡាយ  ចែកឲ្យដល់គ្នានិងគ្នា  ស្លាកកាឡកណ្ណីនោះបានធ្លាក់ដល់មិត្តវិន្ទុក  ៣ ដង  ពួកពាណិជទាំងឡាយក៏ដឹងថា មិត្តវិន្ទុកជាមនុស្សអាក្រក់ចង្រៃពិត **ឧលុម្បំ ឧត្វា** ទើបចាត់ចែងក្បូនតូចមួយឲ្យដល់មិត្តវិន្ទុក បន្ទាប់មកក៏ទម្លាក់ចុះទៅលើក្បូនតូចបណ្ដែតទៅក្នុងមហាសមុទ្រ **សោ ឯកំ ទីបំ បត្វា** កាលបើមិត្តវិន្ទុកចុះកាន់ក្បូនតូចអណ្ដែតមកដល់កោះមួយ  ក៏បានសោយទិព្វសម្បត្តិជាមួយនាងវិមានិកប្រេតទាំងឡាយ  មិត្តវិន្ទុកចង់ទៅកាន់វិមានិកប្រេតដទៃ  ទើបនាងវិមានិកប្រេតហាមថា  ចូរកុំទៅខាងមុខទៀតឡើយមិត្តវិន្ទុកក៏មិនស្ដាប់  បានចេញទៅ  ក៏ទទួលនូវទិព្វសម្បត្តិច្រើន

ជាទ្វេដង ហើយទៅដោយលំដាប់ៗ ទើបឃើញប្រេតម្នាក់មានចក្រវិល នៅលើក្បាល ចក្រដែលវិលនោះប្រាកដដល់មិត្តវិន្ទុក ហាក់បីដូច បទុមជាតិដ៏ស្អាត ទើបមិត្តវិន្ទុកពោលដល់ប្រេតនោះថា **ភោ បុរិស** ហៃបុរសដ៏ចម្រើន សូមអ្នកឲ្យផ្កាបទុមជាតិ ដែលអ្នកប្រដាប់នៅលើ ក្បាលនោះដល់ខ្ញុំម្តង ទើបបុរសជាប្រេត ពោលថា ហៃអ្នកជាសម្លាញ់ ផ្កាបទុមជាតិនេះ មិនមែនជាផ្កាឈូកពិតទេ ផ្កាឈូកនេះមិនមែនជទៃ ឆ្ងាយ គឺចក្រដែលមានមុខដ៏មុត ទើបមិត្តវិន្ទុកពោលថា អ្នកមិនចាំ បាច់មកបោកបញ្ឆោតខ្ញុំទេ ខ្ញុំស្គាល់ច្បាស់ណាស់ អ្នកប្រដាប់ដោយ ខ្លឹមចន្ទន៍ក្រហម មានក្លិនក្រអូបផ្សាយចេញទៅ អ្នកមិនចង់ឲ្យខ្ញុំ ទើបអ្នកបោកបញ្ឆោតថា ចក្រក្រុត ដូច្នេះ ទើបប្រេតនោះគិតថា ប្រហែលមាណពនេះ ជាមនុស្សប្រទូស្តជាមួយមាតារបស់ខ្លួនដូច អញហើយមើលទៅ ទើបឃើញចក្រនេះថាជាផ្កាបទុមជាតិ មកអង្វរ សុំអញដូច្នេះ ទើបបុរសជាប្រេតនោះពោលថា **ហន្ទ** ណ្ហើយចុះ អ្នកឯងជាមនុស្សចង្រៃ ចូរទទួលយកចុះ ពោលរួចហើយ ក៏បោះ ចក្រនោះដាក់ទៅលើក្បាលរបស់មិត្តវិន្ទុក ។ មិត្តវិន្ទុកក៏សោយទុក្ខ វេទនាតទៅ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្តែងនិគមគាថា

ថា ៖-

ចតុព្ភិ អដ្ឋជ្ឈគមា អដ្ឋាកបិ ច សោឡស
សោឡសាបិ ច ទ្វត្តឹសា អត្រិច្ឆំ ចក្កមាសទោ
ឥច្ឆាហាតស្ស បោសស្ស ចក្កំ ភមតិ មត្ថកេ។

អធិប្បាយថា មិត្តវិន្ទុកបានទៅសោយទិព្វសម្បត្តិជាមួយនាងវិមានិកប្រេតទាំងឡាយ ៤ នាក់ ចេញចាកពីនាងវិមានិកប្រេតទាំង ៤នាក់នោះហើយ ក៏បានទៅសោយទិព្វសម្បត្តិជាមួយវិមានិកប្រេត ៨ នាក់ ចេញពីវិមានិកប្រេតទាំង ៨ នាក់នោះហើយ ក៏បានទៅសោយទិព្វសម្បត្តិជាមួយនាងវិមានិកប្រេតទាំង ១៦ នាក់ទៀត លុះចេញចាកនាងវិមានិកប្រេតទាំង ១៦ នាក់នោះហើយ ក៏ទៅសោយទិព្វសម្បត្តិជាមួយនាងវិមានិកប្រេត ទាំង ៣២ នាក់ ។ កាលមាននូវសេចក្តីប្រាថ្នាច្រើនដូច្នោះហើយ **ចក្កមាសទោ** ក៏ទៅដល់កន្លែងចក្រៗ នោះ ក៏វិលនៅលើក្បាលរបស់មិត្តវិន្ទុក អ្នកជាបុត្រថោកទាបលាមក ជាមនុស្សតាំងនៅក្នុងសេចក្តីលោភ ជាអ្នកបៀតបៀនដល់ម្តាយ ដែលជាភ្លើងមួយកង អ្នកណា បានបដិបត្តិខុសដូចមិត្តវិន្ទុកនេះ អ្នកនោះក៏នឹងបាននូវសេចក្តីក្តៅក្រហាយសោយនូវទុក្ខ ដូចមិត្តវិន្ទុកដូច្នេះឯង ។

ម្យ៉ាងទៀត បុរសជាធំក្នុងផ្ទះ គឺស្វាមីនោះ លោកអាចារ្យសម្ដែងថាជាភ្លើងមួយកង ឈ្មោះគហបតគ្គិ គហបតីអ្នកជាស្វាមី ឈ្មោះថាភ្លើងនោះ **ពហូបការោ** រមែងមាននូវគុណូបការៈចំពោះមាតុគ្រាមច្រើន ព្រោះជាអ្នកតាក់តែងនូវទីដេក និងសម្លៀកបំពាក់ និងគ្រឿងប្រដាប់មានប្រការផ្សេងៗ **តំ អតិចរន្តោ** កាលមាតុគ្រាម ជាភរិយាប្រព្រឹត្តល្មើសចំពោះស្វាមីនោះហើយ ក៏នឹងទៅកើតក្នុងអបាយភូមិទាំង ៤ **តស្មា** ព្រោះហេតុនោះ គហបតីអ្នកជាស្វាមីនោះ ទើបឈ្មោះថា **គហបតគ្គិ** ថាជាភ្លើងមួយកង ព្រោះថា ភ្លើង គឺគហបតីនេះ រមែងដុតជារឿយៗ ដោយន័យដែលពោលរួចមកហើយអំពីមុន រឿងរ៉ាវនិទានរបស់គហបតីអ្នកជាស្វាមី ហៅថា ភ្លើងមួយកងនោះ អ្នកប្រាជ្ញគប្បីជ្រាបយ៉ាងនេះ ។

**កស្សបពុទ្ធកាលេ** ក្នុងកាលសាសនានៃព្រះកស្សបសព្វញ្ញូដ៏ប្រសើរ មានភរិយារបស់ឧបាសកម្នាក់ ប្រព្រឹត្តល្មើសចំពោះស្វាមីជាសោតាបន្ន គឺថា ប្រព្រឹត្តខុសក្នុងការសេពសន្ធាសដោយបុរសដទៃ **សោ តំ បច្ចក្ខតោ ទិស្វា** ឧបាសកជាស្វាមីនោះបានឃើញច្បាស់ទើបពោលថា **កស្មា ករោជ** ហេតុដូចម្ដេច ទើបនាងប្រព្រឹត្តក្បត់

ចិត្តខ្ញុំ ដូច្នេះ ឯភរិយាក៏មិនបានសារភាព ទើបចង្អុលសម្គាល់សុនខ កំបុតត្រចៀកមួយនៅក្បែរនោះ ហើយក៏ស្បថថា បើខ្ញុំនេះប្រព្រឹត្ត ក្បត់ចិត្តអ្នកជាស្វាមីហើយ សូមឲ្យសុនខកំបុតត្រចៀកនេះខាំស៊ីខ្ញុំជា អាហារចុះ កាលស្ត្រីនោះស្បថដោយពាក្យមិនពិតដូច្នេះ **កាលំ កត្វា** លុះធ្វើកាលកិរិយាទៅហើយ ក៏បានទៅកើតជានាងវិមានិកប្រេតនៅ ក្បែរស្រះកណ្ណមុណ្ឌទហៈ ក្នុងព្រៃហិមពាន្ត បានសោយទិព្វសម្បត្តិ នៅពេលថ្ងៃ បានសោយនូវសេចក្តីទុក្ខនៅពេលយប់ លុះរាត្រីកាល ចូលមកដល់ ក៏ចុះចាកវិមានទៅកាន់ទីក្បែរកណ្ណមុណ្ឌទហៈ ។

**អថ ឧហាតោ** លំដាប់នោះ មានសុនខសម្បុរខ្មៅខ្ពស់ធំមួយ មានស្លឹកត្រចៀកកំបុតរត់មកអំពីស្រះនោះ បានចូលមកខាំស៊ីសាច់ នាងវិមានិកប្រេត សំឡេងមាត់សុនខនោះឮក្រិបៗ សុនខស៊ីសាច់ និងឈាមសល់តែឆ្អឹង ទើបពាំឆ្អឹងនោះទៅបោលក្នុងទឹក បន្ទាប់មក សុនខនោះក៏អន្តរធានបាត់សូន្យទៅ កាលឆ្អឹងធ្លាក់ទៅក្នុងស្រះទឹក នាងវិមានិកប្រេតក៏ត្រឡប់មានរូបកាយសាដូចដើម ហើយក៏ត្រឡប់ ទៅកាន់វិមានរបស់ខ្លួនវិញ ។

ក្នុងកាលនោះ ព្រះរាជាក្នុងក្រុងពារាណសី **មិគវនំ ចរន្តោ**

កាលបើព្រះអង្គយាងទៅប្រពាតព្រៃ ដេញម្រឹគទៅក្នុងព្រៃដោយលំដាប់ ស្ដេចក៏យាងទៅដល់ស្រះនោះ ព្រះបាទពារាណសី ក៏បានសោយទិព្វសម្បត្តិ ជាមួយនឹងនាងវិមានិកប្រេតនោះ នាងវិមានិកប្រេត កាលនៅសេពសង្វាសជាមួយព្រះបាទពារាណសី លុះដល់ពេលយប់ហើយ ក៏គេចពីព្រះបាទពារាណសី ចុះចាកវិមានទៅសោយនូវសេចក្ដីទុក្ខ ឲ្យសុនខខាំស៊ី **សោ ញត្វា** ព្រះបាទពារាណសី ព្រះអង្គទ្រង់ជ្វល់ ដល់ពេលយប់ហើយ ស្រីនេះទៅទីណា ព្រះអង្គត្រិះរិះដូច្នេះហើយ ក៏ទ្រង់ឃ្លាំចាំមើល ទ្រង់យាងតាមនាងវិមានិកប្រេតពីក្រោយ **អវិទូរេ ឋិតោ** ស្ដេចទៅឈរអែបក្នុងទីមិនជិតពេក មិនឆ្ងាយពេក ទើបឆ្មៀងព្រះនេត្រឃើញសុនខចេញមកពីស្រះ ចូលទៅខាំនាងវិមានិកប្រេតនោះ ព្រះអង្គក៏ទ្រង់កាប់សុនខឲ្យដាច់ជាពីរកំណាត់ដោយព្រះខ័នដ៏មុត **ទេ្វ អហេសុំ** សុនខមួយក៏កើតជាសុនខពីរ ព្រះអង្គក៏ទ្រង់កាប់សុនខទាំងពីរនោះទៀត ក៏កើតឡើងជា ៤ ព្រះអង្គក៏កាប់ទាំង ៤ នោះឲ្យស្លាប់ទៀត សុនខក៏កើតឡើងជា ៨ ព្រះអង្គក៏ទ្រង់កាប់សុនខទាំង ៨ នោះឲ្យស្លាប់ សុនខក៏កើតឡើងជា ១៦ ។ ទើបនាងវិមានិកប្រេតប្រាប់ថា **សាមិ** បពិត្រអយ្យបុត្រ ព្រះអង្គយាងមកធ្វើអ្វី ទើបព្រះបាទពារាណសី

ត្រាស់ថា **កឹ ឥទំ** សុនខនេះមកអំពីទីណា មិនមែនកម្ម មិនមែនពៀរទេ ឬប្រការណា ទើបនាងវិមានិកប្រេតក្រាបទូលថា ព្រះអង្គកុំកាប់ដោយព្រះខ័នឡើយ សូមព្រះអង្គស្តោះទឹកមាត់លើផែនដីហើយសូមព្រះអង្គយកព្រះបាទជាន់ញី **សោ តថា អកាសិ** ព្រះបាទពារាណសី ក៏ធ្វើតាមដូច្នោះ សុនខទាំងឡាយក៏បាត់អស់ទៅ **តំ ទិវសំ** ក្នុងថ្ងៃនោះ នាងវិមានិកប្រេតក៏អស់កម្ម ព្រះបាទពារាណសីក៏ទ្រង់បានរង្កៀសនឹងនាងវិមានិកប្រេត ព្រះអង្គសង្ស័យក្នុងព្រះទ័យ ទ្រង់ប្រារព្ធដើម្បីនឹងចេញចាកអំពីនាងវិមានិកប្រេតនោះ ទើបនាងពោលអង្វរថា **សាមិ** បពិត្រព្រះអង្គជាស្វាមីកម្មរបស់ខ្ញុំម្ចាស់អស់ហើយ សូមព្រះអង្គកុំត្រឡប់ទៅកាន់ប្រទេសរបស់ព្រះអង្គឡើយ ព្រះបាទពារាណសីព្រះអង្គមិនស្តាប់ ព្រះអង្គក៏ចេញចាកអំពីនាងវិមានិកប្រេតនោះ ដោយអាការដែលស្តោះទឹកមាត់នោះ ជាឧបាយប្រៀបដូចជាក្តាប់ដៃទទេ ឧបាយដូច្នេះ ឈ្មោះថា **មុដ្ឋិយោគ** គឺប្រកបដោយឧបាយទទេៗ តែជាកលល្បិចប៉ុណ្ណោះ សុនខទាំងឡាយក៏បាត់សូន្យទៅ ។

**ទក្ខិណេយ្យគ្គីតិ ឯត្ថ** ឥឡូវនេះ នឹងវិសជ្ជនានៅក្នុងបទថា **ទក្ខិណេយ្យគ្គិ** មានបទវិគ្រោះថា **សត្តា** វិសត្វទាំងឡាយ

**ទក្ខិណាន្តិ** ដូច្នេះគឺថា **វឌ្ឍន្តិ** រមែងចម្រើន **សម្បត្តីហិ** ដោយសម្បត្តិទាំងឡាយ **យថាធិបេតា** ដោយសមគួរដល់កិរិយាដែលប្រាថ្នាឯតាយ **ធម្មជាតិយា** ដោយធម្មជាតិនោះ **សា ធម្មជាតិ** រីធម្មជាតិនោះ **ទក្ខិណា** ឈ្មោះថា ទក្ខិណា **ធម្មជាតិ** រីធម្មជាតិ **ទក្ខិណា** ជាហេតុចម្រើនដោយសម្បត្តិទាំងឡាយ ដោយការគួរដល់ការប្រាថ្នារបស់សត្វទាំងឡាយ **ចត្តារោ បច្ចយា** បច្ច័យទាំងឡាយ ៤ ប្រការគឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជៈនោះ **តំ អរហតិ** ភិក្ខុរូបណាសមគួរទទួល នូវចតុប្បច្ច័យ ៤ ភិក្ខុរូបនោះ **ទក្ខិណេយ្យោ** ឈ្មោះថា ទក្ខិណេយ្យ ភិក្ខុសង្ឃដែលឈ្មោះថា **ទក្ខិណេយ្យ** ដែលសមគួរទទួលនូវបច្ច័យទាំងឡាយ ៤ នោះ ។ អធិប្បាយថា ភិក្ខុសង្ឃទាំងឡាយ ដែលជាទក្ខិណេយ្យបុគ្គល សមគួរនឹងទទួលនូវបច្ច័យទាំង ៤ ដែលទាយកជឿនូវផលនៃកម្ម ហើយបូជា **សោ ភិក្ខុ សង្ឃោ** ភិក្ខុសង្ឃអង្គនោះ រមែងមានគុណជាច្រើនដល់គ្រហស្ថទាំងឡាយ ព្រោះថា ជាអ្នកប្រកបក្នុងធម៌ទាំងឡាយដែលជាកុសលដ៏ប្រសើរជាដើមថា នឹងឲ្យទទួលត្រៃសរណគមន៍ និងឲ្យសមាទាន សីល ៥ សីល ៨ សីល ១០ និងឲ្យឧបាយធ្វើនូវ

ឧបដ្ឋាក បដិបត្តិនូវមាតាបិតា សមណព្រាហ្មណ៍ ទាំងឡាយអ្នកមានសីល **តស្មឹ មិច្ឆាទិដ្ឋិប្បដិបន្នា** គ្រហស្ថបដិបត្តិខុស ក្នុងភិក្ខុសង្ឃនោះ គឺជេរស្តីរអ៊ូរទាំ សើចចំអកភិក្ខុសង្ឃក្តី រមែងទៅកើតក្នុងទុគ្គតិទាំងឡាយ មាននរកជាដើម **តស្មា** ព្រោះហេតុនោះ ទើបភិក្ខុនោះ ព្រះនន្ទាចារ្យពោលថា **ឧក្ខិណោយ្យត្តិ** ដោយសភាវៈដែលជាកិរិយាដុតរឿយៗ ដោយន័យដែលសម្តែងខាងដើម ការពិត **គម្ពីរវិមានវត្ថុក្តី បេតវត្ថុក្តី** អ្នកប្រាជ្ញគប្បីសម្តែងឲ្យពិស្តារ ដើម្បីនឹងសម្តែងនូវសេចក្តីមួយប្រការ មានរឿងរ៉ាវមិត្តវិន្ទុកជាដើម អ្នកប្រាជ្ញគប្បីជ្រាបថា ព្រះអដ្ឋកថាចារ្យសម្តែងទុកក្នុង **អដ្ឋកថាសង្គីតិ-សូត្រ** មានន័យសង្គ្រោះនូវពាក្យដែលសម្តែងនូវភ្លើង ៣ កង ក្នុងបទមាតិកាក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

តិវិធគ្គិកថា ចប់

# ទានាទិបុញ្ញកថា

**ទានាទិកម្មញ្ញាតិ ឯត្ថាយំ វិភាវនា** ការៈនេះនឹងសម្តែងក្នុងមាតិកានេះ គឺពិចារណានូវបុញ្ញកម្មផ្សេងៗ មានទានជាដើម យ៉ាងណាទើបឈ្មោះថាទាន មានបទវិគ្រោះថា **ទិយ្យតីតិ ទានំ យំ ធម្មជាតំ** រីធម្មជាតិណា **ជនេន** ដែលជន **ទិយ្យតិ** តែងឲ្យ **ឥតិ** ដូច្នេះ **តស្មា** ព្រោះហេតុនោះ **តំ ធម្មជាតំ** រីធម្មជាតិនោះ **ទានំ** ឈ្មោះថាទាន **ធម្មជាតំ** រីធម្មជាតិ **ទានំ** ដែលបុគ្គលតែងឲ្យធម្មជាតិដែលបុគ្គលតែងឲ្យនោះ **នាមំ** ជាឈ្មោះរបស់ទេយ្យធម៌ទាំងពួង គឺវត្ថុដ៏សមគួរ ដែលនឹងគប្បីបរិច្ចាគ ។ ន័យទី ១ បានដល់ វត្ថុ ទាំងឡាយមានបាយ ទឹកជាដើម ឈ្មោះថា ទាន ។ ន័យទី ២ បានដល់ចេតនាដែលមានវត្ថុគួរនឹងបរិច្ចាគ ។ **ទានំ នាម** ឈ្មោះថា ទានទាននេះ ជាឈ្មោះនៃកិរិយាដែលបរិច្ចាគទ្រព្យសម្បត្តិផ្សេងៗ ប៉ុន្តែទីបំផុតចេតនាកើតខ្លាំងក្លាឡើងក្នុងសន្តានហើយ លះបង់ទ្រព្យសម្បត្តិចេញចំណាយឲ្យដល់ពពួកជនទាំងឡាយ ប្រៀបដូចព្រះពោធិសត្វ ( ព្រះវេស្សន្តរ ) កាលព្រះអង្គធ្វើសត្តកមហាទាន មានព្រះបាលី

គម្ពីរបរិវារ ជាគម្ពីរព្រះវិន័យ អ្នកប្រាជ្ញគប្បីដឹងក្នុងបុញ្ញកម្មចុះ ។

នេះនឹងសម្តែងអំពីទាន ៥ ប្រការ **បញ្ចទានានិ អបុញ្ញានិ បុញ្ញសម្មតានិ លោកស្មឹ សម្មជ្ជទានំ មជ្ជទានំ ឥត្ថីទានំ ឧសភទានំ ចិត្តកម្មទានំ** ពោលថា ទានទាំងឡាយមាន ៥ ប្រការ **សម្មជ្ជទានំ** គឺឲ្យនូវគ្រឿងមហោស្រព ច្រៀងរាំជាដើម ១ **មជ្ជទានំ** គឺឲ្យទឹកស្រវឹង ១ **ឥត្ថីទានំ** គឺឲ្យស្រ្តីដល់បុរស ( ក្នុងវេលាធ្វើនូវមេថុនធម្ម ) ១ **ឧសភទានំ** គឺលែងនូវគោឧសភរាជចូលទៅក្នុងរវាងមេគោ ដើម្បីឲ្យមេគោទាំងឡាយមានការតាំងគភ៌ ១ **ចិត្តកម្មទានំ** គឺឲ្យនូវរូបភាព ( គំនូរ ) ជារូបស្រ្តី ជារូបបុរសប្រកបដោយមេថុននោះ ១ **អបុញ្ញានិ** ទានទាំង ៥ នេះពុំមែនជាបុណ្យទេ ។ **បុញ្ញសម្មតានិ** ឯសត្វលោកទាំងឡាយគោរពថា ជាបុណ្យ ទាន ៥ ប្រការនេះមានក្នុងគម្ពីរបរិវារ **ចិត្តកម្មទាន** នោះ ប្រសិនបើកសាងនូវអាវាសរួចហើយ ឲ្យធ្វើនូវចិត្រកម្ម គូររូបភាពផ្សេងៗ នោះ ក៏គួរលើកលែងតែរូបភាពមេថុនសំយោគ ក្នុងអដ្ឋកថាចេញសេចក្តីថា ទានទាំងឡាយ ៥ ប្រការនេះ លោករាប់ថាមិនជាបុណ្យឡើយ **អជេវា អបុញ្ញានិ អកុសលានិ យេវ** គឺជាទោសពិត ជាអកុសលពិត អាការដែលបុគ្គលឲ្យបុគ្គល

ទាំងឡាយមើលនូវរបាំជាដើម ដើម្បីជាប្រយោជន៍ក្នុងបុណ្យនោះ ឈ្មោះថា ឲ្យគ្រឿងមហោស្រពកំប្រៀងជាទាន មិនមែនជាបុណ្យឡើយ ។

ក្នុងអដ្ឋកថា **គម្ពីរអង្គុត្តរនិកាយ** ក្តី ក្នុង **អដ្ឋកថាវេលាមសូត្រ** ក្តី អដ្ឋកថាចារ្យសម្តែងថា ទានទាំងឡាយ ៥ ប្រការនេះ មិនបានសមគួរនឹងធ្វើជាទាន ។

**យានិ បនេតានិ** ម្យ៉ាងទៀត ទានទាំងឡាយនោះ គឺ **ឥត្ថី-ទាន ឧសភទាន សមជ្ជទាន មជ្ជទាន** នឹងមិនបានជាទានទេ អ្នកប្រាជ្ញមិនបានរាប់ថាជាទាន កាលព្រះបរមពោធិសត្វនៃយើងសោយព្រះជាតិជាវេលាមព្រាហ្មណ៍នោះ ព្រះអង្គបានឲ្យនូវទានទាំងឡាយនេះ ដើម្បីកាត់នូវពាក្យតិះដៀលរបស់មនុស្សពាលទាំងឡាយ ដែលពោលដូច្នេះថា **ឥទំ ឆាម** វត្ថុរបស់របរនេះៗ ក្នុងទានរបស់វេលាមព្រាហ្មណ៍នៅមិនទាន់មាន ទើបព្រះពោធិសត្វឲ្យនូវ **ឥត្ថីទាន ឧសភ-ទាន សមជ្ជទាន មជ្ជទាន** ដើម្បីនឹងកាត់នូវពាក្យរបស់មនុស្សពាលទាំងឡាយ មិនឲ្យតិះដៀលក្នុងការធ្វើទានរបស់ព្រះអង្គបាន ។

**ឯត្ថ ច បញ្ចន្នំ ទានានំ ទាយកស្ស ទេសនាមត្តំ អាយតិ សុខវិបាកតា** សភាវទានទាំងឡាយ ៥ ប្រការនេះ វិសភាវៈនៃ

**ធជសម្មជ្ជធាន** គឺឲ្យស្តាប់ចម្រៀង ដែលព្រះឯកាសនិយត្ថេរ ធ្វើដើម្បីជាប្រយោជន៍បូជាព្រះពោធិ៍ ឲ្យកើតផលជាសុខក្នុងខាងមុខនោះក៏មានក្នុងគម្ពីរអបទានក្នុងគម្ពីរថេរគាថា ទាំងឡាយ ក៏មានសេចក្តីដូចគ្នានឹងព្រះបាលីក្នុងអបទាន ដូច្នេះ អ្នកប្រាជ្ញគប្បីជ្រាបថា កិរិយាដែលធ្វើ **ធជសម្មជ្ជធាន** គឺកើតមានផលានិសង្សជាសុខនោះ ព្រះបាលីក្នុងអបទានសម្តែងថា ៖-

| | |
|---|---|
| វរុណោ នាម នាមេន | ទេវរាជា អហំ តទា |
| ឧបដ្ឋបេសឹ សម្ពុទ្ធំ | សយោគ្គពលវាហនោ |
| និព្វុតេ លោកនាថម្ហិ | អត្ថទស្សិទិបទុត្តមេ |
| តុរិយំ សព្វមាទាយ | អគមំ ពោធិមុត្តមំ |
| វាទិតេន ច នច្ចេន | សព្វតាឡសមាហិតោ |
| សម្មុខា វិយ សម្ពុទ្ធំ | ឧបដ្ឋឹ ពោធិមុត្តមំ ។ |
| ឧបដ្ឋហិត្វា តំ ពោធឹ | ធរណីរុហបាទបំ |
| បល្លង្កំ អាភុជិត្វាន | តត្ថ កាលំ កតោ អហំ ។ |
| ។បេ។ | កតំ ពុទ្ធស្ស សាសនន្តិ ។ |

គ្រានោះ ខ្ញុំកើតជាទេវរាជឈ្មោះ វរុណ មានយានពាហនៈ

បានចូលទៅបម្រើព្រះសម្ពុទ្ធ កាលព្រះអត្ថទស្សី ឧត្តមជាងសត្វជើងពីរ ជាលោកនាថ ទ្រង់បរិនិព្វានហើយ ខ្ញុំនាំយកតូរ្យតន្ត្រីទាំងពួងទៅកាន់ពោធិព្រឹក្សដ៏ប្រសើរ ខ្ញុំប្រមូលគ្រឿងដេញដំទាំងអស់ ចូលទៅបម្រើដើមពោធិព្រឹក្សដ៏ប្រសើរ ដោយការប្រគំ និងការរាំ ដូចជាបម្រើព្រះសាស្តាក្នុងទីចំពោះព្រះភក្ត្រ ។ ខ្ញុំបម្រើដើមពោធិព្រឹក្សក្នុងទីនោះ ជាឈើដុះលើផែនដី ខ្ញុំអង្គុយផ្គត់ភ្នែន ធ្វើកាលកិរិយាក្នុងទីនោះ ។ ខ្ញុំប្រារព្ធនូវអំពើរបស់ខ្លួន មានចិត្តជ្រះថ្លាចំពោះពោធិព្រឹក្សដ៏ប្រសើរ ក៏បានទៅកើតក្នុងស្ថាននិម្មានរតី ដោយចិត្តជ្រះថ្លានោះ ។ តូរ្យតន្ត្រី ៦ ម៉ឺន តែងហែហមខ្ញុំ សព្វៗ កាលដែលកំពុងប្រព្រឹត្តទៅ ក្នុងពួកមនុស្ស និងទេវតា ក្នុងភពតូច និងភពធំ ។ ភ្លើង ៣ ប្រការរបស់ខ្ញុំរលត់ហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុតក្នុងព្រះសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៥ រយអំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រ ៣៤ ជាតិ មានព្រះនាមសុពាហុដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

សេចក្តីដែលថា ទាន ៥ ប្រការ មាន **សម្មជ្ជទាន** គឺឲ្យគ្រឿងមហោស្រព ច្រៀងរាំជាដើមនោះថា មិនមែនជាបុណ្យទេ ក៏ឃើញថា ខ្វាស់គ្នានឹងសេចក្តីក្នុង **គម្ពីរឯកាសនិយត្ថេរាបទាន** សម្តែងដូច្នេះ គប្បីឲ្យអ្នកប្រាជ្ញ ពិចារណាដោយសមគួរដល់ភូមិបរមត្ថ ទើបនឹងឃើញនូវសេចក្តីអធិប្បាយ ទីបំផុតមានតែទឹកចិត្តសទ្ធាជ្រះថ្លាជាធំ បើធ្វើដោយសេចក្តីជ្រះថ្លាពិតហើយ ក៏ទៀងតែជាបុណ្យពិតប្រាកដមិនជាទោសទេ ។

ទានដែលជាអសប្បុរិសទាននោះ មាន ៥ ប្រការ ព្រះសាស្តាត្រាស់សម្តែងទុកក្នុង ចូឡបុណ្ណមសូត្រ ក្នុង មជ្ឈិមនិកាយ ថា **ឥធ ភិក្ខវេ អសប្បុរិសោ អសក្កច្ចំ ទានំ ទេតិ អសហត្ថា ទានំ ទេតិ អចិត្តីកត្វា ទានំ ទេតិ អបវិទ្ធំ ទានំ ទេតិ អនាគមន-ទិដ្ឋិកោ ទានំ ទេតិ ឯវំ ខោ ភិក្ខវេ អសប្បុរិសោ អសប្បុរិ-សទានំ ទេតិ** មានព្រះពុទ្ធតម្រាស់ថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ អសប្បុរសក្នុងលោកនេះ ឲ្យទានដោយមិនគោរព ឲ្យទានមិនមែនឲ្យដោយដៃរបស់ខ្លួន ឲ្យទានមិនធ្វើសេចក្តីកោតក្រែង ឲ្យទានបោះគ្រវែងចោល មិនបានយល់ឃើញផល ហើយឲ្យទាន ម្នាលភិក្ខុទាំងឡាយ

អសប្បុរស ឲ្យអសប្បុរិសទានយ៉ាងនេះឯង ។ ជាអសប្បុរិសទាន ១ ។

ដូចម្តេចទើបឈ្មោះថា មិនគោរពទេយ្យធម៌ គឺថា កាលនឹងឲ្យទាននោះ គឺឲ្យទានមិនមែនដោយដៃរបស់ខ្លួន ឲ្យទានមិនធ្វើសេចក្តីកោតក្រែង ឲ្យទានបោះគ្រវែងចោល ឈ្មោះថា មិនគោរពទេយ្យធម៌ កាលនឹងឲ្យទាននោះ មិនបានសម្អាតអាសនៈជាទីអង្គុយ ក៏ភិក្ខុអ្នកជាបដិគ្គាហកៈ ឲ្យអង្គុយក្នុងទីមិនសមគួរ **យត្ថ តត្ថ ឋានេ** ទីអង្គុយឯណាទីមួយ មើលទៅមិនគាប់ភ្នែក និងលើកយកអាហារណាៗទៅថ្វាយជាទាន សូម្បីថា ថ្វាយវត្ថុទានយ៉ាងនេះ ឈ្មោះថា មិនគោរពបដិគ្គាហកបុគ្គល ។

**អសហត្ថា ទានំ ទេតិ** កាលឲ្យទាននោះ មិនបានឲ្យដោយដៃរបស់ខ្លួន ប្រើឲ្យទាសកម្មករទាំងឡាយឲ្យជំនួស យ៉ាងនេះក៏ចាត់ជា អសប្បុរិសទាន ១ ។

**អបចិតំ កត្វា ទានំ ទេតិ** កាលឲ្យទាន មិនធ្វើសេចក្តីកោតក្រែងក្នុងទេយ្យធម៌ មិនធ្វើសេចក្តីកោតក្រែងបដិគ្គាហកបុគ្គល ឲ្យទានដោយន័យដូចពោលខាងដើម ឲ្យទានយ៉ាងនេះ ក៏ចាត់ជាអសប្បុរិសទាន ១ ។

**អបវិដ្ធំ ទានំ ទេតិ** កាលឲ្យទាននោះ មានសេចក្តីប្រាថ្នាដើម្បីបោះគ្រវែងចោល ប្រៀបដូចចាប់សត្វទន្សេង បោះឲ្យចូលក្នុងជំបូក ឲ្យជាទានយ៉ាងនេះ ក៏ចាត់ជាអសប្បុរិសទាន ១ ។

**អនាគមនទិដ្ឋិកោ ទានំ ទេតិ** កាលឲ្យទាននោះ មិនបានពិចារណាយល់ឃើញនូវផលក្នុងខាងមុខ ហើយឲ្យទាន មិនមាននូវបញ្ញាដែលដឹងនូវផលរបស់ទានក្នុងខាងមុខនោះ ប៉ុន្តែកាលឲ្យក៏ឲ្យតាមៗគ្នា ដូច្នេះ យ៉ាងនេះ ក៏ចាត់អសប្បុរិសទាន ១ ។

**ឥមេ ខោ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអសប្បុរសរមែងឲ្យទានដោយលក្ខណៈ ៥ ប្រការដូច្នេះ ។

ការពិត ទានដែលជារបស់សប្បុរសក៏មានលក្ខណៈ ៥ ប្រការដែរប្លែកគ្នាតែអាការដែលធ្វើ ។ កាលឲ្យទាននោះ ធ្វើដោយគោរពទេយ្យធម៌តាក់តែង ដោយប្រណីតផ្ចិតផ្ចង់ ធ្វើដោយគោរពបដិគ្គាហកបុគ្គលសម្អាតអាវាស តាក់តែងឲ្យល្អស្អាត ហើយលើកទេយ្យធម៌នោះចូលទៅប្រគេនដោយដៃរបស់ខ្លួនឯង បង្អោនសិរសា ប្រយ័ត្នប្រយែងយ៉ាងល្អតម្កល់ទុកដោយល្អ ពិចារណាយល់ឃើញផលក្នុងកាលមុនៗ ប្រៀបដូចថា នឹងកើតដល់ខ្លួន ក្នុងខណៈនោះ ឲ្យរីករាយត្រេកអរ ក្នុងទាន

របស់ខ្លួន លក្ខណៈរបស់សប្បុរិសទានដូច្នេះ ទើបឈ្មោះថា ជាទាន តាមអង្គរបស់សប្បុរសទាំងឡាយ មានព្រះបរមពោធិសត្វជាប្រធាន ជាដើម ដែលបានបំពេញបារមីមកពីអតីតជាតិ ។

លក្ខណៈរបស់សទ្ធាក៏មាន ៤ យ៉ាង **យាយ សមន្នាគតា សទ្ធា** សព្វសត្វទាំងឡាយ ប្រកបដោយសទ្ធាយ៉ាងណា នឹងធ្វើទាន ឲ្យនូវគ្រឿងសក្ការបូជាច្រើនក្តី ឲ្យតែល្មមប្រមាណគួរដល់ប្រ-យោជន៍ក្នុងមួយខណៈក្តី ដល់សមណព្រាហ្មណ៍អ្នកមានសីល មនុស្សកំព្រា ជនអនាថា អ្នកក្រីក្រ អ្នកដើរផ្លូវ ស្មូមយាចកក្តី **សា ចតុព្វិធា** ចិត្តសទ្ធាយ៉ាងនោះ មាន ៤ យ៉ាងគឺ អាគមនសទ្ធា ១ ឱកប្បនសទ្ធា ១ បសាទសទ្ធា ១ អធិគមនសទ្ធា ១ ។

បណ្តាសទ្ធាទាំង ៤ ប្រការនោះ សទ្ធារបស់ព្រះបរមពោធិសត្វទាំងឡាយ ដូចជាសុមេធតាបសព្រះបរមពោធិសត្វ ឈ្មោះថា **អាគមនសទ្ធា** ។ ព្រោះថា សទ្ធាកើតមានផ្តើមតាំងអំពីប្រាថ្នាកាលជាព្រះពុទ្ធដំបូង ដែលព្រះពុទ្ធទីបង្ករទ្រង់ត្រាស់ព្យាករតាំងពីព្យាករហើយ សទ្ធាក៏កើតចាស់ក្លាដល់ព្រះបរមពោធិសត្វក្នុងខណៈនោះ ឈ្មោះថា **អាគមនសទ្ធា**។

**អចលភាវេន ឱកប្បនំ** អាការដែលជឿស៊ប់ដោយភាវៈមិនខ្វាច មិនញញើតក្នុងការដែលពោលចេញព្រះនាមថា **ពុទ្ធោ ធម្មោ សង្ឃោ** ដូច្នេះ ក៏កើតការជឿស៊ប់ពិតៗ ដែលនឹងមិនពោលត្រឡប់ចេញថា **នពុទ្ធោ នធម្មោ នសង្ឃោ** នោះទេ ។ លក្ខណៈសទ្ធាជឿស៊ប់ក្នុងព្រះរតនត្រ័យយ៉ាងនេះ ឈ្មោះថា **ឱកប្បនសទ្ធា។**

អាការដែលបានកើតសេចក្ដីជ្រះថ្លាដ៏ក្រៃលែងនោះ ឈ្មោះថា **បសាទសទ្ធា។**

សទ្ធារបស់អរិយសាវកទាំងឡាយនោះ ឈ្មោះថា **អធិគមនសទ្ធា** ហេតុដូចម្ដេច ហេតុថា សទ្ធានោះ កើតបានដោយការត្រាស់ដឹងនូវអរិយសច្ចធម៌ទាំង ៤ ប្រចក្សច្បាស់ហើយ សម្រេចនូវមគ្គផលវិសេសផ្សេងៗ តាំងអំពីបានត្រាស់ដឹងមគ្គផលហើយនោះសទ្ធាក៏កើត ឈ្មោះថា **អធិគមនសទ្ធា។**

**ឱកប្បនសទ្ធា បសាទសទ្ធា** ២ ប្រការនេះ ជាលោកិយសទ្ធា និងមាន ៣ រួមទាំងអាគមនសទ្ធា ប៉ុន្ដែអធិគមនសទ្ធានោះ ជាលោកុត្តរសទ្ធា កើតរួមជាមួយនឹងមគ្គវិថិ ផលវិថិ ក្នុងសន្ដានរបស់ព្រះអរិយៈទាំងឡាយ សទ្ធា ៤ ប្រការនេះ លោកសម្ដែងទុកនៅក្នុង **ព្រះអដ្ឋកថា**

អង្គុត្តរនិកាយ ចតុក្កនិបាត ។

អដ្ឋកថាអធិប្បាយថា បុគ្គលអ្នកមានបាប បានបណ្ដែតចេញអស់ហើយនោះ ឈ្មោះថា ព្រាហ្មណ៍ មនុស្សទុគ៌តទាំងឡាយនោះ ឈ្មោះថា **កបណា** ជាមនុស្សកំព្រា មនុស្សទាំងឡាយដែលសញ្ចរទៅតាមផ្លូវនោះ ឈ្មោះថា **អទ្ធិកា** ជាមនុស្សដើរផ្លូវ ។ បុគ្គលណាពោលសរសើរនូវទាន ដោយពាក្យជាដើមដូច្នេះថា ទានដែលបុគ្គលឲ្យជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត សូមលោកញុំាងចិត្តរបស់លោកឲ្យជ្រះថ្លាក្នុងទានចុះ លោកនឹងទៅកាន់ស្ថានសួគ៌ ក្នុងភពខាងមុខ បុគ្គលនោះឈ្មោះថា **វណិព្វកា** ។ បុគ្គលណា ជាមនុស្សដើរសុំទានតាមច្រកល្ហក បុគ្គលណា ដើរសុំទាន ដោយពាក្យជាដើមថា **បសតមត្តំ ទេថ** សូមលោកឲ្យទានប្រមាណមួយទូកដៃ **សាវាវមត្តំ** សូមលោកឲ្យទានប្រមាណមួយពែង មួយផ្តិល ដើរសុំទានដូច្នេះ បុគ្គលនោះឈ្មោះថា **យាចកា**។

អាការដែលធ្វើសក្ការបូជាជាច្រើន ជាមហាបូជា ជាសាធារណៈទូទៅនោះ ឈ្មោះថា **យិដ្ឋំ** អាការដែលធ្វើសក្ការបូជា តែល្មមប្រមាណ តែល្មមសមគួរនោះ ឈ្មោះថា **ហុតំ**។

ទាយកអ្នកធ្វើទាន មានសក្ការបូជាឲ្យតិចតួចនោះ ក៏មាន ៣ ប្រការ ដោយអំណាចនៃទេយ្យធម៌ផ្សេងៗ ១-២-៣ ឈ្មោះថា ទាន ១ ។

បណ្តាទានទាំងឡាយ ៣ យ៉ាងនេះ ទាយកណា ខ្លួនឯងបរិភោគ ដ៏ប្រណីត មានឱជារស របស់ដែលមានឱជារសនោះ មិនបានឲ្យដល់បុគ្គលដទៃ **សោ ទាយកោ** ទាយកនោះ រមែងឲ្យទាន តែងតែជាទាសៈដល់ទេយ្យធម៌ ពោល គឺទានរបស់ខ្លួន ដែលគួរគប្បីនឹងឲ្យដោយល្អដោយច្រើនក៏មាន បានឲ្យរបស់របរដែលអាក្រក់ ដែលមិនល្អ មិនស្អាតនោះ ទើបជាទាសទាន ។

**យោ អត្តនោ មធុរំ ភុញ្ជតិ** ទាយកណា ចំណែកដែលខ្លួនបរិភោគនូវរបស់របរដែលមានរសឆ្ងាញ់ កាលនឹងឲ្យទានសោត ក៏ឲ្យដូច្នោះ **សោ ទាយកោ** ទាយកនោះ ឈ្មោះថា ជាសម្លាញ់របស់ទាន ព្រោះថា ឲ្យនូវរបស់របរជាទានស្មើដោយវត្ថុដែលខ្លួនបរិភោគ ទើបជាសាហាយទាន ថាជាសម្លាញ់នៃទេយ្យធម៌ ពោល គឺទាន ។

ទាយកណា ចំណែកដែលខ្លួនបរិភោគនោះ មានតែរបស់របរដែលសមគួរនឹងបរិភោគបាន របស់របរណាមួយមិនបានជ្រើសរើស

តាមតែមានមកយ៉ាងណា ក៏បរិភោគយ៉ាងនោះ ការធ្វើទាននោះ គាត់តែងនូវរបស់របរដ៏ប្រណីតផ្ចិតផ្ចង់ សុទ្ធតែប្រកបដោយឱជារសឆ្ងាញ់នោះ ឲ្យទានដល់បុគ្គលទាំងឡាយ **សោ សាមិ ហុត្វា** ទាយកនោះ ឈ្មោះថា ម្ចាស់របស់ទាន ទើបឈ្មោះថា **ទានបតីទាយក។** ក្នុង **អង្គុត្តរនិកាយ តិកនិបាត** ព្រះពុទ្ធដីកាត្រាស់ទុកដូច្នេះ ។

ក្នុង **អង្គុត្តរនិកាយ ចតុក្កនិបាត** នោះ សម្តែងដល់ព្រះយោគាវចរកុលបុត្រដែលប្រកបដោយសេចក្តីព្យាយាម បានបរិភោគអាហារមួយថ្ងៃ ចិញ្ចឹមជីវិតបានដល់ ៧ ថ្ងៃ មិនបានបរិភោគអាហារបិណ្ឌបាតដទៃទៀតឡើយ ព្រះយោគាវចរពួកនោះ បានឈ្មោះថា បរិភោគអាហារបិណ្ឌបាតមួយថ្ងៃ ចិញ្ចឹមជីវិតបានដល់ ៧ ថ្ងៃជាកំណត់ ដោយអំណាចនៃសេចក្តីព្យាយាម ប្រារព្ធក្នុងកិរិយាដែលធ្វើសមណធម៌ ។

**ឯកស្មឹ បន សេនាសនេ** មួយទៀតសោត ព្រះយោគាវចររូបណានិមន្តចង្រ្កមទៅមកក្នុងទីសប្បាយពេលថ្ងៃ និងពេលយប់ក្នុងសេនាសនៈតែមួយ និងមិនបានលះបង់នូវសេនាសនៈនោះ ទៅកាន់សេនាសនៈដទៃឡើយ ព្រះយោគាវចររូបនោះ ឈ្មោះថា ប្រើប្រាស់នូវសេនាសនៈតែមួយ ដោយអំណាចការសមាទាននូវធុតង្គ ឈ្មោះថា

**យថាសណ្ឋិតធុតង្គ** *ក៏អាស្រ័យនៅដោយការគួរដល់ធុតង្គ ក្នុងកាលមានរោគាព្យាធិម្យ៉ាង ដោយភេសជ្ជៈណាមួយ ព្រះយោគាវចររូបណាមិនបានបរិភោគនូវភេសជ្ជៈដទៃ កំណត់កាលប៉ុន្មាន ព្រះ-យោគាវចររូបនោះ ក៏បានឈ្មោះថា បរិភោគនូវភេសជ្ជៈតែមួយកំណត់កាលត្រឹមប៉ុណ្ណោះ ដោយអំណាចរក្សានូវការអប់រំជាដើម គឺថា* **បូតិមុត្តភេសជ្ជំ និស្សាយ** *ឈ្មោះថា បព្វជិតហើយក៏អាស្រ័យផ្លែសម៉ ត្រាំដោយទឹកមូត្រជាភេសជ្ជៈ ។*

*ក្នុងអដ្ឋកថានៃ* ***អង្គុត្តរនិកាយ តិកនិបាត*** *អធិប្បាយថា* **ភិក្ខូ អាគច្ឆន្តេ ទិស្វា បច្ចុគ្គមនំ ករោន្តោ** *បុគ្គលណាឃើញភិក្ខុទាំងឡាយនិមន្តមកអំពីចម្ងាយ ចេញមកធ្វើការក្រោកទទួលរាក់ទាក់ លុះភិក្ខុទាំងឡាយនិមន្តទៅវិញក៏ជូនដំណើរ រួចក៏ធ្វើសេចក្តីខ្វល់ខ្វាយក្នុងការបោសសម្អាតសាលា រៀបចំតាំង ទីអង្គុយក្នុងសាលា តម្កល់ទឹកសម្រាប់ប្រើប្រាស់ រៀបចំទុកដោយល្អ ធ្វើឧបដ្ឋាកដូច្នោះ បុគ្គលធ្វើយ៉ាងនេះ ឈ្មោះថា បានទទួលនូវចំណែកបុណ្យ ដោយកាយបយោគ ១ ។*

**ភិក្ខូ បិណ្ឌាយ ចរន្តេ ទិស្វា** *បុគ្គលណាឃើញភិក្ខុទាំងឡាយ*

ដែលនិមន្តទៅដើម្បីបិណ្ឌបាត ហើយបានប្រកាសប្រាប់ដល់អ្នកស្រុក ដោយពាក្យថា **យាគុំ ទេថ ភត្តំ ទេថ** សូមអ្នកទាំងឡាយនាំយកនូវយាគូ និងបាយមកដាក់បាត្រ សូមនាំយកសប្បិ នវនីតមកដាក់បាត្រ សូមនាំយកគ្រឿងក្រអូប មានផ្កាកម្រងជាដើមធ្វើការបូជា ថ្ងៃនេះអ្នកទាំងឡាយ ចូររក្សានូវឧបោសថសីល ចូរស្តាប់នូវព្រះធម៌-ទេសនា ចូរទៅនមស្ការ ថ្វាយបង្គំព្រះចេតិយ បុគ្គលដែលពោលពាក្យយ៉ាងនេះ ឈ្មោះថា បានទទួលនូវចំណែកបុណ្យ ដោយវចី-បយោគ ១ ។

**មនសា បុញ្ញំ បសវតិ នាម** បុគ្គលណាឃើញភិក្ខុទាំងឡាយនិមន្តទៅបិណ្ឌបាត មានទឹកចិត្តជ្រះថ្លា គិតតែក្នុងចិត្តថា ភិក្ខុទាំងឡាយនោះ សូមបាននូវចង្ហាន់ដោយងាយស្រួល កុំបានដោយលំបាក បុគ្គលនោះឈ្មោះថា ទទួលនូវចំណែកបុណ្យដោយទឹកចិត្តជ្រះថ្លា ប្រព្រឹត្តទៅដោយមនោបយោគ ១ ។

ក្នុង អដ្ឋកថាអង្គុត្តរនិកាយ ចតុក្កនិបាត សម្តែងថា **ឧហរ-ទារកា មាតាបិតូហិ កតំ ករោម** ក្មេងតូចៗ ទាំងឡាយដែលនៅមិនទាន់ដឹងក្តីនោះ ឃើញមាតាបិតាទាំងឡាយ ធ្វើនូវសក្ការបូជា

ក្រាបថ្វាយបង្គំនូវព្រះចេតិយ ក៏ធ្វើតាមមាតាបិតា លើកដៃ ឱនក្បាល ថ្វាយបង្គំក្រាបចុះ កុសលក៏កើតមានដល់ក្មេងតូចៗ ដែលនៅមិនទាន់ដឹងក្ដីនោះដោយពិត ។

មួយទៀតសោត សត្វតិរច្ឆានទាំងឡាយ មានម្រឹគ និងសត្វស្វាបជាដើម បានស្ដាប់ព្រះធម៌ទេសនា បានថ្វាយបង្គំព្រះសង្ឃ ឬព្រះចេតិយដោយចិត្តជ្រះថ្លារបស់ខ្លួន បុណ្យកុសលនោះក៏កើតមានដល់សត្វតិរច្ឆានទាំងឡាយនោះ ។

ប្រការមួយទៀត ក្មេងតូចៗ ទាំងបៀតបៀនចំពោះមាតាបិតាទាំងឡាយ ដោយដៃ ដោយជើង ចាប់ដុំដី ឬដុំថ្មគ្រវែងភិក្ខុសង្ឃក្ដី មេគោមានកូនខ្ចី ដែលកាកូនដេញភិក្ខុសង្ឃក្ដី រាជសីហ៍ ខ្លាដំបងទាំងឡាយដេញតាមសម្លាប់ភិក្ខុសង្ឃទាំងឡាយ ឲ្យឃ្លាតចាកជីវិតក្ដី ប៉ុន្តែបណ្ដាសត្វទាំងឡាយមិនបានដឹងក្ដី ដែលដឹងក្ដីហើយក្ដី ក៏កើតមានអកុសលធម៌ដែលជាបាបទាំងអស់ ។

អាការដែលធ្វើបាបនោះ បើនឹងរាប់ចូលក្នុងផ្នែកអកុសល បុគ្គលដែលមិនបានដឹងហើយធ្វើនោះ មានទោសច្រើនជាងកម្ម ដែលបុគ្គលដឹងហើយធ្វើ ដែលដឹងហើយធ្វើបំពាន មានទោសតិចជាង

សេចក្តីនេះ ក៏មាននៅក្នុងកម្មភេទ ដែលសម្តែងរួចមកហើយអំពីមុន ។

មួយទៀត មានសេចក្តីក្នុង **អដ្ឋកថាទក្ខិណាវិភង្គ** សម្តែងថា ក្នុងកុសលនោះ ទានដែលព្រះសម្ពុទ្ធឲ្យដល់ព្រះសារីបុត្រ **មហាបួលំ** មានផលច្រើន ក៏ទានដែលព្រះសារីបុត្រថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ មានផលតិច ហេតុដូចម្តេច ហេតុថា បុគ្គលដទៃមិនអាចដើម្បីនឹងដឹងនូវផលនៃទានបាន លើកលែងតែព្រះសម្មាសម្ពុទ្ធ មិនមានអ្នកណាម្នាក់អាចនឹងដឹងនូវផលទាន មានតែសព្វញ្ញុតញ្ញាណមួយព្រះអង្គ ដឹងនូវផលនៃទាន ហេតុដូច្នោះ ព្រះអង្គឲ្យទានដល់ព្រះសារីបុត្រ ទើបមានផលច្រើនជាងទានដែលព្រះសារីបុត្រថ្វាយចំពោះព្រះអង្គ ពិតហើយកុសលកម្មដែលបុគ្គលដឹងហើយធ្វើ មានផលច្រើនជាងកុសលកម្មដែលមិនបានដឹងហើយធ្វើនោះ ព្រោះថា យកបញ្ញាដែលដឹងផលនោះជាប្រធាន ។

មានសេចក្តីមួយទៀត ក្នុងអដ្ឋកថា ទក្ខិណាវិភង្គដដែល សម្តែងថា នឹងកំណត់រាប់នូវសព្វសត្វទាំងឡាយ ដែលតាំងនៅក្នុងកម្មស្សកតាញាណរបស់ខ្លួនឯង ដែលដឹងដោយខ្លួនឯងដូច្នេះថា មាតាបិតា ជាសម្មាទិដ្ឋិ មាននូវបញ្ញាដូច្នេះហើយ ក៏ធ្វើនូវកុសលកម្ម

មានទានជាដើម ក៏រមែងបានទទួលនូវសេចក្តីសុខ គឺការនៅដោយសេចក្តីសុខ ធ្វើបុណ្យទទួលនូវសម្បត្តិ ដោយសម្បត្តិ គឺកិរិយាបរិច្ចាគជាទាន ហើយទៅកាន់អមតមហានិព្វាននោះ មិនអាចកំណត់រាប់បានទេ ច្រើនហួស បញ្ញាដែលដឹងថា សត្វទៅកាន់ព្រះនិព្វាននោះប្រមាណប៉ុណ្ណោះៗ មិនអាចដឹងបាន ។ តែព្រះសម្មាសម្ពុទ្ធទាំងឡាយដែលទៅកាន់ព្រះនិព្វានកន្លងទៅហើយនោះ ក៏ច្រើនជាងគ្រាប់ខ្សាច់ក្នុងផ្ទៃមហាសមុទ្រ ពោលថ្វីដល់សត្វពួកដទៃ មិនគប្បីកំណត់រាប់បានឡើយ ។

សេចក្តីតាមដីកាព្រះវិន័យថា **សោ ហិ ចីវរាទិកេ អដ្ឋ-បរិក្ខារេ បត្តចីវរមេវ វា សោតាបន្នាទិអរិយស្ស បុថុជ្ជនស្សេវ វា សីលសម្បន្នស្ស ទត្វា** ពិតហើយ បុគ្គលទាំងឡាយជាសម្មាទិដ្ឋិ ប្រកបដោយចិត្តជាកុសលនោះ បានថ្វាយនូវគ្រឿងបរិក្ខារ ៨ មានត្រៃចីវរជាដើមក្តី ថ្វាយនូវបាត្រ និងត្រៃចីវរជាដើមក្តីចំពោះព្រះអរិយៈទាំងឡាយ មានព្រះសោតាបន្នបុគ្គលជាដើមក្តី ចំពោះភិក្ខុបុថុជ្ជនដែលប្រកបដោយចតុប្បារិសុទ្ធិសីលក្តី **បត្ថនំ ឋបេសិ** ទើបតាំងនូវសេចក្តីប្រាថ្នាថា **ឥទំ មេ បរិក្ខារទានំ** បរិក្ខារទានរបស់អាត្មា

អញនេះ **បច្ចយោ ហោតុ** សូមបានជាបច្ច័យដល់ឯហិភិក្ខុក្នុង អនាគតកាលនោះចុះ ទានរបស់បុគ្គលនោះ ក្នុងកាលអធិសម្បត្តិ គឺធ្វើនូវកុសលហើយ តាំងប្រាថ្នាដូច្នោះ ក៏នឹងនាំឲ្យបាននូវអដ្ឋបរិក្ខារ ដែលសម្រេចដោយឫទ្ធិ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះសម្ពុទ្ធក្នុងអនាគត កាល មានព្រះអរិយមេត្រីជាដើម **តញ្ចទានំ** ទាននោះ នឹងឲ្យផល ដល់អាត្មាអញក្នុងបច្ឆិមជាតិ ដែលជាទីបំផុតនៃសង្សារ ក្នុងកាល សម្រេចមគ្គផលនោះ ។

មួយទៀត ក្នុងធម្មបទ មាននិទានរឿងនាងវិសាខា ការពិត **ស្បង់ ចីវរ និងសង្ឃាដី** របស់ស្ត្រីភេទ នឹងឲ្យសម្រេចបាននូវគ្រឿង ប្រដាប់ទ្រទ្រង់នូវអាវលតាមហាបសាធន៍ ដូចនាងវិសាខាមហាឧបា-សិកា ដែលជាឧបដ្ឋាយិកការបស់ព្រះពុទ្ធ ។ បើ **ស្បង់ ចីវរ និង សង្ឃាដីទាន** របស់បុរសនោះសោត ក៏បានសម្រេច **ឯហិភិក្ខុ** ព្រម ដោយត្រៃចីវរដែលសម្រេចដោយឫទ្ធិ ដូចព្រះមហាកប្បិនភិក្ខុ ។

អាការដែលថ្វាយយាគូ ព្រះមានជោគមានព្រះពុទ្ធដីកាត្រាស់ ទុកនៅក្នុង **ភេសជ្ជក្ខន្ធកៈ** ក្នុង **គម្ពីរព្រះវិន័យ** ដល់ព្រាហ្មណ៍ម្នាក់ថា ម្នាលព្រាហ្មណ៍ អានិសង្សបបរនេះមាន ១០ យ៉ាង ។ អានិសង្សបបរ

១០ យ៉ាងនោះ តើដូចម្ដេច ? **អាយុំ ទេតិ** គឺបុគ្គលអ្នកឲ្យបបរ ឈ្មោះថា ឲ្យអាយុ ១ **វណ្ណំ ទេតិ** ឲ្យពណ៌សម្បុរ ១ **សុខំ ទេតិ** ឲ្យសេចក្ដីសុខ ១ **ពលំ ទេតិ** ឲ្យកម្លាំងកាយ ១ **បដិភាណំ ទេតិ** ឲ្យបញ្ញា ១ **យាគុ បិត ខុទំ បដិហានតិ** បបរដែលបុគ្គលហុតទៅហើយ រមែងហាមឃាត់នូវសេចក្ដីឃ្លាន ១ **បិបាសំ បដិវិនោ–ទេតិ** បន្ទោបង់សេចក្ដីស្រេក ១ **វាតំ អនុលោមេតិ** ញុំាងខ្យល់ឲ្យដើរទៅស្រួល ១ **វត្ថឹ សោធេតិ** ញុំាងសរសៃឲ្យស្អាត ១ **អាមាវសេសំ ចាចេតិ** ញុំាងអាហារថ្មីដ៏សេសសល់ឲ្យរលួយ ១ ។ ម្នាលព្រាហ្មណ៍ អានិសង្សបបរមាន ១០ យ៉ាងនេះឯង ។

ជនណាបានឲ្យបបរដោយគោរពដល់ពួកសមណៈ ដែលជាអ្នកសង្រួម អ្នកបរិភោគភោជន ដែលអ្នកដទៃឲ្យក្នុងកាលដ៏គួរ ជននោះឈ្មោះថា ឲ្យនូវហេតុនៃអានិសង្សទាំង ១០ យ៉ាង គឺអាយុ ១ ពណ៌សម្បុរ ១ សេចក្ដីសុខ ១ កម្លាំងកាយ ១ ប្រាជ្ញារបស់បុគ្គលនោះតែងកើតឡើង ១ បបរនោះតែងកម្ចាត់បង់សេចក្ដីឃ្លាន ១ សេចក្ដីស្រេក ១ និងញុំាងខ្យល់ឲ្យបានដើរស្រួល ១ ញុំាងសរសៃឲ្យស្អាត ១ ញុំាងកត្តឲ្យរលួយ ១ ។ នេះជាភេសជ្ជៈ ដែលព្រះសុគតទ្រង់សរសើរហើយ ។ ព្រោះ

ហេតុនោះ អ្នកមានសេចក្តីត្រូវការចង់បាននូវសេចក្តីសុខ ជារបស់មនុស្សក្តី ប្រាថ្នាសេចក្តីសុខជារបស់ទិព្វក្តី ចង់បានសេចក្តីល្អរុងរឿងក្នុងមនុស្សក្តី គួរឲ្យបបរជានិច្ចចុះ ។

ក្នុង **អដ្ឋកថាលក្ខណសូត្រ** ក្នុង **គម្ពីរទីឃនិកាយ** នោះថា **លូខភោជនេ** ក្នុងភោជនាហារដ៏សៅហ្មង មិនស្អាត គ្មានអនាម័យធ្លាក់ចុះដល់ផ្ទៃហើយ រមែងមានទោស ធ្វើឲ្យឈាមមិនស្រស់ថ្លាស្បែកមិនស្រស់ថ្លា ស្មុកស្មាំង ហេតុដូច្នោះ សត្វទាំងឡាយឲ្យទានដោយរបស់មិនស្អាត គ្មានអនាម័យ ជាវត្ថុសៅហ្មង កាលកើតមកទើបមានសាច់ និងឈាមតិច មានបាយទឹករកបានដោយលំបាក ប្រៀបដូចមនុស្សប្រេត ព្រោះថា ឲ្យទានដោយវត្ថុដែលសៅហ្មង ។

មួយ៉ាងទៀត ក្នុងកាលភោជនាហារដ៏ប្រណីតផ្ចិតផ្ចង់ ធ្លាក់ចុះដល់ផ្ទៃហើយ ក៏ជាទីចម្រើនសាច់ឈាមទាំងឡាយពេញលេញ ទើបមានរូបរាងសណ្ឋាន ពណ៌សម្បុរ គួរជាទីសរសើរ **ចាសាធិកា** គួរជាទីពិចពិលរមិលមើលនៃមហាជនទាំងឡាយ អាស្រ័យហេតុដែលបានបរិភោគភោជនាហារដ៏ប្រណីតស្អាត មានអនាម័យល្អ ។

ពិតមែនហើយ សព្វសត្វទាំងឡាយ នឹងមានរូបស្អាតនោះ

រមែងស្អាតដោយហេតុ ៤ ប្រការ **អាមិសទានេន** វា គឺស្អាត ដោយអាមិសទាន រៀបចំបាយទឹក ភោជនាហារដ៏ប្រណីតផ្ចិតផ្ចង់ ប្រកបដោយឱជារសផ្សេងៗ ហើយក៏ថ្វាយជាទាន ១ **វត្ថុទានេន** វា គឺស្អាតដោយវត្ថុទាន រៀបចំសម្លៀកបំពាក់សុទ្ធតែល្អៗ មានតម្លៃ ជាសំពត់សាជកសាច់ល្អសាច់ហ្មត់ ស.ដូចសំពត់កោសេយ្យពស្ត្រ រៀបចំដេរដោយការផ្ចិតផ្ចង់ ហើយថ្វាយជាទាន ១ **សម្មជ្ជនេន** វា គឺស្អាតដោយការបោកសម្អាត និងបត់ដោយផ្ចិតផ្ចង់ មានប្រការផ្សេងៗ រៀបចំរួចហើយ ថ្វាយជាទាន ១ **អក្កោធនតាយ** វា គឺស្អាតដោយកិរិយាមិនក្រោធ ចំពោះបុគ្គលណាមួយ តាំងនៅក្នុងអធិវាសនខន្តី និងមេត្តា ១ បុគ្គលដែលនឹងប្រាថ្នាឲ្យរូបស្អាត ក៏គប្បីបដិបត្តិតាមពាក្យក្នុងព្រះសូត្រដែលសម្តែងមកនេះចុះ ។

មានពាក្យនៅក្នុង *អដ្ឋកថាសំយុត្តនិកាយ* នោះថា **អប្បមត្តកំ បណ្ណាមុដ្ឋិមត្តទានកុសលំ** វា កុសលទានដោយថ្នាក់អន់បំផុតត្រឹមតែស្លឹកឈើមួយក្តាប់នោះ ក៏ជាកុសល ១ **វេលាមទានាទិកុសលំ** វា កុសលទានរបស់វេលាមព្រាហ្មណ៍ជាដើម ជាមហន្តទានដ៏ធំ ឲ្យរហូតទូទៅដល់ជនទាំងអស់ក្នុងជម្ពូទ្វីបក្តី ក៏ជាកុសល ១ លក្ខណៈ

ដែលធ្វើទានលើកទុកសិនចុះ បុគ្គលធ្វើទាននោះ ប្រសិនបើប្រាថ្នាសម្បត្តិក្នុងវដ្តសង្សារ គឺប្រាថ្នាសម្បត្តិស្តេចចក្រពត្តិ សម្បត្តិព្រះឥន្ទ្រ សម្បត្តិព្រហ្មលោក និងរហូតដល់ភវគ្គព្រហ្មជាទីបំផុតនោះ ឈ្មោះថាការប្រាថ្នាខុស ដោយអំណាចអាស្រ័យនៅក្នុងវដ្តសង្សារ ក៏ជាកង្វល់នៅក្នុងលោកិយសម្បត្តិ ផលទាននោះ ក៏រមែងនាំមកនូវលោកិយសម្បត្តិឲ្យវិលវល់កើតស្លាប់នៅក្នុងវដ្តសង្សារដោយពិត ។ **វិវដ្តំ** ផលទាននោះ មិនអាចឲ្យសម្រេចនូវព្រះនិព្វានបាន បុគ្គលដែលប្រាថ្នានូវព្រះនិព្វាន ហើយគប្បីប្រាថ្នាថា **អាសវក្ខយាវហំ ហោតុ** សូមកើតផលានិសង្សនាំមកនូវអាសវក្ខយញ្ញាណ គឺបញ្ញាត្រាស់ដឹងអរហត្តមគ្គ ដែលកាត់ផ្តាច់កិលេសជាសមុច្ឆេទប្បហាន មិនបានកើតតទៅទៀត តាំងចិត្តប្រពៃដោយអំណាចការប្រាថ្នាព្រះនិព្វានដូច្នេះហើយ ផលទាននោះក៏អាចឲ្យសម្រេចនូវអរហត្តផល ដល់ភូមិព្រះអរិយសាវក អាចឲ្យសម្រេចបច្ចេកភូមិ អាចឲ្យសម្រេចនូវព្រះសព្វញ្ញុតញ្ញាណ ដល់ភូមិសម្ពោធិញ្ញាណ ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដោយសមគួរដល់ការប្រាថ្នារបស់ខ្លួន និងតាំងសេចក្តីប្រាថ្នាជាសាវក ជាព្រះបច្ចេកពុទ្ធ និងជាព្រះពុទ្ធ តេជះផលទាននោះ ក៏នឹងឲ្យសម្រេចដល់ភូមិបារមី

របស់ខ្លួនពិតប្រាកដ ។

ក្នុង *អដ្ឋកថាអង្គុត្តរនិកាយ ទសកនិបាត* សម្ដែងថា ផលរបស់ទាននោះមានច្រើន ដោយអន់បំផុត សូម្បីបាយប្រមាណត្រឹមតែមួយវែក បណ្ណសាលាប្រមាណប្រវែង ៥ ហត្ថក្ដី ថ្វាយចំពោះលោកអ្នកប្រកបដោយគុណមានសីល សមាធិ បញ្ញាជាដើម ក៏រមែងប្រកបដោយផលច្រើន អាចរក្សាខ្លួនមិនឲ្យធ្លាក់ទៅជាប្រេត ជាអសុរកាយអស់សែននៃកប្បជាកំណត់យូរដល់ប៉ុណ្ណោះមិនមានសេចក្ដីទុក្ខ **បរិយោសានេ ច** ទីបំផុតនៃសង្សារវដ្ដនោះ ក៏កើតជាបច្ច័យដល់ព្រះអមតមហានិព្វានដោយពិត ។

និទានទាំងឡាយក្នុងគាថានេះថា បានថ្វាយទឹកដោះគោក្ដី និទានក្នុងវិមានវត្ថុ និងបេតវត្ថុទាំងអស់ក្ដី អ្នកប្រាជ្ញគប្បីនាំមកសម្ដែងក្នុងផលានិសង្សរបស់ទាន ដែលជាបច្ច័យដល់ព្រះនិព្វានធាតុមិនស្លាប់នោះ ។

ម្យ៉ាងទៀត នៅក្នុង *អដ្ឋកថាអង្គុត្តរនិកាយ* ថា **យេសំ បនកុសលានំ តីណិ សរណានិ បញ្ចសីលានិ** ត្រៃសរណគមន៍ក្ដី សីល ៥ ក្ដី សលាកភត្តទានក្ដី បក្ខិកភត្តទានក្ដី វស្សាវស្សិកទានក្ដី ត្រកូលទាំងឡាយណា បានរក្សាត្រៃសរណគមន៍ សីល ៥ សលាក-

*កត្តទាន ឬធ្វើទានសូម្បីក្នុងថ្ងៃ ១៥ កើតម្តងក្តី សូម្បីថ្ងៃចូលព្រះវស្សា ថ្វាយសំពត់សាដកមួយផ្ទាំងក្តី ឬជីកស្រះជាទានក្តី កសាងអាវាសមួយជាទានក្តី ទានទាំងឡាយនេះ គឺថា ធ្វើជានិច្ច ទើបបានឈ្មោះថា* **និច្ចទ្ធកុសល** *កើតមានដល់ត្រកូលណា គតិនៃត្រកូលនោះ ជាគតិដែលទៀងមិនឃ្លៀងឃ្លាត គឺមានតែសុគតិដោយពិត ។ ត្រកូលទាំងឡាយនោះ* **សោតាបន្នសទិសានិ ឯវ** *ដូចគ្នានឹងព្រះសោតាបន្នបុគ្គលដោយពិត បិទទ្វារអបាយភូមិទាំង ៤ មិនបានកើតក្នុងអបាយភូមិ ។*

*ក្នុង អដ្ឋកថាធាតុសំយុត្តនិកាយ សម្តែងថា* **ញាណសម្ប-យុត្តចិត្តេន បន កតំ កុសលកម្មំ** *កុសលកម្មឯណានីមួយ ដែលសព្វសត្វធ្វើដោយទឹកចិត្ត ប្រកបដោយបញ្ញា ធ្វើដោយស្មោះត្រង់ធ្វើដោយមិនរើសអើង ញុំាងចិត្តប្រកបដោយសម្មាទិដ្ឋិ គឺពិចារណាឃើញនូវសង្ខារទាំងឡាយថា គ្មានខ្លឹមសារ ទើបធ្វើនូវកុសលណានីមួយ ផលកុសលនោះ ក៏នាំនូវសត្វនោះឲ្យកើតក្នុងប្រទេសដ៏សមគួរជាប្រទេសទីកើតនៃព្រះមានជោគ ព្រះបច្ចេកពុទ្ធ ព្រះសាវកទាំងឡាយ ស្តេចចក្រពត្តិ បានជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និង*

បានរៀនព្រះត្រៃបិដក ញុំាងសត្វនោះ ឲ្យសេពលោកអ្នកជាអង្គនៃសប្បុរស មានព្រះពុទ្ធ **សោ ឯវ បុគ្គលោ** បុគ្គលនោះឯង នឹងតាំងនៅក្នុងទីដ៏ល្អ ប្រកបដោយកាយសុចរិត និងវក្យាកម្មបថ ១០ ពេញលេញបរិបូណ៌ ។

មានពាក្យឧបមាថា រូបភាពមិនជាទីពេញចិត្ត ទើបមិនជាទីគាប់ភ្នែកដល់មនុស្សទាំងឡាយ ព្រោះថា ជាងដែលគូរនោះមិនឆ្លាតក្នុងការដែលគូរ ទើបមិនជាទីពេញចិត្តដល់ភ្នែកនៃមនុស្សទាំងឡាយយ៉ាងណាក្តី កុសលកម្មដែលបុគ្គលធ្វើពិតហើយ ធ្វើដោយទឹកចិត្តដែលប្រាសចាកបញ្ញា ជាញាណវិប្បយុត្ត កាលទៅកើតក្នុងសម្បរាយិកភពខាងមុខនោះ មិនបរិបូណ៌ដោយឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើម រមែងមានរូបសណ្ឋានមិនជាទីគាប់ចិត្តរបស់មាតាបិតា មិនតែប៉ុណ្ណោះទេ មានរូបមិនជាទីគាប់ភ្នែកដល់មនុស្សទាំងឡាយ **ឯវំ ឯវ** ក៏មានសេចក្តីឧបមេយ្យដូចរូបភាពដែលអាក្រក់នោះ ។

**យថា បន** ម្យ៉ាងទៀត រូបភាពដែលស្អាតនោះ ព្រោះថ្វីដៃមេជាងដែលឈ្លាសក្នុងការគូរ ពិនិត្យពិចារណាដោយដោយថ្នាំពណ៌ដ៏ស្រស់ស្អាតហើយ ក៏រមែងទាក់ទាញចិត្ត ឲ្យពេញចិត្តមើល

ឲ្យពេញចិត្ត នឹងចង់ពោលសរសើរ មានប្រការផ្សេងៗ យ៉ាងណា កុសលដែលបុគ្គលធ្វើដោយចិត្តប្រកបដោយបញ្ញា ជាញាណសម្បយុត្ត នោះ ក៏នឹងញ៉ាំងរូបសណ្ឋានឲ្យបរិបូណ៌ស្អាតសព្វគ្រប់ ទាំងពណ៌សម្បុរគួរជាទីពិចពិលរមិលមើល ប្រៀបដូចរូបជុំមាសសុទ្ធ **អលង្កតបដិ–យត្តំ វិយ** រូបនោះស្អាតហាក់បីដូចថា តាក់តែងដោយគ្រឿងអលង្ការស្រេចស្រាប់ រមែងគាប់ភ្នែកដល់មនុស្សទាំងឡាយ មានឧបមេយ្យដូចរូបជាងអ្នកឈ្លាសគួរ រមែងវិចិត្ររចនាដ៏ស្អាតនោះ ។

ក្នុង អដ្ឋកថាសង្ខាររូប្បត្តិសូត្រ ក្នុង មជ្ឈិមនិកាយ នោះថា ធម៌ទាំង ៥ គឺសទ្ធា ១ សីល ១ សុតៈ ១ ចាគៈ ១ បញ្ញា ១ ។ ធម៌ទាំង ៥ ប្រការនេះ មាននៅក្នុងសន្តាននៃបុគ្គលណា គឺថា ការប្រាថ្នានោះមិនមាន **តស្ស គតិ អនិពទ្ធា** គតិរបស់បុគ្គលនោះក៏មិនទៀង **យស្ស បត្ថនា អត្ថិ** ម្យ៉ាងទៀត បុគ្គលណាមានសេចក្តីប្រាថ្នា គឺថា ធម៌ទាំង ៥ ប្រការនោះមិនមាន **តស្សបិ គតិ អនិពទ្ធា** គតិនៃបុគ្គលនោះក៏មិនទៀងដែរ **យេសំ ឧភយម្បិ** ធម៌ទាំង ២ គឺធម៌ ៥ ប្រការក្តី និងសេចក្តីប្រាថ្នាក្តី កាលកើតមានក្នុងសន្តាននៃបុគ្គលណា **តេសំ គតិ និពទ្ធា** ទើបគតិនៃបុគ្គលទាំងឡាយនោះនឹងទៀង

**អាកាសេ ខិត្តទណ្ឌោ** កំណាត់ឈើដែលបុគ្គលគ្រវែងឡើងទៅលើអាកាស មិនមានអ្នកណាកំណត់ដឹងបានថា គល់ កណ្តាល ឬក៏ចុងនឹងធ្លាក់ចុះមកមុន យ៉ាងណាមិញ សព្វសត្វទាំងឡាយ នឹងប្រកាន់យកនូវបដិសន្ធិកំណត់មិនបាន ក៏មានឧបមេយ្យដូច្នោះ ព្រោះដូច្នោះបុគ្គលទាំងឡាយបានធ្វើកុសលណាមួយ រួចហើយក៏គួរនឹងតាំងនូវសេចក្តីប្រាថ្នាក្នុងទីកន្លែងណាមួយ តាមការពេញចិត្តរបស់ខ្លួន ទើបគតិដែលខ្លួនបដិសន្ធិនោះទៀង បើលះបង់សេចក្តីប្រាថ្នាចេញហើយ មិនតាំងសេចក្តីប្រាថ្នានោះ មិនសមគួរទេ បុគ្គលដែលប្រកបដោយធម៌ ៥ ប្រការហើយ កាលធ្វើកុសលនោះ ក៏គប្បីតាំងសេចក្តីប្រាថ្នាផង គតិរបស់បុគ្គលនោះទៀង ការធ្វើកុសលមិនមានការប្រាថ្នាហើយ ក៏ដូចបុគ្គលគ្រវែងកំណាត់ឈើឡើងទៅឰដ៏អាកាស មិនមានទីកំណត់ថា គល់ ឬកណ្តាល ឬចុងធ្លាក់ចុះមកមុនទេ ។

ក្នុង **មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ នវមភាគ ទក្ខិណាវិភង្គសូត្រ** ថា ម្នាលអានន្ទ **ទក្ខិណាវិសុទ្ធិ** គឺបរិសុទ្ធ និងមិនបរិសុទ្ធរបស់ទាននេះមាន ៤ យ៉ាង ។ ឯទក្ខិណាវិសុទ្ធិទាំង ៤ តើដូចម្តេច ? ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ១ ។ ម្នាលអានន្ទ

ទក្ខិណាបរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ១ ។ម្នាលអានន្ទ ទក្ខិណាមិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ១ ។ ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួល ផង ១ ។

ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួលតើដូចម្តេច ? ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលមានសីល មានធម៌ល្អ ឯពួកអ្នកទទួល ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថា ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ។ ប្រៀបដូចព្រះវេស្សន្តរបរម-ពោធិសត្វ ពិតហើយ ព្រះវេស្សន្តរបរមពោធិសត្វនោះ ព្រះអង្គទ្រទ្រង់នូវសុចរិតធម៌ ធ្វើទានដល់ជូជកព្រាហ្មណ៍ ព្រះអង្គលះបង់ព្រះ-បិយោរសទាំងពីរឲ្យជាបរមត្ថបារមី ជាកំពូលទានដ៏ប្រសើរ ញ៉ាំងផែនដីឲ្យកម្រើក ធ្វើទានដូចព្រះវេស្សន្តរបរមពោធិសត្វ កាលព្រះអង្គទ្រង់ប្រទានបាជាលី និងនាងក្រស្នាឲ្យដល់ជូជកនោះឯង ឈ្មោះថា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ។

ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកទទួល តែមិនបរិសុទ្ធ

ខាងអ្នកឲ្យ តើដូចម្តេច ? ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលទ្រុស្តសីល មានធម៌ដ៏លាមក ឯពួកអ្នកទទួលជាបុគ្គលមានសីល មានធម៌ល្អ ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណាបរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ។ ប្រៀបដូចនាយប្រមង់ម្នាក់រស់នៅទៀបកល្យាណីនទី បានធ្វើទានចំពោះព្រះថេរៈដ៏ប្រសើរ ។

បានឮមកថា នាយប្រមង់នោះ បានថ្វាយបិណ្ឌបាតទានដល់ ៣ ដង ចំពោះព្រះទីឃសុមត្ថេរ ដែលជាអង្គព្រះខីណាស្រពដ៏ប្រសើរ ។ កាលបើនាយប្រមង់នោះ ដេកនៅលើគ្រែទៀបនឹងស្លាប់ ក៏រឭកដល់បុណ្យដែលខ្លួនបានថ្វាយបិណ្ឌបាតទាន ចេញវាចាថា បិណ្ឌបាតទានដែលខ្ញុំបានថ្វាយចំពោះលោកម្ចាស់ទីឃសុមត្ថេរនោះ សូមជួយលើកស្ទួយខ្ញុំឲ្យផុតពីអបាយគ្រោះនេះ  កាលបើនាយប្រមង់រឭកបានដូច្នោះ ក៏ជាយទាសន្នកម្មប្រាកដដល់នាយប្រមង់ ទើបបានរួចខ្លួន ទៅកាន់សុគតិភព ។

ម្នាលអានន្ទ ទក្ខិណា មិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ? ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទាំងពួកអ្នកទទួលក៏ជាបុគ្គល

ទ្រុស្តសីល មានធម៌ដ៏លាមកដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណា មិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ។ ប្រៀបដូចទានរបស់នាយព្រាន មានប្រក្រតីនៅកន្លែងសម្លាប់សត្វ ។

បានឮមកថា នាយព្រាននោះ កាលនឹងធ្វើនូវទាន ផ្សាយនូវចំណែកកុសលទៅឲ្យដល់ពួកប្រេត ដែលជាញាតិរបស់ខ្លួន ទើបឲ្យទានដល់បុគ្គលទ្រុស្តសីល មានធម៌ដ៏លាមកអស់វារៈ ៣ ដង ក្នុងវារៈជាគម្រប់ ៣ ដងនោះ អមនុស្សក៏ស្រែកឡើងដោយសំឡេងដ៏ខ្លាំងៗ ថា បុគ្គលទ្រុស្តសីល ដណ្តើមនូវចំណែករបស់យើងហើយ គឺថា ទាននោះនឹងមិនបានដល់អមនុស្សនោះទេ លុះកាលនាយព្រានថ្វាយនូវបិណ្ឌបាតទានចំពោះភិក្ខុ ដែលលោកទ្រទ្រង់សីល ១ រូប រួចហើយក៏ឧទ្ទិសនូវចំណែកបុណ្យទៅដល់ប្រេតដែលជាញាតិ ទើបផលទាននោះបានទៅដល់ប្រេតៗ នោះ ក៏បានទទួលនូវចំណែកបុណ្យរួចផុតចាកទុក្ខ ។

ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ? ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គល

មានសីល មានធម៌ល្អ ទាំងពួកអ្នកទទួល ក៏ជាបុគ្គលមានសីល មានធម៌ល្អដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង ។ ប្រៀបដូចអសទិសទានរបស់ព្រះបាទបសេនទិកោសល ព្រះអង្គបានថ្វាយ ចំពោះភិក្ខុសង្ឃមានអង្គព្រះសម្ពុទ្ធជាប្រធាន គ្រានោះ លក្ខណៈទានមានផលច្រើន និងបរិសុទ្ធដោយអ្នកឲ្យ និងអ្នកទទួលដូចសម្ដែងមកនេះ ។

ម្នាលអានន្ទ បាដិបុគ្គលិកាទក្ខិណា គឺទានដែលឲ្យចំពោះបុគ្គលនេះមាន ១៤ យ៉ាង ។ បុគ្គលឲ្យទានចំពោះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ១ ។ ឲ្យទានចំពោះព្រះបច្ចេកពុទ្ធ នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ២ ។ ឲ្យទានចំពោះព្រះអរហន្តជាសាវ័ករបស់ព្រះតថាគត នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ៣ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផល នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ៤ ។ ឲ្យទានចំពោះអនាគាមិបុគ្គល នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ៥ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ៦ ។ ឲ្យទានចំពោះសកទាគាមិបុគ្គល នេះជា

បាដិបុគ្គលិកាទក្ខិណាទានទី ៧ ។ ឲ្យទានចំពោះបុគ្គល អ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល នេះជាបាដិបុគ្គលិកាទក្ខិណាទាន ទី៨។ឲ្យទានចំពោះសោតាបន្នបុគ្គល នេះជាបាដិបុគ្គលិកាទក្ខិណាទាន ទី ៩ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ សោតាបត្តិផល **អដ្ឋកថាថា** សូម្បីឧបាសកអ្នកដល់សរណគមន៍ ៣ ក្តី កាន់សីល ៥ ក្តី សីល ១០ ក្តី សាមណេរ ឬភិក្ខុដែលទើបនឹងបួស បានមួយថ្ងៃក្តី ភិក្ខុមានវត្តប្រតិបត្តិដែលបួសយូរហើយក្តី ភិក្ខុទ្រទ្រង់ វិបស្សនាក្តី ទាំងអស់នេះឈ្មោះថា ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវ សោតាបត្តិផល ។ តែបុគ្គលឲ្យទានចំពោះបុគ្គលទាំងអម្បាលនេះ បានផលច្រើនជាងគ្នាជាលំដាប់ នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ១០ ។ ឲ្យទានចំពោះអ្នកបួសជាខាងក្រៅ ( ព្រះពុទ្ធសាសនា ) ដែល ប្រាសចាកតម្រេកក្នុងកាម (សំដៅដល់ពួកអ្នកជាកម្មវាទី កិរិយវាទ ដែលបានអភិញ្ញាជាលោកិយទាំង ៥) ទាំងឡាយ នេះជាបាដិបុគ្គលិកា-ទក្ខិណាទានទី ១១ ។ ឲ្យទានចំពោះបុថុជ្ជនមានសីល នេះជាបាដិ-បុគ្គលិកាទក្ខិណាទានទី ១២ ។ ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ១៣។ ឲ្យទានចំពោះសត្វតិរច្ឆាន

នេះជាបាដិបុគ្គលិកាទក្ខិណាទានទី ១៤ ។

ម្នាលអានន្ទ បណ្តាបុគ្គលអ្នកទទួលទានទាំងនោះ ទក្ខិណា មានគុណ ១០០ ( **អដ្ឋកថាថា** ឲ្យនូវអានិសង្ស ១០០ គឺ ១០០ អត្តភាព ក្នុងអត្តភាពមួយៗ មានអាយុវែង ១ សម្បុរល្អ ១ សេចក្តីសុខ ១ កម្លាំង ១ ប្រាជ្ញា ១ រួមជាអានិសង្ស ៥០០ ។ ទានក្រៅពីសត្វតិរច្ឆានទៅ ក៏គុណជាប្រាំៗ តាមឧបាយនេះដែរ ) ដែលបុគ្គលត្រូវបាន ព្រោះឲ្យ ទានចំពោះសត្វតិរច្ឆាន ។ ទក្ខិណា មានគុណ ១០០០ ដែលបុគ្គល ត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល ។ ទក្ខិណាមានគុណ ១០០០០០ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនមានសីល ។ ទក្ខិណាទានមានគុណ ១ សែនកោដិ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទាន ចំពោះអ្នកបួសខាងក្រៅ ដែលប្រាសចាកតម្រេកក្នុងកាម ។ ទក្ខិណា មានគុណរាប់មិនបាន ប្រមាណមិនកើត ដែលបុគ្គលត្រូវបាន ព្រោះ ឲ្យទានចំពោះបុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតា-បត្តិផល នឹងនិយាយទៅថ្វីដល់ទក្ខិណាទាន ដែលបុគ្គលឲ្យចំពោះ សោតាបន្នបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល នឹងនិយាយទៅថ្វីចំពោះសកទា-

គាមិបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល នឹងនិយាយទៅថ្វីចំពោះអនាគាមិបុគ្គល នឹងនិយាយទៅថ្វីចំពោះ បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលនឹងនិយាយទៅថ្វីចំពោះព្រះអរហន្តជាសាវករបស់តថាគត នឹងនិយាយទៅថ្វីចំពោះព្រះបច្ចេកពុទ្ធ នឹងនិយាយទៅថ្វី ចំពោះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ អត្ថន័យមួយប្រការទៀត បាដិ-បុគ្គលិកាទក្ខិណាទាំង ១៤ យ៉ាងនេះ គឺទានណាមានផលច្រើន និងមានអានិសង្សផ្សេងៗ គ្នាយ៉ាងណា ទានដែលបុគ្គលជឿនូវកម្មផល នឹងឲ្យដល់សត្វតិរច្ឆាន មានឆ្មា ឆ្កែ មាន់ ទាជាដើម ដែលមកដល់សម្នាក់របស់ខ្លួន នឹងបានឲ្យដោយអំណាចសត្វនោះមានគុណវិសេស ឬដោយអំណាចសត្វនោះ មានគុណូបការៈដល់ខ្លួន ឬដោយអំណាចដើម្បីចិញ្ចឹមសត្វនោះទុក មិនដូច្នោះទេ ទានដែលឲ្យចំពោះប្រយោជន៍ត្រឹមតែមួយចម្អែតដល់សត្វតិរច្ឆាននោះ មានអានិសង្ស ៥០០ ជាតិជាកំណត់ ( ១០០ គុណនឹង ៥ ) ។

ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល បានអានិសង្ស ៥០០០ ជាតិ (១០០០ គុណនឹង ៥ ) ។ ឲ្យទានចំពោះបុថុជ្ជន ដែលជាគោសីលធាតុ

មានប្រក្រតីដូចគោ បានអានិសង្ស ១ សែនជាតិ ( ១០០០០០ គុណនឹង ៥ ) ។ ឲ្យទានចំពោះបុគ្គលអ្នកបួសខាងក្រៅ ព្រះពុទ្ធសាសនា ដែលបានសមាបត្តិ ៨ បានអានិសង្ស ៥ សែនកោដិជាតិ ( ១ សែនកោដិគុណនឹង ៥) ។ ឲ្យទានចំពោះឧបាសកអ្នកតាំងនៅក្នុងត្រៃសរណគមន៍ ជាអ្នកដឹងគុណព្រះរតនត្រ័យ ដោយកំណត់យ៉ាងទាបបំផុត ក៏បាន ឈ្មោះថា ជាអ្នកប្រតិបត្តិតាមព្រះពុទ្ធដីកា ដើម្បីធ្វើសោតាបត្តិផលឲ្យជាក់ច្បាស់ ព្រោះយ៉ាងនោះ ត្រូវបានអានិសង្សរាប់មិនបានប្រមាណមិនកើត ។

ប្រការមួយទៀត ទានដែលបុគ្គលឲ្យចំពោះឧបាសកអ្នកតាំងនៅក្នុងសីល ៥ នោះ នឹងបានអានិសង្សដ៏ក្រៃលែងជាងទានដែលបុគ្គលឲ្យចំពោះឧបាសកអ្នកតាំងនៅក្នុងត្រៃសរណគមន៍ ។ ទានដែលបុគ្គលឲ្យចំពោះបុគ្គល អ្នកតាំងនៅក្នុងសីល ១០ នោះ នឹងបាននូវអានិសង្សច្រើនក្រៃលែងជាងទាន ដែលបុគ្គលឲ្យដល់ឧបាសក អ្នករក្សាសីល ៥ នោះ ។ ទានដែលបុគ្គលឲ្យចំពោះសាមណេរអ្នកបួសក្នុងថ្ងៃនោះ នឹងបាននូវអានិសង្សក្រៃលែងជាងទាន ដែលបុគ្គលឲ្យចំពោះបុគ្គលអ្នករក្សាសីល ១០ នោះ ។ ទានដែលបុគ្គលឲ្យចំពោះភិក្ខុ

អ្នកបាននូវឧបសម្បទារួចហើយ នឹងបាននូវអានិសង្សច្រើនក្រៃលែង ជាងទានដែលបុគ្គលឲ្យចំពោះសាមណេរអ្នកបួសក្នុងថ្ងៃនោះ ។ ទានដែលបុគ្គលឲ្យចំពោះភិក្ខុ អ្នកបាននូវឧបសម្បទារួចហើយ ប្រកបដោយវត្តប្រតិបត្តិដ៏ល្អនោះ គឺរៀនសូត្រព្រះត្រៃបិដក នឹងបានអានិសង្សទ្វេដងជាងទានដែលបុគ្គលឲ្យចំពោះភិក្ខុអ្នកបានឧបសម្បទាថ្មីៗ ។ ទានដែលបុគ្គលឲ្យចំពោះព្រះយោគាវចរ ភិក្ខុអ្នកប្រកបដោយសេចក្តីព្យាយាមពិចារណាត្រៃលក្ខណ៍នោះ នឹងបាននូវអានិសង្សច្រើនក្រៃលែងជាងទានដែលបុគ្គលឲ្យចំពោះភិក្ខុអ្នកប្រកបដោយវត្តប្រតិបត្តិដ៏ល្អនោះ ។ ទានដែលបុគ្គលឲ្យចំពោះព្រះយោគាវចរ ភិក្ខុអ្នកមានវិបស្សនាញាណដែលប្រារព្ធហើយ នឹងបាននូវអានិសង្សច្រើនជាងទានដែលបុគ្គលឲ្យចំពោះព្រះយោគាវចរ ភិក្ខុអ្នកពិចារណាត្រៃលក្ខណ៍នោះ ។ បុគ្គលអ្នកដល់ព្រមដោយមគ្គ ដោយហោចទីបំផុតយ៉ាងក្រៃលែង យ៉ាងឧត្តម យ៉ាងប្រសើរនោះ ក៏បានឈ្មោះថា បុគ្គលបដិបត្តិដើម្បីធ្វើនូវសោតាបត្តិផលឲ្យជាក់ច្បាស់ ទានដែលបុគ្គលឲ្យចំពោះបុគ្គលអ្នកដល់ព្រមដោយមគ្គ ប្រតិបត្តិធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលនោះ នឹងបាននូវអានិសង្ស ប្រសើរលើសជាងទាន

ដែលបុគ្គលឲ្យចំពោះព្រះយោគាវចរ ភិក្ខុអ្នកជាអារទ្ធវិបស្សនានោះ។ សេចក្ដីដែលសម្ដែងមកនេះ ហេតុដូចម្ដេចទើបនឹងដឹងច្បាស់ មានសេចក្ដីអធិប្បាយថា ទានដែលបុគ្គលឲ្យចំពោះបុគ្គល អ្នកដល់ព្រមដោយមគ្គនោះ បានឈ្មោះថា ឲ្យទានចំពោះអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល គឺថា កាលព្រះយោគាវចរភិក្ខុអ្នកមានវិបស្សនាញាណ ដែលប្រារព្ធដ៏តឹងរ៉ឹងទៅដោយវិបស្សនាញាណ គឺបញ្ញានោះ ឈប់តោងយកសង្ខារធម៌ទាំងឡាយ ដោយត្រៃលក្ខណ៍ កាលនិមន្តទៅឈរបិណ្ឌបាតនៅទៀបទ្វារផ្ទះនោះ មនុស្សទាំងឡាយទទួលយកបាត្រព្រះថេរៈមកហើយ ក៏ទៅចាត់ចែងវត្ថុខាទនីយភោជនីយាហារដាក់ក្នុងបាត្រ ។ ក្នុងខណៈនោះឯង បានឈ្មោះថា ព្រះយោគាវចរភិក្ខុអ្នកមានវិបស្សនាញាណ ដែលប្រារព្ធចេញចាកមគ្គ ទានដែលបុគ្គលធ្វើដូច្នេះហើយ ក៏ឈ្មោះថា ឲ្យទានចំពោះបុគ្គលអ្នកដល់ព្រមដោយមគ្គ គឺឲ្យទានចំពោះបុគ្គលអ្នកមានវិបស្សនាញាណដែលប្រារព្ធហើយ មនុស្សទាំងឡាយ បានដាក់បាត្រដោយខាទនីយភោជនីយាហារដែលតាំងនៅក្នុងសម្នាក់របស់ព្រះយោគាវចរ ភិក្ខុអ្នកមានវិបស្សនាញាណ ដែលប្រារព្ធដ៏ក្រៃលែងក្តី ដាក់ក្នុងបាត្រដែល

អ្នកណាមួយទទួលមកពីព្រះហស្តលោក រួចហើយទើបមកតម្កល់ទុកក្នុងត្រកូលឧបាសកក្តី ក៏បានឈ្មោះថា ថ្វាយទានចំពោះលោកអ្នកដល់ព្រមដោយមគ្គ ដូចន័យដែលបានសម្តែងរួចមកហើយនោះ ក្នុងខណៈនោះ ព្រះយោគាវចរភិក្ខុអង្គុយនៅក្នុងទីទាំងឡាយ ដែលមានវិបស្សនាជាវិហារធម៌ និងសេនាសនៈសាលាជាដើមនោះ ក៏បានឈ្មោះថាចេញចាកមគ្គ ទានដែលបុគ្គលបានធ្វើដូច្នេះហើយ ក៏បានឈ្មោះថាឲ្យទានចំពោះលោកអ្នកដល់ព្រមដោយមគ្គ នឹងមានផលានិសង្សដោយវិសេសក្រៃលែងជាងទាន ដែលបុគ្គលឲ្យចំពោះព្រះយោគាវចរភិក្ខុអ្នកជាអារទ្ធវិបស្សកៈ គឺព្រះយោគាវចរភិក្ខុអ្នកជាអារទ្ធវិបស្សកៈនោះឯង ឈ្មោះថា មគ្គសមង្គីបុគ្គលដែលដល់ព្រមដោយមគ្គ កាលបើចេញចាកមគ្គនោះ ក្នុងខណៈមនុស្សទទួលយកបាត្រចេញទៅពីព្រះហស្តបានឈ្មោះថា បដិបត្តិមាំទាំនិងធ្វើឲ្យជាក់ច្បាស់នូវសោតា-បត្តិផល ។ ទានដែលបុគ្គលឲ្យចំពោះព្រះអរិយៈទាំងឡាយ មានសោតាបត្តិមគ្គជាដើម មានព្រះពុទ្ធជាទីបំផុតនោះ នឹងបានអានិ-សង្សរាប់មិនបានប្រមាណមិនកើត ប្រៀបដូចធូលីរបស់ផែនដីប្រមាណប៉ុនមណ្ឌលរបស់ផែនដី ធ្វើនូវធូលីរបស់ផែនដីឲ្យមានជា

មណ្ឌលដ៏ធំទូលាយចេញចាកមណ្ឌលផែនដីនោះទៀត នឹងធ្វើនូវធូលីរបស់ផែនដីឲ្យច្រើនក្រៃលែងជាងនោះទៀត ដរាបចេញទូទៅប៉ុនផែនដី ដ៏ធំទូទាំងជម្ពូទ្វីប ធូលីដែលធ្វើទៅជាដុំឲ្យច្រើនចេញទៅរហូតប៉ុនផែនដីដ៏ធំ អស់ទាំងជម្ពូទ្វីបនោះ ក៏ហៅថា អសង្ខេយ្យអប្បមេយ្យរាប់មិនបាន ប្រមាណមិនកើតដូចគ្នា ផ្សេងគ្នាពីមណ្ឌលដ៏ធំៗ ដរាបប៉ុនផែនដីនោះឯង យ៉ាងណាក្តី ទានដែលបុគ្គលឲ្យចំពោះសោតាបន្នបុគ្គលក៏មានអានិសង្សច្រើនជាអសង្ខេយ្យអប្បមេយ្យ ១ ទានដែលបុគ្គលឲ្យចំពោះសកទាគាមីនោះ មានអានិសង្សជាអសង្ខេយ្យអប្ប-មេយ្យ ១ ទានដែលបុគ្គលឲ្យចំពោះអនាគាមិបុគ្គលនោះ មានអានិសង្សជាអសង្ខេយ្យអប្បមេយ្យ ១ ទានដែលបុគ្គលឲ្យចំពោះអរហន្តបុគ្គលនោះ ក៏មានអានិសង្សច្រើនឡើងទៅជាអសង្ខេយ្យអប្បមេយ្យ ១ ទានដែលបុគ្គលឲ្យចំពោះព្រះបច្ចេកពុទ្ធនោះ ក៏មាននូវអានិសង្សច្រើនវិសេសក្រៃលែងជាងនោះ កំណត់ដោយអសង្ខេយ្យ-អប្បមេយ្យ ១ ទានដែលបុគ្គលឲ្យចំពោះព្រះពុទ្ធនោះ ក៏មាននូវអានិសង្សប្រសើរឡើងទៅ ជាអសង្ខេយ្យអប្បមេយ្យយ៉ាងច្រើនក្រៃលែងជាងអសង្ខេយ្យអប្បមេយ្យនៃព្រះបច្ចេកពុទ្ធ មានឧប-

មេឃដូចធូលីដែលជាគំនរធំៗ ចេញទៅដរាបប៉ុនផែនដីដ៏ធំ ក៏ជាអសង្ខេយ្យអប្បមេយ្យ នឹងរាប់មិនបានប្រមាណមិនកើត ដូច្នេះបាដិបុគ្គលិកាទក្ខិណាទាំង ១៤ យ៉ាងនេះ អ្នកប្រាជ្ញគប្បីចែកចេញទៅដោយប្រការដូច្នេះ ចាត់ជាលក្ខណៈទានឲ្យចំពោះបុគ្គល ។

ម្នាលអានន្ទ សង្ឃគតាទក្ខិណា គឺទានដែលតម្កល់ក្នុងសង្ឃនេះមាន ៧ យ៉ាង ។ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន ( **អដ្ឋកថា** សង្ឃទាំងពីរចំណែក គឺពួកភិក្ខុសង្ឃអង្គុយម្ខាង ពួកភិក្ខុនីសង្ឃអង្គុយម្ខាង ព្រះសាស្តាគង់ត្រង់កណ្តាល ដូច្នេះហៅថា សង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន ។ សង្ឃគតាទក្ខិណាទី ១ នេះ គ្មានទក្ខិណាណាវិសេសស្មើឡើយ ។ តែកាលដែលព្រះសាស្តាបរិនិព្វានទៅហើយ គេតម្កល់ព្រះពុទ្ធប្បដិមា ឬព្រះធាតុលើអាសនៈក្នុងទីចំពោះមុខសង្ឃទាំងពីរចំណែក តម្កល់ម្ហូបចំណីលើតុ ឬជើងស្រាពក៍ គឺជើងពាន ហើយធ្វើកិច្ចទក្ខិណោទកជាដើម ថ្វាយវត្ថុទាំងពួងចំពោះព្រះសាស្តាជាមុន ទើបថ្វាយសង្ឃទាំងពីរចំណែកជាខាងក្រោយ យ៉ាងនេះក៏ឈ្មោះថា ថ្វាយទានដល់សង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធានដែរ < សម័យឥឡូវនេះ

គ្មានភិក្ខុនី មានតែភិក្ខុ ដូច្នេះឈ្មោះថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន > ។ ភោជនដែលថ្វាយចំពោះព្រះមានជោគយ៉ាងនេះ ត្រូវប្រគេនដល់ភិក្ខុណាដែលប្រតិបត្តិព្រះសាស្តា ដែលបរិបូណ៌ដោយវត្តបដិបត្តិ ព្រោះជាវត្ថុរបស់ព្រះពុទ្ធជាបិតា ត្រូវបានដល់ភិក្ខុជាកូន ឬនឹងប្រគេនដល់សង្ឃក៏គួរ ។ បើវត្ថុនោះជាប្រេង ឬសាជក ត្រូវអុជប្រទីប ចងជាទង់ ឬពិតានថ្វាយ ) នេះជាសង្ឃគតាទក្ខិណាទី ១ ។ កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក នេះជាសង្ឃគតាទក្ខិណាទី ២ ។ ឲ្យទានចំពោះតែភិក្ខុសង្ឃ នេះជាសង្ឃគតាទក្ខិណាទី ៣ ។ ឲ្យទានចំពោះតែភិក្ខុនីសង្ឃ នេះជាសង្ឃគតាទក្ខិណាទី ៤ ។ បុគ្គល ( ទៅនិមន្តអំពីសម្នាក់សង្ឃ ) ថា សូមលោកទាំងឡាយចាត់ពួកភិក្ខុប៉ុណ្ណេះ ពួកភិក្ខុនីប៉ុណ្ណេះអំពីសង្ឃដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៥ ។ បុគ្គល ( ទៅនិមន្តអំពីសម្នាក់សង្ឃ ) ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះអំពីសង្ឃដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៦ ។ បុគ្គល ( ទៅនិមន្តអំពីសម្នាក់សង្ឃ ) ថា សូមលោកទាំងឡាយចាត់ភិក្ខុនីប៉ុណ្ណេះអំពីសង្ឃដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃគតា-

ទក្ខិណាទី ៧ ។

ទានដែលបុគ្គលឲ្យចំពោះភិក្ខុ និងភិក្ខុនីសង្ឃទាំងឡាយដូចសម្តែងមកនេះ ជា ៧ យ៉ាងដូច្នេះ ឈ្មោះថា សង្ឃគតាទក្ខិណាទាំងអស់ ៧ យ៉ាងនេះ ។

**ឯកតោ ភិក្ខុសង្ឃោ** ទានដែលចាត់ជាសង្ឃទានដូចសម្តែងមកនេះលើកទុកសិន និងទានតាំងនៅក្នុងទីជាសង្ឃទានពិត នេះក៏កើតមាននៅចំពោះពួកបុគ្គលអ្នកមានគារវៈ អាចដើម្បីនឹងគោរពកោតក្រែងចំពោះព្រះសង្ឃ ។ អាការដែលធ្វើការគោរពកោតក្រែងចំពោះព្រះសង្ឃនោះ ធ្វើបានដោយលំបាក មិនមែនបានដោយងាយៗ នោះទេ ។

អធិប្បាយថា បុគ្គលណាគិតថា នឹងថ្វាយទានឲ្យតាំងនៅក្នុងទីជាសង្ឃទាននោះ ទើបចាត់ចែងគ្រឿងទេយ្យទានទាំងឡាយឲ្យប្រណីតផ្ចិតផ្ចង់ បន្ទាប់មក ក៏ចេញទៅកាន់វត្តអារាម នមស្ការភិក្ខុសង្ឃ ហើយក៏និមន្តថា សូមលោកទាំងឡាយចាត់ភិក្ខុប៉ុណ្ណោះអំពីសង្ឃ ដើម្បីខ្ញុំហើយទើបឲ្យទាន ។ លុះខ្លួនបានតែសាមណេរមកអំពីភិក្ខុសង្ឃ រមែងកើតការក្តៅក្រហាយថា ឥឡូវនេះ ខ្ញុំថ្វាយទាន និមន្តមកបានតែសាមណេរទៅវិញ ទានរបស់បុគ្គលនោះ ក៏មិនតាំងនៅក្នុងទីជាសង្ឃទាន ។

បើនិមន្តបានព្រះមហាថេរៈ ក៏កើតសោមនស្សរីករាយត្រេកអរថា ឥឡូវនេះ ខ្ញុំបានព្រះមហាថេរៈ ទានរបស់បុគ្គលនោះ ក៏មិនតាំងនៅក្នុងទីជាសង្ឃទាន ។ បុគ្គលណាបានសាមណេរ ឬបានភិក្ខុកំលោះដែលឧបសម្បទា ឬព្រះមហាថេរៈចាស់ៗ ឬបានតែភិក្ខុកំលោះពាល ឬបានភិក្ខុអ្នកជាបណ្ឌិតអង្គណាមួយអំពីសម្នាក់សង្ឃនោះ គ្មានការសង្ស័យ តាំងចិត្តក្នុងសង្ឃ ថាខ្លួនបានឲ្យទានចំពោះសង្ឃ ធ្វើដូច្នេះទើបបានឈ្មោះថា សង្ឃទានពិតប្រាកដ ដូចឧបាសកម្នាក់ធ្វើ ។

បានឮមកថា កុដុម្ពិកៈម្នាក់ជាម្ចាស់វត្ត គិតនឹងថ្វាយទានឲ្យតាំងនៅក្នុងទីជាសង្ឃទានពិត ទើបទៅនិមន្តអំពីសម្នាក់សង្ឃថា សូមលោកម្ចាស់ចាត់ភិក្ខុសង្ឃមួយរូប ។កុដុម្ពិកៈនោះបានភិក្ខុទ្រុស្តសីលមួយរូបមក ។ ទើបប្រើអ្នកបម្រើឲ្យរៀបចំសម្អាតអាសនៈឲ្យអស់មន្ទិល ឲ្យក្រាលកម្រាលឲ្យជាអាសនៈដ៏បវរ ខាងលើអាសនៈនោះ ចងដោយពិតានព្យួរទៅដោយកម្រងផ្កា គ្រឿងក្រអូប ធ្វើនូវសក្ការបូជាផ្សេងៗ លាងជើងភិក្ខុទ្រុស្តសីល លាបដោយប្រេងក្រអូប ធ្វើការគោរពកោតក្រែងយ៉ាងក្រៃលែង ដូចគោរពចំពោះព្រះតថាគត អាស្រ័យដោយការគោរពកោតក្រែងចំពោះសង្ឃដ៏ល្អក្រៃលែង ដូច្នេះ

ហើយ ក៏ថ្វាយនូវទានរបស់ខ្លួនដែលគាត់តែងទុកនោះ ។ ខាងក្រោយនៃភត្តកិច្ច ភិក្ខុទ្រុស្តសីលនោះមកកាន់ផ្ទះកុដុម្ពិកៈម្តងទៀត បំណងមកខ្ចីចបទៅជម្រះស្មៅក្នុងវត្ត ឯឧបាសកនោះក៏នៅផ្ទះដែរ ក៏កៀសយកចបដោយជើងរបស់ខ្លួន បោះឲ្យដល់ភិក្ខុទ្រុស្តសីលនោះថាសូមលោកយកទៅចុះ ។ មនុស្សទាំងឡាយឃើញកុដុម្ពិកៈធ្វើដូច្នោះ ទើបពោលជាមួយនឹងកុដុម្ពិកៈនោះថា កាលពីព្រឹកមិញលោកគោរពកោតក្រែងចំពោះភិក្ខុនេះណាស់ ពេលនេះលោកធ្វើចំពោះភិក្ខុរូបនេះ ម្តេចក៏អាក្រក់ម្ល៉េះ កៀសចបដោយជើងបោះឲ្យគ្មានក្រែងសូម្បីតែបន្តិច លោកធ្វើដូច្នេះ មានហេតុផលដូចម្តច ? ទើបឧបាសកប្រាប់ថា នែអ្នកទាំងឡាយ កាលពីព្រឹកមិញនោះ ខ្ញុំគោរពកោតក្រែងចំពោះព្រះសង្ឃ ខ្ញុំគ្មានបានគោរពចំពោះភិក្ខុទ្រុស្តសីលទេ ។ ការគោរពកោតក្រែងក្នុងសង្ឃ ដូចកុដុម្ពិកៈនោះ ទើបជាសង្ឃទានពិតប្រាកដ បានធ្វើសង្ឃទានរួចហើយ ផលទាននោះក៏នឹងមានផលច្រើន កុំគប្បីធ្វើចំពោះភិក្ខុឡើយ សូម្បីបានឲ្យចំពោះភិក្ខុទ្រុស្តសីលក្តី ជននោះឧទ្ទិសចំពោះសង្ឃ ហើយឲ្យទានក៏មានអានិសង្សប្រសើរ ក្រៃលែងជាងបាដិបុគ្គលិកទាន ដែលបុគ្គលថ្វាយ

ចំពោះព្រះឱណាស្រេចនោះទៀត ។

ព្រះមានព្រះភាគត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ ក្នុងកាលជាអនាគត នឹងមានគោត្រភូសង្ឃ គឺសង្ឃមានតែឈ្មោះ មានតែសំពត់កាសាវៈចង-ក ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ជនទាំងនោះឧទ្ទិសចំពោះសង្ឃ ហើយនឹងឲ្យទាន ដល់បុគ្គលទ្រុស្ត-សីលទាំងនោះ ម្នាលអានន្ទ សូម្បីក្នុងកាលនោះ តថាគតក៏ពោលថា សង្ឃគតាទក្ខិណាទានដោយពិត មាននូវអានិសង្សរាប់មិនបានប្រមាណមិនអស់ ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិ-បុគ្គលិកទានថា មានផលច្រើនជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ ។ ព្រះពុទ្ធដីកាត្រាស់ដូច្នេះ ព្រោះថា ព្រះអង្គសំដៅយកសង្ឃគតាទក្ខិណាទាន ដែលបុគ្គលគោរពក្នុងសង្ឃ និងឧទ្ទិសចំពោះសង្ឃហើយទើបឲ្យ ។

សេចក្តីដែលសម្តែងដោយលក្ខណៈផ្សេងៗ តាំងអំពីទក្ខិណាវិសុទ្ធិ ៤ ប្រការ រហូតដល់សង្ឃទាននេះ អ្នកប្រាជ្ញគប្បីជ្រាបថា ព្រះសាស្តាត្រាស់សម្តែងនៅក្នុង ទក្ខិណាវិភង្គសូត្រ ក្នុង មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ នវមភាគ ។

សេចក្តីក្នុង **អដ្ឋកថាចីវរក្ខន្ធកៈ** ព្រះវិន័យនោះ ក៏មានសេចក្តីប្រហាក់ប្រហែលគ្នាថា **បុព្វេ ពុទ្ធប្បមុខស្ស ឧភតោ សង្ឃស្ស ទានំ ទេន្តិ ភគវា មជ្ឈេ និសីទតិ** ក្នុងកាលមុន ព្រះមានព្រះភាគនៅមានព្រះជន្មនៅឡើយនោះ បុគ្គលថ្វាយទាន ចំពោះឧភតោសង្ឃមានព្រះពុទ្ធជាប្រធាន ព្រះអង្គគង់ត្រង់កណ្តាល ។ សង្ឃទាំងពីរចំណែក គឺពួកភិក្ខុសង្ឃអង្គុយម្ខាង ពួកភិក្ខុនីសង្ឃអង្គុយម្ខាង ។ ព្រះសាស្តាព្រះអង្គទទួលនូវបច្ច័យទាំងឡាយ ដែលព្រះអង្គបានដោយចំពោះព្រះអង្គហើយ ញុំាងទាយកទាំងឡាយឲ្យថ្វាយចំពោះភិក្ខុសង្ឃនិងភិក្ខុនីសង្ឃទាំងឡាយ ។ ប៉ុន្តែកាលដែលព្រះសាស្តាបរិនិព្វានទៅហើយនោះ គេតម្កល់ព្រះពុទ្ធប្បដិមា ឬព្រះធាតុលើអាសនៈក្នុងទីចំពោះមុខសង្ឃ តម្កល់ម្ហូបចំណីលើតុ ឬជើងស្រោពក៏ ហើយធ្វើកិច្ចទក្ខិណោទកជាដើម ថ្វាយវត្ថុទាំងពួង ចំពោះព្រះសាស្តាជាមុន **វិហារំ អាហរិត្វា** ហើយនាំទៅកាន់វត្តថា វត្ថុទាំងនេះខ្ញុំថ្វាយចំពោះព្រះចេតិយ មួយទៀត ថ្វាយបិណ្ឌបាត ឬផ្កាឈើ គ្រឿងក្រអូបជាដើម តើថ្វាយដូចម្តេច ? បើជាផ្កាឈើ ឬគ្រឿងក្រអូបនោះ គប្បីលើកឡើងតម្កល់ទុកខាងលើព្រះចេតិយ បើជាបិណ្ឌបាត និងទឹក មានទឹកអំពៅ

ជាដើមនោះ គប្បីប្រគេនដល់បព្វជិត ឬឲ្យគ្រហស្ថ ដែលជាអ្នកបដិបត្តិព្រះចេតិយជានិច្ចនោះ បើបព្វជិត ឬគ្រហស្ថ អ្នកបដិបត្តិព្រះចេតិយមិនមានទេ ក៏គួរនឹងដាក់ក្នុងភាជនៈដែលជារបស់ខ្លួន ធ្វើវត្តជាមុនហើយ ទើបបរិភោគ ឬក៏ពេលនោះ បរិភោគរួចហើយ ទើបធ្វើវត្តជាខាងក្រោយក៏គួរ មិនមានទោសទេ អាការដែលធ្វើវត្ត គឺបោស សម្អាតទីលានព្រះចេតិយ និងដើមពោធិព្រឹក្សមិនឲ្យមានសំរាមមិនឲ្យមានមន្ទិល បើវត្ថុទាំងពួងនោះជាប្រេង ឬសាជក ត្រូវអុជប្រទីបចង្កៀងជាទង់ ឬពិតានទុកបូជាទីព្រះចេតិយបញ្ចុះព្រះបរមធាតុ ។ បុគ្គលជាបណ្ឌិតគប្បីបដិបត្តិដូចពោលមកនេះ ទើបប្រាសចាកទោស ។

**នានាទិបុញ្ញកម្មានិ** បុញ្ញកម្មទាំងឡាយ មានទានជាដើម ព្រះនន្ទាចារ្យសម្តែងទុកយ៉ាងនេះ ដោយអំណាចកំណត់យកពាក្យឧបមា ។

ក្នុង អដ្ឋកថាវេលាមសូត្រ ក្នុង អង្គុត្តរនិកាយ ថា **សចេហិ សកលជម្ពុទីបំ ភេរិតលមិវ សមតលំ កត្វា កោដិតោ បដ្ឋាយ បល្លង្កេ អត្ថរិត្វា អរិយបុគ្គលេ និសីទាបេសុំ** បើបុគ្គលធ្វើជម្ពូទ្វីបឲ្យរាបស្មើដូចផ្ទៃស្គរហើយ ទើបរៀបចំក្រាលនូវអាសនៈ

ដ៏ប្រសើរ ចាប់ផ្តើមតាំងពីទីបំផុតម្ខាង រហូតដល់ទីបំផុតម្ខាងទៀត ពេញទាំងជម្ពូទ្វីបហើយ និមន្តព្រះអរិយបុគ្គលឲ្យមកអង្គុយ សោតាបន្នបុគ្គលអង្គុយជាជួរ ១០ ជួរ សកទាគាមិបុគ្គល ៥ ជួរ អនាគាមិបុគ្គល ៣ ជួរកន្លះ ព្រះខីណាស្រពកន្លះជួរ ព្រះបច្ចេកពុទ្ធ ១ ជួរ **សម្មាសម្ពុទ្ធោ ឯកោវ** ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គគង់ជាប្រធាន ហើយក៏ថ្វាយទានចំពោះតែព្រះពុទ្ធមួយព្រះអង្គ **មហប្ផលំ** មានផលច្រើនជាងទានដែលបុគ្គលថ្វាយចំពោះព្រះអរិយៈទាំងឡាយមានប្រមាណប៉ុណ្ណោះ **សង្ឃគ្គេ កត្វា** ទានដែលបុគ្គលធ្វើចំពោះសង្ឃ មានព្រះពុទ្ធគង់នៅកណ្តាល ហើយថ្វាយចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន **មហប្ផលំ** បានផលច្រើនក្រៃលែងជាងទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធតែមួយព្រះអង្គ **តតោបិ បតិដ្ឋិតេ ចេតិយេ** ព្រះវិហារណា ជាកន្លែងស្តាប់ព្រះធម៌ទេសនា បុគ្គលបានកសាងមានព្រះចេតិយតាំងនៅជាទីសម្គាល់ បណ្ណសាលាប្រមាណ ៤ ហត្ថយ៉ាងតូច ឧទ្ទិសចំពោះសង្ឃ ដែលនិមន្តមកអំពីទិសទាំង ៤ ហើយកសាងក្នុងវត្តនោះ **មហន្តោ** មានផលច្រើនជាងសង្ឃទាន ដែលបុគ្គលថ្វាយចំពោះសង្ឃ មានព្រះពុទ្ធជាប្រធាននោះ **បសន្នមានសា គហិត-**

**សរណាគមធំ** អាការដែលដឹងគុណព្រះរតនត្រ័យ ហើយទីងតាំងនៅក្នុងព្រះត្រៃសរណាគមន៍យ៉ាងមាំទាំស៊ប់សួន ដោយចិត្តជ្រះថ្លា **មហាបួលំ** ក៏មានផលានិសង្សច្រើនក្រៃលែង ជាងអានិសង្សរបស់បណ្ណសាលានោះ **បញ្ចសិក្ខាបទសមាទានធំ** អាការសមាទាននូវសិក្ខាបទ ដែលខ្ទនរក្សាជានិច្ចសីល ដោយចិត្តជ្រះថ្លា ក៏មានអានិសង្សក្រៃលែងជាងការតាំងនៅក្នុងត្រៃសរណាគមន៍ ។ អាការដែលចម្រើនមេត្តាមិនច្រើនប្រមាណស្មើនឹងទឹកដោះគោស្រក់មួយតំណក់ ឬមួយរឹតទឹកដោះគោក៏មានផលានិសង្សច្រើនក្រៃលែងជាងការរក្សាសីល ៥ នោះ។ អាការដែលរឭក ឬត្រិះរិះដល់អនិច្ចសញ្ញា គឺដឹងទៅក្នុងសង្ខារទាំងឡាយនោះ សុទ្ធតែជាអនិច្ចំ មិនទៀងទាត់ ។ សូម្បីការពិចារណាមិនច្រើន ត្រឹមតែមួយខណៈផ្ទាត់ក្រចកដៃក្តី ក៏មានផលានិសង្សច្រើនក្រៃលែងជាងការចម្រើនមេត្តានោះ **ការណ៍**វិហេតុនៃអានិសង្សក្នុងគុណជាតិខាងលើៗ ព្រះអដ្ឋកថាចារ្យសម្តែងទុកក្នុង *អដ្ឋកថាកូដ-ទន្តសូត្រ* ក្នុង *គម្ពីរទីឃនិកាយ* ។

ម្យ៉ាងទៀត អានិសង្សរបស់ចីវរទាន លោកអាចារ្យពួកខ្លះសម្តែងទុកក្នុងលក្ខណាទាន ដោយសុត្តន្តបរិយាយជាដើមដូច្នេះថា ព្រះ

យោគាវចរអ្នកសេពនូវចីវរនោះ ដើម្បីបំបាត់ភាពត្រជាក់ ជាប្រយោជន៍ កំណត់កាលត្រឹមណា ក៏សេពនូវចីវរកំណត់កាលត្រឹមប៉ុណ្ណោះ មាន អានិសង្ស ៣០ ប្រការ លោកអាចារ្យពួកខ្លះ សម្ដែងទុកក្នុងខន្ធក បរិយាយដោយគាថាទាំងឡាយថា **សីតំ ឧណ្ហំ បដិហន្តិ** ជាដើម ដូច្នេះ ហេតុណា ហេតុនោះ វិហារទាំងពួងរមែងមានផលប្រសើរ ជាងចីវរទាន ដែលបុគ្គលឲ្យដូច្នេះ ។ បុញ្ញកម្មដែលលះបង់នូវជីវិតដល់ ព្រះរតនត្រ័យនោះ ឈ្មោះថា បានរក្សាត្រៃសរណគមន៍ គឺតាំង នៅក្នុងគុណព្រះរតនត្រ័យជាទីពឹងដល់ខ្លួន និងតាក់តែងសម្បត្តិឲ្យ ដល់មួយកប្ប ហេតុដូច្នោះ ព្រះត្រៃសរណគមន៍នោះ បើបុគ្គលណា បានរក្សាដោយល្អហើយ ក៏មានអានិសង្សច្រើនក្រៃលែងជាងវិហារ ទាន ។

មានសេចក្ដីក្នុង អដ្ឋកថាកូដទន្តសូត្រ ថា **សរណាគមនេន ទិដ្ឋិឧជុករណំ នាម ភារិយំ សិក្ខាបទសមាទានេបិ វិរត្តិមត្តកមេវ** ឈ្មោះថា ធ្វើបុណ្យ ធ្វើទិដ្ឋិឲ្យត្រង់ តាំងនៅក្នុងព្រះត្រៃសរណគមន៍នោះ ធ្វើបានដោយលំបាកណាស់ មិនធ្វើបានដោយងាយៗ ទេ កុំគប្បីមើល ស្រាលអាការដែលទទួលសីល ៥ នោះ គឺជាថ្ងៃវៀរតែម្ដង ។ កាលបើ

វៀរចាកនូវបាបបញ្ចវេរា មានបាណាតិបាតជាដើមបានហើយ ក៏ឈ្មោះថា បានតាំងនៅក្នុងទីសមាទានសិក្ខាបទទាំង ៥ យ៉ាងមាំទាំ ហេតុដូច្នោះ ព្រះត្រៃសរណគមន៍ របស់បុគ្គលអ្នករក្សាដោយល្អហើយ ក៏មាន ផលានិសង្សច្រើនក្រៃលែងជាងត្រៃសរណគមន៍ នៃបុគ្គលរក្សាធម្មតា ហេតុណា ហេតុនោះ បណ្តាត្រៃសរណគមន៍ និងសីល ៥ ទាំងឡាយ នោះ ត្រៃសរណគមន៍នោះ នឹងប្រសើរជាងសីល ៥ ដែលថារក្សាសីល ៥ ប្រកបដោយផលានិសង្សច្រើនជាងអានិសង្សដែលបានរក្សា ត្រៃសរណគមន៍នោះ គឺដោយអំណាចរបស់សីល ៥ ដែលបុគ្គលតាំង នៅក្នុងព្រះត្រៃសរណគមន៍ជាមុនរួចហើយ ទើបរក្សាសីលប្រាំៗ នោះ មិនប្រសើរជាងត្រៃសរណគមន៍ឡើយ ព្រោះថា សីលនោះកើត មានតាំងពីបឋមកប្បមកម្ល៉េះ តែត្រៃសរណគមន៍នេះ ព្រះសម្មា-សម្ពុទ្ធកើតមានឡើង ទើបកើតមាន ហេតុដូច្នោះ ទើបព្រះត្រៃ សរណគមន៍ ប្រសើរជាងសីល ៥ នោះដោយពិត ។

**រតនត្តយេ កថំ ទានំ ទាតព្វំ** មានពាក្យសួរថា ទានដែល បុគ្គលគប្បីថ្វាយចំពោះព្រះរតនត្រ័យនោះ នឹងថ្វាយដោយប្រការដូច ម្តេច ? ឆ្លើយថា បុគ្គលទាំងឡាយអ្នកធ្វើការបម្រើ ធ្វើសក្ការបូជា

*ព្រះពុទ្ធ កាលព្រះពុទ្ធនៅមានព្រះជន្ម ដោយបច្ច័យទាំងឡាយផ្សេងៗ ខ្លះ កាលព្រះអង្គទ្រង់បរិនិព្វានហើយ បើបុគ្គលណាឧទ្ទិសចំពោះព្រះសម្ពុទ្ធដែលព្រះអង្គបរិនិព្វានទៅហើយ ធ្វើការបម្រើ ធ្វើសក្ការបូជាចំពោះព្រះបរមធាតុដែលបញ្ចុះក្នុងព្រះចេតិយជាដើមនោះ ក៏ឈ្មោះថា ថ្វាយទានចំពោះព្រះពុទ្ធដូចគ្នា ។*

**ធម្មំ បូជេស្សាមិ** *បុគ្គលអ្នកមាននូវសេចក្តីត្រិះរិះធ្វើសក្ការ-បូជានូវព្រះធម៌ ធ្វើការបម្រើ ការបូជាចំពោះបុគ្គលអ្នកស្តាប់ប្រាថ្នានឹងធ្វើឲ្យព្រះធម៌ស្ថិតស្ថេរចិរកាល ក៏ឈ្មោះថា ថ្វាយទានចំពោះព្រះធម៌ដូចគ្នា ។*

**តថា អរិយសង្ឃេ** *មួយទៀតសោត បុគ្គលដែលបានបម្រើ ធ្វើសក្ការបូជាចំពោះព្រះអរិយសង្ឃដោយបច្ច័យទាំង ៤ ក៏ឈ្មោះថា ថ្វាយទានចំពោះព្រះសង្ឃ បើព្រះអរិយសង្ឃមិនមានទេ ក៏ត្រូវបដិបត្តិដូចពោលរួចមកហើយអំពីសង្ឃទាន ។*

*សេចក្តីនេះមានក្នុង អដ្ឋកថាអង្គុត្តរនិកាយ ថា* **យស្មឹ បទេសេ កាបេ្បតិ** *ជាដើម ព្រះគាថានេះ ព្រះមានព្រះភាគកាលព្រះអង្គត្រាស់ព្រះធម៌ទេសនាសម្តែងនូវប្រយោជន៍ ឲ្យនូវចំណែកបុណ្យឧទ្ទិសទៅ*

ដល់ទេវតាទាំងឡាយ ព្រះសម្មាសម្ពុទ្ធត្រាស់ថា មនុស្សទាំងឡាយ ក្នុងបាដលិគ្រាមនោះ បុគ្គលសម្រេចឥរិយាបថនៅក្នុងទីណា ញុំាង នូវបរិស័ទទាំងឡាយ អ្នកមានសីល ជាបណ្ឌិតជាតិ សង្រួមនូវ ឥន្ទ្រិយ រក្សាព្រហ្មចារ្យល្អ បរិច្ចាគអាហារជាទានក្នុងទីនោះហើយ គប្បីឧទ្ទិសនូវចំណែកបុណ្យឲ្យដល់ទេវតាទាំងឡាយ ដែលស្ថិតនៅ ក្នុងទីនោះគ្រប់ពេលវេលា កាលបើទេវតាទាំងឡាយ ដែលបុគ្គល ទាំងឡាយគោរពធ្វើនូវសក្ការបូជាហើយ ក៏ទទួលនូវគ្រឿងសក្ការបូជា របស់បុគ្គលនោះដែរ និងអនុគ្រោះដល់បុគ្គលនោះវិញយ៉ាងក្រៃលែង **មាតាបុត្តំវ ឱរសំ** ប្រៀបដូចមាតាដែលរក្សានូវកូន រមែងអនុគ្រោះដល់ បុត្រដែលកើតពីផ្ទៃ **ទេវតានុកម្បិតោ ចោសោ** បុគ្គលអ្នកជាបុរស មានទេវតារក្សាហើយ ក៏រមែងប្រកបដោយសេចក្តីសុខចម្រើនជានិច្ច **អយំ បនត្ថោ** សេចក្តីនេះ អ្នកប្រាជ្ញគប្បីសម្តែងដោយ មច្ឆទាន-ជាតក ក្នុង តិកនិបាត នោះ ។

**អតីតេ ពោធិសត្តោ កុដុម្ពិកកុលេ និព្វត្តិត្វា វិញ្ញុតំបត្តោ កុដុម្ពំ សណ្ឋបេសិ** ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូល កុដុម្ពិកៈ កាលចម្រើនវ័យធំដឹងក្តីឡើង ក៏សន្សំទ្រព្យដើម្បីបរិភោគ

ប្រើប្រាស់ ។ ព្រះពោធិសត្វនោះ មានប្អូនប្រុសម្នាក់ **អបរភាគេ** កាលក្រោយមក មាតាបិតារបស់កុដុម្ពិកៈទាំងពីរនោះ ក៏ធ្វើកាលកិរិយា **ឯកទិវសំ** ថ្ងៃមួយ កុដុម្ពិកៈពីរនាក់បងប្អូននោះ ទៅទារបំណុលជារបស់បិតា ដែលគេជំពាក់នោះ **កហាបណសហស្សំ លភិត្វា** លុះបានទ្រព្យ ១០០០ កហាបណៈហើយ ក៏ត្រឡប់មកផ្ទះវិញ **ប្ងជ-ភត្តំ ភុញ្ជិំសុ** អ្នកទាំងពីរនាក់ក៏លាតកញ្ចប់បាយបរិភោគ ក្នុងវេលានោះ ព្រះពោធិសត្វឲ្យទាន មានបាយជាដើម ដល់ហ្វូងត្រីទាំងឡាយក្នុងស្ទឹង **ទេវតាយ បត្តិំ អទាសិ** ហើយក៏ឲ្យនូវចំណែកបុណ្យដល់ទេវតាដែលស្ថិតនៅស្ទឹងនោះ ទេវតាអ្នករក្សានូវគង្គាបានទទួលអនុមោទនានូវចំណែកបុណ្យ ក៏មាននូវសេចក្តីត្រេកអររីករាយយ៉ាងក្រៃលែង ។ តាំងអំពីបានអនុមោទនានូវចំណែកបុណ្យនោះ ទេវតាក៏កើនទិព្វសម្បត្តិច្រើនឡើងជាងមុន **អត្តនោ យសវឌ្ឍិំ អាវជ្ជ-មានោ** កាលបើពិចារណាយសរបស់ខ្លួនដែលកើនឡើងទៅ ក៏ដឹងហេតុថា បានទទួលអនុមោទនាចំណែកបុណ្យរបស់ព្រះពោធិសត្វ ទើបកើតយសទិព្វកើនឡើងជាងមុន ។ កាលបើព្រះពោធិសត្វបរិភោគនូវអាហាររួចហើយ ទើបឡើងទៅលើធ្នេរខ្សាច់ក្រាលសំពត់

សាជក ដេកលក់នៅត្រង់ឆ្នេរខ្សាច់ កុដុម្ពិកៈជាប្អូនប្រុសរបស់ព្រះពោធិសត្វនោះ មានចិត្តអាក្រក់ បំណងនឹងមិនឲ្យនូវទ្រព្យ ១០០០ កហាបណៈនោះដល់ព្រះពោធិសត្វ គិតកេងប្រវ័ញ្ចយកតែម្នាក់ឯង ទើបយកគ្រាប់ក្រួសមកខ្ចប់ ឲ្យដូចគ្នានឹងកញ្ចប់កហាបណៈរួចហើយក៏យកទៅដាក់ជាមួយគ្នា ។ កាលបើកុដុម្ពិកៈទាំងពីរនាក់បងប្អូនឡើងទូកទៅដល់កណ្តាលស្ទឹង កុដុម្ពិកៈជាប្អូនក៏ក្លែងធ្វើជាគោះគែមទូក កំណត់នឹងយកកញ្ចប់គ្រាប់ក្រួសចោលទៅក្នុងស្ទឹង ត្រឡប់ជាចាប់យកកញ្ចប់កហាបណៈ ១០០០ ចោលទៅក្នុងស្ទឹង រួចហើយក៏ប្រាប់ដល់ព្រះពោធិសត្វថា **ភាតិក** បពិត្របង កញ្ចប់កហាបណៈ ១០០០ នោះ ធ្លាក់ទៅក្នុងទឹកហើយ ទើបព្រះពោធិសត្វប្រាប់ថា បើកញ្ចប់កហាបណៈធ្លាក់ទឹកទៅហើយ នឹងធ្វើម្តេចកើតនៅកណ្តាលស្ទឹងនេះ ប្អូនកុំគិតអ្វីឡើយ បងទាល់គំនិតហើយ ព្រះពោធិសត្វពោលវាចាត្រង់ទៅដូច្នោះ ។

**នទីទេវតា ចិន្តេសិ** ឯទេវតាដែលរក្សាស្ទឹងរំពឹងថា ខ្លួនបានទទួលការអនុមោទនានូវចំណែកបុណ្យរបស់កុដុម្ពិកៈនេះ កាលថ្ងៃដែលគេឲ្យទានបាយដល់ហ្វូងត្រីទាំងឡាយ ទើបខ្លួនបានកើនយសច្រើនឡើង

ជាងមុន អញនឹងរក្សានូវទ្រព្យរបស់បុរសនេះទុក ទើបបណ្ដាលចិត្ត ត្រីធំមួយឲ្យលេបកញ្ចប់ទ្រព្យ ១០០០ កហាបណៈនោះចូលទៅក្នុង ពោះ ដោយអានុភាពរបស់ខ្លួន ក៏រក្សាត្រីនោះ ។

**សោបិខោ ចោរោ** ឯកុដុម្ពិកៈប្អូនដែលជាចោរនោះទៅដល់ ផ្ទះក៏សប្បាយចិត្តពោលថា អញបោកបញ្ឆោតបងបាន ទ្រព្យនេះអញ បានតែម្នាក់ឯង ទើបលាតកញ្ចប់ដុំក្រួសសម្គាល់ថា ជាកញ្ចប់ទ្រព្យ **សក្ខរំ បស្សិត្វា** ក៏ឃើញដុំក្រួស កើតទោមនស្សសោយសោក ក្រៀមក្រំតែម្នាក់ឯង ។

**តទា កេវដ្ដា** ក្នុងកាលនោះ ពួកនាយប្រមង់ទាំងឡាយ ទៅបង់សំណាញ់ អូសអួនក្នុងស្ទឹងដើម្បីនឹងចាប់ត្រីយកទៅលក់ ត្រី ធំនោះ ក៏ចូលទៅជាប់ក្នុងអួនរបស់នាយប្រមង់ទាំងឡាយ ដោយ អានុភាពរបស់ទេវតា ទើបនាយប្រមង់ទាំងឡាយនាំយកត្រីនោះទៅ លក់ក្នុងក្រុង មនុស្សទាំងឡាយឃើញត្រីធំនោះ ទើបសួរតម្លៃ នាយប្រមង់ពោលថា តម្លៃ ១០០០ កហាបណៈ ៧ មាសកៈ បើ លោកទាំងឡាយឲ្យទ្រព្យ ១០០០ កហាបណៈ ៧ មាសកៈ ដល់ ពួកយើងខ្ញុំ ចូរយកត្រីនេះទៅចុះ មនុស្សទាំងឡាយក៏នាំគ្នាសើច

ចំអកថា ត្រីធំនេះថ្លៃម៉្លេះ រហូតដល់ ១០០០ កហាបណៈ ៧ មាសកៈ ខ្ញុំមិនធ្លាប់ជួប មិនធ្លាប់ឃើញទេ ។ នាយប្រមង់ទាំងឡាយ ក៏នាំគ្នាសែងត្រីធំនោះ ដើរពពាយនាយលក់តទៅទៀត រហូតទៅដល់ មុខផ្ទះព្រះពោធិសត្វ ប្រាប់ថា ខ្ញុំនលក់ត្រី ទើបព្រះបរមពោធិសត្វ សួរនូវតម្លៃរបស់ត្រីធំនោះ ។ ទើបនាយប្រមង់ទាំងឡាយពោលថា បើលោកទិញ យើងទាំងឡាយយកតែ ៧ មាសកៈ ព្រះបរម-ពោធិសត្វសួរថា ប្រសិនបើអ្នកទាំងឡាយ លក់ទៅឲ្យអ្នកដទៃ តើត្រីធំមួយនេះថ្លៃប៉ុន្មាន ? ទើបនាយប្រមង់ទាំងឡាយពោលថា បើលក់ទៅឲ្យអ្នកដទៃ ក្នុងតម្លៃ ១០០០ កហាបណៈ ៧ មាសកៈ **តុម្ហេ បន** ចំណែកលោកវិញ ពួកយើងយកតែកន្សុយ គឺ ៧ មាសកៈប៉ុណ្ណោះ **សោ តេសំ សត្តមាសកេ ទត្វា** ព្រះពោធិសត្វនោះ ក៏ឲ្យទ្រព្យ ៧ មាសកៈដល់នាយប្រមង់ទាំងឡាយ ហើយក៏យកត្រីធំនោះ ឲ្យដល់ភរិយា **សា មច្ឆស្ស កុច្ឆិំ ផាលិយមានា** កាលភរិយា ព្រះពោធិសត្វវះពោះត្រីធំនោះ ឃើញកញ្ចប់កហាបណៈ ក៏ប្រាប់ ដល់ព្រះបរមពោធិសត្វ ។ ព្រះពោធិសត្វពិនិត្យមើលនូវកញ្ចប់ កហាបណៈនោះ ឃើញចំណាំដែលខ្លួនចងចាំបានហើយ ក៏ពោល

ថា ជាកញ្ចប់ កហាបណៈរបស់ខ្លួន ។ **ឥមេ អញ្ញេសំ ធនមានា** ទើប គិតថា នាយប្រមង់លក់ត្រីឲ្យដល់អ្នកដទៃ មានតម្លៃរហូតដល់ ១០០០ កហាបណៈ ៧ មាសកៈ **អម្ហេ បន ធិស្វា** ប៉ុន្តែនាយប្រមង់ ទាំងឡាយនោះយល់ដល់មុខអញ ទើបលក់ត្រីធំនេះឲ្យដល់អញត្រឹម តែ៧មាសកៈប៉ុណ្ណោះ ទាំងនេះព្រោះទ្រព្យ ១០០០ នេះជារបស់អញ ឯប្អូនប្រុសរបស់អញ ជាមនុស្សមិនបានដឹងនូវទោសដោយប្រការ ដូច្នេះហើយ អញក៏មិនអាចដើម្បីនឹងញុំាងប្អូនប្រុសនោះឲ្យជឿនូវ សម្តីរបស់អញបាន **កិំនុខោ** ហេតុដូចម្តេចហ្ន៎ ទើបអញបានទ្រព្យ ១០០០ កហាបណៈនេះវិលមកវិញ កាលព្រះពោធិសត្វរំពឹងដូច្នេះ **តស្មិំ ខណេ** ក្នុងខណៈនោះ ទើបទេវតាអ្នករក្សាគង្គានោះ ហោះ មកនៅឰដ៏អាកាស តែមិនបានសម្តែងកាយឲ្យប្រាកដ ស្រែកប្រាប់ ថា កាលថ្ងៃដែលអ្នកឲ្យទានបាយដល់ហ្វូងត្រីទាំងឡាយ អ្នកបានឲ្យ ចំណែកបុណ្យដល់ខ្ញុំ ខ្ញុំក៏ជួយរក្សានូវទ្រព្យរបស់អ្នកទុកក្នុងពោះ ត្រីមួយនេះ ទើបទេវតាប្រាប់ដល់ឧបាយក្លែងបន្លំរបស់ប្អូនប្រុស ឲ្យ ព្រះបរមពោធិសត្វបានជ្រាបគ្រប់ប្រការ រួចហើយក៏បញ្ជាក់ចំពោះ ព្រះបរមពោធិសត្វថា ពេលនេះប្អូនប្រុសរបស់អ្នក ដេកជាទុក្ខសោក

សោកនៅលើគ្រែ មានចិត្តក្រៀមក្រំ កុដុម្ពិកៈជាប្អូនប្រុសរបស់អ្នក មានចិត្តប្រទូស្តបែបនេះ ក៏នឹងប្រាសចាកនូវសេចក្តីចម្រើន ខ្ញុំជាទេវតាប្រកបដោយឫទ្ធិឃើញថា ទ្រព្យរបស់អ្នកវិនាសអស់ ទើបបណ្តាលចិត្តត្រីជំនេះ ឲ្យលេបកញ្ចប់កហាបណៈរបស់អ្នកទុក បំណងនឹងឲ្យនាំមកនូវទ្រព្យដល់អ្នកវិញ ឥឡូវនេះ អ្នកបានទ្រព្យហើយ ចូរកុំបែងចែកទ្រព្យនេះឲ្យដល់ប្អូនប្រុសដែលជាចោរនោះឡើយ ចូររក្សាទុកជារបស់អ្នកទាំង ១០០០ កហាបណៈចុះ ទេវតាប្រាប់បញ្ជាក់ដូច្នេះហើយ ក៏បានចៀសចេញទៅ ។

**ពោធិសត្តោ** ចំណែកព្រះបរមពោធិសត្វ ព្រះអង្គមានចិត្តស្មោះត្រង់ មានចិត្តប្រកបដោយមេត្តា ករុណា ទើបគិតថា បើមិនឲ្យទ្រព្យដល់ប្អូនប្រុស គឺជាការមិនសមគួរទេ ក៏បែងចែកទ្រព្យពាក់កណ្តាលឲ្យទៅប្អូនប្រុស ។

**ឯវំ បត្តានុមោទនា ទេវតា** ទេវតាទាំងឡាយ កាលបានទទួលអនុមោទនានូវចំណែកបុណ្យហើយ ក៏រមែងអនុគ្រោះដល់បុគ្គលអ្នកដែលឲ្យចំណែកបុណ្យ ឧបមាដូចព្រះបរមពោធិសត្វនេះ ។

**តេន វុត្តំ** ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលធ្វើនូវសក្ការ-

បូជាចំពោះទេវតាទាំងឡាយហើយ ទេវតាក៏រក្សាធ្វើការអនុគ្រោះដល់ អ្នកឲ្យចំណែកបុណ្យនោះវិញ ប្រៀបដូចមាតាមើលថែរក្សាដល់កូនដែលកើតអំពីផ្ទៃរបស់ខ្លួន **អយមេត្ថ ទានាទិបុញ្ញកម្ម-សង្គហានយោ** ន័យដែលសង្គ្រោះយកនូវបុញ្ញកម្ម មានទានជាដើមក្នុងមាតិកានេះ ក៏ចប់ត្រឹមតែប៉ុណ្ណេះ ។

ទានាទិបុញ្ញកម្មកថា ចប់

# សត្តាហារវិភេទនគថា

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងបទមាតិកា គឺការផ្លាស់ប្តូរនូវអាហាររបស់សត្វទាំងឡាយប្លែកៗគ្នា អាហារទាំងឡាយដែលចិញ្ចឹមជីវិតនោះមាន ៤ ប្រការ គឺកពឡិង្ការាហារ ១ ផស្សាហារ ១ មនោ-សញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។

ដូចម្តេចទើបឈ្មោះថា **កពឡិង្ការាហារ** កពឡិង្ការាហារនោះបានដល់ អាហារទាំងឡាយ មានសណ្តែក ល្ង និងភោជនដែលបុគ្គលធ្វើជាដុំៗ ហើយលេបចូលទៅ ទើបឈ្មោះថា **កពឡិង្ការាហារ** ។ កពឡិង្ការាហារ ប្រែថា ធ្វើជាដុំ ។ អាហារ ប្រែថា ប្រមូលលេបចូល ពាក្យថា កពឡិង្ការាហារនោះ គឺជាឈ្មោះរបស់ឱជាដែលជ្រួតជ្រាបនៅក្នុងវត្ថុរបស់របរទាំងឡាយ មានបាយ សណ្តែក ល្ងជាដើម **សោបណ** ក៏កពឡិង្ការាហារនោះ ជាអាហារដ៏គ្រោតគ្រាត ព្រោះវត្ថុគ្រោតគ្រាត ១ កពឡិង្ការាហារកើតប្រាកដសុខុម គឺជាអាហារខាងក្នុងល្អិតសុខុមក្រៃលែង ព្រោះថា អាហារនោះ រាប់ចូលនៅក្នុងសុខុមរូប ដោយសភាវៈជាអត្ថបរមត្ថ ។ វិសភាពនៃអាហារនោះ ឈ្មោះថា

សុខុម ឈ្មោះថា គ្រោតគ្រាត នោះ ព្រោះថា អាហារនោះ ប្រកបដោយវត្ថុដ៏ល្អិត និងវត្ថុដ៏គ្រោតគ្រាត អ្នកប្រាជ្ញគប្បីជ្រាប និងប្រៀបធៀបនូវអាហារទាំងឡាយរបស់សត្វនោះ ។

មានពាក្យអធិប្បាយថា **កុម្ភិលានំ ឧចាទាយ មោរានំ អាហារោ** ប្រសិនបើនឹងយកអាហាររបស់សត្វក្ងោក មកប្រៀបនឹងអាហាររបស់សត្វក្រពើ អាហាររបស់សត្វក្ងោកនោះល្អិតៗ ជាងអាហាររបស់សត្វក្រពើ ព្រោះថា សត្វក្រពើនោះលេបនូវដុំថ្ម **តេ ច នេសំ កុច្ឆិគតា** ដុំថ្មទាំងឡាយនោះធ្លាក់ចុះកាន់ផ្ទៃ របស់សត្វក្រពើទាំងឡាយនោះ ក៏បែកខ្ទេចជាអាហារដ៏គ្រោតគ្រាត **មោរា សប្បវិ- ច្ឆិកាទិខាទេណ** សត្វក្ងោកទាំងឡាយស៊ីនូវសត្វទាំងឡាយ មានពស់ ខ្យួយ ក្អែបជាដើម ជាអាហារដែលតូចៗ ១ ។ ប្រសិនបើយកអាហាររបស់ខ្លែព្រៃ មកប្រៀបធៀបនឹងអាហាររបស់សត្វក្ងោក អាហាររបស់សត្វខ្លែព្រៃល្អិតជាងអាហាររបស់សត្វក្ងោក ធម្មតាខ្លែព្រៃទាំងនោះរមែងស៊ីស្នែងសត្វ និងឆ្អឹងទាំងឡាយ ដែលបុគ្គលបោលអស់រយៈកាល ៣ ឆ្នាំហើយក៏ដោយ ឆ្អឹងនោះក៏ជាអាហាររបស់ខ្លែព្រៃបានដែរ ដែលផ្សើមទៅដោយទឹកមាត់របស់ខ្លែព្រៃទាំងឡាយនោះហើយ ក៏ទន់

រលាយទៅបីដូចមើមដំឡូងដែលតូចខ្ទីជាអាហារ **តិរច្ឆានំ អាហារំ ឧបាទាយ** បើយកអាហាររបស់ដំរីទាំងឡាយ មកប្រៀបធៀបនឹងអាហាររបស់ឆ្កែព្រៃ អាហាររបស់ដំរីល្អិតជាងអាហាររបស់ឆ្កែព្រៃ ព្រោះថា ដំរីទាំងឡាយ តែងតែស៊ីស្មៅ ស្លឹកឈើ មែកឈើផ្សេងៗ ជាអាហារ ទើបល្អិតជាងអាហាររបស់ឆ្កែព្រៃ ។ អាហាររបស់គោ ខ្ទីង រមាំង ទ្រាយជាដើមនោះ ល្អិតជាងអាហាររបស់ដំរីទាំងឡាយ ព្រោះថា គោ ខ្ទីង រមាំង ទ្រាយជាដើមនោះស៊ីតែស្លឹកឈើ និងស្មៅផ្សេងៗ ។ អាហាររបស់គោទាំងឡាយ ល្អិតជាងអាហាររបស់រមាំង និងទ្រាយទាំងឡាយ ព្រោះថា គោនោះស៊ីស្មៅស្រស់ និងស្មៅស្ងួត អាហាររបស់ទន្សាយ ល្អិតជាងអាហាររបស់គោទាំងឡាយ អាហាររបស់សកុណជាតិទាំងឡាយ ល្អិតជាងអាហាររបស់សត្វទន្សាយ ។ អាហាររបស់មនុស្សអ្នកបច្ចន្តប្រទេស ល្អិតជាងអាហាររបស់សកុណជាតិទាំងឡាយ អាហាររបស់នាយគោបាល ( អ្នករក្សាគោព្រះរាជទ្រព្យ ) ល្អិតជាងអាហាររបស់អ្នកបច្ចន្តប្រទេស អាហាររបស់ព្រះមហាក្សត្រ និងមហាមាត្យ ល្អិតជាងអាហាររបស់នាយគោបាល អាហាររបស់ស្តេចចក្រពត្តិ ល្អិតជាងអាហាររបស់ព្រះរាជាទាំងឡាយ

អាហាររបស់កុម្ភទេវតា ល្អិតជាងអាហាររបស់ស្តេចចក្រពត្តិ អាហាររបស់ទេវតាទាំងឡាយក្នុងជាន់ចាតុម្មហារាជិកា ល្អិតជាងអាហាររបស់កុម្ភទេវតាទាំងឡាយ អាហាររបស់ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្ស ល្អិតជាងអាហាររបស់ចាតុម្មហារាជិកាទេវតាទាំងឡាយ អាហាររបស់ទេវតាទាំងឡាយក្នុងជាន់យាមា ល្អិតជាងអាហាររបស់ទេវតាជាន់តាវត្តិង្ស អាហាររបស់ទេវតាទាំងឡាយជាន់តុសិត ល្អិតជាងអាហាររបស់ទេវតាទាំងឡាយក្នុងជាន់យាមា អាហាររបស់ទេវតាទាំងឡាយក្នុងជាន់និម្មានរតី ល្អិតជាងអាហាររបស់ទេវតាទាំងឡាយជាន់តុសិត អាហាររបស់ទេវតាទាំងឡាយក្នុងជាន់បរនិម្មិតវសវត្តី ល្អិតជាងអាហាររបស់ទេវតាទាំងឡាយក្នុងជាន់និម្មានរតី អ្នកប្រាជ្ញគប្បីជ្រាបលក្ខណៈអាហាររបស់ទេវតាទាំងឡាយ ល្អិតជាងគ្នាទៅ គ្រប់ៗ ជាន់ ដោយប្រការដូច្នេះ ។

**ឯត្ថ ច ឱឡារិកេ វត្ថុស្មឹ** ក្នុងកាលវត្ថុទាំងឡាយគ្រោតគ្រាត ឱជារសរបស់វត្ថុដ៏គ្រោតគ្រាតនោះ ក៏ទុព្វលភាព ។ ប្រសិនបើវត្ថុទាំងពួងល្អិត ឱជារបស់វត្ថុដែលល្អិតនោះ ក៏នាំឲ្យមានកម្លាំងមាំមួន ។

**តថា ហិ** ពាក្យដែលពោលនោះសមគួរពិតហើយ **ឯកបត្ត-**

**ប្ចុរម្បិ យាគុំ បិតោ** សូម្បីបុគ្គលបរិភោគយាគូ ហុតចូលទៅប្រមាណមួយបាត្រក្តី មិនយូរប៉ុន្មានយាគូនោះ ក៏នឹងរលាយហួតទៅ អ្នកនោះក៏ផ្សាពោះ មានសេចក្តីប្រាថ្នាដើម្បីបរិភោគវត្ថុណាទីមួយបន្ថែម **សប្បិ បន បសតាមត្តំ បិវិត្វា** ម្យ៉ាងទៀត បើបានផឹកនូវសប្បិប្រមាណមួយទូកដៃ ក៏អាចនឹងធន់នៅមួយថ្ងៃមួយយប់បានមិនឃ្លាននូវអាហារទៀត ព្រោះឆ្អែតដោយសប្បិនោះ ព្រោះថា សប្បិនោះជាអាហារល្អិត ទើបមានកម្លាំងមាំមួនធន់នៅបានមួយថ្ងៃ មួយយប់ **តត្ថ វត្ថុ កម្មជតេជសង្ខាតំ បរិស្សមំ វិនោទេតិ** បណ្តាវត្ថុនិងឱជាទាំងឡាយនោះ វិវត្ថុបរិភោគទាំងឡាយផ្សេងៗ នេះ មានគុណគឺបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយ ពោល គឺភ្លើងធាតុកើតពីកម្ម ប៉ុន្តែវត្ថុទាំងពួងនោះ មិនអាចរក្សាជីវិតទុកបាន តែឱជាដែលជ្រួតជ្រាបទៅក្នុងកាយទាំងមូលនោះ រក្សាជីវិតទុកបាន តែឱជាមិនអាចបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយ ពោល គឺធាតុ ដែលកើតឡើងអំពីកម្មបាន **ទ្វេ បន ឯកតោ ហុត្វា** ធម្មជាតិ ២ ប្រការ គឺវត្ថុ និងឱជាមានសភាពប្រជុំចូលជាមួយគ្នា ក៏អាចបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយ និងអាចដើម្បីរក្សានូវជីវិតបាន អធិប្បាយថា កពឡិង្ការាហារនោះមាន

២ យ៉ាង ជាឧបាទិន្នកម្យ៉ាង ជាអនុបាទិន្នកម្យ៉ាង ។ កពឡិង្គារាហារ ដែលជាឧបាទិន្នកនោះ អ្នកប្រាជ្ញគប្បីជ្រាបដោយអំណាចរបស់សត្វកង្កែប ដែលត្រូវពស់លេបចូលទៅ អធិប្បាយថា សត្វកង្កែបដែលត្រូវពស់លេបចូលទៅក្នុងពោះនោះ មានជីវិតរស់នៅមួយភ្លែតដែរ កាលកង្កែបតាំងនៅក្នុងឧបាទិន្នក គឺមានជីវិតរស់នៅកំណត់អស់កាលប៉ុនណា ក៏មិនទាន់សម្រេចនូវប្រយោជន៍ ជាអាហារអស់កាលប៉ុណ្ណោះ លុះត្រាតែកង្កែបស្លាប់ពេលណា តាំងនៅក្នុងអនុបាទិន្នកហើយ ទើបសម្រេចនូវប្រយោជន៍ជាអាហារ កាលសត្វកង្កែបនៅមានជីវិត ទើបហៅថាឧបាទិន្នកាហារ បើស្លាប់ហើយហៅថា អនុបាទិន្នកាហារ ពាក្យនេះមិនបានគាប់ចិត្តចំពោះព្រះអរិយៈទាំងឡាយទេ ព្រះអរិយៈហាមទុកក្នុងអដ្ឋកថាដោយពិត ឈ្មោះថា ឱជាដែលកើតពី កម្មនោះ គឺកើតព្រមដោយបដិសន្ធិចិត្តរបស់សព្វសត្វទាំងឡាយៗ នេះ សូម្បីមិនបានស៊ីក្តី ឱជានោះគង់តែកើតមានតាំងអំពីបដិសន្ធិម្ល៉េះ ឱជានេះកើតព្រមគ្នានឹងខណៈបដិសន្ធិចិត្ត ទើបចាត់យកជាអាហារបាន **សាយាវសត្តមា ធិវសាចាលេតិ** ឱជានោះជ្រួតជ្រាបទៅ ក៏រក្សាជីវិតទុកបានកំណត់ដល់ ៧ ថ្ងៃ ហេតុដូច្នោះ ឱជាដែលចាត់យកជាអាហារ

កើតព្រមដោយខណៈបដិសន្ធិចិត្តនោះ អ្នកប្រាជ្ញគប្បីជ្រាបថា ជាឧបាទិន្នកកវឡិង្ការាហារ បណ្ដាអាហារទាំង ៤ នោះ រីកពឡិង្ការាហារជាភ្នាក់ងារប្រមូលមកនូវរូបទាំងឡាយ មានឱជាជាគម្រប់ ៨ ។ អធិប្បាយថា កពឡិង្ការាហារប្រមូលមកនូវបឋវី អាបោ តេជោ វាយោ វណ្ណោ គន្ធោ រសោ ឱជា ទើបប្រមូលមកនូវរូបទាំងឡាយ មានឱជាជាគម្រប់ ៨ ។

**ផស្សាហារ** នោះ ប្រមូលមកនូវវេទនាទាំង ៣ផស្សៈនោះបានដល់ ផស្សៈ ៦ ប្រការ គឺចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១ ឃានសម្ផស្ស ១ ជិវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ។ ផស្សៈ ៦ នេះ ក៏ជាអាហារ ព្រោះនាំមកនូវវេទនាទាំង ៣ មានសុខវេទនា ទុក្ខវេទនា និងអទុក្ខមសុខវេទនា កាលបើសត្វទាំងឡាយបានសម្ផស្សប៉ះពាល់នូវអារម្មណ៍ដែលប៉ះខ្ទប់តាមចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនៈនោះហើយ ក៏ទៀងតែនឹងកើតវេទនាទាំង ៣ ប្រការ ហេតុដូច្នោះ ទើបផស្សៈប្រមូលមកនូវវេទនាទាំង ៣ ។

**មនោសញ្ចេតនាហារ** ប្រមូលមកនូវភពទាំង ៣ គឺកាមភព រូបភព អរូបភព ។ ចេតនាដែលជាកុសល និងអកុសល គឺចេតនាដែលជាបុណ្យ និងជាបាបនោះ ប្រកបដោយអាសវធម៌ទាំង ៤ គឺ

កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ អាសវៈទាំង ៤ នេះ ឈ្មោះថា **មនោសញ្ចេតនា** មនោសញ្ចេតនានេះកើតជាអាហារ ប្រមូលមកនូវភពទាំង ៣ ហេតុដូច្នោះ ទើបបានឈ្មោះថា មនោសញ្ចេ-តនាហារ សរុបសេចក្តីថា មនោសញ្ចេតនាហារ គឺចេតនាដែលជាបុណ្យ ជាបាប ប្រកបដោយអាសវធម៌ ដែលកើតក្នុងសន្តានរបស់សត្វទាំងឡាយនោះប្រមូលមកនូវភព ។

**វិញ្ញាណាហារ** ប្រមូលមកនូវនាម និងរូបក្នុងបដិសន្ធិចិត្តទាំងឡាយៗ មាន ១៩ ដួង គឺជាកាមាវចរវិបាក ១០ ដួង និងជាមហគ្គតវិបាក ៩ ដួង ហៅថា វិញ្ញាណ ១៩ ដួង ។ វិញ្ញាណ ១៩ ដួងនេះ កើតជាភ្នាក់ងារតាក់តែងបដិសន្ធិ ។ បដិសន្ធិវិញ្ញាណទាំង ១៩ ដួងនោះ ដួងណាមួយបដិសន្ធិឡើងក្នុងភពហើយ ក៏បានឈ្មោះថា វិញ្ញាណាហារ គឺប្រមូលមកនូវនាម និងរូបក្នុងខណៈដែលបដិសន្ធិនោះ បើនឹងអធិប្បាយវិញ្ញាណទាំង ១៩ ដួងនោះ សេចក្តីក្នុងអាហារក៏វែងឆ្ងាយទៅ ។ **អាហារ** សព្ទនោះ ប្រែថា នាំមក ប្រមូលមក បើជា **កពឡិង្ការាហារ** កាលដាក់ចូលក្នុងមាត់លើអណ្តាតហើយ ក៏ញុំាងរូបទាំងឡាយឲ្យកើតមុន **ឯកេកំ សិត្ថំ** គ្រាប់បាយមួយគ្រាប់ៗ

លម្អិតដោយធ្មេញ ទំពាឲ្យល្អិត រួចហើយលេបចូលទៅនោះ ក៏ញុំាងរូបទាំងឡាយឲ្យកើតកពិត ទើបកពឡិង្ការាហារ នាំមកនូវរូបទាំងឡាយ មានឱជាជាគម្រប់ ៨ ដោយប្រការដូច្នេះ រូបទាំង ៨ នោះហៅថា **អវិនិព្ភោគរូប** ជារូបដែលមិនបែកពីគ្នា ជារូបកលាបៈតែមួយ បានដល់ បឋវី អាបោ តេជោ វាយោ វណ្ណោ គន្ធោ រសោ ឱជា នោះ តែងតែកើតឡើងអំពី **កពឡិង្ការាហារ** ។

**ផស្សាហារោ បន** ឯផស្សាហារនោះកាលកើត ញុំាងបុគ្គលឲ្យទទួលនូវវេទនាជាសុខហើយ ក៏បានឈ្មោះថា នាំមកនូវសុខវេទនា ជាទុក្ខហើយ ក៏បានឈ្មោះថា នាំមកនូវទុក្ខវេទនា កាលកើតឡើង ញុំាងបុគ្គលឲ្យទទួលនូវវេទនាដែលជាឧបេក្ខាហើយ ក៏បានឈ្មោះថា នាំមកនូវអទុក្ខមសុខវេទនា ទើបផស្សាហារបានឈ្មោះថា នាំមកនូវវេទនាទាំង ៣ ដោយប្រការដូច្នេះ គប្បីយល់ចូលចិត្តដោយសេចក្តីថា បើផស្សៈទាំង៦មានចក្ខុសម្ផស្សជាដើម នៅតែប្រព្រឹត្តទៅដរាបណា ក៏ឈ្មោះថា ផស្សៈកើតប្រព្រឹត្តទៅដរាបនោះ ហើយក៏ទៀងតែនឹងនាំមកនូវវេទនាទាំង ៣ ប្រការ កើតជាសុខ កើតជាទុក្ខ កើតជាឧបេក្ខា ក្នុងសន្តានរបស់ខ្លួនគ្រប់ពេលវេលា រហូតដល់ចុតិជា

ទីបំផុត ។

**មនោសញ្ចេតនាហារោ** ចំណែកមនោសញ្ចេតនាហារមិនមែនដទៃ គឺកុសលាកុសលកម្មនេះឯង ។ បុគ្គលធ្វើនូវកុសលកម្មសមគួរ នឹងទៅកើតក្នុងកាមភព ១១ គឺអបាយភូមិ ៤ មនុស្ស ១ កាមាវចរសួគ៌ ៦ ជាន់នោះ បើបុគ្គលធ្វើកម្មសមគួរនឹងទៅកើតជាព្រហ្មក្នុងរូបភពនិងអរូបភព គឺបាននូវសមាបត្តិ ៨ ប្រការនោះហើយក៏នាំមកនូវរូបភព និងអរូបភព បានកើតក្នុងព្រហ្មលោកនោះ ទើបកុសលាកុសលកម្ម បានឈ្មោះថាមនោសញ្ចេតនាហារៗរមែងនាំមកនូវភពទាំងឡាយ ៣ ប្រការដូច្នេះ ។

**វិញ្ញាណាហារោ** ចំណែកវិញ្ញាណាហារ រមែងនាំមកនូវខន្ធទាំង ៣ មានវិញ្ញាណក្ខន្ធជាដើម ជាបាបធម៌ក្តី រមែងនាំមកនូវរូបទាំងឡាយ ដោយអំណាចនៃរូបកលាបៈទាំងឡាយ ៣ គឺកាយទសកៈ ១ វត្ថុទសកៈ ១ ភាវទសកៈ ១ ដែលជារូបធម៌ក្តី កើតព្រមគ្នាក្នុងខណៈបដិសន្ធិចិត្ត ដោយអំណាចជាបច្ច័យដល់គ្នានិងគ្នា មានសហជាតប្បច្ច័យជាដើម ។ ទើបវិញ្ញាណាហារឈ្មោះថា នាំមកនូវនាមធម៌ និងរូបធម៌ក្នុងខណៈបដិសន្ធិ ដោយប្រការដូច្នេះ គប្បី

យល់ចូលចិត្តក្នុងសេចក្ដីថា វិបាកវិញ្ញាណ ១៩ ដួងនោះ សម្រាប់ជាក្នាក់ងារ កើតតាំងពីខណៈបដិសន្ធិចិត្ត បើវិញ្ញាណដែលជាវិបាកកើតជាបដិសន្ធិចិត្តតាំងពីខណៈដំបូងនោះ មាននាមធម៌រូបធម៌កើតព្រមគ្នា ហេតុដូច្នោះ ទើបវិញ្ញាណាហារបានឈ្មោះថា ប្រមូលមកនូវនាមរូបក្នុងខណៈបដិសន្ធិ ដោយប្រការដូច្នេះ ។

**ឯវមេតេ** អាហារទាំងឡាយ ៤ មានកវឡិង្ការាហារជាដើមទាំងនេះ អ្នកប្រាជ្ញគប្បីជ្រាប ឈ្មោះថា អាហារ ហៅថា អាហារ **បច្ចយត្ថេន** ដោយអត្ថថា តែងនាំមកនូវរូបទាំងឡាយ មានឱជដ្ឋមកកើតឡើង និងតែងនាំមកនូវវេទនាទាំង ៣ និងតែងនាំមកនូវភពទាំង ៣ និងតែងនាំមកនូវនាមធម៌ និងរូបធម៌ទាំងឡាយ ទើបឈ្មោះថា អាហារ ។

**ឯត្ថាហ សតិ បច្ចយត្ថេ អាហារត្ថេ អថ កស្មា** មានចោទជាសំណួរមកក្នុងអាហារទាំង ៤ នេះថា ក្នុងកាលឈ្មោះថា **បច្ច័យ** មានហើយ **អាហារ** សព្ទ នោះក៏បានឈ្មោះថា មានអត្ថហើយ គឺថា **បច្ចយ** សព្ទ ប្រែថា **អាហារ** ក៏បច្ច័យទាំងឡាយដទៃៗរបស់សត្វទាំងឡាយក៏មានច្រើន ហេតុដូចម្ដេច ទើបព្រះមានព្រះ

ភាគ មានព្រះពុទ្ធតម្រាស់ថា អាហារនេះមានតែ ៤ ប្រការប៉ុណ្ណោះ វត្ថុណាមួយហៅថាបច្ច័យហើយ ក៏បានឈ្មោះថា អាហារ ក៏បច្ច័យមានច្រើនក្រៃលែង ហេតុដូចម្ដេច ទើបព្រះពុទ្ធដីកា មិនត្រាស់ថាជាអាហារផង ព្រះអង្គត្រាស់ពីបច្ច័យទាំង ៤ នេះថា ជាអាហារៗ មានតែ ៤ ប្រការប៉ុណ្ណោះឬ ?

ឆ្លើយថា បច្ច័យទាំងឡាយដទៃៗ នោះ ព្រះអង្គមិនបានត្រាស់ថាជាអាហារនោះទេ ព្រោះថា បច្ច័យទាំងឡាយដទៃៗ នោះ មិនបានជាបច្ច័យវិសេសដល់អជ្ឈត្តិកសន្តាន អាហារទាំង ៤ ប្រការនេះ ព្រះសម្មាសម្ពុទ្ធមានព្រះតម្រាស់ថា អាហារមានតែ ៤ ប្រការប៉ុណ្ណោះ ព្រោះថា មិនមានអាហារទាំង ៤ នោះ កើតជាបច្ច័យដ៏វិសេសដល់រូបកលាបៈទាំងឡាយ ដែលកើតក្នុងអជ្ឈត្តិកសន្តានខាងក្នុងដោយពិតប្រាកដនោះឡើយ មិនបានត្រាស់ហៅថា ជាអាហារទេ ព្រោះថាមិនបានជាបច្ច័យដ៏វិសេសដល់រូបកលាបៈ ក្នុងអជ្ឈត្តិកសន្តានខាងក្នុង អាហារទាំង ៤ នេះជាបច្ច័យទៀងទាត់ណាស់ សមដូចព្រះពុទ្ធដីកាត្រាស់ថា **សេយ្យថាបិ ភិក្ខវេ អយំ កាយោ អាហារដ្ឋិតិកោ អាហារំ បដិច្ច តិដ្ឋតិ អនាហារោតិ** ម្នាលភិក្ខុទាំងឡាយ **អយំ**

**កាយោ** *រីកាយរបស់សព្វសត្វទាំងឡាយនេះ មានប្រក្រតីតាំងនៅបានដោយសារអាហារ អាស្រ័យនូវអាហារជាបច្ច័យគាំទ្រហើយ ក៏តាំងនៅបានដោយល្អ មិនបានបែកធ្លាយ បើមិនបានការគាំទ្រពីអាហារប្បច្ច័យហើយ កាយក៏មិនអាចតាំងនៅបាន ក៏នឹងដល់នូវការបែកធ្លាយទៅជាជីពិត អាហារជាបច្ច័យ គាំទ្រកាយទុកមិនឲ្យបែកធ្លាយទៅដោយប្រការដូច្នេះ ។*

**សេយ្យថាបិ** *ឧបមានេះយ៉ាងណា វេទនាទាំង ៣ កើតមានមកអំពីផស្សៈជាបច្ច័យ បដិសន្ធិវិញ្ញាណទាំងឡាយនឹងកើតមាន ក៏កើតមានមកពីបុញ្ញាភិសង្ខារ និងអបុញ្ញាភិសង្ខារទាំងឡាយនោះជាបច្ច័យ នាមធម៌ និងរូបធម៌នឹងកើតមាន ក៏កើតមកអំពីវិបាកវិញ្ញាណទាំងនោះជាបច្ច័យ* **តថា** *ក៏មានឧបមេយ្យដូច្នោះ ធម៌ ៤ ប្រការ គឺអាហារជាបច្ច័យដល់រូបកាយ ផស្សៈជាបច្ច័យដល់កងវេទនាទាំងឡាយ* ***បុញ្ញាភិសង្ខារ*** *គឺកិរិយាដែលធ្វើបុណ្យ* ***អបុញ្ញាភិសង្ខារ*** *គឺកិរិយាដែលធ្វើបាប ជាបច្ច័យដល់បដិសន្ធិវិញ្ញាណ ជាបច្ច័យដល់នាមធម៌ និងរូបធម៌ ពាក្យទាំងនេះអ្នកប្រាជ្ញគប្បីជ្រាបថា ព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថារបស់* ***ធម្មសង្គណី*** ***អដ្ឋកថាសម្មាទិដ្ឋិសូត្រ*** *ក្នុង*

មជ្ឈិមនិកាយ និងក្នុង អដ្ឋកថាសំយុត្តនិកាយម្យ៉ាងទៀត សេចក្តីដែលចែកចេញនូវអាហារជាឧបាទិន្នក និងអនុបាទិន្នកនោះ ព្រះអដ្ឋកថាពោលទុកក្នុង អដ្ឋកថាសំយុត្តនិកាយ ប៉ុន្តែពាក្យដ៏សេសនោះ អ្នកប្រាជ្ញគប្បីជ្រាបថា ពោលកែខែដូចគ្នាទាំងអស់គ្រប់គម្ពីរ ។

មានពាក្យសួរថា **ឆន្ន ច កុម្ភិលានំ កុច្ឆិ ផាលេត្វា ធាសាណោ បស្សន្តិ** បុគ្គលវះពោះក្រពើ ក៏រមែងឃើញនូវដុំថ្មក្នុងពោះក្រពើនោះ ឬមិនបានឃើញទេ ដោយប្រការណា ?

ឆ្លើយថា ឃើញដុំថ្មនៅក្នុងពោះក្រពើ កាលឃើញដុំថ្មនៅក្នុងពោះក្រពើនោះហើយ បានពោលថា ក្រពើទាំងឡាយដែលបានលេបនូវដុំថ្មចូលទៅក្នុងពោះនោះ ដុំថ្មក៏បែកខ្ទេចខ្ទី ។ ពាក្យនោះពោលទុកដើម្បីជាប្រយោជន៍ដូចម្តេច មិនទាស់គ្នានឹងពាក្យដែលថា វះពោះក្រពើរួចហើយ ឃើញនូវដុំថ្មក្នុងពោះក្រពើទេឬ ?

ឆ្លើយថា **យថា អចិរភុត្តាហារានំ មនុស្សានំ** កាលមនុស្សទាំងឡាយបរិភោគបាយថ្មីៗ ក៏មានអ្នកមកប្រហារ ចាក់ដោយអាវុធដ៏មុត បាយនោះក៏ហូរចេញជាគ្រាប់ៗ ឃើញប្រាកដយ៉ាងណា មនុស្សទាំងឡាយវះពោះក្រពើ ឃើញនូវដុំថ្ម ដែលវាលេបចូលទៅ

ជិតនឹងស្លាប់ ក៏មានឧបមេយ្យដូច្នោះ សេចក្តីនេះអ្នកប្រាជ្ញគប្បីជ្រាបថា ព្រះអដ្ឋកថាចារ្យពោលទុកក្នុងវិគ្គហៈ គឺនឹងឲ្យកាន់យកនូវសេចក្តីអធិប្បាយដោយបញ្ញាឈ្លាសវៃក្នុងសេចក្តីឱទនាទិវត្ថុ គឺវត្ថុទាំងឡាយមានបាយជាដើម ដែលបុគ្គលគួរទំពាស៊ីក្តី ផឹកនូវទឹកអំពៅ ទឹកឃ្មុំដែលបុគ្គលគួរបរិភោគក្តី ក៏ចាត់ជាអាហារទាំងអស់ **ហេដ្ឋិមទន្តា** ធ្មេញខាងក្រោម ឲ្យសម្រេចនូវមុក្ខុឡកិច្ចជាត្បាល់ ធ្មេញខាងលើឲ្យសម្រេចមូលកិច្ចជាអង្រែ ជិវ្ហាឲ្យសម្រេចដោយហត្ថកិច្ច ត្រឡប់ទៅមក ។ ក្នុងកាលដែលបុរសស្រ្តីទាំងឡាយ បរិភោគនូវអាហារទាំងឡាយនោះ **តំ អាហារំ** អាហារជាតិនោះ បុគ្គលទាំងឡាយបុកដោយអង្រែ ពោលគឺធ្មេញ ធ្វើអាហារឲ្យបែក ដោយធ្មេញក្នុងមាត់ ត្រឡប់ទៅមកដោយដៃគឺផ្សើមដោយទឹកមាត់រាវត្រង់ថ្ងាល់ និងចុងអណ្តាត ដោយទឹកមាត់ខាប់ត្រង់គល់អណ្តាត ជាបដិកូលគួរឲ្យខ្ពើមរអើម ហាក់បីដូចជាកម្អួតឆ្កែ ដែលនៅក្នុងស្នូក **ទន្តក្ខជេន មក្ខិតំ** ហើយក៏ប្រឡាក់ទៅដោយសម្អកធ្មេញ ដែលឈើស្ទន់ ឬប្រាស់ជម្រះសម្អាតមិនដល់ក៏កើតជាប្រយោជន៍ក្នុងឧទរប្រទេស ឲ្យរម្ងាប់នូវសេចក្តីស្រេកឃ្លានក្នុងខណៈនោះ មានភាពវិសេសរបស់សង្ខារទាំងឡាយ គឺពណ៌ ក្លិន

រសនៃអាហារ ដែលបានបរិភោគក្នុងវេលាថ្ងៃនោះ **សោ បន សុវានទោណភិយំ ថបិតំ** អាហារនោះដល់នូវសភាពគួរឲ្យខ្ពើមក្រៃលែង ដូចកម្អួតក្អែក្នុងស្នូក ក្លាយជាហារថ្មី និងអាហារចាស់ដែលមានក្លិនស្អុយ ជាបដិកូល ដែលមហាជនគប្បីខ្ពើមរអើម **ឯវម្ភូតោ បនេសំ វណ្ណោ បរិសមានោ** កាលបើអាហារកើតមានដូច្នេះហើយ ក៏ចូលទៅក្នុងផ្ទៃរបស់សត្វទាំងឡាយ គុហាជាទីនៅទាំង ៤ គឺទីនៅរបស់ប្រមាត់ ទីនៅរបស់ស្លេស្ម ទីនៅរបស់ខ្ទុះ និងទីនៅរបស់ឈាម **អញ្ញតរោ អាសយោ** ទីអាស្រ័យណាមួយ មានដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងស្តេចចក្រពត្តិ ដែលមានបញ្ញាក្រាស់ ក៏អាស្រ័យទាំង ៤ ប្រការនេះ គឺជាទីនៅរបស់ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម មិនមែនមានចំពោះអ្នកទាំងឡាយ ដែលមានបញ្ញាខ្សោយនោះទេ ហេតុដូច្នេះ បើទីអាស្រ័យនៃប្រមាត់របស់អ្នកណាច្រើនក្រៃលែង អាហារនៃអ្នកនោះ ក៏កើតគួរឲ្យខ្ពើមរអើម ប្រៀបដូចប្រេងស្រគំដ៏ខាប់ ។ បើទីអាស្រ័យរបស់ស្លេស្មរបស់អ្នកណាច្រើន អាហាររបស់អ្នកនោះ ក៏កើតគួរឲ្យខ្ពើមរអើម ប្រៀបដូចខ្ទាញ់ពររបស់នាគ និងទឹកស្លឹកឈើស្រស់ ។ បើទីអាស្រ័យនៃខ្ទុះ របស់បុគ្គលណាច្រើន

អាហាររបស់អ្នកនោះក៏កើតគួរឲ្យខ្ពើមរអើម ប្រៀបដូចប្រឡាក់ទៅដោយតក្កៈផ្អូម បើទីអាស្រ័យនៃឈាមរបស់អ្នកណាច្រើនក្រៃលែង អាហាររបស់អ្នកនោះក៏កើតប្រៀបដូចប្រឡាក់ ទៅដោយទឹកជ្រលក់ពណ៌ក្រហម អធិប្បាយថា អាហារទាំងឡាយ ដែលបុគ្គលលេបចូលទៅក្នុងថ្ងៃនោះក្តី លេបចូលពីម្សិលមិញក្តី លេបចូលក្នុងថ្ងៃមុនៗនោះក្តី **ឯកតោវ ហុត្វា** មានសភាពចូលទៅប្រជុំគ្នាក្នុងទីតែមួយស្ទួស្ទុំរុំទុកជ្រាបទៅដូចពពុះបាយ ប៉ោងឡើងដោយភ្លើងធាតុ ក្នុងកាយហើយក៏តាំងនៅក្នុងឧទរ **អន្តបដលំ** ពោះវៀនតាំងនៅខាង លើផ្ចិតពោះវៀនបុរសប្រវែងប្រមាណ ៣២ ហត្ថ ស្រីប្រមាណ ២៨ ហត្ថក៏ឆ្វាយបូលបាន ២០ ចង្វាយ **សេតសប្បសណ្ឋានាយ** មានសណ្ឋានដូចពស់ពណ៌ស ដែលបុគ្គលកាត់ក្បាល ឆ្វាយហើយ ដាក់ក្នុងស្នូកឈាម បានឈ្មោះថា ឧទរប្រទេស **ចានភោជនម្ហិ** នាកាលអាហារមានបាយ និងទឹកជាដើមមិនមាន ពួកជន្តុវទាំងឡាយ គឺត្រកូលជន្តុវ ៣២ ត្រកូល ឈ្មោះថា **តកោដកា គណ្ឌុប្បាទកា តាលហិរាសុចិមុខា បដតន្តុ សុត្តកា អាកុលព្យាកុលា** មានសភាវៈពពាក់ពពូនស្អែកស្អុះវារទៅមកជាពួកៗ ហើយក៏លោតឡើងមកប្រជែងគ្នា

ខាំស៊ីនូវបេះដូងមំសៈ ហ្វូងដង្កូវទាំងឡាយនោះអាស្រ័យនៅក្នុងឧទរ យ៉ាងណា ឧទរនោះក៏រលោងខាងក្រៅ ប្រៀបដូចជាពពុះខ្យល់ ដែលកើតមាននៅក្នុងកណ្ដាលនៃសាជកដែលទទឹក ដែលបុគ្គល ចាប់ជាយទាំងសងខាងចូលគ្នា មានសភាពរជិបរជុប ដូចជ្រាំងខ្ទុំទុំ ។ ហ្វូងដង្កូវទាំងឡាយងើបក្បាលឡើង ក្នុងពេលបុគ្គលបរិភោគបាយ និង ផឹកទឹកជាដើម មានសភាពតក់ក្រហល់ ដណ្ដើមគ្នាស៊ីនូវដុំបាយ ២-៣ ដុំ ដែលបុគ្គលលេបចូលទៅ ។ ឧទរនោះជាមន្ទីរសម្ភព ជាវច្ចកុដិ ជាសាលា ជាព្រៃស្មសានរបស់ពួកដង្កូវទាំងឡាយនោះ **បតិតចាង-ភោជនានិ** ម្យ៉ាងទៀត អាហារ មានបាយ និងទឹកជាដើមធ្លាក់ចូល ក្នុងឧទរនោះ ក៏បែងចេញជា ៥ចំណែក ដង្កូវស៊ីមួយចំណែក **ឧទរគ្គិ ឈាបេតិ** ភ្លើងធាតុក្នុងពោះដុតមួយចំណែក **មុត្តំ ហោតិ** កើតជា ទឹកមូត្រមួយចំណែក **ករីសំ ហោតិ** កើតជាករីសមួយចំណែក **ឯកោ រសភាវមាបជ្ជិត្វា** អាហារមួយចំណែកដល់នូវសភាពជា រសជ្រួតជ្រាបទៅក្នុងកាយ ញ៉ាំងសាច់ និងឈាមឲ្យចម្រើន **សោប-ឆាយ មាហារោ** អាហារនោះដល់នូវភាពតាំងនៅក្នុងទីទាំងឡាយ មាន ៥ ចំណែក ដោយប្រការដូច្នេះឯង ។

**យថា បន ឱទនេ**ម្យ៉ាងទៀត ក្នុងពេលដែលបុគ្គលដាំបាយ រីក្បាលអង្ការម កន្ទក់ ចុងអង្ករជាដើម ពេលក្តៅពុះឡើងមក ប្រឡាក់មាត់ឆ្នាំង ប្រឡាក់គម្របឆ្នាំងយ៉ាងណា អាហារនោះកម្តៅដោយភ្លើងធាតុក្នុងកាយ ដែលផ្សព្វផ្សាយទូទាំងសរីរៈទាំងមូល ឲ្យកើតជាពពុះហៀរចេញមកតាមធ្មេញ លោកទាំងឡាយក៏សន្មតថា អាចម៍ធ្មេញប្រឡាក់អណ្តាតនិងពិតានមាត់ ក៏កើតជាទឹកមាត់ និងស្លេស្ម លាបប្រឡាក់ភ្នែក ត្រចៀក ច្រមុះ និងទ្វារវច្ចមគ្គជាដើម លោកក៏សន្មតហៅថា អាចម៍ភ្នែក អាចម៍ត្រចៀក អាចម៍ច្រមុះ ទឹកមូត្រ ករីសជាដើម ក៏មានសេចក្តីឧបមេយ្យដូច្នោះ ។

**សមាបចមានោ បនាយំ** ម្យ៉ាងទៀត អាហារនេះកាលបើឆ្អិនល្អហើយ ក៏ឲ្យសម្រេចចេញជាសាកសពផ្សេងៗ គឺសក់ រោម ក្រចកធ្មេញជាដើម ។កាលបើមិនឆ្អិនល្អទេ ក៏តែងឲ្យកើតរោគផ្សេងៗ គឺមានរោគសើស្បែក រមាស់ ស្រែង យូង៍ និងរាកមួល ហឺត ក្អក ចុះឈាមជាដើម ។ ពាក្យដែលពោលមកនេះ អ្នកប្រាជ្ញគប្បីជ្រាបថា ព្រះអដ្ឋកថាសម្តែងទុកក្នុង **គម្ពីរវិសុទ្ធិមគ្គ** ។**សោ បនាយំ អាហារោ** អាហារនេះកាលបើបុគ្គលនាំមកដោយល្អហើយ ក៏ឲ្យសម្រេចនូវគុណ

ច្រើនយ៉ាង គឺកើតឯកគ្គតាចិត្ត ជាសមាធិជាដើម ។ កាលបើបុគ្គលនាំមកមិនបានល្អហើយ ក៏រមែងញ៉ាំងនូវសេចក្តីលំបាកចិត្តជាដើម ឲ្យកើតដល់ខ្លួន អធិប្បាយថា ភ្លើងធាតុដែលកើតពីកម្មរបស់បុគ្គលណាចេះសន្ធោសន្ធៅ គេជោធាតុរបស់បុគ្គលនោះ លះចេញនូវអនុបាទិន្នករូប គឺអាហារទាំងឡាយ ទៅដុតនូវឧបាទិន្នករូប គឺសរីរកាយរបស់សត្វទាំងឡាយ នឹងកើតមានញើសហូរចេញពីសរីរកាយ ។ លំដាប់នោះ ភ្លើងធាតុដែលកើតពីកម្ម លះចេញនូវឧបាទិន្នករូប ដោយអំណាចបុគ្គលអត់ធន់ អស់វារៈ ២-៣ ដងហើយ ក៏ទៅចាប់យកនូវអនុបាទិន្នករូបនោះ **ចិត្តំ បសីទតិ** គ្រានោះ ចិត្តក៏ថ្លូវថង់ បុគ្គលនោះក៏ត្រជាក់កាយសប្បាយចិត្ត ប្រៀបដូចបានមុជទឹក ១០០ ក្អម ភ្លើងធាតុនោះក៏ធ្វើនូវកិច្ចរម្ងាប់សេចក្តីក្រវល់ក្រវាយ ។ បុគ្គលអ្នកធ្វើមនសិការនូវកម្មដ្ឋាន ក៏កើតមានឯកគ្គតាចិត្តតាំងមាំចុះកាន់ជាសមាធិ ។ រូបកលាបៈទាំងឡាយដែលជាវិសភាគ មិនបានស្មើគ្នានោះ ក៏ស្ងប់រម្ងាប់ល្អ រូបកលាបៈដែលជាសភាគស្មើគ្នា ទន់ភ្លន់ ចិត្តក៏រីករាយ ។ កាលបើចិត្តថ្លូវថង់ល្អហើយ ឈាមក្នុងសរីរកាយនោះ ក៏ស្រស់ថ្លាសម្បុរស្រស់ថ្លា **ឧចានានានិ** ប៉ុន្តែរូបទាំងឡាយដែលជាឧបាទានរូប

*មានចក្ខុបសាទរូបជាដើមនោះ ជាចិត្តសមុដ្ឋាន កើតពីចិត្តក៏នឹងកើត បរិសុទ្ធល្អ ពិចារណាមើលផ្ទៃមុខស្អាត ហាក់បីដូចផ្លែត្នោតទុំ ដែលជ្រុះពីទងក៏ដូចគ្នា អាហារមានគុណដូច្នេះ ។*

**លោហិតន្តិ ឯត្ថ ហទយលោហិតំ** *វិនិច្ឆ័យឈាមក្នុងបេះដូងថា ឈាមដែលជាទឹកចិញ្ចឹមបេះដូងនោះ បើចិត្តបុគ្គលណាសុខសប្បាយ ប្រកបដោយសោមនស្ស ឈាមដែលចិញ្ចឹមបេះដូងក៏មានពណ៌ក្រហម ប្រៀបដូចផ្លែជ្រៃទុំ ។ បើចិត្តប្រកបដោយទោមនស្ស កើតការប្រព្រឹត្តក្នុងសន្តានពេលណា ឈាមដែលចិញ្ចឹមក្នុងបេះដូងក៏មានពណ៌ខ្មៅជាំ ប្រៀបដូចផ្លែព្រីងទុំក្នុងពេលនោះ បើចិត្តជាឧបេក្ខាពេលណា ឈាមដែលចិញ្ចឹមបេះដូងក៏មានពណ៌ស្រស់ ប្រៀបដូចប្រេងល្ងថ្លាក្នុងពេលនោះ ពាក្យនេះព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាអង្គុត្តរនិកាយ ។*

*ក្នុង អដ្ឋកថាទ្វយតានុបស្សនាសូត្រ ក្នុង សុត្តនិបាត នោះសម្ដែងថា* **សព្វេបិមេ សត្តា ចតុព្វិធា ហោន្តិ សេវិតព្វអាហារ-វសេន** *សត្វទាំងឡាយនេះមាន ៤ ប្រការ គឺ រូបូបគា ( ចូលដល់រូប ) ១* **វេទនូបគា** *( ចូលដល់វេទនា ) ១* **សញ្ញូបគា** *( ចូល*

ដល់សញ្ញា ) ១ **សង្ខារូបគា** ( ចូលដល់សង្ខារ ) ១ ។

**តតោ រូបធាតុយោ** សត្វទាំងឡាយ ក្នុងរូបធាតុខាងលើអំពីកាមធាតុ ១១ នោះឡើងទៅ លើកលែងតែអសញ្ញីសត្វ សត្វដ៏សេសអំពីអសញ្ញីសត្វ គឺជារូបព្រហ្មដទៃៗ នោះ ឈ្មោះថា សត្វដែលប្រកបដោយវេទនា សោយនូវអារម្មណ៍ដែលជាសុខខ្លះ ជាឧបេក្ខាខ្លះ (តាមដែលបានសម្រេចឈានផ្សេងៗ) ព្រោះថា រូបព្រហ្មទាំងឡាយនោះ សេពនូវផស្សាហារ ចិញ្ចឹមជីវិតដោយផស្សាហារ ការពិតព្រហ្មទាំងឡាយ មិនបានបរិភោគនូវកពឡិង្ការាហារទេ **ហេដ្ឋា តិវិធាយ** សត្វទាំងឡាយ ដែលទៅកើតក្នុងអរូបភពខាងក្រោម ៣ ជាន់ គ្មានរូបគ្មានកាយឡើយ មានតែចិត្ត និងចេតសិក គឺអាកាសានញ្ចាយតនៈមួយជាន់ វិញ្ញាណញ្ចាយតនៈមួយជាន់ អាកិញ្ចញ្ញាយតនៈមួយជាន់ ឈ្មោះថា សត្វដែលប្រកបដោយសញ្ញា ព្រោះថា អរូបភពទាំង ៣ នោះ សេពនូវមនោសញ្ចេតនាហារ ដែលកើតអំពីសញ្ញាទាំងឡាយ គឺសេពនូវកុសលចេតនាដែលកើតអំពីសញ្ញាជាអាហារ ជាបច្ច័យឲ្យកើតក្នុងអរូបភព ឈ្មោះថា **សញ្ញូបគា** ។

សត្វទាំងឡាយ ដែលបាននៅសញ្ញានាសញ្ញានាយតនជ្ឈាន

ហើយ ទៅកើតក្នុងជាន់អរូបភព ដែលជាទីបំផុតរបស់ភព គឺជាន់នេវសញ្ញានាសញ្ញាយតនភពនោះ ឈ្មោះថា សត្វប្រកបដោយសង្ខារ ព្រោះថា សត្វទាំងឡាយសេពនូវវិញ្ញាណាហារ ដែលកើតអំពីសង្ខារ គឺធ្វើដោយការចម្រើនឈាន ដែលជាអរូបកុសលបានជំនាញ ចាត់ជាបុញ្ញាភិសង្ខារហើយ ក៏កើតអរូបវិបាកជាបដិសន្ធិ ទើបឈ្មោះថា **វិញ្ញាណាហារ** ។ កាលបើបដិសន្ធិវិញ្ញាណកើតឡើង អរូបភពនោះក៏បានឈ្មោះថា សេពនូវវិញ្ញាណាហារតែម្យ៉ាងប៉ុណ្ណោះ កើតមានអំពីវិញ្ញាណ គឺចិត្ត និងចេតសិកប្រកបគ្នា ប្រាកដនៅក្នុងទិព្វវិមាននោះ មិនមានរូបកាយប្រាកដ មានតែចិត្តវិញ្ញាណ ប្រៀបដូចប្រេងដែលលាបបាត្រ ជាប់នឹងបាត្រនោះ នឹងច្បិចយកនូវប្រេងចេញមកឲ្យឃើញប្រាកដមិនបាន សត្វទាំងឡាយដែលនៅក្នុងអរូបភពទាំង ៤ ជាន់ជាការឥតអំពើអស់ច្រើនកប្ប មិនមានប្រយោជន៍អ្វីសោះ រួចហើយនឹងវិលត្រឡប់មកកើតបន្តទៅទៀត ព្រះមានព្រះភាគជា ទ្រង់ត្រាស់តិះដៀល ។

**សព្វភវេសុ បន សត្តា អាហារតោ ឋិតិ ឯតេ សព្វេ អាហារដ្ឋិតិកា នាម** ម្យ៉ាងទៀត សត្វទាំងឡាយក្នុងភពទាំងពួងនោះ

ក៏មានឈ្មោះថា **អាហារដ្ឋិតិកា** គឺរស់នៅដោយសារអាហារ មានវិគ្រោះថា **ឋិតិ** រីកិរិយាដែលតាំងនៅ **អាហារតោ** អំពីអាហារ **ឯតេសំ សត្តានំ** របស់សត្វទាំងឡាយនោះ **អត្ថិ** មាន **តេ សត្តា** រីសត្វទាំងឡាយនោះ **អាហារដ្ឋិតិកា** ឈ្មោះថា អាហារដ្ឋិតិកា **សត្តា** រីសត្វទាំងឡាយ **អាហារដ្ឋិតិកា** មានសភាវៈតាំងនៅពីអាហារ អធិប្បាយថា **ឯកោ ធម្មោ** រីធម៌មួយ ឈ្មោះថា អាហារនោះ គឺជាហេតុនៃកិរិយាដែលតាំងនៅបាន របស់សត្វទាំងឡាយទាំងពួង មាននូវសត្វទាំងឡាយទាំងពួង ទើបតាំងនៅបាន បើអាហារធម៌មួយនោះមិនមានហើយ សត្វទាំងឡាយទាំងពួង ក៏មិនអាចតាំងនៅបាន ឡើយ ។

ទើបមានពាក្យសួរថា **ឆន្ទ ច ឯវំ សន្តេ យំ វុត្តំ** បើអាហារធម៌មួយនោះមានហើយ ទើបសត្វទាំងឡាយតាំងនៅបាន បើអាហារធម៌មួយនោះមិនមានហើយ សត្វទាំងពួងក៏មិនអាចតាំងនៅបាន ព្រះសម្ពុទ្ធត្រាស់ដូច្នេះ ។ ម្យ៉ាងទៀត ទ្រង់ត្រាស់ថា ទេវតាទាំងឡាយដែលកើតជាអសញ្ញី តាំងនៅក្នុងជាន់អសញ្ញីកត **អហេតុកា** ជាអហេតុកបដិសន្ធិជាសត្វមិនមានហេតុគឺមានតែរូបទទេៗ **អនាហារា**

ជាសត្វគ្មានអាហារ **អផស្សកា** ជាសត្វមិនមានផស្សៈ ប្រៀបដូចដុំថ្មមួយដុំ ឬរូបទីងមោង ដែលធ្វើដោយបាច់ស្មៅ ឬស្លឹកឈើ ពាក្យដូច្នោះព្រះសម្ពុទ្ធទ្រង់ត្រាស់ខុស ឬដូចម្តេច ?

**ឆ វិរុជ្ឈតិ** ឆ្លើយថា ព្រះពុទ្ធដីកាត្រាស់មិនខុសទេ ព្រះអង្គត្រាស់ថា អសញ្ញីសត្វទាំងឡាយគ្មានហេតុ ព្រោះគ្មានអាហារ គ្មានផស្សៈនោះក៏ពិត ព្រះពុទ្ធដីកាត្រាស់អធិប្បាយថា មិនខុសទេ គឺអសញ្ញីសត្វទាំងឡាយមិនមានហេតុ មិនមានអាហារពិតមែន តែព្រះអង្គយកឈានជាអាហារនៃអសញ្ញីសត្វទាំងឡាយនោះ ។

អើ បើចាត់យកឈានមកជាអាហារដូច្នេះហើយ ព្រះពុទ្ធដីកាដែលត្រាស់ថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ អាហារមាន ៤ ប្រការពាក្យនោះ ខុសឬ ?

ឆ្លើយថា ព្រះពុទ្ធដីកាត្រាស់ថា អាហារមាន ៤ ប្រការនោះមិនខុសទេ អធិប្បាយថា ធម៌ទាំងឡាយ ៤ ប្រការនោះ គឺកពឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ គឺអាហារមានលក្ខណៈគួរកំណត់ ឈ្មោះថា **អាហារ** ជាសភាពអាហារ គឺជាអាហារពិត ទើបព្រះសម្ពុទ្ធត្រាស់ហៅថា **អាហារ** ក្នុងពាក្យនោះ

ព្រះអង្គត្រាស់ជានិប្បរិយាយ ត្រាស់ជាសភាវៈពិត ព្រះអង្គត្រាស់ទេសនាថា ឈានជាអាហារនេះ គឺព្រះពុទ្ធអង្គលើកយកបច្ច័យឡើងត្រាស់ថា ឈានប្បច្ច័យក៏ជាអាហារ គឺត្រាស់ដោយបរិយាយជាឧបាយប្រៀបធៀបជិតគ្នា អធិប្បាយថា បច្ច័យរបស់ធម៌ទាំងពួង សមគួរដែលបុគ្គលគប្បីបាន **សោ បច្ចយោ** បច្ច័យនោះ ប្រសិនបើញុំាងផលណាៗ ឲ្យកើតឡើងហើយ រមែងនាំមកនូវផលនោះៗ **តស្មា** ព្រោះហេតុនោះ វត្ថុដែលជាបច្ច័យនោះ ព្រះសម្ពុទ្ធត្រាស់ហៅថា **អាហារ** ព្រោះថា ព្រះអង្គឃើញថា ឈានប្បច្ច័យអាចនាំមកនូវផលបាន ទើបត្រាស់ថា ឈានប្បច្ច័យក៏ជាអាហារម្យ៉ាង ព្រោះហេតុនោះ ព្រះពុទ្ធព្រះអង្គប្រោសប្រទានព្រះធម៌ទេសនាថា **អវិជ្ជាម្ពាំ ភិក្ខវេ អាហារំ វទាមិ នោ អនាហារំ កោចិ ភិក្ខវេ អវិជ្ជាយ អាហារោ** ម្នាលភិក្ខុទាំងឡាយ អវិជ្ជានេះតថាគតក៏ហៅថា ជាអាហារបាន មិនមែនតថាគតមិនហៅថា ជាអាហារនោះទេ សភាពដែលមិនបានដឹងនូវទីបំផុតខាងដើម និងខាងចុងនៃវដ្ដសង្សារនោះ ក៏ហៅថា អវិជ្ជា និងសភាពដែលមិនបានដឹងនូវទុក្ខសច្ច ដែលមានកិច្ច ៤ ជាដើមនោះ ក៏ហៅថា អវិជ្ជា តួអវិជ្ជាដូច្នោះនោះឯង ហៅថា **អាហារ** គឺជាហេតុនាំមកនូវបុណ្យ និងបាប ។

កាលបើអវិជ្ជាជាបច្ច័យនាំមកនូវបុណ្យ និងបាបដូច្នេះហើយ ក៏បាន នាមបញ្ញត្តិថា **អាហារប្បច្ច័យ** ព្រោះថា ជាឧបការៈនាំមកនូវ បុណ្យ និងបាប តាមចេតនារបស់សត្វទាំងឡាយ ហេតុដូច្នោះ ទើប តថាគតមិនត្រាស់ថា អវិជ្ជានេះ មិនជាអាហារនោះទេ ។ ម្នាលភិក្ខុ ទាំងឡាយ ធម៌ដូចម្ដេចជាអាហាររបស់អវិជ្ជា និងនាំមកនូវអវិជ្ជា ព្រះពុទ្ធដីកាត្រាស់ថា នីវរណធម៌ទាំង ៥ គឺកាមច្ឆន្ទនីវរណៈ ព្យា-បាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ នោះ ជាអាហាររបស់អវិជ្ជា គឺនាំមកនូវអវិជ្ជា ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គត្រាស់ឆ្លើយថា **កាមច្ឆន្ទៈ** គឺសេចក្ដីស្រឡាញ់ សេចក្ដីត្រេកអរ ដោយកាមគុណទាំង ៥ ប្រការនោះក៏ចាត់ជានីវរណធម៌ ១ រមែង បិទបាំងផ្លូវព្រះនិព្វាន ព្យាបាទក៏ចាត់ជានីវរណៈ ១ ថីនមិទ្ធៈ ក៏ ចាត់ជានីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ការរាយមាយ ការក្ដៅក្រហាយ ក្នុងចិត្ត ក៏ចាត់ជានីវរណធម៌ វិចិកិច្ឆា គឺសេចកីសង្ស័យ មិនដាច់ ស្រេចក្នុងចិត្តនោះ ក៏ជានីវរណធម៌ សុទ្ធតែជាធម៌ដ៏លាមក រមែងធ្វើ នូវសន្ដានចិត្តរបស់សត្វទាំងឡាយ ឲ្យងងឹតងងល់វង្វេងភ្លេចស្មារតី មិនអាចឲ្យដឹងព្រះពុទ្ធគុណ ហើយប្រព្រឹត្តទៅក្នុងអកុសលជាដើម

ធ្វើនូវកាយទុច្ចរិត មានបាណាតិបាតជាដើម ហើយញ៉ាំងវចីទុច្ចរិត តិះដៀលព្រះអរិយៈជាដើម ហើយញ៉ាំងនូវមនោទុច្ចរិត មានកាម-វិតក្ក ព្យាបាទវិតក្ក វិហិង្សាវិតក្កជាដើម សុទ្ធតែជាអកុសល ថោកទាបលាមក វឹកវរនៅក្នុងចិត្តរបស់សត្វជាអនេកអនន្ត ប្រមាណមិនបាន ព្រោះថា នីវរណធម៌ទាំង ៥ នាំមកនូវអវិជ្ជា ទើបអវិជ្ជាជាអាហារប្បច្ច័យ កើតនូវកិលេសផ្សេងៗ ។ ពាក្យដែលពោលថា ជាបច្ច័យលើកឡើងហៅឈ្មោះថា អាហារនេះ អ្នកប្រាជ្ញបំណាងនាំមកពីព្រះសូត្រ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាចំពោះភិក្ខុទាំងឡាយ ដូច្នេះ ក្នុងកាលអាហារ គឺឈានប្បច្ច័យដទៃៗ ដែលលោកអាចារ្យកាន់យកថា ជាអាហារបាន ហើយអាហារទាំងពួង ជាបរិយាយក្តី ជានិប្បរិយាយក្តី ក៏លោកអាចារ្យកាន់យកទាំងអស់ តែឈានប្បច្ច័យដែលចាត់ជាអាហារនោះ លោកអាចារ្យមិនបានកាន់យកក្នុងអសញ្ញីភព អធិប្បាយថា បុគ្គលទាំងឡាយពីមុន កាលព្រះពុទ្ធមិនទាន់ឧប្បត្តិកក្នុងលោក មិនទាន់មានសាសនា បុគ្គលទាំងឡាយកាន់ភេទជាឥសី ធ្វើនូវវាយោកសិណបរិកម្ម **ចតុត្ថជ្ឈានំ និព្វត្តេត្វា** ញ៉ាំងចតុត្ថជ្ឈានឲ្យកើត **តតោ វុដ្ឋាយ** លុះចូលចតុត្ថជ្ឈានហើយ ក៏ចេញចាក

ចតុត្ថជ្ឈាន ដោយធ្វើមនសិការនៅក្នុងចិត្តដូច្នេះថា អាត្មាអញតិះដៀល ចិត្តនេះ អ្នកប្រាជ្ញគប្បីតិះដៀលដោយពិត បើមិនមានចិត្តហើយ នឹងបានសុខពិត សេចក្តីទុក្ខទាំងឡាយកើតមាននោះ ព្រោះអាស្រ័យ ចិត្តនេះ ទើបកើតនូវសេចក្តីទុក្ខផ្សេងៗ ពីបច្ច័យ មានការវាយ តប់ និងការចាប់ចងជាដើម ញុំាងទុក្ខវេទនាឲ្យកើតឡើង **ចិត្តេ អសតិ** ក្នុងកាលមិនមានចិត្តហើយ ក៏នឹងកើតសេចក្តីទុក្ខមកអំពី ណា សេចក្តីទុក្ខក៏នឹងមិនមាន ញុំាងនូវសេចក្តីពេញចិត្តឲ្យកើត ដូច្នេះហើយ ក៏រក្សាចតុត្ថជ្ឈានមិនឲ្យវិនាស លុះចេញចាកឈាន ហើយ ក៏ជិនឆ្អន់នឿយណាយអំពីចិត្ត ដោយកម្លាំងការពេញចិត្តក្នុង កិរិយាដែលគ្មានចិត្តនោះ ។ កាលបើធ្វើកាលកិរិយាហើយ ទើបទៅ កើតក្នុងអសញ្ញីភព គឺពួកឥសីទាំងឡាយ ខាងក្រៅសាសនាចម្រើន វាយោកសិណ បរិកម្មភាវនា បាននូវចតុត្ថជ្ឈានដូចសម្តែងរួចមកហើយ ដូច្នោះ ឥសីអង្គណាកាលស្ថិតនៅជាមនុស្ស ដោយឥរិយាបថណា លុះ ចុតិហើយ ឥសីអង្គនោះក៏ទៅកើតក្នុងអសញ្ញីភព ដោយឥរិយាបថនោះ ប្រសិនបើឈរស្លាប់ ក៏ទៅកើតនៅឈរស្ងៀម អង្គុយស្លាប់ ក៏ទៅ កើតនៅអង្គុយស្ងៀម បើដេកស្លាប់ក៏ទៅកើតនៅដេកស្ងៀម ។ **ចិត្ត-**

**រូបសទិសោ** ប្រៀបដូចរូបភាពដែលជាងគំនូរគូរតាំងទុក ក្នុងវិមាន អស់កាលប្រមាណ ៥០០ កប្បជាកំណត់ ពាក្យលោកសន្មត ហៅថា រូបព្រហ្ម គឺពួកអសញ្ញីសត្វដូច្នេះ នៅស្ងៀមក្នុងព្រហ្មវិមាន ប្រមាណ ដល់ ៥០០ កប្ប ប្រាកដដូចបុគ្គលដេកលក់ដូច្នេះ និងមិនបានដឹង រឿងរ៉ាវអ្វី ព្រោះថា គ្មានចិត្ត មានតែរូប អាហារ គឺឈាន-ប្បច្ច័យ របស់អសញ្ញីសត្វទាំងឡាយបែបនេះ អ្នកប្រាជ្ញគប្បីជ្រាប ដោយប្រការដូច្នេះ ។

មានពាក្យអធិប្បាយថា អសញ្ញីសត្វទាំងឡាយនោះ ចម្រើន នូវឈានណាហើយ ទៅកើតក្នុងអសញ្ញីភព ឈាននោះ ជាបច្ច័យ ដល់អសញ្ញីសត្វទាំងឡាយ **ចិត្តសរោ** កូនសរដែលបុគ្គលបាញ់ទៅ ដោយកម្លាំងខ្សែ បញ្ជូនទៅដោយកម្លាំងរបស់ខ្សែ មាននៅអស់ កាលប្រមាណប៉ុនណា កូនសរនោះក៏ស្ទុះទៅ អស់កាលប៉ុណ្ណោះ យ៉ាងណាក្តី ឈានប្បច្ច័យមាននៅអស់កាលប៉ុនណា អសញ្ញីសត្វ ទាំងឡាយក៏តាំងនៅក្នុងវិមានកំណត់កាលប៉ុណ្ណោះ **ឯវំ** ក៏មានឧបមេយ្យ ដូច្នោះ **ឈានប្បច្ចយេ អសតិ** ក្នុងកាលឈានប្បច្ច័យ មិនមាន ហើយ អសញ្ញីសត្វទាំងឡាយក៏ធ្លាក់ទៅតាមក្រសែវដ្តសង្សារ ប្រៀប

ដូចកូនសរដែលអស់កម្លាំងហើយក៏ធ្លាក់ចុះ **ចនវកាលេ តេសំ** ក្នុងកាលដែលអសញ្ញីសត្វចុតិនោះ រូបកាយទាំងឡាយ ក៏អន្តរធានបាត់សូន្យទៅ មានកាមាវចរសញ្ញាកើតឡើង ទេវតាទាំងឡាយដែលជាអសញ្ញីសត្វនោះ ក៏ប្រាកដឈ្មោះថា ចុតិចាកកាយនោះ ព្រោះថា កើតកាមាវចរ-សញ្ញានោះ មានសេចក្តីថា កាមាវចរសញ្ញា គឺកាមាវចរបដិសន្ធិកើតឡើងហើយ ក៏ចុតិចាកអសញ្ញីភព រូបកាយទាំងឡាយក៏សូន្យទៅ ។

**យំ បន នេរយិកា នេវ ឧដ្ឋានផលូបជីវីតិ ន បុញ្ញផលូ-ជីវិតិ វុត្តា តេសំ កោ អាហារោតិ** មានពាក្យសួរថា បណ្តាសត្វទាំងឡាយដែលទៅកើតក្នុងនរកនោះ មិនបានចិញ្ចឹមជីវិតដោយផលដែលកើតអំពីទីណាមួយ នឹងបានអាស្រ័យនូវផលរបស់បុណ្យចិញ្ចឹមជីវិតក៏មិនមាន **កោ អាហារោ** ធម្មជាតិអ្វីជាអាហាររបស់សត្វទាំងឡាយដែលកើតក្នុងនរកនោះ សត្វនរកទាំងឡាយបានអ្វីជាអាហារចិញ្ចឹមជីវិត ?

**តេសំ កម្មមេវ អាហារោតិ** ឆ្លើយថា កម្មតែម្យ៉ាងជាអាហាររបស់សត្វទាំងឡាយដែលកើតក្នុងនរក សត្វនរកទាំងឡាយអាស្រ័យនូវកម្មរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ជាអាហារចិញ្ចឹមជីវិត ទៅជាដរាប

រហូតអស់កម្មរបស់ខ្លួន ។

**កិំ បញ្ច អាហារា អត្ថិ** ទើបសួរទៀតថា បើសត្វនរកទាំងឡាយ អាស្រ័យកម្មរបស់ខ្លួនចិញ្ចឹមជីវិត ហើយកម្មនោះក៏ចាត់ចូលជាអាហារមួយប្រការទៀត ហេតុនោះ អាហារទាំងឡាយ ក៏មាន ៥ ប្រការយ៉ាងនោះ ឬដូចម្តេច ?

ឆ្លើយថា **ឥធំ ឆ វត្តព្វំ** ពាក្យដែលលោកពោលថា អាហារមាន ៥ ប្រការ លោកកុំគប្បីពោលដូច្នេះឡើយ ពាក្យដែលលោកពោលថា ធម៌ណាកើតជាបច្ច័យបាន ហើយធម៌ដែលជាបច្ច័យនោះក៏បានឈ្មោះថា ជាអាហារ ពាក្យដូច្នេះ យើងមិនបានពោល ក៏បានពោលរួចហើយអំពីខាងដើមមក ហេតុប្បច្ចយធម៌បានកើតជាអាហារនោះ ពាក្យដែលពោលថាជាអាហារនេះ គឺអាស្រ័យនូវបាបកម្មតែម្យ៉ាង បាបកម្មតែម្យ៉ាងនោះ មិនអស់អំណាចកំណត់កាលប៉ុនណា សត្វនរកនោះ ក៏នៅមិនទាន់ស្លាប់កំណត់កាលប៉ុណ្ណោះ ។ សត្វទាំងឡាយដែលកើតក្នុងនរក ព្រោះហេតុនៃកម្មណា ដែលខ្លួនបានធ្វើទុកហើយ កម្មនោះ ក៏កើតជាអាហាររបស់សត្វនរកទាំងឡាយនោះ ហេតុដូចម្តេចហេតុថា កម្មនោះឯង ជាបច្ច័យញុំាំងសត្វ

ឲ្យតាំងនៅក្នុងនរកនោះ ។

**ဝိပါကော စ ကာတဗ္ဗော** ពាក្យចោទឆ្លើយគ្នានិងគ្នា ដែលអ្នកប្រាជ្ញទាំងឡាយ ប្រាថ្នាយកនូវកពុទ្ធិផ្ការាហារហើយ កុំគប្បីឈ្លោះប្រកែកគ្នានិងគ្នា ក្នុងបទថា គឺកម្មតែម្យ៉ាងជាអាហាររបស់សត្វទាំងឡាយនោះ **អបិ** ដូចយើងខ្ញុំនឹងប្រាប់នូវសេចក្ដីឲ្យយល់ច្បាស់ **អប្បន្នខេឡោ** ទឹកមាត់ដែលកើតក្នុងមាត់របស់សត្វនរកទាំងឡាយ **អាហារកិច្ចំ សាធេតិ** ក៏អាចជាអាហារកិច្ច គឺកើតជាអាហារ ឲ្យសម្រេចជាប្រយោជន៍ដល់សត្វនរកទាំងឡាយ ពិតមែន ពាក្យដែលលោកពោលមកនេះសមគួរហើយ **ខេឡោ ហិ និរយេ ទុក្ខវេទនិយោ ហុត្វា** រីទឹកមាត់នោះមានសភាពកើតជាផល គឺនឹងញុំាងសត្វនរកឲ្យទទួលនូវទុក្ខវេទនាក្នុងនរក **បច្ចយោ ហោតិ** ហេតុដូច្នោះ ទើបប្រាកដជាបច្ច័យចិញ្ចឹមជីវិតរបស់សត្វនរក ឲ្យទទួលនូវទុក្ខវេទនាកំណត់កាលដ៏យូរបហូតអស់កម្ម ។

**សគ្គេ សុខវេទនិយោ** ម្យ៉ាងទៀត ទឹកមាត់ក្នុងមាត់របស់ទេវតាទាំងឡាយនោះ ក៏កើតមានសភាពនឹងញុំាងទេវតាទាំងឡាយឲ្យទទួលនូវសេចក្ដីសុខនៅក្នុងស្ថានសួគ៌ ក៏ជាបច្ច័យរបស់ទេវតាទាំង

ឡាយនោះ **ឥតិ កាមភវេ និប្បរិយាយេន ចត្តារោ អាហារោ** អាហារទាំង ៤ ប្រការនោះ អ្នកប្រាជ្ញគប្បីជ្រាបតាមសេចក្ដីពិត ក្នុងកាមភព ១១ គឺអបាយភូមិ ៤ មនុស្ស ១ កាមាវចរសួគ៌ ៦ ដោយប្រការ ដូច្នេះ កុំគប្បីពោលថា អាហារមាន ៥ ប្រការទៀត គប្បីជ្រាបថា មានតែ ៤ ប្រការចុះ ។

**រូបារូបភវេសុ បនេត្ថ អសញ្ញី សេដ្ឋានំ តយោ** សត្វទាំងឡាយដែលក្រៅអំពីកាមភព ១១ នោះ គឺព្រហ្មក្នុងរូបភព និងអរូបភព ដែលក្រៅអំពីកាមភព ។ រូបភព ១៦ ជាន់ វៀរលែងអសញ្ញីសត្វចេញ ១ នៅតែ ១៥ និងអរូបភព ៤ សរុប ១៩ ព្រហ្មទាំងឡាយ ១៩ ជាន់នោះ មានអាហារតែ ៣ ប្រការ គឺផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។ សត្វទាំងឡាយដែលកើតក្នុងអសញ្ញីសត្វក្តី ដែលកើតក្នុងនរកជាដើមក្តី សត្វទាំងឡាយនោះមានបច្ច័យជាទាន ហៅថា **បច្ចយាហារ** ហេតុដូច្នោះ ព្រះមានព្រះភាគត្រាស់ថា **សព្វេ សត្តា អាហារដ្ឋិតិកា** សត្វទាំងឡាយរមែងតាំងនៅដោយសារអាហារ **ឥមិនា អាហារេន** ដោយអាហារដែលមានលក្ខណៈដូច្នេះ **ឥទម្បន វចនំ** សូម្បីពាក្យនេះលោក

អាចារ្យពោលទុកក្នុង អដ្ឋកថាអង្គុត្តរនិកាយ ទសកនិបាត ថាៈ-

**បត្តកាលេ ឧច្ចារបស្សាវំ អករោន្តស្ស សកលសរីរតោ សេទោ មុញ្ចន្តិ អក្ខីនិ ភមន្តិ ចិត្តំ ន ឯកគ្គំ ហោតិ អញ្ញេ ច រោគា ឧប្បជ្ជន្តិ ករោន្តស្ស បន តំ សព្វំ ន ហោតិ** ក្នុងអដ្ឋកថានៃសតិប្បដ្ឋានសូត្រ បានសម្តែងថា កាលបុគ្គលបរិភោគភោជនាហារដល់ពេលកំណត់ បន្ទោបង់ឧច្ចារៈ និងបស្សាវៈហើយ អត់ទ្រាំមិនបាន បន្ទោបង់ឧច្ចារៈ និងបស្សាវៈ ញើសក្នុងសរីរៈក៏តែងហូរចេញពីសរីរៈ ម្យ៉ាងទៀត ក៏នឹងកើតទោស ធ្វើឲ្យភ្នែកទាំងពីរស្រវាំង ចិត្តក៏មិនធ្លាក់ចុះកាន់អារម្មណ៍តែមួយ **អញ្ញេ ច រោគា** រោគដទៃទាំងឡាយក៏នឹងកើតឡើងខ្លាំងក្លា **ករោន្តស្ស បន** ឯបុគ្គលបរិភោគភោជនាហារ ដល់ពេលកំណត់បន្ទោបង់ឧច្ចារៈ និងបស្សាវៈចេញហើយក៏ទៅកាន់ទីបន្ទោបង់ឧច្ចារៈ និងបស្សាវៈ **តំ សព្វំ** រីទោសទាំងឡាយគឺញើសចេញពីកាយ ដូចជាវិលមុខ ក៏មិនមានកើតឡើងជាដើម ។ កិរិយាដែលអត់ទ្រាំឧច្ចារៈ និងបស្សាវៈដែលប្រកបដោយទោសនោះ សមដូចពាក្យក្នុងព្រះបាលី ដែលមាននៅក្នុងព្រះវិន័យថា **ឯកោ ភិក្ខុ** មានភិក្ខុមួយរូប **វច្ចិតោ** មានទុក្ខខ្លាំងក្លាដោយសារ

អត់ទ្រាំ រហូតដួលសន្លប់នឹងកន្លែង ព្រោះមិនអាចដើម្បីនឹងទ្រទ្រង់កាយបាន ហេតុនោះ អាហារណាមួយ ដែលបុគ្គលបរិភោគ កាលបើធ្លាក់ចុះដល់នូវការលេបចូលទៅតាមបំពង់-ក ហើយនោះ **គោ អាជីវំ ឱស្សយិស្សតិ** បុគ្គលដូចម្តេចប្រទូស្តនូវអាហារ ដូច្នេះ ទោះបីអាហារជាបដិកូល គួរឲ្យខ្ពើមរអើមដូច្នោះក្តី ក៏ចាំបាច់អាស្រ័យនូវអាហារដែលជាបដិកូលនោះចិញ្ចឹមជីវិតរបស់ខ្លួន **សបត្តចាណំ វិចរន្តោ** ហេតុដូច្នោះ ព្រះយោគាវរអ្នកមាននូវសេចក្តីព្យាយាម មានដៃកាន់បាត្រ ត្រាច់ទៅបិណ្ឌបាត ស្វែងរកអាហារដើម្បីចិញ្ចឹមជីវិត **អមូគោវ** មិនមែនមនុស្ស-គ **មុគ្គសម្មតោ** លោកទាំងឡាយសន្មតថា មនុស្ស-គម្នាក់ ព្រោះថា ដល់ពេលព្រឹកហើយ ក៏ដើរទៅឈរមុខផ្ទះរបស់មនុស្សទាំងឡាយ **អប្បំ ធានំ ន ហិឡេយ្យ** ព្រះយោគាវចរភិក្ខុនោះមិនគួរមើលងាយតិះដៀលនូវទាន ដែលតិចប្រមាណមួយវែក ដែលបុគ្គលដាក់ក្នុងបាត្រ **អលំ សុខញ្ញ ភុញ្ជន្តោ** កាលបើព្រះ-យោគាវចរបាននូវអាហារបិណ្ឌបាតហើយ ធ្វើកត្តកិច្ចបរិភោគល្មមផ្អែតជាសុខសប្បាយ មិនបានបរិភោគឲ្យហួសកំណត់ **ឱរូធរោ បីតាហារោ** ធម្មតាព្រះយោគាវចរភិក្ខុអ្នកឃើញភ័យក្នុងវដ្តសង្សារ

*នោះ កាលបើនឹងបរិភោគនូវអាហារ ក៏រមែងបរិភោគតែល្មម ហើយក៏មានសតិសម្បជញ្ញៈដឹងដោយជុំវិញ ក្នុងទីសេពសោយនូវអាហារ* **មនុជស្ស សទា សតិមតោ មត្តំ ជានតោ** *កាលបើសត្វទាំងឡាយក្នុងលោកនេះ ប្រកបទៅដោយសតិសម្បជញ្ញៈ បរិភោគនូវអាហារដែលខ្វនបាននោះ ក៏កើតនូវវេទនាតិចតួច មិនបានលំបាកដល់កាយ និងចិត្ត តែជាធាតុដែលជាភ្នាក់ងារដុតអាហារឲ្យរលួយ នឹងរក្សាជីវិតបាន ក៏ដុតតិចៗ មិនបានធ្វើឲ្យលំបាកកាយ និងចិត្ត ដោយអំណាចនៃបុគ្គលអ្នកប្រកបដោយសតិសម្បជញ្ញៈ ពិចារណាដឹងសព្វគ្រប់នោះ ជាគុណានិសង្សក្នុងកិរិយាដែលបរិភោគនូវអាហារ* **អយំ អាហារភេទនសង្គហនយោ** *វិន័យ គឺការសង្គ្រោះយកនូវកិរិយាវិសេសផ្សេងៗ នៃអាហាររបស់សត្វទាំងឡាយក្នុងលោកជាតុ អ្នកប្រាជ្ញគប្បីជ្រាបថា ក្នុង* ***គម្ពីរសារត្ថសង្គហៈ*** *នេះ ក៏ចប់តែប៉ុណ្ណេះ ។*

*សត្តាហារវិវេចនកថា ចប់*

# សត្តានំយោនិបភេទកថា

*វារៈនេះបានទទួលឆ្លើយ ក្នុងបទមាតិកា ដែលសម្ដែងនូវប្រភេទនៃកំណើតរបស់សត្វទាំងឡាយ មានមនុស្ស សត្វតិរច្ឆាន អសុរកាយ ប្រេតវិស័យ នរក ទេវតា នាគ គ្រុឌផ្សេងៗ ទាំងឡាយ តាមវារៈបាលីថា* **យុវន្តិ តាយ សត្តា អមិស្សិតាបិ សមានជាតិតាយ មិស្សិតា ហោន្តិ** *ប្រែតាមវិគ្រោះថា* **សត្តា** *វីសត្វទាំងឡាយ* **អមិស្សិតាបិ** *សូម្បីមិនបានលាយគ្នា* **យុវន្តិ** *ចម្រើន* **សមាន-ជាតិតាយ មិស្សិតា** *លាយគ្នា ព្រោះសត្វទាំងឡាយនោះមានជាតិស្មើគ្នា* **តាយ ធម្មជាតិយា** *ដោយធម្មជាតិនោះ* **ឥតិ** *ហេតុនោះ* **សា ធម្មជាតិ** *វីធម្មជាតិនោះ* **យោនិ** *ឈ្មោះថា* **យោនិ ធម្មជាតិ** *វីធម្មជាតិ* **យោនិ** *ជាហេតុមិនបានលាយគ្នា គឺថា កើតប្រាកដមិនបានលាយគ្នានៃសត្វទាំងឡាយ អធិប្បាយថា សត្វទាំងឡាយនេះមិនបានលាយគ្នា តាំងនៅជាពួកៗ ជាក្រុមៗ ជាផ្នែកៗ ម្យ៉ាងៗផ្សេងគ្នា ជាមនុស្ស ជាទេវតា ជានាគ ជាគ្រុឌ ជាប្រេត ជាអសុរកាយនិងសត្វតិរច្ឆាន នៅជាក្រុមៗ មិនលាយគ្នាទេ ប៉ុន្តែថា លាយគ្នា*

ដោយជាតិដែលស្មើគ្នា គឺមនុស្ស ។ សត្វតិរច្ឆានក៏ធ្វើការសង្វាស ដោយសត្វតិរច្ឆាន ។ ទេវតា និងទេវតា ក៏ធ្វើនូវការសង្វាសរួមប្រពៃណីនូវគ្នានិងគ្នា គឺនាងទេពអប្សរ និងទេវបុត្រ បរិភោគនូវកាមគុណដែលជាទិព្វ ហើយក៏ធ្វើការឱបរឹតនូវសម្ផស្សគ្នានិងគ្នា ដោយអំណាចតម្រេកក្នុងកិលេសកាម **សោ បន អត្ថតោ** ក៏សត្វទាំងឡាយនោះ បើចែកចេញដោយអត្ថមាន ៤ ប្រភេទ ដោយអំណាចនៃឈ្មោះផ្សេងៗ គ្នា គឺឈ្មោះថា **អណ្ឌជៈ** ( កំណើតរបស់សត្វដែលកើតក្នុងស៊ុត ) ១ **ជលាពុជៈ** ( កំណើតរបស់សត្វដែលកើតអំពីទឹក ) ១ **សំសេទជៈ** ( កំណើតរបស់សត្វដែលកើតក្នុងទីស្មោកគ្រោក ) ១ **ឱបបាតិកៈ** ( កំណើតរបស់សត្វដែលអណ្តែតទៅកើតភ្លាម ) ១ ។ ប្រភេទកំណើត ៤ ពួកនេះ គឺធម្មជាតិជាទីកើតរបស់សត្វទាំងឡាយកើតក្នុងស៊ុត ឈ្មោះថា **អណ្ឌជៈ** ដែលកើតអំពីទឹក ឈ្មោះថា **ជលាពុជៈ** ដែលកើតក្នុងទីស្មោកគ្រោក ឈ្មោះថា **សំសេទជៈ** ដែលអណ្តែតទៅកើតភ្លាមៗ ឈ្មោះថា **ឱបបាតិកៈ** ។

**វុត្តំ ហេតំ** សមដូចព្រះពុទ្ធដីកាព្រះមានព្រះភាគទ្រង់ត្រាស់ចំពោះព្រះសារីបុត្រថា **ចតស្សោ ខោ ឥមា សារីបុត្ត** ម្នាល

សារីបុត្រ **ឥមា យោនិយោ** រីធម្មជាតិដែលមិនបានលាយគ្នា តែលាយគ្នាអំពីជាតិដែលស្មើគ្នា ឈ្មោះថា កំណើតមាន ៤ **កតមា ចតស្សោ** ទើបទ្រង់ត្រាស់ជា **កាជតុកម្យតាបុច្ឆា** ថា កំណើត ៤ នោះ បានដល់ធម្មជាតិដូចម្តេច ព្រះមានព្រះភាគទ្រង់ឆ្លើយដោយព្រះអង្គថា កំណើត ៤ ប្រការនោះ គឺអណ្ឌជកំណើត ១ ជលាពុជកំណើត ១ កំណើតទាំង ២ នេះ សត្វកើតក្នុងផ្ទៃរបស់មាតា ហៅថា **គព្ភសេយ្យកសត្វ** ។ ម្យ៉ាងទៀត គឺសំសេទជកំណើត ១ ឱបបាតិកកំណើត ១ **តត្ថ អណ្ឌជាតា** គប្បីយល់ចូលចិត្តថា បើសត្វទាំងឡាយកើតក្នុងស៊ុតនោះ ឈ្មោះថា **អណ្ឌជៈ** ។ ដែលកើតដោយញើស គឺសង្អើច និងសុច ឈ្មោះថា **សំសេទជៈ** ។ សត្វដែលកើតក្នុងសម្ភពធាតុរបស់មាតា និងបិតាលាយគ្នានោះ ឈ្មោះថា **ជលាពុជៈ** សត្វដែលអណ្តែតមកកើតភ្លាមៗ នោះ ឈ្មោះថា **ឱបបាតិកៈ** គឺជាកំណើតដ៏ឧក្រិដ្ឋ **ឯត្ថ ច បេត្តលោកេ តិរច្ឆានេ មនុស្សេសុ** ការពិត កំណើតទាំង ៤ នេះ តែងតែកើតក្នុងបេតលោក មនុស្ស និងសត្វតិរច្ឆាន នៅក្នុងមនុស្សលោកនេះមាន ៤ ឯមនុស្សជំពូកខ្លះក៏កើតពីឱបបាតិកកំណើតដែរ ជំពូកខ្លះក៏កើតពីអណ្ឌជៈ ដូចជាព្រះ

មហាថេរៈពីររូបបងប្អូនបង្កើត ដែលជាបុត្ររបស់នាងកុន្តិកិន្នរីនោះ ជាឱបបាតិកៈ ដូចបោក្ខរសាតិយព្រាហ្មណ៍ជាដើម ដែលកើតក្នុងស្រទាប់ផ្កាឈូក ។ មនុស្សដែលកើតពីជលាពុជៈនៅក្នុងគភ៌របស់មាតានោះដោយច្រើន ការពិតសត្វដែលកើតក្នុងបេតវិស័យ បើកើតជានិជ្ឈាមតណ្ហិកប្រេតហើយ ក៏មិនមានតម្រេកក្នុងការសេពនូវកាមគុណឡើយ ព្រោះថា សត្វទាំងឡាយដែលជានិជ្ឈាមតណ្ហិកប្រេតនោះ ក្តៅក្រហាយដោយទុក្ខវេទនាខ្លាំងក្លា **តស្មា** ព្រោះហេតុនោះ សត្វទាំងឡាយ ដែលជានិជ្ឈាមតណ្ហិកប្រេតនោះ ទើបមិនបានកើតនៅក្នុងគភ៌របស់ស្រីប្រេតទេ ដែលមានអណ្តាតភ្លើង សន្ធោសន្ធៅសព្វកាល ។ លុះកើតហើយក៏ឆេះក្រៀមសោះអស់ទៅ ព្រោះហេតុនោះ ទើបប្រេតទាំងឡាយនោះ កើតជាឱបបាតិកកំណើតតែម្តង ។ ព្រោះថា សំសេទជកំណើតមិនបានកើតមានដល់និជ្ឈាមតណ្ហិកប្រេតទាំងឡាយទេ **អវសេសបេត្តា បន** ម្យ៉ាងទៀត ប្រេតទាំងឡាយដ៏សេសអំពីនិជ្ឈាមតណ្ហិកប្រេតនោះ រមែងកើតមានព្រមទាំង ៤ ប្រការ **យថា ច តេ ឯវំ យក្ខាបិ** ប្រេតមានកំណើតព្រមទាំង ៤ ប្រការ យ៉ាងណា យក្ខក៏មានកំណើត ៤ ប្រការយ៉ាងនោះ **សត្វចតុប្បាទ**

សត្វទ្វេបាទ (បក្សាបក្សី) សត្វទាំងឡាយក្តី **ទីឃជាតិ** (សត្វមានដងខ្លួនវែង ឧទាហរណ៍ ដូចជាសត្វពស់) សត្វទាំងនេះរមែងប្រកបដោយកំណើតទាំង ៤ **សព្វេ នេរយិកា ច ចាតុម្មហារាជិក–តោបដ្ឋាយ ឧបរុបរិទេវា ច** សត្វនរកទាំងឡាយក្តី ទេវតាទាំងឡាយក្តី តាំងអំពីជាន់ចាតុម្មហារាជិកាឡើងទៅ រហូតដល់កវគ្គព្រហ្មជាទីបំផុតនោះក្តី **ឱបចាតិកាយេវ** សុទ្ធតែជាឱបបាតិកៈទាំងអស់ **ភុម្មទេវា បន** ប៉ុន្តែភុម្មទេវតាទាំងនោះ **ចតុយោនិការ** ប្រកបដោយកំណើតទាំង ៤ បណ្តាសត្វទាំងឡាយនោះ សត្វដែលកើតក្នុងទេវ–លោក និងសត្វដែលកើតក្នុងមនុស្សលោកនេះ មានភាពវិសេសម្យ៉ាងគឺភាពវិសេសនៃសំសេទជកំណើត និងភាពវិសេសនៃឱបបាតិក–កំណើត ។ ប្រសិនបើកើតជាសំសេទជសត្វហើយ ក៏កើតជាទារកតូចបើកើតជាឱបបាតិកសត្វនោះ កើតធំតែម្តង ដូចមាណពទើបតែពេញកំលោះមានអាយុ ១៦ ឆ្នាំ បើជាស្ត្រីវិញ ក៏ធំពេញវ័យក្រមុំសេចក្តីនេះ លោកអាចារ្យសម្តែងទុកក្នុង ***អាលគទ្ទូបមសូត្រ មជ្ឈិមនិកាយ*** និង ***អដ្ឋកថាសង្គីតិសូត្រ ក្នុងគម្ពីរទីឃនិកាយ*** អ្នកប្រាជ្ញទាំងឡាយគប្បី ជ្រាបដោយប្រការដូច្នេះ ។

ប៉ុន្តែសេចក្តីទាំងឡាយនោះដែលពោលថា ក្នុងមនុស្សលោកជំពូកខ្លះ កើតជាឱបបាតិកៈ មានសេចក្តីប្រាកដដូច្នេះ លោកអាចារ្យពោលទុក គឺសង្គ្រោះនូវមនុស្សទាំងឡាយ មាននាងអម្ពបាលីគណិកាជាដើម **សាបនៈ**ចំណែកនាងអម្ពបាលីនោះ អំពីមុនបានបព្វជ្ជាជាភិក្ខុនីក្នុងសាសនារបស់ព្រះសិខីបរមគ្រូ កាលនាងបានឧបសម្បទាហើយក៏អាស្រ័យនៅក្នុងសីល និងផលសុខ **ឯកទិវសំ** ថ្ងៃមួយ ភិក្ខុនីនោះទៅនមស្ការព្រះចេតិយ មួយអន្លើដោយភិក្ខុនីជាច្រើនរូប **ចេតិយំ បទក្ខិណំ ករោន្តី** កាលនិមន្តប្រទក្សិណលានព្រះចេតិយ ភិក្ខុនីជាព្រះខីណាស្រពថេរីមួយរូប កណ្តាសក្នុងពេលនិមន្តប្រទក្សិណព្រះចេតិយ ទឹកមាត់ក៏ធ្លាក់ចុះមកលើលានព្រះចេតិយ មិនបានដឹងថា ទឹកមាត់ធ្លាក់ចុះមកទេ ក៏និមន្តហួសទៅ ភិក្ខុនីក្រមុំនោះនិមន្តតាមក្រោយ ឃើញទឹកមាត់ដែលធ្លាក់ចុះនោះ **អក្កោសិ** ទើបពោលឡើង ដោយពាក្យថា **កា ឆាម គណិកា** ស្ត្រីពេស្យានេះមានឈ្មោះអ្វី ទើបញុំាំងទឹកមាត់ឲ្យធ្លាក់ចុះក្នុងទីលានព្រះចេតិយ ។ ការពិត ភិក្ខុនីរូបនេះ តាំងនៅក្នុងបព្វជ្ជា រក្សាសីល ហើយមានការស្អប់ខ្ពើមនូវកិរិយាដែលនៅក្នុងគភ៌របស់មាតា ក៏តាំងអធិដ្ឋានជាដើម

ថា សូមកើតជាឱបបាតិកកំណើត ។ ដោយអំណាចនៃការរក្សាសីល ក្នុងអត្តភាពមុននោះ ទើបនាងមកកើតជាឱបបាតិកកំណើត ប្រាកដជាកុមារី ក្បែរគល់ស្វាយក្នុងរាជឧទ្យាន របស់ស្តេចលិច្ឆវីទាំងឡាយ ក្នុងក្រុងវេសាលីមហានគរ **តំ ទិស្វា** នាយរក្សាឧទ្យានបានឃើញកុមារី **ឧបនេសិ** ក៏នាំមកកាន់ព្រះនគរ កុមារីប្រាកដឈ្មោះថា **នាងអម្ពបាលី** ព្រោះថា កុមារីនោះកើតនៅជិតដើមស្វាយ ។

**អថ នំ ទិស្វា** គ្រានោះ ព្រះរាជកុមារទាំងឡាយ កាលពិចពិលរមិលមើលនូវនាងអម្ពបាលីនោះ ក៏រវើរវាយក្នុងគុណវិសេស គឺទ្រង់ទ្រាយរូបឆោមដ៏ស្អាតប្រសើរលើសលប់ គួរឲ្យសរសើរ ប្រៀបដូចនាងទេពអប្សរនៅស្ថានសួគ៌ា **អត្តនោ អត្តនោ បរិគ្គហំ កាតុកាមោ** ព្រះរាជកុមារទាំងឡាយ ក៏មានព្រះទ័យប្រាថ្នាជារបស់ខ្លួន រៀងៗ ខ្លួន **អញ្ញមញ្ញំ កលហំ ករោន្តិ** ធ្វើការឈ្លោះប្រកែកគ្នានិងគ្នា ។

**តេសំ តំ កលហំ វូបសមេតុំ តស្សា កម្មសព្ភោធិតា វោហារិកា** ឯព្រាហ្មណ៍ព្រឹទ្ធាចារ្យទាំងឡាយ ដែលជាអាចារ្យធំបង្គាប់បញ្ជា យ៉ាងដាច់ខាតដោយកម្មរបស់នាងអម្ពបាលីនោះដាស់តឿន ទើបតែងតាំងនាងអម្ពបាលីនោះ ក្នុងនាទីជាស្រីនគរសោភិនី មិនមែន

ជាកម្មសិទ្ធិរបស់ព្រះរាជកុមារអង្គណាមួយឡើយ ឲ្យជាសាធារណៈទូទៅចំពោះព្រះរាជកុមារទាំងឡាយ តាមតែព្រះរាជកុមារអង្គណាមកក៏បាន កុំហួងហែងចំពោះគ្នានិងគ្នាឡើយ ។ ព្រាហ្មណ៍ដាក់បង្គាប់ដូច្នេះ ដើម្បីរម្ងាប់រំលត់នូវការវិវាទគ្នា របស់ព្រះរាជកុមារទាំងឡាយ ។ តាំងអំពីថ្ងៃនោះមក នាងអម្ពបាលីក៏នៅក្នុងនាទីជាស្រីពេស្យា ដូចពាក្យរបស់ខ្លួន ដែលជេរចំពោះព្រះខីណាស្រពភិក្ខុនីនោះ **សា សត្ថរិ បដិលទ្ធ សទ្ធា** នាងអម្ពបាលីមាននូវសទ្ធាជ្រះថ្លា ចំពោះព្រះមានជោគ **វិហារំ ការាបេត្វា** នាងអម្ពបាលីនៅក្នុងនាទីជាស្រីពេស្យានោះ បានកសាងព្រះវិហារក្នុងឧទ្យាន ហើយក៏វេរថ្វាយចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ លុះក្រោយមក នាងអម្ពបាលីចេញបួសជាភិក្ខុនី ក្នុងសម្នាក់ព្រះវិមលកោណ្ឌញ្ញត្ថេរជាបុត្ររបស់នាងៗ ក៏បានសម្រេចដល់អរហត្តផល ជាព្រះអសេក្ខបុគ្គល ជាអ្នកប្រាជ្ញមួយរូបដ៏ប្រសើរក្នុងព្រះសាសនានេះ **តេន វុត្តំ អបទានេ** ទើបនាងអម្ពបាលីថេរីពោលពាក្យនៅក្នុង **គម្ពីរអបទាន** ជាព្រះគាថាថា **យោ រំសិរុចិតាវេឡោ ... ធីតា ពុទ្ធស្ស ឱរសា** ប្រែថា ព្រះមហាមុនី ព្រះនាមផុស្សៈណា មានជួរនៃរស្មីដ៏រុងរឿង ព្រះអង្គជា

កំពូលនៃអ្នកប្រាជ្ញ ប្រកបដោយព្រះរស្មីដ៏រុងរឿង **តស្សាហំ ភគិនី** ខ្ញុំបានជាប្អូនស្រីនៃព្រះមហាមុនីនោះ **អជាយិ** ខ្ញុំបានកើតក្នុងខត្តិយត្រកូល **តស្ស ធម្មំ សុណិត្វាហំ** ខ្ញុំបានស្តាប់ព្រះធម៌នៃព្រះមហាមុនីនោះហើយ **មហាទានំ ទទិត្វាន** ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយមហាទាន ហើយប្រាថ្នានូវរូបសម្បត្តិ **ឯកត្តឹសេ ឥតោ កប្បេ** ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រះជិនស្រីព្រះនាមសិខី ជានាយកដ៏ប្រសើរក្នុងលោក ជាពន្លឺនៃលោកជាទីពឹងនៃត្រៃភពកើតឡើង **លោកបជ្ជោតោ** ប្រាកដរុងរឿងដោយប្រទីប គឺព្រះធម៌ **តិលោក-សរណោ** ជាទីពឹងនៃសព្វសត្វ **ជិនោ តទា** កាលនោះ ខ្ញុំកើតក្នុងត្រកូលនៃព្រាហ្មណ៍ ក្នុងអរុណបុរី ជាទីក្រុងរីករាយ **វិមុត្តចិត្តំ កុបិតា** គ្រានោះ ខ្ញុំជាបុថុជ្ជន បួសជាភិក្ខុនី បានខឹងជេរផ្តាសាភិក្ខុនី ដែលមានចិត្តរួចស្រឡះចាកកិលេសហើយ **ជិនសាសនទូសិកា** ដែលមកធ្វើអំពើមិនសមគួរ ញុំាងទឹកមាត់ឲ្យធ្លាក់ចុះក្នុងលានព្រះចេតិយនេះ **ឯវំ អក្កោសយិត្វាន** ខ្ញុំខឹង ជេរផ្តាសាភិក្ខុនី ដោយប្រការដូច្នេះ ទើបធ្លាក់ទៅកើតក្នុងនរក សោយនូវទុក្ខវេទនាយ៉ាងខ្លាំងដោយកម្មដ៏លាមក គឺបានខឹងជេរព្រះខីណាស្រពនោះ **តតោ ចុតា**

*លុះខ្ញុំរួចចាកនរកនោះ បានមកកើតក្នុងមនុស្សលោកនេះ បានសោយនូវចំណែកបាប គឺភាវៈជាស្រីផ្កាមាស អស់ជាតិទាំងឡាយមួយម៉ឺនជាតិជាកំណត់* **តតោ ចាចា ឧ មុច្ចិស្សំ ហុត្វា** *កាលខ្ញុំរួចចាកបាបដ៏លាមកនេះ* **ទុដ្ឋវិសំ យថា** *ឧបមាដូចបុគ្គលរួចចាកថ្នាំពិសដ៏កាចអាក្រក់ ទើបបានសេពគប់នូវភេទដ៏ប្រសើរ គឺភេទបព្វជិតក្នុងសាសនាព្រះជិនស្រីព្រះនាមកស្សបៈ* **តេន កម្មវិបាកេន** *ដោយអំណាចនៃផលកម្មនោះ* **អជាយឹ** *ខ្ញុំទើបបានទៅកើតក្នុងត្រៃត្រឹង្ស* **បច្ឆិមេ ភវសម្បត្តេ** *លុះមកដល់បច្ឆិមភព ខ្ញុំជាឱបបាតិកកំណើតបានកើតក្នុងចន្លោះនៃមែកស្វាយ ព្រោះហេតុនោះ បានជាខ្ញុំឈ្មោះថា អម្ពបាលី ដែលមានបរិវារទាំងឡាយប្រមាណមួយកោដិចោមរោមហើយ បួសក្នុងសាសនាព្រះជិនស្រី បានជាធីតា ជាឱរសនៃព្រះពុទ្ធ ហើយបានដល់ឋានៈដ៏មិនកម្រើក ។ មនុស្សទាំងឡាយជំពូកខ្លះជាឱបបាតិកកំណើត ប្រៀបដូចនាងអម្ពបាលីគណិកាជាដើម អ្នកប្រាជ្ញទាំងឡាយគប្បីជ្រាបដោយប្រការដូច្នេះ ។*

**អណ្ឌជាបិ ហោន្តិ កុន្តិបុត្តា ទ្វេភាតិកត្ថេរា វិយាតិ ឯត្ថ** *ឥឡូវនេះ នឹងបានវិសជ្ជនាក្នុងពាក្យថា មនុស្សទាំងឡាយជាអណ្ឌជ-*

កំណើតនោះ ប្រៀបដូចព្រះមហាថេរៈពីររូបបងប្អូន ជាបុត្ររបស់នាងកិន្នរី ។

មានសេចក្ដីតំណាលថា ក្នុងកាលកន្លងមក មានព្រានព្រៃម្នាក់នៅក្នុងក្រុងបត្តលីបុត្រ បានត្រាច់ទៅស្វែងរកម្រឹគក្នុងដងព្រៃ **សំវាសំ ករប្បេសិ** ព្រានព្រៃនោះ បានជួបនាងកិន្នរី បានរួមសង្វាសជាមួយនាងកុន្តីកិន្នរី នាងមានគភ៌តាំងឡើង **ទ្វេ អណ្ឌានិ វិជាយិ** ប្រសូតមកបានស៊ុតពីរ **តតោ សម្បត្តេ កាលេ** ពេលដល់ព្រមបរិបូណ៌ហើយ ក៏កើតជាទារកពីរ ទម្លាយនូវស៊ុតចេញមកជាមនុស្សទាំងពីរ **តេសុ ជេដ្ឋា** ទារកទាំងពីរ ទារកបងឈ្មោះតិស្សៈ ទារកប្អូនឈ្មោះសុមិត្តៈ **តេ ឧភោបិ** កាលក្មេងតូចទាំងពីរនាក់បងប្អូនចម្រើនវ័យធំដឹងក្ដីហើយ ពិចារណាមើលម្ដាយក៏ប្លែកចម្លែក ឪពុកនោះសោតក៏ជាមនុស្សសៅហ្មង មានតែធ្វើកម្មដ៏លាមក **សំសារេ និព្វិណ្ណា** ក៏កើតសេចក្ដីសង្វេគក្នុងសង្សារទុក្ខ ដែលប្រព្រឹត្តទៅរាប់ជាតិមិនបាន **មហាវរុណត្ថេរស្ស សន្តិកេ បព្វជិត្វា** ទើបទាំងពីរនាក់បងប្អូនចេញបួសក្នុងសម្នាក់នៃព្រះវរុណត្ថេរ បានសិក្សានូវអធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខាក្នុងព្រះពុទ្ធសាសនា **អរហត្តំ ធាបុ-**

**ឈាសុ** ក៏បានសម្រេចនូវអរហត្តផល ជាព្រះអរហន្តដ៏ប្រសើរក្នុងលោកនេះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា **អណ្ឌជកំណើត** ដូចព្រះមហាថេរៈទាំងពីរនាក់បងប្អូននេះ ។

**វុត្តំ ហោតំ មហាវំសេ** ហេតុដូច្នោះ ទើបមានពាក្យសម្ដែងក្នុង **គម្ពីរមហាវង្ស** ថា ព្រះតិស្សត្ថេរជាបង ព្រះសុមិត្តត្ថេរជាប្អូន ជាបុត្ររបស់នាងកុន្តិកិន្នរីនោះ ចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ក្នុងសម្នាក់របស់ព្រះវរុណត្ថេរទាំងពីរនាក់បងប្អូន ក៏បានសម្រេចដល់នូវអរហត្តផល ដែលប្រកបដោយគុណដ៏ប្រសើរ មានអភិញ្ញា ៦ ប្រការ គឺភ្នែកទិព្វ ១ ត្រចៀកទិព្វ ១ ឥទ្ធិឫទ្ធិផ្សេងៗ ១ បុព្វេនិវាសញ្ញាណ មានបញ្ញារឭកជាតិកន្លងហើយ ១ ចេតោបរិយញ្ញាណ មានបញ្ញាដឹងនូវចិត្តអ្នកដទៃ ១ អាសវក្ខយញ្ញាណ មានបញ្ញាជម្រះចេញនូវអាសវធម៌ទាំងពួង បណ្ដាអកុសលដ៏លាមក និងពួកកិលេសទាំងឡាយឲ្យដាច់សូន្យអស់ប្រាសចាកសន្ដាន ១ ។ **ឯវំ ឥមេ ទ្វេ ភាតិកត្ថេរា វិយ** មនុស្សដែលកើតពីស៊ុតមានប្រាកដក្នុងលោកនេះ អ្នកប្រាជ្ញគប្បីជ្រាបចុះថា បានដល់ ព្រះតិស្សត្ថេរ និងព្រះសុមិត្តត្ថេរ ជាបងប្អូនបង្កើត ដូចវិសជ្ជនាមកនេះ ។

**សំសេទជាបិ ហោន្តិ** ម្យ៉ាងទៀត នឹងបានឆ្លើយក្នុងពាក្យថា មនុស្សកើតមកជាសំសេទជៈប្រាកដនៅក្នុងលោកនេះ ដូចព្រាហ្មណ៍ដែលកើតក្នុងផ្កាឈូក មានបោក្ខរសាតិយព្រាហ្មណ៍ជាដើម **សោ ព្រាហ្មណោ** បោក្ខរសាតិយព្រាហ្មណ៍នោះ **តិណ្ណំ វេទនំ ចារគូ** ដល់នូវត្រើយនៃត្រៃវេទដ៏ជំនាញ ដឹងអ្វីៗ គ្រប់យ៉ាងក្នុងវិស័យសិល្បសាស្ត្រ **កស្សបសម្មាសម្ពុទ្ធកាលេ** ក្នុងព្រះសាសនារបស់ព្រះសម្ពុទ្ធកស្សបៈនោះ បានថ្វាយទានចំពោះព្រះពុទ្ធអង្គ **ធម្មទេសនំ សុត្វា** បានស្តាប់ព្រះ ធម៌ទេសនា លុះចុតិចាកមនុស្សលោកហើយ **ទេវលោកេ និព្វត្តោ** ក៏ទៅកើតក្នុងស្ថានសួគ៌ទេវលោក **ទេវលោកតោ ចវិត្វា** លុះច្យុតចាកទេវលោកហើយ ក៏ត្រឡប់មកកាន់មនុស្សលោក **ជិគុច្ឆិត្វា** ទេវបុត្រនោះស្អប់ខ្ពើមកិរិយាដែលនៅក្នុងផ្ទៃរបស់ម្តាយ **តតោ ចវិត្វា** ក៏ច្យុតមកកើតក្នុងផ្កាឈូក ដែលនៅក្នុងមហាស្រះនាព្រៃហិមពាន្ត **អវិទូរេ** ក្នុងទីជិតមហាស្រះនោះ មានតាបសមួយរូបកសាងបណ្ណសាលា អាស្រ័យនៅទីនោះ **ឯកទិវសំ** ថ្ងៃមួយតាបសនោះទៅឈរនៅមាត់ច្រាំងស្រះបោក្ខរណី **តំ បទុមំ ទិស្វា** ក៏ឃើញផ្កាបទុមជាតិនោះ ៗ កិរិយានៃផ្កាបទុមជាតិនោះ ផ្កាធំជាង

ផ្កាបទុមទាំងឡាយ ទើបតាបសនោះគិតថា ផ្កាឈូកធំនោះក៏ក្តោប ជាប្រក្រតី កំណាត់ដល់ ៧ ថ្ងៃហើយ ក៏នៅមិនទាន់រីក តាបស ឃើញចម្លែកក៏ចុះទៅក្នុងស្រះ ដើម្បីនឹងកាច់យកនូវផ្កាបទុមនោះ លុះ តាបសកាច់ចេញចាកទងហើយ ផ្កាឈូកក៏រីកក្នុងខណៈនោះ តាបស បានឃើញទារកនៅក្នុងផ្កាឈូក តាបសមានសេចក្តីត្រេកអរពោលថា ទារកនេះមានបុណ្យច្រើន អញគួរនាំយកទៅចិញ្ចឹមរក្សា **បណ្ណសាលំ នេត្វា** តាបសនាំមកកាន់បណ្ណសាលា លុះចម្រើនវ័យបាន ៧ ឆ្នាំ តាបសក៏ឲ្យរៀនគម្ពីរត្រៃវេទ កុមារនោះ ក៏រៀនចប់គម្ពីរត្រៃវេទ **បណ្ឌិតោ ព្យត្តោ** ប្រកបដោយបញ្ញាឈ្លាស ប្រាកដក្នុងជម្ពូទ្វីប ។ ក្នុងកាលតមក ព្រាហ្មណ៍នេះបានមកសម្តែងសិល្បសាស្ត្រចំពោះ ព្រះបាទកោសលរាជ គ្រានោះ ព្រះបាទកោសលទ្រង់សោមនស្ស សរសើរសិល្បសាស្ត្ររបស់ព្រាហ្មណ៍នោះ ទើបប្រទានស្រុកមួយឲ្យជា សួយ **តស្ស បន កាយេ សេតចោក្ខសទិសោ** សរីរៈរបស់ ព្រាហ្មណ៍នោះស្អាត បរិសុទ្ធឥតគណនា ប្រៀបដូចផ្កាឈូក-ស ស្អាតក្រៃលែង ម្យ៉ាងទៀត កាយរបស់ព្រាហ្មណ៍នោះ ហាក់បីដូចជា សសរប្រាក់ដែលបុគ្គលតម្កល់ក្នុងទេវនគរ សិរសារបស់ព្រាហ្មណ៍

នោះ ប្រកបដោយសក់មានពណ៌ខ្មៅស្រិល ហាក់បីដូចកែវឥន្ទនិល ល្អស្អាតប្រសើរ កាលបើក្រឡេកមើលបបូរមាត់ខាងលើ និងខាងក្រោម **ចន្ទមណ្ឌលេ កាលមេឃរាជី វិយ** ប្រៀបដូចកាឡមេឃដ៏ខ្មៅ ក្នុងមណ្ឌលនៃដួងព្រះចន្ទ **តថា អក្ខីនិ** មួយទៀតសោតរោមភ្នែកទាំងសងខាង ក៏មានសម្បុរខៀវស្អាតឥតគណនា **ឆាសារជនធានធ្យិកា វិយ** នាសិកនោះមូលក្លំស្អាតល្អដូចជានាឡិ ជាវិការនៃប្រាក់ **ចារិសុទ្ធានិ ចេវ** មួយទៀត ផ្ទៃនៃបាតដៃ បាតជើងនោះរាបស្មើបរិសុទ្ធល្អ មានស្នាមឆ្នូតប្រកបដោយលក្ខណៈ ដូចផ្កាពិកុលប្រាក់ស្អាត បបូរមាត់ក្រហមដូចផ្លែបាស់ទុំ ដូចតាក់តែងដោយទឹកល័ខដ៏ស្រស់ស្អាត **តស្មា** ព្រោះហេតុនោះ មនុស្សទាំងឡាយក៏នាំគ្នាហៅព្រាហ្មណ៍ថា បោក្ខរសាតិយព្រាហ្មណ៍ ព្រោះថា ព្រាហ្មណ៍នេះកើតក្នុងផ្កាឈូក ។ រឿងរបស់បោក្ខរសាតិយព្រាហ្មណ៍នេះ មានសេចក្តីពិស្តារក្នុង អដ្ឋកថាអម្ពដ្ឋសូត្រ ក្នុង គម្ពីរទីឃនិកាយ ។

**យេភុយ្យេន បន** មយ៉ាងទៀត មនុស្សទាំងឡាយដែលកើតជាជលាពុជៈនោះ មានដោយច្រើន ជាយេភុយ្យន័យ និងប្រមាណមិនបាន សត្វទាំងឡាយដែលនៅក្នុងកគ៌នៃមាតា ជាជលាពុជកំណើត

*នោះ* **បឋមំ កលលំ ហោតិ** *កាលកើតជាដំបូងជាកលលៈ* **កលលា ហោតិ អព្ពុទំ** *កើតជាអព្ពុទៈ ពណ៌ដូចទឹកលាងសាច់* **អព្ពុទា ជាយតេ បេសិ** *ហើយកើតជាខន់បន្តិចឡើង* **ឃនាបិ សាខា ជាយន្តិ** *ខន់ឡើង ជាដុំក៏បែកជាពក ៥ គឺជាដៃពីរ ជើងពីរ ក្បាលមួយ ហើយទើបមានសក់ រោម ក្រចកទាំងឡាយ* **តត្ថ គព្ភសេយ្យក សត្តានំ បដិសន្ធិក្ខណេ បញ្ចខន្ធា** *ធម្មជាតិទាំងឡាយនោះ គឺកលលៈ អព្ពុទៈ បេសិ និងឃនៈនោះ ជាខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធក៏កើតឡើងព្រមគ្នាតែម្តង មិនមុនមិនក្រោយ កើតព្រមគ្នា ក្នុងខណៈនៃបដិសន្ធិរបស់សត្វទាំងឡាយ ដែលនៅក្នុងគភ៌មាតាតាំងអំពីកលលៈនោះ* **តស្មិំ ខណេ ចាតុក្ខតា កលលសង្ខាតា រូបសន្តតិ** *រីតំណរបស់រូប គឺរូបកលាបៈដែលនៅជាកលលៈ ដែលប្រាកដតាំងពីដំបូង គឺក្នុងកាលបដិសន្ធិជាដំបូងនោះ តូចណាស់ មានសេចក្តីថា* **ឥមស្មិំ ជនបទេ** *សរសៃសក់របស់មនុស្ស អ្នកជម្ពូទ្វីបនេះបែងចេញជា ៧ ភាគ សរសៃសក់ដែលសល់មួយភាគនោះ តូចប៉ុនសរសៃសក់របស់មនុស្សទាំងឡាយក្នុងឧត្តរកុរុទ្វីប ទើបយកសរសៃសក់របស់*

មនុស្ស ក្នុងឧត្តរកុរុទ្វីបនោះជ្រលក់ក្នុងប្រេងល្ងដ៏ថ្លា ហើយលើកឡើងរលាស់ជា ៧ ដង ឯតំណក់ប្រេងល្ង ដែលជាប់នៅខាងចុងសរសៃសក់នោះប្រមាណប៉ុនណា កលលៈនោះ ក៏មានប៉ុណ្ណោះ **តំ បដិវិបិត្វា** ម្យ៉ាងទៀត តំណក់ប្រេងល្ងដែលជាប់នៅចុងសរសៃសក់ អ្នកឧត្តរកុរុទ្វីបដែលរលាស់ ៧ ដងនោះ ឬយកសរសៃរោមជាតិឧណ្ណាលោម គឺរោមទ្រាយចាមរីដ៏ល្អិតនោះ យកតែមួយសរសៃជ្រលក់ក្នុងប្រេងល្ងដ៏ថ្លា លើកឡើងរលាស់ ៧ ដង ឯតំណក់ប្រេងល្ងដ៏ថ្លាដែលជាប់ចុងរោមទ្រាយចាមរីនោះ ជាប់តិចប្រមាណប៉ុនណា កលលៈដែលជាធម្មជាតិនៃបដិសន្ធិរបស់សត្វទាំងឡាយនោះ ក៏ជាប់តិចប្រមាណប៉ុណ្ណោះ **តំ បនេសំ តំ អច្ឆំ ហោតិ** ប្រេងល្ងថ្លាជាប់នៅខាងចុងរោមទ្រាយចាមរីនោះ ថ្លាស្អាតប្រាសចាកមន្ទិល ចាត់ជាទឹកកលលៈដំបូង ក្នុងខណៈបដិសន្ធិរបស់សត្វនោះ ។

ទើបមានពាក្យចោទសួរក្នុង គម្ពីរសម្មោហវិនោទនី អដ្ឋកថាវិភង្គ ថា **តិលតេលស្ស យថាពិន្ទុសប្បិមណ្ឌោ អនាវិលោ ឯវំ វណ្ណបដិភាគំ កលលំ សម្បវុច្ចតិ តតោ សត្តាហាញ្ញយេន មំសធោវនឧទកវណ្ណំ អព្ពុទំ ឆាម ហោតិ** ឯតំណក់ប្រេងសប្បិ

ដែលថ្លាស្អាត គ្មានមន្ទិល យ៉ាងណាក្តី ឯកលលបដិសន្ធិនោះ បរិសុទ្ធស្អាតប្រាសចាកមន្ទិល ដូចប្រេងដ៏ថ្លា លុះកំណត់ ៧ ថ្ងៃ កន្លងទៅហើយ ក៏កើតជាអព្វុទៈ មានពណ៌ដូចទឹកលាងសាច់ ឡើង ខ្ទន់ជាងមុនបន្តិច **សត្តាហំ កលលំ ហោតិ** កាលជាកលលៈ ដ៏ថ្លានោះ ឡើងខ្ទន់ច្រើនបន្តិចគ្រប់ ៧ ថ្ងៃហើយ **តម្ហាវំ អព្វុធំ ជាម** ទើបកើតជាទឹកអព្វុទៈអំពីទឹកកលលៈនោះ កាលទឹកអព្វុទៈឡើងខ្ទន់ បន្តិចគ្រប់ ៧ ថ្ងៃហើយ **វិលីនតិបុសធិសា** ទើបកើតឡើងខ្ទន់ប្រៀប ដូចសំណដែលរលាយ ហេតុដូច្នោះ អព្វុទៈ ទឹកលាងសាច់ចម្រើន ឡើងរាល់ថ្ងៃ គ្រប់ ៧ ថ្ងៃហើយ ក៏ក្លាយជាបេសិ ដូចខ្ញាញ់រាវកើត អំពីអព្វុទៈនោះ កាលកន្លងទៅបាន ៧ ថ្ងៃ ទើបកើតជាដុំមានសណ្ឋាន ដូចពងមាន់ ទើបហៅថា ឃនៈ គឺកើតជាដុំដូចពងមាន់ មានបរិ-មណ្ឌលមូលយ៉ាងណា បរិមណ្ឌលរបស់ឃនបដិសន្ធិនោះ កើត មកអំពីកម្មជាបច្ច័យ ដូច្នេះ កាលបើកើតជាឃនបដិសន្ធិ សណ្ឋាន មូលដូចពងមាន់នោះ ក៏តាំងនៅ ១៥ ថ្ងៃទៀត **បញ្ចមេ បន សត្តាហេ** កាលបើតាំងនៅប្រមាណ ១៥ ថ្ងៃហើយ **ទ្វិន្នំ ហត្ថបាទានំ** ទើបកើតជាពក បែកចេញជា ៥ គឺជាដៃពីរ ជើងពីរ ក្បាលមួយ

បាន ៧ ថ្ងៃ រហូត ដល់ ៣២ ថ្ងៃ **ឃរំ ទ្វាចត្តាឡីសធិវសេ** ក្នុងថ្ងៃ ៤២ កន្ទងទៅដោយប្រការដូច្នេះ ក្នុងលំដាប់នោះ សក់ រោមទាំងឡាយក៏កើតឡើង **ឆាឡេ្ឡា** គឺទងផ្ចិតដែលកើតឡើងអំពីផ្ចិតរបស់សត្វទាំងឡាយ ដែលនៅក្នុងគភ៌មាតាជាប់នឹងពោះរបស់មាតា ទងផ្ចិតនោះមានប្រហោង ដូចដើមឧប្បលជាតិ ស្រូបយកនូវអាហារដែលមាតាបរិភោគចូលទៅ ក៏ញ៉ាំងរូបដែលកើតអំពីអាហារឲ្យចម្រើនទារកនោះក៏នៅមានជីវិត ប្រព្រឹត្តទៅក្នុងផ្ទៃរបស់មាតារហូត ១០ ខែ ព្រោះហេតុនោះ ទើបព្រះសម្ពុទ្ធត្រាស់ថា **យញ្ចស្ស ភុញ្ជតេ មាតា** មាតារបស់ទារកនោះ បរិភោគអាហារណា គឺភោជនាហារផ្សេងៗ ទារកក្នុងឧទរនោះ ក៏ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយអាហារនោះ ព្រះពុទ្ធដីកាដែលត្រាស់ទុកក្នុង **គម្ពីរសំយុត្តនិកាយ** យ៉ាងនេះ ព្រះអដ្ឋកថាចារ្យជ្រាបនូវពុទ្ធាធិប្បាយ ទើបពោលទុកក្នុងអដ្ឋកថាថា **គព្ភំ បន អគណ្ហនកិត្ថិយោ ឆាម ឆត្ថិ** សេចក្តីមួយប្រការថា ឈ្មោះថា ស្ត្រីភេទនោះ ដែលមិនតាំងគភ៌នោះ មិនមាន **ឧតុសមយេ សព្វិត្ថិយោ** ស្ត្រីភេទ ទាំងឡាយកាលដល់ឧតុសម័យហើយ ក៏រមែងមានគភ៌ ។

**យា បនាយំ** ម្យ៉ាងទៀត ស្ត្រីភេទជំពូកណា ព្រះមានព្រះភាគត្រាស់ថា ជាស្រីអារ គឺអកុសលវិបាក ដែលជាផលរបស់បាបតាមមកទាន់ ដែលសត្វទាំងឡាយអ្នកមកកើតក្នុងផ្ទៃរបស់ស្ត្រីអារនោះ **តេ បរិត្តកុសលវិបាកេន** សត្វទាំងឡាយដែលមានផលកុសលតិចមកបដិសន្ធិនោះ កម្លាំងអកុសលខ្លាំងក្លាគ្របសង្កត់បាន ទើបវិនាសសូន្យមិនកើតក្នុងផ្ទៃស្ត្រីនោះបានទេ ។

ទើបមានពាក្យទទួលថា ការពិត សត្វដែលតាំងនៅក្នុងផ្ទៃស្ត្រីអារនោះមិនបានដោយហេតុ ២ ប្រការ គឺកម្លាំងខ្យល់ខ្លាំងក្លា ១ សត្វល្អិតក្នុងផ្ទៃបៀតបៀន ១ ។ ប្រសិនបើវាយោធាតុក្នុងផ្ទៃរបស់មាតានោះបក់ខ្លាំងក្លា **សោសេត្វា អន្តរធាបេតិ** ក៏ញុំាងសត្វដែលចុះកាន់បដិសន្ធិ ឲ្យរីងស្ងួតអន្តរធានទៅ **ចាណកា** ម្យ៉ាងទៀត សត្វ គឺហ្វូងជង្គួរទាំងឡាយដែលកាចៗ ក៏ខាំស៊ីនូវសត្វដែលបដិសន្ធិថ្មីៗនោះ **តស្ស បន វាតស្ស វា ចាណកានំ វា** បើគ្រូពេទ្យផ្សំនូវឱសថកម្ចាត់បំបាត់នូវវាយោធាតុ ឬហ្វូងជង្គួរទាំងឡាយ កាលបើកម្ចាត់បំបាត់អស់ហើយ សត្វដែលចុះកាន់បដិសន្ធិក្នុងផ្ទៃនោះ ទើបតាំងគភ៌បាន ។ ការពិត ឈាមដែលកើតក្នុងកាលស្ត្រីភេទមានរដូវនោះ អ្នក

ប្រាជ្ញហៅថា **មាតុគាមស្ស យស្មឹ ឱកាសេ ទារកោ និព្វត្តតិ។**

មានពាក្យជាកណ្តាលក្នុងទីនេះថា ក្រពេញឈាមរបស់មាតុគ្រាមកើតឡើងហើយ ចម្រើនឡើង ៧ ថ្ងៃ រួចហើយក៏បែកចេញ គឺទារកនឹងកើតមានក្នុងទីណា ក៏កើតមានក្នុងទីនោះ កាលបើឈាមនៅហូរច្រើន កំណត់កាលប៉ុនណា បដិសន្ធិកម្មដែលបិតាឲ្យក៏មានទោសប៉ុណ្ណោះ ព្រោះថា ( ឈាម ) នៅហូរច្រើន ទើបជាទោសមិនអាចបដិសន្ធិ ឲ្យតាំងគភ៌បានទេ កាលបើទោស គឺឈាមនោះបរិសុទ្ធស្អាត ហើយមាតាបិតាទាំងពីរនាក់ រួមសង្វាសតែមួយពេលក៏មានកំណត់ព្រំដែន ៧ ថ្ងៃជាកំណត់នៃបដិសន្ធិ ក្នុងកាលកំណត់ព្រំដែន ៧ ថ្ងៃនោះ មាតាបិតាមិនបានរួមសង្វាស ស្ត្រីភាពក៏មានការតាំងគភ៌ឡើង កិរិយាដែលស្ត្រីភាពមានការតាំងគភ៌នោះ ប្រកបដោយហេតុ ៦ យ៉ាង **កាយសំសគ្គេន** គឺមានការតាំងគភ៌ដោយការប៉ះពាល់កាយ ១ **ចោឡគហណេន** គឺកាន់យកនូវក្រណាត់សំពត់ ១ **អសុចិបានេន** គឺបៀមនូវទឹកអសុចិ ១ **នាភិបរាមាសនេន** គឺកិរិយាដែលស្ទាបអង្អែលនូវនាភី ( ផ្ចិត ) ១ **ទស្សនេន** គឺកិរិយាសម្លឹងមើលបុរស ១ **គន្ធេន** គឺបានស្រូបក្លិន ហិតក្លិន ១

ជា ៦ យ៉ាង ដូច្នេះ ។ អធិប្បាយថា ស្ត្រីជំពូកខ្លះមានតម្រេកខ្លាំងក្លា គ្រាន់តែបុរសប៉ះអវយវៈ កើតសេចក្តីត្រេកអរឡើង ហើយក៏រមែងមានគភ៌តាំងឡើង យ៉ាងនេះឈ្មោះថា មានគភ៌ដោយកាយសំសគ្គៈ ។

**បុរាណទុតិយិកា** ភិក្ខុនីករិយាចាស់របស់ព្រះឧទាយិត្ថេរ កាលនាំយកសំពត់ព្រះឧទាយិត្ថេរទៅបោកគក់ ឃើញទឹកអសុចិជាប់លើសំពត់ មាននូវតម្រេកកើតឡើង ទើបបៀមយកនូវសំពត់ប្រឡាក់ទឹកអសុចិក្នុងមាត់ **ឯកំ តេសំ បក្ខិបិ** ទើបចាប់យកនូវសំពត់ប្រឡាក់ទឹកអសុចិមួយចំណែកទៀត ទៅដាក់ក្នុងឥត្ថីនិមិត្តរបស់ខ្លួន ដោយអំណាចតម្រេកខ្លាំងក្លា ភិក្ខុនីក៏តាំងគភ៌ឡើង កិរិយាដែលស្ត្រីមានគភ៌យ៉ាងនេះ ឈ្មោះថា មានគភ៌ដោយការប៉ះពាល់នូវសំពត់ ។

**ឥសីសិង្គតាបសស្ស មាតា មិគី** ម្រឹគីជាមាតារបស់ឥសីសិង្គតាបស កាលមានរដូវ គ្រានោះ ព្រះបរមពោធិសត្វបន្ទោបង់បស្សាវៈនៅក្នុងទីមួយ ម្រឹគីមកលិទ្ធទឹកបស្សាវៈ ក្នុងទីបន្ទោបង់របស់ព្រះបរមពោធិសត្វ ម្រឹគីក៏តាំងគភ៌ឡើង រហូតដល់ពេលប្រសូតបុត្រ គឺឥសីសិង្គតាបសយ៉ាងនេះឯង ឈ្មោះថា មានគភ៌

ដោយលិទ្ធនូវទឹកអសុចិ ។

**ឧតុនីកាលេ** ក្នុងកាលមាតារបស់ព្រះពោធិសត្វសុវណ្ណសាម មានរដូវកើតឡើងនោះ តាបសទុកូលបណ្ឌិតស្ទាបនូវផ្ចិតដោយមេដៃ ប៉ុណ្ណោះ តាបសិនីក៏តាំងគភ៌ឡើង កើតព្រះពោធិសត្វសុវណ្ណសាម យ៉ាងនេះឯង ឈ្មោះថា មានគភ៌ដោយការស្ទាបអង្អែល ។

**ឃតេនេវ ឆយេន** នាំនិទានរបស់មណ្ឌព្យមាណពក្តី ( កូនរបស់មាតង្គតាបស ) ស្តេចចណ្ឌប្បជ្ជោតក្តី អ្នកប្រាជ្ញគប្បីជ្រាបដោយន័យដូចពោលមកហើយនោះ ការពិត កាលមាតារបស់ស្តេចចណ្ឌប្បជ្ជោតមានរដូវ យាងចូលទៅកាន់ក្រឡាព្រះបន្ទំ មានសត្វខ្យួយមួយវារឡើងទៅលើផ្ចិតរបស់ព្រះនាង ព្រះនាងក៏ទ្រង់តាំងគភ៌ ព្រោះត្រូវសម្ផស្សរបស់សត្វខ្យួយនោះ ។

**កថំ ឧស្សនេន ហោតិ** មានពាក្យសួរថា ស្ត្រីភាពដែលមានគភ៌ ដោយកិរិយាសម្លឹងមើលនោះដូចម្តេច ?

ឆ្លើយថា **ឥធេកច្ចា ឥត្ថិយោ** ស្ត្រីទាំងឡាយពួកខ្លះ ក្នុងលោកនេះ កាលមានរដូវហើយ មិនបានប៉ះពាល់នូវកាយជាមួយនឹងបុរស ចូលនៅក្នុងទីកំបាំងដែលជាខាងក្នុងផ្ទះ សម្លឹងមើលនូវបុរស ដោយ

តម្រេកចំពោះបុរស ដូចស្និទាំងនោះ **សា តេន គត្តំ គណ្ហាតិ** ស្ត្រីនោះក៏ដល់នូវការតាំងគភ៌ដោយអំណាចរាគៈខ្លាំងក្លា នឹងសម្លឹង មើលនូវបុរស ដោយអំណាចមាននូវសេចក្តីត្រេកអរ ស្រឡាញ់ យ៉ាងនេះឯង ឈ្មោះថា ស្ត្រីភេទមានការតាំងគភ៌ ដោយការសម្លឹង មើលបុរស ។

**ពកា បន** ចំណែកមេកុកទាំងឡាយ មិនមានឈ្មោល កាល មេកុកមានរដូវ បានឮសំឡេងផ្គរលាន់ឮដ៏អាកាស ក៏រមែងតាំងគភ៌ ។ ពាក្យនេះក្នុងបាលីថេរាបទានថា មេកុកទាំងឡាយ មិនមានឈ្មោល ផ្គរលាន់ឡើងក្នុងពេលណា មេកុកក៏តាំងគភ៌អស់កាលយូរ រហូត អស់ផ្គរលាន់ លុះភ្លៀងធ្លាក់ច្រើនពេលណា មេកុកទាំងឡាយក៏ផុត អំពីការពង គឺការតាំងគភ៌ក្នុងពេលនោះដែរ ។

**កុក្កុដិយោបិ**ម្យ៉ាងទៀត មេមាន់ទាំងឡាយបានឮសំឡេង មាន់ឈ្មោលរងាវក៏តាំងគភ៌ឡើង ម្យ៉ាងទៀត គោញីទាំងឡាយបានឮ សំឡេងគោឈ្មោលរោទ៍ ក៏មានការតាំងគភ៌ ដូចមេមាន់យ៉ាងនោះ ក៏មានដែរ ឈ្មោះថា មានគភ៌ដោយការស្តាប់នូវសំឡេង ។ ប្រការ មួយទៀត គោញីទាំងឡាយបានធុំក្លិនគោឧសភរាជ ជួនកាលក៏តាំងគភ៌

យ៉ាងនេះក៏មាន យ៉ាងនេះឈ្មោះថា មានគភ៌ដោយការហិតក្លិន ។

បដិសន្ធិរបស់សត្វទាំងឡាយ មានហេតុផ្សេងៗ ជាច្រើនដូច្នេះ កាលសត្វទាំងឡាយ ដែលជាគព្ភសេយ្យកសត្វនៅក្នុងគភ៌របស់មាតានោះ នឹងមិនកើតមាននូវខ្យល់ដកដង្ហើមចេញ-ចូលទេ កាលប្រសូតមក ទើបមានខ្យល់ខាងក្នុងបក់ចេញទៅមុន បន្ទាប់ពីនោះមក ខ្យល់ខាងក្រៅទើបបក់នាំយកខ្យល់ល្អិតចូលទៅខាងក្នុង **តាលុំ អាហច្ច និព្វាយតិ** កាលបើប៉ះត្រូវពិតានមាត់ចូលទៅហើយ ក៏រលត់ចុះ ។ ពាក្យទាំងនេះ អដ្ឋកថាចារ្យពោលទុកក្នុង អដ្ឋកថាព្រះវិន័យ អ្នកប្រាជ្ញគប្បីជ្រាបដោយប្រការដូច្នេះ ។

**ឯវំ កាយសំសគ្គាទិនា** សត្វទាំងឡាយចុះកាន់បដិសន្ធិក្នុងផ្ទៃ ដោយហេតុ ៦ យ៉ាង មានកាយសំសគ្គៈជាដើមយ៉ាងនេះ អាការដែលកើតក្នុងផ្ទៃនេះ ជាទីគួរឲ្យខ្ពើមរអើមក្រៃលែង ហើយក៏អប់ដោយក្លិនផ្សេងៗ ម្យ៉ាងទៀត គឺចង្អៀត មិនអាចនឹងរំកិលខ្លួនបាន អង្គុយនៅកណ្ដាលឆ្អឹងខ្នងរបស់មាតា នៅខាងក្រោមអាហារថ្មី ខាងលើអាហារចាស់ ប្រៀបដូចសត្វដង្កូវមួយ ដែលកើតនៅលើត្រី ឬវត្ថុដែលស្អុយរលួយ និងត្រង់បង្គន់ ដែលមានក្លិនស្អុយឆ្អួល **ឯវំ និព្វត្តាវ**

**មាតុបក្កាសយំ អវត្ថិត្វា អាមាសតំ ឧក្ខិបិត្វា** កាលកើតដោយប្រការដូច្នេះ ក៏រមែងអង្គុយសង្កត់នូវអាហារចាស់របស់មាតា ទូលនូវក្រពះអាហារថ្មីរបស់មាតា បែរខ្នងមករកផ្ទៃពោះរបស់មាតា បែរមុខទៅរកឆ្អឹងខ្នងរបស់មាតា **ហនុកំ ឋបេត្វា** យកដៃទាំងពីរទ្រចង្ការបស់ខ្លួន ហើយអង្គុយប្រហោង ប្រៀបដូចសត្វស្វា ចូលទៅជ្រកទឹកភ្លៀងក្នុងប្រហោងឈើ ។ កាលនៅក្នុងគភ៌មាតានោះតែងលំបាកក្តៅធំដោយភ្លើងធាតុក្នុងផ្ទៃរបស់មាតានោះ **បូដចាកំ វិយ** ប្រៀបដូចកញ្ចប់បាយដ៏ក្តៅ តែងទទួលនូវសេចក្តីទុក្ខយ៉ាងក្រៃលែង នឹងបត់ ឬសណ្តូកដៃ ជើងមិនបាន ម្យ៉ាងទៀត ពេលមាតាដើរលឿន ឬងាកឆ្វេង ស្តាំរហ័សពេកក្តី ក៏មានសេចក្តីលំបាកហួសអំពីការទ្រាំ **សុរាធុត្តហត្ថគតោ ឯឡកចោតកោ វិយ** ប្រៀបដូចកូនពពែតូចៗដែលនៅក្នុងដៃរបស់អ្នកលេងសុរា មិនដូច្នោះ ប្រៀបដូចពស់ដែលនៅក្នុងកណ្តាប់ដៃ អាយលម្ពាយ **កម្មជវាតេហិ បរិវត្តេត្វា** កាលដល់ពេលប្រសូត ខ្យល់កម្មជវាតបក់ត្រឡប់ក្បាលសំយុងចុះក្រោមជើងឡើងលើ ហើយតម្រង់ទៅតាមទ្វារដ៏ចង្អៀតគួរខ្លាចក្រៃលែង ប្រៀបដូចជារណ្តៅនរក ដ៏ជ្រៅរយជួរបុរស **អាកឌ្ឍិយមានា** កាល

*ទារកទ្ធិទាំងឡាយ ដែលធ្លុបចាប់ទាញអំពីទ្វារកំណើតដ៏ចង្អៀត ប្រៀប ដូចដំរីសាចេញមកអំពីប្រហោងរន្ទុកទ្វារ* **មាតុកុច្ឆិតោ និក្ខមន្តិ** *ចេញចាកផ្ទៃរបស់មាតាសោយនូវវេទនាដ៏ក្រៃលែង ដូចសត្វនរក ដែលចូលទៅខាងក្នុងចន្លោះភ្នំ ប៉ះទង្គិចគ្នាក៏រមែងបែកខ្ទេច* **៩ធំ បឋ ធីយកាយេន មហាបទាន សុត្តវណ្ណនាយញ្ច** *ពាក្យដែលសម្តែង មកនេះ ព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថានៃ* ***មហាបទានសូត្រ ទីឃនិកាយ ១ អដ្ឋកថាសម្បសាទនីយសូត្រ ១ ក្នុង អដ្ឋកថា វិភង្គសូត្រ ១*** *។ ពាក្យដែលព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលទុក ក្នុងអដ្ឋកថាទាំងឡាយនេះ ព្រះនន្ទាចារ្យនាំយកមករចនាជាពួកជា មួយគ្នា ក្នុង* ***គម្ពីរសារត្ថសង្គហៈ*** *នេះ ។*

*មួយទៀត ក្នុងអដ្ឋកថានៃ* ***ខគ្គវិសាណសូត្រ*** *ក្នុង* ***សុត្តនិបាត*** *នោះ* **ឧរកា អាគតានិ គត្តានិ ឧណ្ហានិ ហោន្តិ តស្មា តេ កុច្ឆិនា ធារេន្តា មាតរោ ច ឧយ្ហមានេន ឧទរេន កិច្ឆេន គព្ភំ ធារេន្តិ** *សត្វទាំងឡាយ ដែលកើតអំពីនរកនោះក្តៅខ្លាំងប្រាកដដូចជាអណ្តាត ភ្លើង* **តស្មា** *ព្រោះហេតុនោះ កាលមាតាទ្រទ្រង់គភ៌សត្វដែលមកអំពី នរក ចូលចាប់បដិសន្ធិក្នុងផ្ទៃ ធ្វើឲ្យផ្ទៃរបស់មាតានោះក្តៅ មិនមាន*

សេចក្តីសុខ ប្រកបដោយសេចក្តីទុក្ខលំបាកក្រៃលែង ។

ម្យ៉ាងទៀត ក្នុង **អដ្ឋកថាសមណមុណ្ឌិកសូត្រ** ក្នុង **មជ្ឈិមនិកាយ** សម្តែងថា **ឧបាវកុមារំ ចិត្តំ អតីតារម្មណំ ហុត្វា បវត្តតិ** ចិត្តរបស់សត្វទាំងឡាយដែលប្រសូតថ្មីៗ ជាទារកតូចខ្ចីនោះ តែងតែមានអតីតារម្មណ៍ប្រព្រឹត្តទៅជារឿយៗ ។ បើសត្វមកអំពីនរក ក៏តែងតែរឭកដល់សេចក្តីទុក្ខក្នុងនរកនោះ ជាអារម្មណ៍ហើយក៏យំ ។ បើសត្វមកអំពីទេវលោក ក៏តែងតែរឭកដល់ទិព្វសម្បត្តិ ក្នុងទេវលោក ក៏ញញឹមញញ្ញែម ។

ឯក្នុង **អដ្ឋកថាមហាតណ្ហាសង្ខយសូត្រ** ក្នុង **មជ្ឈិមនិកាយ** សម្តែងថា **យថា បន តំ មាតា ថញ្ញំ ធាយេតិ** មាតាញ៉ាំងទារកជាបុត្រនោះឲ្យបៅដោះក្នុងពេលណា ពេលនោះឈាមក្នុងបេះដូងរបស់មាតានោះ រមែងរត់ទៅដល់បុត្រ **បណ្ឌរំ ហោតិ** ទើបញ៉ាំងឈាមឲ្យក្លាយជាទឹកដោះពណ៌ស ព្រោះមានសេចក្តីស្រឡាញ់ក្នុងបុត្រនោះកើតមានដល់មាតាដ៏ខ្លាំង ទើបញ៉ាំងឈាមឲ្យក្លាយជាទឹកដោះពណ៌ស ។

ឯក្នុង **អដ្ឋកថាមហាបទានសូត្រ** ថា **សត្តមាសេ ជាតោ ន ជីវតិ សីតុណ្ហក្ខមោ បន ន ហោតិ អតិវិយ សុខុមាលតាយ**

សត្វចុះចាប់បដិសន្ធិបាន ៧ ខែ ហើយក៏ចេញចាកគភ៌របស់មាតានោះ នឹងមិនមានជីវិតរស់នៅទេ ព្រោះថា សត្វនោះមិនអាចទប់ទល់នូវភាពត្រជាក់ ឬក្តៅបាន មានកាយបសាទដ៏ល្អិតសុខុម លុះត្រាតែពេលណាសត្វចុះចាប់បដិសន្ធិបាន ៨-៩-១០-១១-១២ ខែ ទើបមានជីវិតរស់នៅបាន ។

ក្នុងដីកាអធិប្បាយថា **អដ្ឋមាសេ ជាតោ** តាមពិតសត្វចុះចាប់បដិសន្ធិបាន ៨ ខែនោះ មានការចម្រើនជាងសត្វដែលចុះចាប់បដិសន្ធិបាន ៧ ខែ **ឯកាហេន** បន្ត មួយថ្ងៃទៀត អវយវៈរបស់សត្វដែលចុះចាប់បដិសន្ធិបាន ៧ ខែនោះ **កម្មបច្ចយា** នៅជានាទីរបស់កម្មកាលបើចម្រើនឡើង ក៏នៅមិនទាន់អាចអត់ទ្រាំនូវកិរិយា ដែលប៉ះទង្គិចបាន ព្រោះយ៉ាងនោះ សត្វដែលចុះចាប់បដិសន្ធិបាន ៧ ខែនោះ ទើបមិនមានជីវិតរស់នៅ ។ រីអវយវៈទាំងឡាយរបស់សត្វដែលបដិសន្ធិបាន ៧ ខែ សូម្បីកើតហើយ ក៏នៅមិនទាន់ចម្រើនបានដែរ ។

ក្នុង អដ្ឋកថាព្រហ្មជាលសូត្រ សម្តែងថា ក្លិនកាយរបស់ទារកទាំងឡាយ ដែលចេញចាកគភ៌របស់មាតានោះ លុះត្រាតែកាលកន្លងទៅបាន ១២ ឆ្នាំ ទើបបាត់នូវក្លិននោះ ។

ប្រសិនបើពោលដោយបុត្រនោះ មាន ៣ យ៉ាង គឺអតិជាតបុត្រ ១ អនុជាតបុត្រ ១ និងអវជាតបុត្រ ១ ។

**យោ បុត្តោ** បុត្រពួកណា ប្រសើរលើសមាតាបិតា ដោយគុណវិសេសរបស់ខ្លួន មានសីលជាដើម បុត្រពួកនោះ ឈ្មោះថា **អតិជាតបុត្រ** មានគុណវិសេសក្រៃលែងជាងមាតាបិតា ។

**យោ បុត្តោ** បុត្រពួកណា មានគុណវិសេសប្រហាក់ប្រហែលមាតាបិតា ឬស្មើគ្នា បុត្រពួកនោះឈ្មោះថា **អនុជាតបុត្រ** គឺមានគុណវិសេសស្មើគ្នានឹងគុណរបស់មាតាបិតា ។

**អសមោ ហុត្វា** បុត្រពួកណា មិនបានស្មើដោយគុណវិសេសរបស់មាតាបិតា ជាមនុស្សទោបថោកជាងមាតាបិតា បុត្រពួកនោះឈ្មោះថា **អវជាតបុត្រ** ពាក្យនេះ ព្រះអដ្ឋកថាចារ្យសម្តែងទុកក្នុង **អដ្ឋកថាអង្គុត្តរនិកាយ** និង **មង្គលទីបនី** ។

ម្យ៉ាងទៀត ក្នុង **ឯកនិបាតកដ្ឋហារិកជាតក** ថា លក្ខណៈបុត្រនោះមាន ៤ ពួក គឺអត្តជៈ ១ ពួក ខេត្តជៈ ១ ពួក អន្តេវាសិក ១ ពួក ទិន្នកៈ ១ ពួក ។ បុត្របង្កើតឈ្មោះថា **អត្តជៈ** បុត្រដែលកើតក្នុងទីទាំងឡាយ មានបន្ទប់ដំណេក ទីបល្ល័ង្កជាដើម ឈ្មោះថា **ខេត្តជៈ**

បុត្រដែលមករៀន ឬសិក្សាក្នុងសម្នាក់ឈ្មោះថា **អន្តេវាសិក** បុត្រដែលគេប្រគល់ឲ្យតាំងពីតូច ឬកូនចិញ្ចឹមឈ្មោះថា **ទិន្នកៈ** ។

ក្នុង *អដ្ឋកថាវិភង្គ* ថា **មាតា ទមិឡី បិតា អន្ធកោ តេសំ ជាតទារកោ សចេ មាតុកថំ បឋមំ សុណាតិ ទមិឡភាសំ ភាសិស្សតិ** សេចក្តីថា មាតាជាស្ត្រីទមិឡ បិតាជាអ្នកអន្ធកៈ ក្មេងជាបុត្ររបស់មាតាទាំងឡាយដូច្នោះកើតមក ប្រសិនបើបានឮពាក្យសម្តីមាតា ក្មេងជាបុត្រនោះ ក៏ពោលនូវពាក្យជាភាសាទមិឡ បានឮពាក្យរបស់បិតាមុន ក៏ពោលនូវពាក្យជាអន្ធកភាសា និយាយតាមបិតាជាអ្នកអន្ធកៈ ។

ម្យ៉ាងទៀត ក្មេងជាបុត្រនោះ មិនបានឮ មិនបានស្តាប់ពាក្យមាតាបិតាទាំងពីរនាក់ដូចពោលរួចមកហើយ ក៏ពោលនូវពាក្យជាមគធភាសា គឺពោលថា **ជស្សោ វេទនា សញ្ញា** ជាដើមដូច្នោះ ហៅថា **មគធភាសា** ។

មួយទៀតសោត បុគ្គលណាកើតក្នុងព្រៃធំ មិនមែនជាភូមិស្រុក **យត្ថ អញ្ញោ** បុគ្គលដទៃក្នុងទីណា មិនបានពោលនូវពាក្យណាមួយ ទារកនោះ ក៏ញុំាងនូវពាក្យឲ្យកើតឡើង ដោយធម្មតារបស់ខ្លួនឯង

ក្នុងទីដទៃនោះ គឺនឹងពោលនូវមគធភាសា ។

ម្យ៉ាងទៀត អដ្ឋកថាមហាសុទស្សនសូត្រ ថា **លោកេ សត្តា ឆាម** ធម្មតាសត្វទាំងឡាយក្នុងលោកនេះ ក្នុងពេលខ្លួនធ្វើនូវកាលកិរិយា **អតិវិយ វិរោចន្តិ** រមែងមាននូវសេចក្តីសប្បាយរីករាយច្រើន កិរិយាដែលរីករាយនោះ **សា បេក្ខកាលកិរិយា** មួយទៀតសោត ពេលធ្វើកាលកិរិយានោះ បើចិត្តជាប់ជំពាក់នូវវត្ថុណាទីមួយក្នុងផ្ទះរបស់ខ្លួន ដោយអំណាចដែលហួងហែងទ្រព្យសម្បត្តិទាំងពួងហើយ កាលកិរិយានោះ ក៏ជាហេតុឲ្យកើតជាយក្ខ សុនខ ចៀម ពពែ គោ ក្របី កណ្តុរ សង្កើច ស្រមោចជាដើមក្នុងផ្ទះរបស់ខ្លួន កិរិយាដែលមនុស្សទាំងឡាយ ធ្វើកាលកិរិយាក្នុងទីណាមួយ ទៅកើតក្នុងទីជិត ឬទីឆ្ងាយ ក៏កើតព្រមគ្នាក្នុងខណៈតែមួយ **ឯវំ ឧប្បជ្ជ-មានោ បន** កាលបើសត្វកើតព្រមគ្នា ក្នុងខណៈតែមួយដូច្នេះ នឹងថាជាសត្វនោះទៅកើតក៏ថាមិនបាន **ឆ ច អញ្ញោ ឆិព្វត្តតិ** នឹងថាជាសត្វដទៃមកចាប់បដិសន្ធិក៏ថាមិនបាន ប្រការមួយទៀតសោតរីអាយតនៈទាំងឡាយ ៥ មានចក្ខាយតនៈជាដើមរបស់សត្វទាំង-ឡាយដែលបដិសន្ធិឡើងនោះ ក៏កើតដោយកម្មទាំងឡាយផ្សេងៗ ជា

ដើម សេចក្តីនេះ ព្រះបាទមិលិន្ទត្រាស់សួរព្រះនាគសេនៗ បាន ថ្វាយចម្លើយយ៉ាងពិស្តារទូលំទូលាយ ប្រកបដោយសេចក្តីឧបមា ផ្សេងៗ **វុត្តំ ហិ តត្ថ** សមដូចពាក្យរបស់លោកអាចារ្យបានសម្តែង ក្នុងមិលិន្ទប្បញ្ហាថា ព្រះបាទមិលិន្ទត្រាស់សួរថា **ភន្តេ នាគសេន** បពិត្រព្រះនាគសេនដ៏ចម្រើន បុគ្គលម្នាក់ ស្លាប់អំពីមនុស្សលោក នេះ ទៅកើតក្នុងព្រហ្មលោក បុគ្គលម្នាក់ទៀត ស្លាប់អំពីមនុស្ស លោកនេះកើតនៅក្នុងមនុស្សលោកនេះឯង បុគ្គលពីរពួកនេះ អ្នក ណាលឿនជាងគ្នា ?

ព្រះនាគសេនថ្វាយចម្លើយថា **មហារាជ** សូមថ្វាយព្រះពរ មហាបពិត្រ បុគ្គលពីរពួកនេះទៅកើតស្មើគ្នា មិនលឿន មិនរហ័ស ជាងគ្នាឡើយ ។

**ឧបមំ ករោហិ** ព្រះបាទមិលិន្ទត្រាស់ថា លោកម្ចាស់ ឆ្លើយដូច្នេះ ខ្ញុំព្រះករុណានៅមិនទាន់យល់ច្បាស់ សូមលោកម្ចាស់ លើកយកនូវសេចក្តីឧបមាឲ្យខ្ញុំព្រះករុណាយល់ច្បាស់សិន ។

ព្រះនាគសេនថ្វាយនូវចម្លើយថា បពិត្រមហារាជ អាត្មាសូម សួរទីកើតរបស់មហាបពិត្រកើតក្នុងទីណា ? ព្រះបាទមិលិន្ទត្រាស់ថា

ខ្ញុំព្រះករុណាកើតក្នុងប្រទេសកលសិគ្រាម ។ ព្រះនាគសេនបានសួរថា ស្រុកកលសិគ្រាមអំពីនេះទៅចម្ងាយប្រមាណប៉ុន្មាន ? ព្រះបាទមិលិន្ទឆ្លើយថា បពិត្រលោកម្ចាស់ អំពីនេះទៅចម្ងាយប្រមាណ ២០០ យោជន៍ ។ **កីវទូរេ ឥតោ កស្មិរំ** ព្រះនាគសេនសួរអំពីទីនោះទៅដល់ក្រុងកស្មិរ ចម្ងាយប្រមាណប៉ុន្មាន ? ព្រះបាទមិលិន្ទឆ្លើយថា បពិត្រលោកម្ចាស់ អំពីនេះទៅដល់ក្រុងកស្មិរឆ្ងាយពីគ្នាប្រមាណ ១២ យោជន៍ ។ **ឥង្ឃំ ត្វំ មហារាជ** សូមថ្វាយព្រះពរមហារាជ ដូច្នេះអាត្មាសូមជាស់តឿនព្រះអង្គ សូមព្រះអង្គគិតដល់ស្រុកកលសិគ្រាមមើលសិនចុះ ។ ព្រះបាទមិលិន្ទតបថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាគិតដល់ស្រុកកលសិគ្រាមហើយ ។ ព្រះនាគសេនប្រាប់ថា **មហារាជ** សូមថ្វាយព្រះពរមហាបពិត្រ សូមព្រះអង្គគិតដល់កស្មិរមើលចុះ ។ ព្រះបាទមិលិន្ទតបថា ខ្ញុំព្រះករុណាគិតហើយលោកម្ចាស់ ។ **កីន្នុខោ ចិរតរំ** ព្រះនាគសេនសួរថា សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គគិតដល់កលសិគ្រាម និងទ្រង់គិតដល់កស្មិរប្រទេសនោះ មានរយៈចម្ងាយ ២០០ យោជន៍ខ្លះ ១២ យោជន៍ខ្លះ តើគិតខាងណាលឿនជាង ។ ព្រះបាទមិលិន្ទតបថា បពិត្រលោកម្ចាស់ សូម្បីគិត

ចម្ងាយដល់ទៅ ២០០ យោជន៍ខ្លះ ១២ យោជន៍ខ្លះ ក៏គិតទៅលឿនស្មើគ្នា ។ **ឯវមេវ ខោ មហារាជ** ព្រះនាគសេនថ្លើយថា សូមថ្វាយព្រះពរមហាបពិត្រ ព្រះអង្គគិតដល់កលសិគ្រាម និងទ្រង់គិតដល់ កស្មិរគ្រាមនោះ ក៏គិតទៅលឿនស្មើគ្នាក្នុងពេលតែមួយ នឹងមិនបានលឿនជាងគ្នាទេ យ៉ាងណាមិញ សត្វដែលបដិសន្ធិក្នុងព្រហ្មលោក និងសត្វដែលបដិសន្ធិក្នុងកស្មិរប្រទេស ( ក្នុងមនុស្សលោកនេះ ) កើតព្រមគ្នា ស្មើគ្នាក្នុងពេលតែមួយ មិនបានលឿនជាងគ្នា ក៏មានឧបមេយ្យដូច្នោះឯង ។ **កល្លោសិ** ព្រះបាទមិលិន្ទទ្រង់ជ្រាបនូវន័យប្រស្នា ទើបត្រាស់ថា លោកម្ចាស់មានថេរវាចាពីរោះប្រពៃហើយ គួរនឹងជឿចូលចិត្តស្តាប់បាន ។

ទើបត្រាស់សួរថា **ភន្តេ នាគសេន** បពិត្រលោកម្ចាស់នាគសេន **យោ ឧប្បជ្ជតិ** សត្វណាកើតឡើងនោះ នឹងជាបុគ្គលទៀតឬ ? **ឧទាហុ** ឬថា បុគ្គលដទៃបដិសន្ធិឡើង ដូចម្តេច ?

**មហារាជ ន ច សោ ន ច អញ្ញោ** សូមថ្វាយព្រះពរ បុគ្គលដែលមកបដិសន្ធិនោះ នឹងជាអ្នកធ្វើកាលកិរិយាទៅកើតក៏មិនមែន នឹងជាបុគ្គលដទៃមកបដិសន្ធិក៏មិនមែន ។

ទើបព្រះបាទមិលិន្ទត្រាស់សួរថា **ឧបមំ ករោហិ** និមន្ត លោកម្ចាស់ឧបមាឲ្យញោមបានយល់មើល៍ !

ទើបព្រះនាគសេនត្ថេរ ថ្វាយវិសជ្ជនាថា **យថា មហារាជ ខីរំ ទយ្ហមានំ** សូមថ្វាយព្រះពរ បពិត្រព្រះរាជសម្ភារ កាល បុគ្គលរឹតនូវទឹកដោះគោហើយ ទឹកដោះស្រុះនោះគង់នឹងប្រែទៅជាទធិ ដោយពិត កាលកន្លងទៅក៏ប្រែជាជូរ **មហារាជ** សូមថ្វាយព្រះពរ ព្រះរាជសម្ភារ ទឹកដោះនោះឬ គឺទធិ ទធិនោះឬ គឺនវនីត នវនីត នោះឬ គឺតក្កៈ **ន ហិ ភន្តេ** បពិត្រលោកម្ចាស់ នឹងពោលដូច្នោះ មិនបាន ចំណែកទធិ ក៏គឺទធិ នវនីត ក៏គឺនវនីត តក្កៈ ក៏គឺតក្កៈ របស់ទាំង ៣ យ៉ាងនេះកើតក៏អាស្រ័យទឹកដោះគោនោះតែម្យ៉ាង នឹងថាជាវត្ថុដទៃៗ នោះ ថាមិនបាន **ឯវមេវ ខោ មហារាជ** សូម ថ្វាយព្រះពរមហាបពិត្រ សេចក្តីនេះ យ៉ាងណា **ធម្មសន្តតិ** អាការ បន្តនៃធម៌ក៏កើតឡើង តាំងឡើងតទៅបដិសន្ធិ ក៏មានឧបមេយ្យយ៉ាង នោះ **អញ្ញោ ឧប្បជ្ជតិ អញ្ញោ និរុជ្ឈតិ** សត្វដទៃកើតឡើង សត្វដទៃក៏រលត់ បដិសន្ធិក៏តាំងឡើងព្រមគ្នា **ន ច សោ ន ច អញ្ញោ** នឹងពោលថា សត្វនោះ ក៏ពោលមិនបាន នឹងពោលថាសត្វ

ដទៃ ក៏ថាមិនបាន តែថាដល់នូវការសង្គ្រោះយកនូវបច្ឆិមវិញ្ញាណខាងក្រោយ និងជាធម៌សន្តតិ គឺការបន្តនៃធម៌ដោយប្រការដូច្នេះ ។

ទើបព្រះមហាក្សត្រ ត្រាស់សួរថា **ភន្តេ នាគសេន** បពិត្រលោកម្ចាស់នាគសេន **បញ្ចាយតនានិ** អាយតនៈទាំង ៥ គឺចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ កើតដោយកម្មផ្សេងៗ ឬកើតដោយកម្មតែម្យ៉ាង ?

**នានាកម្មេហិ មហារាជ និព្វត្តា** សូមថ្វាយព្រះពរមហារាជ អាយតនៈទាំង ៥ នោះ កើតឡើងដោយកម្មផ្សេងៗ នឹងបានកើតដោយកម្មតែម្យ៉ាងនោះមិនមែន ប្រៀបដូចពូជ ៥ យ៉ាង ដែលបុគ្គលព្រោះក្នុងស្រែមួយ ផលនៃពូជ ៥ យ៉ាងនោះ ក៏ផ្សេងគ្នា ៥ យ៉ាង យ៉ាងណា **ឯវមេវ ខោ មហារាជ** សូមថ្វាយព្រះពរមហាបពិត្រ អាយតនៈទាំង ៥ ប្រការនោះ រមែងកើតដោយកម្មផ្សេងៗ ដូច្នោះ **កល្លោសិ ភន្តេ នាគសេន** បពិត្រលោកម្ចាស់នាគសេន លោកម្ចាស់បានឆ្លើយបញ្ហានេះពីរោះណាស់ សមជាវិសុទ្ធិសង្ឃអង្គអរហន្តដ៏ប្រសើរ ។ សេចក្តីក្នុងមិលិន្ទបញ្ហា មានប្រមាណតែប៉ុណ្ណេះ ។

សត្វទាំងឡាយធ្វើនូវកម្មនោះ រមែងប្រព្រឹត្តទៅតាមកុស-លាកុសលកម្មរបស់ខ្លួន **បរិវត្តន្តិ** ក៏រមែងត្រាច់វិលទៅមកនៅក្នុងគតិទាំង ៥ គឺនិរយគតិ តិរច្ឆានគតិ បេតគតិ មនុស្សគតិ ទេវគតិ រមែងអន្ទោលកើតស្លាប់ ក្នុងវាលវដ្តសង្សារគ្មានឈប់ **យន្តពន្ធ-គោណា វិយ** ប្រៀបដូចគោដែលបុគ្គលចងក្នុងខ្សែយន្តឃ្នាបដូច្នោះ ដោយការព្រមព្រៀងយ៉ាងណា **សា សមង្គី** រីការព្រមព្រៀងនោះ **បញ្ចវិធា** មាន៥ប្រការគឺអាយូហនសមង្គី ១ ចេតនាសមង្គី ១ កម្ម-សមង្គី ១ វិបាកសមង្គី ១ ឧបដ្ឋានសមង្គី ១ ។ សមង្គីទាំង ៥ ប្រការនោះ **អាយូហនសមង្គី** គឺខណៈដែលបុគ្គលបានធ្វើនូវកុស-លាកុសល ។ ប្រសិនបើបុគ្គលធ្វើនូវកុសលកម្ម មានការវៀរចាកបាណាតិបាតជាដើម ឬធ្វើនូវអកុសលកម្ម មានបាណាតិបាតជាដើម ក៏បានឈ្មោះថា អាយូហនសមង្គីក្នុងខណៈធ្វើនូវកម្មនោះ ។

ចេតនាសមង្គី បានដល់ លក្ខណៈបុគ្គលជាបុថុជ្ជនទាំង-ឡាយ ដែលនៅប្រកបដោយចេតនាផ្សេងៗ **យាវ បន អរហត្តំ ន បាបុណន្តិ** សត្វទាំងឡាយមិនទាន់បានសម្រេចដល់អរហត្តផលដរាបណា ព្រះពុទ្ធអង្គត្រាស់ថា នៅមានចេតនាសមង្គីដរាបនោះ ។

**សព្វេបិ សត្តា បុព្វេបិ ឧបចិតំ វិចាការហំ កម្មំ សន្ធាយ**
សព្វសត្វទាំងនោះ ព្រះសម្ពុទ្ធអាស្រ័យនូវកម្មដែលសមគួរដល់ផល ដែលបុគ្គលបានសន្សំមកអំពីអតីតកព ព្រះលោកនាថត្រាស់ថា ជាកម្មសមង្គី ក៏កម្មសមង្គីនោះ អ្នកប្រាជ្ញគប្បីជ្រាបថា បានដល់សព្វសត្វផ្សេងៗ នោះឯង ។

វិបាកសមង្គីនោះសោត អ្នកប្រាជ្ញគប្បីជ្រាបថា ក្នុងខណៈកើតផល សត្វទាំងឡាយមិនទាន់បានសម្រេចអរហត្តដរាបណា ក៏គង់នឹងកើតមានវិបាកសមង្គីដរាបនោះ គឺនឹងបានឃ្លៀងឃ្លាត ផុតចាកផលរបស់កម្មនោះមិនមាន ។

**នេសំ តតោ តតោ ចវិត្វា និរយេ តាវ ឧប្បជ្ជមានានំ**
ក្នុងលក្ខណៈរបស់ឧបដ្ឋានសមង្គីនេះ បានដល់ ឧបបត្តិនិមិត្ត ហេតុដែលនឹងកើតនោះ កើតប្រាកដដល់ខ្លួនដូច្នេះ បើសត្វទាំងឡាយចុតិចាកទីនោះ នឹងកើតក្នុងនរកក្តី ចុតិចាកនរកហើយ នឹងកើតក្នុងនរកនោះក្តី ក៏រមែងមាននិមិត្តកើតប្រាកដដល់ខ្លួន មានអណ្តាតភ្លើងនរកមកប្រាកដជាដើម ។ បើសត្វនឹងកើតក្នុងស្ថានសួគ៌ និមិត្តដែលជាទេវលោកក៏មកប្រាកដ ។ បើសត្វនឹងមកនៅក្នុងគភ៌មាតា និមិត្ត

*ក៏មកកើតប្រាកដ ។ បើនឹងទៅកើតក្នុងទេវលោក ដើមកប្បព្រឹក្ស ឬទិព្វវិមានជាដើម អណ្តែតត្រសែតមកប្រាកដដល់ខ្លួន* **អបរិមុត្តតា** *ឯភាវៈរបស់សត្វទាំងឡាយនោះ មិនបានរួចផុតពីនិមិត្តទាំងឡាយ ដែលជាហេតុ គឺនឹងឲ្យកើត ។ អ្នកប្រាជ្ញគប្បីជ្រាបថា ឧបដ្ឋានសមង្គី ដោយប្រការដូច្នេះ* **សា ពលវតី** *ឧបដ្ឋានសមង្គីនោះមានកម្លាំងខ្លាំងក្លាជាងសមង្គីទាំងឡាយ* **សេសាសមង្គិតា** *ឯសភាវៈសមង្គីដ៏សេសនោះ គ្មានកម្លាំងខ្លាំងក្លាដូចឧបដ្ឋានសមង្គីទេ ឯសមង្គីដ៏សេសនឹងទុព្វលភាព មានកម្លាំងតិចតួច ។ សេចក្តីនេះ សមដូចពាក្យថា* **និរយេ ហិ ឧបដ្ឋិតេបិ ទេវលោកោ ឧប្បដ្ឋាតិ ទេវលោកេឧប្បដ្ឋិតេបិ និរយោ ឧបដ្ឋាតិ មនុស្សលោកេ ឧប្បដ្ឋិតេបិ តិរច្ឆានយោនិ ឧបដ្ឋាតិ តិរច្ឆានយោនិយា ឧប្បដ្ឋិតាយបិ មនុស្សលោកោ ឧបដ្ឋាតិយេវ** *សេចក្តីថា ការពិត សត្វទាំងឡាយកាលបើធ្វើកាលកិរិយា រមែងមានគតិនិមិត្ត កើតប្រាកដផ្សេងៗ ជំពូងនិមិត្តផ្នែកខាងនរកមកកើតមុន រួចហើយ និមិត្តសួគ៌ទេវលោកមកប្រាកដជាខាងក្រោយ ជួនកាលនិមិត្តផ្នែកខាងសួគ៌ទេវលោកមកកើតមុន រួចហើយនិមិត្តផ្នែកខាងនរកក៏មកកើតប្រាកដជាខាងក្រោយ*

ជួនកាលនិមិត្តផ្នែកខាងមនុស្សលោកមកកើតប្រាកដមុន រួចហើយនិមិត្តផ្នែកខាងតិរច្ឆានមកកើតប្រាកដជាខាងក្រោយ ជួនកាលនិមិត្តផ្នែកខាងតិរច្ឆានមកកើតប្រាកដមុន រួចហើយនិមិត្តផ្នែកខាងមនុស្សលោក ទើបមកកើតប្រាកដជាខាងក្រោយយ៉ាងនេះ ក៏មានដែរ ។

**តត្រិទំ វត្ថុ** នឹងនាំយកនិទានដែលជានិមិត្តផ្នែកខាងនរកមកកើតប្រាកដមុននោះឲ្យឃើញ សេចក្ដីថា **កិរ ឯកោ ធម្មកថិកោ** បានឮមកថា មានភិក្ខុអ្នកសម្ដែងព្រះធម៌ដ៏វិសេសមួយរូប ឈ្មោះថា **សោណត្ថេរ** មានបញ្ញាក្លៀវក្លាជំនាញក្នុងបរមត្ថ ។ ព្រះថេរៈមានប្រក្រតីគង់នៅក្នុងបព្វលិវិហារ ក្បែរជើងភ្នំឈ្មោះសោណគិរី ។ បិតារបស់សោណត្ថេរនោះជាព្រានសុនខ **តំ បដិពាហន្តោ** ព្រះសោណៈហាមបិតា តែក៏មិនអាចញ៉ាំងបិតាឲ្យតាំងនៅក្នុងសីលបាន **មហល្ល–កកាលេ** កាលបើបិតានោះជរាភាព ក៏មានសេចក្ដីករុណាដល់បិតាថា បិតាជាមនុស្សកំព្រា សូមកុំវិនាសចាកគុណជាតិជាកុសល **អកាមកំ បព្វាជេសិ** ទើបញ៉ាំងបិតាជាមនុស្សមិនប្រាថ្នា ដើម្បីនឹងបួសនោះឲ្យបួសជាសាមណេរ កាលបួសជាសាមណេរហើយ ក៏ដេកឈឺនៅលើគ្រែ ។ គ្រានោះ គតិនិមិត្តផ្នែកខាងនរកមកកើតប្រាកដមុន គឺ

ឲ្យឃើញមានឆ្កែធំៗ រត់ចេញមកពីជើងភ្នំជុំវិញខ្លួន ហាក់បីដូចខាំស៊ីខ្លួនជាអាហារ ។ សាមណេរចាស់នោះ ភ័យខ្លាច តក់ស្លុត ស្រែកហៅឲ្យព្រះសោណត្ថេរ ដែលជាបុត្រជួយដេញឆ្កែ ។ ទើបព្រះថេរៈសួរថា បពិត្របិតា តើលោកឃើញនូវហេតុដូចម្តេច ? បិតាក៏ប្រាប់នូវហេតុនោះឲ្យច្បាស់គ្រប់ប្រការថា ខ្ញុំព្រះករុណាឃើញហ្វូងឆ្កែវារត់មកជាច្រើន គិតនឹងខាំស៊ីខ្ញុំព្រះករុណា ។ ទើបព្រះសោណៈដែលត្រូវជាបុត្រគិតថា បិតារបស់កិក្ខុដូចអាត្មាអញនេះ នឹងបណ្តាយឲ្យទៅកើតក្នុងនរកឬ អាត្មាអញមិនត្រូវឲ្យបិតាទៅកើតក្នុងនរកទេ **បតិដ្ឋា អស្ស ភវិស្សាមិ** អាត្មាអញនឹងជួយដល់បិតាក្នុងគ្រានេះ ទើបញុំាងឲ្យសាមណេរ ទាំងឡាយបេះផ្កាផ្សេងៗយ៉ាងច្រើន ធ្វើនូវគ្រឿងកម្រាលដោយផ្កាឈើ ធ្វើសក្ការបូជា និងអាសនៈបូជាក្នុងទីលានព្រះចេតិយព្រះស្រីមហាពោធិ៍ ទើបឲ្យមនុស្សលើកបិតាដាក់លើគ្រែ រួចហើយក៏សែងទៅកាន់លានព្រះចេតិយ លុះដល់ហើយ ក៏ឲ្យអង្គុយរំលឹកជាស់តឿនថា សូមបិតាពោលនូវពាក្យថា **ភគវា** បពិត្រព្រះមានព្រះភាគ **អយំ មហាថេរប្ជា** គ្រឿងសក្ការបូជានេះ ខ្ញុំព្រះអង្គដែលជាមហាថេរៈ ធ្វើការតាក់តែងដើម្បីជាប្រយោជន៍ចំពោះព្រះអង្គ គ្រឿងសក្ការ

បូជាដែលជាទុគ្គតបណ្ណាការ ( បណ្ណាការរបស់អ្នកក្រីក្រ ) នេះ គឺជារបស់ខ្ញុំព្រះអង្គ តាក់តែងមកធ្វើសក្ការបូជាចំពោះព្រះអង្គ បិតាចេញវាចាដូច្នេះហើយ សូមនមស្ការព្រះពុទ្ធ ទើបញ៉ាំងទឹកចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ។ សាមណេរចាស់ក្រឡេកមើលឃើញ គ្រឿងសក្ការបូជាផ្កាឈើ ហើយក៏ធ្វើតាមពាក្យព្រះសោណត្ថេរ ដែលត្រូវជាបុត្រក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា ខណៈនោះ និមិត្តផ្នែកខាងសួគ៌ទេវលោក ក៏កើតដល់សាមណេរចាស់នោះ គឺទិព្វវិមាន នន្ទវ័ន និងបារុសក្កវ័នទាំងនាងទេពអប្សរក៏មកប្រាកដ ហាក់បីដូចជានៅចោមរោមព័ទ្ធជុំវិញ ។ ខណៈនោះ សាមណេរចាស់ ក៏ដេញព្រះសោណត្ថេរឲ្យចេញទៅថា បពិត្រព្រះសោណៈ សូមលោកថយចេញទៅ ។ ទើបព្រះសោណៈសួរថា បិតាឃើញហេតុអ្វីឬ ទើបដេញខ្ញុំព្រះករុណាឲ្យចេញទៅដូច្នេះ ? ទើបសាមណេរចាស់ប្រាប់ថា ទេពអប្សរទាំងឡាយជាមាតារបស់លោកមកមកចោមរោម សូមលោកចេញទៅចុះ ។ ព្រះសោណត្ថេរជ្រាបច្បាស់ថា និមិត្តផ្នែកខាងស្ថានសួគ៌មកប្រាកដដល់សាមណេរ ចាស់ដែលត្រូវជាបិតារបស់អាត្មាអញហើយ ។ ឧបដ្ឋានសមន្តី និមិត្តមានកម្លាំងខ្លាំងក្លា ដូច្នេះ ។ ពាក្យទាំងនោះព្រះ

អដ្ឋកថាចារ្យបានវិសជ្ជនានៅក្នុង អដ្ឋកថាវិភង្គ និង អដ្ឋកថាពហុធាតុកសូត្រ ក្នុងមជ្ឈិមនិកាយ ។

**ឯវំ ឧប្បជ្ជមានានំ បដិសន្ធិយា អារម្មណានិ ហោន្តិ** អារម្មណ៍របស់បដិសន្ធិចិត្តនៃសត្វទាំងឡាយ កើតដោយប្រការដូច្នេះ ចាត់ជា ៣ យ៉ាង ហៅថា កម្មារម្មណ៍ម្យ៉ាង គតិនិមិត្តារម្មណ៍ម្យ៉ាង កម្មនិមិត្តារម្មណ៍ម្យ៉ាង **អាយូហិតកុសលាកុសលកម្ម-ចេតនា** ចេតនាដែលជាកុសលកម្ម និងជាអកុសលកម្ម ដែលបុគ្គលធ្វើអំពីជាតិមុននោះ អ្នកប្រាជ្ញគប្បីជ្រាបថា ឈ្មោះថា **កម្មារម្មណ៍** បើជាផ្នែកខាងកុសល ក៏ឲ្យអ្នកជិតនឹងស្លាប់នោះសុខសប្បាយ មិនមានសេចក្តីក្រវល់ក្រវាយ បើជាផ្នែកខាងអកុសលវិញ ក៏ឲ្យកើតក្តៅអន្ទះអន្ទែង និមិត្តផ្នែកខាង អបាយប្រាកដឡើង **កម្មនិមិត្តំ នាម** បុគ្គលធ្វើនូវវត្ថុណាជាអាម្មណ៍ ហើយនឹងធ្វើនូវកម្មនោះ ឈ្មោះថា **កម្មនិមិត្តារម្មណ៍** ។ បើជាផ្នែកខាងកុសល ដូចជាឃើញសណ្តែកល្ង នំចំណី បិណ្ឌបាតជាដើម ឬឃើញដូចជាផ្កា គ្រឿងសក្ការបូជាមកប្រាកដ ជានិមិត្តឲ្យឃើញនៅក្នុងដួងចិត្ត ក្នុងពេលជិតនឹងធ្វើនូវកាលកិរិយា ។ បើជាផ្នែកអកុសល ដូចជាឃើញជងសន្ទូច ជង់

អន្ទាក់ជាដើមមកប្រាកដជាកម្មនិមិត្តារម្មណ៍ ឲ្យចិត្តតោងយកនូវវត្ថុដែលប្រាកដនោះ ។

**គតិនិមិត្តំ នាម និព្វត្តនកឱកាសេ ឯកោ វណ្ណោ ឧបដ្ឋាតិ** ម្យ៉ាងទៀត កើតប្រាកដជានិមិត្តក្នុងទីដែលនឹងកើតរបស់បុគ្គលហើយ ក៏ឈ្មោះថា គតិនិមិត្តារម្មណ៍ ដូចជាឃើញអណ្តាតភ្លើង លោហកុម្ភី សួគ៌ទេវលោកផ្សេងៗ ជាដើមនោះ កាលបើគតិនិមិត្តផ្នែកនរកកើតប្រាកដ ក៏កើតប្រាកដដូចជាឃើញលោហកុម្ភី កាលបើគតិនិមិត្តផ្នែក ខាងមនុស្សមកចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតា **កម្ពលយានសទិសា ហុត្វា ឧបដ្ឋាតិ** ក៏អាការដែលនិមិត្តមកប្រាកដដូចជាឃើញកម្ពលយាន ដែលរុំដោយសំពត់ក្រហម បើគតិនិមិត្តផ្នែកខាងសួគ៌ទេវលោកនោះមកកើតប្រាកដ ដូចជាឃើញដើមកប្បព្រឹក្ស វិមាន និងសិរីសេយ្យាសនៈដ៏ប្រសើរ ជាវិការនៃកែវ និងមាស មានប្រការផ្សេងៗ ជាដើម **ឥមេសុ តីសុ អារម្មណេសុ** បណ្តានិមិត្តទាំងឡាយ ៣ ដែលជាអារម្មណ៍នេះ និមិត្តណាមួយគង់នឹងកើតដោយពិត សូម្បីក្នុងកាលដែលសត្វទាំងឡាយ ធ្វើកាលកិរិយាប្រកបដោយមោហៈនោះ ។ ការពិតសត្វទាំងឡាយ ដែលធ្វើនូវ

កាលកិរិយា ប្រកបដោយមោហៈនោះ មាន ៣ ពួក គឺបុគ្គលកាត់នូវក្បាលដោយដាវដ៏មុតពីខាងក្រោយនៃបុគ្គលដែលដើរ ទៅនៅពីខាងមុខ ១ សម្លាប់ដោយថ្នាំពិស ឬកាប់ដោយដាវដ៏មុត ចំពោះបុគ្គលដែលដេកលក់ស៊ប់ ១ បុគ្គលទាំងឡាយញុំាងបុគ្គលឲ្យលិចចូលក្នុងទឹក រួចហើយក៏សម្លាប់ ១ បុគ្គលស្លាប់ដោយសេចក្តីព្យាយាមរបស់បុគ្គលដទៃទាំង ៣ យ៉ាងនេះ ចាត់ជាការធ្វើនូវកាលកិរិយាប្រកបដោយមោហៈទាំង ៣ គឺកម្ម កម្មនិមិត្ត និងគតិនិមិត្ត និមិត្តណានីមួយគង់តែនឹងកើតប្រាកដ ក្នុងពេលធ្វើនូវកាលកិរិយាដែលប្រកបដោយមោហៈបែបនេះ ដោយពិត **អញ្ញំ លហុកំ មរណំ ឆាម ឧត្តិ** កិរិយាដែលធ្វើនូវកាលកិរិយាយ៉ាងដទៃនោះ នៅមានទៀត គឺបុគ្គលទាំងឡាយប្រហារសត្វរុយដែលទំនៅលើដងពន្លាក ដោយអន្ទង់ដូច្នេះ ក៏គង់មានកម្ម កម្មនិមិត្ត និងគតិនិមិត្តណាមួយកើតប្រាកដជាអារម្មណ៍មុន ទើបសត្វរុយស្លាប់ ។ ក្នុងពេលសត្វរុយស្លាប់ដោយអន្ទង់ដូច្នេះ កាយទ្វារាវជ្ជនចិត្តនឹងបានពិចារណានូវភវង្គមុន ។ ក្នុងលំដាប់នោះ ទើបជវនចិត្តកើត ៧ ខណៈ សោយនូវអារម្មណ៍ រួចហើយ ធ្លាក់ចុះកាន់ភវង្គយ៉ាងនេះជាវិថី ១ ក្នុងទុតិយវារៈ ជាគម្រប់

ពីរនោះ ទើបកាយទ្វារាវជ្ជនចិត្តកើតពិចារណានូវភវង្គ កាលបើដាច់ចាកភវង្គ ទើបជាកាយទ្វារាវជ្ជនចិត្ត ឡើងសោយនូវអារម្មណ៍ ហើយក្នុងលំដាប់នោះ វិថីជវនចិត្ត កាយវិញ្ញាណ សម្បដិច្ឆន្នៈ សន្តីរណៈ វោដ្ឋព្វនៈ កើតឡើងជាលំដាប់គ្នា ទើបជវនចិត្តកើត ៥ ខណៈ សោយនូវអារម្មណ៍ ហើយធ្លាក់ចុះកាន់ភវង្គសាជាថ្មី ។ ក្នុងលំដាប់នោះ ទើបដល់តតិយទ្វារ ក្នុងតតិយទ្វារនោះ មនោទ្វារាវជ្ជនចិត្តកើតពិចារណានូវភវង្គ រូបហើយក៏រលត់ទៅ ។ក្នុងកាលនោះ ទើបជវនចិត្តកើតឡើង ៤ ខណៈ សោយនូវអារម្មណ៍ រូបហើយ ក៏ធ្លាក់ចុះកាន់ភវង្គ ក្នុងទីបំផុតនៃការធ្លាក់ចុះកាន់ភវង្គនោះ ទើបសត្វរុយស្លាប់ ។

**ឥធំ វចនំ កិមត្ថំ** ពាក្យនេះ ព្រះអដ្ឋកថាចារ្យពោលដើម្បីជាប្រយោជន៍ដូចម្ដេច ពាក្យនេះព្រះអដ្ឋកថាចារ្យពោលទុកក្នុង **អដ្ឋកថាបដិច្ចសមុប្បាទវិភង្គ** ក្នុង **គម្ពីរវិភង្គ** ដើម្បីញ៉ាំងកុលបុត្រឲ្យដឹងខ្លឹមសារក្នុងបរមត្ថដូច្នេះថា ឈ្មោះថា វិស័យរបស់អរូបធម៌ទាំងឡាយ គឺចិត្ត និងចេតសិក រមែងប្រព្រឹត្តទៅរហ័ស ដោយប្រការដូច្នេះ ដូចជាសត្វរុយដែលទំលើដុំដែកបណ្ដាសត្វដែលបុគ្គលប្រហារដោយញញួរ វិថីចិត្តកើតដល់ ៣ វិថី ទើបសត្វរុយស្លាប់ដោយ

ពិត លោកពោលដើម្បីឲ្យដឹងច្បាស់ដូច្នេះ ។

អាយុរបស់សត្វទាំងឡាយ រមែងប្រព្រឹត្តទៅរហ័ស និងកំណត់ថ្ងៃស្លាប់នោះ កំណត់ដឹងបានដោយលំបាក និងមិនដឹងពេលស្លាប់នោះទេ ។មួយទៀត មិនបានដឹងកំណត់នោះច្រើន ឬតិចឡើយ **សម្មា-សម្ពុទ្ធេន អបរិច្ឆិន្នំ** អាយុសត្វទាំងឡាយ ក្នុងអបាយភូមិទាំង ៤ ឬក្នុងភុម្មទេវតាទាំងឡាយ ព្រះសម្មាសម្ពុទ្ធក៏មិនអាចកំណត់ដឹងច្រើន ឬតិចប៉ុណ្ណេះប៉ុណ្ណោះបានដែរ **តំ តស្មា** ព្រោះហេតុអ្វី បានជាព្រះសម្មាសម្ពុទ្ធមិនអាចកំណត់នូវអាយុ របស់សត្វទាំងឡាយដូច្នោះបាន អធិប្បាយនូវអាយុរបស់សត្វក្នុងនរកនោះសិន **កម្មមេវ** កម្មមួយជាប្រមាណ **យាវ កម្មំ ន ខីយតិ** ប្រសិនបើកម្មនៅមិនទាន់អស់កំណត់កាលប៉ុនណា សត្វទាំងឡាយនៅក្នុងនរក ក៏រងទុក្ខវេទនានៅក្នុងនរកកំណត់កាលប៉ុណ្ណោះ ម្យ៉ាងទៀតសោត សត្វទាំងឡាយក្នុងអបាយភូមិដ៏សេស គឺសត្វតិរច្ឆាន និងអសុរកាយទាំងឡាយ ក៏មានកម្មជាប្រមាណដូចនរក **ភុម្មទេវានម្បិ** មួយទៀត ភុម្មទេវតាទាំងឡាយក្តី ក៏មានកម្មមួយជាអាយុប្បមាណា អធិប្បាយថា សត្វទាំងឡាយដែលកើតជាភុម្មទេវតានោះ តាំងនៅ ៧ ថ្ងៃក៏មាន តាំងនៅប្រមាណ

កន្លះខែក៏មាន **កោចិ មាសំ** សត្វខ្លះតាំងនៅមួយខែក៏មាន **កប្បំ តិដ្ឋមានាបិ អត្ថិយេវ** សត្វទាំងឡាយដែលកើតជាកុម្មទេវតានោះពួកខ្លះតាំងនៅប្រមាណមួយកប្បក៏មាន ។ ការពិត ពាក្យទាំងនេះព្រះអដ្ឋកថាចារ្យពោលនៅក្នុង **អដ្ឋកថាធម្មហទយវិភង្គ** ក្នុង គម្ពីរវិភង្គ ។

ក្នុង អដ្ឋកថាអង្គុត្តរនិកាយ សម្តែងថា **មនុស្សេសុ បន កោចិ តជា ចោក្ខរសាតិយព្រាហ្មណោ** សម្តែងពីអាយុរបស់មនុស្សមនុស្សខ្លះ ក៏មានអាយុវែង ពាក្យទាំងនេះសមដូចពាក្យខាងក្រោយថា នាងវិសាខានោះមានអាយុតាំងនៅបាន ១២០ ឆ្នាំ មួយទៀត បោក្ខរសាតិយព្រាហ្មណ៍ ព្រហ្មាយុព្រាហ្មណ៍ សេលព្រាហ្មណ៍ ពាវរីព្រាហ្មណ៍ ព្រះអានន្ទ និងព្រះមហាកស្សបៈ សុទ្ធតែមានអាយុតាំងនៅបាន ១២០ ឆ្នាំដូចគ្នា ប៉ុន្តែព្រះអនុរុទ្ធមានអាយុតាំងនៅបាន ១៥០ ឆ្នាំ ។ ព្រះពាកុលៈមានអាយុតាំងនៅបាន ១៦០ ឆ្នាំ ប៉ុន្តែមិនមានដល់ ២០០ ឆ្នាំទេ ។

ទីនេះនឹងពោលអំពីបដិសន្ធិរបស់សត្វទាំងឡាយ **បដិសន្ធិវិញ្ញាណស្ស ឋានំ** រីទីតាំងរបស់បដិសន្ធិវិញ្ញាណ **វិញ្ញាណដ្ឋិតិ នាម**

ឈ្មោះថា វិញ្ញាណដ្ឋិតិ **សា សត្តវិធា** ក៏វិញ្ញាណដ្ឋិតិនោះមាន ៧ យ៉ាង គឺនានត្តកាយានានត្តសញ្ញី ១ នានត្តកាយាឯកត្តសញ្ញី ១ ឯកត្តកាយានានត្តសញ្ញី ១ ឯកត្តកាយាឯកត្តសញ្ញី ១ **ហេដ្ឋាតិស្សោ អរូបភូមិយោ** អរូបភូមិ ៣ ដែលជាថ្នាក់ទាប គឺអាកាសា-នញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ ទើបជាវិញ្ញាណដ្ឋិតិ ៧ ប្រការដូច្នេះ អធិប្បាយថា មនុស្សទាំងឡាយនឹងរាប់ប្រមាណមិនបាន ចក្រវាលនឹងរាប់ប្រមាណមិនបាន ។ មនុស្សពីរនាក់បងប្អូនក្តី ក៏មិនដូចគ្នាដោយអំណាចនៃវណ្ណៈសណ្ឋានជាដើម គង់នឹងផ្សេងគ្នាដោយពិត ។ កន្លែងខ្លះថា ពីរនាក់បងប្អូនជាកូនភ្លោះស្មើគ្នាដោយសម្បុរ និងសណ្ឋានក្តី គង់ប្លែកគ្នាដោយការក្រឡេកមើលទៅមុខ ក្រឡេកមើលឆ្វេងស្តាំ ការនិយាយ ការញញឹម ការដើរ ការឈរជាដើម គង់តែប្លែកគ្នា ផ្សេងគ្នាដោយពិត **តស្មា** ព្រោះហេតុនោះ ទើបមនុស្សទាំងឡាយនោះ ឈ្មោះថា **នានត្តកាយា** គឺមានកាយផ្សេងគ្នា ម្យ៉ាងទៀត បដិសន្ធិសញ្ញារបស់សត្វទាំងឡាយនោះក៏ផ្សេងគ្នា **តិហេតុកាបិ** គឺកើតជាតិហេតុកបដិសន្ធិខ្លះ ជាទុហេតុក-បដិសន្ធិខ្លះ ជាអហេតុកបដិសន្ធិខ្លះ ព្រោះហេតុនោះ ទើបសត្វទាំង

នោះ ឈ្មោះថា **ឆានត្តសញ្ញី** គឺមានបដិសន្ធិសញ្ញានោះផ្សេងគ្នា តថា **ចកាមាវចរទេវតា** ទេវតាទាំងឡាយ ក្នុងឆកាមាវចរសួគ៌ ទាំង ៦ ជាន់ ក៏ឈ្មោះថា **ឆានត្តកាយាឆានត្តសញ្ញី** ដូចមនុស្សដែរ អធិប្បាយថា ទេវតាពួកខ្លះមានកាយខៀវ ខ្លះមានកាយលឿងជាដើម ផ្សេងៗ គ្នា ដោយអំណាចនៃវណ្ណៈ និងសណ្ឋាន ។ ឯបដិសន្ធិសញ្ញា ក៏ផ្សេងគ្នា ទេវតាអង្គខ្លះជាទុហេតុកបដិសន្ធិ អង្គខ្លះជាតិហេតុកបដិសន្ធិ ប៉ុន្តែមិនមានអហេតុកបដិសន្ធិទេ ។ម្យ៉ាងទៀត យក្ខិនីទាំងឡាយ មានឧត្តរមាតាយក្ខិនីជាដើម ដែលផុតចាកអបាយភូមិទាំង ៤ និងប្រេត ទាំងឡាយដែលឈ្មោះថា វិមានិកប្រេត ក៏ជានានត្តកាយានានត្តសញ្ញី ។ អធិប្បាយថា ប្រេតទាំងឡាយនោះ មានកាយផ្សេងៗ គ្នា ដោយអំណាចសម្បុរខ្មៅ សម្បុរដាំងជាដើម ដោយអំណាចស្គម ធាត់ ទាប និងខ្ពស់ជាដើម ម្យ៉ាងទៀត បដិសន្ធិសញ្ញានោះផ្សេងៗ គ្នា ដូចជាទុហេតុកៈខ្លះ ជាអហេតុកៈខ្លះ ដូចបដិសន្ធិសញ្ញារបស់ មនុស្ស ហេតុដូច្នោះ មនុស្សទាំងឡាយ ពួកទេវតាទាំងឡាយក្តី និង ឆកាមាវចរៈក្តី បានឈ្មោះថា **នានត្តកាយានានត្តសញ្ញី** គឺមានកាយ ផ្សេងគ្នា បដិសន្ធិសញ្ញាក៏ផ្សេងគ្នាដូចវិសជ្ជនាមកនេះ ។

**បឋមំ ឈានំ បរិត្តមជ្ឈិមបណីតវសេន ភាវេត្វា យថាកម្មំ ព្រហ្មបារិសជ្ជ ព្រហ្មបុរោហិត មហាព្រហ្មេសុ ឧប្បជ្ជន្តិ** *ព្រះយោគាវចរ កុលបុត្រអ្នកចម្រើនបឋមជ្ឈាន ៣ យ៉ាង គឺយ៉ាងទាប យ៉ាងកណ្តាល និងយ៉ាងប្រណីត ទើបទៅកើតក្នុងព្រហ្មលោក ដែលចម្រើនបឋមជ្ឈានយ៉ាងទាប ក៏តែងតែទៅកើតក្នុងជាន់ព្រហ្មបារិសជ្ជា ដែលចម្រើនបឋមជ្ឈានយ៉ាងកណ្តាល ក៏តែងតែទៅកើតក្នុងជាន់ព្រហ្មបុរោហិត ដែលចម្រើនបឋមជ្ឈានយ៉ាងខ្ពស់នោះ ក៏តែងតែទៅកើតក្នុងជាន់មហាព្រហ្ម ដោយលំដាប់ៗ ដូច្នេះ ។ រូបកាយរបស់ព្រហ្មបុរោហិតធំជាងរូបកាយ របស់ព្រហ្មបារិសជ្ជា រូបកាយរបស់ស្តេចមហាព្រហ្ម ធំជាងរូបកាយ របស់ព្រហ្មបុរោហិត ហេតុដូច្នោះ ទើបព្រហ្មជាន់បឋមជ្ឈានភូមិនោះ បានឈ្មោះថា* **នានត្តកាយា** *មានកាយផ្សេងគ្នា ប៉ុន្តែបដិសន្ធិសញ្ញាដូចគ្នា ដោយអំណាចនៃបឋមជ្ឈានវិបាក មានបដិសន្ធិដូចគ្នា ហេតុដូច្នោះ ទើបបានឈ្មោះថា* **ឯកត្តសញ្ញី** *ដោយប្រការដូច្នេះ ។*

**យថា ច តេ ឯវំ ចតូសុ អបាយេសុ សត្តា** *ព្រហ្មទាំងឡាយក្នុងជាន់បឋមជ្ឈានភូមិនោះ ឈ្មោះថា នានត្តកាយាឯកត្តសញ្ញី*

យ៉ាងណា សត្វទាំងឡាយក្នុងអបាយភូមិទាំង ៤ ក៏បានឈ្មោះថា នានត្តកាយាឯកត្តសញ្ញីដូចគ្នា អធិប្បាយថា អត្តភាពនៃសត្វទាំងឡាយក្នុងនរកនោះ ពួកខ្លះមានកាយប្រមាណមួយគាវុតក៏មាន ពួកខ្លះមានកាយប្រមាណកន្លះយោជន៍ក៏មាន ពួកខ្លះ មានកាយប្រមាណមួយយោជន៍ក៏មាន ប៉ុន្តែកាយរបស់ទេវទត្តកើតប្រាកដប្រមាណ ១០០ យោជន៍ ។ សត្វទាំងឡាយក្នុងកំណើតតិរច្ឆាន ពួកខ្លះមានសរីរៈនោះ ពួកខ្លះមានសរីរៈធំផ្សេងៗ គ្នា ។ មប៉្យាងទៀត សត្វទាំងឡាយក្នុង បេត-វិស័យ ពួកខ្លះមានសរីរៈខ្ពស់ប្រមាណ ៦០ ហត្ថ ពួកខ្លះមានកម្ពស់ប្រមាណ ៨០ ហត្ថ ពួកខ្លះមានសម្បុរសេណ្ឋានស្អាតដូចមាស ពួកខ្លះមានសម្បុរអាក្រក់ ។

មួយទៀត អសុរកាយដែលឈ្មោះថា កាឡកញ្ជិកាសុរនោះក៏ឈ្មោះថា នានត្តកាយាដូចប្រេតដែរ ប៉ុន្តែអសុរកាយមួយពួកឈ្មោះថា **ទីឃបិដ្ឋិកាសុរ** អសុរកាយពួកនេះក៏មានកាយខ្ពស់ប្រមាណ ៦០ យោជន៍ មានកាយផ្សេងអំពីអសុរកាយ ។ សត្វទាំងឡាយដែលកើតក្នុងអបាយភូមិទាំង ៤ នោះ អកុសលវិបាកនេះជាអហេតុកចិត្ត មានបដិសន្ធិសញ្ញាដូចគ្នាទាំងអស់ ព្រោះហេតុនោះ ទើបសត្វដែលកើត

ក្នុង អបាយភូមិទាំង៤ បានឈ្មោះនានត្តកាយាឯកត្តសញ្ញី ប៉ុន្តែបណ្តាព្រហ្មទាំងឡាយក្នុងបឋមជ្ឈានភូមិក្តី សត្វទាំងឡាយដែលកើតក្នុងអបាយភូមិក្តី អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ជាឯកត្តសញ្ញីទាំងអស់ ។

ហេតុដូចនោះ **បញ្ចកនយេ ទុតិយតតិជ្ឈាន ទ្វយញ្ច បរិត្តមជ្ឈិមអប្បមាណវសេន ភាវេត្វា យថាកម្មំ បរិត្តាភា អប្បមាណាភា អាភស្សរេសុ អប្បជ្ជន្តិ** កាលព្រះយោគាវចរ គឺកុលបុត្រអ្នកចម្រើននូវទុតិយជ្ឈានទាំងពីរ ដោយអំណាចការចម្រើនជា ៣ យ៉ាង គឺបរិត្ត មជ្ឈិម អប្បមាណ ចម្រើនជាបញ្ចកន័យហើយ ក៏ទៅកើតក្នុងជាន់បរិត្តាភាព្រហ្ម អប្បមាណាភាព្រហ្ម អាភស្សរព្រហ្ម ដោយលំដាប់គ្នា ក្នុងជាន់ទុតិយជ្ឈានភូមិនោះ មានរូបកាយធំប៉ុនគ្នាដូចគ្នា ប៉ុន្តែបដិសន្ធិសញ្ញានោះផ្សេងគ្នា គឺពួកខ្លះគ្មានវិតក្ក មានតែវិចារ ពួកខ្លះគ្មានវិតក្កវិចារ ផ្សេងគ្នាដូច្នេះ ព្រោះដូច្នោះ ទើបព្រហ្មក្នុងជាន់ទុតិយជ្ឈានភូមិបានឈ្មោះថា ឯកត្តកាយានានត្តសញ្ញី មានរូបកាយដូចគ្នា ប៉ុន្តែបដិសន្ធិសញ្ញាផ្សេងគ្នា ។

មួយទៀត ព្រះយោគាវចរ គឺកុលបុត្រអ្នកចម្រើននូវចតុត្ថជ្ឈាន ដោយអំណាចនៃការចម្រើន ៣ យ៉ាង គឺបរិត្ត មជ្ឈិម អប្បមាណ

ដោយការចម្រើនបញ្ចកន័យហើយ កើតក្នុងជាន់តតិយជ្ឈានភូមិតាមលំដាប់គ្នា ដោយអំណាចជាន់បរិត្តសុភាព្រហ្ម អប្បមាណសុភាព្រហ្ម សុភកិណ្ហាព្រហ្ម ។ ព្រហ្មទាំង ៣ យ៉ាងនេះជាព្រហ្មនៅក្នុងតតិយជ្ឈានភូមិ រូបកាយរបស់ចតុត្ថជ្ឈានសញ្ញានោះដូចគ្នាទាំងអស់ ទើបបានឈ្មោះថា **ឯកត្តកាយឯកត្តសញ្ញី** គឺកាយក៏ដូចគ្នា **ចតុត្ថជ្ឈាន-សញ្ញា** ក៏ដូចគ្នា ។

ម្យ៉ាងទៀត ព្រហ្មទាំងឡាយ គឺវេហប្ផលាព្រហ្ម និងសុទ្ធាវាសទាំង ៥ គឺជាន់អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា ក៏ឈ្មោះថា **ឯកត្តកាយាឯកត្តសញ្ញី** ដូចគ្នា **ឯត្ថ បន សុទ្ធាវាសា** ក៏ប៉ុន្តែបណ្តាព្រហ្មវេហប្ផលា និងសុទ្ធាវាសទាំងឡាយនេះ សុទ្ធាវាសទាំង ៥ រមែងតាំងនៅតែក្នុងកប្បដែលចម្រើន មិនបានតាំងនៅគ្រប់កាលឡើយ ។ **ន ឧប្បជ្ជន្តិ** ព្រហ្មទាំងឡាយក្នុងជាន់សុទ្ធាវាសនោះ មិនបានកើតក្នុងកប្បដែលសូន្យទទេចាកព្រះសម្មាសម្ពុទ្ធឡើយ ទោះបីមួយអសង្ខេយ្យកប្បក្តី មួយសែនមហាកប្បក្តី កាលបើកើតមាន ក៏កើតតែក្នុងពេលព្រះពុទ្ធកើតឡើងក្នុងលោក ខាងក្នុងមួយម៉ឺនប្រាំបួនពាន់កប្បនោះ ព្រហ្មទាំងឡាយកើតក្នុងជាន់សុទ្ធាវាស

ក៏កើតប្រាកដ ប្រៀបដូចកងទ័ពរបស់ព្រះពុទ្ធ លុះកាលព្រះអង្គយាងទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ដើម្បីត្រាស់សម្ដែងព្រះធម្មចក្កប្បវត្តនសូត្រ ទៀបក្រុងពារាណសី **តស្មា** ព្រោះហេតុនោះ ព្រហ្មទាំងឡាយក្នុងជាន់សុទ្ធាវាសនោះ ទើបមិនសោយនូវវិញ្ញាណដ្ឋិតិ និងសត្តាវាស មាននានត្តកាយានានត្តសញ្ញីជាដើម ។ ព្រះសីវលីសម្ដែងថា **ឥទំ បន សោ សត្តាវាសោ សុលព្ភរូបោ សោ មយា** ជាដើមដូច្នេះ អធិប្បាយថា ព្រហ្មទាំងឡាយមិនបានសេពនូវវិញ្ញាណដ្ឋិតិជាគម្រប់ ៤ និងសត្តាវាសជាគម្រប់ ៤ គឺឯកត្តកាយាឯកត្តសញ្ញី ព្រះថេរៈសម្ដែងដោយសូត្រនេះថា **សោ សត្តាវាសោ** ទីនៅរបស់សត្វ មានបឋមជ្ឈានភូមិជាដើម **ឥទំ បន សុលព្ភរូបោ** ការពិត មិនមាននូវការៈដែលបុគ្គលគប្បីបានដោយងាយនោះទេ **សោ សត្តាវាសោ** វិសត្តាវាសមានបឋមជ្ឈានភូមិជាដើមនោះ អាត្មាអញមិនធ្លាប់បាននៅអស់កាលយូរ និងអាត្មាអញ មិនធ្លាប់បាននៅក្នុងជាន់សុទ្ធាវាសដែរ ។ ថេរវាចានៃព្រះសីវលីនេះ សមគ្នានឹងព្រះពុទ្ធដីកាព្រះសម្ពុទ្ធត្រាស់អនុញ្ញាតទុកហេតុដូចម្ដេច ហេតុថា សូត្រដែលព្រះសីវលីសម្ដែងនោះ ព្រះសម្ពុទ្ធមិនបានហាម **ឥតិ អាភ–**

**សត្តានំ បរិវារិតោ** *ប៉ុន្តែអសញ្ញីសត្វទាំងឡាយនោះ ព្រះពុទ្ធមិនបានត្រាស់ក្នុងវិញ្ញាណដ្ឋិតិទី ៥ គឺឯកត្តកាយាឯកត្តសញ្ញីនោះ ព្រោះថា អសញ្ញីសត្វទាំងឡាយនោះ មិនមានបដិសន្ធិវិញ្ញាណ គឺអសញ្ញីសត្វមិនមានចិត្ត មិនមានវិញ្ញាណ បដិសន្ធិមានតែរូបក្ខន្ធ បដិសន្ធិតាំងនៅដូចតុក្កតា គ្មានចិត្ត គ្មានវិញ្ញាណ ទើបមិនបានរាប់បញ្ចូលក្នុងវិញ្ញាណដ្ឋិតិទី ៤ ។ នេវសញ្ញានាសញ្ញាយតនៈ ក៏មិនបានរាប់បញ្ចូលក្នុងវិញ្ញាណដ្ឋិតិ ព្រោះថា ចតុត្ថារូបនោះមានសញ្ញាក៏ល្អិត វិញ្ញាណក៏ល្អិត នេវសញ្ញានាសញ្ញាយតនៈសញ្ញាល្អិត យ៉ាងណា នេវវិញ្ញាណាវិញ្ញាយតនៈនោះ មានវិញ្ញាណល្អិតដូច្នេះ ហេតុនោះ ទើបមិនបានរាប់ចតុត្ថារូបចូលក្នុងវិញ្ញាណដ្ឋិតិដោយសត្តាវាស ៩ នោះគឺសញ្ញីសត្វ ១ ចតុត្ថារូប ១ និងវិញ្ញាណដ្ឋិតិទាំង ៧ ចូលគ្នាជា ៩ ហៅថា សត្តាវាស ៩ គឺជាទីនៅរបស់សត្វ ដោយប្រការដូច្នេះ ។*

*មួយទៀត ព្រះអដ្ឋកថាចារ្យវិសជ្ជនាក្នុង អដ្ឋកថាអង្គុត្តរនិកាយថា* **យត្ថ យត្ថុប្បជ្ជន្តស្ស បន ឧប្បត្តិយា ហេតុភូតំ កុសលាកុសលកម្មំ កម្មភវោ នាម កម្មនិព្វត្តា ខន្ធា ឧប្បត្តិភវោ នាម ខន្ធានំ និព្វត្តិ ជាតិនាម ភេទោ មរណំ នាមាតិ វេទិ–**

**តព្ភោ** អធិប្បាយថា កុសលកម្ម និងអកុសលកម្ម ជាហេតុដែលឲ្យសព្វសត្វទៅកើតក្នុងភពណាៗ ភពនោះៗ ឈ្មោះថា កម្មភព **កម្មនិព្វត្តា ខន្ធា** ខន្ធទាំង ៥ មានរូបក្ខន្ធជាដើមដែលកើតអំពីកម្មភពនោះ ឈ្មោះថា ឧប្បត្តិភព **ខន្ធានំ និព្វត្តិ** អាការដែលកើតឡើងហើយនៃខន្ធទាំង ៥ នោះ ឈ្មោះថា **ជាតិភេទោ** អាការដែលបែកធ្លាយនៃខន្ធទាំង ៥ នោះ ឈ្មោះថា **មរណំ ។** ក្នុងបទមាតិកាទាំងនេះ មានព្រះគាថាសម្តែងថា **ឯកាទស កាមភវា សោឡសរូបិនោ** ជាដើមដូច្នេះ អធិប្បាយតាមព្រះគាថាថា **ឯកាទស កាមភវា** កាមភព ១១ គឺអបាយភូមិ ៤ មនុស្ស ១ ឆកាមាវចរស្ហគ៌ ៦ ឈ្មោះថា **កាមភព** រូបព្រហ្ម ១៦ មានបឋមជ្ឈានភូមិជាដើម មានសុទ្ធាវាសបចតុត្ថជ្ឈានភូមិជាបរិយោសាន ឈ្មោះថា **រូបភព** អរូបភពទាំង ៤ គឺអាកាសានញ្ចាយតនៈជាដើមនេះ ឈ្មោះថា **អរូបភព** **ភវសង្គហានយោ** មួយ៉ាងទៀត ការសង្គ្រោះយកនូវភពទាំង ៣ គឺកាមភព ១១ រូបភព ១៦ អរូបភព ៤ ជា ៣១ ភព ។ អសញ្ញីសត្វក៏ចាត់ជាភព ១ ឈ្មោះថា ឯកវោការភព គឺមានតែរូបក្ខន្ធតែមួយ ដែលសល់ពីអសញ្ញីនោះ ហៅថា សញ្ញីភពទាំងអស់ ជាន់ចតុត្ថារូបនោះ ហៅថា

នៅសញ្ញានាសញ្ញីភព ជា ៣ ភព ដោយប្រការដូច្នេះ ។ អរូបព្រហ្មទាំង ៤ ឈ្មោះថា **ចតុវោការភព** អសញ្ញីភព ហៅថា **ឯកវោការភព** ។ **ភវោ សេសោ** ភពដ៏សេស ពីភពទាំងពីរនោះ ហៅថា **បញ្ចវោការភព** ព្រោះថា កើតបញ្ចក្ខន្ធទាំង ៥ ប្រការ ។ បើសង្គ្រោះចូលក្នុងកំណើតទាំង ៥ ឱបបាតិកកំណើតសង្គ្រោះចូលក្នុងសត្វនរក និងទេវតាទាំងឡាយ ។ **អណ្ឌជ ជលាពុជ សំសេទជ ឱបបាតិក** ទាំងឡាយនោះ រមែងកើតមានក្នុងបេតលោក សត្វតិរច្ឆាន កុម្ភទេវតា មនុស្សនិងអសុរកាយទាំងឡាយ បើពោលដោយគតិ មាន ៥ គឺនិរយគតិ ១ តិរច្ឆានគតិ ១ បេតគតិ ១ មនុស្សគតិ ១ ទេវតាគតិ ១ ។ **និម្មលលោចនោ** ព្រះសម្ពុទ្ធព្រះអង្គប្រកបដោយព្រះនេត្រទាំង ៥ មិនមានមន្ទិល ព្រះអង្គទ្រង់ពិចារណាឃើញនូវគតិដែលប្រព្រឹត្តទៅរបស់សត្វ មាន ៥ពួក គឺនរក តិរច្ឆាន ប្រេត មនុស្ស ទេវតា វេបចិត្រាសុរ និងកាឡកញ្ជិកាសុរ ទាំងពីរអសុរនេះក៏រាប់ចូលទៅក្នុងពួកប្រេត **កាមសុគតិយោ** កាមសុគតិទាំង ៧ គឺមនុស្ស ១ ឆកាមាវចរសួគ៌ទាំង ៦ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា នានត្តកាយានានត្តសញ្ញី ព្រោះថា រូបកាយក៏ផ្សេងគ្នា

បដិសន្ធិសញ្ញាក៏ផ្សេងគ្នា ព្រហ្មក្នុងបឋមជ្ឈានភូមិ និងសត្វក្នុងអបាយភូមិទាំង ៤ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា នានត្តកាយា-ឯកត្តសញ្ញី ព្រោះមានកាយផ្សេងគ្នា ប៉ុន្តែបដិសន្ធិសញ្ញានោះក៏ដូចគ្នា ព្រហ្មក្នុងទុតិយជ្ឈានភូមិនោះ ព្រះមានព្រះភាគត្រាស់ហៅថា ឯកត្ត-កាយានានត្តសញ្ញី ព្រោះមានរូបកាយដូចគ្នា ប៉ុន្តែបដិសន្ធិសញ្ញាផ្សេងគ្នា ព្រហ្មខាងលើតាំងអំពីអាភស្សរាព្រហ្មឡើងទៅ ព្រះមានព្រះភាគត្រាស់ហៅថា ឯកត្តកាយាឯកត្តសញ្ញី ព្រោះមានរូបកាយក៏ដូចគ្នា បដិសន្ធិសញ្ញាក៏ដូចគ្នា ទើបយកអរូបព្រហ្មខាងក្រោម ៣ គឺអាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ ផ្សំចូល ទើបជាវិញ្ញាណដ្ឋិតិ ៧ អសញ្ញីសត្វ ព្រះមានព្រះភាគមិនបាន សង្គ្រោះចូលក្នុងវិញ្ញាណដ្ឋិតិទាំង ៧ ទេ ព្រោះមិនមានវិញ្ញាណសព្វកាល ម្យ៉ាងទៀត ចតុត្ថារូប គឺនេវសញ្ញានាសញ្ញា-យតនអរូបព្រហ្ម ក៏មិនបានរាប់ចូលក្នុងវិញ្ញាណដ្ឋិតិទាំង ៧ ព្រោះមានវិញ្ញាណតិចតួច ។ ព្រះមានព្រះភាគត្រាស់ថា អសញ្ញីសត្វ ចតុត្ថារូប និងវិញ្ញាណដ្ឋិតិទាំង ៧ នេះ ហៅថា សត្តាវាស ៩ ។ ម្យ៉ាងទៀត ត្រាស់ថា **អថាយម្ហា ចុតា** សត្វទាំងឡាយចុតិចាកអបាយភូមិហើយ ក៏មកកើតក្នុងមនុស្ស និងឆកាមាវចរសួគ៌ទាំង ៦ ។

ម្យ៉ាងវិញទៀត ប្រសិនបើចុតិចាកកាមភពដ៏សេសពីអបាយភូមិទាំង ៤ នោះ **សព្វត្ថាបេិ ជាយន្តិ** ក៏តែងតែទៅកើតក្នុងភពផ្សេងៗ តាមតែកុសលាកុសលកម្មរបស់ខ្លួន ។ មួយទៀត បើចុតិចាកសុទ្ធាវាស ខាងលើ បានដល់លោកអ្នកដែលបានសម្រេចនូវព្រះអនាគាមិផល **អសញ្ញិម្ហា ចុតា** បើចុតិចាកអសញ្ញីភពហើយ ក៏ទៅកើតក្នុងកាម-សុគតិភពទាំង ៧ មានមនុស្សជាដើម **សេស រូបា ចុតា** បើចុតិចាកអរូបភពដ៏សេស ក៏កើតក្នុងភពទាំងឡាយ វៀរតែអបាយភូមិទាំង ៤ ។ បើចុតិចាកអរូបភព ទៅកើតក្នុងកាមសុគតិក៏មាន កើតក្នុងអរូបភពខាងលើក៏មាន បើជាបុថុជ្ជនវិញ លុះធ្វើកាលកិរិយាហើយ ទៅកើតក្នុងអសញ្ញីភពខ្លះ ក្នុងអបាយភូមិខ្លះ តាមតែកុសលាកុសលកម្មរបស់ខ្លួន ប៉ុន្តែបុគ្គលដែលបានសម្រេចអនាគាមិផលហើយនោះ កាលបើចុតិក៏ទៅកើតក្នុងជាន់សុទ្ធាវាស ជាន់ណាមួយ **អយំ យោនិ វិភាវនេសង្គហនយោ** ន័យនៃការសង្គ្រោះយកកិរិយាដែលសម្តែងនូវកំណើតផ្សេងៗ នេះ ក៏ចប់ត្រឹមតែប៉ុណ្ណេះ ។

សត្តានំយោនិបភេទកថា ចប់

# បុមិត្ថីបរិវត្តនកថា

**បុមិត្ថីបរិវត្តនន្តិ បុរិសានំ ឥត្ថិភាវូបគមនេន ឥត្ថីនំ បុរិសត្តភាវូបគមនេន បរិវត្តនំ តត្រាយំ វិភាវនា ឥត្ថីលិង្គ-បុរិសលិង្គញ្ច បឋមកប្បិកានំ បវត្តេ សមុដ្ឋាតិ** *អំពីនេះនឹងបំភ្លឺនូវកិរិយាដែលប្តូរភេទជាបុរស ឬប្តូរជាស្ត្រី អាការដែលប្រព្រឹត្តទៅដល់នូវអត្តភាពជាស្ត្រី ជាបុរសនោះ បានឈ្មោះថា ប្តូរភេទបុរស ឬប្តូរភេទស្ត្រី* **តត្រាយំ វិភាវនា** *វិកិរិយាដែលសម្តែងក្នុងបទមាតិកា គឺភេទបុរសប្តូរភេទជាស្ត្រី អ្នកប្រាជ្ញគប្បីជ្រាបដោយប្រការដូច្នេះ គឺភេទស្ត្រី ឬភេទបុរស កើតមានប្រាកដក្នុងបវត្តិកាល ចំពោះមនុស្សទាំងឡាយដែលកើតក្នុងបឋមកប្ប ។ លុះពេលកន្លងមក ភេទស្ត្រីក្លាយជាភេទបុរស កើតប្រាកដតែក្នុងបដិសន្ធិកាល ហើយក៏ត្រឡប់ក្លាយប្រែប្រួលទៅក្នុងបវត្តិកាល ។ ព្រះសម្ពុទ្ធត្រាស់ទេសនាដូច្នេះថា* **តេន ខោ បន សមយេន** *ក្នុងសម័យនោះ ភេទស្ត្រីកើតប្រាកដចំពោះភិក្ខុមួយរូប មាននាម និងគោត្រមិនប្រាកដ ។ ឯភេទបុរសសោតក៏កើតប្រាកដចំពោះភិក្ខុនីមួយរូប មាននាម និងគោត្រមិនប្រាកដ ។*

**ឥមេសុ បន លិង្គេសុ** បណ្តាភេទទាំងពីរនេះ **បុរិសលិង្គំ** ការពិត ភេទបុរសនេះ ជាភេទដ៏ប្រសើរ ភេទរបស់ស្ត្រីជាភេទថោកថយ **តស្មា** ព្រោះហេតុនោះ កាលបើភេទបុរសអន្តរធានបាត់ទៅ គឺបាត់ទៅព្រោះ អកុសលកម្មមានកម្លាំងខ្លាំងក្លា ភេទស្ត្រីកើតឡើង ព្រោះកុសលកម្ម ទុព្វលភាព ។ សេចក្តីនេះពោលដោយភិក្ខុត្រឡប់ភេទជាស្ត្រី ។ មួយ ទៀត ភេទស្ត្រីអន្តរធានបាត់ទៅនោះ ក៏អន្តរធានបាត់ទៅព្រោះអកុសល កម្មទុព្វលភាព ភេទបុរសកើតឡើង ព្រោះកុសលកម្មមានកម្លាំងខ្លាំងក្លា ។ សេចក្តីនេះពោលដោយភិក្ខុនីត្រឡប់ភេទជាបុរស ។ **ឯវំ ឧភយម្បិ** ភេទទាំងពីរ គឺភេទបុរស និងភេទស្ត្រីអន្តរធានទៅ ព្រោះអកុសលកម្ម ទុព្វលភាព ដែលសត្វទាំងឡាយត្រូវបានដោយកុសលទុព្វលភាព និងអកុសល មានកម្លាំងខ្លាំងក្លា ។ ពាក្យទាំងនេះព្រះអដ្ឋកថាចារ្យ វិសជ្ជនាក្នុង **អដ្ឋកថាធម្មសង្គណី** និង **អដ្ឋកថាបឋមបារាជិក** ក្នុង ព្រះវិន័យ កិរិយាដែលវិនាស និងកិរិយាដែលកើតនៃឥន្ទ្រិយតែមួយ អ្នកប្រាជ្ញគប្បីជ្រាបថា ព្រះសម្ពុទ្ធត្រាស់ថា ភេទបុរសអន្តរធានបាត់ទៅ ក៏ព្រោះអកុសលមានកម្លាំងខ្លាំងក្លា ទើបភេទស្ត្រីកើតប្រាកដឡើង ។ អធិប្បាយថា កាលបើភេទស្ត្រីអន្តរធានទៅ ឬកើតឡើង អាការ

ដែលអន្តរធានទៅ អាការដែលតាំងឡើងរបស់ភេទនោះ អាស្រ័យនូវឥត្ថិន្ទ្រិយនោះក៏កើតមាន សមដូចពាក្យថា ឥត្ថិន្ទ្រិយ គឺភេទស្ត្រី កើតមានក្នុងខណៈណា បុរិសិន្ទ្រិយ គឺភេទបុរស ក៏មិនបានកើតឡើងក្នុងខណៈនោះ ។ ចាប់ផ្ដើមអំពី ១៧ ខណៈចិត្តពេញបរិបូណ៌ ព្រោះថា ការប្រព្រឹត្តទៅព្រមគ្នានៃឥន្ទ្រិយទាំងពីរនោះ មិនបានកើតក្នុងសន្តានតែមួយ ព្រោះហេតុអ្វី ព្រោះថា ព្រះពុទ្ធត្រាស់ក្នុង**គម្ពីរយមកៈ** ទ្រង់ត្រាស់ជាកថេតុកម្យតាបុច្ឆាថា ឥត្ថិន្ទ្រិយរបស់បុគ្គលណាកើត បុរិសិន្ទ្រិយរបស់បុគ្គលនោះកើតដែរឬ ត្រាស់វិសជ្ជនាថា ឥត្ថិន្ទ្រិយរបស់បុគ្គលណាកើត បុរិសិន្ទ្រិយនៃបុគ្គលនោះកើតផង មិនមាន ។ ម្យ៉ាងទៀត ត្រាស់សួរថា បុរិ-សិន្ទ្រិយរបស់អ្នកណាកើត ឥត្ថិន្ទ្រិយរបស់អ្នកនោះក៏កើតដែរឬ ត្រាស់ឆ្លើយថា បុរិសិន្ទ្រិយរបស់អ្នកណាកើត ឥត្ថិន្ទ្រិយរបស់អ្នកនោះនឹងមិនកើតឡើយ ។ ព្រះសម្ពុទ្ធត្រាស់ទុកក្នុងគម្ពីរយមកៈយ៉ាងច្បាស់ដូច្នេះ ។ ក្នុងកាលបុរិសិន្ទ្រិយទាំងឡាយ ដែលកើតតាំងអំពី ១៧ ខណៈចិត្តនោះក្ដី រលត់ទៅតាមលំដាប់ព្រមជាមួយសហជាតរូបទាំងឡាយក្ដី ឥន្ទ្រិយកើតក្នុងសន្តានរបស់ភិក្ខុនោះ ក្នុងកាល

រូបទាំងឡាយដែលជាកម្មសមុដ្ឋានក្តី ក្នុងរូបទាំងឡាយដ៏សេសក្តី ប្រព្រឹត្តទៅជាអាការរបស់បុរស និងសណ្ឋានរបស់បុរសប្រព្រឹត្តទៅ អស់កាលមួយស្របក់ រួចហើយក៏រលត់ក្នុងកាលនោះ ។ ម្យ៉ាងទៀត ក្នុងកាលរូបដែលមានចិត្តជាសមុដ្ឋាន ប្រព្រឹត្តទៅដោយឥត្ថិន្ទ្រិយ និងអាការរបស់ស្ត្រី និងសណ្ឋានរបស់ស្ត្រី ឯបុរសសណ្ឋានជាដើមនោះ ទើបអន្តរធានបាត់ទៅ ទើបឥត្ថីសណ្ឋានកើតប្រាកដឡើងសាជាថ្មី ។ ព្រះមានព្រះភាគត្រាស់ថា **អយមេវ ឆយោ** ន័យនេះអ្នកប្រាជ្ញគប្បីជ្រាបថា ភេទស្ត្រីមកប្រាកដក្នុងភេទបុរស ។

ម្យ៉ាងទៀត **បុរិសលិង្គំ ពលវអកុសលេន អន្តរធាយតិ ឥត្ថីលិង្គំ ទុព្វលកុសលេន បតិដ្ឋាតិ** ភេទបុរសអន្តរធានបាត់ទៅ ព្រោះអកុសលកម្មមានកម្លាំងខ្លាំងក្លា ទើបភេទស្ត្រីកើតឡើង ព្រោះកុសលកម្មទុព្វលភាព ។

ទើបមានពាក្យសួរថា **កថំ** ដោយហេតុដូចម្តេច ? ឆ្លើយថា **បដិសន្ធិយំ តាវ បុរិសិន្ទ្រិយុប្បាទកំ អន្វូបហាតសាមត្ថិយំ ពលវកុសលកម្មំ យាវតា យុកំ បុរិសិន្ទ្រិយមេវ ឧប្បាទេតិ** កុសលកម្មដែលមានកម្លាំងខ្លាំងក្លា មានប្រក្រតីញុំាងបុរិសិន្ទ្រិយឲ្យ

*កើតឡើងក្នុងបដិសន្ធិកាលនោះ ប្រសិនបើអំណាចអកុសលមិនអាចបៀតបៀនបាន ក៏ញ៉ាំងបុរិសិន្ទ្រិយតែមួយឲ្យកើតជាបអស់អាយុ* **តេនេវ បដិសន្ធិទាយកំ កុសលកម្មំ** *បើពោលថា កុសលកម្មដែលញ៉ាំងបដិសន្ធិឲ្យកើតឡើងនោះ មានអំណាចក្នុងកិរិយាដែលញ៉ាំងនូវបដិសន្ធិឲ្យកើត និងមិនឲ្យកើតបាន ព្រោះអកុសលកម្មមានកម្លាំងមានការគប់រកដោយកិរិយារបស់អ្នកដទៃជាដើម មានបច្ច័យដែលខ្វះបានក្នុងចន្លោះនោះ ក៏មិនបានញ៉ាំងបុរិសិន្ទ្រិយឲ្យកើតបាន ទើបញ៉ាំងនូវឥត្ថិន្ទ្រិយដ៏សមគួរ ដល់អំណាចរបស់ខ្លួនកើតឡើងប្រាកដក្នុងបវត្តិកាល ។ មយ៉ាងទៀត អកុសលកម្មដែលមានអំណាចក្នុងការញ៉ាំងបុរិសិន្ទ្រិយឲ្យកើតនោះ បើកុសលកម្មមានកម្លាំង មិនបានគប់រកកិរិយាអ្នកដទៃជាដើម មានបច្ច័យ ដែលខ្វះបានហើយធ្វើនូវការបៀតបៀនក្នុងកាលនឹងឲ្យបដិសន្ធិនោះ កុសលកម្មទុព្វលភាពក៏មិនអាចញ៉ាំងបុរិសិន្ទ្រិយឲ្យតាំងឡើងបាន ទើបញ៉ាំងឥត្ថិន្ទ្រិយឲ្យកើតមានក្នុងបដិសន្ធិក្ខណៈ* **តស្មា** *ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភេទបុរសអន្តរធានបាត់ទៅ ព្រោះអកុសលកម្មមានកម្លាំងខ្លាំងក្លា ទើបភេទស្ត្រីកើតឡើងបាន ព្រោះកុសលកម្មទុព្វល*

ដូចវិសជ្ជនាមក ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យដែលពោលថា ភេទស្ត្រីដែលអន្តរធានបាត់ទៅនោះ ព្រោះអកុសលកម្មទុព្វល ។ អធិប្បាយថា ក្នុងកាលអកុសលកម្មដែលខ្លាំងក្លា មានការគប់រកដោយកិរិយារបស់អ្នកដទៃជាដើម ហាមនូវកិរិយាដែលញ៉ាំងបុរិសិន្ទ្រិយឲ្យកើតនោះ ប្រសិនបើអកុសលកម្មទុព្វលហើយ ពេលភេទស្ត្រីនឹងអន្តរធានបាត់ទៅនោះ ទើបអន្តរធានបាត់ទៅដោយកុសលកម្ម សមដូចពាក្យថា **បរទារិកត្ថាធិពលវអកុសល–កម្មេន ពាធិតត្តា ។បេ។ អន្តរធាតីតិ វុច្ចតិ** កុសលកម្មដែលទុព្វលនោះ ញ៉ាំងឥត្ថិន្ទ្រិយឲ្យកើតក្នុងបដិសន្ធិកាល មិនអាចញ៉ាំងបុរិសិន្ទ្រិយឲ្យកើតឡើងបានទេ ព្រោះហេតុអ្វី ព្រោះថា កុសលទុព្វល អកុសលមានកម្លាំងខ្លាំងក្លា មានការគប់រកកិរិយារបស់អ្នកដទៃជាដើមហាមឃាត់ ក៏មកក្នុងបវត្តិកាល កាលជាស្ត្រីនោះមានអំណាចឡើង ព្រោះកុសលកម្ម ដែលមានកម្លាំងដែលខ្លួនបានធ្វើមានការប្រព្រឹត្តនូវព្រហ្មចរិយធម៌ជាដើម ឬពោលដោយអំណាចនៃវិរតិចេតនា វៀរចាកកាមេសុមិច្ឆាចារ **បុរិសបត្ថនាវសេន វា** ឬដោយអំណាចនៃសេចក្តីប្រាថ្នាដើម្បីភាពជាបុរស អំណាចកុសលកម្ម

នោះនាំមក ទើបញ៉ាំងនូវបុរិសិន្ទ្រិយ ដ៏សមគួរដល់អំណាចរបស់ខ្លួន ឲ្យកើតឡើងក្នុងបវត្តិកាល អកុសលកម្មដែលជាអ្នកហាមមិនឲ្យបុរិសិន្ទ្រិយកើតឡើងនោះ បើទុព្វលភាពហើយ ភេទស្ត្រីកាលនឹងអន្តរធានបាត់ទៅ ដោយអកុសលកម្មដែលទុព្វលនាបវត្តិកាលនោះ ។ ព្រះមានព្រះភាគត្រាស់ថា ភេទបុរសកើតប្រាកដឡើងដោយកុសលកម្មមានកម្លាំង ព្រោះហេតុអ្វី ព្រោះថា បុរិសិន្ទ្រិយដែលកុសលកម្មមានកម្លាំងឲ្យកើតឡើង **អយំ ឆយោ** ន័យនេះ អ្នកប្រាជ្ញគប្បីជ្រាបក្នុងកិរិយាដែលកើតឡើងមានអំពីមុន ។ ប៉ុន្តែក្នុងបដិសន្ធិកាល មានសេចក្តីថា ភេទទាំងពីរ គឺភេទស្ត្រី និងភេទបុរសនឹងអន្តរធានបាត់ទៅនោះ ក៏អន្តរធានបាត់ទៅ ដោយអកុសលកម្មមានកម្លាំងខ្លាំងក្លា ទើបភេទបុរសអន្តរធានបាត់ទៅ ភេទស្ត្រីអន្តរធានបាត់ទៅនោះសោតក៏អន្តរធានបាត់ទៅដោយអកុសកម្មទុព្វល ទើបភេទស្ត្រីបាត់ទៅ ម្យ៉ាងទៀត ភេទបុរសដែលសត្វទាំងឡាយគប្បីបាន ក៏បានដោយកុសលមានកម្លាំង ឯភេទស្ត្រីនោះវិញ សត្វទាំងឡាយគប្បីបានក៏ដោយកុសលទុព្វល ទើបភេទស្ត្រីកើតប្រាកដឡើង ។ ពាក្យទាំងនេះ អាចារ្យអាស្រ័យនូវសុគតិភពហើយ ទើបពោលថា អាការដែលកើតឡើងនូវ

សេចក្តីវិនាសនៃភេទទាំងពីរនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានយ៉ាងនេះថា ភេទស្ត្រីកើតឡើងនោះ ក៏កើតដោយអកុសលដែលមានកម្លាំងខ្លាំងក្លា ។

**ឯត្ថ ច លិង្គំ ហត្ថាទិសណ្ឋានំ និមិត្តំ មិហិតាទិកំ កុត្តំ សុប្បាទិនា កីឡា អាកប្បា គមនាទិកំ** វារៈនេះនឹងបានវិនិច្ឆ័យក្នុងលក្ខណៈឥន្ទ្រិយទាំងពីរនេះ វិសណ្ឋាន មានសណ្ឋាននៃដៃ និងជើងជាដើម អ្នកប្រាជ្ញគប្បីជ្រាបថា ឈ្មោះថា **លិង្គ មិហិ-តាទិកំ** រីអាការមានកិរិយាដែលញញឹមញញែមជាដើមនោះ **និមិត្តំ** ឈ្មោះថា **និមិត្ត** អាការដែលលេងមានការលេងបាយឡុកបាយឡជាដើមនោះ ហៅថា **កុត្តៈ** ។ អាការផ្សេងៗ មានការដើរជាដើមនោះ ឈ្មោះថា **អាកប្បៈ** ជាកិរិយារបស់ស្ត្រី ឬរបស់បុរសទាំងឡាយ **បុរិសានំ មាតុគាមការោ មាតុគាមានញ្ច បុរិសការោ អត្ថិ** មួយទៀត សេចក្តីក្នុង **អដ្ឋកថាអនមតគ្គសំយុត្ត** ក្នុង **សំយុត្ត-និកាយ** ថា បុរសដល់ពេលកើតជាមាតុគ្រាម ក៏ក្លាយភេទទៅជាមាតុគ្រាមយ៉ាងនោះ ។ មួយវិញទៀត មាតុគ្រាមពេលកើតជាបុរស ក៏ក្លាយភេទទៅជាបុរសយ៉ាងនោះក៏មាន ។ មួយទៀត សត្វទាំងឡាយដែលត្រាច់រង្គាត់ទៅ នៅក្នុងសង្សារវដ្តនេះ ចេញចាកចក្រវាលនេះ

ហើយ ទៅកើតក្នុងចក្រវាលដទៃក៏មាន ។ ចេញចាកចក្រវាលដទៃ ហើយ មកកើតក្នុងចក្រវាលនេះក៏មាន ។ បើនឹងកំណត់ទារកអ្នកជាបុត្រតែមួយបៅដោះ ក្នុងកាលដែលកើតជាមនុស្ស ដែលមានឈ្មោះតែមួយ លើកលែងជាតិផ្សេងៗ ក្នុងកាលកើតជាមាតុគ្រាម ក្នុងចក្រ-វាលទាំងឡាយនោះៗ តែក្នុងមណ្ឌលចក្រវាលនេះ ទឹកដោះដែលខ្ញុំបៅក៏ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ នោះទៀត ។

ការពិត បុរសដែលមិនធ្លាប់កើតជាស្ត្រីនោះមិនមាន ឯស្ត្រីសោតដែលមិនធ្លាប់កើតជាបុរសនោះ ក៏មិនមានដែរ ។ ការពិតកាលបុរសប្រព្រឹត្តខុសក្នុងកិរិយារបស់អ្នកដទៃ លុះធ្វើកាលកិរិយាទៅហើយ ក៏នឹងទៅកើតក្នុងនរកប្រមាណពាន់ឆ្នាំដ៏ច្រើន ។ កាលរួចផុតពីនរកឡើងមកកើតជាមនុស្ស ក៏នឹងកើតជាស្រីរយជាតិជាកំណត់ ។ ព្រះអានន្ទត្ថេរ មានបារមីបំពេញប្រមាណមួយសែនកប្បហើយ កាលនៅត្រាច់រង្គាត់ក្នុងសង្សារវដ្ត ជាតិមួយ ទៅកើតនៅក្នុងត្រកូលជាងមាស ធ្វើនូវបរទារកកម្មហើយ ទើបទៅកើតក្នុងនរក ។ កាលរួចផុតចាកនរកឡើងមកកើតជាមាតុគ្រាម ជាបាទបរិចារិការបស់បុរសអស់ ១៥ ជាតិ ដោយអកុសលកម្មមានកម្លាំងដែលសេសសល់ផល

ពីនរក លោកត្រូវរងទុក្ខវេទនា **ពីជុទ្ធរណំ ចាបុណាំ** អកុសល នាំឲ្យលោកត្រូវគេក្រៀវអស់ ៧ ជាតិ ព្រោះការប្រព្រឹត្តខុសក្នុងកិរិយារបស់អ្នកដទៃ **ទានានីនិ បុញ្ញានិ កត្វា** កាលស្ត្រីទាំងឡាយធ្វើនូវបុណ្យ មានទានជាដើម ដោយការនឿយណាយចាកភេទស្ត្រី **អធិដ្ឋហិត្វា** គប្បីតាំងសេចក្តីប្រាថ្នាដើម្បីបានជាភេទបុរសថា **សំវត្តតុ** បុណ្យដែលខ្ញុំបានធ្វើគ្រានេះ សូមឲ្យខ្ញុំបានជាបុរស **កាលំ កត្វា** លុះធ្វើកាលកិរិយាហើយ ក៏គង់នឹងបាននូវអត្តភាពជាបុរសដូចការតាំងនូវសេចក្តីប្រាថ្នា ។ មួយទៀត រឿងរ៉ាវសោរេយ្យវត្ថុដែលសម្តែងទុកក្នុងអដ្ឋកថាធម្មបទថា **បតិទេវតា ហុត្វា** ភរិយាទាំងឡាយដែលតាំងនៅក្នុងនាទីរបស់ខ្លួន គោរពកោតក្រែងចំពោះស្វាមី ដូចគោរពចំពោះទេវតាហើយ ក៏គង់នឹងបាននូវអត្តភាពជាបុរស ដោយអំណាចបដិបត្តិដ៏ល្អចំពោះស្វាមី **តំ បន អនន្ត្តវេន អនុភូតំ** រីសេចក្តីទុក្ខវេទនាដែលព្រះអានន្ទបានទទួល អ្នកប្រាជ្ញគប្បីជ្រាបដោយសង្ខេបតែប៉ុណ្ណោះសិនចុះ ។

ដោយន័យដែលមានក្នុង *មហានារទកស្សបជាតក* ទើបមានពាក្យអះអាងទុកក្នុងទីនេះថា ក្នុងអតីតកាល ព្រះអានន្ទ ជាបុត្រ

របស់ជាងមាស ក្នុងក្រុងរាជគ្រឹះមហានគរ ទៅសេពគប់ជាមួយនឹង បាបមិត្រ ទើបធ្វើបរទារកម្ម លុះចុតិចាកជាតិនោះហើយ ផលរបស់ កុសលកម្មបានឱកាស ក៏បានមកកើតជាបុត្រទោលនៃត្រកូលសេដ្ឋី ដែលមានទ្រព្យ ៨០ កោដិ ក្នុងនគរកោសម្ពី **និច្ចំ សក្កតោ បូជិតោ ហោតិ** បានធ្វើនូវសក្ការបូជាបដិបត្តិជានិច្ច បានអាស្រ័យនូវកល្យាណ មិត្ត ទើបធ្វើនូវបុណ្យកុសលដ៏ច្រើន តែផលនៃបទារកម្មនោះបាន ឱកាសហើយ ក៏ចុតិអំពីជាតិនោះ កើតក្នុង **មហារោរុវនរក** ទទួល នូវសេចក្តីទុក្ខអស់កាលដ៏យូរអង្វែង **តតោ ចុតា** លុះចុតិចាក មហារោរុវនរកនោះហើយ កើតជាពពែមួយនៅក្នុង **ផេណកជ-ជនបទ** ។ បុត្ររបស់អមាត្យទាំងឡាយ ក្នុងជនបទនោះ ចាប់ពពែ នោះក្រៀវពោលថា ពពែមួយនេះ ពួកយើងក្រៀវរួចហើយ យល់ថា នឹងមានកម្លាំងខ្លាំងក្លាក្រៃលែង **អត្ថនោ ពាហនំ** បុត្ររបស់អមាត្យ ទាំងឡាយក៏ក្រៀវពពែនោះទៅ ឲ្យជាពាហនៈបរលេងតាមសប្បាយ ពពែនោះក៏បានទទួលនូវសេចក្តីទុក្ខជាអនេក **តតោ ចុតា** កាល ពពែនោះចុតិហើយ ក៏ទៅកើតក្នុងកំណើតជាស្វា អាស្រ័យនៅ ក្នុងព្រៃធំ ។ ក្នុងគ្រានោះ មេស្វាក៏នាំកូនរបស់ខ្លួនមកបង្ហាញដល់ស្វា

ដែលជាមេហ្វូង ក្នុងថ្ងៃដែលកើតដំបូង **សោ យូថបតិ** រីស្វាមេហ្វូងនោះ ក៏ហៅឲ្យចូលមកជិត ហើយចាប់កូនស្វាតូចនោះមិនឲ្យរើរួច កូនស្វាតូចនោះស្រែកយំទធាក់ដីទៅមក ស្វាមេហ្វូងក៏ខាំនូវអង្គជាតិរបស់កូនស្វាតូចនោះ ចោលដោយធ្មេញឲ្យដាច់ចេញ ហើយក៏លែងទៅ ។ កូនស្វាតូចនោះ ក៏សោយនូវទុក្ខវេទនាឈឺចាប់យ៉ាងខ្លាំងក្រៃលែង **តតោ ចុតា** កូនស្វានោះចុតិចាកជាតិនោះ ក៏ទៅកើតក្នុងកំណើតគោ នៅក្នុងជនបទមួយ ទើបម្ចាស់គោចាប់កូនគោនោះក្រៀវ ពោលថា គោនេះកាលបើអញក្រៀវវាហើយ នឹងបានជាទីពេញចិត្តរបស់អញ ។ កូនគោនោះក៏ទទួលនូវទុក្ខវេទនាដ៏ខ្លាំងក្លា **តតោ ចុតា** លុះចុតិចាកកំណើតគោកាលនោះហើយ **ឆបុំសកោ ហុត្វា ឆិព្វត្តិ** ក៏ទៅកើតជាខ្ទើយក្នុងត្រកូល អ្នកមានស្តុកស្តម្ភមួយ ក្នុងដែនវជ្ជី **សោ តតោ ចុតា** បន្ទាប់អំពីជាតិខ្ទើយហើយ កាលផលនៃបុញ្ញកម្មដែលខ្លួនបានធ្វើ កាលអំពីខ្លួនកើតជាសេដ្ឋីបុត្រនោះឲ្យឱកាស ដោយភាវៈកើតជាស្រីអប្សរ បានជាបាទបរិចារិការបស់ព្រះឥន្ទ្រនៅនាស្ថានតាវត្តិង្ស ។ លុះចុតិចាកជាតិនោះហើយ ក៏ទៅកើតស្រីអប្សរទៀត បានជាបាទបរិចារិការបស់ព្រះឥន្ទ្រម្តងទៀត ។ ប្រមាណអត្តភាព

២-៣ ជាកំណត់ **បញ្ចមេ អត្តភាវស្មឹ យេវ** លុះក្នុងជាតិអត្តភាពជាទី ៥ ការពិតកើតជាអគ្គមហេសីជវនទេវបុត្ត ក្នុងទេវលោកនោះ ។ក្នុងជាតិទី ៦ បានមកកើតជាព្រះរាជធីតារបស់ព្រះបាទអង្គតិរាជបរម-ក្សត្រដ៏ប្រសើរ នាក្រុងមិថិលាមហានគរ ដែលជាដែនវិទេហរាស្ត្រ ព្រះនាមថា នាងរុចារាជធីតា **អភិរូចា** រូបស្អាតក្រៃលែង គួរពិចពិលរមិលមើល ។ ក្នុងកាលនោះ ព្រះបាទអង្គតិរាជជាព្រះរាជបិតា **ចាសាទំ ការេត្វា** ក៏ញ៉ាំងជាងឲ្យសាងប្រាសាទ ៧ ជាន់ ព្រោះស្រឡាញ់បុត្រីខ្លាំងក្លាក្រៃលែង **ធាតីគណំ បរិវុត្តំ បរិវារញ្ច សាបេត្វា** ដែលពួកកីលៀងទាំងឡាយចោមរោមជាបរិវារ ស្ថិតនៅក្នុងប្រាសាទនោះ **ទិវសេ ទិវសេ ចាហេសិ** ហើយព្រះអង្គឲ្យជញ្ជូននូវប្រអប់មាសទាំងឡាយ ២៥ ប្រអប់ ដែលពេញទៅដោយផ្កាផ្សេងៗ សំពត់សាច់ម៉ដ្ឋ គ្រឿងប្រដាប់ផ្សេងៗ ទៀត មួយអន្លើ ដោយព្រះក្រយាស្ងោយ ប្រមាណមិនបាន ។ ព្រះរាជទានឲ្យដល់ព្រះរាជធីតារៀងរាល់ថ្ងៃ ។ មួយទៀតសោត ព្រះអង្គព្រះរាជទាននូវកហាបណៈមួយពាន់ៗ រាល់កន្លះខែ ដោយប្រាប់ថា ចូរបុត្រីកាន់យកនូវកហាបណៈនេះ ឲ្យទានដល់ពួកស្មូមយាចកទាំងឡាយចុះ **សា តំ**

**គហេត្វា** កាលបើព្រះរាជធីតា បានទទួលព្រះរាជទានទ្រព្យ ១០០០ កហាបណៈរាល់កន្លះខែម្ដងហើយ ព្រះនាងមានបញ្ញារឭកជាតិបាន ក៏រឭកដល់គំនរវេទនាដែលព្រះនាងបានទទួលមកអំពីកាលមុន ដោយបរទារកម្មមានកម្លាំង ទើបបានតាំងនូវសេចក្ដីប្រាថ្នាជាបុរស ហើយឲ្យទាន រក្សាសីល ជានិច្ចកាល **តតោ ចុតា** លុះចុតិចាកជាតិនោះ ក៏ទៅកើតជាទេវបុត្រមួយអង្គ មានអានុភាពច្រើននៅក្នុងតាវត្តិង្សទេវលោក ផុតចាកបាបកម្មដ៏អាក្រក់នោះ **សោ បង** លោកម្ចាស់អានន្ទ កាលនៅជាព្រះរាជធីតារុចានោះ បានប្រទានឱវាទអប់រំដល់មហាជន ដោយគាថាដូច្នេះថា

**យោ ឥច្ឆេ បុរិសោម ហោតុំ ជាតី ជាតី បុនប្បុនំ**
**បរទារំ វិវជ្ជេយ្យ ធោតបាទោវ កទ្ទមំ ។**
**យា ឥច្ឆេ បុរិសោ ហោតុំ ជាតី ជាតី បុនប្បុនំ**
**សាមិកំ អបចាយេយ្យ ឥន្ទំវ បរិចារិកា ។**

ក្នុងឱវាទនោះ មានសេចក្ដីថា ប្រុសណា ប្រាថ្នាឲ្យបានជាភេទប្រុសរាល់ៗ ជាតិ ត្រូវវៀរប្រពន្ធអ្នកដទៃ ដូចជាបុគ្គលមានជើងលាងហើយ វៀរបង់នូវភក់ ដូច្នោះ ។

ប្រការមួយទៀតថា ស្រីណា ប្រាថ្នាឲ្យបានជាប្រុសរាល់ៗ ជាតិ ត្រូវគោរពប្តី ដូចជាពួកស្រីអប្សរ ជាអ្នកបម្រើគោរពព្រះឥន្ទដូច្នោះ ។

**អយមេត្ថ បុមិត្ថិ បរិវត្តនកថា សង្គហានយោ** វិន័យ គឺធ្វើការសង្គ្រោះនូវការសម្តែងកិរិយាប្តូរភេទរបស់បុរស ឬស្ត្រីនេះ អ្នកប្រាជ្ញគប្បីជ្រាបក្នុងបទមាតិកាទាំងនេះចុះ ក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

បុមិត្ថិបរិវត្តនកថា ចប់

# ឥត្ថីវិភាវនកថា

**ឋីនំ វិភាវនត្ថំ ឥត្ថីនំ សរូបតោ វិភាវនំ តនេវ វេទិតព្វំ** *ឥឡូវនេះ នឹងសម្តែងនូវលក្ខណៈអធ្យាស្រ័យ សេចក្តីពេញចិត្តរបស់ស្ត្រីភេទ វីកិរិយាសម្តែងដោយសរុបនូវលក្ខណៈរបស់ស្ត្រីទាំងឡាយឈ្មោះថា ថីនវិភាវនាមួយប្រការ* **តំ ឃរ វិភាវនំ** *វីកិរិយានោះសម្តែងការពិត អ្នកប្រាជ្ញគប្បីជ្រាបដូច្នេះ* **ហិ** *ការពិត* **ឃសោ មាតុគាមោ ឆាម** *ឈ្មោះថា មាតុគ្រាម* **លោលោ ហោតិ** *កើតមានសេចក្តីល្មោភ ដោយភាវៈ ជាអ្នកមានសេចក្តីល្មោភ ៥ ប្រការ* **អាហារលោលតាយ** *គឺភាពល្មោភជាប់នៅក្នុងអាហារ ១* **អលង្ការលោលតាយ** *គឺភាពល្មោភជាប់នៅក្នុងគ្រឿងប្រដាប់តាក់តែង ១* **បរបុរិសលោលតាយ** *គឺភាពល្មោភចង់បានបុរសដទៃ ១* **ធនលោលតាយ** *គឺភាពល្មោភត្រូវការនូវទ្រព្យ ១* **ចាគលោលតា** *គឺភាពល្មោភពេញចិត្តត្រាច់ទៅខាងនេះខាងនោះ ១* **អញ្ញំ អលង្ការមលភមានោ** *កាលបើមាតុគ្រាមមិនបានតាក់តែងនូវខ្លួនដោយគ្រឿងប្រដាប់ដទៃហើយ ដោយកំណត់ ទីបំផុតញ៉ាំងសក់ឲ្យសើម ឲ្យ*

ជោកដោយទឹកក្ដៅ ក៏កក់ ឬលាងសក់ ផាត់មុខដោយគ្រឿងលម្អិត តុបតែងដូច្នោះ ទើបពោលថា ល្មោភក្នុងគ្រឿងតាក់តែង ។

**បរបុរិសលោលតាយ** មាតុគ្រាមតែងតែប្រាថ្នាចង់បាននូវបុរសដទៃ ដោយហោច សូម្បីតែកូនរបស់ខ្លួន ឲ្យចូលទៅក្នុងទីស្ងាត់ហើយ រំពឹងគិតដោយចិត្ត ដោយអំណាចនៃកិរិយាដែលនឹងសេពនូវអសទ្ធម្មជាដើមជាមួយនឹងខ្លួននោះ ។

**ធនលោលតាយ** មាតុគ្រាមតែងតែល្មោភ និងចង់បាននូវទ្រព្យ គឺចាប់សុវណ្ណហង្សបានទាំងមូលក្ដី ក៏ល្មោភហួសប្រមាណដកស្លាបសុវណ្ណរាជហង្សនោះ គ្រានោះ ទើបវិនាសចាកមាស ដែលជាលាភរបស់ខ្លួន ព្រោះថា ល្មោភច្រើនក្រៃលែង ។

**ធានលោលតាយ** ធម្មតា មាតុគ្រាមនេះ តែងតែពេញចិត្តដែលទៅកាន់ទីទាំងឡាយ មានសួនច្បារជាដើមជាធម្មតា **សព្វំ ធនំ វិនាសេតិ** រមែងញ៉ាំងទ្រព្យដែលមានមកអំពីមុន ឲ្យដល់នូវសេចក្ដីវិនាស ពាក្យទាំងនេះលោកអាចារ្យពោលទុកនៅក្នុង **អដ្ឋកថាធនិយ-**សូត្រ ក្នុង សុត្តនិបាត ។

**ហិ** ការពិត **បុព្វណ្ហសមយស្មិំ** ក្នុងពេលព្រឹក មាតុគ្រាម

រមែងប្រារព្ធដើម្បីនឹងធ្វើនូវការតាក់តែងទឹកដោះខាប់ជាដើម ឬការចម្អិនស្ងោរ អាំងមានប្រការផ្សេងៗ កាលបើបុគ្គលទាំងឡាយចូលទៅទូចសូម ក៏មិនប្រាថ្នាដើម្បីនឹងឲ្យ សូម្បីត្រឹមតែបន្តិចបន្តួច យ៉ាងនេះក៏ជាលក្ខណៈរបស់មាតុគ្រាម ១ **មជ្ឈន្តិកសមយេ បន** ក្នុងវេលាថ្ងៃត្រង់ មាតុគ្រាមខឹងច្រើន **អន្តោ ឃរេ** កាលបើមិនបានធ្វើនូវការឈ្លោះ ពីខាងក្នុងផ្ទះរបស់ខ្លួនហើយ **បដិវិស្សកំ ឃរំ គន្ត្វា...** ក៏ត្រាច់ទៅកាន់ផ្ទះមិត្តភក្តិ អ្នកជិតខាង ញ៉ាំងវិវាទផ្សេងៗឲ្យកើតឡើង មានប្រការផ្សេងៗ រួចហើយត្រឡប់មកវង់ចាំរវាំងសម្លឹងមើលនូវ ទីកន្លែងឈរ ទីកន្លែងអង្គុយរបស់ស្វាមីខ្លួន យ៉ាងនេះក៏ជាលក្ខណៈ របស់មាតុគ្រាម ១ **សាយណ្ហសមយេ បន** កាលបើវេលាល្ងាច ហើយ

ចិត្តរបស់មាតុគ្រាមនោះក៏បង្អោនទៅដើម្បីនឹងស្វែងរកនូវកិរិយា

សេពអសទ្ធម្មក៏ជាលក្ខណៈរបស់មាតុគ្រាម ១ ពាក្យទាំងនេះ លោកអាចារ្យពោលទុកក្នុង **អដ្ឋកថាមាតុគាមសំយុត្ត** នៅក្នុង គម្ពីរសំយុត្តនិកាយ ។

**មាតុគាមេសុ រញ្ជនវសេន បវត្តោ រាគោ ឆាម** *រី កិលេសដែលប្រព្រឹត្តទៅក្នុងមាតុគ្រាមទាំងឡាយ ដោយអំណាចនៃសេចក្តីត្រេកត្រអាលក្នុងកាមគុណ អ្នកប្រាជ្ញគប្បីជ្រាបថា ឈ្មោះថា រាគៈ* **សោ រាគោ** *រីកិលេស គឺរាគៈបែបនេះ កើតមានទូវតម្រេកក្នុងកិរិយារបស់ខ្លួនជាដើមនោះ* **អប្បសាវជ្ជោ** *មានទោសតិច មិនឲ្យបដិសន្ធិក្នុងអបាយភូមិឡើយ* **តស្មិំ សណិកំ វិរជន្តោ** *តែការមិនប្រាសចាកការនឿយណាយអំពីតម្រេកបែបនោះ មិនអាចនឹងលះបង់បានងាយៗ ទេ* **ឧសីឃំ មុញ្ចន្តោ** *នឹងលះបង់ ឲ្យរហ័សមិនបានងាយៗ ទេ* **ចិរំ អនុពន្ធតិ** *រមែងជាប់តាមសន្តានជារឿយៗ នឹងលះចេញអំពីចិត្តនោះជាការលំបាកអស់កាលយូរអង្វែង ។* **តេលមសិរាគោ វិយ** *ប្រៀបដូចសំពត់ ដែលជ្រលក់ដោយម្រ័ក្សណ៍ដោយជ័រ ដូច្នេះ* **ទ្វេ តីណិ ភវន្តរានិ គន្ត...** *។ តទៅភពដទៃអស់ ២-៣ ភពហើយ ទើបនឹងដល់នូវសេចក្តីវិនាស ទើបរបូតចេញចាក សន្តានរបស់ខ្លួន សេចក្តីនេះមានរឿងនិទានដូច្នេះ ជាពាក្យមិន យៀងឃ្លាតថា* **ឯកោ បុរិសោ ភាតុជាយាយ មិច្ឆា ចរតិ** *បុរសជា ប្អូនថ្លៃ*

បានប្រព្រឹត្តខុសចំពោះបងថ្លៃស្រី **សោ យេវ បិយតរោ** ការពិតបុរសជាប្អូននោះ ជាទីស្រឡាញ់របស់បងថ្លៃយ៉ាងក្រៃលែងជាងស្វាមីរបស់ខ្លួន **សា តំ អាហ** ទើបពោលជាមួយនឹងប្អូនថ្លៃថា ហេតុដែលធ្វើនូវកិច្ចបាចកំបាំងយ៉ាងនេះកើតប្រាកដហើយ ពាក្យគេនិន្ទាក៏នឹងមានច្រើនដល់យើងទាំងពីរនាក់ កុំបង្អង់យូរឡើយ **ភាតិកំ ឃាតេហិ** សូមអ្នកសម្លាប់បងប្រុសអ្នកចោលទៅ ។ បុរសនោះមានសេចក្ដីស្រឡាញ់បងប្រុសរបស់ខ្លួន ទើបពោលដោយពាក្យបញ្ឈឺចិត្តថា នែស្រីកំណាច នាងចូរវិនាសតែឯងចុះ កុំមកនិយាយពាក្យដូច្នេះតទៅទៀតឡើយ **សា តុណ្ហី ហុត្វា** ស្រីនោះក៏នៅស្ងៀមប្រមាណ ២-៣ ថ្ងៃ **បុន កថេសិ** ហើយពោលម្ដងទៀត គ្រានោះចិត្តរបស់ប្អូនថ្លៃនោះក៏ទ្រោមចុះ ក្នុងវារៈជាទី ៣ នេះ កាលបងថ្លៃមកក៏ពោលពិភាក្សាគ្នាថា យើងនឹងធ្វើដូចម្ដេច ទើបនឹងបាននូវឱកាសសម្លាប់បងប្រុស ។ ក្នុងលំដាប់នោះ ទើបកិរិយារបស់បងប្រុសប្រាប់ឧបាយថា សូមអ្នកធ្វើតាមពាក្យរបស់ខ្ញុំចុះ ។ ត្រង់ទីឯណោះមានកំពង់ទឹកមួយនៅទៀបដើមទន្លាមួយដើម **តត្ថ តិក្ខិណំ ឆណ្ឌក–វាសិំ គហេត្វា** សូមអ្នកកាន់ផ្គាក់ ទៅឈរចាំនៅត្រង់ដើមទន្លាធំ

នោះចុះ **សោ តថា អកាសិ** បុរសនោះក៏ធ្វើតាមបងថ្លៃ លុះវេលាល្ងាចបងប្រុសត្រឡប់មកពីធ្វើការមកកាន់ផ្ទះវិញ ឯភរិយានោះ ក៏ធ្វើជាមានចិត្តទន់ភ្លន់ រត់មកទទួល រួចហើយ ក៏ពោលថា **សាមិ** បពិត្រអ្នកជាម្ចាស់ អ្នកមកហើយ ត្រង់ក្បាលរបស់បងប្រឡាក់ដីច្រើនម៉្លេះ ហើយក៏ហុចកញ្ចប់លម្អិតផ្លែកន្ទួតព្រៃឲ្យ ហើយពោលលួងលោមថា សូមបងទៅកាន់កំពង់ទឹក ងូតទឹកដុសសម្អាតខ្លួនកក់ក្បាលឲ្យអស់ធូលីដែលប្រឡាក់នេះចេញ ។

**សោ តាយ វុត្តតិត្ថមេវ គន្ត្វា...** ។ ឯបុរសអ្នកជាស្វាមីនោះក៏តម្រង់ទៅកាន់កំពង់ទឹកដែលភរិយាប្រាប់ **ឧទកំ ឱរុយ្ហ** ចុះទៅកាន់កំពង់ទឹកឱនក្បាលចុះ ធ្វើការជម្រះក្បាលរបស់ខ្លួន ដោយលម្អិតកន្ទួតព្រៃ ។ ក្នុងខណៈនោះ បុរសជាប្អូនប្រុសក៏ចេញមកអំពីទីចន្លោះដើមទន្លានោះ ហើយក៏ប្រហារអំពីក្រោយខ្នងត្រង់-ករបស់បុរសបងប្រុសនោះដោយផ្គាក់ **ជីវិតា វោរោបេត្វា** ញ៉ាំងជីវិតដាច់ចុះហើយ ក៏ត្រឡប់ទៅកាន់ផ្ទះវិញ **ឥតរោ** បុរសជាបងប្រុសមិនទាន់ដាច់អាល័យក្នុងភរិយារបស់ខ្លួន ។ លុះធ្វើនូវកាលកិរិយា ក៏ទៅកើតជាពស់តុកកែធំមួយ នៅក្នុងផ្ទះនោះ ។ **សោ តស្ស ឋិតាយបិ**

**និសិន្នាយបិ គន្ត... ។ សរីរេ បតតិ** ពស់តុកកែនោះរត់ចុះរត់ឡើង ត្រង់ទីឈរ ទីអង្គុយរបស់ភរិយានោះ ហើយក៏ទម្លាក់ខ្លួនមកលើខ្លួន របស់ភរិយា ។ ក្នុងកាលនោះ ស្ត្រីនោះក៏យល់ប្រាកដថា ពស់តុកកែ នេះ ពិតជាស្វាមីចាស់របស់អញហើយ ក៏សម្លាប់ពស់តុកកែនោះ ចោលទៅ ។ ពស់តុកកែនោះ ក៏នៅតែមានសេចក្តីស្រឡាញ់យ៉ាងខ្លាំង ក្នុងស្ត្រីនោះដដែល ទើបកើតជាកូនសុនខតូចនៅនឹងផ្ទះនោះទៀត ។ តាំងអំពីកូនឆ្កែចេះរត់ហើយ កូនឆ្កែនោះក៏តែងតែដើរតាម រត់តាម ស្ត្រីនោះពីក្រោយ **អរញ្ញំ គច្ឆន្តិយា** កាលស្ត្រីនោះទៅកាន់ព្រៃ ក៏ដើរ ជាប់តាមទៅដែរ ។ មនុស្សទាំងឡាយឃើញហើយ ក៏សើចចំអកស្ត្រី នោះថា នែព្រានសុនខឯងចេញទៅកាន់ព្រៃស្វែងរកម្រឹគនៅក្នុងទី ណា ស្ត្រីនោះក៏មាននូវសេចក្តីខ្មាសអៀន ក្រោធហើយ ទើបសម្លាប់ សុនខនោះចោល សុនខនោះ នៅតែមានចិត្តស្រឡាញ់ក្នុងស្ត្រីនោះ ដដែល ក៏កើតជាកូនគោនៅផ្ទះនោះទៀត កាលគោធំហើយ ក៏ដើរតាម ស្ត្រីនោះពីក្រោយដូច្នោះទៀត មនុស្សទាំងឡាយក៏នាំគ្នាសើចចំអក ស្ត្រីនោះទៀតថា នាយគោបាលចេញទៅហើយ ហ្វូងគោទាំងឡាយនឹង ដើរទៅទីណាហ្ន៎ **សា ឥត្ថី** ទើបស្ត្រីនោះសម្លាប់គោនោះ **សោ គោណោ**

គោនោះមិនអាចកាត់នូវសេចក្តីស្រឡាញ់ចេញបាន ក៏ទៅកើតនៅក្នុងផ្ទៃរបស់ស្ត្រីនោះទៀត ។ ការពិត ក្នុងវារៈជាទី ៤ កើតជាកូនរបស់ស្ត្រីនោះ មានប្រក្រតីរឭកជាតិបាន ក៏ពិចារណាឃើញនូវភាវៈនៃខ្លួន ដែលត្រូវស្ត្រីនោះសម្លាប់ក្នុងអត្តភាពទាំង ៤ ជាតិដោយលំដាប់ គឺជាតិជាស្វាមីមួយជាតិ ជាតិជាពស់តុកកែមួយជាតិ ជាតិជាសត្វសុនខមួយជាតិ ជាតិជាសត្វគោមួយជាតិ ។ ទើបគិតថាឥឡូវនេះ អាត្មាអញមកកើតក្នុងផ្ទៃស្ត្រីជាសត្រូវដូច្នេះទៀត **តតោ បដ្ឋាយ** ចាប់ផ្តើមអំពីនោះមក ក៏មិនឲ្យស្ត្រីនោះចាប់កាន់នូវកាយរបស់ខ្លួនដោយដៃរបស់ស្ត្រីនោះឡើយ ។ ក្នុងគ្រានោះ ជីដូនរបស់ទារកនោះចិញ្ចឹម រក្សាថែទាំ រហូតដល់ធំឡើង ។ ទើបជីតាពោលជាមួយនឹងចៅថា **តាត** នៃចៅ ហេតុអ្វី ទើបចៅមិនឲ្យម្តាយចាប់កាន់ដោយដៃដូច្នេះ ។ **សចេ តំ សា ផុស្សតិ** ប្រសិនបើម្តាយរបស់ចៅចាប់កាន់បី-ពហើយ ចៅតែងតែស្រែកយំដោយសំឡេងខ្លាំងៗ ពេលណាម្តាយមិនបី-ព ចៅក៏មិនយំ **អយ្យកេន បុដ្ឋោ** កាលក្មេងតូចនោះត្រូវជីតាសួរដូច្នេះ ទើបប្រាប់ថា **ឯសា ឥត្ថី** ស្ត្រីនេះមិនមែនជាម្តាយរបស់ខ្ញុំទេ **បច្ចាមិត្តា ឯសា** ស្ត្រីនេះជាសត្រូវរបស់ខ្ញុំ

**សព្វំ តំ បវុត្តិំ អារោចេសិ** *ហើយប្រាប់នូវរឿងរ៉ាវទាំងឡាយតាំងអំពីដើម ឲ្យជីតាស្តាប់គ្រប់ប្រការ* **សោ តំ អាលិង្គិត្វា** *ជីតានោះក៏ក្រសោបឱបចៅ ហើយក៏កើតនូវសេចក្តីសង្វេគថា* **ឯហិ តាត** *នែចៅអើយ អ្នកចូរមកចុះ យើងរស់នៅទីនេះធ្វើអ្វី នៅក្នុងទីនេះប្រកបដោយសត្រូវដូច្នេះ យ៉ាងនេះ ប្រយោជន៍អ្វីដោយភាពជាគ្រហស្ថ* **តំ អាទាយ និក្ខមិត្វា** *ទើបនាំចៅចេញអំពីផ្ទះ តម្រង់ទៅកាន់ព្រះវិហារ* **ឧភោបិ ជនា** *ជីតា និងចៅនោះ ក៏បួសនៅក្នុងព្រះពុទ្ធសាសនា* **អរហត្តំ ចាបុណឹសុ** *ធ្វើសេចក្តីព្យាយាម មិនយូរប៉ុន្មាន ក៏សម្រេចអរហត្តផល* **ឥទំ បន អង្គុត្តរតិកវណ្ណនាយំ វុត្តំ** *រឿងនេះព្រះអដ្ឋកថាចារ្យពោលទុកក្នុង* ***អដ្ឋកថាអង្គុត្តរនិកាយ តិកនិបាត*** *ដើម្បីនឹងឲ្យឃើញនូវសេចក្តីថា កាមច្ឆន្ទៈដែលមានសភាពនឹងលះចេញចាកសន្តាននោះយឺតយូរច្រើនជាតិយ៉ាងនេះ ដើម្បីឲ្យបុគ្គលទាំងឡាយកើតការសង្វេគក្នុងចិត្តរបស់ខ្លួន ។*

**កាមា ហិ ឆាមេតេ ឯវំ អាទីនវា** *ការពិត វីកាមគុណទាំងឡាយនោះ រមែងប្រកបទៅដោយទោសបែបនេះ ពាក្យដែលពោលមកនោះ ក៏សមដូចព្រះបាលីដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះ*

**អដ្ឋិកង្គលូបមា កាមា** សេចក្ដីប្រាថ្នាក្នុងវត្ថុកាម និងកិលេសកាម នោះ ឧបមាដូចរាងឆ្អឹង គ្មានខ្លួរ គ្មានរសជាតិ ដោយការៈមានសុខតិច **មំសបេសូបមា កាមា** មួយទៀត ឧបមាដូចដុំសាច់ ដោយសភាព ជាសាធារណៈ ទូទៅដល់សត្វទាំងឡាយ **តិណុក្កូបមា កាមា** មួយទៀត ឧបមាដូចគប់ស្មៅ ដែលឆេះសន្ធោសន្ធៅមានអណ្ដាត ភ្លើង ដោយសភាពក្ដៅរឿយៗ **អង្គារកាសូបមា កាមា** មួយទៀត ឧបមាដូចរងើកភ្លើង ដោយសភាពប្រែកគួរខ្លាច **សុបិនក្កូបមា កាមា** មួយទៀត ឧបមាដូចការយល់សុបិន ដោយសភាពមិនជារបស់កើត ប្រាកដ មិនស្ថិតស្ថេរឡើយ **យាចិក្កូបមា កាមា** មួយទៀត ឧបមាដូចរបស់ខ្ចីគេ **រិសរុក្ខផលូបមា កាមា** មួយទៀត ឧបមា ដូចផ្លែឈើមានពិស ដោយអត្ថថា គឺឲ្យខូចនូវអវយវៈតូចធំ និង ធ្វើឲ្យសោកសៅ **អសិសូលូបមា កាមា** មួយទៀត ឧបមាដូច ដាវ និងលំពែងដ៏មុត **សត្តិលូបមា កាមា រិជិរិជ្ឈនដ្ឋេន** មួយ ទៀត ឧបមាដូចលំពែងដ៏មុត ដោយអត្ថថា នឹងចាក់ដោតឲ្យលំបាក រីសេចក្ដីប្រាថ្នាក្នុងកាមគុណទាំងឡាយនោះ អ្នកប្រាជ្ញគប្បីជ្រាបថា រាគៈ គឺសេចក្ដីត្រេកត្រអាល ។ ឈ្មោះថា ឆន្ទៈ គឺសេចក្ដីប្រាថ្នា

ដើម្បីនឹងធ្វើ ព្រោះញុាំងបុគ្គលឲ្យរីករាយ ត្រេកអរ ។ ឈ្មោះថា **បេមៈ** គឺការពេញចិត្ត ដោយអត្ថថា ញុាំងសេចក្តីស្រឡាញ់ឲ្យកើត ។ ឈ្មោះថា សេចក្តីចង់បាន ដោយអត្ថថា មានសេចក្តីប្រាថ្នាដើម្បីនឹងបរិភោគ ។ **បរិឡាហោ** ឈ្មោះថា សេចក្តីក្រវល់ក្រវាយ ដោយអត្ថថា នឹងដុតរឿយៗ គឺតណ្ហាតែមួយ មានលក្ខណៈផ្សេងៗគ្នាយ៉ាងនេះ ហេតុដូច្នោះ ទើបមនុស្សទាំងឡាយ ប្រព្រឹត្តនៅក្នុងនិពន្ធវត្ថុ ការពិត គឺបរិភោគនូវបញ្ចកាមគុណជានិច្ច **យត្ថ បដិពទ្ធចិត្តា** មនុស្សទាំងឡាយមានចិត្តពាក់ព័ន្ធនៅក្នុងមាតុគ្រាមណា **សតម្បិ សហស្សម្បិ ទត្វា** ក៏ព្រមឲ្យនូវទ្រព្យ ១០០ ខ្លះ ១០០០ ខ្លះ **តមេវ មាតុគាមំ អានេត្វា** នាំមកនូវមាតុគ្រាមនោះ **និពទ្ធភោគំ ភុញ្ជន្តិ** ប្រើប្រាស់ (បរិភោគ) នូវមាតុគ្រាមតាមសេចក្តីប្រាថ្នា ។

**ឯកច្ចេ ទេវា ចាតុម្មហារាជិកតោ បដ្ឋាយ** មួយទៀត ទេវតាទាំងឡាយពួកខ្លះ ដែលនៅក្នុងជាន់ចាតុម្មហារាជិកាទេវលោកនោះ ក៏ប្រព្រឹត្តទៅក្នុងទិព្វវត្ថុ បរិភោគនូវបញ្ចកាមគុណដូចគ្នានឹងមនុស្ស អ្នកប្រាជ្ញគប្បីជ្រាបក្នុងរឿងរ៉ាវរបស់បញ្ចសិខទេវបុត្រ សព្វសត្វទាំងឡាយនេះ លើកលែងតែសត្វក្នុងនរក សត្វទាំង

ឡាយក្នុងអបាយភូមិដ៏សេសក្តី ក៏ប្រព្រឹត្តទៅក្នុងកាមកិលេសទាំងអស់ ។ អធិប្បាយថា មច្ឆាជាតិទាំងឡាយក៏មានសេចក្តីត្រេកត្រអាលដោយមេមច្ឆាជាតិនៃខ្លួន អណ្តើកទាំងឡាយក្តី ក៏មានសេចក្តីត្រេកត្រអាលដោយមេអណ្តើករបស់ខ្លួន គឺសត្វទាំងឡាយមានសត្វតិរច្ឆានក្តី ប្រេតទាំងឡាយក្តី អសុរកាយទាំងឡាយក្តី ក៏មានសេចក្តីត្រេកត្រអាលដូចគ្នា **តស្មា** ព្រោះហេតុនោះ សត្វទាំងឡាយតាំងអំពីអបាយភូមិ លើកលែងតែសត្វក្នុងនរក រហូតដល់ជាន់តុសិត សត្វទាំងឡាយសុទ្ធតែបានឈ្មោះថា មានសេចក្តីប្រាថ្នាបញ្ចកាមគុណនោះប្រាកដច្បាស់ **និម្មានរតី ឯតេ សន្តិ និម្មានរតិនោ** ទេវតាទាំងឡាយ ក្នុងជាន់និម្មានរតីនោះផ្សេងគ្នា បន្តិចបន្តួច ទេវតាទាំងឡាយឈ្មោះថា និម្មានរតី មានសេចក្តីត្រេកអរចំពោះរូបនិមិត្ត ទើបឈ្មោះថា និម្មានរតី ។

**ឯវំ តេ កិរ នីលបីតាទិវសេន យាទិសំ យាទិសំ រូបំ ឥច្ឆន្តិ តាទិសំ តាទិសំ រូបំ និមិត្វា វសេនតិ រមេនតិ បរេហិ និម្មិតេ កាមេ វសំ វត្តេន្តិ បរនិម្មិតវសវត្តិនោ តេសំ មនំ ញត្វា បរេ យថា រុចិតំ កាមភោគំ និម្មិនន្តិ តេ តត្ថ វសំ**

**វត្តេន្តិ** មានពាក្យមិនឃ្លៀងឃ្លាតក្នុងទីនេះថា ទេវតាទាំងឡាយក្នុងជាន់និម្មានរតីនោះ ប្រាថ្នានូវរូបបែបណា ដោយអំណាចរូបពណ៌ខៀវ ពណ៌លឿងជាដើម ទេវតាទាំងឡាយនោះ **និម្មិតា** និម្មិតហើយ **តានិសំ រូបំ** នូវរូបទាំងឡាយផ្សេងៗ បែបនោះហើយត្រេកអររីករាយនូវរូបនិម្មិតនោះតាមសេចក្ដីប្រាថ្នា **បរេហិ និម្មិតេ** ប៉ុន្តែទេវតាទាំង-ឡាយក្នុងជាន់បរនិម្មិតវសវត្តីនោះ រមែងញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅក្នុងបញ្ចកាមគុណ ដែលទេវតាទាំងឡាយដទៃនិម្មិតឲ្យ ហេតុដូច្នោះទើបទេវតាទាំងឡាយឈ្មោះថា បរនិម្មិតវសវត្តី **តេសំ មនំ ញត្វា** ទេវតាអន្តដទៃទាំងឡាយ ជ្រាបនូវទឹកចិត្តរបស់ទេវតាទាំងឡាយនោះជ្រាបថា ទេវតាទាំងឡាយពេញចិត្តរូបស្រីទេពអប្សរយ៉ាងនោះ **យថា រុចិតំ តំ កាមភោគំ** ក៏និម្មិតស្រីទេពអប្សរយ៉ាងនោះឡើង ដោយសមគួរដល់ការគាប់ចិត្ត ទេវតាទាំងឡាយឃើញនូវរូបស្រីទេពអប្សរ ដែលទេវតាទាំងឡាយដទៃនិម្មិតឲ្យហើយ **តត្ថ វសំ វត្តេន្តិ** ក៏ញ៉ាំងអំណាចរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងរូបទាំងឡាយនោះ ។

**កថំ តេ បរស្ស មនំ ជានន្តិ** ព្រះអដ្ឋកថាមានពាក្យសួរថា ហេតុដូចម្តេច ទើបទេវតាទាំងឡាយ ជ្រាបនូវទឹកចិត្តរបស់ទេវតាទាំងឡាយនោះ ?

លោកអាចារ្យអ្នកដឹងនូវសេចក្តី ទើបឆ្លើយថា ដឹងជាធម្មតា ។ អធិប្បាយថា **សូទោ** វិចុងភៅអ្នកធ្វើនូវសូបព្យញ្ជនៈ ( ព្រះក្រយាបាយ សម្ល ) ដ៏មានរសជាតិ ថ្វាយព្រះរាជាឲ្យព្រះអង្គសព្វព្រះហឫទ័យដោយវត្ថុណា ៗ **តំ តំ ជានាតិ** ក៏ដឹងនូវសូបព្យញ្ជនៈនោះ ៗ ហើយក៏ចាត់ចែងតាក់តែងថ្វាយដល់ព្រះរាជាឲ្យសព្វព្រះរាជហឫទ័យ យ៉ាងណាក្តី **ឯវំ បកតិយា អភិរុចិតារម្មណំ ញត្វា** ទេវតាទាំងឡាយជ្រាបនូវអារម្មណ៍ ដែលជាទីពេញចិត្តដល់ទេវតាទាំងឡាយអ្នកមាននូវសេចក្តីប្រាថ្នាស្រីទេពអប្សរ និងចង់បរិភោគនូវកាមគុណនោះដោយប្រក្រតី ហើយក៏និម្មិតនូវបញ្ចកាមគុណឲ្យបរិភោគដូច្នោះ **ឯវំ** ដូច្នេះ **តថា** ក៏មានសេចក្តីឧបមេយ្យដូច្នោះ ។ **តេ តត្ថ វសំ វត្តេន្តិ** កាលបើទេវតាទាំងឡាយដទៃជ្រាបទឹកចិត្ត ក៏និម្មិតថ្វាយ ហើយទេវតាទាំងឡាយនោះ ក៏ញ៉ាំងអំណាចរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងបញ្ចកាម-គុណនោះ **មេថុនសេវនាទិវសេន** ទេវតាទាំងឡាយតែងតែបរិភោគ

នូវបញ្ចកាមគុណទាំងឡាយ ដោយអំណាចនៃកិរិយាសេពនូវមេថុន ជាដើម ។

**កោចិ បន** អាចារ្យខ្លះពោលថា ទេវតាទាំងឡាយជាន់ខ្ពស់ខាងលើនោះ នឹងបរិភោគនូវកាមគុណដោយអំណាចសេពនូវមេថុនធម្ម ដូចជាមនុស្សទាំងឡាយមិនមាន **ហសិតមត្តេន វា** ដោយត្រឹមតែសើចញញឹមប៉ុណ្ណោះ ក៏ជាការសម្រេចកិច្ចកាមគុណម្យ៉ាងទៀត ត្រឹមតែសម្លឹងមើលនូវរូបស្រីទេពអប្សរប៉ុណ្ណោះ ក៏សម្រេចកិច្ចក្នុងកាមគុណ **អាលិង្គិតមត្តេន វា** ម្យ៉ាងទៀត ត្រឹមតែប៉ះពាល់ចាប់កាន់ឱបថើបប៉ុណ្ណោះ ក៏សម្រេចកិច្ចក្នុងកាមគុណ **ហត្ថគហណ-មត្តេន វា** មួយទៀត ត្រឹមតែចាប់កាន់ដៃជើងប៉ុណ្ណោះ ក៏សម្រេចកិច្ចក្នុងកាមគុណ **តំ អដ្ឋកថាណយំ ឃរំ ឆត្តីតិ បដិក្ខិត្តំ** ពាក្យរបស់កេចិអាចារ្យទាំងឡាយ ព្រះអដ្ឋកថាចារ្យទាំងឡាយហាមឃាត់ថា **ឃរំ ឆត្តិ** ដែលនឹងសម្រេចកាមកិច្ចបាន ដោយកិរិយាត្រឹមតែញញឹមនិងសម្លឹងមើល ប៉ះពាល់ ចាប់កាន់ឱបថើបនោះមិនមានទេ អធិប្បាយថា កាមមេថុនធម្មនេះ ប្រសិនបើមិនបានប៉ះពាល់ ចាប់កាន់ដោយកាយនិងកាយហើយ ក៏មិនអាចញ៉ាំងកាមកិច្ចឲ្យសម្រេចដោយរហ័សបាន

*ព្រោះដូច្នោះ ទេវតាទាំងឡាយក្នុងឆកាមាវចរសួគ៌នោះ បរិភោគនូវកាមគុណជាប្រក្រតីប្រាកដ ដូចមនុស្សទាំងឡាយដោយពិត ឈ្មោះថា* **សព្វកាមសមង្គី** *គឺទេវតាទាំងឡាយក្នុងឆកាមាវចរនោះ មានគ្រឿងបញ្ចកាមគុណបរិភោគសព្វយ៉ាង អាយុទាំងឡាយទាំងពួងក៏កើតជាចំណែកមួយ* **ឥធម្បន ឥតិវុត្តកវណ្ណនាយញ្ច ទីឃនិកាយេ សង្គីតិសុត្តវណ្ណនាយញ្ច វុត្តន្តិ វេទិតព្វំ** *ពាក្យនេះអ្នកប្រាជ្ញគប្បីជ្រាបថា លោកអាចារ្យបានពោលទុកនៅក្នុង អដ្ឋកថាខុទ្ទកនិកាយ ឥតិវុត្តកៈ ឧប្បត្តិសូត្រ និងអដ្ឋកថាសង្គីតិសូត្រ ក្នុងទីឃនិកាយ ។*

*ព្រះបាលីក្នុង គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត តតិយភាគ សម្តែងថា* **អាកង្ខេយ្យុំ ចេ គហបតយោ ឧភោ ជានិបតយោ ទិដ្ឋេ ចេវ ធម្មេ អញ្ញមញ្ញំ បស្សិតុំ អភិសម្បរាយញ្ច អញ្ញមញ្ញំ បស្សិតុំ ។** *ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី និងគហបតានីទាំងឡាយ បើជនទាំងពីរនាក់ប្តីប្រពន្ធ ប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ទើបជួបគ្នាក្នុងបច្ចុប្បន្ននេះផង ជួបគ្នាក្នុងបរលោកផង ។*

**វិភង្គវណ្ណនាយំ វុត្តំ** មួយទៀត នៅក្នុង ព្រះអដ្ឋកថាវិភង្គ ថា **ឥត្ថិយោ ច ឥធ ខោ ឈានំ ភាវេត្វា** ស្រីភេទទាំងឡាយក្នុង លោកនេះ ចម្រើនឈានសមាបត្តិបានហើយ **កាលំ កត្វា** កាលបើ ធ្វើកាលកិរិយាហើយ **ឧប្បជ្ជន្តិ** ក៏កើតបានត្រឹមតែព្រហ្មជាន់បារិ- សជ្ជា មិនអាចកើតដល់ជាន់មហាព្រហ្មបានទេ ។ ព្រហ្មទាំងឡាយ នោះមានសណ្ឋាន ដូចសណ្ឋានបុរស គ្មានរូបសណ្ឋានជាស្រី ឡើយ **ឥធមេតុ យុវត្តីធំ សរូបវិភាវនំ** សម្តែងមកក្នុងបទមាតិកា ពោលដោយស្ត្រី ក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

ឥត្ថីវិភាវនកថា ចប់

# បណ្ឌកានំទិភាវនកថា

ឥឡូវនេះ នឹងបានវិនិច្ឆ័យក្នុងបទមាតិកា ពោលដោយបណ្ឌកៈតទៅ បក្ខោបក្កមិកាសិត្តា ឧស្សុយោ បង បណ្ឌកោ ឆំបុសកេង បញ្ចេតេ បណ្ឌកា បរិឌីបិតា រីបណ្ឌកៈទាំងឡាយនោះ មាន ៥ ប្រការ បក្កមិបណ្ឌកៈ ១ ឱបក្កមិបណ្ឌកៈ ១ អាសិត្តបណ្ឌកៈ ១ ឧស្សុយោបណ្ឌកៈ ១ នបុំសកបណ្ឌកៈ ១ ។ បណ្ដាបណ្ឌកៈទាំង ៥ ប្រការនោះ យោ បុគ្គលោ រីបុគ្គលណាកើតជាបណ្ឌកៈខាងរនោច គឺឲ្យកើតមាននូវសេចក្ដីខ្វល់ខ្វាយខ្លាំង ដោយអានុភាពនៃអកុសលវិបាក លុះដល់ខាងខ្នើត តម្រេកត្រេកត្រអាលក៏ស្ងប់រម្ងាប់ទៅ បុគ្គលនេះឯង ឈ្មោះថា បក្ខបណ្ឌក ព្រោះមាននូវតម្រេកត្រេកត្រអាលតែខាងរនោច ។

យស្ស ឧបក្កមេង ពីជានិ អបនីតានិ រីពូជទាំងឡាយនៃបុរសណា អបនីតានិ ដែលគេនាំចេញហើយ បុគ្គលនេះឯង បានឈ្មោះថា ឱបក្កមិបណ្ឌក។

យស្ស បរេសំ បុគ្គលណាកើតមាននូវសេចក្ដីតម្រេក មាន

សេចក្ដីខ្វល់ខ្វាយអន្ទះអន្ទែងកើតឡើងហើយ យកមាត់បៀមនូវអង្គជាតិនៃបុរសទាំងឡាយដទៃ លេបនូវទឹកអសុចិ ទើបស្ងប់រម្ងាប់សេចក្ដីក្រវល់ក្រវាយអន្ទះអន្ទែងទាំងអស់នោះបាន បុគ្គលនេះឯងឈ្មោះថា **អាសិត្តបណ្ឌក**។

**យស្ស បរេសំ អជ្ឈាចារំ បស្សតោ** បុគ្គលណាឃើញនូវការប្រព្រឹត្តតាមអធ្យាស្រ័យរបស់បុគ្គលដទៃទាំងឡាយហើយ កើតមាននូវការប្រណៃន សេចក្ដីខ្វល់ខ្វាយរបស់ខ្លួននោះ ក៏ស្ងប់រំម្ងាប់ក្នុងកាលឃើញនោះឯង បុគ្គលនេះឯងឈ្មោះថា **ឧស្សូយបណ្ឌក**។

**យោ បដិសន្ធិយំ យេវ** បុគ្គលណា មិនមានឥត្ថីភាវរូប មិនមានបុរិសភាវរូបក្នុងបដិសន្ធិកាល កើតមកមិនមែនជាស្ត្រី មិនមែនជាបុរស ភេទស្ត្រី ភេទបុរសនោះ មិនប្រាកដទេ បុគ្គលនេះឯងបានឈ្មោះថា **នបុំសកបណ្ឌក** គឺខ្ទើយអំពីកំណើត ។

**ឧភតោព្យញ្ជនំ** វឺឧភតោព្យញ្ជនៈទាំងពីរកើតប្រាកដមានដល់បុគ្គលណា បុគ្គលនោះបានឈ្មោះថា **ឧភតោព្យញ្ជនក** ព្រោះថាកម្មដែលនឹងញុំាងឥត្ថីភាវនិមិត្តឲ្យកើតនោះក៏មាន ដែលនឹងញុំាងបុរិ-សភាវនិមិត្តឲ្យកើតនោះក៏មាន នឹងជាស្ត្រីក៏បាន នឹងជាបុរសក៏បាន

មានទាំងពីរភេទ ហេតុដូច្នោះ ទើបឈ្មោះថា ឧភតោព្យញ្ជនក។

**សោ ទុវិធោ ហោតិ** ឧភតោព្យញ្ជនកៈនោះ មាន ២ ពួក ឈ្មោះថា **ឥត្ថីឧភតោព្យញ្ជនកៈ** ១ ពួក ឈ្មោះថា បុរិសុភតោព្យញ្ជនកៈ ១ ពួក ។ ឥត្ថីឧភតោព្យញ្ជនកៈនោះ ញុំាងអធ្យាស្រ័យឲ្យស្រឡាញ់ស្ត្រីទាំងឡាយ កាលនឹងស្វែងរកស្ត្រីទាំងឡាយ ធ្វើអជ្ឈាចារនោះ ឥត្ថីនិមិត្តរបស់ខ្លួនក៏បាត់ទៅ បុរិសនិមិត្តក៏ប្រាកដចេញមក ទើបធ្វើការស្រឡាញ់ស្ត្រីទាំងឡាយបាន បុរិសុភតោព្យញ្ជនកៈនោះ ដល់ពេលដេកជាមួយនឹងបុរសទាំងឡាយហើយ បុរិសនិមិត្តរបស់ខ្លួនក៏បាត់ទៅ ឥត្ថិនិមិត្តក៏កើតប្រាកដឡើង ឲ្យបុរសទាំងឡាយសេពតាមអធ្យាស្រ័យ ។

ម្យ៉ាងទៀត ឥត្ថីឧភតោព្យញ្ជនកៈនោះ ខ្លួនឯងមានគភ៌ដោយបុរសទាំងឡាយបាន ញុំាងស្ត្រីទាំងឡាយដទៃឲ្យមានគភ៌ឡើងដោយខ្លួនឯងក៏បាន បុរិសុភតោព្យញ្ជនកៈនោះ ខ្លួនឯងមិនមានការតាំងគភ៌ទេ ប៉ុន្តែញុំាងស្ត្រីទាំងឡាយដទៃឲ្យតាំងគភ៌បានដែរ ។ ឥត្ថីឧភតោព្យញ្ជនកៈ និងបុរិសុភតោព្យញ្ជនកៈនេះ មានឧទាហរណ៍ផ្សេងគ្នាដូច្នេះ **វុត្តមេតំ វិនយដ្ឋកថាយំ** ពាក្យទាំងនេះលោកអាចារ្យពោលទុកក្នុង អដ្ឋកថាព្រះវិន័យ ។

**អយមេត្ថ ដីកា** ក្នុងដីកានោះពន្យល់ថា ឧភតោ-ព្យញ្ជនកៈដូច្នេះ មានឥន្ទ្រិយតែមួយ ឬមានឥន្ទ្រិយពីរ ? វិសជ្ជនាថា មានឥន្ទ្រិយមួយ មិនមានឥន្ទ្រិយពីរ កើតក្នុងសន្តានតែមួយឡើយ ឥន្ទ្រិយតែមួយកើតអំពីឥត្ថីឧភតោព្យញ្ជនកៈ បុរិសិន្ទ្រិយក៏ដូចគ្នា កើតមានដល់បុរិសុភតោព្យញ្ជនកៈ តែឥត្ថីឧភតោព្យញ្ជនកៈនឹងទៅជាភេទប្រុសក៏បាន បុរិសុភតោព្យញ្ជនកៈនឹងជាស្ត្រីក៏បាន តែភេទទាំងពីរនេះតាំងនៅជានិច្ចរកមិនបានឡើយ ។

ទើបមានពាក្យចោទសួរថា បើភេទស្ត្រីក៏មិនតាំងនៅ ភេទបុរសក៏មិនតាំងនៅដូច្នោះហើយ ភេទស្រី ភេទប្រុសនៃឧភតោព្យ-ញ្ជនកៈនោះ ក៏មិនគួរនឹងពោលថា មានពីរឡើយ ភេទស្រី ភេទប្រុស នៃឧភតោព្យញ្ជនកៈទាំងពីរពួកនោះ មានដោយពិត ។

អធិប្បាយថា ឥន្ទ្រិយមួយជាហេតុនៃភេទស្ត្រី ភេទបុរស កាលឥន្ទ្រិយមានហើយ ក៏ជាហេតុនៃភេទស្ត្រី ។ កាលបុរិសិន្ទ្រិយកើតហើយ ក៏ជាហេតុនៃភេទបុរស ។ ប្រសិនបើឥត្ថីឧភតោព្យញ្ជនកៈកើតតម្រេកត្រេកត្រអាល ចង់រួមរក្សជាមួយនឹងស្ត្រីហើយ បុរិស-ព្យញ្ជនកៈក៏ប្រាកដមានមក ញុំាងកិច្ចឲ្យសម្រេចបាន ។ ឥត្ថីព្យញ្ជនកៈរបស់ខ្លួននោះក៏បាត់ទៅ ។ មួយ៉ាងទៀត បុរិសុភតោព្យញ្ជនកៈនោះ

កាលបើកើតមានសេចក្ដីត្រេកត្រអាល ចង់ឲ្យបុរសរួមរក្សជាមួយនឹងខ្លួនហើយ ឥត្ថីព្យញ្ជនកៈនោះក៏ប្រាកដមានមក ឲ្យបុរសធ្វើការរួមរក្សជាមួយនឹងខ្លួន (ដោយភេទស្ត្រីរបស់ខ្លួនដែលកើតប្រាកដមានមកនោះ) ឥន្ទ្រិយរបស់ឥត្ថីឧភតោព្យញ្ជនកៈ និងបុរិសុភតោព្យញ្ជនកៈទាំងឡាយនោះ ក៏ជាហេតុនៃទុតិយព្យញ្ជនកៈដោយប្រការ ដូច្នេះ ។ ទើបព្យញ្ជនកៈទាំងឡាយនោះមានប្រាកដបានគ្រប់ពេល តែមិនតាំងនៅទៀងក្នុងភេទមួយឡើយ **តស្មា** ព្រោះហេតុនោះ អ្នកប្រាជ្ញគប្បីជ្រាប ដោយប្រការដូច្នេះថា រាគចិត្តនោះ មិនជាហេតុនៃព្យញ្ជនកៈឡើយ តែថាជាហេតុក្នុងឧភតោព្យញ្ជនកៈទាំងពីរនេះ គឺឥន្ទ្រិយតែមួយកើតឡើង ឧភតោព្យញ្ជនកៈទាំងពីរពួកនោះ ហេតុដូច្នោះ ទើបឥត្ថីឧភតោព្យញ្ជនកៈ មានការតាំងគភ៌ដោយខ្លួនឯងខ្លះ ឬក៏ញ៉ាំងស្ត្រីឲ្យមានគភ៌ខ្លះ ។ បុរិសុភតោព្យញ្ជនកៈនោះ នឹងញ៉ាំងស្ត្រីដទៃឲ្យមានគភ៌បាន ប៉ុន្តែខ្លួនឯងមិនមានការតាំងគភ៌ទេ **ឥធមេត្ថ បណ្ឌកាធំ វិភាវធំ** សម្ដែងដោយបណ្ឌកៈក៏ចប់ត្រឹមតែប៉ុណ្ណេះ ។

បណ្ឌកាទិវិភាវនកថា ចប់

# នាគានំវិភាវនកថា

*ឥឡូវនេះ នឹងសម្តែងនូវនាគទាំងឡាយ* **នាគានន្តិ អហិ–នាគានំ វិភាវនំ តត្ថ យេ នាគា មហាសមុទ្ទេ ឩម្មិបិដ្ឋេ បដិវសន្តិ តេសំ នាគិនិយោ បន ឧតនិសមយេ បរិដ្ឋិតគព្ភា ចិន្តេន្តិ សចេ មយំ ឥធ វិជាយិស្សាម ឯវំ នោ ទារកា ឩម្មិវេគញ្ច សុបណ្ណស្ស ច បក្ខន្ទិត្វា អគតស្ស វេគំ សហិតុំ ន សក្ខិស្សន្តិ** *វីនាគទាំងឡាយណា ដែលអាស្រ័យនៅខាងលើរលកនាមហាសមុទ្រ ក្នុងកាលបើនាងនាគទាំងឡាយរបស់ស្តេចនាគទាំងឡាយនោះ កាលបើមានគភ៌តាំងឡើងហើយ ក៏រំពឹងគិតដូច្នេះថា យើងទាំងឡាយប្រសិនបើនឹងប្រសូតបុត្រក្នុងទីនេះ បុត្ររបស់យើងនៅជាទារក មិនអាចអត់ធន់នឹងទឹករលកបាន មួយទៀត មិនអាចទប់ទល់នូវកម្លាំងរបស់ស្តេចគ្រុឌដែលហើរមកបាន នាគញីទាំងឡាយនោះក៏មុជចុះទៅតាមផ្លូវទឹក កាលទៅដល់មហានទីទាំង ៥ ហើយ ក៏ទៅកាន់ព្រៃហិមពាន្ត ជាទីកន្លែងសម្រាកសម្រាន្ត ក្នុងល្អាងកែវល្អាងមាស ដែលស្តេចគ្រុឌទាំងឡាយមិនអាចហើរទៅដល់បាន* **វិជា–**

**យិត្វា** ទើបប្រសូតបុត្រក្នុងល្អាងទាំងឡាយនោះ **ឱតារេត្វា** ហើយញ៉ាំងនាគទាំងឡាយដែលនៅតូចៗ នោះឲ្យហាត់ហែលទឹកក្នុងទីដែលទឹករាក់ៗ ប្រមាណត្រឹម-កជើងជាដើមសិន ។ ទើបបង្រៀនកូននាគទាំងឡាយឲ្យហាត់ហែលទឹក **អថ យថានុក្កមេន** ក្នុងកាលនោះកូននាគទាំងឡាយ មានកម្លាំងល្មមនឹងហែលទឹកបានទៅខាងណេះខាងណោះ ហែលទៅហែលមកបាន ។ កាលបើនាគទាំងឡាយដឹងច្បាស់ថាឥឡូវនេះ កូននាគទាំងឡាយរបស់យើង អាចទប់ទល់នូវកម្លាំងរលកធំៗបានហើយ អាចទប់ទល់កម្លាំងរបស់ស្តេចគ្រុឌក៏បាន **មហាមេឃំ សមុដ្ឋាបេត្វា** ក្នុងកាលនោះ ទើបញ៉ាំងមហាមេឃឲ្យកើតឡើងដោយអានុភាពរបស់ខ្លួន **ក្ររុមាណា** ទើបធ្វើព្រៃហិមពាន្តទាំងឡាយឲ្យប្រាកដដូចមហានទី ញ៉ាំងភ្លៀងមួយមេធំឲ្យធ្លាក់ចុះក្នុងព្រៃហិមពាន្តនិម្មិតនូវមហានទីទាំងឡាយពាសពេញទៅដោយទូកកែវ ទូកមាស ទូកប្រាក់ ចងពិតានខាងលើ ព្យួរសំយុងនូវកម្រងផ្កា និងគ្រឿងក្រអូបវិចិត្រទៅដោយផ្កាយប្រាក់ ផ្កាយមាសផ្សេងៗ ហើយកាន់យកនូវគ្រឿងបរិភោគដ៏វិសេស និងផ្កា គ្រឿងក្រអូប គ្រឿងតាក់តែង ។ **ឱតាហិត្វា** ទើបញ៉ាំងកូននាគទាំងឡាយឲ្យចូលមហានទីទាំង ៥ ដោយ

ទូកទាំងឡាយផ្សេងៗ ទៅកាន់មហាសមុទ្រដោយលំដាប់ ។ ចំណែក កូននាគតូចៗ ទាំងឡាយនោះ មានប្រមាណ ១០០ ព្យាម ១០០០ ព្យាម ដល់នូវការចម្រើនធំឡើងដោយលំដាប់ ។

**អាសីវិសា ចតុព្វិធា** ពស់ទាំងឡាយដែលជាសញ្ជាតិរបស់ ស្តេចនាគមាន ៤ ពួគ គឺកដ្ឋមុខ ១ បូតិមុខ ១ អគ្គិមុខ ១ សត្ថមុខ ១ កាលបើពស់ឈ្មោះថា កដ្ឋមុខខាំសត្វទាំងឡាយ កាយរបស់សត្វទាំង មូលនោះក៏ស្ងួតក្រៀមទៅ ប្រៀបដូចកំណាត់ឈើមួយដុំដែលស្ងួត ត្រង់ ទីទាំងឡាយដែលខ្នងលាតចេញ និងបត់ចូល ក៏រឹងស្តូកទាំងអស់ ដូច គេដោតដោយខ្នាស់ដែក ។ បើពស់ឈ្មោះថាបូតិមុខខាំ កាយទាំង មូលនោះ ក៏កើតជាខ្ទុះរលួយស្អុយ រាលដាលទៅ ប្រៀបដូចខ្ទុរ បាយស្រាទុំ មានខ្ទុះហូរចេញ ដូចទឹកដែលស្រក់ចុះត្រង់សំពត់តម្រង ទឹក ។ បើពស់ឈ្មោះថា អគ្គិមុខខាំ រាងកាយទាំងមូលធ្វើឲ្យក្រៀមទៅ ប្រៀបដូចបាច់ស្មៅដែលនៅរាត់រាយ ឲ្យក្តៅអន្ទះអន្ទែង ។ បើពស់ ឈ្មោះថាសត្ថមុខខាំ រាងកាយទាំងមូលដាច់ជាដុំៗ ដូចទីទៅនៃកាំរន្ទះ (អសនីបាត) មានមុខរបួសដាច់រយះចេញ ដូចស្នាមនៃមុខពន្លាកធំ ដែលជាងឈើដាប់ ។ ពស់ទាំងឡាយ មានមាត់សុទ្ធតែពិសដោយ

ចែកផ្សេងៗ គ្នាជា ៤ ពួក ដោយប្រការដូច្នេះ ។

មួយទៀតសោត ពោលដោយវិការនៃកម្លាំងពិស ចែកចេញជា ១៦ ពួក ។ អធិប្បាយថា ពស់ដែលឈ្មោះថា កដ្ឋមុខនោះក៏ចែកជា ៤ ពួក ។ បូតិមុខក៏មាន ៤ ពួក ។ អគ្គិមុខក៏មាន ៤ ពួក ។ សត្ថមុខក៏មាន ៤ ពួក ។ ទើបជាអសិរពិស ១៦ ពួកដូច្នេះ ។ កដ្ឋមុខមាន ៤ ពួកនោះគឺ ១- ទដ្ឋវិសោ ២- ទិដ្ឋវិសោ ៣- ផុដ្ឋវិសោ ៤- វាតវិសោ ។អធិប្បាយថា បើសរីរកាយសត្វទាំងពួងត្រូវអសិរពិសឈ្មោះថា **ទដ្ឋវិសោ** ខាំចឹកហើយ ទើបមានការឈឺចាប់ បើពស់ឈ្មោះថា **ទិដ្ឋវិសោ** ឃើញសត្វទាំងឡាយហើយ សត្វទាំងឡាយក៏ឈឺចាប់ បើពស់ឈ្មោះថា **ផុដ្ឋវិសោ** ប៉ះពាល់ហើយ សត្វទាំង-ឡាយក៏ដល់នូវការឈឺចាប់ បើពស់ឈ្មោះថា **វាតវិសោ** ត្រូវខ្យល់ប្រហារហើយ សត្វក៏ដល់នូវការឈឺចាប់ ធ្វើឲ្យសរីរៈទាំងមូលរឹងមានវិការផ្សេងៗ ដោយប្រការដូចពោលមកហើយ ។ អាសិរពិស ១៦ ពួក កើតដោយអំណាចវិការនៃកម្លាំងពិសនីមួយៗ ដូច្នេះដូចគ្នាទាំង ១៦ពួក ។ ប៉ុន្តែក្នុងគម្ពីរបុគ្គលបញ្ញត្តិនោះ ចែកអាសិរពិស ៦៤ ពួក ។ អធិប្បាយថា កដ្ឋមុខដែលឈ្មោះថា ទដ្ឋវិសោនោះចែក ៤

ប្រការគឺ **អាគតវិសោ នោ ឃោរវិសោ ១ ឃោរវិសោ នោ អាគតវិសោ ១ អាគតវិសោ ច ឃោរវិសោ ១ នេវ អាគតវិសោ នោ ឃោរវិសោ ១ ។**

**យស្ស វិសំ** រីពិសរបស់អាសិរពិសណាខាំ-ចឹកហើយ ពិសក៏ជ្រួតជ្រាបទៅយ៉ាងរហ័ស ដូចគប់ភ្លើងឆេះ ដល់នូវការៈគួរពោលថា ពិសជ្រួបដល់ត្របកភ្នែក ជ្រួបដល់បំពង់-ក ជ្រាបដល់ក្បាល ប៉ុន្តែអាយលម្ពាយដ៏ឈ្លាសក្នុងការរាយមន្តផ្លុំ សូត្រមន្តអាគមផ្លុំចូលទៅតាមរន្ធត្រចៀក ចាប់មែកឈើបោក ។ អធិប្បាយថា ពិសនោះ ថយចុះទៅតាំងនៅត្រង់មុខរបួស ធ្វើឲ្យជាំ ស្លេកស្លាំង ធ្វើឲ្យហើម ប្រៀបដូចជាពិសពស់ខៀវ អាសិរពិសយ៉ាងនេះ មានឈ្មោះថា **អាគតវិសោ នោ ឃោរវិសោ** ប្រែថា ពិសជ្រាបរហ័ស តែមិនខ្លាំងក្លា ។

**យស្ស បន វិសំ** រីពិសរបស់អាសិរពិសណាខាំ-ចឹកហើយ ពិសក៏ជ្រាបទៅសន្សឹមៗ ប្រៀបដូចទឹកចាក់ស្រោចផ្ទៃដែក ក៏មិនជ្រួតជ្រាបចូលទៅក្នុងផ្ទៃដែកមិនបាន បើជ្រាបបានក៏តិចតួច ពិសនោះទន់ខ្សោយដូចពិសពស់ត្រី ។ អំណើះតទៅដល់ ១២ ឆ្នាំ ទើបពិសនោះប្រាកដក្នុងទីទាំងឡាយជាដើម គឺត្រង់សៀតផ្កា និងត្រង់កញ្ចឹង-ក

កាល អាយលម្ពាយទាំងឡាយរាយមន្ត សូត្រអាគមផ្លុំអស់កាលយូរ ប៉ុនណា ក៏មិនបានធូរថយ ពិសនោះ ក៏រឹងរឹតតែរីករាលដាលរៀងរាល់ថ្ងៃ អាសិរពិសយ៉ាងនេះឈ្មោះថា **ឃោរវិសោ ឆោ អាគតវិសោ** ប្រែថា មានពិសខ្លាំងក្លា មិនមានពិសរួសរាន់ ។

**យស្ស បន វិសំ សីឃំ អភិរុឡ្ហតិ ន សីឃំ ឱតរតិ** រីពិសនៃពស់ណាខាំរួចហើយ ពិសនោះជ្រាបរហ័ស ប៉ុន្តែមិនបានថយចុះរហ័សឡើយ ដូចពិសនៃពស់ថ្លាន់ជាដើម យ៉ាងនេះឈ្មោះថា **អាគតវិសោ ឃោរវិសោ ច។**

**យស្ស វិសំ មន្ទំ** រីពិសនៃពស់ណានៅតូច ខាំហើយ ពិសក៏ថយចុះងាយៗ ដូចពិសពស់ខៀវ ពស់ត្រីជាដើមយ៉ាងនេះ ឈ្មោះថា **នេវ អាគតវិសោ ឆោ ឃោរវិសោ** ជាជាតិអាសិរពិស, ជាពិសដែលជ្រួតជ្រាបយឺត មិនពិសមិនខ្លាំងក្លា ។អាសិរពិសទាំងឡាយ ១៦ ពួកនោះ ចែកចេញជា ៤ ពួក សរុបជាដប់ប្រាំមួយ ៤ ដង ជាអាសិរពិស ៦៤ ពួកៈ នេះជាការពោលក្នុងបុគ្គលប្បញ្ញត្តិ ហើយយក ៦៤ ជាតំណាង ហើយយកមកគុណនឹង ៤ ដោយអំណាចកំណើតទាំង ៤ គឺជលាពុជៈ អណ្ឌជៈ សំសេទជៈ ឱបបាតិកៈ

ដូច្នេះ ក៏ត្រូវជាអាសិរពិស ២៥៦ ពួក យក ២៥៦គុណនឹង២ ដោយអំណាចអាសិរពិសកើតក្នុងទឹកមួយពួក លើគោកមួយពួក ទើបជាអាសិរពិស ៥១២ ពួក យក ៥១២ គុណនឹង ២ ដោយអំណាចនៃអាសិរពិសឈ្មោះកាមរូប ១ ឈ្មោះអកាមរូប ១ ទើបជាពស់ ១០២៤ ពួក ។ មានបទវិគ្រោះថា **អាសិត្តវិសាតិ អាសីវិតា ។ អសិតវិសាតិបិ អាសីវិសា ។ អសិសឥសវិសាតិ អាសីវិសា** ប្រែថា នាគណា មានពិសដូចចាក់ស្រោចក្នុងសកលកាយនៃបុគ្គលដទៃ នាគនោះឈ្មោះថា **អាសីវិស** ។ ន័យមួយទៀតថា នាគទាំងឡាយណាស៊ីនូវវត្ថុណាមួយ វត្ថុនោះក៏ក្លាយទៅជាពិសទាំងអស់ ហេតុដូច្នោះ ទើបនាគទាំងឡាយនោះ ឈ្មោះថា **អសីវិស** ។ ន័យមួយទៀតថា ពិសនៃនាគទាំងឡាយមានឫទ្ធិខ្លាំងក្លា អាចផ្តាច់យកស្បែករបស់សត្វបុគ្គលដទៃ ប្រៀបដូចដាវដ៏មុត ទើបនាគទាំងឡាយនោះឈ្មោះថា **អាសីវិស** គឺមានពិសដូចដាវដ៏មុត ។ ឧរគសត្វពួកណាលូនទៅដោយទ្រូង សត្វពួកនោះឈ្មោះថា ឧរគសត្វ គឺជាឈ្មោះនៃពស់ទាំងឡាយ **សោ សប្បោ** រីពស់នោះមាន ២ ពួក គឺកាមរូបី ១ ពួក អកាមរូបី ១ ពួក ។ ពស់ឈ្មោះថាកាមរូបីនោះ មាន ២

ពួក **ជលជោ** គឺកើតក្នុងទឹក ១ ពួក **ថលជោ** គឺកើតលើគោក ១ ពួក ៗ ពស់ និងនាគ ដែលកើតក្នុងទឹកឈ្មោះថា កាមរូបក្នុងទឹក និងមិនមែនឈ្មោះកាមរូបលើគោកឡើយ ប្រៀបដូចសង្ខបាលនាគរាជ ដែលកើតលើគោកនោះ ក៏បានឈ្មោះថាកាមរូបលើគោក និងមិនមែនឈ្មោះថា កាមរូបក្នុងទឹកឡើយ គឺទឹកក៏សមាគមគ្នាតែកំណើតក្នុងទឹកដូចគ្នា ឯកំណើតលើគោកក៏សមាគមគ្នាតែកំណើត លើគោកដូចគ្នាដែរ ៗ

មួយទៀត កាលបើពស់ និងនាគ នឹងសកសំណាករបស់ខ្លួន ក៏សកសំណាករហូតផុតកន្ទុយ ប៉ុន្តែតាំងនៅក្នុងជាតិរបស់ខ្លួន គឺជាជាតិពស់ កាលបើសកសំណាកនោះ ក៏មានការស្អប់ខ្ពើមណាស់ ៗ អធិប្បាយថា ពស់ទាំងឡាយមិនអាចកន្លងចោលនូវជាតិរបស់ខ្លួនក្នុងទីទាំងឡាយ ៥ ប្រការ ៗ **ឧប្បត្តិយំ** គឺកាលកើតក៏ជាភេទពស់ ១ **ចុតិយំ** គឺកាលស្លាប់ ក៏ត្រូវស្លាប់ក្នុងភេទពស់ ១ ៗ **វិសដ្ឋនិទ្ទោកមនេន** គឺចុះកាន់និទ្រាក៏ជាភេទពស់ ១ ៗ **មេថុនបដិសេវនេ ច** គឺកាលបើនឹងសេពមេថុនជាមួយនាគញី ដែលមានជាតិស្មើគ្នានោះក៏ក្នុងភេទជាពស់ ១ ៗ **ជិណ្ណាតចជហានេ** កាលសកសំណាករបស់

ខ្លួននោះ ក៏ត្រូវមានភេទជាពស់ ១ ។ **យទា តចំ ជហាតិ** ធម្មតា ពស់ទាំងឡាយសកសំណករបស់ខ្លួនក្នុងកាលណា កាលនោះ ក៏តាំងនៅក្នុងភេទជាពស់ មែនពិត ពស់កាលសក តែស្អប់ខ្ពើមសំណកពាក់កណ្តាល មិនបានសលពាក់កណ្តាលទៀត ខណៈនោះ ក៏មានការស្អប់ខ្ពើមកាយរបស់ខ្លួន ក៏អាស្រ័យចន្លោះកំណាត់ឈើ ឬផ្ទាំងថ្មហើយ ក៏ញុំាងកម្លាំងឲ្យកើត ធ្វើនូវសេចក្តី ព្យាយាម ឧស្សាហ៍ធ្វាយរន្ធលកន្ទុយរបស់ខ្លួន អត់ដង្ហើម បើកពពារ លុះសកសំណកនោះផុតចាកសរីរៈហើយ ក៏លូនទៅកាន់ទីតាមសេចក្តីប្រាថ្នា កាលបើសេពមេថុនធម្មតាគញ្ញីដែលមានជាតិស្មើគ្នា ក៏ត្រូវមានភេទជាពស់ ។

ក្នុងអដ្ឋកថាវិន័យថា កាលនាគសេពមេថុនជាមួយជាតិដទៃផ្សេងគ្នា មានមនុស្សស្រីជាដើមក្នុងកាលណា នាគក៏ប្រាកដជារូបទេវបុត្រក្នុងកាលនោះ ទើបសេពជាមួយនឹងមនុស្សស្រីនោះ ។

ក្នុងអដ្ឋកថាកោសលសំយុត្តបានសម្តែងថា កាលបើនាគនោះត្រាច់ទៅស្វែងរកនូវអាហារ និងបាននូវអាហារមកបរិភោគនោះដោយភេទណា សូម្បីនឹងបានដោយភេទពស់ក្តី ដោយភេទជាទេវតាក្តី ដោយភេទជាកន្តឹកក្តី ដោយកំណត់ជាទីបំផុត នាគទាំងឡាយដែលត្រាច់ទៅ

ស្វែងរកអាហារដោយភេទនោះៗ ( ក៏បានអាហារតាមភេទនោះៗ ) **អយំ នាគានំ វិភាវនកថា សង្គហានយោ** វិន័យអធិប្បាយដែលនឹងជ្រាបនូវវិធីសម្តែងនូវនាគទាំងឡាយ ក្នុងបទមាតិកានេះក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

នាគានំវិភាវនកថា ចប់

# សុបណ្ណានំវិមានគាថា

បទមាតិកាពោលដោយប្រភេទផ្សេងៗ របស់គ្រុឌទាំងឡាយ ព្រះអដ្ឋកថាចារ្យលើកឡើងមក ដើម្បីវិសជ្ជនាតទៅ ក្នុងខ្ទឹមសារដីកានៃ **បទលោកវិទូ** ក្នុង **ពុទ្ធានុស្សតិនិទ្ទេស គម្ពីរវិសុទ្ធិមគ្គ សិម្ពលិរុក្ខោ** រីដើមរកា គឺជារុក្ខវិមានរបស់ស្តេចគ្រុឌទាំងឡាយ ប្រតិស្ឋាននៅក្នុងជាន់មេរុជាគម្រប់ ២ និងជាទីនៅរបស់ស្តេចគ្រុឌ ។

ក្នុង **ដីកាចូឡសីហនាទសូត្រ គម្ពីរមជ្ឈិមនិកាយ** ថា ស្រះសិម្ពលីមួយទំហំប្រមាណ ៥០ យោជន៍ ជេរជាសទៅដោយដើមរកា តាំងនៅជាន់មេរុជាគម្រប់ ២ ជាព្រៃធំ សុទ្ធតែដើមរកានៅព័ទ្ធជុំវិញស្រះនោះ ពួកគ្រុឌទាំងឡាយអាស្រ័យនៅក្នុងព្រៃរកានោះ ។ ស្តេចគ្រុឌមានកាយធំទំហំ ៥០០ យោជន៍ ស្លាបម្ខាងៗ ៥០ យោជន៍ **បិញ្ឆវតី ឆដ្ឋី យោជនិកា** កន្ទុយរបស់ស្តេចគ្រុឌ ៦០ យោជន៍ **គីវា តឹសយោជនិកា** កប្រមាណ ៣០ យោជន៍ ។ ចំពុះប្រមាណ ៩ យោជន៍ ជើងនីមួយៗ ប្រមាណ ១២ យោជន៍ **តស្មិំ សុបណ្ណេ** ក្នុងកាលស្តេចគ្រុឌប្រារព្ធដើម្បីនឹងទទះស្លាបហើរ

ម្ដងបានចម្ងាយ ៧ យោជន៍ ។ កាលបើស្ដេចគ្រុឌធាបចាប់យកនូវនាគជាអាហាររបស់ខ្លួននោះ ផ្ទៃនៃទឹកស្រះនោះរាចទំហំដល់រយយោជន៍ ដោយជុំវិញ ញាប់ញ័រទៅដោយកម្លាំងខ្យល់របស់ស្លាប ទើបចាប់នាគបានដោយសំយុងក្បាលចុះក្រោម រួចហើយនាំទៅកាន់ទីតាមសេចក្ដីប្រាថ្នា **ឆាតេ គណ្ហាន្តា** កាលស្ដេចគ្រុឌចាប់នូវនាគទាំងឡាយជាអាហាររបស់ខ្លួន អាចចាប់បានតែនាគដែលមានកំណើតថោកថយជាងខ្លួន ឬស្មើខ្លួនប៉ុណ្ណោះ មិនអាចចាប់នាគដែលមានកំណើតនាគប្រសើរជាងខ្លួនបានឡើយ ។ ការពិតនាគទាំងឡាយមាន ៧ ពួកដែលគ្រុឌមិនអាចចាប់បាន គឺបណីតតរនាគ ១ ពួក កម្ពលស្សរ-តរនាគ ១ ពួក ធតរដ្ឋនាគ ១ ពួក សត្តសីទន្តរនាគ ១ ពួក បឋវីដ្ឋកនាគ ១ ពួក បព្វតដ្ឋកនាគ ១ ពួក វិមានដ្ឋកនាគ ១ ពួក ។ បណីតតរនាគនោះ ប្រសិនបើនឹងពោលដោយកំណើត ជាឧក្រិដ្ឋប្រសើរជាងគ្រុឌ បើគ្រុឌជាជលាពុជៈ នឹងចាប់នាគដែលជាជលាពុជកំណើតស្មើគ្នានឹងខ្លួនបាន ចាប់នូវនាគដែលជាអណ្ឌជកំណើតដែលតូចទាបជាងខ្លួនបាន មិនអាចចាប់នូវនាគដែលជាសំសេទជៈនិងឱបបាតិកកំណើតបានទេ ។ វិសេសភាវៈស្មើគ្នា តូចជាងគ្នា ឧត្តម

ជាងគ្នានៃនាគទាំងឡាយ ដោយអំណាចកំណើត ។ អ្នកប្រាជ្ញគប្បី ជ្រាបដូច្នេះ នាគទាំងឡាយ ដែលមាននាទីជានាគសេនាបតីឈ្មោះថា កម្ពលស្សតរនាគ ស្ដេចគ្រុឌណាមួយ កាលឃើញនូវកម្ពលស្ស-តរនាគរាជទាំងឡាយ ក្នុងទីណាទីមួយក្ដី ក៏មិនអាចដើម្បីនឹងចាប់ នូវកម្ពលស្សតរនាគរាជនោះជាអាហារបានឡើយ ។ នាគរាជដែល ឈ្មោះថាធតរដ្ឋនាគរាជ ស្ដេចគ្រុឌក៏មិនអាចចាប់ជាអាហារបានដែរ ។ នាគទាំងឡាយដែលអាស្រ័យនៅក្នុងសីទន្តរមហាសមុទ្រ ចន្លោះភ្នំ សត្តបរិភណ្ឌនោះ ស្ដេចគ្រុឌក៏មិនអាចចាប់ជាអាហារបានឡើយ ។ មួយទៀត នាគទាំងឡាយដែលនៅលើផែនដី ភ្នំ សាគរទាំងឡាយ ដែលមានទីលាក់ខ្លួន គ្រុឌទាំងឡាយក៏មិនអាចចាប់បាន **យេ បន មហាសមុទ្ទេ ឩម្មិបិដ្ឋេ វសន្តិ** ម្យ៉ាងទៀត នាគទាំងឡាយដែល អាស្រ័យនៅក្នុងរលកទឹកមហាសមុទ្រ នាគទាំងឡាយនោះសូម្បីស្ដេច គ្រុឌមានកំណើតស្មើគ្នាក្ដី ប្រណីតជាងគ្នាក្ដី ក៏មិនអាចចាប់នាគទាំង-ឡាយនោះជាអាហារបានឡើយ **វុត្តមេតំ សំយុត្តនិកាយេ សុបណ្ណសំយុត្តវណ្ណនាយំ** សេចក្ដីនោះមាននៅក្នុង អដ្ឋកថា សុបណ្ណសំយុត្ត ក្នុង សំយុត្តនិកាយ **អយមេត្ថ សុបណ្ណានំ**

**វិភាវនកថា សង្គហានយោ** អធិប្បាយក្នុងសុបណ្ណកថា ក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

សុបណ្ណានំវិភាវនកថា ចប់

# បេតាន់ំវិភាវនកថា

បន្ទាប់អំពីនេះ នឹងសម្ដែងនូវសត្វទាំងឡាយ ដែលធ្វើនូវអកុ-សលកម្ម រាប់ចូលក្នុងប្រេតពោលដោយពពួកប្រេតទាំងឡាយ **បេតា ហិ** ការពិត ប្រេតទាំងឡាយមាន ៣ ពួក ជាទ្វិហេតុកៈ ១ ពួក ជាតិហេតុកៈ ១ ពួក ជាអហេតុកៈ ១ ពួក ។ ប្រេតទាំងឡាយពួកខ្លះ មិនមានសក្តានុភាព ដូចទេវតាទាំងឡាយ ដែលមិនមានអានុភាព ជាប្រេតមានអានុភាពតិច ដូចមនុស្សកំព្រាបានបាយទឹកលំបាក មានតែសេចក្ដីទុក្ខបៀតបៀន **ឯកច្ចេ កាឡបក្ខេ ទុក្ខិតា** ពួកខ្លះបានសោយនូវសេចក្ដីទុក្ខខាងរនោច **ជុណ្ហាបក្ខេ សុខិតា ហោន្តិ** បានសោយនូវសេចក្ដីសុខខាងខ្នើត ជាពួកវេមានិកប្រេត បើប្រេតពួកណា ជាតិហេតុកបដិសន្ធិវិបាកកើតប្រកបដោយវាសនាបារមី ប្រេតពួកនោះក៏បានត្រាស់ដឹងនូវមគ្គ និងផល **បិយង្ករមាតាយក្ខិនី** ប្រៀបដូចយក្ខនីជាមាតារបស់បិយង្ករនោះ ការពិត បិយង្ករមាតានោះ ថ្ងៃមួយ ក៏បានឮសំឡេងព្រះអនុរុទ្ធត្ថេរស្វាធ្យាយធម៌វេលាជិតភ្លឺ ទើបហាមកូនថា នែកូនបិយង្ករ ឯងកុំឡូឡា ព្រោះភិក្ខុលោកកំពុងតែ

ស្វាធ្យាយនូវព្រះធម៌ កាលបើយើងបដិបត្តិតាមព្រះធម៌ ឯងចូរតាំងចិត្ត ពិចារណាន័យព្រះធម៌ឲ្យដឹង ក៏នឹងបានជាប្រយោជន៍ យើងនឹងរក្សាសីល មិនសម្លាប់សត្វ មិនពោលកុហក និងសិក្សាសង្រួមនូវភាពនៃខ្លួនមាន សីលល្អ ទើបយើងរួចផុតពីកំណើតបិសាច **ឯវំ បុត្តកំ សញ្ញាបេត្វា** យក្ខិនីក៏ញ៉ាំងបុត្រ ឲ្យទទួលយកនូវពាក្យដូច្នេះក្នុងពេលនោះ ក៏ បានតាំងចិត្តស្តាប់ ហើយបានសម្រេចសោតាបត្តិផល ។ យក្ខិនី មួយពួកទៀត ជាមាតារបស់ឧត្តរមាណព បានស្តាប់ព្រះធម៌របស់ ព្រះពុទ្ធ ក៏សម្រេចដល់សោតាបត្តិផល រឿងនេះមាននៅក្នុង អដ្ឋកថាមហាបរិនិព្វានសូត្រ ក្នុង គម្ពីរទីឃនិកាយ និងក្នុង អដ្ឋកថា សំយុត្តនិកាយ ។

ពាក្យក្នុង **នេមិរាជជាតក** ថា ទេវតាទាំងឡាយក្នុងចកាមាវចរស្ថគ៌ ក៏គួរនឹងហៅថាប្រេតបាន ព្រោះថា ទេវតាទាំងឡាយនោះ សូម្បីថា មានទ្រព្យជាប្រការណា ៗ ក៏ហៅថា **កំព្រា** ព្រោះទេវតាទាំងឡាយនោះ ប្រាថ្នានូវសម្បត្តិដទៃអំពីហេតុនៃកិលេសវត្ថុ មានរូបជាដើម ទើបគួរ នឹងហៅថា **ប្រេត** ។ ពួកប្រេតទាំងឡាយដែលមានជាតិជាបង្សុបិសាច នោះ **អសុចិឋានេ និព្វត្តិ** តែងតែកើតក្នុងទីមិនស្អាត **កិរ** បានឮមក

ថា បិសាចទាំងឡាយ **ឃកាំ មូលំ គហេត្វា** កាន់ឫសឈើមួយ ដុំដើរស្វែងរកអាហារស៊ី **អធិស្សមានកាយា** មិនមានកាយប្រាកដ ដល់មនុស្ស ដោយអំណាចឫសថ្នាំនោះ **តត្រិទំ វត្ថុ** មានសេចក្ដី និទានថា មានបិសាចម្នាក់ញុំាងទារកទាំងពីរនាក់ ជាកូនឲ្យអង្គុយនៅ ទៀបខ្លោងទ្វារ ចូលទៅកាន់ជូបារាម ចូលទៅកាន់ទីក្រុងដើម្បីស្វែង រកនូវអាហារ ។ ភិក្ខុមួយរូបនិមន្តទៅបិណ្ឌបាតពេលព្រឹក **ឃកាំបិ បិណ្ឌចាតិកាត្ថេរំ ធិស្វា** ទារកទាំងពីរបានឃើញភិក្ខុរូបនោះ ទើប ស្រែកថ្លាំដោយពាក្យថា បពិត្រលោកម្ចាស់ដ៏ចម្រើន មាតារបស់ខ្ញុំ ព្រះករុណាម្ចាស់ ចូលទៅកាន់ទីក្រុង សូមលោកម្ចាស់ប្រាប់ផង ឲ្យ មាតារបស់ខ្ញុំព្រះករុណាកាន់យកនូវអាហារណានីមួយ ប្រញាប់រួស រាន់ កូនទាំងពីរនាក់ឃ្លានអាហារណាស់ មិនអាចអត់ទ្រាំបានទេ ។ ទើបព្រះថេរៈសួរថា អាត្មានឹងឃើញនូវមាតារបស់អ្នកឯងដូចម្ដេច **ឃកមូលកខណ្ឌំ អទំសុ** ទើបទារកទាំងពីរនោះប្រគេនឫសថ្នាំមួយ កំណាត់ចំពោះភិក្ខុរូបនោះ ពោលថា សូមលោកម្ចាស់ទទួលយក នូវឫសថ្នាំនេះ កាន់ទៅចុះ ។ កាលបើព្រះថេរៈ បាននូវឫសថ្នាំ ដែលបិសាចទាំងពីរនាក់ប្រគេននោះ ។ គ្រានោះ បិសាចទាំង-

ឡាយច្រើនជាងរយ ច្រើនជាងពាន់ប្រាកដដល់ព្រះថេរៈៗ ក៏ឃើញបិសាចដែលជាមាតារបស់ទារកទាំងពីរ ដែលឲ្យឫសថ្នាំនោះ មានកាយដ៏អាក្រក់ ដើរស្វែងរករបស់មិនស្អាត មានមន្ទិលគក៏ជាដើម ។ ទើបព្រះថេរៈប្រាប់មាតារបស់ទារកទាំងពីរនោះ ។ ទើបស្រីបិសាចសួរថា ហេតុដូចម្តេច ទើបលោកម្ចាស់ មើលឃើញខ្ញុំព្រះករុណា ទើបព្រះថេរៈលើកបង្ហាញនូវឫសថ្នាំនោះឡើង ស្រីបិសាចបានឃើញនូវឫសថ្នាំនោះ ក៏ស្ទុះចូលទៅជណ្តើមយកឫសថ្នាំអំពីដៃរបស់ព្រះថេរៈ ។ បានឮថា ពពួកបិសាចទាំងឡាយ រមែងកាន់យកនូវឫសថ្នាំដើរទៅ មិនបានប្រាកដដល់ភ្នែកមនុស្សទាំងឡាយ ដោយប្រការដូច្នេះ សេចក្តីនេះមាននៅក្នុង **អដ្ឋកថាចូឡសកុលុទាយីសូត្រ** ក្នុង **មជ្ឈិមនិកាយ** ។

សេចក្តីដែលពោលដោយសរីរកាយ របស់បិសាចទាំងឡាយ ដែលស្លាប់ប្រាកដក្តី នឹងសម្តែងនូវការឧទ្ទិសបុណ្យចំពោះពពួកប្រេតទាំងឡាយក្តី ព្រះបាទមិលិន្ទក៏បានត្រាស់សួរព្រះនាគសេន ។ ព្រះនាគសេនបានថ្វាយការវិសជ្ជនាទុកដោយពិស្តារ ការពិតមានពាក្យក្នុងមិលិន្ទបញ្ហាថា ព្រះបាទមិលិន្ទត្រាស់សួរព្រះនាគសេនថា **ភន្តេ**

**ឆាគសេឆ** បពិត្រព្រះនាគសេនដ៏ចម្រើន ក្នុងលោកនេះមាន បិសាច ឬមិនមានទេ ? ព្រះនាគសេនថ្វាយព្រះពរថា បិសាច មាននៅក្នុងលោកនេះ ( មិលិន្ទ ) ទើបសួរថា បិសាចទាំងឡាយ តែងតែស្លាប់ពីកំណើតរបស់បិសាចដែរឬទេ ( នាគសេន ) សូមថ្វាយ ព្រះពរ បិសាចទាំងឡាយដែលស្លាប់អំពីកំណើតយក្ខនោះ សរីរកាយ មិនឃើញប្រាកដ ក្លិនសាកសពក៏មិនបានប្រាកដដែរ ( មិលិន្ទ ) ហេតុ ដូចម្តេច លោកម្ចាស់ មានថេរវាចាថា បិសាចស្លាប់ហើយ សរីរកាយ ក៏មិនប្រាកដ ក្លិនរបស់សពក៏មិនប្រាកដ ( នាគសេន ) សូមថ្វាយ ព្រះពរមហារាជដ៏ប្រសើរ កាលបិសាចទាំងឡាយស្លាប់ហើយ ក៏ តែងតែមានសរីរកាយប្រាកដ ដោយភេទជារបោម ជាកណ្តូប ជា ដង្កូវ ជាក្អែប ជាបក្សា បក្សី ជារមាំងទ្រាយ ជានាគ ជាគ្រុឌ ផ្សេងៗ ច្រើនប្រការ ។ កាលព្រះនាគសេនថ្វាយការវិសជ្ជនាថា ពួកបិសាចស្លាប់ហើយក៏មានកាយប្រាកដដោយភេទជារបោម ... ជា ដើមនោះ ។ ព្រះបាទមិលិន្ទត្រាស់សរសើរថា បញ្ហានេះខ្ញុំព្រះករុណា សួរលោកម្ចាស់ៗ ក៏បានវិសជ្ជនាដូច្នេះ ជាក្រៃលែងហើយ បញ្ហា នេះជ្រាលជ្រៅគម្ពីរភាពដូច្នេះ បុគ្គលដទៃមិនអាចដោះស្រាយបាន

ឡើយ ប្រសិនបើវៀរលោកម្ចាស់ហើយ ។

ទើបព្រះបាទមិលិន្ទ ត្រាស់បន្តទៅទៀតថា **ភន្តេ ឆាគសេន** បពិត្រព្រះនាគសេនដ៏ចម្រើន ទាយកគេធ្វើនូវទានហើយ គេតែងតែឧទ្ទិសទៅឲ្យដល់ញាតិទាំងឡាយ ដែលធ្វើកាលកិរិយាទៅកាន់បរលោកនោះ ខ្ញុំព្រះករុណាសូមសួរលោកម្ចាស់ ប្រសិនបើញាតិនោះទៅកើតជាប្រេត នឹងបាននូវចំណែកបុណ្យដែលញាតិរបស់ខ្លួនឧទ្ទិសឲ្យនោះ តើបាន ឬមិនបានដោយប្រការណា ?

ព្រះនាគសេនថ្វាយនូវការវិសជ្ជនាថា សត្វទាំងឡាយដែលកើតក្នុងនរក កើតជាមនុស្សលោក កើតជាសត្វតិរច្ឆាន កើតជាទេវតា កើតជាខុប្បិបាសិកប្រេត និងជានិជ្ឈាមតណ្ហិកប្រេត សត្វទាំងឡាយទាំងនេះមិនបានទទួលនូវចំណែកទានរបស់ទាយក ដែលឧទ្ទិសឲ្យបានទេ ។ លុះត្រាតែសត្វទាំងឡាយណា ស្លាប់ទៅកើតជាបរទត្តូបជីវិប្រេត សត្វនោះរឭកដល់ញាតិកា ចាំទទួលនូវការអនុមោទនា ទើបបានទទួលនូវរបស់វិសេស មានប្រការផ្សេងៗ ដែលប្រាកដជាគ្រឿងទិព្វ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើពោលថា ពពួកប្រេតទាំងឡាយ មិនបាននូវរបស់វិសេសហើយ ទានរបស់ទាយកអ្នកធ្វើការ

ឧទ្ទិសទៅឲ្យនោះ នឹងមានផល ឬមិនមានផលទេ ដោយប្រការណា ?

សូមថ្វាយព្រះពរ អ្នកដែលធ្វើទានឧទ្ទិសទៅឲ្យ ដែលថាមិនមានផលនោះមិនមាន ទាយកអ្នកឲ្យទានក៏បានចំណែកផលទានដោយពិត អាការដែលឲ្យទានហើយ នឹងមិនបានមានផលនោះមិនមាន សូមលោកម្ចាស់ ញ៉ាំងខ្ញុំព្រះករុណា ឲ្យជ្រាបច្បាស់ដោយសេចក្តីឧបមាសិនចុះ **យថា មហារាជ មនុស្សា សុភាភត្តំ បដិយាទេត្វា ញាតិកុលំ គច្ឆន្តិ** សូមថ្វាយព្រះពរមហារាជដ៏ប្រសើរ ឧបមាថា បុគ្គលតាក់តែងនូវអាហារ និងសុរា ធ្វើនូវគ្រឿងបណ្ណាការបញ្ជូនទៅឲ្យចំពោះពួកញាតិ ប្រសិនបើពួកញាតិមិនបានទទួលនូវគ្រឿងបណ្ណាការផ្សេងៗ នោះ ក៏គ្រឿងបណ្ណាការ មានសុរា និងអាហារជាដើមនោះ នឹងបោលទៅ ឬក៏ត្រឡប់មកដល់ម្ចាស់របស់វិញ ឬដូចម្តេច ?

បពិត្រលោកម្ចាស់ដ៏ចម្រើន វត្ថុទាំងពួងជាគ្រឿងបណ្ណាការវិសេសផ្សេងៗ នោះ នឹងមិនបានបោលទៅទេ គង់នឹងត្រឡប់វិលវិញ

ដល់ម្ចាស់អ្នកតាក់តែង ។

**មហារាជ** សូមថ្វាយព្រះពរ សេចក្តីទាំងនេះមានឧបមាយ៉ាងណា ទាយកទាំងឡាយអ្នកធ្វើទានឧទ្ទិសឲ្យដល់ពពួកប្រេត ប្រសិនបើពពួកប្រេត មិនបានទទួលចំណែកបុណ្យហើយ ទាយកអ្នកជាម្ចាស់របស់ទាននោះ ក៏បានទទួលនូវចំណែកផលទានរបស់ខ្លួន ក៏មានឧបមេយ្យដូច្នេះ ។

ព្រះបាទមិលិន្ទក៏ជ្រាបដោយបញ្ញាថា ទាយកអ្នកធ្វើទានឧទ្ទិសឲ្យដល់ញាតិ ពពួកប្រេតដែលជាញាតិមិនបានទទួលនូវផលរបស់ទានផងខ្លួន មិនបានអនុមោទនាហើយ ទាយកអ្នកម្ចាស់របស់នោះ ក៏បានទទួលនូវផលទានរបស់ខ្លួន ទើបមានព្រះរាជឱង្ការថា **កល្លោសិ ភន្តេ នាគសេន** បពិត្រលោកម្ចាស់នាគសេនដ៏ចម្រើន លោកម្ចាស់វិសជ្ជនានេះសមគួរណាស់ គួរនឹងមនសិការទុកជាឧទាហរណ៍ សេចក្តីក្នុង មិលិន្ទបញ្ហាចប់ ត្រឹមតែប៉ុណ្ណេះ ។

សេចក្ដីថា ខុប្បិបាសិកប្រេតទាំងឡាយ មិនបាននូវចំណែកនៃទាន ដែលញាតិឧទ្ទិសឲ្យនោះ គឺខ្លួនមានតែសេចក្ដីទុក្ខវេទនា ស្រេកឃ្លានខ្លាំងក្លា ព្រោះអត់អាហារជាច្រើនចន្លោះព្រះពុទ្ធ ។ និជ្ឈាមតណ្ហិកប្រេតនោះសោត ក៏មានភ្លើងឆេះកាយសន្ធោសន្ធៅនៅពីខាងក្នុងខ្លួន ប្រៀបដូចគំនរភ្លើងដែលឆេះខាងក្នុងប្រហោងឈើ មានតែការក្ដៅជានិច្ច ព្រោះដូច្នេះ ទើបមិនបានមកចាំទទួលការអនុមោទនាទាន ដែលញាតិទាំងឡាយធ្វើបុណ្យហើយឧទ្ទិសទៅឲ្យ ទើបមិនបានទទួលនូវផលនៃបុណ្យ ។សម្ដែងមកដោយពពួកប្រេតទាំងឡាយ ចប់ដោយសង្ខេបត្រឹមតែប៉ុណ្ណេះ ។

បេតានំវិភាវនកថា ចប់

# អសុរានំវិភាវនគថា

អធិប្បាយក្នុងអសុរកាយទាំងឡាយនោះ ក្នុង ទសុត្តរសូត្រ **ទីឃនិកាយ** ថា ពពួកប្រេតទាំងឡាយទៅកាន់អាវាហមង្គលដល់ពពួកអសុរកាយទាំងឡាយ ព្រោះយ៉ាងនោះ ទើបពួកអសុរកាយទាំងឡាយសង្គ្រោះចូល ក្នុងពពួកប្រេតកាឡកញ្ជិកាសូរ មានអត្តភាពខ្ពស់ ៣ គាវុត គឺ ៣ រយេសិន ប្រាសចាកសាច់ និងឈាម ស្គមលឿង ដូចស្លឹកឈើស្ងួត មានភ្នែកទាំងពីរលៀនចេញមក ដូចភ្នែកក្ដាមតាំងនៅលើក្បាល មានមាត់តូចប៉ុនប្រហោងម្ជុល ប្រាកដនៅលើក្បាល ។ កាលបើដើរស្វែងរកអាហារក៏វារទៅ ។ អសុរកាយមួយពួកទៀតទាបថោកជាងអសុរកាយទាំងឡាយ ជួនកាលកាន់នូវដំបងដែក ដែលឆេះក្រហមប្រាលប៉ុនដើមត្នោត ប្រហារគ្នានិងគ្នា ជាប្រេតអសុរកាយឆេះនៅក្នុងភ្លើង ដូច្នោះ ។ ពពួកអសុរកាយទាំងឡាយមានសភាពផ្សេងៗ ដោយឡែកពីគ្នា ដូចស្ដេចវេបចិត្រាសូរជាដើម ដែលជាគូដៃធ្វើសង្គ្រាមជាមួយនឹងព្រះឥន្ទ្រាធិរាជ ។

អសុរានំវិភាវនគថា ចប់

# ទេវានំវិភាវនគាថា

អធិប្បាយអំពីទេវតាទាំងឡាយ ការពិត ទេវតាទាំងឡាយនោះ មាន ៣ ពួក គឺសម្មតិទេវតា ១ ពួក ឧបបាតិកទេវតា ១ ពួក វិសុទ្ធិទេវតា ១ ពួក ។ ព្រះមហាក្សត្រ ដែលមនុស្សលោកគោរពរាប់អាន ឈ្មោះថា **សម្មតិទេវតា** ។ ទេវតាទាំងឡាយដែលកើតក្នុងស្ថានសួគ៌ ដោយអានុភាពរបស់ខ្លួននោះ ឈ្មោះថា **ឧបបាតិកទេវតា** ។ ប៉ុន្តែព្រះខីណាស្រពទាំងឡាយ ដែលមានសន្តានបរិសុទ្ធស្អាត ប្រាសចាកកិលេសទាំងពួង ឈ្មោះថា វិសុទ្ធិទេវតាស្អាតល្អក្រៃលែងជាងទេវតាទាំងឡាយទាំងពួង **ទេវលោកេ ទេវានំ ធីតា ច បុត្តា ច អង្គេ និព្វត្តន្តិ** ធម្មតា ទេវតាទាំងឡាយក្នុងទេវលោកនោះ បុត្រធីតាមិនកើតដូចមនុស្សនោះឡើយ ។ បុត្រធីតាទាំងឡាយ កាលនឹងកើតតែងតែកើតនៅលើភ្លៅរបស់ទេវតាទាំងឡាយ ។ ប្រសិនបើជាទេពធីតាកើតជាបាទបរិចារិកា តែងតែកើតឡើងត្រង់ក្រឡាព្រះបន្ទំ ។ ទេវតាជាអ្នកតាក់តែងស្អិតស្អាង ប្រដាប់ប្រដាកូសាជាដើមនោះ តែងតែកើតជុំវិញក្រឡាព្រះបន្ទំ បើជាអ្នកខ្វល់ខ្វាយ ( វេយ្យាវច្ចករ ) នោះ

តែងតែកើតឡើងខាងក្នុងវិមាន កាលបើកើតឡើងខាងក្នុងវិមាន ដូច្នេះហើយ ក៏មិនបានកើតទំនាស់ដល់គ្នាទេ ។ ប្រសិនបើទេវតាទាំងឡាយ មាននាងទេពធីតាជាបាទបរិចារិកាជាដើម កើតក្នុងចន្លោះដែនទេវតាទាំងឡាយណា ទេវតាទាំងឡាយនោះក៏កើតទំនាស់ដល់គ្នាកាលមិនអាចដោះស្រាយគ្នាបានថា ជារបស់ទេវតាអង្គណាបានហើយក៏នាំគ្នាទៅកាន់សម្នាក់របស់ទេវរាជ ជាធំជាងទេវតាទាំងឡាយ ។ បើវិមានរបស់ទេវតាអង្គណានៅជិតជាង សក្កទេវរាជក៏សម្រេចឲ្យជារបស់ទេវតាអង្គនោះ ។ ទីបំផុតត្រឹមទេវតាអង្គណាមកកើតថ្មី ជិតគ្នានឹងវិមានរបស់ទេវតាអង្គណា ក៏ជារបស់ទេវតាអង្គនោះ ទេ្វបិសមបាំងទេវតាអង្គណាកើតថ្មីប្រាកដក្នុងទីដែលស្មើគ្នា ប៉ុនគ្នារបស់ទេវតាទាំងពីរអង្គនោះ ទេវតាអ្នកកើតថ្មីសម្លឹងមើលនូវវិមានរបស់ទេវតាអង្គណា សក្កទេវរាជក៏សម្រេចឲ្យជារបស់ទេវតាអង្គនោះ បើទេវតាអ្នកកើតថ្មីមិនសម្លឹងមើលនូវវិមានណាទីមួយ ហើយសក្កទេវរាជក៏សម្រេចយកជារបស់ព្រះអង្គ ។ ដើម្បីនឹងផ្ដាច់នូវទំនាស់របស់ទេវតាទាំងឡាយ សេចក្ដីដែលពណ៌នាមកនេះ មានក្នុងអដ្ឋកថាសក្កបញ្ហសូត្រ ក្នុងទីឃនិកាយ និង អដ្ឋកថាចូឡតណ្ហាសង្ខយសូត្រ ក្នុង មជ្ឈិម

និកាយ ។

មួយទៀត **វសវត្តីមារាធិរាជ** ជាទេវតាដ៏ប្រសើរដែលនៅក្នុងជាន់បរនិម្មិតវសវត្តីទេវលោក សោយនូវទិព្វសម្បត្តិ ទ្រង់ជាធំនៅក្នុងជាន់បរនិម្មិតវសវត្តីនោះ ឯស្តេចមារាធិរាជញុាំងឥស្សរិយយសរបស់ព្រះអង្គឲ្យប្រព្រឹត្តទៅក្នុងទេវលោក មិនមានទេវតាទាំងឡាយ នឹងប្រៀបស្មើបាន ដោយទិព្វសម្បត្តិដ៏ប្រសើរ ដូចជាព្រះរាជបុត្រនៃព្រះមហាក្សត្រព្រះអង្គជាមហាចោរ ឈ្មោះថា **ទាមរិកចោរ** កាលបានសោយរាជសម្បត្តិក្នុងលង្កាទ្វីបនោះ កំណត់ដែននៃរាជសម្បត្តិ មានដែនអាណាខេត្តដោយជុំវិញ ក្នុងប្រទេសមួយនៃក្រុងលង្កា ។

ក្នុងសួគ៌ទេវលោក ខាងលើឡើងទៅជាន់ព្រហ្មលោកនោះ ទេវតាទាំងឡាយ ដែលជាព្រហ្ម ដែលឈ្មោះថា **អសញ្ញីសត្ត** មានតែរូបកាយ គ្មានសញ្ញា គ្មានចិត្ត ជាមួយនឹងវេហប្ផលាព្រហ្មនោះ នៅក្នុងជាន់ព្រហ្មលោកជាមួយគ្នា មានផ្ទៃស្មើគ្នា **ចិត្តកម្មរូបសទិសាហុត្វា** ការពិត ក្នុងមនុស្សលោកនេះ មានបុគ្គលណានីមួយចេញបួសជាតាបសឥសី ចម្រើនឈាននៅក្នុងព្រៃ ធ្វើបរិកម្មភាវនា នឿយណាយចិត្ត ស្អប់ខ្ពើម មិនបានប្រាថ្នាឲ្យចិត្តកើត ដោយមនសិការថា

រូបកាយសត្វទាំងឡាយ ត្រូវទទួលទោសទណ្ឌកម្ម វាយដំប្រំធាក់ចាប់ចងប្រការផ្សេងៗ នោះ អាស្រ័យចិត្តតែមួយ ព្រោះចិត្តធ្វើឲ្យរូបកាយ ត្រូវទទួលទោសផ្សេងៗ ប្រសិនបើមិនមានចិត្តហើយ រូបកាយក៏ជាសុខសប្បាយ មិនមានទោសភ័យ ទើបធ្វើបរិកម្មភាវនា ស្អប់ខ្ពើមចិត្ត ចម្រើនវាយោកសិណ ប្រាថ្នានឹងមិនឲ្យមានចិត្តកើតឡើង កាលបើបានកសិណឈាននៅក្នុងព្រៃ រហូតដល់ថ្ងៃធ្វើមរណកាល ដោយឥរិយាបថណា គឺអង្គុយស្លាប់ក្តី ដេកស្លាប់ក្តី ក្នុងមនុស្សលោកនេះ ។ លុះទៅកើតក្នុងព្រហ្មលោក ក៏កើតមានតែរូបកាយប្រាកដនៅក្នុងវិមាន ដោយឥរិយាបថអង្គុយ ដេក តាមឥរិយាបថនោះឯង រហូតដល់ ៥០០ កប្បគ្មានវិញ្ញាណ ទៅប្រតិស្ឋាននៅក្នុងវិមានទិព្វ ដូចរូបភាពដែលបុគ្គលគូរ កំណត់ដល់ ៥០០ កប្ប ។ដែលលោកវោហារហៅថាព្រះព្រហ្មចម្លាក់ គឺអាស្រ័យយកព្រហ្មក្នុងជាន់អសញ្ញីកពនោះ **ឥទំ បន មជ្ឈិមនិកាយេ មូលបរិយាយសុត្តវណ្ណនាយំ វុត្តំ** សេចក្តីមាននៅក្នុង អដ្ឋកថាមូលបរិយាយសូត្រ ក្នុង មជ្ឈិមនិកាយ ។

**ទីឃនិកាយេ មហាបទានសុត្តាវណ្ណនាយំ មជ្ឈិមនិ-កាយេ អច្ឆរិយធម្មសុត្តវណ្ណនាយញ្ច វុត្តំ** ក្នុង ព្រះអដ្ឋកថា

អច្ឆរិយធម្មសូត្រ ក្នុង **មជ្ឈិមនិកាយ** និង **មហាបទានសូត្រ** ក្នុង **ទីឃនិកាយ** ថា ទេវតាទាំងឡាយក្នុងជាន់ស្ថានសួគ៌ទេវលោក ទ្រទ្រង់គ្រឿងប្រដាប់ គឺសំពត់ទិព្វដែលស្លៀកដណ្តប់នោះ មានរស្មីដ៏រុងរឿង ភ្លឺផ្សាយទៅ ១២ យោជន៍ ។ មួយទៀត រស្មីគ្រឿងអលង្ការអាភរណៈផ្សេងៗក្តី រស្មីវិមានដែលស្ថិតនៅនោះក្តី ក៏ភ្លឺរុងរឿងផ្សាយទៅបាន ១២ យោជន៍ ហេតុដូច្នោះ ទើបស្ថានសួគ៌ទេវលោកគ្មានយប់ងងឹត ដូចស្ថានមនុស្សលោកនេះទេ មានភាពភ្លឺតែម្យ៉ាង ដោយអំណាចរស្មីមាស ប្រាក់ កែវ កងរតនៈទាំងឡាយដ៏ជាទិព្វ ជាគ្រឿងប្រដាប់ប្រដា ដែលកើតដោយបុណ្យ អានុភាពដែលធ្វើនូវកងការកុសល មានសីល និងភាវនាជាដើម ក្នុងជាតកសម្តែងថា សំពត់ទិព្វ ក្ដូសារបស់ទេវតាដែលស្លៀកដណ្តប់នោះ មានផ្ទាំងធំប៉ុនគ្នានឹងផ្កាវល្លិ៍មាស ឯផ្ទាំងតូចវិញប៉ុនគ្នានឹងផ្កាអង្គាបុស្ស សូម្បីបណ្តោយ និងទទឹង ក៏សមគួរនឹងរូបកាយ ៣ គាវុតរបស់ទេវតានោះ ។

ក្នុង **មារតជ្ជនិយសូត្រ មជ្ឈិមនិកាយ** ពោលថា ស្ថានសួគ៌ទេវលោកនោះ មានទីប្រជុំ គឺរោងសុធម្មាគ្រប់ជាន់ទាំង ៦ ។

**អដ្ឋកថាចូឡសមាទានសូត្រ មជ្ឈិមនិកាយ** ថា **រុក្ខវិមានានិ**

**នាម មនុស្សានំ ចក្ខុវិសយាតីតានិ មហារាជសន្តិកា លទ្ធ-រុក្ខដ្ឋវិមានានិ តេសុ រុក្ខទេវតានំ វិមានេសុ យំ សាខដ្ឋ-កវិមានំ ហោតិ** *វិមានណាដែលតាំងនៅលើមែកឈើ ទេវតាទាំងឡាយដែលជារុក្ខទេវតា ក្នុងកាលមែកឈើទាំងឡាយបាក់ដាច់ចុះក្នុងទីនោះៗ បាក់មួយមែកៗ ក្តី បាក់មែកទាំងអស់ក្តី ទើបវិមាននោះបាក់បែក ធម្មតា រុក្ខទេវតាទាំងឡាយដែលនៅរុក្ខវិមាននោះ ទោះបីដើមឈើនោះបាក់មែក នៅសល់តែដង្គត់ប៉ុណ្ណោះ វិមាននោះក៏តាំងនៅបានដែរ* **កិរ** *បានឮមកថា ទេវតាសន្និបាត គឺការប្រជុំរបស់ទេវតាទាំងឡាយ មាននៅនាថ្ងៃបក្ខតិថីខាងខ្នើត ខាងរនោចក្នុងព្រៃហិម-ពាន្ត ។ ពាក្យសួរនូវរុក្ខធម៌ដល់គ្នានិងគ្នា លោកតាំងនៅក្នុងរុក្ខធម៌បាន ឬមិនបានទេ ប្រឹក្សានូវគ្នានិងគ្នាដូច្នេះ ។ ដូចម្តេចទើបហៅថារុក្ខធម៌ ? អធិប្បាយថា ដើមឈើណានីមួយដែលជារុក្ខវិមាននោះសូម្បីបាក់ដាច់ចុះក្តី ទេវតាមិនមាននូវសេចក្តីក្រោធ មិនបានតូចចិត្ត យ៉ាងនេះឯងឈ្មោះថា រុក្ខធម៌ ។ ប្រសិនបើទេវតាអង្គណាមិនបានតាំងនៅក្នុងរុក្ខធម៌ ទេវតាអង្គនោះមិនអាចចូលទៅកាន់ទីសន្និ-បាតរបស់ទេវតាទាំងឡាយបានឡើយ* **វិនយេ ភូតគាមសិក្ខាបទ-**

**វណ្ណានាយំ វុត្តំ** ពាក្យនេះមាននៅក្នុង អដ្ឋកថាភូតគាមសិក្ខាបទ ព្រះវិន័យ ។ ការពិត ទេវតាចុតិចាកទេវលោកនោះដោយហេតុ ៤ ប្រការ គឺចុតិដោយអស់អាយុ ១ ចុតិដោយអស់បុណ្យ១ចុតិដោយ អត់អាហារ ១ ចុតិដោយសេចក្ដីក្រោធ ១ ។ អធិប្បាយថា ទេវតា អង្គណា ធ្វើនូវបុណ្យកុសលច្រើន ទេវតាអង្គនោះលុះអស់អាយុពី មនុស្សលោកនេះ **ទេវលោកេ ឧបបជ្ជិត្វា** ក៏បានឡើងទៅកើតក្នុង ស្ថានសួគ៌ ដោយតេជះបុណ្យកុសលរបស់ខ្លួនដែលធ្វើច្រើន **យាវតាយុកំ** តាំងនៅយូរហូតកំណត់ដល់អាយុទិព្វ ស្មើគ្នានឹង អាយុក្នុងជាន់ទេវលោកដោយលំដាប់ជាដើម គឺអាយុក្នុងជាន់ចាតុ- ម្មហារាជិកា ៥០០ ឆ្នាំទិព្វ បើពោលឆ្នាំក្នុងមនុស្សលោកនេះ ៩ លានឆ្នាំមនុស្ស **ឧបរុបរិ និព្វត្តតិ** ហើយឡើងទៅកើតក្នុងឋាន ជាន់តាវត្តិង្ស យាមា តុសិត និម្មានរតី បរនិម្មិតវសវត្តី ខាងលើៗ ដូច្នេះ ទើបបានឈ្មោះថា ចុតិដោយអស់អាយុពីជាន់ចាតុម្មហា- រាជិកា **យេន បរិត្តបុញ្ញំ** ទេវតាអង្គណាធ្វើបុណ្យតិច បានសន្សំ កងការកុសលពីក្នុងមនុស្សលោកនោះតិចហើយ កាលបុណ្យកុសល របស់ខ្លួនអស់ក្នុងចន្លោះ ឧបមាដូចស្បៀងអង្ករ ប្រមាណ៤-៥នាឡិ

តែប៉ុណោះដែលទុកដាក់ក្នុងជង្រុក ក្នុងជោកតិចពេក **អន្តរាវ កាលំ ករោតិ** នៅមិនទាន់ដល់កំណត់អាយុ ក៏ចុតិក្នុងចន្លោះជាដើមដូច្នេះ យ៉ាងនេះឯង ឈ្មោះថា ទេវតាចុតិដោយអស់បុណ្យ ។

**អបរា កាមគុណាបរិភុញ្ជមានា** ពួកទេវតាដទៃនោះសោត បើបរិភោគបញ្ចកាមគុណ សរសើរនូវទិព្វសម្បត្តិរបស់ខ្លួន ភ្លើតភ្លើនទៅដោយស្រីពេទធីតា ភ្លេចបរិភោគនូវអាហារ មិនបានបរិភោគនូវអាហារទិព្វដែលជាបច្ច័យដល់ជីវិត ចំពោះករជកាយរបស់ខ្លួនដ៏សុខុម **កិលន្តកាយោ** មានកាយទ្រុឌទ្រោម ក៏ចុតិដោយអស់បុណ្យអស់ជីវិត យ៉ាងនេះឯងឈ្មោះថា ទេវតាចុតិដោយអត់អាហារ ។

ទេវតាពួកមួយទៀត មិនអាចរម្ងាប់នូវសេចក្ដីក្រោធបាន លុះឃើញសិរីសម្បត្តិរបស់ទេវតាអន្ដដទៃ ក៏កើតសេចក្ដីប្រណែន ក្រោធឡើងក្នុងខណៈនោះ **កាលំ ករោន្តិ** ក៏ចុតិតចាកទេវលោក ទើបបានឈ្មោះថា ទេវតាចុតិដោយសេចក្ដីក្រោធ ។ សេចក្ដីនេះ ព្រះអដ្ឋ-កថាចារ្យពោលទុកក្នុងអដ្ឋកថាធម្មបទ ពោលដោយរឿងឃោសកៈ ។

**បញ្ចនិមិត្តានិ ឧប្បជ្ជន្តិ** កាលទេវតាទាំងឡាយតាំងនៅ ៧ ថ្ងៃ ទៀងនឹងចុតិ ( ថ្ងៃក្នុងមនុស្សលោក ) ក៏កើតមានបុព្វនិមិត្ត ៥

ប្រការ **មាលា មិលាយន្តិ** គឺផ្កាដែលជាគ្រឿងប្រដាប់កាយតាំង អំពីថ្ងៃ ដំបូងចុះកាន់បដិសន្ធិនោះ ស្វិតស្រពោល ។ អធិប្បាយថា ផ្កាទិព្វនោះរីកស្រស់ស្អាត កំណត់កាលស្មើគ្នានឹងអាយុ បើទេវតា មានអាយុតាំងនៅអស់កាលប៉ុនណា ផ្ការីកស្រស់ស្អាតអស់កាលយូរ ប៉ុណ្ណោះ ។ កាលដល់កំណត់ជិតចុតិហើយ ផ្កានោះ ក៏ស្វិតស្រពោន **វត្ថានិ កិលិស្សន្តិ** សំពត់ទិព្វទាំងឡាយដែលជាគ្រឿងប្រដាប់កាយ ដូចជាផ្កាទិព្វក៏សៅហ្មង **កច្ឆេហិ សេទា មុញ្ចន្តិ** ញើសហូរចេញ អំពីក្លៀក **យេទុព្វណ្ណិយំ ឱក្កមតិ** មួយទៀត ពណ៌សម្បុរ ក៏ សៅហ្មងមានប្រាកដក្នុងសរីរទេវតា **ទេវាសនេ ន សណ្ឋាតិ** ទី ស្ថិតនៅរបស់ខ្លួន ដែលធ្លាប់អង្គុយនោះ ក៏មិនអាចអង្គុយនៅជា ប្រក្រតីបាន តែងតែឲ្យក្រវល់ក្រវាយមានប្រការផ្សេងៗ ។ សេចក្តីថា ទេវតាទាំងឡាយ មិនមាននូវសេចក្តីក្រវល់ក្រវាយដោយត្រជាក់ និង ក្តៅ កំណត់កាលស្មើគ្នានឹងអាយុ ហេតុដូច្នេះ កាលជិតនឹងចុតិ ញើសក៏ហូរចេញចាកសរីរៈជាតំណក់ៗ ស្រក់មកឲ្យឃើញប្រាកដ ។

មួយទៀត អាការសៅហ្មង មានប្រការផ្សេងៗ ជាដើម គឺ ធ្មេញបាក់ សក់ស្កូវ សម្បុរអាក្រក់ មិនប្រាកដមានក្នុងសរីរកាយរបស់

ទេវតាទាំងឡាយ កំណត់កាលស្មើគ្នានឹងអាយុ សូម្បីទេពធីតាក៏មានរូបឆោមល្អល្អះ ដូចមានអាយុ ១៦ ឆ្នាំ បើជាទេវបុត្រវិញ ក៏មានរូបឆោមល្អល្អះដូចគ្នាដែរ ។

មាន ២០ ឆ្នាំជាកំណត់ ហេតុដូច្នោះ កាលបើទេវតាជិតចុតិ ទើបមានសរីរៈសៅហ្មង មានប្រការផ្សេងៗ ។

មួយទៀត ក្នុងស្ថានទេវលោកនោះ មិនបានដឹង នូវសេចក្តីទុក្ខលំបាកកាយ លំបាកចិត្ត ជរាបដល់អស់អាយុ ។ ទេវតាទាំងឡាយសោយទិព្វសម្បត្តិជាសុខុម រហូតដល់កាលជិតនឹងចុតិនោះ ខ្យល់ដកដង្ហើមក៏មិនស្រួល ឲ្យចង្អៀតក្នុងផ្លូវដកដង្ហើម ឲ្យក្តៅក្រហល់ក្រហាយ **ទិជិឞាត្តិ** តែងតែធ្វើកាយឲ្យស្ពឹកស្រពន់ ខ្ជិលច្រអូស មិនត្រេកអរក្នុងអាសនៈ មានអាការសោប់សេល់ កើតជាបុព្វនិមិត្តឲ្យឃើញប្រាកដនោះ ។ ធម្មតា ក្នុងមនុស្សលោកនេះ ស្តេច មហាមាត្យទាំងឡាយ ប្រកបដោយបុញ្ញាភិសម្ភារ កាលហេតុនឹងមានរមែងកើតមានបុព្វនិមិត្តប្រាកដ គឺឧក្កាបាតធ្លាក់ ផែនដីញាប់ញ័រ ចន្ទ្រគ្រាស និងសូរ្យគ្រាស យ៉ាងណា បុព្វនិមិត្តទាំង ៥ ប្រការនេះ ក៏កើតប្រាកដដល់ទេវទាំងឡាយ អ្នកទ្រទ្រង់មហេសក្ខានុភាពច្រើន

ដូច្នោះ ហេតុទាំងឡាយ គឺចន្ទ្រគ្រាស សូរ្យគ្រាសជាដើម បុគ្គលពួកដទៃមិនបានដឹង ដឹងតែចំណែកមនុស្សលោកមួយពួក យ៉ាងណាមិញ បុព្វនិមិត្តទាំងឡាយ ៥ ប្រការ កើតចំពោះទេវតាទាំងឡាយនោះ ទេវតាទាំងឡាយមិនដឹងឡើយ ដឹងបានតែទេវតាដែលជាអ្នកប្រាជ្ញ សេចក្តីទាំងឡាយនេះ មានក្នុង **អដ្ឋកថាមហាបទានសូត្រ** និង **អដ្ឋកថាឥតិវុត្តកៈ** ដូចគ្នា ៗ ប៉ុន្តែក្នុង **អដ្ឋកថាសក្កបញ្ហសូត្រ** នោះ កាលបើទេវតាទាំងឡាយចុតិហើយ ទីទៅរបស់អត្តភាពនោះមិនបានឃើញប្រាកដ និងមិនមានសាកសពដូចមនុស្សឡើយ ។ លុះចុតិហើយរាងកាយ ក៏សូន្យបាត់ទៅ **ឪបសិខាគមធំ វិយ** ប្រៀបដូចជាអណ្តាតប្រទីបរលត់ៗ សម្តែងមកដោយទេវតាទាំងឡាយ ក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

ទេវានំវិភាវនកថា ចប់

# បឋវីវឌ្ឍនវិភាវនកថា

**បឋវីវឌ្ឍន្តិ មហាភូតបឋវិយា វឌ្ឍនំ តត្រាយំ វិភាវនា ចន្ទិមសុរិយា ច ភូមិតោ ចត្តាឡីសសហស្សយោជនេ អាកាសបទេសេ វិចរន្តិ** *ឥឡូវនេះ នឹងវិសជ្ជនាក្នុងមាតិកា ពោលអំពីផែនដីចម្រើន កិរិយាដែលចម្រើនឡើងខ្ពស់នៃបឋវីដ៏ធំ មានសម្ដែងក្នុងលក្ខណៈ ផែនដីដែលដុះខ្ពស់ឡើង កំណត់យកផែនដីដែលដុះខ្ពស់ឡើងទៅលើអាកាសប្រមាណ ៤ ម៉ឺន ២ ពាន់យោជន៍ គឺជាទីកំណត់នៃព្រះចន្ទ្រ ព្រះអាទិត្យ ត្រាច់បំភ្លឺលោក ។ ពាក្យដែលថា ខ្ពស់ ៤ ម៉ឺន ២ ពាន់យោជន៍ជាទីកំណត់ព្រះចន្ទ្រព្រះអាទិត្យត្រាច់បំភ្លឺលោកដោយជុំវិញព្រះមេរុនោះ គឺពោលដោយអំណាចពីដំបូង តាំងពីផែនដីកើតឡើង ឥឡូវនេះ ផែនដីដុះខ្ពស់ឡើងរៀងរាល់ថ្ងៃ មនុស្ស និងស្ថានសួគ៌ ក៏នឹងជិតគ្នា និងមិនមានដល់ ៤ ម៉ឺន ២ ពាន់យោជន៍ ។ យល់ថា នឹងថយចុះ ២-៣ យោជន៍ដោយពិតសូម្បីផែនដីនឹងថយចុះ ២-៣ យោជន៍ ក៏មិនគួរនឹងរាប់ដែរ* **តថា វុត្តំ** *ក៏គួរនឹងពោលថា ខ្ពស់ ៤ ម៉ឺន ២ ពាន់ យោជន៍ជាកំណត់ ។ ក្នុងព្រះ*

ត្រៃបិដក ព្រះសម្ពុទ្ធត្រាស់សម្តែងថា ផែនដីដុះខ្ពស់ឡើងនោះ មានសេចក្តីដូច្នេះថា គុហាមួយ កើតមានឡើងក្នុងផែនដី ក្នុងកាលព្រះពុទ្ធសាសនាព្រះកស្សបទសពលនោះ ប្រាកដឃើញមាត់ល្អាង កាលផែនដីដុះខ្ពស់ឡើងៗ រហូតមួយពុទ្ធន្តរ គុហានោះក៏រាក់ ។ លុះដល់សាសនាព្រះសម្ពុទ្ធនៃយើង **ឯកោ សូករោ** មានជ្រូកមួយឈ្មួសដីចុះទៅ រហូតដល់ទីជិតនៃមាត់ល្អាងនោះ កាលរដូវវស្សា ភ្លៀងក៏ធ្លាក់ច្រោះដីរហូតដល់ឃើញមាត់ល្អាង **ឯកោ វនចរកោ** ព្រានព្រៃម្នាក់ដើរទៅដល់ទីនោះ **តំ លេណំ ទិស្វា** បានឃើញនូវល្អាងនោះ ទើបមានការប្រឹងប្រែងជញ្ជូនអាចម៍ដីដែលនៅជុំវិញ ដោយមានមនសិការថា ល្អាងនេះសមគួរនឹងជាទីនៅនៃលោក អ្នកទ្រទ្រង់ភេទបព្វជ្ជាដ៏វិសេស អាត្មាអញនឹងរៀបចំឲ្យស្អាត **លេណំ សោធាបេត្វា** ទើបនាយព្រានធ្វើការបោសសម្អាតលាង ល្អាងនោះឲ្យស្អាត ធ្វើជញ្ជាំងជុំវិញ និងមានទ្វារផង ធ្វើផ្ទៃភូមិភាគនោះ ឲ្យរាបស្មើល្អ ទើបយកដីខ្សាច់មានពណ៌សដូចពណ៌ប្រាក់ ដាក់ពង្រាយក្នុងបរិវេណនៃល្អាងនោះ **ភគវតោ អត្ថាយ អទាសិ** ទើបឯនាយព្រាននោះថ្វាយល្អាងនោះចំពោះព្រះមានព្រះភាគ ដើម្បីឲ្យព្រះអង្គសម្ងំនៅ

ដោយផាសុក ។ ល្អានទោះជ្រោត្រូវមានជណ្តើរចុះឡើង ប្រាកដឈ្មោះថា ល្អានជ្រូកឈ្មួស ហេតុដល់សព្វថៃនេះ ពាក្យដែលសម្តែងមកនេះ ព្រះអដ្ឋកថាចារ្យវិសជ្ជនាទុកនៅក្នុង **អដ្ឋកថាសំយុត្តនិកាយ** និង **ទីឃនខសូត្រ** ក្នុង **មជ្ឈិមនិកាយ** ។

មួយទៀត បាលី **អនមត្តគ្គសំយុត្ត** ថា **បព្វតានំ អវឌ្ឍ-ឆតោ បឋវី បន វឌ្ឍិត្វា បព្វតេ ឱសីទាបេសិ** ធម្មតា ផែនដីនេះមានតែចម្រើនខ្ពស់ឡើងៗ ហេតុញ៉ាំងភ្នំដែលខ្ពស់ឲ្យលិចចុះទៅក្នុងផែនដី ព្រោះថា ភ្នំទាំងឡាយមិនបានដុះចម្រើនឡើង ។

ព្រះបាលីក្នុង **អនមត្តគ្គសំយុត្ត** នោះសម្តែងថា **ភូតបុព្វំ ភិក្ខវេ ឥមស្ស វេបុល្លស្ស បព្វតស្ស ចាចីនវំសោតេវ សមញ្ញា ឧទបាទិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ មនុស្សទាំងឡាយមានឈ្មោះប្រាកដហៅថា **តិវរា** ។ មនុស្សទាំងឡាយដែលឈ្មោះថា **តិវរា** នោះ មានអាយុប្រមាណ ៤ ម៉ឺនឆ្នាំ មនុស្សទាំងឡាយនឹងឡើងចុះភ្នំបាចីនវង្សនោះយូរដល់ ៤ ថ្ងៃ ។ក្នុងគ្រានោះ ព្រះសម្ពុទ្ធព្រះនាមកកុសន្ធោ ជាអគ្គបុគ្គលដ៏ប្រសើរ បានសម្រេចដល់សម្ពោធិញ្ញាណត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ កើតឡើងក្នុងលោក ។ លុះចំណោរតមក

ភ្នំវេបុល្លនោះមានឈ្មោះហៅថា **ភ្នំវង្កត** ។ក្នុងគ្រានោះ មនុស្សទាំងឡាយក៏ប្រែប្រួល មានឈ្មោះថា **រោហិតស្ស** មនុស្សទាំងឡាយដែលឈ្មោះថារោហិតស្សនោះ មានអាយុប្រមាណ ៣ ម៉ឺនឆ្នាំ កាលនឹងឡើងចុះភ្នំវង្កតនោះ យូរដល់ ៣ ថ្ងៃ ក្នុងគ្រានោះ ព្រះសម្ពុទ្ធ ព្រះនាមកោនាគមនោបានត្រាស់ដឹងក្នុងលោក ។លុះចំណេរតមក ភ្នំវង្កតនេះមានឈ្មោះថា **សុបុស្សបពិត** ក្នុងគ្រានោះ មនុស្សទាំងឡាយមាននាមបញ្ញត្តិហៅថា **សុប្បិយ** មនុស្សដែលហៅថា សុប្បិយនោះ មានអាយុប្រមាណ ២ ម៉ឺនឆ្នាំ កាលនឹងឡើងចុះភ្នំសុបុស្សនោះ យូរប្រមាណដល់ ២ ថ្ងៃ ក្នុងគ្រានោះ ព្រះសម្ពុទ្ធ ព្រះនាមកស្សប ព្រះអង្គកើតឡើងក្នុងលោក **ឯតរហិ ខោ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយនុស្សទាំងឡាយ លុះកន្លងយូរមកដល់សព្វថ្ងៃនេះ ភ្នំសុបុស្សនោះក៏ត្រឡប់ក្លាយឈ្មោះថា **ភ្នំវេបុល្ល** ក្នុងកាលមនុស្សទាំងឡាយឈ្មោះថា **មាគធៈ** មនុស្សមាគធៈនោះមានអាយុតិចណាស់ **យោ ចិរំ ជីវតិ** មនុស្សណារស់នៅយ៉ាងយូរ មនុស្សនោះរស់នៅត្រឹម ១ រយឆ្នាំ ខ្វះច្រើនជាង ១ រយឆ្នាំខ្វះ ។ កាលនឹងឡើងចុះភ្នំវេបុល្លនេះ ត្រឹមតែមួយសន្ទុះប៉ុណ្ណោះ នេះសបញ្ជាក់ថា ផែនដីដុះឡើងជាលំដាប់ ក៏ក្នុងកាលព្រះពុទ្ធនៃយើង គួរនឹងពោលថា មនុស្សទាំងឡាយឡើងចុះភ្នំ

វេបុល្លនេះត្រឹមតែមួយថ្ងៃ ។ ប៉ុន្តែព្រះពុទ្ធ មិនបានត្រាស់ដូច្នោះទេ ព្រះអង្គមានព្រះពុទ្ធតម្រាស់ថា មនុស្សទាំងឡាយឡើងចុះភ្នំវេបុល្ល តែមួយស្របក់ គឺចន្លោះព្រះពុទ្ធកស្សប និងព្រះពុទ្ធនៃយើង ផែនដីដុះខ្ពស់ឡើងជាងពីមុន សមដូចពាក្យក្នុងជាតកនិទានថា ស្តេចមហាកាលនាគរាជ កាលបានស្តាប់នូវសំឡេងភាជន៍មាស ដែលព្រះមហាបុរសបណ្តែតទៅក្នុងស្ទឹង ក្នុងថ្ងៃដែលព្រះអង្គបានត្រាស់ដឹងសម្ពោធិញ្ញាណ ភាជន៍មាសដែលព្រះអង្គបណ្តែតទៅនោះ ប៉ះទង្គិចនឹងភាជន៍មាសដែលតាំងនៅអំពីមុននោះ មានសំឡេងក្រឹកៗ ក៏ពោលថា ម្សិលមិញ ព្រះពុទ្ធកើតឡើងក្នុងលោកមួយព្រះអង្គ ថ្ងៃនេះក៏កើតឡើងមួយព្រះអង្គទៀត ។ ការពិត ការដុះឡើងនៃផែនដីប្រមាណ ១ យោជន៍ និង ៣ គាវុតក្តី ជា ១ ពុទ្ធន្តរ ដូចមហាកាលនាគរាជកំណត់ថាថ្ងៃនេះ និងថ្ងៃម្សិលមិញនេះក៏ដូចគ្នា ។ ប្រសិនបើ មួយពុទ្ធន្តរនឹងកំណត់កាលយូរស្មើគ្នាប៉ុនគ្នា ព្រះពុទ្ធពីរព្រះអង្គកើតក្នុងកប្បណា កប្បនោះ ឈ្មោះថា វិវដ្តដ្ឋាយីអសង្ខេយ្យកប្ប គឺរាប់បាន ៦៤ អន្តរកប្បនោះ ក៏គួរនឹងពោលបានថា មួយពុទ្ធន្តរ ម្យ៉ាងទៀត ធម្មតាព្រះពុទ្ធទាំងឡាយ មិនកើតក្នុងលោកម្តងពីរព្រះអង្គទេ អ្នកប្រាជ្ញគប្បីសន្និដ្ឋានយល់ចូលចិត្តចុះថា មួយពុទ្ធន្តរមិនយូរស្មើគ្នា

ប៉ុនគ្នាឡើយ ព្រោះហេតុអ្វី ព្រោះថា អាចារ្យពោលថា ព្រះពុទ្ធអង្គ ដទៃកើតមុន អំពីដំបូងនៃបដិសន្ធិនៃព្រះពុទ្ធមួយព្រះអង្គក្តី កើតខាង ក្រោយពីព្រះបរមធាតុចូលកាន់ព្រះនិព្វានហើយក្តី មិនបានហាមឃាត់ ឡើយ ។ម្យ៉ាងទៀត កាលបើព្រះបរមធាតុរបស់ព្រះពុទ្ធមួយព្រះអង្គក្តី ចូលកាន់ព្រះនិព្វានកន្លងទៅយូរជរាបដល់កាលកំណត់ និងផែនដីដុះ ក្រាស់ឡើងប្រមាណ ១ យោជន៍ ទើបព្រះបារមីរបស់ព្រះពោធិសត្វ ចាស់ក្លាគ្រប់បរិបូណ៌ មិនមាននិយាមកំណត់បាន អាចារ្យទាំងឡាយ ពោលថា កាលយូរប្រមាណបាន ១០០០ ឆ្នាំ ផែនដីដុះក្រាស់ខ្ពស់ ឡើង ១ ថ្នាំងដៃ ។ លុះដល់ ១០០០ ឆ្នាំផែនដីដុះក្រាស់ខ្ពស់ឡើង ១ ថ្នាំងដៃ ។ រហូតដល់កាលផែនដីដុះឡើងប្រមាណ ១ យោជន៍ អស់កាល ប៉ុន្មាន កាលប្រមាណប៉ុណ្ណោះ ហៅថា មួយពុទ្ធន្តរ ។ ពាក្យដែល ពោលមកនេះ ជាពាក្យអធិប្បាយរបស់អាចារ្យទាំងឡាយ ហេតុដូច្នោះ មិនជាទីតាំងនៃផលឡើយ មិនយកជាប្រមាណ ។

**ឯវំ បន វឌ្ឍមានាយ បឋវិយា កស្មា សុរិយោ សន្តេ ន តាបេតិ** ទើបមានពាក្យសួរថា កាលបើផែនដីដុះខ្ពស់ឡើងនោះ ហេតុ ដូចម្តេច សុរិយោទ័យជិតគ្នានឹងសត្វទាំងឡាយ ទើបមិនបានញុំាងសត្វ ទាំងឡាយឲ្យក្តៅអន្ទះអន្ទែង ។

ធ្វើយថា កាលបើលោកវិនាសនោះ មានគំនរភ្លើង កាលកប្បវិនាសឆេះសន្ធោសន្ធៅឡើង ព្រមគ្នាទូទាំងសែនកោដិចក្កវាឡ តាំងនៅដោយជុំវិញ ក៏ជាប្រក្រតី មិនកើតភ្លើងប្រល័យឡើយ ភ្លើង ភ្លើងប្រល័យកប្ប ដែលដុតបំផ្លាញលោកនោះ មិនបានញុាំងសត្វទាំងឡាយក្នុងចក្កវាឡដទៃ ដែលតាំងនៅដោយជុំវិញនោះឲ្យក្តៅឡើយ ព្រោះកម្មដូច្នោះ ក្នុងចក្កវាឡទាំងឡាយ មិនបានកើតមាន **យថា** យ៉ាងណា កាលផែនដីចម្រើនឡើងទៅជិតនឹងព្រះអាទិត្យដែលបំភ្លឺលោក ព្រះអាទិត្យដែលបំភ្លឺលោកនោះ ក៏មិនអាចញុាំងសត្វឲ្យក្តៅបាន ដោយអានុភាពកម្ម **ឯវំ** ក៏មានសេចក្តីឧបមេយ្យដូច្នោះ **អយមេត្ថ បឋវី-វឌ្ឍនកថា សង្ខេបានយោ** សម្តែងដោយផែនដីចម្រើនខ្ពស់ឡើងក្នុងបទមាតិកានេះ ក៏ចប់ត្រឹមតែប៉ុណ្ណោះ ។

បឋវីវឌ្ឍនវិភាវនកថា ចប់

# មហីកម្បនវិភាវនកថា

**មហីកម្បនន្តិ បឋវិយា ចលនំ** *អធិប្បាយក្នុងបទមាតិកាពោលដោយផែនដីកក្រើកបន្តទៅ* **តត្រាយំ** *បាលី ក្នុងបទមាតិកានេះ មានព្រះបាលីព្រះសម្ពុទ្ធត្រាស់សម្ដែងថា* **អដ្ឋ ខោ អានន្ទ ហេតុប្បច្ចយា មហាតោ ភូមិចាលស្ស បាតុភាវាយ កតមេ អដ្ឋាតិ** *មានព្រះពុទ្ធដីកាត្រាស់ចំពោះព្រះអានន្ទថា* **អានន្ទ** *ម្នាលអានន្ទ ការកក្រើកនៃផែនដីនោះ ដោយហេតុ ៨ ប្រការ ។ ព្រះពុទ្ធដីកាដូច្នេះ ព្រះអង្គត្រាស់ទុកក្នុង* **មហាបរិនិព្វានសូត្រ** *អ្នកប្រាជ្ញគប្បីនាំមកសម្ដែងក្នុងទីនេះ ដោយន័យដែលមានក្នុងអដ្ឋកថា ដើម្បីនឹងធ្វើឲ្យប្រាកដថា ការកក្រើកនៃផែនដី ដោយហេតុ ៨ ប្រការនោះ* **វាយោធាតុកោបេ** *គឺការកក្រើកដោយវាយោធាតុបក់ខ្លាំងក្លា ១* **ឥទ្ធិមតោ ឥទ្ធិវិកុព្វនេ** *គឺកិរិយាសម្ដែងឫទ្ធិ របស់លោកអ្នកមានឫទ្ធានុភាព ១* **មាតុកុច្ឆិយំ ឱក្កមនេ** *ព្រះបរមពោធិសត្វចុះកាន់បដិសន្ធិក្នុងគភ៌របស់ព្រះមាតា ១* **និក្ខមនេ** *ព្រះបរមពោធិសត្វចេញបព្វជ្ជា ១* **អភិសម្ពោធិយំ** *ព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធ ១* **ធម្ម–**

**ចក្កប្បវត្តនេ** ព្រះមានព្រះភាគព្រះអង្គសម្ដែងធម្មចក្កប្បវត្តនសូត្រ ១ **អាយុសង្ខារវោស្សជ្ជនេ** ព្រះអង្គដាក់នូវព្រះជន្មាយុសង្ខារ ១ **បរិ-និព្វានេ** ព្រះអង្គរំលត់ខន្ធបរិព្វាន ១ ហេតុ ៨ ប្រការនេះប្រាកដមានហើយ ក៏ប្រព្រឹត្តទៅដើម្បីនឹងឲ្យការកក្រើកនូវផែនដី ។

ប្រការដែលពោលថា ការកក្រើកនៃផែនដី ដោយវាយោធាតុនោះ គឺខ្យល់មួយពួកឈ្មោះថា **ឧក្ខេបកវាត** កើតឡើងកម្ចាត់បង់ចេញនូវខ្យល់ដែលទ្រទឹកៗ នោះ កម្រាស់ ៩ សែន ៦ ម៉ឺនយោជន៍ ខ្ចាត់ខ្ចាយបាត់ទៅដោយកម្លាំងឧក្ខេបកវាតបក់ខ្លាំងក្លា គ្រានោះទឹកដែលទ្រនូវផែនដីក៏អណ្ដែតទៅឰដ៏អាកាស ។ កាលបើទឹកទ្រនូវផែនដីឡើងទៅលើអាកាសហើយ ផែនដីក៏អណ្ដែតនៅលើទឹក មានខ្យល់ឧក្ខេបកវាតបក់ខ្លាំងក្លា ក្រសោបយកនូវទឹកទ្រផែនដីក្រសោបយ៉ាងមាំ ដោយកម្លាំងរបស់ខ្លួនមិនបានកម្រើក ឲ្យនៅនឹងថ្កល់ ដូចទឹកខាងក្នុងនៃធម្មក្រក ។ លំដាប់នោះ ទឹកក៏ប៉ោងឡើងមក **ឧគ្គច្ឆតេ តស្មិំ** កាលបើទឹកទ្រផែនដីប៉ោងឡើងហើយ ផែនដីដែលតាំងនៅលើទឹកនោះ ក៏អណ្ដែតឡើង ទឹកទ្រផែនដីដូច្នេះ ទើបផែនដីកក្រើក ដូចសម្ដែងមកនេះ អាការដែលទឹក និងផែនដីកក្រើក

ទើបប្រាកដរហូតដល់សព្វថ្ងៃនេះ ក៏រមែងមានផែនដីកក្រើកដោយប្រការដូច្នេះ ។ អាការដែលផែនដីស្រុតចុះ និងប៉ោងឡើង មិនបានឃើញប្រាកដដល់សត្វលោកនោះទេ ព្រោះថា ផែនដីក្រាស់ធំទូលំទូលាយផុតចក្ខុវិស័យ សត្វទាំងឡាយមិនអាចឃើញបានឡើយ ។

ប្រការដែលពោលថា ការកក្រើកនៃផែនដីដោយឫទ្ធិរបស់លោកអ្នកប្រកបដោយឫទ្ធិនោះ ដូចព្រះមហាមោគ្គល្លានត្ថេរ ញុំាងនូវឫទ្ធិដើម្បីនឹងញុំាងធម្មសង្វេគឲ្យកើត ហើយក៏ញុំាងនូវផែនដីឲ្យកក្រើក ដូចព្រះសង្ឃរក្ខិតសាមណេរ ដែលត្រូវជាក្មួយរបស់ព្រះមហានាគត្ថេរ ញុំាងឫទ្ធិដើម្បីសាកល្បងឲ្យផែនដីញាប់ញ័រ ។

សេចក្តីថា គ្រាមួយ ព្រះសម្ពុទ្ធមានព្រះតម្រាស់នឹងព្រះមហាមោគ្គល្លានថា ម្នាលមោគ្គល្លាន អ្នកចូរញុំាងភិក្ខុទាំងឡាយប្រមាណ ៥០០ រូបដែលបួសថ្មី នៅមិនទាន់បានពិចារណាឃើញនូវព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្មទៅរួមប្រជុំគ្នា នៅលើថ្ងៃប្រាសាទរបស់នាងវិសាខា ហើយធ្វើសំឡេងអ៊ូអរអឺកធឹក ដោយពាក្យពោលដល់លាភសក្ការៈមានប្រការផ្សេងៗ ឲ្យកើតធម្មសង្វេគ ខណៈនោះ ព្រះមហាមោគ្គល្លានទទួលព្រះពុទ្ធដីកាថា សាធុ **អាចោកសិណំ សមាបជ្ជិត្វា**

ព្រះមហាមោគ្គល្លានក៏ចូលអាបោកសិណសមាបត្តិ សម្តែងនូវឫទ្ធិញ៉ាំង មហាប្រាសាទដែលតាំងនៅលើផែនដី ឲ្យញាប់ញ័រដោយមេជើងរបស់ លោក ប្រៀបដូចខ្យល់ព្យុះធំ បក់ខ្ទាំង ញ៉ាំងនាវាដ៏ធំឲ្យញាប់ញ័រ ។ **អថ តេ ភិក្ខុ វិស្សរំ ករោន្តា** ក្នុងគ្រានោះ ភិក្ខុទាំង ៥០០ រូបនោះ ភ័យតក់ស្លុតក្នុងចិត្តមួយរូបៗ ក៏ស្រែកយំ បោលចីវររបស់ ខ្លួនគេចរត់ទៅតាមទ្វារទាំង ៤ ។ ចំណែកព្រះមានព្រះភាគ ព្រះអង្គ គង់នៅក្នុងព្រះគន្ធកុដិ ភិក្ខុទាំងឡាយក៏នាំគ្នារត់តម្រង់ទៅកាន់សម្នាក់ ព្រះសាស្តា ហើយក្រាបថ្វាយបង្គំ មានកាយញាប់ញ័រ ព្រះសាស្តា ត្រាស់ថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកិយភ័យតក់ស្លុត ដូច្នេះ ព្រោះហេតុអ្វី ហេតុទាំងពួង គឺការញាប់ញ័រប្រាសាទនេះ មិនមែនជារបស់ដទៃទេ គឺមហាមោគ្គល្លាន ញ៉ាំងឫទ្ធិឲ្យប្រាសាទ នោះញាប់ញ័រ ដើម្បីញ៉ាំងភិក្ខុទាំងឡាយ ដែលមិនមានស្មារតី តាំង នៅក្នុងសេចក្តីប្រមាទ ដូចអ្នកទាំងឡាយនេះ ឲ្យដល់នូវសេចក្តី សង្វេគ **ធម្មំ ទេសេសិ** ហើយព្រះអង្គទ្រង់សម្តែងធម៌ទេសនាប្រោស ដល់ភិក្ខុទាំងឡាយនោះ ។

**សង្ឃរក្ខិតសាមណេរោ ខុរគ្គេ យេវ អរហត្តំ បត្វា ៦**

ព្រះសង្ឃរក្ខិតសាមណេរ កាលជម្រះកិច្ច គឺការកោរសក់រួចហើយ ក៏បានសម្រេចជាព្រះអរហន្ត ទើបត្រិះរិះថា វេជយ័ន្តប្រាសាទរបស់ព្រះឥន្ទ្រាធិរាជនោះ តើមានភិក្ខុរូបណាបានសម្រេចនូវព្រះអរហត្ត ហើយញ៉ាំងវេជយ័ន្តប្រាសាទឲ្យញាប់ញ័រអំពីកាលមុននោះ មានខ្លះឬទេ ? លុះពិចារណាទៅ ក៏ជ្រាបច្បាស់ថា មិនមានភិក្ខុរូបណានីមួយឡើយ ។ កាលសាមណេរដកពិសោធឫទ្ធិ ដោយគិតថា នឹងញ៉ាំងវេជយ័ន្តប្រាសាទរបស់សក្កទេវរាជឲ្យញាប់ញ័រ ទើបនិមន្តទៅដោយកម្លាំងអភិញ្ញា អណ្តែតនៅពីខាងលើវេជយ័ន្តប្រាសាទ ជាន់កំពូលប្រា-សាទដោយមេជើង ក៏មិនអាចញ៉ាំងវេជយ័ន្តប្រាសាទឲ្យកក្រើកបាន **អថ ឆាជកិត្តិយោ** កាលនោះ ទេពធីតាដែលកំពុងតែរាំថ្វាយដល់សក្កទេវរាជនោះ ក៏សើចចំអកព្រះសង្ឃរក្ខិតសាមណេរថា **បុត្តសង្ឃរក្ខិតោ** បពិត្រសង្ឃរក្ខិតសាមណេរអ្នកជាកូន លោកម្ចាស់ក៏នៅជាក្មេងតូច ព្រះសីសៈនៅមិនទាន់បាត់ជុំក្លិនទឹកដោះផងដូចម្តេចបានជាប្រាថ្នាញ៉ាំងវេជយ័ន្តប្រាសាទឲ្យញាប់ញ័រ វេជយ័ន្តប្រាសាទនេះមាំទាំណាស់ លោកម្ចាស់មិនអាចញ៉ាំងវេជយន្តប្រាសាទឲ្យញាប់ញ័របានឡើយ ។ ទើបសាមណេររំពឹងគិតពិចារណាថា ទេពធីតាទាំងនេះ

មកសើបចំអកអាត្មាអញ អាត្មាអញនៅមិនទាន់បានជួបអាចារ្យនៅឡើយ **ឆុខោ** គិតយ៉ាងណាហ្ន៎ គ្រានេះ ព្រះមហាថេរៈអាស្រ័យនៅក្នុងមហាសមុទ្រ ព្រះមហានាគត្រូវជាគ្រូអាចារ្យរបស់អញ លោកគង់នៅទីណាហ្ន៎ ។ កាលសាមណេរពិចារណាទៅក៏ឃើញអាចារ្យនិម្មិតប្រាសាទមួយនៅក្នុងមហាសមុទ្រ ព្រះថេរៈនិមន្តទៅគង់សម្រាកជាសុខក្នុងវេលាថ្ងៃ ។ លុះសាមណេរជ្រាបច្បាស់ដូច្នោះ ក៏ហោះទៅកាន់មហាសមុទ្រ ចូលទៅក្រាបថ្វាយបង្គំព្រះនាគត្រូវជាអាចារ្យ ។ កាលនោះ ទើបអាចារ្យពោលថា អាវុសោ ឥឡូវនេះ លោកមិនអាចតទល់នឹងទេវតាបានឬ ទើបលោកមកកាន់សម្នាក់ខ្ញុំរហូតដល់ផ្ទៃនៃមហាសមុទ្រនេះ លោកមិនអាចញុំាងវេជយ័ន្តប្រាសាទឲ្យកម្រើកបានឬ ? ទើបសាមណេរទូលថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណានៅមិនទាន់បានជួបគ្រូអាចារ្យជាមុន ទើបមិនអាចញុំាងវេជយ័ន្តប្រាសាទឲ្យកម្រើកទៅបាន **សាមណេរ** នែសាមណេរ បុគ្គលដែលប្រកបដោយឫទ្ធិដូចលោកនេះ មិនអាចធ្វើ ឲ្យកម្រើកបាន តើបុគ្គលដូចម្តេចទើបនឹងញុំាងវេជយ័ន្តប្រាសាទឲ្យកម្រើកបានទៅ ?ទើបព្រះមហាថេរៈប្រាប់ន័យដល់សាមណេរថា សាមណេរ ដុំអាចម៍គោដែលស្ងួត ដែល

អណ្តែតនៅលើផ្ទៃទឹកអំពីមុនមក លោកបានឃើញខ្លះដែរឬទេ ? នែសាមណេរ កាលមនុស្សទាំងឡាយ ធ្វើនំអំបែង ក៏រមែងចាក់មេ្សៅនំអំពីខាងៗ ចូលទៅ ក្នុងន័យទាំងនេះ ចូរលោកគិតទៅចុះ ។ ពាក្យទាំងនេះខ្ញុំព្រះករុណាយល់ច្បាស់ហើយ ខ្ញុំព្រះករុណានឹងញុំាងវេជយន្តឲ្យកម្រើកទៅបានជាមិនខាន ។ ខណៈនោះ សាមណេរក៏ក្រាបថ្វាយបង្គំលាគ្រូអាចារ្យចេញទៅ ទើបអធិដ្ឋានឲ្យកំពូលភ្នំព្រះសុមេរុដែលជាទីតាំងវេជយន្តប្រាសាទនោះឲ្យក្លាយទៅជាទឹកហើយ ក៏បែរមុខឆ្ពោះទៅវេជយន្តប្រាសាទ ហោះទៅកាន់ស្ថានតាវត្តិង្ស គ្រានោះទេពធីតាទាំងឡាយ មួយអន្លើៗ ក៏សើចចំអកសាមណេរថា លោកម្ចាស់សង្ឃរក្ខិតៈ ជាកូនរបស់យើង បានទូវភាពអាម៉ាស់មុខរត់ទៅហើយ ឥឡូវនេះលោកម្ចាស់ត្រឡប់មកម្តងទៀត មិនខ្មាចក្រែងទេឬ **សក្កោ ទេវរាជា** ទើបសក្កទេវរាជត្រាស់ថា នែនាងទាំងឡាយ ចូរកុំសើចចំអកឲ្យសាមណេរជាបុត្ររបស់យើង ឥឡូវនេះ សាមណេរបានជួបអាចារ្យហើយ បន្តិចទៀត ក៏នឹងញុំាងវេជយន្តប្រាសាទរបស់យើងឲ្យកម្រើក ។ ខណៈនោះ ទើបសាមណេរ ជាន់កំពូលវេជយន្តប្រាសាទ ដោយមេជើងប៉ុណ្ណោះ វេជយន្តប្រាសាទ ក៏យោ្រងយោ្រងទៅ

គ្រប់ទិសទាំង ៤ ។ ឯទេពធីតាទាំងឡាយភ័យតក់ស្លុត ក៏ស្រែកអង្វរថា **បតិដ្ឋាតុំ តេហិ** សូមលោកម្ចាស់ញុំាងវេជយន្តប្រាសាទឲ្យតាំងនៅដូចមុន ហើយក៏កើតនូវសេចក្តីសោមនស្ស បន្លឺនូវឧទានគាថាថា **អជ្ជេវាហំ បព្វជិតោ** ជាដើម  អធិប្បាយថា អាត្មាអញជាបព្វជិតកាលឥឡូវនេះ ដល់នូវការអស់អាសវៈ អាត្មាអញញុំាងវេជយន្តប្រាសាទឲ្យកម្រើកបានក្នុងកាលនេះ គុណព្រះពុទ្ធ គុណព្រះធម៌និងគុណព្រះសង្ឃដ៏ប្រសើរ អញបានឃើញប្រចក្សគ្រប់ប្រការ ។

**ឥមេសុ អដ្ឋ បឋវីកម្បេសុ** បណ្តាការកម្រើកនៃផែនដីដោយ ហេតុ ៨ ប្រការនេះ **បឋមោ** ការកក្រើកនៃផែនដីដោយហេតុទី ១ នោះ គឺកក្រើកដោយវាយោធាតុ ។ កក្រើកទី ២ គឺកក្រើកដោយអានុភាពបរិនិព្វាននៃព្រះសាស្តា សេចក្តីនេះអ្នកប្រាជ្ញគប្បីជ្រាបថា ការកក្រើកនៃផែនដីនោះ មិនកក្រើកដោយអំណាចនាងធរណី ឬទេវតាឡើយ ការកក្រើកនេះប្រព្រឹត្តទៅ ដោយអានុភាពឫទ្ធិ និងខ្យល់ដែលទ្រទឹកនោះ បើនឹងកំណត់ដោយវែងឆ្ងាយ គឺកំណត់ស្មើគ្នានឹងម៉ឺនចក្រវាលអន្តរធានទៅ ប្រាកដដូចខ្យល់ដែលឈ្មោះថា ឧក្ខេបកវាត តាំងនៅក្នុងឱកាសជាទី តាំងនៃខ្យល់ដែល

តាំងនៅក្នុងកាលមុន ខ្យល់ឧក្ខេបកវាតមានអាការដូច្នោះ ក៏កម្ចាត់បង់នូវខ្យល់ទ្រទឹកដែលក្រសោបឲ្យមាំទាំនោះ ដោយអំណាចលាតចេញដូចជាពិតាន ។ លុះខ្យល់បក់ខ្លាំងក្លាដូច្នោះ ទឹកក៏ប៉ោងឡើងទៅខាងលើ ការកក្រើកនៃផែនដីក្នុងចន្លោះ មិនមានឃើញប្រាកដទេ ព្រោះថា ផែនដីធំក្រៃលែងណាស់ ។ អធិប្បាយថា ផែនដីទាំងឡាយធំក្រៃលែង ក៏ស្រុតចុះប៉ោងឡើង ទើបមិនបានឃើញប្រាកដ សេចក្តីថា ការកក្រើកនៃផែនដីនោះ រកក្រើកដោយឥទ្ធិឫទ្ធិក៏មាន កក្រើកដោយបុញ្ញឫទ្ធិក៏មាន កក្រើកដោយកម្លាំងបារមីនៃព្រះសព្វញ្ញូពោធិសត្វក៏មាន កក្រើកដោយអានុភាពអសាធារណញ្ញាណក៏មាន ។ មួយទៀត ព្រះធម៌ទេសនា ដែលព្រះមានព្រះភាគត្រាស់សម្តែងនោះ ជាអសាធារណៈមិនបានទូទៅដល់អ្នកដទៃ បុគ្គលណានីមួយ មិនអាចសម្តែងព្រះធម៌ដូចព្រះពុទ្ធបាន ហេតុដូច្នោះ ការកក្រើកនៃផែនដីដោយអំណាចដែល ឲ្យសាធុការចំពោះព្រះធម៌ទេសនា **យេន ភគវា** ម្យ៉ាងទៀត ព្រះសាស្តាទ្រទ្រង់ព្រះសិរីស្អាតទៅដោយព្រះរូបឆោមវិចិត្រដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ប្រដាប់ដោយអនុព្យញ្ជនៈ ៨០ ប្រការ ។ ព្រះវរកាយបរិបូណ៌ដូចកែវដែលមានខ្លឹមសារ

ជាដើម គឺសីលក្ខន្ធាទិគុណដ៏បរិសុទ្ធដោយប្រការទាំងពួង គួរតែសរសើរ ព្រះសម្ពុទ្ធ ព្រះអង្គអាចទ្រទ្រង់ទុកនូវខន្ធបញ្ចកៈ មានសញ្ញាឈ្មោះថា អត្តភាពនៃព្រះអង្គ នឹងស្ថិតនៅយូរអស់មួយកប្បក៏បាន ច្រើនជាង មួយកប្បក៏បាន ព្រះអង្គមិនបានអាល័យ អើពើក្នុងសង្ខារធម៌ទាំង ឡាយ ដែលបច្ច័យប្រជុំតាក់តែង ដោយមិនមានព្រះទ័យប្រាថ្នានៅ ក្នុងលោក ដោយទ្រទ្រង់ព្រះញាណពិចារណា ស្អប់ខ្ពើមអៀនខ្មាស ក្នុងរូបកាយសង្ខារទាំងពួង មិនមានសេចក្តីអើពើ ហើយក៏ដាក់ចុះនូវ ព្រះជន្មាយុសង្ខារ ព្រះអង្គត្រាស់ចំពោះភិក្ខុទាំងឡាយថា កំណត់ ៣ ខែទៀត តថាគតនឹងរំលត់ខន្ធចូលកាន់ព្រះនិព្វាន ផែនដីត្រូវ អភិឃាត ព្រះពុទ្ធដីកាប៉ះខ្ទប់ប៉ុណ្ណោះ ផែនដីក៏មិនអាចទ្រទ្រង់នៅ ជាប្រក្រតីបាន ទើបកក្រើកញាប់ញ័រទូទាំងម៉ឺនលោកធាតុ ។ ព្រះពុទ្ធ ដីកាត្រាស់ចំពោះភិក្ខុសង្ឃទាំងឡាយនោះ ប្រកបដោយករុណា ផែនដី ត្រូវព្រះពុទ្ធដីកានេះពាល់ត្រូវ ក៏កក្រើក មិនអាចតាំងនៅបាន ផែនដី មិនមានចេតនាគង់ឲ្យសាធុការ ដោយសំឡេងញាប់ញ័រនោះ ។ កាល បើមានហេតុ ប្រាកដហើយ ផែនដីដែលមានកម្រាស់ ២ សែន ៤ ម៉ឺន យោជន៍ ទូលំទូលាយរហូតមួយម៉ឺនលោកធាតុ ក៏កក្រើកញាប់ញ័រ

កើតកោលាហល ទាំងនេះក៏កើតដោយអំណាចចិត្ត របស់ទេពធីតា ដែលរក្សានូវផែនដីនោះ បណ្តាលឲ្យកើតមហាអស្ចារ្យ មានប្រការផ្សេងៗ **វាតោ វាយតិ** ម្យ៉ាងទៀត ខ្យល់បក់ខ្លាំងក្លាកើតឡើង ដោយអំណាចនៃចិត្តវលាហកទេវតា យ៉ាងណាក្តី រដូវត្រជាក់ រដូវក្តៅ រដូវចុះអ័ព្ទ រដូវភ្លៀង ក៏កើតឡើងដោយអំណាច នៃសីតា-វលាហកៈ ឧណ្ហវលាហកៈ អព្ភវលាហកៈ និងវស្សវលាហកៈ ក៏មានឧបមេយ្យដូច្នោះឯង ។

មួយទៀត កាលដល់ថ្ងៃពេញបូណ៌មីខែពិសាខ ព្រះពោធិសត្វ ព្រះអង្គប្រថាប់គង់នៅលើរតនបល្ល័ង្កដ៏ប្រសើរ នៅខាងក្រោមនៃដើមមហាពោធិព្រឹក្ស ដើម្បីប្រយោជន៍នឹងបានត្រាស់ដឹងនូវសម្ពោធិញ្ញាណ **អចេតនាយម្បឋវី** គ្រានោះ ផែនប្រឹថពីដ៏ធំទម្លាយចេញជានាងទេពធីតា ក្នុងលំដាប់នៃព្រះពុទ្ធដីការបស់ព្រះសព្វញ្ញូសម្ពុទ្ធ ព្រះអង្គអធិដ្ឋានថា **អចេតនាយម្បឋវី** ផែនដីនេះមិនមានចិត្តវិញ្ញាណ មិនបានដឹងនូវសេចក្តីសុខ និងសេចក្តីទុក្ខ ក៏កក្រើកញាប់ញ័រដល់ ៨ ដង ដោយអំណាចទានបារមីរបស់តថាគត ជាសក្ខីភាពរបស់តថាគតផងចុះ ខណៈនោះ នាងធរណីក៏ប្រាកដជានាងទេពធីតា ដើម្បីនឹង

កម្ចាត់ចេញនូវស្តេចមារ មួយអន្លើដោយសេនា ដែលមាននៅជុំវិញព្រះអង្គ ប្រាថ្នាញ៉ាំងនូវសេចក្តីអន្តរាយចំពោះព្រះអង្គ នាងធរណីក៏ចាប់ទាញនូវផ្នួងសក់ច្បួតចុះក្រោម ញ៉ាំងទឹកដ៏ច្រើនឡើងជន់លិចពលមារ និងស្តេចមារាធិរាជដល់នូវសេចក្តីវិនាស ស្តេចមារាធិរាជក៏គេចរត់ចេញទៅ ។ ផែនដីមិនមានចិត្តវិញ្ញាណ ក៏បណ្តាលឲ្យកើត ជានាងទេពធីតាមានចិត្តវិញ្ញាណដូច្នេះ ។

ម្យ៉ាងទៀត ផែនដីនឹងឲ្យសាធុការ ឲ្យប្រព្រឹត្តទៅនូវសំឡេងសាធុនោះមិនមាន ព្រោះថា ផែនដីមិនមានចិត្តវិញ្ញាណ ក៏គួរនឹងពោលថា ផែនដីធ្វើឲ្យមានសំឡេងសាធុការ គឺប្រព្រឹត្តទៅដោយអំណាចធម្មតាដោយន័យដែលបានវិសជ្ជនារួចមកហើយអំពីមុន ។ **អានុភាវស–ភាវោ** អានុភាពរបស់បុណ្យក្តី ញាណក្តី រមែងកើតមានពិត អានុភាពរបស់បុណ្យទាំងនោះ មិនមែនដទៃឆ្ងាយ បើនឹងពោលដោយអត្ថ គឺថាធម្មតានៃបុណ្យ ធម្មតានៃធម៌ មិនមែនអ្វីដទៃឡើយ បើពោលដោយអត្ថ មានសេចក្តីដូច្នេះថា ធម្មតាបុណ្យក្តី ធម៌ក្តី គួរឃើញអស្ចារ្យយ៉ាងនេះ ។ ពាក្យទាំងឡាយដែលសម្តែងមក អ្នកប្រាជ្ញគប្បីពិចារណាតាមការអធិប្បាយផ្សេងៗ យ៉ាងនេះ ផែនដីដែលឈ្មោះថាសុធាធរណី

ដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ធំទូលាយទូទាំងម៉ឺនលោកធាតុកក្រើកញាប់ញ័រ ដោយអំណាចគុណនៃព្រះពុទ្ធ ព្រះអង្គពិចារណានូវធម៌ទាំងឡាយ មានបារមី ១០ ជាដើម ដែលមានកិច្ចនិងលក្ខណៈទៀតទាត់ស្ថិតស្ថេរជាដើមនោះ អ្នកប្រាជ្ញគប្បីពិចារណាឲ្យល្អដោយបញ្ញា ។ សម្ដែងតាមអដ្ឋកថា និងដីកានៃមហាបរិនិព្វានសូត្រ មានសេចក្ដីអធិប្បាយផ្សេងៗ ដូចពណ៌នាមកដូច្នេះ និងហេតុការណ៍កក្រើកនៃផែនដី មាន ៨ ប្រការនេះ ព្រះអដ្ឋកថាពោលទុកក្នុង **អដ្ឋកថាមហាបរិនិព្វានសូត្រ និង អដ្ឋកថាសុត្តនិបាត ក្នុង អង្គុត្តរនិកាយ** ការកក្រើកនៃផែនដី មិនមែនដោយហេតុត្រឹមតែប៉ុណ្ណោះទេ រមែងកក្រើកដោយហេតុ ៨ ប្រការដទៃទៀត **មហាភិនិក្ខមនេ** គឺកក្រើកដោយកម្លាំងការព្យាយាមរបស់ព្រះបរមពោធិសត្វ ព្រះអង្គយាងចេញបព្វជ្ជា ១ **ពោធិមណ្ឌុបសង្កមនេ** គឺកក្រើកដោយវិរិយៈរបស់ព្រះអង្គ កាលទ្រង់បព្វជ្ជា និងចុះកាន់ទីតាំងនៃពោធិញ្ញាណបារមី នៅទៀបគល់ពោធិព្រឹក្ស ១ **បំសុកូលគហនេ** ព្រះអង្គពិចារណានូវសំពត់មហាបង្សុកូលរបស់នាងបុណ្ណាទាសី ១ **បំសុកូលធោវនេ** ព្រះអង្គបោកនូវសំពត់បង្សុកូល ១ **កាលការាមសុត្តេ** គឺ ត្រាស់ទេសនាកាល

កាឡាមសូត្រ ១ **គោតមសុត្តេ** គឺត្រាស់ទេសនាគោតមសូត្រ ១ **វេស្សន្តរជាតកេ** ព្រះអង្គត្រាស់ទេសនាវេស្សន្តរជាតកប្រការ ១ **ព្រហ្មជាលេ** ព្រះអង្គត្រាស់ទេសនាព្រហ្មជាលសូត្រ ១ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ការកក្រើកផែនដីដោយហេតុ ៨ ប្រការទៀតដោយប្រការដូច្នេះ ។

អធិប្បាយថា **ចត្តារោ មហាទីបេ បហាយ បព្វជិត្វា** គឺទុក្ករកិរិយាដែលបុគ្គលធ្វើបានដោយលំបាកនោះ ព្រះបរមពោធិសត្វ ព្រះអង្គធ្វើបាន ព្រះអង្គលះបង់ចោលនូវរាជសម្បត្តិស្តេចចក្រពត្តិ ដែលព្រះអង្គជាធំក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារ ព្រះអង្គយាងចេញបព្វជ្ជា ព្រះអង្គទៅកាន់ព្រៃស្មសាន ។ កាន់យកសំពត់បង្សុកូលចីវរ ដែលជាគ្រឿងសម្រាប់ដណ្តប់ ជាការធ្វើបានកម្រក្រៃលែង គួរអស្ចារ្យ ផែនដីក៏ត្រូវអភិឃាតក៏កក្រើកម្តង។ កាលព្រះអង្គបោកសំពត់បង្សុកូលក្តី សម្តែងវេស្សន្តរជាតកក្តី ផែនដីក៏កក្រើកឡើង ។ ការកក្រើក នៃផែនដី គឺកក្រើកដោយគ្មានកាលកំណត់ កាលព្រះអង្គត្រាស់សម្តែង **កាលកាឡាមសូត្រ** និង **គោតមសូត្រ** ផែនដីក៏កក្រើកម្តង គឺកក្រើកដោយហេតុថា ផែនដី

នឹងជាសាក្សី ។ កាលព្រះអង្គត្រាស់សម្ដែងព្រហ្មជាលសូត្រ កម្ចាត់បង់នូវទិដ្ឋិ ៦២ ដែលជាព្រៃក្រាស់ នៅក្នុងសន្ដានរបស់សព្វសត្វនោះ ផែនដីក៏កម្រើកដោយអំណាចនៃការសម្រេចសាធុការ ។

**ឆ កោវលំ តេសុ យេវ ឋានេសុ** ផែនដីនឹងកើតការកក្រើក មិនមែនមានត្រឹមតែហេតុ ៨ ប្រការនោះទេ **អបរេហិ តីសុ មង្គលេសុ** កាលព្រះមហាថេរៈទាំងឡាយ លើកឡើងធ្វើសង្គាយនា ៣ ដង ផែនដីក៏កក្រើកដល់ ៣ ដង ។ សម័យមួយ ព្រះមហិន្ទត្ថេរចេញទៅកាន់លង្កាទ្វីប អង្គុយនៅនាចេតិយគិរីបព៌ត ព្រះថេរៈក៏សម្ដែងព្រះធម៌ទេសនា ថ្វាយព្រះរាជាក្នុងឧទ្យានក្នុងមហាមេឃវ័ន ផែនដីក៏កក្រើក ។ មួយទៀត កាលព្រះបិណ្ឌបាតិយត្ថេរ នៅក្នុងកល្យាណិយវិហារ ទៅធ្វើការបោសសម្អាតទីលានព្រះចេតិយ ហើយមកអង្គុយនៅទីលានព្រះចេតិយនោះ ក៏បាននូវបីតិ មានគុណព្រះពុទ្ធមកជាអារម្មណ៍ ទើបប្រារព្ធនូវព្រះសូត្រ ហើយស្វាធ្យាយព្រហ្មជាលសូត្រ **សុត្តន្តបរិយោសានេ** លុះចប់ព្រះសូត្រ ខណៈនោះ ផែនដីដែលមានទឹកជាទីបំផុត មានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ក៏កក្រើកញាប់ញ័រ ។

**អម្ពលដ្ឋិកដ្ឋានំ នាម** មួយទៀត មានទួលស្វាយមួយនៅខាងកើតនៃលោហប្រាសាទនោះ ជាទីអង្គុយរបស់ភិក្ខុសង្ឃទាំង-ឡាយ ដែលជាថេរានុត្ថេរ ជំនាញក្នុងទីឃនិកាយ អង្គុយនៅលើទីទួលនោះ ប្រារព្ធស្វាធ្យាយនូវព្រហ្មជាលសូត្រ **សជ្ឈាយបរិ-យោសានេ** លុះចប់ ព្រះសូត្រផែនដីក៏កក្រើកម្ដង ។

អាការកក្រើកនៃផែនដីក្នុងទីកន្លែងទាំងឡាយខ្វះក្តី និងការកក្រើកទូទាំងលោកធាតុក្តី គឺការកក្រើកដោយហេតុទាំងឡាយផ្សេងៗ ជាច្រើន តែថា ហេតុណានីមួយកើតមានហើយ ផែនដីក៏ញាប់ញ័រ ព្រោះហេតុដូចម្ដេច ទើបព្រះមានព្រះភាគត្រាស់ថា ការកក្រើកនៃផែនដីដោយហេតុ ៨ ប្រការប៉ុណ្ណោះ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ការកក្រើកនៃផែនដីដោយហេតុ ៨ ប្រការនោះ ជាការកំណត់យ៉ាងឧក្រិដ្ឋ ដែលនឹងកក្រើកដោយហេតុទាំងឡាយដទៃអំពីហេតុ ៨ ប្រការនោះ មិនជាការកំណត់ទេ ។ ជួនកាលសូម្បីកើតមានហេតុដ៏សេស ផែនដីក៏មិនបានកក្រើក ដូចព្រះយោគាវចរដែលបោកសំពត់បង្សុកូលក្តី ផែនដីក៏មិនបានកក្រើកឡើយ ។

មួយទៀត ព្រះធម្មកថិករូបដទៃ នឹងសម្ដែងនូវកាលការាមសូត្រ

គោតមសូត្រក្តី ផែនដីក៏មិនបានកក្រើក ទោះបីសម្តែងវេស្សន្តរជាតក សម្តែងព្រហ្មជាលសូត្រក្តី ផែនដីក៏មិនបានកក្រើកដូចព្រះសម្ពុទ្ធសម្តែង ព្រោះយ៉ាងនោះ ទើបពោលថា ហេតុដ៏សេសក្រៅអំពីហេតុ ៨ ប្រការនោះ មិនមានការកំណត់យ៉ាងឧក្រិដ្ឋទេ **មហាចលន-កថាសង្គហាណយោ** ន័យសង្គ្រោះយកការកក្រើកផែនដី ក្នុងបទមាតិកា *មហីកម្បនវិភាវនកថា* ចប់ត្រឹមប៉ុណ្ណេះ ។

មហីកម្បនវិភាវនកថា ចប់

# វុដ្ឋិវាតាទិកថា

**វុដ្ឋិវាតាទីនំ បវត្តិ វិការនំ** *សម្ដែងនូវអាការដែលកើតឡើងនៃភ្លៀង និងខ្យល់ជាដើមតទៅថា*

**តេ បន សីតវលាហក ឧណ្ហវលាហក អព្ភវលាហក វាតវលាហក វស្សវលាហក ទេវតានំ ចិត្តវសេន ភវន្តិ** *ការពិត រដូវត្រជាក់ក្ដី មេឃចុះអ័ព្ទក្ដី ខ្យល់បក់ខ្លាំងក្លាក្ដី ក៏រមែងកើតឡើងដោយអំណាចចិត្តរបស់សីតវលាហកទេវតា ( អ្នកបណ្ដាលនូវធាតុត្រជាក់ ) ឧណ្ហវលាហកទេវតា ( អ្នកបណ្ដាលនូវធាតុក្ដៅ ) វស្សវលាហកទេវតា ( អ្នកបណ្ដាលនូវភ្លៀង ) អព្ភវលាហកទេវតា (អ្នកបណ្ដាលនូវអ័ព្ទ) វាតវលាហកទេវតា (អ្នកបណ្ដាលនូវខ្យល់) នេះហៅថា ទេវតាទាំងឡាយជាពួកវលាហកៈ ។ ទេវតានេះជាអ្នកទ្រទ្រង់នូវឫទ្ធិ ញ៉ាំងនូវមេឃឲ្យកើតជាបច្ច័យដល់រដូវរងា ត្រជាក់ឲ្យកើតឡើង មានឈ្មោះប្រាកដថា* ***សីតវលាហកៈ*** *ទេវតាទាំងឡាយពួកនេះ ញ៉ាំងធាតុត្រជាក់ឲ្យកើតឡើងដូច្នោះ ក៏ផ្សាយចេញទៅនូវធាតុត្រជាក់ តាមការគួរដល់សេចក្ដីប្រាថ្នា រមែងធ្វើពពកឲ្យបិទបាំង*

ខាងនេះខាងនោះ ឲ្យត្រជាក់ទូទាំងក្នុងលោក ។ រដូវក្តៅ រដូវភ្លៀងក៏មានន័យដូចគ្នា កើតដោយអំណាចចិត្តរបស់ទេវតាទាំងឡាយ ។ កាលបើទេវតាទាំងឡាយឲ្យប្រាសចាករដូវត្រជាក់ រដូវក្តៅ រដូវភ្លៀងហើយ ក៏ញ៉ាំងរដូវចុះអ័ព្ទតែម្យ៉ាង ឲ្យកើតពពកពាសពេញ ។កាលបើមនុស្សលោកនេះនឹងកើត មានជារដូវភ្លៀង រដូវត្រជាក់ រដូវក្តៅ គឺវស្សន្តរដូវ ហេមន្តរដូវ គិម្ហន្តរដូវនោះ ក៏កើតមានការប្រព្រឹត្តទៅដោយអំណាចនៃចិត្តវលាហកទេវតាទាំងឡាយ អ្នកបណ្តាលឲ្យកើតឡើង បានតែធាតុត្រជាក់ម្យ៉ាង ។ ប្រសិនបើរដូវត្រជាក់កើតជាប្រក្រតី ក្នុងរដូវត្រជាក់នោះ ក៏បានឈ្មោះថា កើតតាមរដូវ ។ ប្រការមួយ ប្រសិនបើត្រជាក់កើតឡើង ក្នុងគិម្ហរដូវហួសប្រមាណនោះ ក៏គួរយល់ថា ធាតុត្រជាក់នោះ កើតដោយអានុភាពសីតវលាហកៈ **គិម្ហន្តវានេវ ឧណ្ហតំ** ប្រសិនបើក្តៅកើតក្នុងគិម្ហរដូវតែម្យ៉ាង ក្តៅជាប្រក្រតីធម្មតា មិនបានក្តៅពេក **ឧតុសមុដ្ឋាហិកំ** ឈ្មោះថា ក្តៅកើតតាមរដូវ **ឧណ្ហាបិ អតិឧណ្ហា** បើក្តៅហួសជាងប្រក្រតី ធម្មតា មិនបានកើតក្នុងរដូវក្តៅ ដូច្នោះ ប្រសិនបើក្តៅនោះត្រឡប់កើតមានក្នុងរដូវត្រជាក់ ប្រសិនបើមានយ៉ាងនេះ ក៏គួរយល់ចូលចិត្តចុះថា

ក្តៅនោះ កើតដោយអំណាចអានុភាពឧណ្ហវលាហកទេវតា ។

**វស្សានេ ច អត្តំ ឧប្បជ្ជតិ** ប្រសិនបើពពកកើតក្នុងវស្សន្តរដូវ កើតជាប្រក្រតីធម្មតា ក៏គួរយល់ថា ជាឧតុសមុដ្ឋានកើតចំពោះរដូវពិតប្រាកដ ។ **អត្តយេវ អតិអត្តំ** ប្រសិនបើពពកកើតជាប្រក្រតីធម្មតា កើតក្នុងខែចេត្រ ខែពិសាខ ពពកនោះបិទបាំងព្រះចន្ទទេវបុត្រ និងព្រះអាទិត្យទេវបុត្រឲ្យងងឹតហួស ៧ យប់ ៧ ថ្ងៃ **អត្តវលាហកទេវតានុភាវេន ឧប្បន្នអត្តំ ណាម** ពពកដូច្នេះគួរយល់ចូលចិត្តថា កើតដោយអានុភាពអត្តវលាហកទេវតា ។

**យោ តស្មិំ ឧតុម្ហិ** ខ្យល់បក់ជាប្រក្រតី គឺខ្យល់បក់អំពីទិសខាងជើងជាដើមក្នុងរដូវនោះ ខ្យល់ពួកនេះឈ្មោះថា **ឧតុសមុដ្ឋានវាត** កើតតាមរដូវ គឺមិនមែនជាខ្យល់បក់ខ្លាំងក្លា បំផ្លាញបោលនូវរុក្ខជាតិទាំងឡាយឡើយ ។ មួយទៀត ខ្យល់ដូចនេះក្តី ខ្យល់យ៉ាងដទៃក្តី រមែងបក់ខ្លាំងក្លា រហូតបំផ្លាញបោលនូវរុក្ខជាតិតូចធំទាំងឡាយ ក៏បានឈ្មោះថា **អកាលវាត** ជាខ្យល់កើតមិនមែនក្នុងរដូវ ខ្យល់យ៉ាងនេះគួរយល់ចូលចិត្តថា កើតដោយអានុភាពរបស់វាតវលាហកទេវតា ។

**ចត្តារោ មាសេ វស្សំ** ភ្លៀងធ្លាក់ចុះមួយរដូវ ( ៤ ខែ )

ដែលជាវស្សន្តរដូវ ភ្លៀងនោះឈ្មោះថា ឧតុសមុដ្ឋាន ភ្លៀងធ្លាក់តាមរដូវ ។ **ចិត្តវិសាខមាសេសុ** ប្រសិនបើភ្លៀងធ្លាក់ចុះមិនបានហួសកំណត់ ធ្លាក់ចុះក្នុងខែចេត្រ ខែពិសាខ ភ្លៀងធ្លាក់យ៉ាងនេះឈ្មោះថា កើតដោយអំណាចវស្សវលាហកទេវតា **តត្រិទំ វត្ថុ** មាននិទានរឿងជាឧទាហរណ៍មកអំពីមុនដូច្នេះថា **កិរ** បានឮមកថា វស្សវលាហកទេវតាមួយអង្គចុះមកកាន់សម្នាក់ព្រះខីណាស្រព ដែលអាស្រ័យនៅក្នុងតគរកូដ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាថេរៈក៏ស្ថិតនៅក្នុងទី ដ៏សមគួរ ។ គ្រានោះ ទើបព្រះមហាថេរៈមានថេរវាចាថា **កោសិ តុំ** លោកឈ្មោះអ្វី ? ទើបពិតដល់ព្រះមហាថេរៈថា **វស្សវលាហកទេវបុត្តោ** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាឈ្មោះថា វស្សវលាហកទេវបុត្រ **តុម្ហាកំ កិរ** បានមកថា ភ្លៀងរមែងធ្លាក់ចុះដោយអានុភាពលោកពិតមែនឬ ? **អាម ភន្តេ** បពិត្រលោកម្ចាស់ ភ្លៀងនោះរមែងធ្លាក់ចុះ ដោយអានុភាពរបស់ខ្ញុំព្រះករុណាពិតមែន ។ អើ ល្អហើយ អាត្មាចង់ឃើញអានុភាពរបស់លោក សូមលោកធ្វើ ភ្លៀងឲ្យធ្លាក់ចុះឲ្យអាត្មាឃើញច្បាស់បន្តិចសិនចុះ ។ បពិត្រលោកម្ចាស់ លោកម្ចាស់ចង់ឃើញអានុភាពរបស់

ខ្ញុំព្រះករុណាក៏បាន មិនជាថ្វីទេ តែថា ខ្ញុំព្រះករុណានឹងធ្វើក្នុងកាលឥឡូវនេះ លោកម្ចាស់ក៏នឹងទទឹក **មេឃសីលំ វា មេឃគជ្ជិតំ វា ន បញ្ញាយតិ** ព្រះថេរៈពោលថា ពពកខ្មៅ និងសំឡេងផ្គរមិនប្រាកដ តើអាត្មាសើមដូចម្ដេច ។ **សាលំ បវិស្សថ** បពិត្រលោកម្ចាស់ អាការដែលនឹងញ៉ាំងភ្លៀងឲ្យធ្លាក់ចុះនោះ មិនបានយឺតយូរទេ ប្រសិនបើខ្ញុំគិតឲ្យភ្លៀងធ្លាក់ ភ្លៀងក៏ធ្លាក់ចុះមកមួយរំពេច តាមវារចិត្តគិតរបស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ចូលទៅខាងក្នុងបណ្ណសាលាសិនចុះ ។ ខណៈនោះ ព្រះមហាថេរៈក៏ទទួលពាក្យថា សាធុ **ចាវេ គោវិន្ទា** ព្រះមហាថេរៈក៏លាងជើង រួចស្រេចហើយ ក៏ចូលទៅក្នុងបណ្ណសាលា ប៉ុន្តែខណៈនោះ ព្រះមហាថេរៈមិនទាន់ចូលក្នុងបណ្ណសាលាផង ទេវបុត្រក៏លើកដៃឡើងដេញភ្លេងវលាហកៈ ពពកក៏តាំងឡើងព្រមគ្នាមួយរំពេច ដែលមានប្រមាណ ៣ យោជន៍ ក៏ពាសពេញទៅដោយពពក ភ្លៀងក៏ធ្លាក់ចុះស្រោចស្រព ត្រូវកាយព្រះមហាថេរៈសើមពាក់កណ្ដាលខ្លួន ទើបចូលដល់ខាងក្នុងបណ្ណ-សាលា ការពិត ភ្លៀងដែលធ្លាក់ចុះរហ័សដូច្នេះ ក៏ព្រោះអំណាចចិត្តរបស់វស្សវលាហកទេវតា ។

មួយទៀត ព្រះអដ្ឋកថាចារ្យបានវិសជ្ជនាទុកនៅក្នុង **អដ្ឋកថា** វលាហកសូត្រ ក្នុង **សំយុត្តនិកាយ** ថា ភ្លៀងធ្លាក់នោះដោយហេតុ ៨ ប្រការ **នាគានុភាវេន** ភ្លៀងធ្លាក់ដោយអានុភាពនាគរាជ ១ **សុបណ្ណានុភាវេន** ភ្លៀងធ្លាក់ដោយអានុភាពសុបណ្ណរាជ ១ **ទេវតានុភាវេន** ភ្លៀងធ្លាក់ដោយអានុភាពរបស់ទេវតា ១ **សច្ចកិរិយាយ** ភ្លៀងធ្លាក់ដោយអំណាចការពោលនូវសច្ចវាចា ១ **ឧតុសមុដ្ឋានេ** គឺភ្លៀងធ្លាក់តាមរដូវ ១ **មារាវដ្ដនេ** ភ្លៀងធ្លាក់ដោយអានុភាពមារ ១ **ឥទ្ធិពលេន** ភ្លៀងធ្លាក់ដោយកម្លាំងឫទ្ធិ ១ **វិនាសមេឃេន** ភ្លៀងធ្លាក់ដោយកប្បវិនាស ១ ជា ៨ ប្រការដូច្នេះ លក្ខណៈភ្លៀងធ្លាក់នោះផ្សេងៗ ៨ ប្រការដូច្នេះ ។

សេចក្ដីមួយទៀត វិសជ្ជនាថា ព្រះឥន្ទ្រាធិរាជមានទេវបញ្ជាឲ្យរកវស្សវលាហកទេវបុត្រចូលមកជួប ហើយក៏មានព្រះរាជឱង្ការត្រាស់ឲ្យបណ្ដាលជាភ្លៀងធ្លាក់ ។ វស្សវលាហកទេវបុត្រ ក៏ទទួលបញ្ជា **ឯកំ វលាហកំ និវាសេត្វា** ក៏ទ្រទ្រង់ព្រះភូសាសម្រាប់វលាហកទេវបុត្រមួយផ្ទាំង ស្លៀកមួយផ្ទាំង ដណ្ដប់មួយផ្ទាំង ដេញភ្លេងវលាហកៈដើម្បីឲ្យភ្លៀងធ្លាក់រួចហើយ ក៏រត់ទៅក្នុងផ្ទៃអាកាស ស្ទុះទៅកាន់

អាកាស បែមុខទៅកាន់បាចីនលោកធាតុទាទិសខាងកើត ខណៈនោះ ដុំពពកក៏តាំងឡើងក្នុង ទិសខាងកើត មានប្រមាណប៉ុនលានស្រូវ ។ រំពេចនោះ ពពកក៏ក្រាស់ឡើងដល់រយពាន់ស្រទាប់ **អភិត្ថនន្តោ** ឲ្យសំឡេងគ្រហឹមលាន់ឡើងឰដ៏អាកាស ផ្គរបន្ទោរមានពន្លឺផ្លេកៗ ផ្ការទឹកភ្លៀងក៏ហូរធ្លាក់ចុះមកមួយរំពេច ប្រៀបដូចក្អមទឹកដែលបុគ្គលចាក់ផ្កាប់មានមាត់ចុះក្រោម ហូរជ្រួតជ្រាបលិចពេញភូមិ ពេញស្រុក ពេញក្រហែង ព្រែក អូរ គ្រប់កន្លែង សម្តែងមកនេះ ឲ្យយល់ថា ភ្លៀងនោះធ្លាក់ចុះទៅតាមចិត្តប៉ងនៃវស្សវលាហកទេវបុត្រ ។

ន័យមួយទៀត មានសេចក្តីវិសជ្ជនាទុកក្នុងអបណ្ណកជាតក ក្នុងឯកនិបាតនោះថា **វុដ្ឋិវាតោ យោជនមត្តំ វាយតិ** ខ្យល់ដែលប្រកបដោយតំណក់ទឹកភ្លៀង រមែងបក់ទៅឆ្ងាយបានមួយយោជន៍ **មេឃសីសំ យោជនមត្តំ បញ្ញាយតិ** មួយទៀត ដុំពពកនោះប្រាកដក្នុងទីឆ្ងាយបានមួយយោជន៍ បុគ្គលដែលនៅឆ្ងាយប្រមាណមួយយោជន៍នោះ អាចមើលឃើញដុំពពកដែលតាំងឡើង **វិជ្ជុលតា ចតុបញ្ញាសយោជនមត្តំ បញ្ញាយតិ** មួយទៀត ផ្គរបន្ទោរនោះប្រាកដឆ្ងាយបាន ៤-៥ យោជន៍ **មេឃសទ្ទោ ទ្វិយោជនមត្តំ**

**សុយាតិ** មួយទៀត សំឡេងផ្គរលាន់ឮ ឆ្ងាយបានប្រមាណ ២ យោជន៍ ។

ន័យមួយទៀត ព្រះអដ្ឋកថាចារ្យវិសជ្ជនាទុកនៅក្នុង អដ្ឋកថាធនិយសូត្រ ក្នុង សុត្តនិបាត នោះថា **គោបាលកា ឆាម វស្សនិមិត្តំ ជានន្តិ** នាយគោបាលទាំងឡាយនោះតែងតែដឹងវស្សនិមិត្ត យល់ច្បាស់ពិតថា ឆ្នាំនេះភ្លៀងធ្លាក់ច្រើន ឆ្នាំនេះភ្លៀងធ្លាក់តិចដឹងច្បាស់ដូច្នេះ ដោយសម្គាល់ហេតុនៃបក្សី និងក្តាម ។ បើបក្សីទាំងឡាយមានសត្វចាបពូកជាដើម ធ្វើសម្បុកលើចុងឈើ ធ្វើសម្បុកនៅទីខ្ពស់ មាណពអ្នកឃ្វាលគោទាំងឡាយក៏យល់ថា ឆ្នាំនេះភ្លៀងធ្លាក់ច្រើន ត្រូវធ្វើស្រែដែលទួល ទើបល្អ និងបានផលច្រើន **យទា សកុណិកា** ប្រសិនបើបក្សីទាំងឡាយធ្វើសម្បុកក្នុងទីទាប ធ្វើសម្បុកត្រង់មាត់ទឹកកាលណា មាណពអ្នកឃ្វាលគោទាំងឡាយក៏យល់ថា ឆ្នាំនេះ ភ្លៀងធ្លាក់តិច មិនល្អ ក្នុងកាលនោះ **កក្កដកា** បើក្តាមទាំងឡាយបិទរន្ធដែលធ្លាប់ចូលចេញក្នុងទីជិតទឹកនោះចោល ធ្វើរន្ធក្នុងទីទួល ដើរចូលចេញក្នុងទីទួលពេលណា មាណពអ្នកឃ្វាលគោទាំងឡាយក៏យល់ថា ឆ្នាំនេះភ្លៀងធ្លាក់ច្រើន ក្នុងកាលនោះ ។

ក្នុងដីកានោះអធិប្បាយថា រន្ទះបាញ់ មានលក្ខណៈ ៩ ប្រការ ក្នុងអដ្ឋកថាមហាបរិនិព្វានសូត្រក៏អធិប្បាយដូចគ្នាដែរ ។ រន្ទះបាញ់ មានលក្ខណៈ ៩ ប្រការនោះ គឺអសញ្ញា ១ ឯកចក្កា ១ សតេរា ១ តគ្គរា ១ កបិសីសា ១ មច្ឆវិលោលិកា ១ កុក្កុដកា ១ ទណ្ឌមណិកា ១ សុក្ខាសនី ១ ។ រន្ទះបាញ់ឈ្មោះ **អសញ្ញា** ញុាំងឲ្យបុគ្គលក្នុងប្រទេសនោះ ប្រាសចាកសញ្ញាគ្មានស្មារតី ដូចជាព្រះយោគាវចរ ដែលចូលកាន់សមាបត្តិ ៨ ។ រន្ទះឈ្មោះថា **ឯកចក្កា** មានរស្មីមូលដូចកងចក្រ ។ រន្ទះឈ្មោះ **សតេរា** មានរស្មីប្រាកដដូចក្តោងសំពៅ ដែលពាណិជបើកត្រដាងត្រង់សសរក្តោង ។ រន្ទះឈ្មោះ **តគ្គរា** ឲ្យលាន់ឮសំឡេងគ្រឹមៗ ប្រៀបដូចផ្គរលាន់ ។ រន្ទះដែលឈ្មោះថា **កបិសីសា** កាលធ្លាក់ចុះដល់ដីហើយ ក៏ត្រឡប់ផ្ងារឡើង មានអាការដូចស្វាដែលងើយមុខ សណ្ឋាននៃរស្មីនោះ មានអាការដូចក្បាលស្វា ។ នទះដែលឈ្មោះថា **មច្ឆវិលោលិកា** កាលដែលធ្លាក់ចុះដល់ដីហើយក៏ស្ទុះឡើង មានអាការដូចត្រីលោតឡើង ។ រន្ទះឈ្មោះ **កុក្កុដកា** មានរស្មីប្រាកដដូចមាន់ត្រដាងស្លាប ។ រន្ទះឈ្មោះ **ទណ្ឌ-មណិកា** មានរស្មីប្រាកដដូចរូបផ្នាំង ដែលបុគ្គលព្យួរត្រង់យាម

នឆ្គ័ល ។ វន្ទះឈ្មោះថា **សុក្ខាសនី** ធ្លាក់ចុះទីណា ក៏ទីនោះធ្វើឲ្យបែកខ្ទាត់ខ្ទាយ ធ្លាក់ត្រូវវត្ថុណាមួយក៏បាក់បែកខ្ទេចអស់ ។ វន្ទះឈ្មោះថា **សុក្កាសនី** នេះ មានរស្មីដ៏ក្តៅជាអណ្តាតភ្លើង មិនមែនត្រជាក់ដោយទឹក ធ្លាក់ចុះក្នុងទីណា អណ្តាតភ្លើងក៏ឆេះក្នុងទីនោះ អធិប្បាយដូច្នេះតាមពាក្យអដ្ឋកថា និងដីកានៃ **មហាបរិនិព្វានសូត្រ** ។

**យថា អន្តោ កុច្ឆិយំ សមិជ្ឈមានោ វាតោ ។បេ។ តំ លោកោ មេឃគជ្ជនន្តិ វទតិ** ម្យ៉ាងទៀត វាយោធាតុដែលនៅខាងក្នុងឧទរ-បទេស លុះប៉ះខ្ទប់គ្នាជាមួយនឹងផ្ទៃមេឃដែលកើតសម្រាប់រដូវ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើងឮដ៏អាកាស **ឯវមេវ តថា** មានឧបមេយ្យដូចជាវាយោធាតុ ក្នុងផ្ទៃពោះដែលបក់បោកប៉ះខ្ទប់នឹងផ្ទៃពោះ ញុំាងឲ្យមានសំឡេង គ្រកៗ គឺសំឡេងខ្យល់ និងសំឡេងទឹកភ្លៀងដែលប៉ះខ្ទប់គ្នានោះឯង មនុស្សទាំងឡាយហៅថា ផ្គរលាន់ **យថា ចាសា-ណាទីនំ បហារណាប្បច្ចយា** ម្យ៉ាងទៀត ខ្យល់ និងមេឃដែលប៉ះខ្ទប់គ្នានោះ មិនមែនប៉ះខ្ទប់តិចៗ ទេ គឺប៉ះខ្ទប់ខ្លាំង ទើបប្រាកដជាផ្ទេកបន្ទោរបាំងភ្នែក ប្រៀបដូចបុគ្គលវាយដែកបែកចេញជាផ្កាភ្លើង លុះដែកភ្លើង និងថ្ម ប៉ះគ្នា បែកចេញជាផ្កាភ្លើង ប្រាកដច្បាស់ធ្វើឲ្យបាំង

ក្អែកយ៉ាងណា កាលដែលខ្យល់ និងមេឃប៉ះខ្ទប់គ្នា ក៏ប្រាកដជាផ្ទេកបន្ទោរ មានឧបមេយ្យដូច្នេះ **សញ្ញាតា លោកំ វិជ្ជុតិ វធន្តិ** ផ្ទេកបន្ទោរកើតអំពីហេតុ គឺខ្យល់ និងមេឃ ប៉ះខ្ទប់គ្នានោះឯង ។ មនុស្សទាំងឡាយហៅថា ផ្ទេកបន្ទោរ **សុរិយរំសិយោ មេឃវលា-ហកមាគម្ម** មយ៉ាងទៀត ពន្លឺនៃព្រះអាទិត្យបំភ្លឺទៅឮដ៏អាកាសនោះបើប្រសព្វគ្នានឹងមេឃ ឃើញប្រាកដជាវង់កោង ប្រៀបដូចដងធ្នូក្នុងពេលណា មនុស្សទាំងឡាយហៅថា ឥន្ទធនូផឹកទឹក ហៅថា ធ្នូព្រះឥន្ទ្រក្នុងពេលនោះ គឺឥន្ទធនូផឹកទឹកនេះ បើជាវេលាព្រឹក រមែងប្រាកដក្នុងទិសខាងលិចបើជាវេលាល្ងាច រមែងប្រាកដក្នុងទិសខាងកើត កើតឡើងក្នុងកាលដែលព្រះ អាទិត្យស្រទន់ កើតក្នុងវេលាព្រឹក-ល្ងាច ពន្លឺព្រះអាទិត្យប្រសព្វគ្នានឹងមេឃ ដែលកើតតាមរដូវក្នុងអាកាសនោះ រមែងប្រាកដជារូបផ្សេងៗ ជួនកាលដូចរូបដំរី រូបសេះ រូបខ្លា រូបម្រឹគ រូបមនុស្ស រូបគ្រុឌ រូបនាគ ប្លែកៗ គ្នា ។ ជារូបដទៃៗ ហោរាទាំងឡាយពោលថា បញ្ញត្តិនាមផ្សេងៗ តាមតម្រាទស្សន៍ទាយដែលប្រាកដ ជាវង់ពន្លឺពណ៌ ក្រហម ពណ៌ខៀវចូលគ្នា ក៏ហៅថា ឥន្ទធនូផឹកទឹក ហៅថា ធ្នូព្រះឥន្ទ្រ ការពិត គឺមេឃដែលប្រសព្វស្របគ្នានឹង

ពន្លឺព្រះអាទិត្យនោះឯង ឆ្លើយដូច្នេះ អ្នកប្រាជ្ញគប្បីពិចារណាដោយបញ្ញា ហើយកាន់យក មិនមែនក្នុងអដ្ឋកថា និងដីកាឡើយ ។

នេះនឹងសម្តែងនូវអន្តរាយរបស់ភ្លៀងមាន ៥ ប្រការ តាមព្រះពុទ្ធដីកាដែលត្រាស់ទេសនាចំពោះភិក្ខុទាំងឡាយថា **បញ្ចិមេ ភិក្ខវេ វស្សស្ស អន្តរាយា យំ នេមិត្តកា ន ជានន្តិ យត្ថ នេមិត្តានំ ចក្ខុនិ នក្ខមន្តិ** ម្នាលភិក្ខុទាំងឡាយ អន្តរាយនឹងមិនឲ្យភ្លៀងធ្លាក់ដែលហោរមិនដឹង បញ្ញាចក្ខុនៃហោរដឹងមិនដល់មាន ៥ ប្រការ **កតមេ បញ្ច** អន្តរាយភ្លៀង ៥ ប្រការនោះ គឺអ្វីខ្លះ ? **អាកាសេ តេជោធាតុ កុប្បតិ** គឺតេជោធាតុក្នុងអាកាសកម្រើកក្តៅ អាបោ-ធាតុដែលកើតឡើងក្នុងអាកាសនោះស្ងួតទៅ មិនអាចតាំងនៅបាន ទោះបីមហាមេឃដ៏ធំនឹងមានឡើងក៏ដោយ **វិគច្ឆន្តិ** មហាមេឃក៏ហួតហែងសាបសូន្យអន្តរធានបាត់ទៅ មិនតាំងនៅ ព្រោះហេតុដែលតេជោធាតុក្នុងអាកាសក្តៅខ្លាំង ទាំងនេះចាត់ជាអន្តរាយនៃភ្លៀងទី ១ ។ វាយោធាតុក្នុងអាកាសកម្រើកមិនបានជាធម្មតា ខ្យល់បក់ខ្លាំងក្លា មហាមេឃដែលតាំងឡើងនោះ ប្រើនទៅដោយខ្យល់ **អយំ ទុតិយោ វស្សស្ស អន្តរាយោ** ទាំងនេះចាត់ជាអន្តរាយនៃភ្លៀងទី ២ ។

**ធារណភិនា ឧទកំ សម្បជិច្ចិត្វា** អសុរិន្ទរាហូដៃទទួលទទឹកភ្លៀងនោះ ហើយបាចទៅក្នុងមហាសមុទ្រ មិនឲ្យទឹកភ្លៀងនោះធ្លាក់ចុះបាន អាការដែលរាហូធ្វើនេះ ជាអន្តរាយដល់ភ្លៀងទី ៣ ។ **វលាហកទេវា បមត្តា ហោន្តិ** ទេវតាដែលមាននាទីញុំាងភ្លៀងឲ្យធ្លាក់ មានឈ្មោះថាវស្សវលាហកៈ មានសេចក្តីប្រមាទគ្មានស្មារតី មិនយកចិត្តទុកដាក់ដែលនឹងឲ្យភ្លៀង ទាំងនេះចាត់ជាអន្តរាយនៃភ្លៀងទី ៤ ដែលហោរទាំងឡាយមិនបានដឹង បញ្ញាចក្ខុរបស់ហោរទៅមិនដល់ ។ **មនុស្សា អធម្មិកា** មនុស្សទាំងឡាយមិនប្រកបដោយធម៌ តែងតែត្រេកអរក្នុងអំពើបាប ធ្វើកម្មដ៏លាមក មិនមានការខ្មាសអៀន ចិត្តប្រាសចាកការខ្វល់ខ្វាយក្នុងកិច្ចការជាកុសល ឬសុចរិត ចូលចិត្តតែក្នុងអំពើខុស ញុំាងអកុសលកម្មដ៏លាមក ខុសផ្លូវធម៌កាលណា ក៏ជាអន្តរាយនៃភ្លៀងទី ៥ ការគ្មានភ្លៀងធ្លាក់តាមរដូវទាំង ៥ នេះ ផុតវិស័យដែលហោរនឹងយល់ដឹង ព្រះពុទ្ធដីកាត្រាស់ទេសនាអន្តរាយនៃភ្លៀងមាន ៥ ប្រការដូច្នេះឯង ។

មួយទៀត មានសេចក្តីអធិប្បាយថា ចំពោះមនុស្សដែលមិនប្រកបដោយធម៌នោះ គឺក្សត្រទាំងឡាយ ព្រះអង្គគ្រប់គ្រងនូវភូមិភាគ

(ផែនដី) នេះ **អធម្មិកា ហោន្តិ** រមែងមិនតាំងនៅក្នុងទសពិធរាជធម៌ កាលបើក្សត្រទាំងពួងមិនតាំងនៅក្នុងទសពិធរាជធម៌ហើយ ឧបរាជ សេនាបតី ចុះរហូតទៅដល់ប្រជានុរាស្ត្រសាមញ្ញទាំងឡាយ ក៏មិនបាន ប្រកបដោយធម៌ កាលបើក្សត្រ និងជនសាមញ្ញជាដើមមិនប្រកប ដោយធម៌ហើយ ទេវតា ព្រហ្មទាំងឡាយក៏មិនបានតាំងនៅក្នុងធម៌ ។ កាលបើមនុស្ស និងទេវតាទាំងឡាយមិនបានតាំងនៅក្នុងធម៌ហើយ ព្រះចន្ទ និងព្រះអាទិត្យដែលវិលទៅជុំវិញភ្នំសុមេរុក៏គោចរមិនស្មើ មិន ដើរតាមប្រក្រតី ព្រោះថា សត្វទាំងឡាយមិនតាំងនៅក្នុងធម៌ ។ ទើប មានសេចក្តីអធិប្បាយថា កាលបើខ្យល់បក់មិនស្មើ បក់ខ្លាំងខ្លះ តិចខ្លះ មិនបានបក់ព្រះចន្ទ និងព្រះអាទិត្យឲ្យវិលជុំវិញភ្នំសុមេរុ មិនដើរតាមប្រក្រតីទេ អាស្រ័យហេតុណា អាស្រ័យហេតុដែលថា កម្មកើតជាឧបនិស្ស័យនៃអនិដ្ឋផល គឺកម្មដែលនឹងឲ្យផលមិនបាន ជាទីប្រាថ្នា មានរោគាព្យាធិផ្សេងៗ កើតដល់សត្វទាំងពួង ដែលមិន បាន តាំងនៅក្នុងធម៌ ព្រះចន្ទ ព្រះអាទិត្យដែលជាប្រធានរបស់ លោក ជាអ្នកបំភ្លឺលោកឲ្យភ្លឺ មិនបានប្រព្រឹត្តទៅដោយសមគួរដល់ វិថី ខ្យល់ក៏មិនបក់ដោយសមគួរដល់វិថី កាលបើខ្យល់មិនបក់តាមវិថី

ក៏ញ៉ាំងអាកាសដួកវិមានទាំងឡាយឲ្យកម្រើក កាលបើវិមានទាំងឡាយ កម្រើកដោយកម្លាំងខ្យល់នោះ ចិត្តរបស់ទេវតាទាំងឡាយ ក៏មិនបាន សប្បាយក្នុងការដែលលេងនក្ខត្តឫក្សតាមវិស័យរបស់ទេវតា កាល ទេវតាមិនសប្បាយចិត្តក្នុងការដែលលេងនក្ខត្តឫក្សហើយ រដូវផ្សេងៗ មានរដូវក្តៅ រដូវត្រជាក់ជាដើម ក៏មិនបរិបូណ៌ជាប្រក្រតី កាលបើ រដូវមិនជាប្រក្រតីដូច្នោះហើយ ភ្លៀងក៏មិនធ្លាក់ជាប្រក្រតីដែរ **កទាចិ វស្សតិ** ជួនកាលក៏ភ្លៀង ជួនកាលក៏រាំងក្នុងទីណាមួយ **វស្សន្តោបិ វស្សកាលេ** កាលបើផុតរដូវទៅហើយ ទើបភ្លៀងធ្លាក់ជាឧបការដល់ ពន្រ្លោះដែលព្រោះក្នុងស្រែ និងដល់នូវការបែកមាត់ចាបក្ដុះពន្លកឡើង ភ្លៀងរមែងធ្លាក់ចុះក្នុងកាលដែលព្រោះរួចហើយក៏មាន ជួនកាលរាំង គ្មានភ្លៀងសោះក៏មាន ហេតុដូច្នោះ ទើបពន្រ្លោះមិនមានផល ( ផ្លែ ) ស្មើ គឺស្អក ប្រាសាចាកក្លិន និងរស ។ កាលបើយកអង្ករនោះទៅ ចម្អិន ក៏មិនឆ្អិនល្អ កន្លែងខ្លះឆ្អិន កន្លែងខ្លះឆៅ ( បាយឆៅដុបៗ ) អង្ករប្រកបដោយទោសដូច្នេះ កាលបើមនុស្សទាំងឡាយបរិភោគ ក៏ មិនបានរលាយល្អ រមែងមានទោស ៣ យ៉ាង គឺមិនរលាយល្អ ១ រលាយចំណែកខ្លះៗ ១ រលាយតែមួយចំណែក ១ ។ ហេតុដូច្នោះ

សត្វទាំងឡាយបរិភោគនូវអាហារដែលសៅហ្មងនេះ ទើបកើតរោគផ្សេងៗ ទាំងអាយុក៏ខ្លី រហ័សស្លាប់ ។ ប្រសិនបើក្សត្រ និងប្រជាជនសាមញ្ញជាដើម តាំងនៅក្នុងធម៌ហើយ ទាំងព្រះចន្ទ និងព្រះអាទិត្យត្រាច់បំភ្លឺលោកស្មើ ជាប្រក្រតីតាមវិថី ដោយសមគួរដល់វិថីរដូវកាលទាំងឡាយក៏ស្មើល្អ ទាំងភ្លៀងក៏ធ្លាក់ចុះតាមរដូវមិនបានដាច់ ទាំងសស្សធញ្ញាហារក៏បរិបូណ៌សព្វគ្រប់ អង្ករក៏ប្រកបដោយឱជារស មនុស្សទាំងឡាយបរិភោគ ក៏ប្រកបទៅដោយគុណជាទីសប្បាយដល់ចិត្ត ក៏រមែងជាសុខសប្បាយ ប្រាសចាករោគាព្យាធិទាំងពួង ។

មានសំណួរថា **អគ្គិសន្តាបំ អាគម្ម** ហេតុអ្វីទឹកដែលនៅក្នុងភាជនៈ អាស្រ័យនូវភ្លើងដ៏ក្តៅ ទើបញ៉ាំងនូវសំឡេងឲ្យប្រាកដដល់ត្រចៀកនៃមនុស្សទាំងឡាយ **កស្មា សាគរំ លោណជាតំ** សេចក្តីមួយទៀតថា ហេតុដូចម្តេច ទើបទឹកក្នុងមហាសមុទ្រមានរសប្រៃ **កថំ បឋវិសន្ធារកំ** មួយទៀតថា ខ្យល់ទ្រទ្រង់ទុកនូវទឹកទ្រផែនដី ហេតុដូចម្តេច ទើបអាចបក់ទឹកមិនឲ្យហៀរទៅបាន **សព្វមេតំ មិលិន្ទរញ្ញា បុដ្ឋេន** ការសួរនេះព្រះបាទមិលិន្ទ ទ្រង់បានទូលសួរព្រះនាគសេនៗ ក៏បានឆ្លើយថ្វាយដោយពិស្តារ មានសេចក្តីពិស្តារ

ក្នុងមិលិន្ទប្បញ្ហានោះថា **មិលិន្ទោ រាជា** ព្រះបាទមិលិន្ទជាក្សត្រមានព្រះរាជឱង្ការត្រាស់សួរព្រះនាគសេនថា **ភន្តេ នាគសេន** បពិត្រលោកម្ចាស់នាគសេនដ៏ចម្រើន ទឹកដែលបុគ្គលយកទៅដាំនោះ កាលបើតម្កល់ទុកលើជើងក្រាន ក៏រមែងក្តៅហុយពុះកញ្ជ្រោល ញ៉ាំងសំឡេងឲ្យប្រាកដដល់សោតបសាទនៃជនទាំងឡាយ ទឹកនោះមានជីវិតឬ ឬថា ធម្មជាតិដទៃបៀតបៀន ទើបមានសំឡេងប្រាកដឡើង ខ្ញុំព្រះករុណាសង្ស័យណាស់ ? ទើបព្រះនាគសេនថ្វាយនូវចម្លើយថា **នហិ មហារាជ** សូមថ្វាយព្រះពរមហាបពិត្រ ទឹកនោះមិនមានជីវិតទេ ជីវិតក្តី សត្វក្តី ក៏មិនមានក្នុងទឹកនោះដែរ ពាក្យថា ទឹកមានសំឡេងនោះ អាស្រ័យភ្លើងញ៉ាំងឲ្យក្តៅ ទើបមានសំឡេង ។ ព្រះបាទមិនលិន្ទត្រាស់ថា លោកម្ចាស់ពោលថា ទឹកមិនមែនសត្វ មិនមែនជីវិត ខ្ញុំព្រះករុណាក៏ស្តាប់បានហើយ តែពួកនិគ្រន្ថអន្យតិរ្ថិយរាប់អានថា ទឹកមានជីវិត តែងតែតិះដៀលថា សមណៈអ្នកជាសក្យបុត្រ បៀតបៀនជីវិតសត្វ សូមលោកម្ចាស់ឆ្លើយនូវសេចក្តី ដែលសង្កត់សង្កិននូវបរប្បវាទ កុំឲ្យពួកនិគ្រន្ថអន្យតិរ្ថិយចូលមកនិន្ទាបាន **មហារាជ** សូមថ្វាយព្រះពរមហាបពិត្រ ទឹកដែលនៅក្នុងស្រះ ក្រហែង អូរ ព្រែក ជ្រោះ

ត្រពាំង ប្រឡាយ បឹងទាំងឡាយនោះ កាលបើត្រូវពន្លឺថ្ងៃក្នុងរដូវក្តៅ ក៏រមែងហួតហែងទៅក្នុងទីទាំងពួង មានស្រះបោក្ខរណីជាដើមនោះ ហេតុអ្វីមិនមានសំឡេង ហេតុអ្វីមិនឮសំឡេង មហាបពិត្របានឮថា ទឹកក្នុងទីទាំងឡាយ មានស្រះបោក្ខរណីជាដើមនោះ ញុំាងសំឡេងឲ្យប្រាកដឡើងខ្លះឬ ? ព្រះបាទមិនលិន្ទត្រាស់ថា **ន ហិ ភន្តេ** បពិត្រលោកម្ចាស់ ទឹកក្នុងទីទាំងឡាយ មានស្រះបោក្ខរណីជាដើមនោះ សូម្បីខ្យល់ និងកម្តៅថ្ងៃដុត ឲ្យហួតស្ងួតទៅ មិនមានសំឡេងលាន់ឮឡើយ **យទិ មហារាជ** សូមថ្វាយព្រះពរមហាបពិត្រពួកអន្យតិរ្ថិយទាំងឡាយប្រកាន់ថា ទឹកមានជីវិត ប្រសិនបើទឹកមានជីវិតពិតនោះ កាលដែលខ្យល់ កម្តៅថ្ងៃពាល់ត្រូវ ក៏រមែងនឹងញុំាងសំឡេងឲ្យប្រាកដឡើង ។ ប្រការមួយទៀត ទឹកនៅក្នុងបំពង់ដែលបុគ្គលតម្កល់ទុកក្នុងទីនោះៗ មិនបានធ្វើសំឡេងឲ្យលាន់ឮឡើយ ដោយហេតុអ្វី ? ឯទឹកក្នុងមហាសមុទ្រនោះ ហេតុអ្វី ទើបមានរលកញុំាងសំឡេងឲ្យលាន់ឮឡើងគ្រាំៗ ពេញផ្ទៃមហាសមុទ្រ ។ **មហា-វាតវេគមហន្តំ** បពិត្រលោកម្ចាស់ ទឹកក្នុងមហាសមុទ្រនោះ មិនអាចធន់ទឹងកម្លាំងខ្យល់បាន ព្រោះថា ខ្យល់ក្នុងមហាសមុទ្រនោះ

មានកម្លាំងខ្លាំងក្លា ទើបបង្កើតនូវរលកបោកបក់ ធ្វើនូវសំឡេងឲ្យលាន់ឡើងគ្រាំៗ ពេញផ្ទៃនៃមហាសមុទ្រ ។ ឯទឹកក្នុងទីទាំងឡាយ មានស្រះបោក្ខរណីជាដើមនោះ និងទឹកដែលបុគ្គលទុកក្នុងបំពង់នោះ មិនមានវត្ថុណាមួយប៉ះទង្គិច ទាំងខ្យល់ក៏មានកម្លាំងតិច មិនអាចបក់ឲ្យជារលកបាន ទើបមិនញុំាំងសំឡេងឲ្យលាន់រំពង ដូចជាទឹកក្នុងមហាសមុទ្រនោះ **មហារាជ** សូមថ្វាយព្រះពរមហារាជ ទឹកក្នុងសមុទ្រនឹងកម្រើកបង្កើតជារលក ញុំាំងសំឡេងគ្រាំៗ កងរំពងយ៉ាងណាក្តី ទឹកក្នុងភាជនៈដែលបុគ្គលតម្កល់ទុកលើជើងប្រានោះ ក៏មិនអាចធន់ទ្រាំបាន ទើបញុំាំងសំឡេងឲ្យប្រាកដឡើង ដោយអំណាចភ្លើងពុះក្តៅហុយឡើងឮដល់ត្រចៀកនៃបុគ្គលទាំងឡាយ ក៏មានសេចក្តីឧបមេយ្យដូចទឹកក្នុងមហាសមុទ្រ មានសំឡេងគ្រាំៗ ក៏អាស្រ័យដោយអំណាចខ្យល់ ។ ពាក្យដែលមហាបពិត្រប្រកាន់ថា ទឹកនេះមានជីវិត ទើបញុំាំងសំឡេងឲ្យប្រាកដឡើងបាន ប្រសិនបើមហាបពិត្រយល់ដូច្នោះ ទឹកក៏នឹងមាន ២ យ៉ាង គឺទឹកដែលញុំាំងសំឡេងឲ្យប្រាកដឡើងបាននោះមានជីវិត ទឹកដែលមិនញុំាំងសំឡេងប្រាកដបាននោះគ្មានជីវិត ក៏មាន ២ យ៉ាង ដូច្នេះ ។ **មហារាជ** សូមថ្វាយព្រះពរមហាបពិត្រ សូមទ្រង់កុំ

ប្រកាន់ថា ទឹកនោះមានជីវិតឡើយ ទឹកនេះមិនមែនសត្វ មិនមែនជីវិត ។ ប្រសិនបើទឹកមានជីវិត ដូចមហារាជមានព្រះរាជឱង្ការត្រាស់ហើយនោះ កាលដីរីមានខ្លួនដ៏ប្រសើរ បឺតទឹកផឹកដោយប្រមោយនោះ លុះដល់ចន្លោះធ្មេញដីរីនោះ ក៏រមែងញុំាងសំឡេងឲ្យប្រាកដដល់ត្រចៀកនៃបុគ្គលទាំងឡាយ នេះមិនដូច្នោះទេ មិនមានសំឡេងសូម្បីតែបន្តិចឡើយ ។ ហេតុដូច្នេះ ទើបទឹកនោះមិនមែនសត្វ មិនមែនជីវិត ។ អាការដែលទឹកញុំាងសំឡេងឲ្យប្រាកដឡើងនោះ អាស្រ័យដោយខ្យល់បោកបក់ ទើបរំជើបរំជួលលាន់ស្នូរគ្រាំៗ ទូទាំងផ្ទៃមហាសមុទ្រ សូមមហាបពិត្រទ្រង់ជ្រាប ដូចការថ្វាយនូវចម្លើយមកនេះ ។ ព្រះបាទមិលិន្ទ ទ្រង់បានព្រះសណ្តាប់ព្រះនាគសេនថ្វាយនូវចម្លើយដូច្នោះ ក៏ត្រាស់សរសើរព្រះនាគសេនដោយអនេកបរិយាយ ហើយក៏មានសំណួរតទៅទៀតថា

**ភន្តេ នាគសេន** បពិត្រព្រះនាគសេនដ៏ចម្រើន បញ្ញត្តិវោហារ ដែលហៅថា សមុទ្រនោះ យកនាមបញ្ញត្តិទឹកនោះឬ មកហៅថាសមុទ្រ ? ព្រះថេរៈវិសជ្ជនាថា **អាម មហារាជ** សូមថ្វាយព្រះពរមហារាជ ទឹកនេះឯងបានឈ្មោះថា សមុទ្រ **យត្តកំ ឧទកំ** សូម

ថ្វាយព្រះពរមហារាជ ទឹកក្នុងសមុទ្រនោះ មានប្រមាណប៉ុនណា ក៏រមែងមានរសប្រៃប៉ុណ្ណោះ ។ ព្រះរាជាត្រាស់សួរថា **កេនការណេន ឯករសោ** បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុអ្វីទឹកក្នុងមហាសមុទ្រនោះ ទើបមានរសប្រៃតែម្យ៉ាង ។ ព្រះថេរៈវិសជ្ជនាថា **ចិរំ ឋិតត្តា ខោ មហារាជ** សូមថ្វាយព្រះពរមហារាជ សេចក្តីដែលថា ទឹកក្នុងមហាសមុទ្រមានរសប្រៃតែម្យ៉ាងនោះ ព្រោះថា ទឹកនោះតាំងនៅយូរប្រមាណ ៦៤ កប្បជាកំណត់ កាលទឹកតាំងនៅយូរដូច្នោះហើយ ក៏កើតមានរសប្រៃតែម្យ៉ាង ។ ព្រះបាទមិលិន្ទត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សេចក្តីដែលថា ទឹកក្នុងមហាសមុទ្រមានរសប្រៃតែម្យ៉ាង ព្រោះថា តាំងនៅយូរ ខ្ញុំព្រះករុណាក៏ដឹងច្បាស់ហើយ ប្រការមួយទៀត លោកម្ចាស់មានថេរវាចាថា មហាប្រឹថពីដ៏ធំនេះតាំងនៅលើទឹក ទឹកតាំងនៅលើខ្យល់ ខ្យល់តាំងនៅលើអាកាស ពាក្យនេះខ្ញុំព្រះករុណានៅមិនទាន់ជឿទេ ។ ព្រះនាគសេនក៏លើកនូវធម្មក្រក ដែលដាក់ទឹកឡើង ទើបមានថេរវាចាថា សូមថ្វាយព្រះពរមហាបពិត្រ ទឹកក្នុងធម្មក្រកនេះ តាំងនៅដោយអំណាចខ្យល់ យ៉ាងណា ខ្យល់ដែលទ្រផែនដីនោះ ក៏បក់ទ្រទុកបាន ក៏មានឧបមេយ្យដូច្នោះ ។ បពិត្រ

មហារាជ សូមទ្រង់ជ្រាបដូចវិសជ្ជនាមកនេះ ។ ព្រះបាទមិលិន្ទក៏ទ្រង់ជ្រាបដូចព្រះនាគសេនថ្វាយនូវការវិសជ្ជនា **វុឌ្ឍិវាតាទិនំ សង្គហ-ឆយោ** ន័យនេះសង្គ្រោះយកនូវខ្យល់ និងភ្លៀងជាដើមក្នុងបទមាតិកានេះ ក៏ចប់ត្រឹមតែប៉ុណ្ណេះ ។

វុឌ្ឍិវាតាទិកថា ចប់

# បកិណ្ណកកថា

**បកិណ្ណកកថាតិ ឋោមិស្សកកថា តទេវំ វេទិតព្វំ តិវិធំ ហិ ចាដិហារិយំ ឥទ្ធិចាដិហារិយំ អាទេសនាចាដិហារិយំ អនុ-សាសនី ចាដិហារិយន្តិ** *ទាំងនេះនឹងសម្តែងក្នុងបទបកិណ្ណកកថា គឺសម្តែងនូវបទដែលរាយរង បន្ទាប់បន្សំ មានប្រការផ្សេងៗ ក្នុងបទបកិណ្ណកកថានេះថា បាដិហារ្យមាន ៣ ប្រការ គឺឥទ្ធិបាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ អធិប្បាយថា កាលព្រះយោគាវចរអ្នកស្ទាត់ជំនាញក្នុងឫទ្ធិប្រការផ្សេងៗ ញ៉ាំងឫទ្ធានុភាព ឲ្យប្រាកដដល់សត្វលោកទាំងឡាយនោះ ឈ្មោះថា ឥទ្ធិប្បាដិហារ្យ* **បរស្ស ចិត្តាចារំ ញត្វា កថនំ** *អាការដែលដឹងនូវវារៈចិត្តរបស់អ្នកដទៃ និងសម្តែងធម៌តាមអធ្យាស្រ័យរបស់សត្វនោះ* **អាទេសនាចាដិហារិយំ** *អាទេសនាបាដិហារ្យនោះ មិនមែនដទៃទេ គឺព្រះធម៌ទេសនារបស់ព្រះពុទ្ធទាំងឡាយ និងព្រះសាវកទាំងឡាយ ចាប់ផ្តើមតាំងអំពីព្រះអង្គបានត្រាស់ដឹងហើយ ក៏សម្តែងព្រះធម៌ទេសនាដូចគ្នានឹងព្រះពុទ្ធនៃយើងទ្រង់យាងទៅ ត្រាស់សម្តែងព្រះធម៌ទេសនា*

ព្រះធម្មចក្កប្បវត្តនសូត្រ ក្នុងព្រៃឥសិបតនមិគទាយវ័ន ប្រោស
បញ្ចវគ្គិយ **តស្ស តស្ស អជ្ឈាសយានុកុលំ** អាការដែលព្រះពុទ្ធ
ប្រទានឱវាទប្រៀនប្រដៅចំពោះព្រះសាវ័កទាំងឡាយ ដោយសមគួរ
អនុកូលតាមអធ្យាស្រ័យនៃសត្វនោះៗ ឈ្មោះថា អនុសាសនីបាដិ-
ហារ្យ តាមទំនៀមរបស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គយ៉ាងនេះមកមិនដាច់
ឥទ្ធិប្បាដិហារ្យ និងអនុសាសនីបាដិហារ្យនោះ ជារបស់ព្រះមហា
មោគ្គល្លានធ្លាប់ធ្វើដោយច្រើន ប៉ុន្តែអាទេសនាបាដិហារ្យ និងអនុ-
សាសនីបាដិហារ្យនោះ ជាព្រះធម៌ទេសនារបស់ព្រះពុទ្ធគ្រប់ៗ ព្រះ
អង្គ សេចក្តីនេះ ព្រះអដ្ឋកថាចារ្យវិសជ្ជនាទុកក្នុងអគ្គិនិព្វុតឋាន គឺទី
ជាទីរលត់នៃភ្លើងក្នុងវដ្តកជាតកនោះ ភ្លើងមិនបានឆេះ ក៏តាំងនៅអស់
មួយកប្ប **ឃដិការនិវេសនដ្ឋានំ** គឺផ្ទះទីលំនៅរបស់ឃដិការស្មូន
ឆ្នាំងនោះ ភ្លៀងក៏មិនបានលិច តាំងនៅអស់មួយកប្ប **ឆទ្បចា-
ទោក្ខរណីយំ បរិវារេត្វា ឧដ្ឋិតនឡា** ម្យ៉ាងទៀត ព្រៃបបោសទាំង
ឡាយដែលនៅជុំវិញនឡបានបោក្ខរណីនោះ មានប្រហោងរហូតដល់
ចុង ក៏តាំងនៅអស់មួយកប្ប ។ មានសេចក្តីថា នាយឃដិការស្មូន
ឆ្នាំងបានសម្រេចដល់ព្រះអនាគាមិផល អាស្រ័យនៅក្នុងវេហឡនិគម

នាយស្នូនផ្ទាំងនោះ ចិញ្ចឹមមាតាបិតាដែលចាស់ជរាគ្រាំគ្រា មានក្អែក ងងឹត **ភគវន្តំ ឧបដ្ឋាតិ** ហើយក៏បានជាឧបដ្ឋាកព្រះសម្ពុទ្ធព្រះនាម កស្សបៈ ។ សម័យមួយ ព្រះគន្ធកុដិព្រះមានព្រះភាគនោះលិចភ្លៀង ទទឹកព្រះអង្គ ទើបព្រះអង្គត្រាស់ប្រើភិក្ខុទាំងឡាយ ឲ្យទៅរុះរើដំបូល ផ្ទះមាតាបិតារបស់នាយឃដិការស្នូនផ្ទាំងនោះ យកមកប្រក់ដំបូល ព្រះគន្ធកុដិ គ្រានោះ ដំបូលផ្ទះនោះ ក៏អស់ទៅ មានតែអាកាស ជាដំបូលគ្មានគ្រឿងប្រក់ ក៏ប៉ុន្តែសូម្បីមានភ្លៀងខ្លាំងធ្លាក់ចុះមក យ៉ាងណា ទីនេះមិនបានទទឹកសូម្បីត្រឹមតែមួយតំណក់ ។ មួយទៀត ខ្យល់ កម្តៅថ្ងៃ ក៏មិនបានបៀតបៀន មនុស្សដែលនៅក្នុងផ្ទះនោះក៏ រស់នៅជាធម្មតា សមគួរតាមរដូវ ។ ចំណេរកាលតមក និគមនោះ មនុស្សលះបង់ចោលនៅតែទីទទេប៉ុណ្ណោះ ភ្លៀងក៏មិនបានលិចកន្លែង នោះដែរ ។ មនុស្សទាំងឡាយទៅធ្វើស្រែចម្ការនោះ លុះមាន ភ្លៀងធ្លាក់ចុះមក ក៏យកសម្លៀកបំពាក់ និងវត្ថុអ្វីៗ ទៅទុកក្នុងទីនោះ ហើយក៏ធ្វើនូវការងាររបស់ខ្លួន ភ្លៀងមិនបានធ្លាក់ត្រូវរបស់ទាំងឡាយ នោះទេ **តញ្ច ទោ ឋានំ** ទើបកន្លែងនោះជាបាដិហារ្យប្រាកដដូច្នេះ មិនមែនអានុភាពឡើយ ជាបាដិហារ្យកើតប្រាកដ ដោយគុណសម្បត្តិ

របស់មនុស្សទាំងឡាយនោះ ដែលធ្វើនូវការគោរពចំពោះព្រះសម្ពុទ្ធ អធិប្បាយថា មាតាបិតារបស់យដិការស្នូនថ្មាំង នឹងបានកើតទោមនស្សតូចចិត្តថា ហេតុដូចម្តេចព្រះពុទ្ធប្រើឲ្យភិក្ខុសង្ឃ មករុះរើជំបូលផ្ទះរបស់យើង ដែលជាអ្នកមានក្អែកងងឹតដូច្នេះ អ្នកទាំងពីរនាក់នោះមិនបានគិតដូច្នោះទេ ត្រឡប់កើតសោមនស្សខ្លាំងក្លា ក្លេចបរិភោគអស់ ៧ ថ្ងៃថា ព្រះមានព្រះភាគ ជាអគ្គបុគ្គលដ៏ប្រសើរក្នុងលោកទេវលោក មារលោក និងព្រហ្មលោក ព្រះអង្គឲ្យនាំយកជំបូលផ្ទះរបស់អញទៅប្រក់ព្រះគន្ធកុដិ ហេតុដូច្នេះ ទើបជាបាដិហារិយ្យតាំងនៅអស់មួយកប្ប ។ ក្នុង ព្រះអដ្ឋកថាអង្គុលិមាលសូត្រ សម្តែងថា បាដិហារ្យដែលតាំងនៅអស់មួយកប្បនោះគឺទីកន្លែងឯណា ដែលអង្គុលិមាលគង់ធ្វើនូវសច្ចកិរិយា ដើម្បីនឹងឲ្យស្ត្រីប្រសូតបុត្រមិនរួច ត្រឡប់ឲ្យប្រសូតបុត្រមានសិរីសួស្តី គ្មានអន្តរាយ គ្រែនោះ មនុស្សទាំងឡាយនាំសត្វតិរច្ឆានញីមានគភ៌ចាស់ កើតកូនមិនរួច មកដាក់ចុះលើគ្រែឲ្យដេក ក្នុងខណៈនោះ សត្វតិរច្ឆាននោះក៏កើតកូនរួចដោយមិនមានអន្តរាយ **យា ទុព្វលា** ស្ត្រីភេទណាទុព្វលភាពខ្លាំងមិនអាចនាំយកមកឲ្យដេកនៅលើគ្រែនោះបាន យកតែទឹកលាងគ្រែទៅ

ស្រោចពីលើក្បាលស្ត្រីនោះប៉ុណ្ណោះ ក៏ប្រសូតបុត្របានងាយគ្មានអន្តរាយ **អញ្ញំបិ ភោគំ** មួយ៉ាងទៀត ភោគជទៃៗ ក៏រម្ងាប់អស់ទៅដែរ សេចក្តីថា គ្រៃដែលព្រះអង្គុលិមាលធ្វើសច្ចកិរិយានោះ ប្រាកដជាបាដិហារ្យតាំងនៅអស់មួយកប្បដោយប្រការដូច្នេះ ។

ក្នុងសកលជម្ពូទ្វីបនេះ ន័យមួយទៀតថា បានឮសំឡេង ៤ ប្រការ ផ្សាយចេញទូទាំងជម្ពូទ្វីប គឺយក្ខសេនាបតីឈ្មោះបុណ្ណកយក្ខលេងបាស្កា ភ្នាល់ជាមួយនឹងស្តេចធនញ្ជ័យកោរព្យរាជ ប្រសិនបើឈ្នះហើយ ក៏ទះដៃប្រកាសថា យើងឈ្នះហើយប្រការមួយ ។ ការស្រែកប្រកាសរបស់ព្រះឥន្ទ្រ ក្នុងកាលព្រះពុទ្ធសាសនានៃព្រះពុទ្ធកស្សបរៀវរោយថយចុះ ក៏បានញុំាំងវិស្សកម្មទេវបុត្រជារូបសុនខធំឲ្យស្រែកឡើងថា យើងនឹងខាំស៊ីនូវភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាទាំងឡាយ ដែលជាមនុស្សបាប មនុស្សអធម៌នោះប្រការមួយ ។ ក្នុងកាលព្រះនគរ ត្រូវក្សត្រាធិរាជទាំងឡាយ ៧ អង្គមកហ៊ុមទុកព្រោះចង់បាននូវបភាវតីទេវី ដែលជារបស់ព្រះបរមពោធិសត្វកុសរាជ ។ គ្រានោះ ព្រះបរមពោធិសត្វមហាបុរសដ៏ប្រសើរ លើកនាងបភាវតីឡើងជិះដំរីជាមួយនឹងព្រះអង្គ ស្តេចចេញអំពីព្រះនគរ

ដើម្បីនឹងធ្វើសង្គ្រាមជាមួយនឹងក្សត្រទាំងនោះ ហើយទ្រង់បន្លឺសីហនាទថា យើងឈ្មោះមហាកុសរាជ ដែលជាផៅពង្សសីហរាជដ៏ប្រសើរ សូរសីហនាទនោះ ក៏លាន់ឮឡើងពេញទាំងជម្ពូទ្វីបប្រការមួយ ។ កាលបើអាឡវកយក្ខឈរនៅលើកំពូលភ្នំកៃលាស ហើយប្រកាសប្រាប់ឈ្មោះថា យើង គឺអាឡវកយក្ខនោះប្រការមួយ ។ រីសំឡេងទាំងឡាយ ៤ ប្រការដែលប្រាកដបានឮទូទាំងសកលជម្ពូទ្វីប ប្រៀបដូចសំឡេងដែលបុគ្គលឈរនៅក្បែរមាត់ទ្វារផ្ទះ ហើយស្រែក ។

ក្នុងលោកនេះឮថា អាវុធទាំងឡាយដ៏ប្រសើរទាំងឡាយមាន ៤ យ៉ាង គឺវជិរាវុធរបស់ព្រះឥន្ទ្រ ១ គទាវុធរបស់ ស្តេចវេស្សវ័ណ ១ នយនាវុធរបស់ស្តេចយមរាជ ១ ធ្នូតក្បាលរបស់អាឡវកយក្ខ ១ ។ អធិប្បាយថា បើព្រះឥន្ទ្រនឹងប្រហារនូវភ្នំសិនេរុ គប្រវែងទៅនូវវជិរាវុធ ភ្នំសិនេរុដ៏ខ្ពស់ធំ ក៏នឹងបាក់បែកខ្ទេចខ្ទីរាបស្មើផ្ទៃដី ។ ម្យ៉ាងទៀត កាលស្តេចវេស្សវ័ណនៅជាបុថុជ្ជននោះ បានគប្រវែងដំបងទៅចំក្បាលរបស់យក្ខទាំងឡាយច្រើនជាងពាន់នាក់ ឲ្យដាច់ធ្លាក់ចុះ ដំបងនោះក៏វិលត្រឡប់មកកាន់ព្រះហស្តទ្រង់វិញ ។ មួយទៀតសោត យមរាជមានឫទ្ធិ កាលកើតសេចក្តីក្រោធ នឹងសម្លក់សម្លឹងពួក

កុម្ភណ្ឌ ឬពួកយក្ខទាំងឡាយ ច្រើនជាងពាន់នាក់ក៏នឹងវិនាសខ្ចាត់ខ្ចាយទៅ ប្រៀបដូចគ្រាប់ល្ងដែលគេដាក់ក្នុងខ្ទះដ៏ក្ដៅ ។ ម្យ៉ាងទៀត បើអាឡវកយក្ខខឹងក្រោធ បោះសំពត់ធ្នួតក្បាលទៅលើអាកាស ភ្លៀងត្រូវរាំងអស់ ១២ ឆ្នាំ បើបោះទៅលើផែនដី បណ្ដារុក្ខជាតិតូចធំទាំងឡាយ ក៏នឹងក្រៀមក្រញង់ មិនដុះឡើងវិញអស់ ១២ ឆ្នាំ ។ បើបោះទៅក្នុងមហាសមុទ្រ ទឹកក្នុងផ្ទៃមហាសមុទ្រក៏នឹងរីងអស់ទៅ ដូចជាតំណក់ទឹកតិចតួចធ្លាក់ចុះក្នុងខ្ទះដ៏ក្ដៅ បើចោលទៅត្រូវភ្នំដ៏ធំដូចជាភ្នំសិនេរុនោះ ក៏នឹងបែកដាច់ខ្ទេចខ្ទីចេញអំពីគ្នា ជាដុំតូចធំខ្ចាត់ខ្ចាយទៅ ។

ក្នុង **អដ្ឋកថាសំយុត្ត** ថា ការប្រហារមាន ៤ ប្រការ **១– ឱមដ្ឋោ** គឺបុគ្គលឈរនៅលើទីខ្ពស់ឱនមុខចុះទើបប្រហារប្រការមួយ **២– ឧមដ្ឋោ** គឺបុគ្គលឈរនៅខាងក្រោមងើយមុខឡើងលើ ទើបប្រហារប្រការមួយ **៣– វេមដ្ឋោ** គឺបុគ្គលប្រហារដោយជុំវិញប្រការមួយ ។ រីការប្រហារទាំង ៣ យ៉ាងនោះប្រមូលចូលគ្នា ឈ្មោះថា វិមដ្ឋប្រការមួយ ចាត់ជាលក្ខណៈប្រហារគ្នា ក្នុងយុទ្ធនាការសង្គ្រាមតទល់គ្នា ទើបតាំងចតុរង្គសេនា ៤ ប្រការ ហៅថា ហត្ថាណិក ១ អស្សាណិក ១ រថាណិក

១ បត្តាណិក ១ ។ អធិប្បាយថា ហត្ថាណិកៈនោះ គឺដំរី ៣ ក្បាល ដំរីមួយក្បាលៗ នោះ មានបុរស ១២ នាក់ គឺបុរសជិះលើខ្នងដំរី ៤ នាក់ បុរសដែលនៅត្រង់ជើងដំរីមួយ ២ នាក់ រួមជា ៨ នាក់ រួមទាំងអ្នកជិះ រួមជា ១២ នាក់ ដំរី ៣ ក្បាល ទើបបុរស ៣៦ នាក់ ។ អស្សាណិកៈនោះ គឺសេះ ៣ ក្បាល សេះមួយក្បាលៗ មានបុរស ៣ នាក់ គឺបុរសម្នាក់ជិះ បុរស ២ នាក់អមសងខាង រួមសេះ ១ មានបុរស ៣ រួមសេះ ៣ មានបុរស ៩ នាក់ ។ រថាណិកៈ គឺរថ ៣ គ្រឿង រថនីមួយៗ មាន បុរស ៤ នាក់ គឺនាយសារថីម្នាក់ យោធាម្នាក់ បុរសអ្នករក្សាពីរនាក់ ទើបរថ ៣ គ្រឿងនោះមានបុរស ១២ នាក់ ។ បត្តាណិកៈនោះ គឺបុរស ៤ នាក់ កាន់អាវុធគ្រប់ដៃ ។ ដំរី ៣ ក្បាល មនុស្ស ៣៦ នាក់ សេះ ៣ ក្បាល មនុស្ស ៩ នាក់ រថ ៣ គ្រឿង មនុស្ស ១២ នាក់ និងមនុស្ស ៤ នាក់ចូលផង ជាចតុរង្គសេនា គឺដំរី ៣ ក្បាល សេះ ៣ ក្បាល រថ ៣ គ្រឿង បុរសអ្នកជិះ និងថ្មើរជើងនោះជាបុរស ៦១ នាក់ ( ៣៦ + ៩ + ១២ + ៤ ) ឈ្មោះថា មួយចតុរង្គសេនាជាទីបំផុត ដែលច្រើនជាងនេះទៅទៀតអ្នកប្រាជ្ញគប្បីជ្រាបដោយន័យដូច្នេះ ។

ទីងសម្តែងនូវបុគ្គល ៤ ពួក ដោយអំណាចកំណត់នូវការត្រាស់ដឹងមគ្គ និងផល គឺឧគ្ឃដិតញ្ញូបុគ្គលមួយពួក វិបច្ចិតញ្ញូបុគ្គលមួយពួក នេយ្យបុគ្គលមួយពួក បទបរមបុគ្គលមួយពួក ។បុគ្គលណាត្រាស់ដឹងនូវធម្មាភិសម័យរហ័ស ក្នុងខណៈដំបូងនៃការសម្តែងធម៌ក៏បានសម្រេចក្នុងពេលនោះ បុគ្គលពួកនោះ ឈ្មោះថា **ឧគ្ឃដិតញ្ញូ** ។ ក្នុងកាលព្រះធម៌ទេសនា ដែលព្រះពុទ្ធត្រាស់សម្តែងដោយសង្ខេប ហើយព្រះអង្គចែកចេញជាអត្ថដោយពិស្តារ ទូលំទូលាយចេញទៅ បុគ្គលណាត្រាស់ដឹងនូវមគ្គ និងផល បុគ្គលពួកនោះឈ្មោះថា **វិបច្ចិ-តញ្ញូ** ។ បុគ្គលណារៀនសូត្រទាំងព្រះបាលី និងអដ្ឋកថា និងព្យា-យាមសាកសួរ ព្យាយាមញ៉ាំងនូវមនសិការ ដោយឧបាយនៃបញ្ញា ព្យាយាមសេពសមាគមកល្យាណមិត្តជារឿយៗ ទើបត្រាស់ដឹងមគ្គ និងផល បុគ្គលពួកនោះ ឈ្មោះថា **នេយ្យបុគ្គល** ។ បុគ្គលណាបានរៀនសូត្រច្រើន ទ្រទ្រង់ចាំទុកក៏ច្រើន ពោលប្រាប់ក៏ច្រើនក៏នៅមិនបានត្រាស់ដឹងនូវធម៌វិសេសក្នុងជាតិនោះ ញ៉ាំងសេចក្តីព្យាយាមគ្រាន់តែឧបនិស្ស័យប្បច្ច័យក្នុងអនាគត បុគ្គលពួកនេះឈ្មោះថាបទបរមបុគ្គល ដូចយើងគេទាំងឡាយដែលនៅជាបុថុជ្ជន ដូច្នេះ ។

ប្រការមួយទៀតពោលថា បុគ្គលទាំងឡាយអ្នកប្រាថ្នាតិច មាន ៤ ប្រការ **បច្ចយអប្បិច្ឆោ** គឺព្រះយោគាវចរអ្នកប្រាថ្នាតិចក្នុងចតុប្បច្ច័យ ១ **បរិយត្តិអប្បិច្ឆោ** គឺប្រាថ្នាតិចក្នុងព្រះបរិយត្តិធម៌ ១ **អធិគមអប្បិច្ឆោ** គឺប្រាថ្នាតិចក្នុងកិរិយាត្រាស់ដឹង១ **ធុតង្គអប្បិច្ឆោ** គឺអ្នកប្រាថ្នាតិចក្នុងធុតង្គ ១ ។ក្នុងកាលទានវត្ថុដែលទាយកទាំងឡាយថ្វាយច្រើនក្រៃលែង ព្រះយោគីអ្នកប្រាថ្នាតិច ក៏ទទួលនូវទានតែតិចតួច ។ ក្នុងកាលទានវត្ថុដែលទាយកថ្វាយតិចតួច ក៏ទទួលទានបន្តិចបន្តួចប៉ុណ្ណោះ ម្យ៉ាងទៀត ជួនកាលក៏មិនបានទទួលសោះ ព្រោះថាទានវត្ថុនេះតិចតួច បើនឹងទទួលហើយក៏អស់ និងមិនទូទៅដល់បដិគ្គាហកៈដទៃ យ៉ាងនេះឯងបានឈ្មោះថា អ្នកប្រាថ្នាតិចក្នុងចតុប្បច្ច័យ ។

ចំណែកលោកអ្នកប្រាថ្នាតិចក្នុងព្រះបរិយត្តិនោះ **តេបិដកោសមាណោ** សូម្បីទ្រទ្រង់ចាំព្រះធម៌ដ៏ជំនាញក្តី ក៏មិនបានមានសេចក្តីប្រាថ្នាដើម្បីនឹងញុំាងអ្នកដទៃឲ្យដឹងនូវភាវៈនៃខ្លួនថាជាពហូស្សូត ។

មួយទៀត អ្នកដែលប្រាថ្នាតិចក្នុងមគ្គ និងផលធម៌វិសេសត្រាស់ដឹងនោះ មិនមានសេចក្តីប្រាថ្នាដើម្បីនឹងឲ្យអ្នកដទៃដឹងថា

ខ្លួនត្រាស់ដឹងធម៌វិសេស បានមគ្គ បានផលឡើយ ។

ឯអ្នកប្រាជ្ញាតិចក្នុងធុតង្គនោះ ក៏លាក់នូវគុណធម៌ មិនបានឲ្យអ្នកដទៃដឹងថា ខ្លួនរក្សានូវធុតង្គ អដ្ឋកថាអង្គុត្តរនិកាយ ចតុក្កនិបាត សម្ដែងអ្នកប្រាជ្ញាតិចមាន ៤ ប្រការដូច្នេះ ។

**ចត្តារោ សាគរា សំសារសាគរោ ជលសាគរោ នយសាគរោ ញាណសាគរោ** វិសាគរទាំងឡាយនោះមាន ៤ គឺ សំសារសាគរោ ១ ជលសាគរោ ១ នយសាគរោ ១ ញាណ-សាគរោ ១ ។ វិសង្សារវដ្ដ ដែលព្រះពុទ្ធសម្ដែងព្រះធម៌ទេសនាតាមលំដាប់នៃខន្ធ លំដាប់នៃធាតុ លំដាប់នៃអាយតនៈទាំងឡាយ **អព្វោច្ឆិន្នំ** មិនដាច់សូន្យឡើយ សព្វសត្វទាំងឡាយកើតមកហើយ ក៏មានតែសេចក្ដីស្លាប់ប៉ុណ្ណោះ កិរិយាដែលវិលកើតវិលស្លាប់ បន្ដគ្នារឿយៗ ដូច្នោះមានតែខន្ធ ធាតុ អាយតនៈតិចឬច្រើនទៅអស់កាលដ៏យូរ ទើបហៅថា **សង្សារវដ្ដ** វិសង្សារវដ្ដនេះបានឈ្មោះថា សង្សារសាគរ ហើយសង្សារសាគរនេះ មានទីបំផុតខាងដើមមិនឃើញប្រាកដដោយន័យអធិប្បាយ ដែលព្រះពុទ្ធត្រាស់ទុកដូច្នេះថា **សព្វេបិ សត្តា** សព្វសត្វទាំងឡាយដែលកើតក្នុងអតីតកាលនោះៗ មិនមាន

ទីបំផុតខាងដើមឡើយ ។ អធិប្បាយថា ក្នុងទីបំផុតនៃរយឆ្នាំក្តី ពាន់ក្តី សែនឆ្នាំក្តី ក្នុងទីបំផុតនៃរយកប្បក្តី ពាន់កប្បក្តី សត្វទាំងឡាយកើតមានអំពីកាលនោះ នឹងកើតមានមុនកាលនោះមិនមាន កាលសត្វទាំងឡាយកើតនោះ កើតក្នុងកាលនៃស្តេចឈ្មោះឯណោះ ក្នុងកាលព្រះសាសនាព្រះពុទ្ធទ្រង់ព្រះនាមឯណោះ នឹងបានកើតមុនអំពីកាលនៃស្តេច និងព្រះពុទ្ធឈ្មោះឯណោះ នុ៎ះមិនមាន ។ មួយ៉ាងទៀត គឺកំណត់កាលដែលកើតនៃសត្វទាំងឡាយកំណត់បានយ៉ាងនេះ ពិតប្រាកដម្នាលភិក្ខុទាំងឡាយ តួអវិជ្ជាក្នុងគ្រាមុន ក្នុងកាលមុននោះ នឹងមិនមានទីបំផុតឡើយ ទីបំផុតក្នុងពេលមុននៃតួអវិជ្ជានោះ មិនបានឃើញប្រាកដថា អវិជ្ជាកើតក្នុងកាលនោះ មិនមានក្នុងកាលមុននៃសម័យនោះ នៃលំដាប់នោះ ក្រោយមកអវិជ្ជាកើតមានដូចអំពីមុន ព្រះពុទ្ធដីកាត្រាស់ដូច្នេះ ហេតុណា ហេតុនោះ សង្សារវដ្តនេះ អ្នកប្រាជ្ញទាំងឡាយទើបដឹងច្បាស់ ឈ្មោះសង្សារសាគរ គឺជ្រាលជ្រៅ គម្ភីរភាព ដោយវិលចល់កើតស្លាប់ ព្រោះអវិជ្ជានោះរឹតរុំ មិនឃ្លាតចាកខន្ធសន្តានឡើយ ។

វីជលសាគរនោះ បានដល់ មហាសមុទ្រ ។

ព្រះពុទ្ធវចនៈទាំងឡាយ នៅក្នុងព្រះត្រៃបិដកនោះ ឈ្មោះថា **នយសាគរ** ដែលនឹងដឹងនូវការអធិប្បាយនោះដោយលំបាក ។

ព្រះសព្វញ្ញុតញ្ញាណនោះឈ្មោះថា **ញាណសាគរ** គឺជ្រៅដោយព្រះញាណ ដែលដឹងទៅក្នុងញេយ្យធម៌ទាំងឡាយ មិនមានទីបំផុត មិនសេសសល់ ។ សេចក្តីនៃពាក្យទាំងនេះមានក្នុង **អដ្ឋកថាធម្មសង្គណី** ។

ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រនោះ ពោលដោយអវិជ្ជាដែលជាធំនៃកិលេស ជាក្បាលរបស់កិលេសទាំងឡាយនៅក្នុងបដិច្ចសមុប្បាទធម៌នោះ ។ ព្រះសម្មាសម្ពុទ្ធ កាលព្រះអង្គត្រាស់សម្តែងនូវតួអវិជ្ជានោះ គឺទីបំផុតខាងដើមនៃសង្សារមិនឲ្យឃើញប្រាកដ ត្រាស់សម្តែងនោះ ឲ្យឃើញសមគ្នាជាមួយនឹងអវិជ្ជា និងមានសេចក្តីអធិប្បាយដូចម្តេច ? អធិប្បាយថា អវិជ្ជាកើតឡើង ក៏ព្រោះអាសវៈទាំង ៤ កើតឡើង ។ កាលធ្វើការអធិប្បាយដូច្នេះ ក៏ឃើញច្បាស់ថា ទីបំផុតខាងដើមនៃអវិជ្ជានោះមិនប្រាកដ ។ មួយទៀត តួអវិជ្ជា មិនមែនសង្សារវដ្ត នឹងមិនមានទីបំផុតខាងដើម និងមិនមានទីបំផុតខាងចុង ព្រោះហេតុអ្វី ព្រោះថា មិនទាន់ត្រាស់ដឹងធម្មាភិសម័យ លុះសម្រេចដល់

ព្រះអរហត្ត កាត់កិលេសដាច់ហើយនោះឯង ទើបឃើញប្រចក្សគ្រប់យ៉ាង ។

មួយទៀតសោត ក្នុង **អដ្ឋកថាសំយុត្ត** ថា អត្ថរបស់ **ឧបធិ** សព្ទ មាន ៣ ប្រការ ខន្ធទាំងឡាយ ៥ ក៏ឈ្មោះថា **ឧបធិ** ព្រោះថា ខន្ធទាំងឡាយនោះ ជាទីអាស្រ័យនៃកងទុក្ខទាំងពួង ព្រោះជាឫសគល់នៃខន្ធទាំងឡាយ ។ម្យ៉ាងទៀត កងកិលេសធម៌ទាំងឡាយក្តី ក៏ឈ្មោះថា **ឧបធិ** ព្រោះថា ជាឫសគល់នៃកិលេសទាំងឡាយ ជាទីនៅអាស្រ័យនៃអបាយទុក្ខ ។ ម្យ៉ាងទៀត កងអភិសង្ខារទាំងឡាយ គឺបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារ ក៏ឈ្មោះថា **ឧបធិ** ព្រោះថា អភិសង្ខារទាំងឡាយជាទីតាំង ជាទីអាស្រ័យនៃកងទុក្ខក្នុងភពទាំង ៣ ។

មានពាក្យមកក្នុងទីនេះថា សត្វទាំងឡាយ ៤ ពួក ខ្លាចចំពោះធម្មជាតិដែលមិនគួរខ្លាច **គណ្ឌុប្បាទោ** គឺសត្វជន្លេនមួយពួក សត្វត្រដេវវិចមួយពួក សត្វក្រៀលមួយពួក ព្រាហ្មណ៍មួយពួក ។ធម្មតាសត្វជន្លេនទាំងឡាយនោះ មានតែដីជាអាហារ តែមិនហ៊ានស៊ីដីឲ្យឆ្អែតឡើយ ព្រោះខ្លាចផែនដីធំអស់ទៅ ។ សត្វត្រដេវវិចទាំងឡាយ

តែងតែដេកផ្ងារ ថែរក្សាស៊ុតរបស់វាដោយខ្លួន ព្រោះខ្លាចមេឃរលំសង្កត់ ។ សត្វក្រៀលទាំងឡាយ កាលដើរឈានជាន់លើផែនដីនោះ ឈានដើរថ្នមៗ ដើរលបៗ និងជាន់ដីដោយចុងម្រាម ព្រោះថា ជាន់ឲ្យស៊ប់ជើងទៅនោះ ផែនដីនឹងស្រុត ។ មយ៉ាងទៀត ឈ្មោះថាជាតិព្រាហ្មណ៍ទាំងឡាយ រមែងមានសេចក្តីខ្វល់ខ្វាយ ស្វះស្វែងរកនូវកិរិយា កាលនឹងនៅស្ងៀមយូរមិនបានទេ ព្រោះថា ខ្លាចវង្សត្រកូលព្រាហ្មណ៍របស់ខ្លួនជាចសូន្យ បំណងឲ្យវង្សត្រកូលព្រាហ្មណ៍មានបន្តគ្នាទៅ ។ សត្វទាំងឡាយ ៤ ពួកនេះ ខ្លាចចំពោះធម្មជាតិដែលមិនគួរខ្លាច ទើបជាសត្វប្រកបទៅដោយសេចក្តីវង្វេង សេចក្តីនេះមានក្នុង *អដ្ឋកថាព្រាហ្មណធម្មិយសូត្រ* ក្នុង *សុត្តនិបាត* ។

ក្នុង *អដ្ឋកថាអង្គុត្តរនិកាយ* ថា កវីមាន ៤ ប្រការ គឺចិន្តកវី សុតកវី អត្ថកវី បដិភាណកវី ។ កាលបើបុគ្គលរំពឹងគិតរឿយៗ តែងកំណាព្យកាព្យឃ្លោងពោលយ៉ាងពីរោះនោះ ឈ្មោះថា **ចិន្តកវី** គឺគិតហើយពោល កាលបុគ្គលអ្នកបានស្តាប់ច្រើន ចាំពាក្យកាព្យឃ្លោង ឈ្មោះថា **សុតកវី** គឺស្តាប់ចាំហើយពោល កាលបើបុគ្គលអាស្រ័យនូវអត្ថខ្លឹមសារសេចក្តីច្បាស់លាស់ និងតែងកំណាព្យឈ្មោះថា

**អត្ថការី** គឺស្ដាប់សេចក្ដីរៀបរយហើយពោល ប្រៀបដូចវង្គីសត្ថេរ ពោលពាក្យជាសុភាសិត និងព្រះពុទ្ធដីកាដែលត្រាស់ទុក ។ កាលបុគ្គលមានបញ្ញាវាងវៃស្រួចស្រាល់ ពោលនូវសេរកញ្ញ ឬពោលនូវគាថាបានភ្លាមៗ ដោយបញ្ញារបស់ខ្លួននោះ ឈ្មោះថា **បដិភាណការី** គឺបានដល់បញ្ញាបដិសម្ភិទាញាណ កើតអំពីអរហត្ត ។

ក្នុង **អដ្ឋកថាវិមានវត្ថុ** នោះថា មនុស្សទាំងឡាយមាន ៤ ពួក គឺមនុស្សនរក ១ ពួក មនុស្សតិរច្ឆាន ១ ពួក មនុស្សប្រេត ១ ពួក មនុស្សភូត ១ ពួក ។ មនុស្សពួកណាធ្វើនូវកម្ម មានបាណាតិបាតជាដើមដែលមិនគួរគប្បីធ្វើ កាលធ្វើក៏ត្រូវរាជអាជ្ញាព្រះរាជាធ្វើទារុណកម្មមានប្រការផ្សេងៗគឺដាក់ទោសដោយត្រូវកាត់ដៃ-ជើងជាដើមបានសោយទុក្ខវេទនាសែនលំបាក មនុស្សពួកនេះឈ្មោះថា **មនុស្សនរក** ។

មួយទៀត មនុស្សពួកណាដើរស្វែងរកអាហារ និងសំពត់ស្លៀកសំពត់ដណ្ដប់នោះបានដោយលំបាក ដោយកម្មរបស់ខ្លួនធ្វើទុកអំពីមុន មានតែសេចក្ដីខ្វះខាតគ្រប់សង្កត់ ច្រើនទៅដោយសេចក្ដីទុក្ខលំបាកកាយ-ចិត្តជានិច្ចនិរន្ត ដើរទៅគ្រប់កន្លែង ក៏មិនបាននូវលាភសមគួរតាមសេចក្ដីប្រាថ្នា មនុស្សពួកនេះឈ្មោះថា **មនុស្សប្រេត** ។

មនុស្សពួកណាចិញ្ចឹមជីវិត អាស្រ័យអ្នកដទៃឲ្យទាន ប្រឹងប្រែង ធ្វើការងារលើសែងនូវរបស់ធ្ងន់ៗ កិច្ចការងាររបស់ខ្លួននោះដាច់អស់ មិនបានធ្វើទេ ជាអ្នកខ្សត់ញាតិ មានតែអ្នកដទៃជេរស្តីគំរាមសព្វកាល ច្រើនទៅដោយមរណភ័យ និងកងទុក្ខផ្សេងៗ **ហិតាហិតំ អជា-នន្តោ និលជ្ជោ** មិនស្គាល់របស់មានប្រយោជន៍ និងមិនមានប្រ-យោជន៍ ប្រាសចាកការអៀនខ្មាស ត្រាច់ទៅពោរពេញ ដោយកិរិយាដែលបន្ទោបង់ នូវសេចក្តីស្រេកឃ្លាន ជាទុក្ខមិនចេះចប់ មនុស្សពួកនេះឈ្មោះថា **មនុស្សតិរច្ឆាន** ។

**យោ វា បន ហិតាហិតំ ជានន្តោ កម្មផលំ សទ្ទហន្តោ** មនុស្សពួកណាដឹងនូវប្រយោជន៍ និងមិនមែនប្រយោជន៍ ជឿនូវផលរបស់កម្ម ប្រកបដោយហិរិឱត្តប្បៈ មានសេចក្តីខ្មាសបាប ខ្លាចបាបបរិបូណ៌ដោយចិត្តករុណា កើតធម៌សង្វេគក្នុងសព្វសត្វទាំងឡាយដែលប្រកបដោយសេចក្តីទុក្ខផ្សេងៗ **បរិវជ្ជន្តោ** ហើយក៏វៀរចាកនូវអកុសលធម៌ ប្រព្រឹត្តតែអំពើល្អក្នុងកុសល តាំងនៅក្នុងកាយសុចរិត វចីសុចរិត មនោសុចរិត ញ៉ាំងបុញ្ញកិរិយាវត្ថុ ១០ ប្រការ មានទាន សីល ភាវនាជាដើមឲ្យបរិបូណ៌ មានបញ្ញាជឿត្រង់តាមព្រះពុទ្ធវាទ

មនុស្សពួកនេះ ឈ្មោះថា **មនុស្សភូត** ជាមនុស្សពិត ជាមនុស្សស្ថិតនៅក្នុងធម៌ ដោយអំណាចបរមត្ថ ។

**ចត្តារិ នាមានិ អាវត្ថិកោ លិង្គិកោ នេមិត្តកោ អធិច្ចសមុប្បន្នកោ ចាតិ** ក្នុងវិនយនិទានថា នាមមាន ៤ ប្រការ គឺអាវត្ថិកនាម ១ លិង្គិកនាម ១ នេមិត្តកនាម ១ អធិច្ចសមុប្បន្ន-នាម ១ ។ **វច្ឆោ ទម្មោ ពលិពទ្ទោ** ឃើញកូនគោតូច ក៏ហៅថាកូនគោតូច ឃើញកូនគោជំទង់ ក៏ហៅថា គោស្ទាវ ។ លុះល្មមនឹងហ្វឹកហាត់ប្រើការបាន ឃើញថាធំមានកម្លាំងមាំមួន ក៏ហៅថាគោឡើងក នាមដូច្នេះ ឈ្មោះថា **អាវត្ថិកនាម** ។ ឈ្មោះហៅតាមលិង្គ គឺ **ទណ្ឌី ឆត្តី** មនុស្សមានដៃកាន់ឈើច្រត់ជាមនុស្សចាស់ មនុស្សបាំងឆត្រជាអ្នកដំណើរ ពេលក្តៅ ពេលភ្លៀងធ្លាក់ ក៏ហៅថា មនុស្សមានឆត្រ **សិខី ករី** ហៅថា នាគរាជ និងក្ងោកមានសិរ ដំរីមានប្រមោយ ហៅតាមលិង្គយ៉ាងនេះ ឈ្មោះថា **លិង្គិកនាម** ។ នាមហៅតាមហេតុ តាមនិមិត្តថា **តេវិជ្ជោ ឆឡភិញ្ញោ** គឺលោកអ្នកទ្រទ្រង់វិជ្ជា ៣ បាននូវទិព្វចក្ខុញាណ បុព្វេនិវាសញ្ញាណ និងអរហត្តញ្ញាណ ហៅតាមគុណធម៌យ៉ាងនេះ ឈ្មោះថា **នេមិត្តក-**

**ឈាម** ។ កំណត់យកនូវអត្ថរបស់សព្ទជាដើមដូច្នេះ គឺ **សិរីវឌ្ឍោ** ពោលនាមហៅថា ជាអ្នកចម្រើននូវសិរី ចម្រើនទ្រព្យនោះ ឈ្មោះថា **អធិច្ចសមុប្បន្នឈាម** គឺនាមនោះអាស្រ័យអត្ថកើតប្រាកដចំពោះលោក តាមលោកវោហារ គឺគិតឃើញចំណុចហើយ ពោលកិរិយាដែលគិតនោះជាអចិន្តេយ្យ ។

អចិន្តេយ្យទាំងឡាយមាន ៤ ប្រការ ព្រះពុទ្ធដីកាត្រាស់ចំពោះភិក្ខុទាំងឡាយថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ពុទ្ធវិស័យរបស់ព្រះពុទ្ធទាំងឡាយ ជាអចិន្តេយ្យ ១ ។ ឈានវិស័យរបស់បុគ្គលអ្នកបានឈាន ជាចិន្តេយ្យ ១ ។ វិបាករបស់កម្មជាអចិន្តេយ្យ ១ ។ លោកចិន្តា ( ការគិតអំពីលោក ) ជាអចិន្តេយ្យ ១ ។ អចិន្តេយ្យទាំង ៤ ប្រការនេះដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាកទទេ ។

សេចក្តីក្នុង **អដ្ឋកថាអង្គុត្តរនិកាយចតុក្កនិបាត តតិយភាគ** ថា កិរិយាដែលប្រព្រឹត្តទៅរបស់ព្រះពុទ្ធ មានព្រះសព្វញ្ញុតញ្ញាណ និងអានុភាពរបស់ព្រះពុទ្ធគុណទាំងឡាយផ្សេងៗ ជាដើមនោះ ហៅថា **ពុទ្ធវិស័យ** ។ មានសេចក្តីអធិប្បាយថា ព្រះពុទ្ធនៃយើងមានព្រះ

កាយកម្ពស់ប្រមាណ ១៨ ហត្ថនៃមជ្ឈិមបុរស ដោយសមត្ថភាពរបស់ព្រះអង្គ និមន្តចង្ក្រមនៅក្នុងគ្រាប់ស្ពៃបាន គ្រាប់ស្ពៃនោះ និងព្រះអង្គឃើញថា ព្រះអង្គធំខ្ពស់ នឹងធំខ្ពស់តាម ព្រះអង្គក៏មិនមែន ព្រះអង្គឃើញថា គ្រាប់ស្ពៃតូចប៉ុណ្ណោះ នឹងតូចតាមគ្រាប់ស្ពៃក៏មិនមែនដែរ ។ វិបាជិហារ្យដូច្នេះ មិនបានជាវិស័យរបស់អ្នកទ្រទ្រង់ឫទ្ធិទាំងឡាយដទៃឡើយ ហេតុដូច្នោះពុទ្ធវិស័យ ទើបជាអចិន្តេយ្យ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាកទទេ ។

មានរឿងតំណាលថា បុរសម្នាក់គិតនូវពុទ្ធវិស័យរបស់ព្រះពុទ្ធដូច្នេះ ក៏ដល់នូវភាវៈឆ្កួតខូចចិត្ត ហើយត្រាច់ទៅ ។ មានបុរសម្នាក់ជាអ្នកប្រាជ្ញនាំបុរសឆ្កួតនោះទៅកាន់ទីជិតមហាចេតិយដ៏ខ្ពស់ ទើបបង្ហាញឲ្យបុរសឆ្កួតនោះមើលនូវមហាចេតិយ ដែលមានទំហំ ១២០ ហត្ថ កម្ពស់ ៣៦០ ហត្ថ រួចហើយក៏លើកយកកញ្ចក់ដាក់ចុះចំពោះមហាចេតិយ មហាចេតិយដ៏ធំខ្ពស់ប៉ុណ្ណោះនឹងឃើញថា កញ្ចក់តូចហើយនឹងតូចតាមកញ្ចក់ក៏មិនមែន រង្វង់កញ្ចក់តូចប៉ុណ្ណោះនឹងឃើញថា មហាចេតិយធំ នឹងធំតាមមហាចេតិយក៏មិនមែន បុរសអ្នកប្រាជ្ញនោះ

ញុំាងបុរសអ្នកក្តួតឲ្យជឹងខ្លួន ដោយន័យឧបមាដូច្នោះថា បាដិហារ្យ របស់ព្រះពុទ្ធក៏មានឧបមាដូច្នោះដែរ ។

មួយទៀតសោត វិស័យរបស់អភិញ្ញានៃលោកអ្នកទាំងឡាយ ដែលទ្រទ្រង់ឫទ្ធិ គួរនឹងស្ទាបព្រះចន្ទ និងព្រះអាទិត្យមកធ្វើជាកំណល់ ជូតជើងជាអាសនៈ អង្គុយ ដេកក៏បានដូចសេចក្តីប្រាថ្នា ។

មួយទៀត ព្រះចន្ទ ព្រះអាទិត្យទាំងឡាយនោះក៏តាំងនៅជាធម្មតា មិមឃ្លៀងឃ្លាតចាកវិថីដើរបំភ្លឺលោកនោះទេ បាដិហារ្យដូច្នេះ ជាលក្ខណៈឈានវិស័យ ក៏ជាអចិន្តេយ្យ ។

រីផលរបស់កម្មទាំងឡាយ មានទិដ្ឋធម្មវេទនីយកម្មជាដើម ហៅថា **កម្មវិបាក** ។ រីកម្មមួយដែលជាកុសល សត្វទាំងឡាយធ្វើឲ្យច្រើនហើយ ពួកខ្លះបានទៅកើតក្នុងមនុស្សលោក ពួកខ្លះបានទៅកើតក្នុងឆកាមាវចរសួគ៌ មានជាន់ចាតុម្មហារាជិកាជាដើម ក្នុងជាន់ណាទីមួយនោះ ។ កាលបើសត្វទាំងឡាយកើតដោយកម្មដូច្នេះ ពួកខ្លះមានសម្បុរមិនល្អ ពួកខ្លះមានសម្បុរស្អាតលឿងដូចមាស ពួកខ្លះក៏ខ្ពស់ ពួកខ្លះក៏ទាប ពួកខ្លះក៏មានសក្តិតូច ពួកខ្លះក៏មានសក្តិធំ ។ សព្វសត្វទាំងឡាយកើតផ្សេងៗ គ្នាដូច្នេះ ។ អំពីចំណែកបុណ្យ និង

បាបក៏មានន័យដូចគ្នាទើបឃើញច្បាស់ថាកម្មវិបាកនោះក៏ជាអចិន្តេយ្យ

ការគិតអំពីលោក ជាអចិន្តេយ្យនោះដូចម្តេច អធិប្បាយថា ការគិតអំពីលោក គិតថា ព្រះចន្ទ ព្រះអាទិត្យនេះ អ្នកណាសាង ផែនដីដ៏ធំនេះ អ្នកណាសាង មហាសមុទ្រនោះ អ្នកណាសាង ពួកសត្វទាំងឡាយ អ្នកណាសាងឲ្យមានរូបកាយ មានប្រការផ្សេងៗ ។ មួយទៀត ព្រៃព្រឹក្សាទាំងឡាយ មានដើមស្វាយ ដើមដូង ដើមត្នោត ជាដើមនោះ អ្នកណាបង្កើតជាដំបូង គំនិតយ៉ាងនេះហៅថា លោកចិន្តា ( ការគិតអំពីលោក ) ។ មួយទៀត អាកាសលោក គឺទីតាំងរបស់លោកកើតតាមរដូវដូចម្តេច កើតដោយអាការដូចម្តេច ទើបមិនមានទីបំផុត ព្រោះដូច្នោះ ទើបពោលថា ការគិតដល់លោកនោះ ក៏ជាអចិន្តេយ្យ ដែលបុគ្គលមិនគួរគិត ។

**បីតិ បញ្ចវិធា ហោតិ ខុទ្ទកាបីតិ ខណិកាបីតិ ឱក្កន្តិកាបីតិ ឧព្វេង្គាបីតិ ផរណាបីតិ តត្ថ ខុទ្ទកាបីតិ សរីរេ លោមហំសមត្តមេវ កាតុំ សក្កោតិ** ឥឡូវនេះនឹងអធិប្បាយក្នុងបីតិដែលមានលក្ខណៈ ៥ ប្រការ គឺលក្ខណៈខុទ្ទកាបីតិ ១ លក្ខណៈខណិកាបីតិ ១ លក្ខណៈឱក្កន្តិកាបីតិ ១ លក្ខណៈឧព្វេង្គាបីតិ ១

លក្ខណៈផរណាបីតិ ១ ។

លក្ខណៈខុទ្ទកាបីតិនោះ អាចធ្វើឲ្យព្រឺព្រួច បះរោមទូទាំងកាយ រហូតដល់ចុងសក់ ។

លក្ខណៈខណិកាបីតិនោះ ធ្វើឲ្យមានពន្លឺទូទាំងកាយ ដូចផ្លេក បន្ទោរជាខណៈៗ ។

លក្ខណៈឱក្កន្តិកាបីតិនោះ ធ្វើឲ្យដូចជាទឹករលកទូទាំងកាយ រួចហើយបាត់ទៅ ប្រៀបដូចរលកដែលប៉ះខ្ទប់ច្រាំងមហាសមុទ្រ រួចហើយអស់ទៅ ។

លក្ខណៈឧព្វេង្គាបីតិ ប្រសិនបើកើតចាស់ក្លា ធ្វើកាយឲ្យស្រាល អណ្តែតឡើងលើ ដូចហោះអណ្តែតទៅលើអាកាស ដូចតំណាលថា

ព្រះមហាតិស្សត្ថេរ អាស្រ័យនៅនាបុណ្ណវល្លិកវិហារ ក្នុងថ្ងៃ ១៥ កើត ពេលល្ងាចត្រជាក់និមន្តទៅកាន់លានព្រះចេតិយ និងឃើញព្រះចន្ទភ្លឺចិញ្ចែងចញ្ចង់វេហាស៍ ទើបបែរមុខឆ្ពោះព្រះបរមចេតិយ ដោយមនសិការថា ពេលវេលាដូច្នេះបរិស័ទទាំង ៤ ទៅថ្វាយបង្គំ ព្រះមហាចេតិយ ។ គ្រានោះ ព្រះមហាថេរៈញុំាងឧព្វេង្គាបីតិដោយមានគុណព្រះពុទ្ធជាអារម្មណ៍ឲ្យកើតឡើង ហោះអណ្តែតទៅតាមអាកាស

ចុះត្រង់ទីលានព្រះមហាចេតិយ ប្រៀបដូចសត្វបក្សីចុះលើផ្ទៃដីដ៏រាបដូច្នោះ ។

មួយទៀត នាងកុលធីតាម្នាក់ អាស្រ័យនៅនាវត្តកាឡក ក្បែរគិរិកន្ទវិហារ ក៏ហោះអណ្តែតទៅតាមអាកាសដោយអានុភាពឧព្វេង្គាបីតិ ដែលមានគុណព្រះពុទ្ធជាអារម្មណ៍ខ្លាំងក្លា **កិរ** បានឮមកថា មាតាបិតារបស់កុមារីនោះ វេលាល្ងាចត្រជាក់ធ្វើដំណើរទៅកាន់ព្រះវិហារ ដើម្បីនឹងស្តាប់ព្រះធម៌ទេសនា ទើបហាមកូនថា **អម្ម** នែកូន កូនជាស្រីក្រមុំ វេលាយប់មិនគួរចេញចាកផ្ទះទេ ម៉ែ និងពុកទៅស្តាប់ព្រះធម៌ទេសនា នឹងឲ្យចំណែកបុណ្យដល់កូន ហាមដូច្នេះហើយ ក៏ធ្វើដំណើរចេញទៅ ឯកុលធីតាប្រាថ្នានឹងទៅដែរ ប៉ុន្តែនាងខ្លាចក្រែងម្តាយឪពុក មិនតប-តអ្វីឡើយ នាងក៏នៅស្ងៀម នឹកតែក្នុងចិត្ត ទើបចេញទៅឈរនៅរានហាល សម្លឹងមើលលានព្រះចេតិយ ភ្លឺដោយរស្មីនៃព្រះចន្ទ និងគ្រឿងសក្ការបូជា មានផ្កាកម្រង និងគ្រឿងក្រអូប និងប្រទីបដុតបូជាព្រះចេតិយភ្លឺស្វាង **ចតស្សោ បរិសា** ទើបគិតតែក្នុងចិត្តថា បរិស័ទទាំង ៤ នោះ លោកបានធ្វើសក្ការបូជាព្រះចេតិយដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ថែមទាំងដើរប្រទក្សិណព្រះ

ចេតិយ បានស្តាប់ព្រះសង្ឃស្វាធ្យាយ ព្រះធម៌ជាពួកៗ បរិស័ទទាំង ៤ នោះ សុទ្ធតែជាអ្នកមានបុណ្យច្រើនពិត ទើបលោកបានទៅកាន់ព្រះវិហារ និងទីលានព្រះចេតិយ បានស្តាប់នូវធម្មកថាដូច្នេះៗ កុមារីសម្លឹងមើលព្រះចេតិយនោះ ដូចឃើញនូវកែវមុក្តា កើតឧព្វេង្គាបីតិឡើងក្នុងចិត្ត ក៏ហោះទៅដល់ព្រះចេតិយមុនម្តាយឪពុករបស់នាង លុះចុះចាកអាកាសហើយ ឡើងទៅទីលានព្រះចេតិយ ក្រាបថ្វាយបង្គំព្រះ-ចេតិយ ហើយស្ថិតនៅក្នុងទីដ៏សមគួរ ។ ក្នុងកាលនោះ មាតាបិតាមកដល់ ទើបសួរនាងថា **អម្ម** នែនាង កូនមករបៀបដូចម្តេច ? នាងជម្រាបមាតាបិតាថា ខ្ញុំមកតាមអាកាស នឹងមិនបានមកតាមផ្លូវធម្មតានោះទេ ។ ទើបមាតាបិតា ពោលថា នឹងហោះទៅបានតាមអាកាសនោះ ក៏មានតែព្រះអរហន្តទាំងឡាយប៉ុណ្ណោះ **កថំ ត្វំ អាគតា** កូនឯងនេះ ជាព្រះអរហន្តីចាប់តាំងពីពេលណាមក ទើបហោះមកតាមអាកាសបាន ។ ទើបកុលធីតាជម្រាបមាតាបិតាឲ្យជ្រាបថា កាលខ្ញុំឃើញព្រះចេតិយដោយរស្មីព្រះចន្ទ ទើបឈរនៅឯពានហាល ក៏កើតបីតិ ត្រេកអរខ្លាំងក្លា ដែលមានពុទ្ធគុណជាអារម្មណ៍ ខ្ញុំមិនដឹងខ្លួនថា ឈរ ឬអង្គុយនោះទេ ក៏អណ្តែតមកកាន់លានព្រះ

ចេតិយ ដោយនិមិត្តដែលខ្ញុំកាន់យកក្នុងខណៈនោះឯង ឧព្វេង្គាបិតី ខ្ញាំងក្លាហើយ ក៏នាំហោះអណ្តែតទៅដូចកុមារិកានោះ ។

លក្ខណៈផរណាបីតិ កាលបើកើតឡើងហើយ ក៏ជ្រួតជ្រាប ទូទាំងកាយឲ្យពេញឆ្អែត ដូចពោះវៀនពេញទៅដោយខ្យល់ ឬដូចភ្នំ ដែលមានខ្សែទឹកហូរមិនបានឈប់ ឲ្យកើតជាខ្សែទឹករុំព័ទ្ធក្នុងហទយវត្ថុ របស់ខ្លួន សេចក្តីនេះព្រះអដ្ឋកថាចារ្យវិសជ្ជនាទុកនៅក្នុង **អដ្ឋកថា ធម្មសង្គណី** និង **គម្ពីរវិសុទ្ធិមគ្គ** ក៏ពោលដូចគ្នា ។

អធិប្បាយក្នុងនិយាមថា និយាមមាន ៥ ប្រការ គឺពីជនិយាម ១ ឧតុនិយាម ១ កម្មនិយាម ១ ចិត្តនិយាម ១ ធម្មនិយាម ១ ។ វល្លិ៍ ក្នុំដែលវិលជុំវិញជាទក្ខិណាវដ្តនោះក្តី ផ្កាឈូករ័ត្នទាំងឡាយ កាលបើ រីកបែរមុខត្តោះព្រះអាទិត្យក្តី ដើមជ្រៃឈមមុខទៅរកឈើធំក្តីមួយទៀត ផ្លែដូងមានប្រហោងខាងក្នុងក្តី បណ្តាពូជទាំងឡាយនោះ ឲ្យផ្លែដូច្នោះក្តី និងកំណត់ព្រៃព្រឹក្សាលតាវល្លិ៍ដូច្នេះ ឈ្មោះថា **ពីជនិយាម** ។ អាការ ដែលព្រៃព្រឹក្សាលតាវល្លិ៍ទាំងឡាយនោះ មានផ្កា មានផ្លែព្រមគ្នាបាន ឈ្មោះថា **ឧតុនិយាម** គឺកំណត់យកតាមរដូវមួយក្នុងជនបទនោះ ក្នុង ទេសកាលនោះៗរុក្ខជាតិទាំងឡាយបញ្ចេញផ្កា និងផ្លែព្រមគ្នាជាដើមក្តី

ខ្យល់បក់ក្តី មិនបានបក់ក្តី ថ្ងៃក្តៅក្តី មិនក្តៅក្តី ភ្លៀងធ្លាក់ក្តី មិនធ្លាក់ក្តី ផ្កាបទុមជាតិទាំងឡាយរីកក្នុងវេលាថ្ងៃក្តី ក្តោបក្នុងវេលាយប់ក្តី កំណត់នូវវត្ថុទាំងឡាយជាដើមដូច្នេះ ឈ្មោះថា **ឧតុនិយាម** ។ សព្វសត្វទាំងឡាយ ដែលធ្វើកម្មជាត្រៃហេតុ ក៏ឲ្យផលជាត្រៃហេតុ ធ្វើកម្មជាទុហេតុ ក៏ឲ្យផលជាទុហេតុ ធ្វើកម្មជាអហេតុ ក៏ឲ្យផលជាអហេតុ និងធ្វើកម្មជាទុហេតុក្តី ជាអហេតុក្តី ឲ្យផលជាត្រៃហេតុមិនមាន ។រីកម្មនោះៗ ឲ្យនូវផលនោះៗ ពិតដូច្នេះ ឈ្មោះថា **កម្មនិយាម** គឺកំណត់យកកម្មជាប្រមាណ ។ មួយទៀត កុសលកម្មនោះក៏ឲ្យផលតាមសេចក្តីប្រាថ្នា ។ អកុសលកម្មនោះ មិនឲ្យផលតាមសេចក្តីប្រាថ្នា កំណត់ដោយកម្មនិយាម ។ លក្ខណៈកម្មដែលជាត្រៃហេតុ ទុហេតុ អហេតុនោះគឺបុគ្គលដែលធ្វើកុសលកម្មប្រកបដោយអលោភៈអទោសៈ អមោហៈនោះ ឈ្មោះថា ធ្វើកម្មជាត្រៃហេតុ ។ បើខ្វះហេតុណាមួយ មានតែពីរហេតុក៏ហៅថា **កម្មជាទុហេតុ** ។ បើខ្វះហេតុទាំង ៣ គឺ អលោភៈ អទោសៈ អមោហៈនោះ កម្មនោះឈ្មោះថា **អហេតុ** ។ គប្បីពិចារណាមើល យកតាមព្រះអភិធម្មត្ថសង្គហៈនោះចុះ ។

កម្មនិយាមនោះ អ្នកប្រាជ្ញគប្បីដឹងតាមរឿងតំណាលតាមធម៌

ដែលព្រះសម្ពុទ្ធត្រាស់ទេសនាដោយព្រះគាថាថា **ឆ អន្តលិក្ខេ** ជាដើមដូច្នេះ អធិប្បាយថា បុគ្គលពួនអំពីស្តេចមច្ចុរាជ ក្នុងប្រទេសអាកាសនោះ នឹងមិនបានរួចផុតឡើយ គង់តែនឹងស្លាប់ដោយពិតមួយទៀត មានស្ត្រីម្នាក់ឈ្លោះគ្នា ជាមួយនឹងប្តី ទើបរត់ទៅចង-កស្លាប់នៅក្នុងស្រុកមួយ ។ គ្រានោះ មានបុរសម្នាក់មាន និងគោត្រមិនប្រាកដ បុរសនោះអង្គុយសំលៀងកាំបិតព្រា ក្រឡេកឃើញស្ត្រីនោះក៏មានបំណងដើម្បីនឹងជួយកាត់ខ្សែចំណង-ករបស់ស្ត្រីនោះ ទើបនិយាយលួងលោមទៅថា នាងកុំទន្ទេតចិត្តឡើយ ។ កាលបុរសនោះនិយាយលួងលោមដូច្នេះហើយ ក៏ស្ទុះរត់ទៅកាត់ខ្សែត្រង់-ករបស់ស្ត្រីនោះ ។ ក្នុងខណៈនោះខ្សែដែលចង-កនោះ ក៏ត្រឡប់ជាអាសិរពិសបើកពពារឡើង បុរសនោះក៏ភិតភ័យរត់គេចចេញទៅ ស្ត្រីនោះក៏ដល់នូវការស្លាប់ក្នុងពេលនោះឯង ។

មានស្ត្រីម្នាក់ទៀត ព្យាយាមឈ្លោះនឹងប្តី ក៏ចង-កសម្លាប់ខ្លួននៅលើចុងឈើ ទើបយកកន្ទុយខ្សែចង-កឲ្យមាំ ។ មានចោរម្នាក់ត្រាច់ទៅក្នុងពេលរាត្រីគិតថា យើងនឹងរើសយកខ្សែដែលសំយុងធ្លាក់មកនេះទៅចងវត្ថុណាមួយ ក៏ដើរចូលទៅដើម្បីនឹងកាត់ខ្សែនោះ

ខ្សែនោះ ក៏ក្លាយជាអាសិរពិស បញ្ចេញនូវសំឡេងឃូៗ ចោរនោះភ័យ ក៏រត់គេចចេញទៅ ។ ស្ត្រីចេញចាកផ្ទះយកខ្សែធ្វើជាអន្ទាក់ពាក់ត្រង់-កឲ្យមាំហើយ ក៏លោតចុះមក ស្ត្រីនោះក៏ដល់នូវសេចក្ដីស្លាប់ក្នុងទីនោះ កម្មដូច្នេះឈ្មោះថា **កម្មនិយាម** ។

នាកាលព្រះបរមពោធិសត្វទាំងឡាយ ចុះចាប់បដិសន្ធិជាដើមនោះ លោកធាតុកក្រើកញាប់ញ័រ ឈ្មោះថា **ធម្មនិយាម** គឺកំណត់យកនូវកងបុណ្យទាំងពួង មានបារមី ៣០ ជាដើម **អារម្មណោ បនបសាទេ ឃដិតេ** កាលរូបារម្មណ៍មកប៉ះខ្ទប់បសាទរូបដ៏តូចប្រមាណប៉ុនក្បាលចៃនោះ ចិត្តដួងណានីមួយមិនធ្វើឯង ឬឲ្យអ្នកដទៃធ្វើ ចាប់អំពីអារម្មណ៍ថា លោកអ្នកនោះចូរជាអាវជ្ជនៈ អ្នកនោះចូរជាសម្បដិច្ឆន្នៈ អ្នកនោះចូរជាសន្តីរណៈ អ្នកនោះចូរជាវោដ្ឋព្វនៈ អ្នកនោះចូរជាជវនៈ នឹងបានបង្គាប់បញ្ជាគ្នាយ៉ាងនេះមិនបាន ។ ចាប់ផ្ដើមអំពីអារម្មណ៍ប៉ះខ្ទប់បសាទរូបហើយ ក៏កើតជវនៈ កើតជាលំដាប់តគ្នាដោយធម្មតារបស់ខ្លួនៗ កំណត់ដូច្នេះឈ្មោះថា **ចិត្តនិយាម** ។ ពាក្យដែលពោលមកនេះ មាននៅក្នុង **អដ្ឋកថាធម្មសង្គណី** និង **សម្បសាទនីយសូត្រ ទីឃនិកាយ** អាចារ្យរួបរួមទុកក្នុងទីជាមួយ

គ្នាថា និយាមមាន ៥ ប្រការ គឺពីជនិយាម ឧតុនិយាម កម្មនិយាម ធម្មនិយាម និងចិត្តនិយាម ដូចការពណ៌នាមកនេះ ។

នេះនឹងសម្ដែងដោយទោសដែលមិនបានសម្អាតធ្មេញ ដោយឈើស្ទន់មាន ៥ ប្រការ **អចក្ខុស្សំ** គឺចក្ខុមិនស្រស់ថ្លា ១ **មុខទុគ្គន្ធំ** ក្លិនមាត់ស្អុយ ១ **រសាហរណយោ ន វិសុជ្ឈន្តិ** សរសៃដែលនាំមកនូវរសអាហារមិនបានបរិសុទ្ធ ១ **បិត្តំ សេម្ហំ** ប្រមាត់ និងស្លេស្មមិនបានរុំព័ទ្ធអាហារដែលបរិភោគ ១ **ឆច្ឆាទេតិ** អាហារដែលបរិភោគនោះមិនបានពេញចិត្ត ១ នេះជាទោស ៥ ប្រការ ។

អានិសង្សនៃការសម្អាតធ្មេញក៏មាន ៥ ប្រការ គឺបុគ្គលនឹងសម្អាតធ្មេញដោយឈើស្ទន់នោះ មានភ្នែកស្រស់ថ្លា ១ ក្លិនមាត់មិនស្អុយ ១ សរសៃដែលទទួលរសអាហារនោះបរិសុទ្ធ ១ ប្រមាត់ និងស្លេស្មនឹងរុំពទ្ធអាហារល្អ ១ នឹងបរិភោគនូវអាហារមានរស ១ អានិសង្សនៃការសម្អាតធ្មេញមាន ៥ ប្រការដូច្នេះ ។

ទោសដែលអាំងភ្លើងមាន ៥ ប្រការ គឺមានភ្នែកស្រវាំង ១ មានសម្បុរអាក្រក់ ១ ប្រជុំគ្នាជាក្រុម ជាពួក ១ ភ្លើងឆេះសំពត់ ១ និងនិយាយតិរច្ឆានកថា ១ ។

បុគ្គលដែលនិយាយច្រើនមានទោស ៥ ប្រការ គឺនិយាយកុហក ១ និយាយញុះញង់ស៊កសៀត ១ និយាយពាក្យអសុរោះ ១ និយាយពាក្យឥតប្រយោជន៍ ១ កាលបើស្លាប់ហើយ រមែងទៅកើតក្នុងអបាយភូមិទាំងបួន ១ ។

បុគ្គលដែលមិនតាំងនៅក្នុងខន្តីមានទោស ៥ ប្រការ គឺ **អប្បិយោ** គឺមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តដល់មហាជនទាំងឡាយ ១ ច្រើនទៅដោយពៀរ ១ ច្រើនទៅដោយទោសផ្សេងៗ ១ កាលបើស្លាប់នោះបាត់បង់ស្មារតី ១ លុះធ្វើកាលកិរិយាហើយ តែងតែទៅកាន់ក្នុងអបាយភូមិ ១ ។

បុគ្គលដែលតាំងនៅក្នុងអធិវាសនខន្តីនោះ មានអានិសង្ស ៥ ប្រការ គឺ **បិយោមនាបោ** ជាទីស្រឡាញ់ជាទីពេញចិត្តដល់មហាជន ១ មិនបានច្រើនទៅដោយពៀរ ព្យាបាទ ១ មិនមានទោសដល់ខ្លួន ១ កាលធ្វើកាលកិរិយា មានស្មារតីរឭកដល់គុណព្រះពុទ្ធជាដើម ១ លុះធ្វើនូវកាលកិរិយាហើយ រមែងទៅកើតនៅក្នុងសុគតិភូមិ ១ ។ ការតាំងនៅក្នុងអធិវាសនខន្តី មានអានិសង្ស ៥ យ៉ាងនេះឯង ។

អានិសង្សក្នុងការបង្គ្រមនោះមាន ៥ យ៉ាង **អទ្ធានក្ខមោ ហោតិ**

*គឺជាអ្នកអត់ធន់ក្នុងដំណើរផ្លូវឆ្ងាយ ១* **បធានក្ខមោ ហោតិ** *អត់ធន់ក្នុងការព្យាយាម ១* **អប្បាពាធោ ហោតិ** *មិនមានជំងឺ ១* **អសិតំ បីតំ ខាយិតំ សាយិតំ សម្មាបរិណាមំ គច្ឆតិ** *ភោជនដែលបរិភោគ ផឹក ទំពាស៊ី លិទ្ធភក្សហើយ រមែងរលួយដោយស្រួល ១* **ចង្កមាធិគតោ សមាធិ ចិរដ្ឋិតិកោ ហោតិ** *គឺសមាធិកើតអំពីការចង្ក្រម រមែងតាំងនៅអស់កាលយូរ ១ ។ ម្នាលភិក្ខុទាំងឡាយអានិសង្សក្នុងការចង្ក្រម មាន ៥ យ៉ាងនេះឯង ។ សេចក្តីអធិប្បាយនេះមាននៅក្នុង គម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត បញ្ចមភាគ ។*

*ក្នុង អង្គុត្តរនិកាយ សត្តកនិបាត អដ្ឋមភាគ មិត្តប្រកបដោយអង្គ ៧ ប្រការគួរសេពគប់ គឺ* **ទុទ្ទទំ ទទាតិ** *គឺមិត្តឲ្យនូវរបស់ដែលគេឲ្យបានដោយកម្រ ១* **ទុក្ករំ ករោតិ** *ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ១* **ទុក្ខមំ ខមតិ** *អត់ធន់ចំពោះហេតុដែលគេអត់ធន់បានដោយកម្រ ១* **គុយ្ហមស្ស អាវិក្ករោតិ** *បើកបង្ហាញសេចក្តីកំបាំងរបស់ខ្លួនដល់គ្នា ១* **គុយ្ហមស្ស បរិគូហាតិ** *បិទសេចក្តីកំបាំងរបស់គ្នា ១* **អាបទាសុ ន ជហាតិ** *មិនលះគ្នាក្នុងគ្រាមានសេចក្តីអន្តរាយ ១* **ខីណេន នាតិមញ្ញតិ** *មិនមើលងាយគ្នាព្រោះអស់ភោគៈ ១ ។*

ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៧ ប្រការនេះឯងគួរសេព ។

មិត្តឲ្យនូវរបស់ដែលគេឲ្យបានដោយកម្រផង ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រផង មួយទៀត អត់ធន់ចំពោះពាក្យដែលពោលអាក្រក់ និងហេតុដែលអត់ធន់បានដោយកម្រផង ប្រាប់សេចក្តីកំបាំងរបស់ខ្លួនដល់គ្នាផង បិទសេចក្តីកំបាំងរបស់គ្នាផង មិនលះគ្នាក្នុងគ្រាមានសេចក្តីអន្តរាយផង មិនមើលងាយគ្នា ព្រោះអស់កោគៈផងហេតុទាំងនេះមានក្នុងបុគ្គលណា ក្នុងលោកនេះ បុគ្គលមានសភាពដូច្នោះនោះ ហៅថា មិត្ត ជនអ្នកមានប្រាថ្នានូវមិត្តគប្បីសេពគប់ ។

ព្រះទសពលមានព្រះពុទ្ធដីកាត្រាស់ថា **សត្តហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត...** ។ល។ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាង ភិក្ខុមិនទាន់ចូលទៅជិត មិនគួរចូលទៅជិតទេ ឬបានចូលទៅជិតហើយ មិនគួរអង្គុយឡើយ ។ ៧ យ៉ាងតើអ្វីខ្លះ ? **ន មនាបេន បច្ចុដ្ឋេន្តិ** គឺពួកជនមិនក្រោកទទួលដោយសេចក្តីពេញចិត្ត ១ **ន មនាបេន អភិវាទេន្តិ** មិនថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ **ន មនាបេនអាសនំទេន្តិ** មិនប្រគេនអាសនៈដោយសេចក្តីពេញចិត្ត ១ **សន្តមស្ស បរិគុហន្តិ** លាក់ទុក

នូវទេយ្យធម៌របស់គេ ១ **ពហុកម្ហិ ថោកំ ទេន្តិ** កាលបើទេយ្យធម៌មានច្រើនឲ្យតិច ១ **បណីតម្ហិ លូខំ ទេន្តិ** កាលបើមានទេយ្យធម៌ដ៏ឧត្តម ឲ្យរបស់សៅហ្មង ១ **អសក្កច្ចំ ទេន្តិ នោ សក្កច្ចំ** ឲ្យដោយសេចក្តីមិនគោរព មិនឲ្យដោយសេចក្តីគោរព ១ ។ ម្នាលភិក្ខុទាំងឡាយត្រកូលប្រកបដោយអង្គ ៧ យ៉ាងនេះឯង ភិក្ខុមិនទាន់ចូលទៅជិត មិនគួរចូលទៅជិតទេ ឬបានចូលទៅជិតហើយ មិនគួរអង្គុយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាង ភិក្ខុមិនទាន់ចូលទៅជិត គួរចូលទៅជិត ឬបានចូលទៅជិតហើយ គួរអង្គុយបាន ។ ៧ យ៉ាងតើអ្វីខ្លះ ? គឺជនពួកក្រោកទទួល ដោយសេចក្តីពេញចិត្ត ១ ថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ ប្រគេនអាសនៈដោយសេចក្តីពេញចិត្ត ១ មិនលាក់ទុកនូវទេយ្យធម៌របស់គេ ១ កាលបើមានទេយ្យធម៌ច្រើន ប្រគេនច្រើន ១ កាលបើមានទេយ្យធម៌ដ៏ឧត្តម ប្រគេនទេយ្យធម៌ដ៏ឧត្តម ១ តែងប្រគេនដោយសេចក្តីគោរព មិនប្រគេនដោយសេចក្តីមិនគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាងនេះឯង ភិក្ខុមិនទាន់ចូលទៅជិត គួរចូលទៅជិតបាន ឬចូលទៅជិតហើយ គួរអង្គុយបាន ។

ក្នុង អដ្ឋកថាអង្គុត្តរនិកាយ អដ្ឋកនិបាត នវភាគ កម្លាំងមាន ៨ យ៉ាង គឺពួកក្មេងមានការយំជាកម្លាំង ១ ពួកមាតុគ្រាមមានសេចក្តីក្រោធជាកម្លាំង ១ ពួកចោរមានគ្រឿងអាវុធជាកម្លាំង ១ ពួកព្រះរាជាមានឥស្សរិយៈជាកម្លាំង ១ ពួកជនពាលមានការលើកទោសជាកម្លាំង ១ ពួកបណ្ឌិតមានការរំពឹងគិតជាកម្លាំង ១ ពួកពហុស្សុតមានការពិចារណាជាកម្លាំង ១ ពួកសមណព្រាហ្មណ៍មានការអត់ធន់ជាកម្លាំង ១ ។ អធិប្បាយថា ពួកក្មេងមានការយំជាកម្លាំង គឺយំច្រើន ។ ពួកមាតុគ្រាមមានសេចក្តីក្រោធជាកម្លាំង គឺតាំងសេចក្តីក្រោធជាប្រមុខ ។ ពួកចោរមានគ្រឿងអាវុធជាកម្លាំង ពួកចោរទាំងឡាយនោះ តែងចាត់ចែងស្វែងរកនូវគ្រឿងអាវុធជាកម្លាំង ។ ធម្មតាព្រះរាជានោះ មានតែការស្រេវឹងដោយរាជឥស្សរិយយសជាកម្លាំង ។ ជនពាលទាំងឡាយ មានការលើកទោសជាកម្លាំងនោះ គិតនូវកិច្ចការអ្វីៗ មានតែការនិន្ទាថា អាក្រក់ លើកទោសអ្នកឯទៀតជាកម្លាំង ។ ពួកបណ្ឌិតមានការរំពឹងគិតជាកម្លាំង ជាវិស័យប្រពៃណីរបស់បណ្ឌិតទាំងឡាយ មានតែការពិចារណាស្វែងរកនូវហេតុដែលជាប្រយោជន៍ តែងលះបង់ចោលនូវហេតុដែលគ្មានប្រយោជន៍ ដឹង

ថា កម្មណាមិនគួរធ្វើ កម្មនេះធ្វើហើយមានទោស កម្មនេះមិនមានប្រយោជន៍ កម្មនេះធ្វើហើយមានប្រយោជន៍ ពិចារណាដូច្នេះជាកម្លាំងរបស់បណ្ឌិតទាំងឡាយអំពីបុរាណបន្តគ្នាមក ។ ពួកពហុស្សូតតែងប្រកបដោយសេចក្តីព្យាយាម ពិចារណានូវសង្ខារធម៌រឿយៗ ជាកម្លាំងដាក់បញ្ញាពិចារណាឃើញសង្ខារធម៌សុទ្ធតែជា **អនិច្ចំ ទុក្ខំ អនត្តា** ។ ធម្មតាសមណព្រាហ្មណ៍អ្នកមានសីលនោះ ប្រកបដោយកម្លាំងខន្តីសង្កត់ចិត្តជាអនេក កម្លាំង ៨ ប្រការនេះ តែងតែកើតដល់បុគ្គលទាំងឡាយដោយប្រការនេះឯង ។

មានរឿងតំណាលថា កាលពីអតីត គ្រាដែលព្រះបាទឱក្កាករាជបរមក្សត្រដ៏ប្រសើរ ដែលជាដើមវង្សនៃសក្យរាជ ក្នុងក្រុងកបិលពស្តុមហានគរនោះ រមែងធ្វើការសង្គ្រោះដល់ប្រជានុរាស្ត្រទាំងឡាយ ដោយសង្គហវត្ថុ ៤ ប្រការ គឺសស្សមេធំ ១ បុរិសមេធំ ១ សម្មាបាសំ ១ បិយវាចា ១ ។ អាការនៃសន្ទូងដែលល្អបរិបូណ៌ ១០ យក ១ ឈ្មោះថា **សស្សមេធំ** គឺសន្ទូងឲ្យផលជាគ្រាប់ប្រមាណ ១០ រទេះ ក៏យកពន្ធ ១ រទេះ ព្រះរាជាដែលទ្រទ្រង់នូវបញ្ញាឈ្លាសវៃក្នុងអាការ ញ៉ាំងស្រូវឲ្យបរិបូណ៌យ៉ាងនេះ ឈ្មោះថា **សស្សមេធំ** ។ អាការដែល

ព្រះរាជទានបៀវត្សប្រចាំឆ្នាំ និងទ្រព្យសម្បត្តិទាំងឡាយសមគួរដល់អ្នករាជការ សូម្បី ៦ ខែហើយ ក៏ព្រះអង្គព្រះរាជទានដែរ ដូច្នេះឈ្មោះថា **បុរិសមេធំ**។ អាការដែលទ្រទ្រង់បញ្ញាវាងវៃក្នុងការសង្គ្រោះដល់យោធា មានពាហនៈ តូចធំ សង្គ្រោះឲ្យឱ្យឱ្យបុលនូវព្រះរាជទ្រព្យប្រមាណ ១០០០-២០០០ ធ្វើបញ្ជីកំណត់ហេតុ ស្នាមមេដៃពីអ្នកឱ្យនោះ ។ លុះកន្លងទៅបាន ៣ ឆ្នាំ ទើបហៅបុរសនោះមកយកតែប្រាក់ដើម ឈ្មោះថា **សម្មាបាសំ** គឺទំនុកបម្រុងចិញ្ចឹមមនុស្សក្រីក្រទាំងឡាយ ចាត់ចែងឲ្យធ្វើការរកស៊ីជាធម្មតា ហាក់បីដូចជាចងស្រែះទុកក្នុងហទយៈ ហេតុដូច្នោះ ទើបឈ្មោះថា **សម្មាបាសំ** ។ អាការដែលមានព្រះបន្ទូលពីរោះផ្អែមល្ហែម គឺហៅថា ហៃកូន ឬអ្នកម្ដាយដោយន័យជាដើមដូច្នេះ ឈ្មោះថា **បិយវាចា** ឬ **វាចាបិយំ** ។ ជនបទរាជនីតូចធំទាំងឡាយ ដែលព្រះបាទឱក្កាករាជព្រះអង្គសង្គ្រោះដោយសង្គហវត្ថុ ៤ ប្រការដូច្នេះ ក៏មាំទាំបរិបូណ៌ទៅដោយបាយទឹក ភោជនាហារដ៏ច្រើន មិនបានខ្វះខាត សុខសប្បាយទូទាំងព្រះរាជាណាចក្រ ប្រាសចាកចោរអន្តរាយទាំងឡាយ មនុស្សទាំងឡាយក៏នាំគ្នាសរសើរព្រះរាជា ប្រកបទៅដោយសេចក្ដីសុខក្សេមក្សាន្តជា

អនេក ញុំាងពពួកក្មេងទាំងឡាយ ឲ្យរាំច្រៀងសប្បាយរីករាយ ក្នុងប្រទេសរបស់ខ្លួន ។ **អបារុតឃរា** ទ្វារផ្ទះបើកជានិច្ច មិនបានបិទ **អយំ បោរាណាបវេណី** នេះជារាជប្រពៃណីអំពីមុនមក ព្រះបាទឱក្កាករាជ ព្រះអង្គគ្រប់គ្រងព្រះនគរ សុខសប្បាយយូរអង្វែង ។

**អបរភាគេ បន** ចំណេរកាលក្រោយមកនោះ ព្រាហ្មណ៍ទាំងឡាយក៏មកផ្លាស់ប្តូរនូវសង្គហវត្ថុនោះជាថ្មី ញុំាងនូវរាជសម្បត្តិស្រុក ក្រុងឲ្យប្រែប្រួល កាលព្រាហ្មណ៍ធ្វើវិធីបូជាយញ្ញ គ្រានោះពួកព្រាហ្មណ៍ស្លៀកដណ្តប់ពណ៌លឿងពណ៌-ស ពណ៌ក្រហមផ្សេងៗ ហើយក៏សម្លាប់គោទាំងឡាយដ៏ច្រើន រួចហើយកាត់សាច់គោស៊ីក្នុងរណ្តៅយញ្ញ គោទាំងឡាយកាលឃើញពួកព្រាហ្មណ៍ទាំងពួង ស្លៀកដណ្តប់សំពត់ពណ៌ផ្សេងៗ ក៏រន្ធត់ចិត្តភ័យខ្លាចនាំគ្នាផ្អើលរត់ចេញទៅជាច្រើន ។ សេចក្តីនេះមានពិស្តារក្នុង **អដ្ឋកថាព្រាហ្មណធម្មិយសូត្រ** និង ***កោសលសំយុត្ត*** ។

ក្នុង ***អដ្ឋកថាវិភង្គ*** សម្តែងថា ពីជផែនដីជាដើម គឺសិលា ភ្នំ និងក្រួសផ្សេងៗ ជាច្រើនដុំតូចប្រមាណប៉ុនគ្រាប់សណ្តែក សូម្បីធំប៉ុនមួយក្តាប់ដៃ ក៏ហៅថាក្រួស គ្រាប់ក្រួសមានប្រមាណប៉ុនគ្រាប់

សណ្តែក តូចជាងគ្រាប់សណ្តែកក្តី តូចរហូតប៉ុនគ្រាប់ខ្សាច់នោះ ហៅថា ខ្សាច់ទាំងអស់ និងគ្រាប់ក្រួសធំដែលតាំងនៅលើបាតដៃមិនបាន ធំឡើងទៅរហូតប៉ុនខ្ទួនដំរីជាកំណត់ ឈ្មោះថា **ចាសាណា** ផ្ទាំងថ្មជា និងដុំសិលា តាំងអំពីដុំសិលាធំប៉ុនខ្ទួនដំរី ធំៗ ឡើងទៅនោះ ឈ្មោះថា ភ្នំ អធិប្បាយថា ធម្មជាតិទាំងឡាយដែលកើតលើផែនដីនោះ ឈ្មោះថា មាស ក៏មាសដែលជាគ្រឿងប្រើប្រាស់នៃមនុស្សទាំងឡាយ យកមក ប្រដាប់តាក់តែងជាអាភរណៈ ជាគ្រឿងអលង្ការ ជាខ្សែ-ក ខ្សែដៃ សង្វារជាដើមនោះ ។ មាសមានផ្សេងៗ គ្នា គឺមាសដែលឈ្មោះថា យុត្តិកតៈ រសវិទ្ធុ អាករុបបន្ន ចាមិករ សាតកុម្ភៈ ជម្ពូនទៈ សិង្គី ។ ការពិត មាសរសវិទ្ធុល្អជាងមាសយុត្តិកតៈៗ នោះ ជាមាសគ្មានតម្លៃ មាសអារុបបន្ននោះល្អជាងមាសរសវិទ្ធុ មាសឈ្មោះចាមិករៈនោះ ល្អជាង មាសអាករុបបន្ន មាសសាតកុម្ភៈនោះល្អជាងមាសចាមិករៈ មាសជម្ពូនទៈ នោះល្អជាងមាសសាតកុម្ភៈ មាសសិង្គីនោះល្អជាងមាសជម្ពូនទៈ ។ការពិត មាសសិង្គីនោះប្រសើរជាងមាសទាំងពួង ហេតុដូច្នោះ ព្រះសម្ពុទ្ធ នាថ្ងៃពុទ្ធដំណើរទៅកាន់ក្រុងរាជគ្រឹះ គ្រានោះ ព្រះឥន្ទ្រពោល សរសើរកិត្តិគុណថា ព្រះមានព្រះភាគ ព្រះអង្គជាកំពូលនៃលោក ព្រះ

អង្គផុតចាកកិលេសទាំងឡាយ ចោមរោមទៅដោយព្រះខីណាស្រព ជាច្រើនរូប សុទ្ធតែផុតចាកកិលេសទាំងអស់ ។ ព្រះកាយរបស់ ព្រះមុនី មានពណ៌សម្បុរផូរផង់ឥតគណនា ស្អាតប្រៀបដូចមាស សិង្គី ។ ព្រះឥន្ទ្រាធិរាជយកព្រះធរីនៃព្រះមានព្រះភាគ ប្រៀបនឹងដោយ មាសសិង្គី ដូច្នេះ ព្រោះហេតុដូច្នោះ ទើបមាសសិង្គីនេះ ល្អជាងមាស ទាំងពួង ។ ឯមាសដែលស្រមោចខ្មៅស្រមោចក្រហមទាំងឡាយ ពាំយកមកនោះ ឈ្មោះថា មាសហជកៈ ពាក្យនេះមាននៅក្នុង **អដ្ឋកថាអង្គុត្តរនិកាយ តិកនិបាត ទុតិយភាគ** ។

ក្នុង **អដ្ឋកថាគម្ពីរសំយុត្ត** នោះសម្តែងថា មាសដែលឈ្មោះថា ជាតរូបនោះ ជាមាសបដិរូបកៈ សមគួរហៅថាមាសពិត មាសយ៉ាងល្អ ប្រសើរ និងមាសដែលសម្រេចហើយទៅដោយសេវិទ្ធ អារកុដៈនោះ ជាមាសគ្រឿងប្រដាប់តាក់តែងរបស់មនុស្ស បើសាច់មាសនោះ មាស ដែលមានតម្លៃច្រើនហៅថា **មាសនិក្ខៈ** ។

ពោលដោយកែវមុក្តាមាន ៨ ប្រការគឺ **ហត្ថិកុម្ភជា** កែវមុក្តា កើតអំពីកំពកក្បាលដំរី មានពណ៌លឿងស្រអាប់ ១ **វរាហទាឋជា** កែវមុក្តាកើតអំពីខ្នាយជ្រូក មានពណ៌លឿងដូចខ្នាយជ្រូក ១ **ភុជង្គ-**

**សីសជា** កែវមុក្តាកើតអំពីក្បាលរបស់នាគ មានសណ្ឋានមូល មានពណ៌ខៀវបរិសុទ្ធស្អាត ១ **វលាហកជា** កែវមុក្តាកើតអំពីវលាហកៈ មានរស្មីដូចពន្លឺព្រះអាទិត្យ បើតាំងទុកក្នុងវេលារាត្រី រមែងកម្ចាត់នូវភាពងងឹត សមគួរជារបស់ប្រើប្រាស់នៃទេវតាទាំងឡាយ ១ **វេឡុជា** កែវមុក្តាកើតអំពីដើមឫស្សី មានពណ៌-ស ភ្លឺថ្លាដូចតំណក់ទឹកភ្លៀង ១ **មច្ឆាសីសជា** កែវមុក្តាកើតលើក្បាលរបស់ត្រី ក្នុងមហាសមុទ្រ មានសណ្ឋានមូល ប៉ុន្តែពណ៌ដូចត្រីស្ងាត មានរស្មីស្រអាប់ ១ **សង្ខជា** កែវមុក្តាកើតអំពីស័ង្ខ មានពណ៌-សដូចពស់របស់ស័ង្ខ មានសណ្ឋានប្រមាណប៉ុនផ្លែក្របៅ មានពណ៌ស្រអាប់ ១ **សិប្បិជា** កែវមុក្តាកើតអំពីខ្យង មានសណ្ឋានល្អវិសេសផ្សេងៗ ។ កែវមុក្តាដែលកើតអំពីស័ង្ខ និងខ្យងនោះ ជាកែវមុក្តាកើតក្នុងផ្ទៃមហាសមុទ្រ ។ កែវមុក្តាដែលកើតលើក្បាលនាគក្តី កើតអំពីផ្ទៃមហាសមុទ្រ កែវមុក្តាឯទៀតក្រៅអំពីនេះ មិនបានកើតអំពីមហាសមុទ្រ និងកើតក្នុងខ្យងនោះ រមែងប្រាកដមានក្នុងលោកដោយច្រើន កែវមុក្តាយ៉ាងដទៃនោះ ជួនកាលទើបកើតប្រាកដឡើងក្នុងលោក ព្រោះហេតុដូច្នោះ ទើបលោកពោលទុកក្នុងសម្មោហវិនោទនីនោះថា កែវមុក្តាកើតក្នុងផ្ទៃមហាសមុទ្រនោះ

ពោលដោយអំណាចយេកុយ្យន៍យ ពាក្យនេះមាននៅក្នុងព្រះវិន័យ ។

មួយទៀត មាសដែលបុគ្គលធ្វើដោយធាតុក្រហមនោះឈ្មោះថា អារកូដលោហៈ ក៏កិត្តិមលោហៈនោះ មាន ៣ ប្រការគឺ **កំសលោហ ១ វដ្តលោហ ១ អារកូដលោហ ១** ។ កំសលោហនោះ បុគ្គលលាយចូលនូវដុំខ្មៅតែម្យ៉ាង ជាជាតិសង្កសីទេស វដ្តលោហនោះ បុគ្គលលាយចូលនូវដុំខ្មៅតែម្យ៉ាង ធ្វើទុកប្រើប្រាស់ គឺមាសលឿង មាស-ស អារកូដលោហនោះ បុគ្គលលាយចូលនូវបារត និងទង់ដែង ធ្វើទុកប្រើប្រាស់ គឺជាធាតុមាស កិត្តិមលោហទាំងឡាយ ៣ នេះ ហៅថាកិត្តិមលោហនោះឯង ដែលកើតឡើងដោយហេតុផ្សេងៗ គ្នា ដូច្នេះធ្វើទុកប្រើប្រាស់ ប៉ុន្តែអារកូដលោហនោះ មានពណ៌លឿង សាច់ក៏ទន់ ដូចមាសដ៏ល្អ និងដែលថា មាស ឬទង់ហ្វាក៏តាមតែមនុស្សប្រើប្រាស់ ។

មួយទៀតកែវពិទូរ្យដែលកើតក្នុងក្រុងក្បែរភ្នំវិរុឡ្ហ និងស្រុកវិរុឡ្ហលាយចូលគ្នា មានពណ៌សម្បុរស្អាត ដូចពណ៌ផ្កាត-ករបស់សត្វក្ងោកក៏មាន ពណ៌ដូចស្លាបក្អែកក៏មាន ពណ៌ដូចខ្នងឫស្សីស្រស់ក៏មាន ។ ពាក្យទាំងនេះពោលទុកក្នុង **អដ្ឋកថាវិមានវត្ថុ** ។

ក្នុង **អដ្ឋកថាអង្គុត្តរនិកាយ** នោះថា កែវពិទូរ្យនោះ មានពណ៌ ដូចឫស្សីព្រៃដែលមានអាយុបាន ១ ឆ្នាំ ។

ក្នុងដីកាព្រះវិន័យថា កែវពិទូរ្យកើតក្នុងបំពង់ឫស្សី លាយក្រហម ដូចពណ៌ឈាម ហើយពណ៌ស្រអាប់ ។

ក្នុង **អដ្ឋកថាកោសលសំយុត្ត** កែវទាំងឡាយចាត់ជាពីរពួក ។ កែវ ៧ ប្រការ ឈ្មោះថា សុវណ្ណ ១ រជត ១ មុត្តា ១ វេឡុរិយា ១ ពពាល ១ សិលា ១ ស័ង្ខ ១ ជាកែវ ៧ ប្រការ ។ កែវ ១០ ប្រការនោះ គឺមុត្តា ១ មណី ១ វេឡុរិយា ១ ស័ង្ខ ១ សិលា ១ ពពាល ១ រជត ១ សុវណ្ណ ១ មសារគល្វ ១ លោហិត ១ កែវ ១០ ប្រការកើតក្នុងលោក ចាប់ផ្ដើមពីព្រះអាទិត្យរះកើតឡើងលើក្នុំយុគន្ធរ រុក្ខជាតិទាំងឡាយ កើតក្នុងពេលដែលព្រះអាទិត្យក្ដៅសព្វ ។ រសផែនដី និងរសអាបោ ក៏ចេញអំពីស្លឹក ចេញអំពីអំពីមែក ទៅកាន់ដើម ទៅកាន់គល់ ហើយ ក៏ចូលទៅកាន់ផែនដីដោយលំដាប់ដូច្នេះ ចាប់តាំងពីព្រះអាទិត្យអស្ដង្គត ហើយ រសទាំងឡាយនោះ ក៏ចេញអំពីផែនដីទៅកាន់ឫសនៃរុក្ខជាតិ ទាំងឡាយ ចេញអំពីឫសទៅកាន់ដើម ទៅកាន់មែក ទៅកាន់ស្លឹកចាស់ ទៅកាន់ត្រួយទាំងឡាយជាដើម ដោយលំដាប់គ្នាដូច្នេះ បើរសទាំង

ឡាយចូលទៅកាន់ឫស និងដើមជាដើមនោះ ប្រសិនបើផ្លែឈើស្រគាល ទុំ ទុំជោរ រសទាំងឡាយ ក៏មិនបានទៅកាន់ទងរបស់ផ្លែ ទងរបស់ផ្លែមិនមានរសជី រសទឹកជាប្រមាណ កាលត្រូវពន្លឺព្រះអាទិត្យក៏ក្រៀមស្វិត ហេតុដូច្នោះ ទើបផ្លែឈើទាំងឡាយតែងតែជ្រុះអំពីពេលព្រឹក ។

ក្នុង **អដ្ឋកថាថេរគាថា** សម្តែងថា បាតនៃមហាសមុទ្រនោះ មានអន្លង់ផ្សេងៗ គ្នា មានប្រមាណ ១០០ យោជន៍ជាដើម កើតមានតាំងអំពីដំបូងក្នុងបឋមកប្ប ។ រីកន្លែងខ្លះ ក៏ជាទីលំនៅរបស់នាគទាំងឡាយ កន្លែងខ្លះទំនេរមិនមានអ្នកណានៅឡើយ ។

មានពាក្យសម្តែងទុកក្នុងទីនេះថា នៅខាងក្នុំវេភារនោះ មានពិភពរបស់នាគរាជទាំងឡាយ ដែលនៅក្នុងផែនដីប្រមាណ ៥០០ យោជន៍ សប្បាយដូចស្ថានទេវលោក ដែលប្រកបទៅដោយផ្លែកែវ និងឧទ្យាន ។ក្នុងឧទ្យាននោះ មានស្ទឹងធំ ទឹកថ្លាស្អាត គួរជាទីត្រេកអរសប្បាយចិត្ត មានហ្វូងត្រី ហ្វូងអណ្តើកជាច្រើន គឺជាទីលេងកម្សាន្តរបស់នាគរាជទាំងឡាយ មានទាំងគុម្ពបទុមជាតិទាំងឡាយ មានផ្កាធំប្រមាណប៉ុនកង់រទេះ ក្នុងពិភពនាគរាជនោះ មានស្រះឈ្មោះថាតបោទា

មានទឹកក្តៅហុយៗ ហេតុដូចម្តេចទើបមានទឹកក្តៅហុយៗ ដូច្នោះ ?

មានចម្លើយថា **រាជគហំ បរិវារេត្វា** រវេបតលោកដ៏ធំជុំវិញ នៅទីក្រុងរាជគ្រឹះ ស្ទឹងតបោទាហូរកាត់មហាគម្ភីនរកទាំងឡាយ ក្នុងបេតលោកនោះ **តស្មា** ព្រោះហេតុដូច្នោះ ទើបទឹកក្តៅហុយៗ ជានិច្ច ។ ពាក្យទាំងនេះលោកសម្តែងទុកក្នុង **អដ្ឋកថាទេវតាសំយុត្ត** ដែលមាននិយាមកំណត់ទុក ជាកន្លែង ជាទីតាំងរបស់នរកទាំងឡាយដ៏សេសក្តី របស់នាគពិភពទាំងឡាយក្តី ការកើតនៃត្រី និងអណ្តើក មួយអន្លើដោយបទុមជាតិទាំងឡាយជាដើម ដែលមាននៅក្នុងស្ទឹង និងស្រះទាំងឡាយជាដើម ដែលទ្រផែនដីនោះ និងមិនមានកំណត់ ។ អ្នកប្រាជ្ញគប្បីជ្រាបដោយន័យដូច្នេះ ដែលលើកលែងតែលោកន្តរនរក គឺមាននិយាមកំណត់ទុកថា ចន្លោះរបស់ចក្រវាលទាំងឡាយដែលជាអនន្តអបរិមាណ របស់ចក្រវាលទាំងឡាយ ៣ នោះ មានឈ្មោះថា **លោកន្តរនរក** សត្វទាំងឡាយដែលកើតក្នុងចន្លោះចក្រវាលទាំង ៣ នោះឈ្មោះថា **សត្វលោកន្តរ** រលោកន្តរនរកនីមួយៗ មាននៅក្នុងចន្លោះនៃចក្រវាលទាំង ៣ ដូចផ្កាបទុមជាតិទាំងឡាយ ៣ ដ៏ធំ ប្រមាណប៉ុនកង់រទេះ តាំងនៅជិតៗ គ្នា **សោ**

**បង  បរិមាណតោ** ប្រសិនបើនឹងប្រមាណលោកន្តរនរកនោះ ប្រហោងជានិច្ច គ្មានវត្ថុណានីមួយបិទបាំង គឺជាចន្លោះទទេ ប្រមាណ ៨ ពាន់យោជន៍ ។ ក្នុងទីកន្លែងលោកន្តរនរកនោះ មិនមានផែនដី ខាងក្រោមបិទបាំងនូវទឹកទុកឡើយ ហេតុដូច្នោះ ទើបលោកន្តរ-នរកគ្មានវត្ថុណាបិទបាំងឡើយ ខាងក្រោមយ៉ាងណា ខាងលើនោះ ក៏គ្មានវត្ថុបិទដែរ ព្រោះមិនមានវិមានទេវតាទាំងឡាយ ។ លោកន្តរនរក ប្រកបទៅដោយភាពងងឹតខ្លាំងក្រៃលែង អាចហាមនូវកិរិយាកើតនៃ ចក្ខុវិញ្ញាណ បិទគ្របគ្មានពន្លឺ សូម្បីព្រះចន្ទព្រះអាទិត្យ ផ្សាយនូវពន្លឺ ទៅក្នុងទ្វីបទាំង ៣ ឲ្យភ្លឺព្រមគ្នាក្នុងពេលតែមួយបាន ក៏មិនអាចនឹង សម្តែងអាការលោកឲ្យភ្លឺក្នុងលោកន្តរនរកនោះបានឡើយ ។ ការពិត ព្រះចន្ទព្រះអាទិត្យទាំងពីរត្រាច់ចរជុំវិញភ្នំសិនេរុដ៏ខ្ពស់ ប្រមាណត្រឹម កំពូលភ្នំយុគន្ធរ ជាកណ្តាលនៃភ្នំចក្រវាល ។ លោកន្តរនរកនោះតាំង នៅខាងក្រៅភ្នំកណ្តាប់ចក្រវាល ហេតុដូច្នោះ ព្រះចន្ទ ព្រះអាទិត្យ បំភ្លឺឲ្យភ្លឺមិនបាន ។ មួយទៀតសោត ចក្ខុវិញ្ញាណក៏មិនបានកើត ។ កាលព្រះបរមពោធិសត្វចុះចាប់បដិសន្ធិជាដើម ទើបនឹងកើតមានពន្លឺ ភ្លឺស្វាង ទើបកើតចក្ខុវិញ្ញាណបានឃើញពន្លឺដូចពន្លឺផ្លេកបន្ទោរ ។ ពិត

ហើយ សត្វទាំងពួងបានឃើញគ្នា និងគ្នាក្នុងពេលនោះ ពោលថា សត្វទាំងឡាយកើតក្នុងទីនេះមានច្រើនហ្ន៎ ។ រីពន្លឺនៅគ្រានោះ មិនភ្លឺបានយូរ និងតាំងនៅយូរប្រមាណហុតទឹកបបរមួតភ្លេតក៏មិនមែន លឿនរហ័សដូចផ្លេកបន្ទោរ ប្រមាណមួយផ្ទាត់ម្រាមដៃប៉ុណ្ណោះ ល្មមតែសត្វទាំងឡាយពោលថា នេះវត្ថុអ្វី រួចហើយក៏ងងឹតសូន្យឈឹង ។ សួរថា ពួកសត្វទាំងឡាយនេះ ធ្វើកម្មដូចម្ដេច ទើបទៅកើតនៅក្នុងលោកន្តរនរកនោះ ?

ឆ្លើយថា ធ្វើកម្មលាមកថោកទាបក្រៃលែង គឺប្រទូស្តចំពោះមាតាបិតា និងសមណព្រាហ្មណ៍ទាំងឡាយ អ្នកតាំងនៅក្នុងធម៌ ធ្វើតែបាណាតិបាត ប្រទូស្តចំពោះមាតាបិតាជាដើម រាល់ថ្ងៃគ្មានដាច់ ទើបធ្លាក់ទៅកើតក្នុងលោកន្តរនរកនោះ ប្រៀបដូចចោរទាំងឡាយ មាននាគចោរ និងអភយចោរក្នុងលង្កាទ្វីបជាដើម អត្តភាពនៃសត្វទាំងឡាយក្នុងលោកន្តរនរកនោះធំប្រមាណ ៣ គាវុត ។ សត្វនរកទាំងនោះមានក្រចកវែងៗ ដូចក្រចកសត្វប្រចៀវ ប្រតោងខ្លួននៅតាមជើងភ្នំកណ្ដាប់ចក្កវាឡ ដោយក្រចកទាំងឡាយ ដូចសត្វប្រចៀវប្រតោង នៅតាមមែកឈើ ដូច្នោះ កាលបើប្រតោងវារទៅប៉ះនូវដៃគ្នានិងគ្នាក៏សម្គាល់

ថា បានជួបប្រទះអាហារ មានកិរិយាខ្វល់ខ្វាយស្រវាចាប់យកនូវគ្នា និងគ្នាស៊ី ។ លុះរបូតដៃធ្លាក់ចុះត្រូវទឹកក្រុត ក៏រលាយ រលួយដូចម្សៅជាផង់លម្អិតក្នុងទឹកក្រុតនោះ ។ ការពិត លោកន្តរនរកនោះ ជាកន្លែងទឹកក្រុតតែម្យ៉ាង ព្រោះអាស្រ័យនូវភាវៈដ៏ត្រជាក់ក្រៃលែង និងព្រោះមិនមានកម្តៅទៅដល់ ។

អធិប្បាយនូវសេចក្តីសង្ស័យ ក្នុងទឹកក្រុតថា ទឹកក្រុតដែលនៅក្នុងលោកន្តរនរក មិនជាទឹកទ្រផែនដី ដែលកើតជាមួយនឹងទឹកភ្លៀងឡើយ ហេតុដូច្នោះ ទឹកក្រុតលោកន្តរនរក មិនជាទឹកក្រុតប្រល័យកប្បឡើយ បើជាទឹកក្រុតប្រល័យកប្បហើយ ផែនដី និងចក្រវាលគប្បីរលាយជាផង់ ទៅជាទឹកក្រុត ដូច្នោះ ប៉ុន្តែសត្វក្នុងលោកន្តរនរកទាំងឡាយនោះ ប្រៀបដូចទឹកធម្មតា ដែលកើតជាបុព្វលោហិតដល់ពពួកប្រេតទាំងឡាយ ដោយអំពើបាបរបស់ខ្លួន លុះធ្លាក់ចុះទៅលើផ្ទៃនៃទឹកក្រុតនោះ ក៏រលាយរលួយជាផង់ទៅ ប្រៀបដូចដុំម្សៅដែលធ្លាក់ចុះទៅក្នុងទឹកក្រុត ពាក្យនេះមាននៅក្នុង **មហាបទានសូត្រ** ក្នុង **ទីឃនិកាយ** ។

ក្នុង **អដ្ឋកថាហេមវតសូត្រ** នោះថា បុព្វនិមិត្តទាំងឡាយ ៣២

ប្រការ ដែលកើតមានក្នុងខណៈដែលព្រះបរមពោធិសត្វចុះចាប់បដិសន្ធិ ចេញសាងមហាភិនេស្រ្កមណ៍ បានត្រាស់ដឹងបរមាភិសេកសម្ពោធិ-ញ្ញាណ ស្តេចរំលត់ខន្ធចូលកាន់ព្រះនិព្វាននៃព្រះពុទ្ធជាម្ចាស់ទាំងឡាយ នឹងមិនបានតាំងនៅយូរ ប៉ុន្តែខណៈដែលព្រះមានជោគត្រាស់សម្តែង **ធម្មចក្កប្បវត្តនសូត្រ** នោះ ប្រាកដតាំងនៅអស់កាលដ៏យូរ ទើបអន្តរធានទៅ ។

ក្នុង **អដ្ឋកថាមហាសច្ចកសូត្រ** ក្នុង **មជ្ឈិមនិកាយ** ថា ធម្មតាក្អែកនោះសូម្បីបានស៊ីមធុបាយាសដែលលាយដោយទឹកដោះដ៏មានរសរហូតឆ្អែតពេញពោះរួចហើយក្តី បើបានជួបលាមក ទោះបីមិនបានស៊ីក៏ត្រូវហិតបន្តិច ទើបចៀសចេញទៅ បើមិនបានហិតបន្តិចទេនោះ ហើយដើរចេញទៅ សុនខនោះក៏ឈឺក្បាលតែម្យ៉ាង ក៏ប្រៀបដូចនិគ្រន្ថជួបព្រះសម្ពុទ្ធហើយ ក៏ចំអកដៀមដាមបន្តិច ទើបចៀសចេញទៅ ។

ក្នុង **កបោតកជាតក ខុទ្ទកនិកាយជាតក សត្តមភាគ ឯកនិបាត** សម្តែងថា ព្រាបព្រះពោធិសត្វពោលថា បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះតែងដេកសោកសៅ ដូចក្អែកតាំងនៅក្នុង

កណ្តាប់ដៃនៃបុគ្គលជាសត្រូវ ព្រោះមិនធ្វើតាមពាក្យនៃសត្វព្រាប ។

ក្នុង **កាឡជាតក ខុទ្ទកនិកាយជាតក សត្តមភាគ ឯកនិបាត** សម្តែងថា អ្នកពោធិសត្វពោលថា អ្នកទាំងឡាយ ជាសត្វមានហឫទ័យក្វាក់ផ្អើលជានិច្ច ជាសត្វបៀតបៀនមនុស្សលោកទាំងពួង ព្រោះហេតុនោះ បានជាខ្ញាញ់រាវនៃពួកអ្នកដែលជាញាតិរបស់យើងទាំងនោះ មិនមានឡើយ ។

មួយទៀត ព្រះមានព្រះភាគ ព្រះអង្គប្រារព្ធនូវសេចក្តីវិនាសដែលព្រះទេវទត្តឃើញចំពោះលាភសក្ការៈហើយ សូម្បីចំពោះខ្លួននោះឲ្យជាហេតុ ទើបត្រាស់ព្រះធម៌ទេសនាថា **ផលំ វេ កទលឹ ហន្តិ** មានសេចក្តីថា ដើមចេកក្តី ដើមឫស្សីក្តី កាលបើមានផ្លែហើយ ក៏តែងតែសម្លាប់នូវដើមដោយពិត យ៉ាងណា លាភសក្ការៈ គោរពបូជា ដែលជាអាមិសដ៏ប្រសើរផ្សេងៗ នោះ ក៏នឹងបៀតបៀន នឹងសម្លាប់នូវបុសដែលល្មោភ ប្រៀបដូចសេះអស្សតរកើតហើយតែងសម្លាប់មេរបស់វា ។ កាលបើមេសេះអស្សតរមានគភ៌ចាស់ហើយ ក៏មិនអាចកើតកូនបាន ទើបឈរទន្ទ្រំដី មនុស្សទាំងឡាយនាំគ្នាចាប់ចងជើងទាំង ៤ ទៅនឹងបង្គោលទាំង ៤ យ៉ាងមាំ ទើបវះពោះមេសេះយកកូន

ចេញមក មេសេះក៏ស្លាប់នឹងកន្លែងនោះ ហេតុដូច្នោះ ទើបពោលថា កូនសេះដែលជាសេះអស្សតរតែងតែសម្លាប់នូវមេរបស់វា ដោយប្រការដូច្នេះឯង ។

**អយំ វិភាគោ** ពេលឥឡូវនេះ នឹងចែកចេញនូវលក្ខណៈឆ្កួតទាំងឡាយផ្សេងៗ គ្នា គឺឆ្កួតស្រា ឆ្កួតប្រមាត់កម្រើក ឆ្កួតព្រោះយក្ខចូល ។ មានសេចក្តីថា លក្ខណៈប្រមាត់មាន ២ ប្រការ **អពទ្ធបិត្ត** ១ **ពទ្ធបិត** ១ ។ **អពទ្ធបិត្ត** នោះ មានពណ៌ដូចផ្កាត្រកៀតស្រពោន ជ្រួតជ្រាបទូទៅពេញសរីរកាយ លើកលែងតែសក់ រោម ក្រចក ធ្មេញទាំងឡាយដែលប្រាសចាកសាច់ ស្បែក ដែលរឹង ។ ប្រសិនបើអពទ្ធបិត្តកម្រើក សត្វទាំងឡាយនឹងវិលមុខ មានកាយញាប់ញ័រ ឲ្យឈឺ ឲ្យរមាស់ ត្រូវឲ្យអេះ ត្រូវឲ្យអង្អែល ត្រូវផ្សំថ្នាំរក្សារោគរមាស់នោះ ទើបស្ងប់រម្ងាប់ អាការយ៉ាងនេះជាលក្ខណៈប្រមាត់ដែលឈ្មោះថា **អពទ្ធបិត្ត** គឺប្រមាត់មិនមានស្រោម ។ ប្រមាត់ឈ្មោះថា **ពទ្ធបិត្ត** គឺប្រមាត់ដែលនៅក្នុងស្រោម មានពណ៌ដូចប្រេងស្រគំដែលខាប់ អាស្រ័យនូវសាច់ថ្លើម តាំងនៅចន្លោះហទយវត្ថុ និងសួត ចូលទៅនៅក្នុងស្រោមដូចសាញនោងទុំ ដូច្នោះ

ក្នុងកាលប្រមាត់ឃ្លាតចាកអំពីស្រោមតាំងនៅខាងក្រៅហើយ ទើបសត្វទាំងឡាយឆ្កួត ក៏មានចិត្តឃ្លាតចាកការអៀនខ្មាស ធ្វើនូវអំពើដែលមិនគួរធ្វើ ខ្លាចចំពោះរបស់ដែលមិនគួរខ្លាច គិតនូវរបស់ដែលមិនគួរគិត និងមិនដឹងនូវហេតុការណ៍សូម្បីតែបន្តិចបន្តួច ដូចជាភ្លើងក្តៅមាសក្តី ប្រាក់ក្តី របស់អាក្រក់ មានលាមកក្តី របស់ល្អ មានខ្ទឹមចន្ទន៍ក៏យល់ថា ដូចតែគ្នា គឺឆ្កួតជារៀងរហូត **ភេសជ្ជ កិរិយាយ អតេកិច្ឆា** ព្យាបាលរក្សាដោយថ្នាំប្រមាណប៉ុនណា ក៏មិនបាត់ឡើយ យ៉ាងនេះឈ្មោះថា ឆ្កួតប្រមាត់កម្រើក ។ ឆ្កួតព្រោះយក្ខចូលនោះ **សត្តេ ឧម្មត្តកេ ករោន្តា** គឺកាលបើយក្ខញ៉ាំងសត្វទាំងឡាយឲ្យឆ្កួតតែងបង្ហាញរូបបោកបញ្ឆោតឲ្យប្លែក គួរឲ្យភ័យខ្លាច ។ ជួនកាលយកដៃទៅខ្ទាំប្រចាប់ដួងហទយៈ ។អធិប្បាយថា យក្ខទាំងឡាយ ប្រាថ្នាដើម្បីនឹងញ៉ាំងចិត្តនៃអ្នកណាមួយឲ្យរវើរវាយ ក៏ក្លែងភេទរបស់ខ្លួន ឲ្យមានមុខ-ស ពោះខៀវ ដៃជើងក្រហម ក្បាលធំ ភ្នែកត្រឡោតភ្លឺដូចភ្លើង មើលទៅគួរឲ្យស្បើម ឲ្យប្រាកដចំពោះអ្នកនោះ **ភេរវំ សទ្ទំ សាវេន្តិ** ជួនកាលធ្វើឲ្យបានឮសំឡេងយ៉ាងចម្លែក គួរខ្លាច ។ កាលបើមនុស្សទាំងឡាយនិយាយរក ក៏លូកដៃចូលទៅចាប់មាត់ប្រចាប់

បេះដូង ដូនកាលក៏និម្មិតខ្លួនឲ្យតូចចូលទៅក្នុងពោះ ប្រាប់បេះដូង តាំងអំពីនោះ ចិត្តក៏មិនតាំងនៅជាប្រក្រតីទេ សត្វទាំងឡាយក៏ធ្លាត មិនដឹងខ្លួនឡើយ ក៏ជាមនុស្សធ្លាតដើរទៅតាមយថាកម្ម ។ លក្ខណៈ ធ្លាតយ៉ាងនេះ ជួនកាលក៏អាចដឹងខ្លួនខ្លះៗ ប៉ុន្តែបើធ្លាតដោយប្រមាត់ កម្រើក មិនបានដឹងខ្លួនឡើយ ផ្សេងគ្នាដូច្នោះ **គំ ហទយមំសំ** មួយ ទៀត សាច់បេះដូងនោះ មានពណ៌ដូចស្រទាប់បទុមជាតិក្រហម មានសណ្ឋានដូចផ្កាឈូកក្រហម ដែលបុគ្គលបេះស្រទាប់ខាងក្រៅ ចេញ ដាក់សំយុងមុខចុះក្រោម **ពាហិមដ្ឋំ** រលោងខាងក្រៅ ខាងក្នុងដូចផ្លែននោងព្រៃ ។ បុគ្គលទាំងឡាយ ដែលមានបញ្ញាច្រើន បេះដូងរីកធំបន្តិច បើបញ្ញាទន់ ឬបញ្ញាតិច ក៏ក្តោបតូច ខាងក្នុង នៃបេះដូងនោះមូលរលោងដូចទីតាំងនៃផ្ការំដួល ខាងក្នុងមានឈាម ប្រមាណកន្លះទូកដៃ តាំងនៅក្នុងបេះដូងនោះ ជាទីកចិញ្ចឹមរក្សាបេះដូង ប្រសិនបើបុគ្គលជារាគចរិតក៏ពណ៌ក្រហមប្រាល បុគ្គលជាទោសចរិត មានពណ៌ខ្មៅ បុគ្គលជាមោហចរិតពណ៌ដូចទឹកលាងសាច់ បុគ្គលជា វិតក្កចរិតមានពណ៌ដូចប្រេងសណ្តែក បុគ្គលជាសទ្ធាចរិតមានពណ៌ ដូចផ្កាកណិការ បុគ្គលជាបញ្ញាចរិត ក៏ភ្លឺថ្លាផូរផង់ ស.បរិសុទ្ធ

ប្រាកដដូចកែវមណី ដែលដុសលាងសម្អាតថ្មីៗ ។

សេចក្ដីណាជាខ្លឹមសារក្នុងបកិណ្ណកកថា ដែលអាចារ្យពោលដោយន័យផ្សេងៗ យ៉ាងច្រើនដូច្នេះ អ្នកប្រាជ្ញគប្បីធ្វើនូវសេចក្ដីព្យាយាម ដើម្បីនឹងកាន់យកនូវន័យដែលមានខ្លឹមសារនោះ ក្នុងគម្ពីរសារត្ថសង្គហៈនេះ ។ សម្ដែងអំពីហទយវត្ថុនោះ មាននៅក្នុងគម្ពីរវិសុទ្ធិមគ្គ និងន័យសង្គ្រោះយកនូវបកិណ្ណកកថា ក្នុងបទមាតិកានេះក៏ចប់ត្រឹមតែប៉ុណ្ណេះ ។

បកិណ្ណកកថា ចប់

# ឥទ្ធិកថា

ក្នុងលំដាប់បកិណ្ណកកថានោះ នឹងវិនិច្ឆ័យ ក្នុងបទមាតិកាឥទ្ធិ ពោលដោយឫទ្ធិទាំងឡាយផ្សេងៗ ។ ឈ្មោះថាឥទ្ធិនោះ ដោយអត្ថថា សម្រេច និងអត្ថថា **សា ឧសវិធា** រីឫទ្ធិនោះមាន ១០ ប្រការ គឺ **អធិដ្ឋានឥទ្ធិ ១ វិកុព្វនាឥទ្ធិ ១ មនោមយាឥទ្ធិ ១ ញាណវិប្ផារឥទ្ធិ ១ អរិយាឥទ្ធិ ១ សមាធិវិប្ផារឥទ្ធិ ១ កម្មវិបាកជាឥទ្ធិ ១ បុញ្ញវតោឥទ្ធិ ១ វិជ្ជាមយាឥទ្ធិ ១ ឥជ្ឈនដ្ឋេនឥទ្ធិ ១** ជាឫទ្ធិ ១០ ប្រការដូច្នេះ ។

អធិប្បាយថា ធម្មជាតិដែលសម្រេចព្រមទៅដោយការព្យាយាមជាបច្ច័យ ឈ្មោះថា **ឥទ្ធិ** ។ កាលបើកើតឫទ្ធិឡើងនោះ គឺលោកអ្នកឯណាមួយ ដែលទ្រទ្រង់នូវឥទ្ធានុភាព ពិចារណារឿងរ៉ាវឲ្យច្រើនដោយប្រក្រតី ក៏ពិចារណាឲ្យបាន ១ រយដងក្តី ១ ពាន់ដងក្តី ១ ម៉ឺនដងក្តី ១ សែនដងក្តី និងធ្វើនូវអធិដ្ឋាន ដោយញាណពិសេសថា អាត្មាអញនឹងនិម្មិតកាយឲ្យច្រើនក្នុងកាលឥឡូវនេះ ក៏សម្រេចដោយអំណាចអធិដ្ឋាន ឥទ្ធិយ៉ាងនេះ ឈ្មោះថា **អធិដ្ឋានឥទ្ធិ** ។

វិកុព្វនាឥទ្ធិនោះ គឺលោកអ្នកទ្រទ្រង់នូវឫទ្ធិនោះ លះបង់នូវភេទ

ជាប្រក្រតី ក៏ក្លែងភេទជាកុមារ ជាស្តេចនាគ ជាស្តេចគ្រុឌ ជាអាសុរ ជាព្រះឥន្ទ្រ ជាព្រះព្រហ្ម ជាទេវតា ជាមហាសមុទ្រ ជាភ្នំធំ និងសត្វជើង ៤ ដូចជារាជសីហ៍ ជាខ្លា ជាខ្លាធំ ខ្លាដំបង ជាដំរី ជាសេះ ជារថ ជាកងទ័ព ជាក្បួនកងទ័ពមានប្រការផ្សេងៗ ក៏ប្រព្រឹត្តទៅដោយអំណាចនៃអាការដែលក្លែងភេទនោះ ឥទ្ធិយ៉ាងនេះឈ្មោះថា **វិកុព្វនាឥទ្ធិ** គឺប្លែងភេទប្រការណា ប្រាថ្នានូវភេទណាៗ ក៏គប្បីធ្វើអធិដ្ឋាននូវភេទនោះៗ ជាដើម គឺភេទកុមារក៏ប្រាកដឡើងព្រមគ្នានឹងអធិដ្ឋាន សេចក្តីថា លោកអ្នកទ្រទ្រង់នូវឥទ្ធិនោះចូលកាន់ឈាន ដែលជាទីតាំងនៃអភិញ្ញា ហើយចេញចាកឈាន អធិដ្ឋានថា អាត្មាអញជាកុមារចុះ ។ ខណៈនោះ ភេទកុមារក៏ប្រាកដឡើងព្រមគ្នានឹងចិត្តដែលអធិដ្ឋាន នឹងអធិដ្ឋានឲ្យជាដំរី ជាសេះ ជារថ ជាពលថ្មើរជើងក្តី ក៏ប្រាកដឡើង ដូចអធិដ្ឋានដូច្នោះគ្រប់ៗ ប្រការ រីឥទ្ធិយ៉ាងនេះឈ្មោះថា **វិកុព្វនាឥទ្ធិ** ។ ភិក្ខុក្នុងព្រះពុទ្ធសាសនានេះ និម្មិតនូវកាយដទៃអំពីកាយនេះ រីករាយត្រេកអររូបកាយ ដែលប្រកបទៅអវយវៈទាំងពួង ហើយទៅដោយចិត្ត ឥទ្ធិយ៉ាងនេះក៏ប្រាកដដោយ ន័យដូច្នេះ ឈ្មោះថា **មនោមយាឥទ្ធិ** ព្រោះថា សរីរកាយដែលប្រព្រឹត្តទៅខាងក្នុងនៃសរីរ-

កាយរបស់លោកអ្នកមានឫទ្ធិសម្រេចដូចសេចក្តីប្រាថ្នា ។ កាលបើមានសេចក្តីប្រាថ្នានឹងធ្វើមនោមយាឥទ្ធិនោះ ចូលកាន់ឈានហើយ ចេញចាកអំពីឈានដែលជាបាទរបស់អភិញ្ញា ទើបពិចារណានូវកាយជាមុនក្នុងទីបំផុតការធ្វើបរិកម្មនោះ ចូលឈានសាជាថ្មី ចេញអំពីឈានហើយទើបអធិដ្ឋានថា **សុសិរោ ហោតុ** ក្នុងពេលឥឡូវនេះ សូមឲ្យកើតជាប្រហោងៗ ក៏កើតឡើងក្នុងកាយ ទើបពិចារណាកាយរបស់ខ្លួនខាងក្នុងរបស់កាយដែលប្រហោងនោះ ធ្វើបរិកម្មហើយ អធិដ្ឋានដោយន័យដូចពោលមកហើយ ។ ខណៈនោះ កាយដទៃក៏កើតប្រាកដក្នុងខាងក្នុងកាយរបស់ភិក្ខុអ្នកទ្រទ្រង់ឫទ្ធិនោះ ប្រៀបដូចបណ្តូលស្មៅយាប្លងដែលដកចេញមកអំពីស្មៅយាប្លង និងប្រៀបដូចដាវដែលដកចេញអំពីស្រោម យ៉ាងណាក្តី មនោមយាឥទ្ធិនេះ ក៏មានសេចក្តីឧបមេយ្យដូច្នោះឥទ្ធិយ៉ាងនេះ ឈ្មោះថា **មនោមយាឥទ្ធិ** ។

កាលបើញាណកើតមានហើយ គុណវិសេសក៏កើតមានដោយអានុភាពរបស់ញាណដល់គ្នា ក្នុងកាលមុនក្តី ពេលក្រោយក្តី ក្នុងខណៈនោះក្តីក៏សម្រេចដោយពិត ទើបឈ្មោះថា **ញាណវិប្ផារឥទ្ធិ** ។ ញាណវិប្ផារឥទ្ធិនេះ ដូចព្រះពាកុលត្ថេរ ព្រះសង្កិច្ចត្ថេរ និងព្រះភូតបាល

ទារកនោះ ។

**កិរ** បានឮមកថា ការពិត ព្រះពាកុលៈដ៏មានអាយុ កាលនៅជាទារក មេដោះបាននាំយកទៅកាន់កំពង់ទឹក ក្នុងថ្ងៃធ្វើមង្គល មេដោះធ្វេសប្រហែសក៏ធ្លាក់ទឹកអណ្តែតទៅតាមក្រសែទឹក ត្រីធំមួយក៏លេបទារកនោះ ហែលទៅរហូតដល់ក្រុងពារាណសី ។ មានព្រានប្រមង់ម្នាក់ ចាប់បានត្រីធំនោះ យកទៅលក់ឲ្យភរិយារបស់សេដ្ឋីម្នាក់ ភរិយាសេដ្ឋីកើតការចង់បានត្រី គិតនឹងស្ងួត្រីនោះ ទើបវះត្រីនោះអំពីខ្នង ឃើញទារកតូចស្អាត សម្បុរដូចមាសក្នុងពោះត្រីធំនោះ ក៏កើតការរីករាយត្រេកអរ ពោលថា អញបានកូនធម៌ម្នាក់ ។ កាលដែលពាកុលត្ថេរដ៏មានអាយុនៅក្នុងពោះត្រី មិនមានរោគាព្យាធិបៀតបៀនទេ ដូច្នេះឈ្មោះថា **ញាណវិប្ផារឥទ្ធិ** ព្រោះអ្វី ព្រោះថា ព្រះពាកុលត្ថេរជាបច្ឆិមភវិកសត្វ កើតដោយអានុភាពនៃអរហត្ត-មគ្គញ្ញាណ ដែលលោកនឹងគប្បីបាន ក្នុងអត្តភាពដែលជាជាតិចុងក្រោយនេះ ។

ចំណែកព្រះសង្កិច្ចត្ថេរនោះ កាលលោកនៅក្នុងគភ៌ ម្តាយរបស់លោកធ្វើកាលកិរិយា ពួកញាតិទាំងឡាយលើកដាក់លើជើងថ្ករ

ធ្វើឈាបនកិច្ច អ្នកទទួលការបូជាសពយកស្នូល៍ ចាក់ប៉ុកចំត្រូវបកភ្នែក របស់កុមារក្នុងគភ៌ ទារកនោះក៏ស្រែកយំឡើងខ្លាំងៗ ។ ក្រុមញាតិទាំងឡាយនោះ ម្នាក់ៗ ក៏ស្លុតចិត្ត ពោលថា ទារកនៅក្នុងគភ៌នោះនៅមានជីវិត **ឱតារេត្វា** ទើបលើកយកសពមាតាចេញអំពីជើងថ្ករ នាំទារកចេញ ក្រោយមក ទើបបូជាសពម្ដាយទៀត លុះបូជាសពរួចហើយ ក៏នាំយកទារកនោះទៅឲ្យដល់ជីដូនចិញ្ចឹម ជីដូនធ្វើការទំនុកបម្រុងចិញ្ចឹមចៅរហូតចម្រើនវ័យធំ ចៅនោះក៏ចេញបព្វជ្ជានៅក្នុងព្រះសាសនា ក៏បានសម្រេចអរហត្ត ព្រមទាំងបដិសម្ភិទាញាណប្រាកដឈ្មោះថា ព្រះសង្កិច្ចត្ថេរ ។ រីកាវៈរបស់ព្រះសង្កិច្ចត្ថេរនោះមិនមានរោគអន្តរាយជីវិតក្នុងកន្ទែងជើងថ្ករ ដោយន័យដូចពោលមកនេះក៏ចាត់ជាញាណវិប្ផារឥទ្ធិ ។

ចំណែកកូតបាលទារកនោះ កាលឪពុកឲ្យជិះរទេះទៅជាមួយដើម្បីទៅប្រមូលឧសក្នុងព្រៃ ក្បែរក្រុងរាជគ្រឹះ **ធារុភារំ កត្វា** បិតាជាមនុស្សទុគ៌ត ប្រមូលឧសដាក់រទេះពេញហើយ បររទេះទៅដល់ទីជិតក្រុងរាជគ្រឹះ ក្នុងវេលាល្ងាច ដោះគោចេញអំពីនឹម គោនោះក៏ចូលទៅកាន់ក្រុង ទើបឪពុកកូតបាលទារកនោះ ដាក់កូនរបស់ខ្លួន

ឲ្យអង្គុយនៅក្បែររទេះ ខ្លួនទៅតាមគោឯក្រុង ដើរតាមដានជើងគោទាំងឡាយ ។ កាលត្រឡប់ចេញមកនោះ នាយឆ្មាំទ្វារបិទទ្វារព្រះនគរ ក៏ចេញមិនរួច ក៏ត្រូវនៅជាប់ក្នុងព្រះនគរ ទារកនោះក៏ដេកនៅក្រៅក្រុង ។ ក្នុងយប់នោះ មានពួកយក្ខចិត្តអាក្រក់ទាំងឡាយចោមរោមបៀតបៀន ដើម្បីផ្តាច់បង់នូវជីវិត ក៏មិនញុំាងសេចក្តីអន្តរាយអ្វីឡើយ រហូតដល់បានបួសនៅក្នុងព្រះពុទ្ធសាសនា ប្រាកដឈ្មោះថា ព្រះ-ភូតបាលត្ថេរ យ៉ាងនេះក៏ចាត់ជា ញាណវិប្ផារឥទ្ធិ ។

ដូចជាសមាធិរបស់ព្រះសារីបុត្រ ព្រះខានុកោណ្ឌញ្ញត្ថេរ នាងឧត្តរា និងនាងសមាវតីនោះ ។ ព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានអាស្រ័យនៅក្នុងទីមួយ ឈ្មោះថា កបោតកន្ទរប្រទេស លោកទាំងពីររូបដាក់ព្រះកេសាថ្មីៗ ទៅគង់ចម្រើនសមណធម៌ ក្នុងទីវាលក្នុងវេលាយប់ព្រះចន្ទភ្លឺច្បាស់ ទូទាំងពួងនភាល័យ ឯកោ ទុដ្ឋយក្ខោ មានយក្ខចិត្តឃោរឃៅម្នាក់ កាលបើយក្ខជាសម្លាញ់ម្នាក់ ហាមមិនស្តាប់ ហោះចុះមកវាយត្រង់សិរសារបស់ព្រះសារីបុត្រដោយដំបង មានសំឡេងដូចសំឡេងរន្ទះបាញ់ ឬដូចសំឡេងផ្គរលាន់ឯពួងអាកាស ។ ក្នុងកាលមហាយក្ខវាយនោះ ព្រះសារីបុត្រចូលកាន់ឈានសមាបត្តិ ទើប

មិនមានសេចក្តីទុក្ខព្យាធិបៀតបៀនណានីមួយ ដោយការវាយរបស់មហាយក្ខនោះឡើយ រឹតទ្ធិយ៉ាងនេះរបស់ព្រះសារីបុត្រដ៏មានអាយុក៏ចាត់ជា **សមាធិវិប្ផារឥទ្ធិ** ។

ចំណែកព្រះខានុកោណ្ឌញ្ញត្ថេរនោះ ច្រើនទៅដោយសមាបត្តិជាធម្មតា ក្នុងពេលយប់មួយព្រះថេរៈគង់ចូលសមាបត្តិនៅក្នុងជងព្រៃគ្រានោះ ពួកចោរទាំងឡាយ ៥០០ នាក់ ត្រាច់ធ្វើចោរកម្ម បានទ្រព្យជាច្រើន ចោរទាំងឡាយមានសេចក្តីប្រាថ្នាឈប់សម្រាកក្នុងទីនោះ ដោយសម្គាល់ថា គ្មាននរណាតាមមកទាន់ឡើយ ។ កាលដាក់បង្វេចទ្រព្យដែលខ្លួនស្ពាយលីសែងមកនោះ ចោរទាំងឡាយសម្គាល់ព្រះមហាថេរៈថាជាជង្គត់ឈើ ទើបដាក់បង្វេចទ្រព្យលើព្រះសិរសារបស់ព្រះមហាថេរៈទាំង ៥០០ នាក់ ។កាលចោរទាំងឡាយបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយ អស់ការនឿយហត់ហើយ កាន់យកទ្រព្យដែលខ្លួនដាក់ទុកលើព្រះសិរសារបស់ព្រះមហាថេរៈ ក៏ដល់ពេលកំណត់ដែលព្រះថេរៈចេញអំពីឈានសមាបត្តិ ។ ចោរទាំងឡាយក៏បានឃើញកិរិយាអាការរបស់ព្រះមហាថេរៈនោះ ម្នាក់ៗ ក៏រន្ធត់ចិត្តស្រែកជ្រួលច្របល់ ។ ទើបព្រះមហាថេរៈមានថេរវាចាថា នែឧបាសកទាំងឡាយ

អ្នកកុំភ័យខ្លាចអ្វីឡើយ អាត្មាជាភិក្ខុសាវ័ករបស់ព្រះពុទ្ធទេ ចោរទាំងឡាយបានស្តាប់ព្រះថេរវាចាដូច្នោះ ក៏វិលត្រឡប់មកថ្វាយបង្គំព្រះ-មហាថេរៈដោយសេចក្តីគោរព សូមខមាទោសរួចហើយ សូមបព្វជ្ជាក្នុងសម្នាក់ព្រះមហាថេរៈទាំង ៥០០ នាក់ ។ លុះបានបព្វជ្ជារួចហើយក៏ប្រឹងប្រែងបំពេញនូវសមណធម៌ បានសម្រេចជាព្រះអរហន្ត មួយអន្លើដោយបដិសម្ភិទាគ្រប់ទាំង ៥០០ រូប ។ វីភាវៈរបស់ចោរទាំងឡាយដែលដាក់បង្វេចទ្រព្យសង្កត់លើព្រះសិរសា របស់ព្រះមហាថេរៈនោះមិនបានកើតទុក្ខវេទនាបៀតបៀន ចាត់ជា **សមាធិវិប្ផារឥទ្ធិ** ។

ចំណែកនាងឧត្តរាឧបាសិកា ជាធីតាបុណ្ណសេដ្ឋីនោះ នាងនគរសោភិនីម្នាក់ឈ្មោះថា **នាងសិរិមា** មានចិត្តប្រណែនគ្របសង្កត់ដួសយកខ្លាញ់ដ៏ក្តៅហុយទ្រលោម ដែលនៅក្នុងខ្ទះដោយវែកចាក់ស្រោចទៅលើក្បាលនាងឧត្តរានោះ **ឥស្សាខណោ** ក្នុងខណៈនោះ នាងឧត្តរាឧបាសិកាក៏ផ្សាយនូវមេត្តាចិត្ត ប្រេងដ៏ក្តៅហុយទ្រលោមនោះ ក៏ហូរអំពីក្បាលហាក់បីដូចជាតំណក់ទឹកដ៏តិច ផ្ងាតធ្លាក់ចុះអំពីស្លឹកឈូក និងមិនបានក្តៅរលាកអ្វីឡើយ ឥទ្ធិយ៉ាងនេះឈ្មោះថា **សមាធិវិប្ផារឥទ្ធិ**

ចំណែកនាងសាមាវតី ព្រះនាងជាអគ្គមហេសីរបស់ព្រះបាទ

ឧទេននោះ កាលមាគន្ទិយព្រាហ្មណ៍ប្រាថ្នា នឹងឲ្យធីតារបស់ខ្លួនបាន ជាមហេសីរបស់ព្រះបាទឧទេនដែរនោះ ទើបញុំាងនាងមាគន្ទិយធីតា របស់ខ្លួនឲ្យចាប់អាសិរពិសមកដកចង្កូមចេញ ហើយដាក់ទុកក្នុងពិណា របស់ព្រះបាទឧទេន រួចហើយក្រាបទូលថា ឥឡូវនេះ នាងសាមាវតី ប្រាថ្នានឹងសម្លាប់ព្រះអង្គ ចាប់អាសិរពិសក្នុងពិណា ព្រះបាទឧទេន ទតឃើញច្បាស់នឹងព្រះនេត្រ ដូច្នេះ មិនបានពិចារណា ខឹងក្រោធ នាងសាមាវតី ។ ទើបព្រះអង្គទាញយកសរលាបដោយថ្នាំពិស ប្រាថ្នា ដើម្បីនឹងបាញ់នាងសាមាវតី មួយអន្លើដោយបរិវារ ៥០០ នាក់ឲ្យ ស្លាប់ នាងក៏ផ្សាយនូវមេត្តាចិត្តចំពោះព្រះបាទឧទេននៅក្នុងគ្រានោះ ព្រះរាជាមិនអាចនឹងយឺតធ្នូបាញ់ព្រះនាងសាមាវតីបាន ព្រះអង្គទ្រង់ ប្រថាប់ឈរយឺតធ្នូបាញ់ព្រួញមិនចេញ សំកាំងដៃនៅទីនោះ ដរាប លំបាកព្រះកាយ ភ័យញាប់ញ័រស្រឡាំងកាំង លំបាកទ្រាំនូវទុក្ខ-វេទនា ។ ព្រះនាងសាមាវតីក៏អនុញ្ញាតឲ្យដាក់ធ្នូចុះ ក្នុងខណៈនោះ ទើបសររបូតអំពីព្រះហស្ត ធ្លាក់ជិតព្រះបាទមូលរបស់ព្រះបាទឧទេន លំដាប់នោះ ទើបព្រះនាងសាមាវតីឲ្យឱវាទថា បពិត្រព្រះអង្គទ្រង់ជា ព្រះមហាក្សត្រដ៏ប្រសើរ បុគ្គលណាមិនបានគិតប្រទូស្តចំពោះព្រះអង្គៗ

កុំប្រទូស្តបុគ្គលនោះ ។ ព្រះបាទឧទេន មិនអាចដើម្បីនឹងលែងសរចេញទៅបាននោះ ចាត់ជា **សមាធិវិប្ផារាឥទ្ធិ** ដោយប្រការដូច្នេះ ។

ប្រការមួយទៀតថា សភាវៈមានសញ្ញាមិនគួរស្អប់ខ្ពើមជាដើមក្នុងវត្ថុទាំងឡាយ ដែលជាបដិកូល គួរខ្ពើមជាដើម ព្រះសម្ពុទ្ធត្រាស់ហៅថា **អរិយាឥទ្ធិ** ព្រោះថា បដិក្កូលសញ្ញាយ៉ាងនេះ កើតមានចំពោះតែព្រះអរិយៈទាំងឡាយ ដែលសម្រេចនូវ **វសិតា** គឺជំនាញក្នុងសមាធិចិត្ត លោកមិនបានខ្ពើមក្នុងបដិក្កូលដែលគួរខ្ពើម ។

ប្រការមួយទៀត បក្សាទាំងឡាយ មិនបានរៀនវិបស្សនាក៏ហើរទៅក្នុងអាកាសតាមវិស័យរបស់ខ្លួនក្តី ពួកទេវតាទាំងឡាយក្តីមនុស្សទាំងឡាយខ្លះ ដែលកើតក្នុងបឋមកប្បក្តី ក៏ហោះហើរក្នុងអាកាសបាន ពួកអសុរកាយទាំងឡាយខ្លះជាដើម គឺបិយង្ករមាតាយក្ខិនីឧត្តរាមាតាយក្ខិនី ស្រីអសុរកាយដែលឈ្មោះថា **ផុស្សមិត្តា** និងធម្មគុត្តាទាំងឡាយ ក៏ហោះទៅក្នុងអាកាស ចាត់ជាកម្មវិបាកជាឥទ្ធិទាំងអស់ ។

មួយទៀត កម្មវិបាកជាឥទ្ធិនោះមានច្រើនប្រការ ប្រសិនបើជានាគរាជក៏ហៅថា **នាគិទ្ធិ** ជាគ្រុឌក៏ហៅថា **សុបណ្ណិទ្ធិ** ជាយក្ខក៏ហៅថា

**យក្ខិទ្ធិ** ជាទេវតាក៏ហៅថា **ទេវិទ្ធិ** ជាស្តេចក៏ហៅថា **រាជិទ្ធិ** គឺជាឫទ្ធិរបស់នាគ គ្រុឌ យក្ខ ទេវតា និងព្រះរាជាទាំងឡាយ ។ នាគមួយពួកឈ្មោះថា ទិដ្ឋទដ្ឋផុដ្ឋ បានឃើញ បានខិប បានពាល់ត្រូវ នូវសត្វទាំងឡាយដទៃ ក៏អាចបៀតបៀន គឺធ្វើឲ្យស្លាប់បាន ឫទ្ធិយ៉ាងនេះឈ្មោះថា **នាគិទ្ធិ** ។ គ្រុឌពួកខ្លះក៏មានកម្លាំងអាចចាប់នាគរាជដ៏ធំវែងប្រមាណ ១៣០ ព្យាម ទាញឡើងអំពីមហាសមុទ្របាន យ៉ាងនេះក៏ចាត់ជាសុបណ្ណិទ្ធិ ជាឫទ្ធិរបស់ស្តេចគ្រុឌ ។ពួកយក្ខទាំងឡាយកាលបើមកមិនបានប្រាកដ កាលប្រហារក៏មិនបានប្រាកដ កាលសត្វទាំងឡាយត្រូវប្រហារដោយយក្ខទាំងឡាយនោះ ក៏ធ្វើនូវកាលកិរិយាស្លាប់ក្នុងទីនោះ យ៉ាងនេះក៏ជាឫទ្ធិរបស់យក្ខ ។

ទេវឫទ្ធិ គឺឫទ្ធិរបស់ទេវតាទាំងឡាយនោះ អ្នកប្រាជ្ញគប្បីជ្រាបក្នុងកាលធ្វើកាលកិរិយារបស់កុម្ភណ្ឌទាំងឡាយ ដោយគទាវុធ គឺដំបងរបស់ស្តេចវេស្សវណ្ណ ដែលលែងទៅដោយសេចក្តីក្រោធ ក្នុងកាលដែលនៅមិនទាន់បានជាព្រះសោតានោះក្តី និងការសម្លាប់ដោយអានុភាពឫទ្ធិរបស់ទេវតាទាំងឡាយដទៃ ដែលមានសក្តិធំ មានអានុភាពច្រើនក្តី ឈ្មោះថា **ទេវឫទ្ធិ** ។

រាជឫទ្ធិនោះ អ្នកប្រាជ្ញគប្បីជ្រាបក្នុងកិរិយាដែលប្រព្រឹត្តរបស់ស្តេចសិរីធម្មាសោកនោះ ក្នុងប្រទេសធំប្រមាណមួយយោជន៍ និងផ្ទៃអាកាសប្រមាណមួយយោជន៍ស្មើគ្នា ។ រីឫទ្ធិទាំងឡាយជាដើម គឺហោះទៅក្នុងអាកាសរបស់ស្តេចចក្រពត្តិទាំងឡាយជាដើមនោះ ឈ្មោះថា បុញ្ញវតោឥទ្ធិ គឺសម្រេចដោយអំណាចទ្រទ្រង់បុញ្ញានុភាពច្រើន ។

មួយទៀត សេដ្ឋី៤នាក់ ដែលមានបុណ្យច្រើន គឺជោតិកសេដ្ឋី ជដិលសេដ្ឋី ឃោសកសេដ្ឋី មេណ្ឌកសេដ្ឋី ។ សេដ្ឋីទាំង ៤ នាក់ក៏ចាត់ជាបុញ្ញវតោឥទ្ធិទាំងអស់ ។ បើនឹងពោលដោយសង្ខេបក្នុងកាលបុណ្យបារមីរបស់លោកទាំងឡាយនោះបានអប់រំចាស់ក្លាហើយ គុណវិសេសផ្សេងៗ នោះ ក៏សម្រេចគ្រប់ប្រការ យ៉ាងនេះឯងឈ្មោះថា **បុញ្ញវតោឥទ្ធិ** ប្រាង្គប្រាសាទកែវទាំងឡាយទម្លាយចេញអំពីផែនដីដុះឡើងមកដោយល្អ ឯដើមកប្បព្រឹក្ស ១៦ ដើម ក៏ដុះឡើងដោយល្អចំពោះជោតិកសេដ្ឋី គុណានិសង្សយ៉ាងនេះចាត់ជាបុញ្ញវតោឥទ្ធិ គឺសម្រេចដោយបុណ្យ ។ភ្នំមាសកម្ពស់ ៨០ ហត្ថ កើតចំពោះជដិលសេដ្ឋីក៏ឈ្មោះថា **បុញ្ញវតោឥទ្ធិ** ។ ឃោសកសេដ្ឋីកាលនៅជាកុមារ ជនទាំងឡាយព្យាយាមសម្លាប់ក្នុងទីទាំងឡាយអស់វារៈ ៧ ដង ក៏មិន

មានអន្តរាយដល់ជីវិត យ៉ាងនេះក៏ឈ្មោះថា **បុញ្ញវតោឥទ្ធិ** ។ វិសេសភាពពពែទាំងឡាយដែលសម្រេចទៅដោយកែវ ៧ ប្រការ កើតប្រាកដដល់មេណ្ឌកសេដ្ឋីខាងក្រោយផ្ទះ ប្រមាណមួយករីសនោះ គឺ ៧ សិន ( ១ សិន =២០ ព្យាម ) ក៏ជា **បុញ្ញវតោឥទ្ធិ** ។

ជនទាំង ៥ នាក់ គឺមេណ្ឌកសេដ្ឋី ១ នាងចន្ទបទុមាដែលជាភរិយា ១ ធនញ្ជយសេដ្ឋីដែលជាបុត្រ ១ នាងសុមនាដែលជាកូនប្រសាស្រី ១ និងនាយបុណ្ណជាទាសៈ ១ សុទ្ធតែជាមនុស្សមានបុណ្យច្រើន ។

ក្នុងកាលដែលមេណ្ឌកសេដ្ឋី មុជទឹកកក់សក់ជម្រះខ្លួនរួចហើយសម្លឹងមើលអាកាស គ្រានោះ ជង្រុកស្រូវទាំង ២៥០០ ពេញប្រៀបទៅដោយស្រូវសាលី ដែលជាធារស្រូវហូរចុះមកអំពីអាកាស ។ ឯនាងចន្ទបទុមា ដែលជាភរិយាចាត់ចែងបាយចំនួនអង្ករប្រមាណមួយនាឡិឲ្យដល់មនុស្សក្នុងជម្ពូទ្វីប ក៏មិនចេះអស់បាយដែរ ធនញ្ជយសេដ្ឋីដែលជាបុត្រកាន់ថង់ទ្រព្យ ១០០០ ចែកឲ្យដល់មនុស្សក្នុងសកលជម្ពូទ្វីប ក៏មិនចេះអស់ប្រាក់ នាងសុមនាដែលជាកូនប្រសាស្រីដាក់គ្រាប់ពូជក្នុងល្អី ឲ្យមនុស្សទាំងឡាយអស់ទាំងជម្ពូទ្វីប គ្រាប់ពូជក្នុងល្អីនោះ

ក៏មិនអស់ឡើយ នាយបុណ្ណៈដែលជាទាសៈ ភ្ជួរស្រែតែមួយគន្លង អាចម៍ដីបំណះបែកចេញជា ១៤គន្លង គុណានិសង្សកើតសម្រេចដល់លោកទាំង ៥ នាក់ ឈ្មោះថា **បុញ្ញវតោឥទ្ធិ** ។

ឫទ្ធិទាំងឡាយ មានការហោះទៅឯវេហាស៍អាកាសរបស់មនុស្សទាំងឡាយជាដើម គឺវិជ្ជាធរនោះ ឈ្មោះថា **វិជ្ជាមយាឥទ្ធិ** ព្រោះសម្រេចហើយទៅដោយវិជ្ជាការចេះដឹងរបស់ខ្លួន ។

**វិជ្ជាធរា វិជ្ជហិត្វា** មនុស្សទាំងឡាយដែលទ្រទ្រង់នូវវិជ្ជានោះ ធ្វើបរិកម្មរាយមន្តរួចហើយ ក៏ហោះទៅឯវេហាស៍អាកាស មិនមែនតែប៉ុណ្ណោះទេ សូម្បីនិម្មិតនូវពលដំរី ពលសេះជាដើម និងក្បួនទ័ពមានប្រការផ្សេងៗ ឲ្យដេរដាសជាអនេកប្បការ និងប្រមាណមិនបាន ។ មួយទៀត សិល្ប៍សាស្ត្រផ្សេងៗ គឺត្រៃវេទ និងព្រះត្រៃបិដក ដោយហោការសាបព្រោះស្រូវក្នុងស្រែ និងកិច្ចការទាំងឡាយនោះ កើតមានដោយអំណាចធ្វើជាព្យុហៈនេះ មានសកដព្យុហៈជាដើម ឫទ្ធិយ៉ាងនេះឈ្មោះថា **វិជ្ជាមយាឥទ្ធិ** ។ បណ្ដាឥទ្ធិទាំង ១០ ប្រការដែលសម្ដែងមកនេះ ព្រះយោគាវចរ គឺកុលបុត្រទាំងឡាយណា បាននូវចតុត្ថជ្ឈានទោះ លោកតែងប្រើប្រាស់ឥទ្ធិ ៣ គឺអធិដ្ឋានឥទ្ធិ ១

វិកុព្វនាឥទ្ធិ ១ មនោមយាឥទ្ធិ ១ ។

មានពាក្យអះអាងថា លោកអ្នកមានឥទ្ធិវិធីនោះ ប្រាថ្នាដើម្បីនឹងដើរចង្រ្កមក្នុងទីជិតនៃពហុជនក្តី ប្រាថ្នាដើម្បីនឹងសួរបញ្ហាក្តី ដើម្បីស្វាធ្យាយព្រះធម៌ក្តី និងធ្វើឲ្យច្រើនដល់រយ ដល់ពាន់ ម៉ឺនសែនក្តី ក៏ធ្វើបានដូចសេចក្តីប្រាថ្នា សួរថា ធ្វើដូចម្តេច ឆ្លើយថា លោកចូលកាន់ចតុត្ថជ្ឈាន ចេញចាកចតុត្ថជ្ឈាន បើប្រាថ្នាដើម្បីនឹងធ្វើឲ្យបាន ១០០ ក៏បរិកម្មថា **សតំ ហោតិ** ឥឡូវនេះ អាត្មាអញកើតបាន ១០០ នាក់ ហើយត្រឡប់ចូលកាន់ចតុត្ថជ្ឈាន ដែលជាទីតាំងរបស់អភិញ្ញាម្តងទៀត លុះចេញចាកអំពីចតុត្ថជ្ឈានហើយ ធ្វើអធិដ្ឋាន រីរូប ១០០ នាក់ ក៏កើតមានព្រមគ្នានឹងអធិដ្ឋានចិត្ត នឹងធ្វើជាពាន់នាក់ ម៉ឺននាក់ សែននាក់ ក៏បានដូចគ្នា ។ បើធ្វើដូច្នេះនៅមិនទាន់បានសម្រេច ធ្វើបរិកម្មម្តងទៀត ចូលកាន់ឈានជាគម្រប់ ២ ដង ចេញចាកឈានហើយ ទើបធ្វើអធិដ្ឋាន រីបរិកម្មចិត្ត និងអធិដ្ឋានចិត្ត ក៏មានមួយរយមួយពាន់ មួយម៉ឺនសែនជាអារម្មណ៍ រូបនិម្មិតទាំងឡាយ ក៏សម្រេចដូចលោកអ្នកទ្រទ្រង់នូវឫទ្ធិ ។

ម្យ៉ាងទៀត ការប្រាថ្នានឹងធ្វើនូវអាកប្បកិរិយាផ្សេងៗ ឲ្យ

ប្រាកដឡើង គឺកិរិយាអង្គុយជាដើមក្តី កិរិយានិយាយស្តីក្តី កិរិយានៅស្ងៀមជាដើមក្តី លោកអ្នកមានឫទ្ធិក៏ធ្វើឲ្យសម្រេចគ្រប់ប្រការ ឲ្យរូបនិម្មិតនោះកើតប្រាកដដូចសេចក្តីប្រាថ្នា ។

**សចេ បន នានាវណ្ណកតុកា ហោតិ** មួយទៀត ប្រសិនបើប្រាថ្នាដើម្បីនឹងធ្វើនូវភេទផ្សេងៗ គឺបឋមវ័យ មជ្ឈិមវ័យ បច្ឆិមវ័យ ភេទទុកសក់វែង ភេទកោរតែពាក់កណ្តាល ភេទគ្រងនូវចីវរដែលជ្រលក់ទឹកមូត់មួយផ្ទាំងក្តី ភេទគ្រងចីវរពណ៌លឿងនោះក្តី ពោលឬសូធ្យសម្តែងព្រះធម៌ក្តី ចោទសួរដោះប្រស្នាក្តី ជាភិក្ខុកំពុងជ្រលក់ចីវរក្តី កំពុងដេរចីវរក្តី ក៏ធ្វើបានគ្រប់ប្រការ តាមសេចក្តីប្រាថ្នា លោកអ្នកទ្រទ្រង់នូវឫទ្ធិនោះចេញចាកអំពីចតុត្ថជ្ឈាន ធ្វើបរិកម្មដោយន័យដូច្នេះថា ភិក្ខុទាំងឡាយប្រមាណប៉ុណ្ណោះៗ ចូរកើតជាបឋមវ័យទាំងអស់ ចូលឈានម្តងទៀត ចេញចាកអំពីឈានធ្វើអធិដ្ឋានដូច្នោះ វិប្រការទាំងឡាយដែលខ្ញុំនប្រាថ្នា ក៏បានសម្រេចដូចបំណងព្រមគ្នានឹងអធិដ្ឋានចិត្ត ។ ភិក្ខុទាំងឡាយជាច្រើនរូបក៏កើតមានប្រាកដ

**ឃរំ ពហុភាវំ និមិត្វា** ធ្វើនូវនិមិត្តឲ្យច្រើនដោយប្រការដូច្នេះហើយក្តី និងធ្វើនូវនិមិត្តឲ្យនៅតែម្នាក់ឯងក្តី ប្រាកដដល់មនុស្សទាំងឡាយដោយ

ភាពជាអ្នកប្រាថ្នាតិច ថាយើងតែម្នាក់ដើរចង្ក្រម ធ្វើការស្វាធ្យាយ ដោះស្រាយបញ្ហាកម្ម ។ កាលប្រាថ្នានឹងឲ្យកើតប្រាកដតែម្នាក់ឯងនោះ ចូលកាន់ចតុត្ថជ្ឈានដែលជាទីតាំងនៃឫទ្ធិ ចេញចាកអំពីឈានហើយ ធ្វើបរិកម្មថា **ឯកោ ហោតិ** អាត្មាអញចូរប្រាកដក្នុងកាលឥឡូវនេះ រួចហើយចូលកាន់ចតុត្ថជ្ឈានសាជាថ្មី ចេញអំពីឈានដោយអធិដ្ឋាន ថា **ឯកោ ហោមិ** កាលបើដូច្នេះ ក៏សម្រេចឥទ្ធិដែលកើតប្រាកដតែម្នាក់ឯង ព្រមគ្នានឹងអធិដ្ឋាន មិនមែនតែប៉ុណ្ណោះ សូម្បីការប្រាថ្នាធ្វើឲ្យងងឹត ឲ្យភ្លឺក្តី ទីកំបាំងឲ្យឃើញច្បាស់ក្តី ទីឆ្ងាយឲ្យដូចជាទីជិតក្តី ក៏ធ្វើបានគ្រប់ប្រការ ។

**កដំ** តើធ្វើដូចម្តេច ? ឆ្លើយថា ការពិត លោកអ្នកដែលទ្រទ្រង់នូវឫទ្ធិវិធីនេះ សូម្បីស្ថិតនៅទីកំបាំងក្តី នៅទីឆ្ងាយរាប់យោជន៍ក្តី ប្រាថ្នាឲ្យឃើញប្រាកដយ៉ាងណា ក៏ធ្វើនូវខ្លួនឲ្យប្រាកដយ៉ាងនោះ ។ កាលបើលោកចេញអំពីឈាន ធ្វើអាវជ្ជនៈពិចារណាថា ឥឡូវនេះ ទីងងឹតនេះចូរឲ្យភ្លឺ ទីកំបាំងចូរឲ្យស្រឡះ ទីឆ្ងាយរាប់យោជន៍នោះចូរឲ្យជិត ឲ្យមើលឃើញប្រាកដ ទើបធ្វើបរិកម្មាដូច្នោះ ហើយចូលកាន់ឈាន ចេញអំពីឈាន ធ្វើអធិដ្ឋានដោយន័យ ដូចពោលមក

នោះ រីហេតុគួរដល់អធិដ្ឋានក៏ប្រាកដមាន ក្នុងខណៈធ្វើអធិដ្ឋានចិត្តនោះ បុគ្គលដទៃទាំងឡាយនៅឆ្ងាយ ក៏មើលឃើញលោកអ្នកទ្រទ្រង់ឥទ្ធិវិធី ។ លោកអ្នកទ្រទ្រង់នូវឥទ្ធិវិធីនោះ ក៏មើលឃើញនូវបុគ្គលដទៃៗ ទាំងឡាយ **ឃតំ បន ចាដិហារិយំ** រីបាដិហារ្យដូច្នោះ បុគ្គលដូចម្ដេចបានធ្វើពីមុនមកខ្លះ បាដិហារ្យយ៉ាងនេះ ព្រះពុទ្ធធ្វើមកអំពីមុន ។

មានពាក្យអធិប្បាយថា **ចូឡសុភទ្ទាយ និមន្តិតោ** កាលនាងចូឡសុភទ្ទានិមន្តព្រះពុទ្ធ ទ្រង់ពុទ្ធដំណើរទៅកាន់ក្រុងសាកេត ។ ក្រុងសាវត្ថីទៅកាន់ក្រុងសាកេតមានចម្ងាយ ៨ យោជន៍ ព្រះអង្គគង់ប្រថាប់លើបុស្បកទិព្វទាំង ៥០០ ដែលវិស្សកម្មទេវបុត្រនិម្មិតថ្វាយមួយអន្លើដោយសាវកទាំងឡាយជាបរិវារ ទ្រង់អណ្ដែតទៅដូចស្ដេចហង្សមាសហោះទៅក្នុងនភាល័យ អ្នកក្រុងសាកេតមើលឃើញយ៉ាងណា ព្រះពុទ្ធក៏ធ្វើអធិដ្ឋានចិត្តដូច្នោះ ។ ម្យ៉ាងទៀត ព្រះអង្គបើកមហាប្រឹថពី ឲ្យឃើញរហូតដល់អវិចីមហានរកក្ដី បើកអាកាសខាងលើឲ្យភ្លឺឡើង រហូតដល់ព្រហ្មលោកក្ដី ហើយទើងសម្ដែងនូវបាដិហារ្យបើកលោកទាំងឡាយឲ្យឃើញនូវគ្នានិងគ្នា ក៏បានសម្រេចគ្រប់ប្រការ ។ សេចក្ដីនេះអ្នកប្រាជ្ញគប្បីជ្រាបដោយន័យ កាលដែលព្រះ

អង្គចុះមកអំពីស្ថានតាវត្តិង្ស កាលស្ដេចឡើងទៅសម្ដែងព្រះ-អភិធម្ម ៧ គម្ពីរ ប្រោសពុទ្ធមាតា ។

**អបិច តម្ពបណ្ណិទីបេ ឆគរវាសី ធម្មទិន្នត្ថេរោ** មួយទៀត ព្រះធម្មទិន្នត្ថេរមានប្រក្រតីនៅក្នុងព្រះនគរអនុរាធបុរី ក្នុងលង្កាទ្វីប ។ ថ្ងៃមួយ លោកទៅគង់ទីលានព្រះចេតិយ នៅនាមហាតិស្សវិហារ ។ កាលនឹងសម្ដែងនូវអបណ្ណកសូត្រនោះ ធ្វើផ្ចិតវាល-វីជនីឲ្យមុខសំយុងចុះក្រោម ខណៈនោះ ខាងក្រោមរហូតទៅដល់អវីចីនរក ខាងលើរហូតដល់ព្រហ្មលោក ប្រាកដភ្លឺតែម្យ៉ាង ។ ព្រះថេរៈញាំងជនទាំងឡាយដែលមើលឃើញនរកនោះឲ្យភ័យខ្លាច ជនទាំងឡាយដែលមើលឃើញស្ថានសួគ៌នោះឲ្យរីករាយ ។ ព្រះថេរៈគំរាមដោយភ័យក្នុងនរក ធ្វើការលួងលោមដោយទិព្វសម្បត្តិក្នុងស្ថានសួគ៌ ដូច្នោះ ទើបសម្ដែងព្រះធម៌ទេសនា **កេចិ សោតាបន្នា** ជនពួកខ្លះ បានសម្រេចព្រះសោតា ជនពួកខ្លះបានសម្រេចព្រះសកទាគាមី ជនពួកខ្លះបានសម្រេចព្រះអនាគាមី ជនពួកខ្លះបានសម្រេចព្រះអរហន្ត បាដិហារ្យយ៉ាងនេះ គប្បីធ្វើងងឹតឲ្យភ្លឺ ទីឆាយឲ្យជិត រហូតមើលឃើញ ។

មួយទៀតសោត ប្រាថ្នានឹងធ្វើទីភ្លឺឲ្យងងឹត ទីវាលនោះ ឲ្យបិទបាំង មិនឲ្យឃើញប្រាកដក៏ធ្វើបានគ្រប់យ៉ាង ។ បាដិហារ្យយ៉ាងនេះ បុគ្គលណាធ្វើមុនគេ គឺព្រះពុទ្ធធ្វើមុនគេ **យសកុលបុត្តំ សមិបេ និសិន្នំ យេវ** ការពិត បិតារបស់យសកុលបុត្រ មិនបានមើលឃើញយស-កុលបុត្រដែលអង្គុយនៅទីជិត យ៉ាងណា ព្រះពុទ្ធក៏ធ្វើនូវបាដិហារ្យដូច្នោះ ។

មួយទៀត ព្រះមហាក្សត្រព្រះនាមទេវានម្បិយតិស្សៈ ថ្ងៃដែលព្រះមហិន្ទត្ថេរចេញទៅកាន់លង្កា ព្រមដោយព្រះអរហន្តទាំងឡាយជាសព្រហ្មចារី ព្រះអង្គទតឃើញព្រះមហិន្ទត្ថេរតែមួយរូប មិនបានឃើញព្រះមហាថេរៈទាំងឡាយដទៃ យ៉ាងណា បាដិហារ្យយ៉ាងនេះ ព្រះមហិន្ទត្ថេរធ្វើមកអំពីមុន ដូច្នោះ ក្នុងថ្ងៃដែលព្រះថេរៈចូលដល់លង្កាទ្វីប បាដិហារ្យដែលប្រាកដនោះជា ***អាវិភាវនាបាដិហារិយ*** ។ បាដិហារ្យមិនបានប្រាកដឈ្មោះនោះ ឈ្មោះថា ***តិរោភាវបាដិហារិយ*** ។ ឥទ្ធិក្តី លោកអ្នកមានឥទ្ធិក្តី កើតប្រាកដតែក្នុងបាដិហារ្យដែលប្រាកដ ។ម្យ៉ាងទៀត អំពីឥទ្ធិតែមួយប្រាកដក្នុងបាដិហារ្យដែលមិនបានប្រាកដ និងលោកអ្នកមានឫទ្ធិនោះ មិនបានកើតប្រាកដក្នុង

បាដិហារ្យដែលមិនប្រាកដឡើយ មិនតែប៉ុណ្ណោះ ទោះបីទៅក្នុងភ្នំ កំពែង និងវង់ ក៏មិនបានទើសទាក់ អាចទៅបានដោយស្រួល ដូចទៅក្នុងអាកាសដូច្នោះ មិនទើសទាក់អ្វីឡើយ ។ កាលបើលោកប្រាថ្នានឹងទៅនោះ ធ្វើអាវជ្ជនៈពិចារណានូវជញ្ជាំង កំពែង ភ្នំចក្កវាឡ និងភ្នំសិនេរុទាំងឡាយ ទីបំផុតសូម្បីត្រឹមតែវត្ថុណាមួយ ហើយធ្វើបរិកម្មអធិដ្ឋានឲ្យជញ្ជាំងកំពែង និងភ្នំទាំងឡាយនោះឲ្យជាអាកាស ក៏ជាអាកាសដោយពិត ប្រាថ្នានឹងមុជចុះខាងក្រោមក្តី ប្រាថ្នានឹងឡើងទៅខាងលើក្តី ក៏ធ្វើអធិដ្ឋានឲ្យភ្នំនោះឲ្យជាចន្លោះ ជាលម្ហ ក៏ទៅតាមន្លោះលម្ហទាំងឡាយនោះ មិនបានទើសទាក់ដោយជញ្ជាំង ភ្នំ កំពែងនោះទេ **សចេ គច្ឆន្តស្ស** កាលហោះអណ្តែតទៅនោះ បើឃើញភ្នំទាំងឡាយជាដើម ដែលលោកអ្នកមានឫទ្ធិមួយរូបទៀតនិម្មិតឡើងវាងពាក់កណ្តាលផ្លូវ ក៏គប្បីហោះទៅបានអំពីខាងលើ ឬខាងក្រោម ព្រោះថា កម្លាំងអធិដ្ឋានមុន មានកម្លាំងដោយវិសេស ។ មិនមែនតែប៉ុណ្ណោះទេ សូម្បីមុជចុះទៅក្នុងផែនដី ងើបឡើងអំពីផែនដីក៏បាន គប្បីកំណត់ជាមុន ធ្វើបរិកម្មអធិដ្ឋាន ធ្វើផែនដីឲ្យជាអាកាសហើយផុសឡើងក៏បាន មុជចុះក៏បាន **សោ តត្ថ** លោកអ្នកមានឫទ្ធិនោះ

ក៏ងើបឡើង និងមុជចុះទៅក្នុងផែនដី មិនមែនតែប៉ុណ្ណោះទេ នឹងធ្វើផែនដីឲ្យទៅជាទឹក សម្រាប់លាងជម្រះវត្ថុនានា ក៏អាចធ្វើបានគ្រប់យ៉ាង ។ **ឆ កោវលញ្ច ឧទកំ ឃរំ** មិនមែនត្រឹមតែធ្វើផែនដីឲ្យជាទឹកប៉ុណ្ណោះទេ សូម្បីជាខ្លាញ់ ជាទឹកឃ្មុំ ជាទឹកអំពៅ មានរសផ្អែមក៏ធ្វើបានគ្រប់យ៉ាង កំណត់បរិកម្មអធិដ្ឋានជាមុន ហើយផែនដីក៏ប្រព្រឹត្តទៅគ្រប់ប្រការដូចអធិដ្ឋាននោះ ។ បើជាសប្បិ ក៏ជាសប្បិ បើជាខ្លាញ់ ក៏ជាខ្លាញ់ បើជាប្រេង ក៏ជាប្រេង បើជាទឹកអំពៅ ក៏ជាទឹកអំពៅ បើជាអូរ ឬស្ទឹង ក៏ជាអូរ ឬស្ទឹង ។

មួយទៀត ប្រាថ្នានឹងឲ្យកាយទទឹក ក៏ទទឹក ឬមិនបានប្រាថ្នាឲ្យកាយទទឹក ក៏មិនទទឹក ។ ផែនដីនោះក៏ជាទឹកប្រាកដដល់អ្នកធ្វើនូវឫទ្ធិតែម្នាក់ ។ ប៉ុន្តែជនទាំងឡាយដ៏សេសនោះ **បឋវី** ក៏ជាដីពិត មនុស្សទាំងឡាយក៏ដើរទៅលើផែនដី ដោយជើងទាំងឡាយរបស់ខ្លួន សូម្បីនឹងទៅដោយពលពាហនៈទាំងឡាយជាដើម ក៏ទៅដោយធម្មតា **សចេ បនាយំ តេសំបិ ឧទកំ ហោតិ** បើលោកអ្នកមានឫទ្ធីប្រាថ្នាធ្វើផែនដីឲ្យកើតជាទឹក ចំពោះមនុស្សទាំងឡាយដ៏វិសេសក្តី ក៏ធ្វើបានដោយពិត **បរិច្ឆិន្នកាលំ បន អតិក្កមិត្វា** លុះកន្លងកាល

កំណត់អធិដ្ឋានហើយ ទឹកដែលកំណត់នោះក៏ជាផែនដីដូចដើម វៀរលែងតែទឹកដែលនៅកាជនៈតូចធំ និងទឹកស្រះទាំងឡាយ ។ ក្នុងកាលដែលទឹកមិនបានរាវហើយ ក៏អាចដើរទៅបាន បើទឹកនោះរាវហើយ ដើរទៅលើទឹកនោះក៏លិចចុះ ទឹកដែលមិនរាវនោះជាទឹកវិបរិត គឺទឹកកើត ដោយអំណាចលោកអ្នកទ្រទ្រង់ឫទ្ធិធ្វើអធិដ្ឋាន ។ កាលបើលោកអ្នកមានឫទ្ធិប្រាថ្នានឹងដើរទៅលើទឹក លោកក៏ចូលបឋវីកសិណ-ជ្ឈាន ចេញអំពីឈានហើយ កំណត់អធិដ្ឋានថា ទឹកនេះ ចូរកើតជាដីចុះ គឺធ្វើទឹកឲ្យកើតជាដី ទឹកនោះក៏ត្រឡប់ក្លាយទៅជាដីព្រមគ្នានឹងអធិដ្ឋាន រួចហើយក៏ដើរទៅ ប្រាថ្នានឹងសម្រេចឥរិយាបថណា ក៏សម្រេចបទ្ធិដោយឥរិយាបថនោះគ្រប់ប្រការ ។ មិនមែនធ្វើឲ្យត្រឹមតែជាផែនដីតែម្យ៉ាងប៉ុណ្ណោះទេ **មណិ សុវណ្ណបព្វតរុក្ខាទីសុ** ប្រាថ្នានឹងធ្វើទឹកឲ្យកើតជាវត្ថុរបស់របរផ្សេងៗ ដូចជាកែវ មាស ប្រាក់ ភ្នំ ព្រឹក្សជាតិទាំងឡាយផ្សេងៗ ប្រការណា ធ្វើអាវជ្ជនៈបរិកម្មអធិដ្ឋាន ហើយក៏ប្រព្រឹត្តទៅបានដោយសមគួរដល់អធិដ្ឋាន ។ រីទឹកដែលធ្វើឲ្យកើតជាផែនដីនោះ ក៏ជាផែនដីចំពោះលោកអ្នកដែលទ្រទ្រង់ឫទ្ធិ ទឹកនោះក៏តាំងនៅជាទឹកដដែល ដោយប្រក្រតីដល់ជនទាំងឡាយដ៏សេស ។

ហ្វូងអណ្តើក ត្រីទាំងឡាយក្តី ក្អែកទឹកទាំងឡាយក្តី ក៏ចុះហែល ចុះមុជទៅតាមការពេញចិត្ត បើប្រាថ្នាធ្វើទឹកនោះឲ្យកើតជាដីដល់ហ្វូងសត្វទាំងឡាយនោះ ក៏អាចធ្វើបានដោយគួរដល់ពេលវេលាកំណត់លុះកន្លងកាលកំណត់ហើយ ក៏តាំងនៅជាទឹកដដែល **ឆ កោវលំឃត្តកំ ឃរ** មិនមែនធ្វើបានវត្ថុតែមួយទេ សូម្បីហោះទៅឰដ៏អាកាសទាំងបល្ល័ង្ក ប្រៀបដូចសត្វស្លាបដែលហើរទៅក្តី ក៏អាចអណ្តែតលឿនទៅបាន លោកអ្នកទ្រទ្រង់ឫទ្ធិប្រាថ្នាដូច្នោះ ក៏ចូលកាន់បឋវីកសិណជ្ឈាន ចេញចាកឈានហើយ ប្រាថ្នានឹងអង្គុយលើបល្ល័ង្កហើយក៏ហោះទៅ ធ្វើកំណត់នូវទីមានប្រមាណប៉ុនបល្ល័ង្កបរិកម្មអធិដ្ឋានដូចខាងដើម បើប្រាថ្នាដេកលើបល្ល័ង្កអណ្តែតទៅ ក៏អធិដ្ឋានទីប្រមាណប៉ុនគ្រែ ។ បើប្រាថ្នានឹងចង្រ្កមដោយជើងអណ្តែតទៅ ក៏ធ្វើអធិដ្ឋានទីប្រមាណប៉ុនផ្លូវដើរ ធ្វើការកំណត់ដោយសមគួរហើយ ក៏អធិដ្ឋានឲ្យកើតជាបឋវីធាតុ ទីត្រង់នោះក៏កើតជាដីព្រមគ្នានឹងអធិដ្ឋាន ។ ភិក្ខុដែលមានឫទ្ធិប្រាថ្នានឹងហោះទៅតាមអាកាស ព្រោះហេតុនោះ ក្នុងរវាងផ្លូវដែលហោះទៅនោះ កើតមានព្រឹក្សាជាតិ និងភ្នំទាំងឡាយជាដើម ដែលជាឧតុសមុដ្ឋាន កើតឯងតាមរដូវក្តី ឬនាគ គ្រុឌទាំង

ឡាយ មានសេចក្តីប្រណែន និម្មិតភ្នំ និងព្រឹក្សាជាតិដើមធំៗ ពាំង ពីមុខក្តីលោកដែលបានភ្នែកទិព្វនោះ កាលហោះទៅក៏មិនបានឃើញ

**តេ បន និស្វា** ទើបមានសំណួរថា បើឃើញភ្នំ និងដើមឈើធំៗ ពាំងពីមុខនោះ នឹងគប្បីធ្វើដូចម្តេច ?

ឆ្លើយថា បើឃើញវត្ថុណាមួយនៅពាំងអំពីមុខ ក៏គប្បីចូលឈាន ដែលជាទីតាំងរបស់ឫទ្ធិ ចេញចាកឈានហើយ ទើបធ្វើនូវអធិដ្ឋាន ឲ្យវត្ថុដែលនៅពាំងអំពីមុខនោះជាអាកាស ទើបហោះតទៅបាន ។

មួយទៀត ភិក្ខុដែលបានទិព្វចក្ខុនេះ កាលបើហោះទៅនោះ គ្រានឹងចុះ ក៏មានទីកន្លែងដើម្បីនឹងចុះ ។ អធិប្បាយថា ហេតុអ្វី ទើបមានទីកន្លែងនឹងចុះដូច្នោះ ព្រោះថា បើនឹងចុះនៅទីកំពង់ទឹកដែលជាកន្លែងប្រជុំជន កាលចុះហើយក៏នឹងប្រាកដដល់មហាជន គឺបានឃើញលោកហោះ **តស្មា** ព្រោះហេតុនោះ លោកដែលបាននូវទិព្វ-ចក្ខុ ហោះទៅក្នុងអាកាស ក្រឡេកឃើញអារម្មណ៍ទាំងពួង គឺពិចារណានូវទីដែលមិនគួរចុះ និងទីដែលគួរចុះ **ឥមេបិ ចន្ទិមសុរិយេ ឯវំ មហិទ្ធិកេ មហានុភាវេ** លោកអ្នកទ្រទ្រង់ឫទ្ធិនោះ សូម្បីស្ទាបអង្អែល កាន់យកនូវមណ្ឌលព្រះចន្ទ និងមណ្ឌលព្រះអាទិត្យដែលមាន

មហានុភាព ទ្រទ្រង់មហិទ្ធិឫទ្ធិប្រកបទៅដោយរស្មី ភ្លឺច្បាស់ទូទាំង លោកធាតុដូច្នេះ ដោយដៃរបស់ខ្លួនបានគ្រប់ប្រការ និងមិនបាន ខ្វាចក្រែងឡើយ ។ ឫទ្ធិយ៉ាងនេះក៏សម្រេចដោយអំណាចចតុត្ថ-ជ្ឈានដែលជាទីតាំងរបស់អភិញ្ញា ដែលមិនមាននិយាមកំណត់ កសិណសមាបត្តិក្នុងអភិញ្ញានោះឡើយ ប្រើកសិណបរិកម្ម ១ ក្នុង កសិណទាំង ១០ ។ **ឥច្ចតិ គន្ធ...។ បរាមសតិ** បើលោកអ្នក ទ្រទ្រង់ឫទ្ធិយ៉ាងនេះ ប្រាថ្នាហោះទៅឰដ៏អាកាស ចាប់យកព្រះចន្ទ និងព្រះអាទិត្យទាំងពីរ ក៏ហោះទៅចាប់យកបានដូចសេចក្តីប្រាថ្នា ។ បើប្រាថ្នាអង្គុយនៅក្នុងមនុស្សលោកនេះ លូកដៃទៅចាប់ ក៏ចាប់បាន ដោយ កម្លាំងអធិដ្ឋានឲ្យព្រះចន្ទ ព្រះអាទិត្យកើត ប្រាកដក្នុងហត្ថ-បាស ហើយក៏ចាប់ផ្តាច់យកបាន ប្រៀបដូចផ្លែត្នោត ដែលជ្រុះចាក ទង ព្រោះឈោងដៃទៅបេះយកបាន ។

មានសំណួរក្នុងទីនេះថា កាលបើលោកអ្នកទ្រទ្រង់ឫទ្ធិ ធ្វើ ឲ្យធំវែងទៅបាននោះ ឧបាទិន្នករូប គឺរាងកាយនេះចម្រើនធំឡើង វែងទៅឬ ឬថា អនុបាទិន្នករូប គឺប្រហោងសោរីកធំ ឬដូចម្តេច ?

ឆ្លើយថា អនុបាទិន្នករូប គឺប្រហោងសោជាដើមនោះអាស្រ័យ

នូវឧបាទិន្នករូបនេះ ក៏រីកធំ ។

បុច្ឆា វិសជ្ជនានេះ ព្រះតិបិដកចូឡនាគត្ថេរ បានសួរឯង ឆ្លើយឯង ដល់ភិក្ខុសង្ឃទាំងឡាយថា អាវុសោទាំងឡាយ ខ្ញុំសូម សួរឧបាទិន្នកធម៌នេះតូចធំប៉ុនណា ក៏ថាមិនបាន បើភិក្ខុចេញអំពី ប្រហោងសោក្ខុងកាលណា រាងកាយភិក្ខុដែលជាឧបាទិន្នកធម៌នោះ ក៏តូចប៉ុនប្រហោងសោក្ខុងកាលនោះ ។

ម្យ៉ាងទៀត បើធ្វើអត្តភាពឲ្យធំប៉ុនណា អត្តភាពនោះ ក៏ធំ ក្នុងកាលនោះ ដូចជាព្រះមហាមោគ្គល្លានធ្វើដូច្នោះ ។

ទើបមានពាក្យពោលក្នុងទីនេះថា **ឯកស្មឹ សមយេ** ក្នុងគ្រាមួយ អនាថបិណ្ឌិកសេដ្ឋី ស្តាប់ព្រះធម៌ទេសនារួចហើយ ក្រាបបង្គំទូល អារាធនាថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន វេលាព្រឹកស្អែកនេះ ខ្ញុំព្រះអង្គសូមអារាធនាព្រះអង្គ មួយអន្លើដោយភិក្ខុសង្ឃប្រមាណ ៥០០ រូប ទទួលនូវភត្តក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ ព្រះមានព្រះភាគទទួល ដោយតុណ្ហីភាព ។ លុះពេលបច្ចូសសម័យ ព្រះអង្គប្រមើលមើល នូវលោកធាតុ ឃើញនូវនន្ទោបនន្ទនាគរាជ ចូលមកនៅក្នុងសំណាញ់ ញាណរបស់ព្រះអង្គ ទើបទ្រង់ពិចារណាមើលថា ស្តេចនាគនេះមក

កាន់សំណាញ់ញាណរបស់តថាគត **អត្ថិ នុ ខោ** ដូចតថាគតត្រិះរិះ ស្ដេចនាគនេះជាមិច្ឆាទិដ្ឋិ បុគ្គលណាហ្ន៎ គប្បីដោះចេញនូវមិច្ឆាទិដ្ឋិ ក្នុងសន្ដានរបស់ស្ដេចនាគនេះបាន ។ ព្រះលោកនាយក ក៏ឃើញនូវ ព្រះមហាមោគ្គល្លាន **តទនន្តរំ** លំដាប់នោះ ព្រះអាទិត្យរះបំភ្លឺលោក លើកំពូលភ្នំយុគន្ធរ ។ ព្រះវិជិតមារទ្រង់ធ្វើសរីរកិច្ចរួចហើយ ទើប មានព្រះពុទ្ធដីកា ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ តថាគតនឹងទៅកាន់ទេវចារិក អ្នកចូរប្រាប់ភិក្ខុ ៥០០ រូបឲ្យជ្រាប ព្រមគ្នា ។

**តំ ទិវសំ** ក្នុងវេលាថ្ងៃនោះ នន្ទោបនន្ទនាគរាជបញ្ជាឲ្យបរិស័ទ ចាត់ចែងសុរាជយបាន ក្នុងទីសុរាបានភូមិ នឹងសោយសុរាដ៏មាន រសឲ្យសប្បាយ **បល្លង្កេ និសីទិត្វា** ឡើងអង្គុយលើបល្ល័ង្ក មានអ្នកបាំងស្វេតច្ឆត្រថ្វាយ ហើយចោមរោមទៅដោយពួកនាគបរិស័ទ ទាំងឡាយ ដែលជាអ្នកជំនាញក្នុងការច្រៀងរាំ **ឱលោកិយមានោ** កាលបើក្រឡេកឃើញនូវអន្នបាន ( បាយ ) និងទឹក គ្រឿងទិព្វទាំង ឡាយដែលពួកស្រីស្នំទាំងឡាយ លើកយកមកតម្កល់ក្នុងភាជន៍ មាស សុទ្ធតែមានឱជារសក្រអូបឈ្ងុយដ៏វិសេសមានប្រការផ្សេងៗ ។

គ្រានោះ ព្រះមានជោគ ទ្រង់អធិដ្ឋានឲ្យស្តេចនាគមើលឃើញ ព្រះអង្គ ក្នុងពេលព្រះអង្គ និងភិក្ខុសង្ឃទាំង ៥០០ រូប ហោះឆ្ពោះទៅកាន់ស្ថានតាវត្តិង្ស ខាងលើវិមានរបស់ស្តេចនាគ **តេន សមយេន** ក្នុងគ្រានោះ មិច្ឆាទិដ្ឋិដ៏លាមកកើតដល់ស្តេចនាគថា សមណៈក្បាលត្រងោលទាំងឡាយនេះ ទៅកាន់ស្ថានតាវត្តិង្ស ក៏ទៅដោយខាងលើភពរបស់អញ ចេញអំពីស្ថានតាវត្តិង្ស ក៏ចេញមកខាងលើភពរបស់អញ គ្មានសេចក្តីកោតក្រែងអញសោះ ឥឡូវនេះ ក៏នឹងមកជម្រុះនូវធូលីលើក្បាលរបស់អញៗ នឹងមិនឲ្យទៅ **ឧដ្ឋាយ សិនេរុបាទំ គន្ត្វា...** ។ ស្តេចនាគក៏ក្រោកអំពីបល្ល័ង្កទៅកាន់ភ្នំសិនេរុ ទើបធ្វាយរង្វេល ព័ទ្ធភ្នំសិនេរុ ៧ ជាន់ បើកពពារដ៏ធំមិនឲ្យឃើញនូវស្ថានតាវត្តិង្ស **ទេវលោកស្ស រដ្ឋបាលត្ថេរោ** គ្រានោះ ទើបព្រះរដ្ឋបាលត្ថេរទូលសួរព្រះមានព្រះភាគថា អំពីមុនខ្ញុំព្រះអង្គមកឈរនៅទីនេះ ក៏មើលឃើញនូវភ្នំសិនេរុ ឃើញនូវភ្នំសត្តបរិភណ្ឌ ឃើញនូវស្ថានតាវត្តិង្ស ឃើញនូវវេជយន្តប្រាសាទ ឃើញនូវទង់ ឃើញនូវឆត្រ ដោតនៅលើកំពូលប្រាង្គប្រាសាទ ឥឡូវនេះ ហេតុដូចម្តេច ទើបខ្ញុំព្រះអង្គមើល

មិនឃើញអ៊ីចឹង ។ ទើបព្រះសម្ពុទ្ធមានព្រះពុទ្ធដីកាថា ម្នាលរដ្ឋបាល ថ្ងៃនេះ នន្ទោបនន្ទនាគរាជខឹងអ្នកទាំងឡាយ ទើបធ្វាយរង្វេលពទ្ធជុំវិញភ្នំសិនេរុដោយកាយរបស់ខ្លួន ៧ ជាន់ បើកពពាររបិទបាំងទាំងអស់ ធ្វើឲ្យងងឹតស្លុប ។ ទើបព្រះរដ្ឋបាលសូមជានាទៅទូន្មានស្តេចនាគ ។ ព្រះលោកនាយក ទ្រង់មិនអនុញ្ញាត ។ គ្រានោះ ទើបព្រះសាវ័កទាំងអស់សូមជានា ទៅទូន្មានស្តេចនាគដោយលំដាប់គ្នា គឺព្រះកទ្ទិយត្ថេរ ព្រះរាហុលជាដើម។ ព្រះសម្មាសម្ពុទ្ធទ្រង់មិនអនុញ្ញាត ។

លំដាប់នោះ ទើបព្រះមហាមោគ្គល្លាន ក្រាបទូលថា ខ្ញុំព្រះអង្គសូមជានាដើម្បីទៅទូន្មានស្តេចនាគនោះ ។ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាត **ថេរោ អត្តភាវំ វិជហិត្វា** ព្រះមហាមោគ្គល្លានក៏ប្លែងភេទជានាគរាជដ៏ធំ ចូលទៅធ្វាយរង្វេលពីខាងលើកាយរបស់នន្ទោបនន្ទនាគរាជយ៉ាងមាំ បើកពពារគ្របសង្កត់អំពីលើពពាររបស់ស្តេចនាគនោះ ។

ចំណែកនន្ទោបនន្ទនាគរាជ ក៏ព្រួសផ្សែង កើតជាផ្សែងហុយទ្រលោមឡើងពេញអាកាស ។ ទើបព្រះមហាមោគ្គល្លានប្រាប់ថា ផ្សែងរបស់អ្នកមិនបានប៉ះត្រូវសរីរកាយរបស់អាត្មាទេ ដូចគ្មានផ្សែង

ដូច្នោះ ៗ ផ្សែងរបស់អាត្មាក៏មានច្រើន ទើបព្រះមហាមោគ្គល្លាន បណ្តាលឲ្យមានផ្សែងខ្មៅកើតឡើង ហុយទ្រលោមក្រៃលែងជាង បិទបាំងខ្លួនរបស់ស្តេចនាគ គឺផ្សែងរបស់ស្តេចនាគមិនបានបៀត បៀនព្រះមហាថេរៈ ផ្សែងរបស់ព្រះមហាថេរៈ ធ្វើការបៀតបៀនស្តេច នាគ ៗ នាគរាជអត់ធន់មិនបាន ទើបបញ្ចេញភ្លើងសន្ធោសន្ធៅជុំវិញ ព្រះភ្នំសិនេរុ ព្រះមហាមោគ្គល្លានត្រូវពោលថា ភ្លើងរបស់អ្នកមិន បានក្តៅសរីរកាយរបស់អាត្មាទេ ភ្លើងរបស់អាត្មានេះក៏មានច្រើន ទើបព្រះមហាថេរៈសម្តែងតេជោកសិណាឫទ្ធិឲ្យប្រាកដតែម្យ៉ាង ទៅ ពាសពេញសរីរកាយស្តេចនាគ តែភ្លើងរបស់ស្តេចនាគ មិនបាន បៀតបៀនព្រះមហាថេរៈ ភ្លើងរបស់ព្រះមហាថេរៈក្តៅខ្លាំងក្លា ធ្វើការ បៀតបៀនស្តេចនាគ កាលក្តៅហួសពីការទ្រាំ ទើបស្តេចនាគគិតថា បុគ្គលណាមកសង្កត់អញ្ចផ្ទាប់នឹងភ្នំសិនេរុ ហើយក៏ព្រួសជាភ្លើងពិស ចេញមក និងជាជាតិនាគរាជកំណើតណា ទើបសួរថា ភោ បពិត្រ លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឈ្មោះអ្វី ? អាត្មាឈ្មោះមហាមោគ្គ- ល្លាន ជាសាវ័ករបស់ព្រះពុទ្ធ ៗ ទើបនន្ទោបនន្ទនាគរាជពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន និមន្តលោកម្ចាស់ប្រាកដដោយភេទជាភិក្ខុ

វិញចុះ ។ ព្រះមហាមោគ្គល្លាន ក៏ប្រាកដសរីរកាយជាភិក្ខុទ្រទ្រង់សំពត់កាសាវៈ ឬភេទបព្វជិត ហើយនិម្មិតកាយ ចូលទៅតាមរន្ធត្រចៀកខាងស្ដាំរបស់ស្ដេចនាគ ចេញមកតាមរន្ធត្រចៀកខាងឆ្វេង មួយទៀតចូលទៅតាមរន្ធត្រចៀកខាងឆ្វេង ចេញមកវិញតាមរន្ធត្រចៀកខាងស្ដាំមួយទៀត ចូលតាមរន្ធច្រមុះខាងស្ដាំ ចេញទៅតាមរន្ធច្រមុះខាងឆ្វេង ហើយប្ដូរទីកន្លែងចូល-ចេញតាមរន្ធច្រមុះរបស់ស្ដេចនាគ ។ ខណៈនោះស្ដេចនាគក៏ហាមាត់ឡើង ព្រះមហាថេរៈចូលទៅតាមមាត់ និមន្តចង្ក្រមនៅក្នុងពោះ និមន្តអំពីក្បាលទៅកន្ទុយ ។ ទើបព្រះមានព្រះភាគត្រាស់ដាស់តឿនថា ម្នាលមោគ្គល្លាន អ្នកចូរមានមនសិការ ស្ដេចនាគនេះមានឫទ្ធិអានុភាពច្រើន ។ ទើបព្រះមហាមោគ្គល្លានក្រាបទូលថា ឥទ្ធិបាទ ៤ ប្រការ ខ្ញុំព្រះអង្គធ្វើឲ្យចម្រើន ស្ទាត់ជំនាញបានច្រើន ជាយាន ធ្វើឲ្យវត្ថុរបស់របរដ៏ប្រសើរប្រាកដរឿយៗ សន្សំដោយល្អហើយ ប្រារព្ធជាអារម្មណ៍គ្រប់ខណៈដកដង្ហើមចេញ-ចូល នន្ទោបនន្ទនាគរាជមានឫទ្ធិនេះលើកទុកសិនចុះ សូម្បីនាគរាជទាំងឡាយឯទៀត ដែលមានឫទ្ធិច្រើនដូចស្ដេចនាគនេះ ប្រមាណមួយរយក្ដី មួយពាន់ក្ដី ខ្ញុំព្រះអង្គអាចទូន្មានបាន ។

ចំណែកនន្ទោបនន្ទនាគរាជ គិតថា កាលភិក្ខុចូលទៅក្នុងពោះអញក៏ខាំមិនទាន់ បើភិក្ខុចេញមកវិញ អញនឹងខាំក្នុងចន្លោះចង្កូមទំពាស៊ី ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមនិមន្តចេញមកចុះ កុំនិមន្តនៅក្នុងពោះរបស់ខ្ញុំព្រះករុណា ធ្វើឲ្យខ្ញុំព្រះករុណាលំបាក សូមប្រញាប់និមន្តចេញមកខាងក្រៅចុះ **ថេរោ និក្ខមិត្វា** ព្រះមហាមោគ្គល្លានចេញមកប្រតិស្ឋាននៅខាងក្រៅ ចំពោះមុខស្តេចនាគៗ ឃើញប្រាកដថា ព្រះមហាថេរៈរូបនេះដឹងចិត្តអាត្មាអញ ទើបព្រួសពិសចេញជាខ្យល់ពិស ព្រះមហាមោគ្គល្លាន ក៏ចូលកាន់ចតុត្ថជ្ឈាន ពិសខ្យល់របស់ស្តេចនាគនោះ សូម្បីត្រឹមតែរោមមួយសរសៃរបស់ព្រះថេរៈ ក៏មិនអាចបៀតបៀនបានឡើយ ការពិតភិក្ខុទាំងឡាយដទៃៗ ដែលមានឫទ្ធិនោះ ក៏អាចធ្វើបាដិហារ្យទាំងពួងបានអំពីដើមមក **៩៩ំ បឆ** តែលុះមកដល់ដំណាក់ការនេះ កាលបើស្តេចនាគព្រួសខ្យល់ពិសចេញចំពោះមុខ សូម្បីទ្រទ្រង់ឫទ្ធានុភាពច្រើនក្តី ក៏មិនអាចចូលកាន់ចតុត្ថជ្ឈានឲ្យលឿនរហ័ស ផុតអំពីការទទួលរងពិសស្តេចនាគបានឡើយ លើកលែងតែព្រះមហាមោគ្គល្លានមួយ

រូប ។ ហេតុដូច្នោះ ទើបព្រះមានព្រះភាគ មិនបានអនុញ្ញាតឲ្យសាវក ទាំងឡាយទូន្មានស្តេចនាគ ព្រះអង្គអនុញ្ញាតតែព្រះមហាមោគ្គល្លាន តែមួយរូបប៉ុណ្ណោះ ។

**ឆន្ទោបនន្ទរាជា** ចំណែកនន្ទោបនន្ទនាគរាជ គិតថា ខ្លួនមិនអាចញុំាងព្រះសមណៈ អ្នកទ្រទ្រង់នូវឫទ្ធិឲ្យញាប់ញ័រចិត្តដោយ ពិសបាន សូម្បីត្រឹមតែរោមមួយសរសៃក៏មិនបានកក្រើក អញមិនអាច នឹងតស៊ូជាមួយព្រះសមណៈអ្នកទ្រទ្រង់នូវឫទ្ធិនេះបានទេ ហើយស្តេច នាគក៏រត់គេចចេញអំពីទីនោះទៅ ។ ព្រះមហាថេរៈក៏និម្មិតខ្លួន ជាស្តេចគ្រុឌ សម្តែងនូវខ្យល់ស្លាបហើរដេញជាប់តាមស្តេចនាគៗ ក៏ ភ័យ ទើបប្លែងកាយជាភេទមាណព ពោលថា បពិត្រលោក ម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាជ្រាបច្បាស់ហើយ ពេលនេះ សូម ដល់នូវសមណៈជាទីពឹងរបស់ខ្ញុំព្រះករុណា ។ ពោលដូច្នេះហើយ ក៏ លើកដៃឡើងនមស្ការ ថ្វាយបង្គំបាទាព្រះមហាថេរៈ ។ ទើបព្រះ មហាមោគ្គល្លានមានថេរវាចាថា នែស្តេចនាគ ឥឡូវនេះ ព្រះពុទ្ធ ទ្រង់យាងមក អ្នកចូរទៅគាល់ព្រះអង្គចុះ ។ ព្រះមហាមោគ្គល្លាន ទូន្មានស្តេចនាគឲ្យព្យសកំណាច រួចហើយ នាំមកកាន់សម្នាក់ព្រះ

មានព្រះភាគ ។ នន្ទោបនន្ទនាគរាជក៏នមស្ការ ថ្វាយបង្គំព្រះ-យុគលបាទនៃព្រះសាស្តា ពោលថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គសូមដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងជាទីរឭករបស់ខ្ញុំព្រះករុណា ។ ទើបព្រះពុទ្ធត្រាស់ថា ម្នាលស្តេចនាគ អ្នកចូរនៅជាសុខសប្បាយចុះ ។ ត្រាស់ដូច្នេះហើយ ព្រះអង្គ ព្រមដោយភិក្ខុសង្ឃក៏វិលត្រឡប់មកកាន់ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ។ ក្នុងខណៈនោះទើបអនាថបិណ្ឌកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដចម្រើន ខ្ញុំព្រះអង្គសូមទូលសួរ ថ្ងៃនេះហាក់បីដូចយឺតយូរ មានហេតុការណ៍ដូចម្តេច ? ព្រះមានជោគត្រាស់ថា ថ្ងៃនេះ មហាមោគ្គល្លាន និងនន្ទោ-បនន្ទនាគរាជធ្វើសង្គ្រាមនឹងគ្នា ។ បពិត្រព្រះអង្គដ៏ចម្រើន តើអ្នកណាឈ្នះ អ្នកណាចាញ់ ? ព្រះពុទ្ធត្រាស់ប្រាប់ថា មោគ្គល្លានឈ្នះ នន្ទោបនន្ទនាគរាជចាញ់ ក្នុងពេលនោះ ទើបអនាថបិណ្ឌិកសេដ្ឋីក្រាបទូលអារាធនានិមន្តព្រះពុទ្ធថា **ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមទទួលអាហារបិណ្ឌបាតរបស់ខ្ញុំព្រះអង្គអស់ ៧ ថ្ងៃ ខ្ញុំព្រះអង្គធ្វើនូវបាដិ-ហារិយកត្តនោះ ជាគ្រឿងបូជាថ្វាយចំពោះព្រះមហាមោគ្គល្លាន ៧ ថ្ងៃ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលអារាធនាដូច្នេះហើយ ក៏ថ្វាយនូវមហា

សក្ការបូជាដល់ភិក្ខុទាំងឡាយ ៥០០ រូប មានព្រះពុទ្ធអង្គជាប្រធាន រហូតអស់ ៧ ថ្ងៃជាកំណត់ ។ ព្រះតិបិដកចូឡនាគត្ថេរ អាស្រ័យនូវអត្តភាពជាធំ ដែលព្រះមហាមោគ្គល្លាន និម្មិតក្នុងកាលទូន្មាននន្ទោបនន្ទនាគរាជ ដូច្នេះ ទើបពោលឆ្លើយចំពោះភិក្ខុទាំងឡាយថា នាគរាជទាំងឡាយ ធ្វើសរីរកាយធំៗ ប្រមាណប៉ុនណា ក្នុងកាលណា លោកទាំងឡាយដែលទ្រទ្រង់ឫទ្ធិនោះ ក៏ធ្វើសរីរកាយឲ្យធំក្រៃលែងជាងនោះ ក្នុងកាលនោះ ប្រៀបដូចព្រះមហាមោគ្គល្លានទូន្មានស្តេចនាគ ។ ពាក្យដូច្នេះ គឺព្រះតិបិដកចូឡនាគត្ថេរជាអ្នកពោល ភិក្ខុទាំងឡាយក៏ពោលតបថា អនុបាទិន្នករូបនឹងចម្រើនធំៗ ក៏អាស្រ័យនូវឧបាទិន្នករូប ទើបធំ ពាក្យនេះក៏សមគ្នា លោកអ្នកមានឫទ្ធានុភាពនោះធ្វើបានដូច្នេះ មិនមែនត្រឹមតែស្ទាបអង្អែលព្រះចន្ទ ព្រះអាទិត្យតែប៉ុណ្ណោះទេ សូម្បីប្រាថ្នានឹងធ្វើឲ្យព្រះចន្ទ ព្រះអាទិត្យទៅជាតាំង ជាជ្រញ់សម្រាប់ទ្រជើង ក៏អាចធ្វើបានដូចសេចក្តីប្រាថ្នា ឬញុំាងព្រះចន្ទព្រះអាទិត្យឲ្យមកនៅក្បែរជើង ឡើងអង្គុយសង្កត់ពីលើក៏បាន ឬធ្វើជាក្តារបង្អែក ក៏ធ្វើបានគ្រប់ប្រការ ។ **យថា ឃកោ ឃរ អបរេហិ** លោកអ្នកមានឫទ្ធិម្នាក់ ធ្វើព្រះចន្ទព្រះអាទិត្យជាបាដិហារ្យ

ប្រាកដផ្សេងៗ យ៉ាងណា លោកអ្នកទាំងឡាយដទៃឯទៀត ដែលមានឫទ្ធិក៏ធ្វើបានដូច្នោះដែរ ឈ្មោះថាភិក្ខុទាំងឡាយជាច្រើនប្រមាណមួយសែនរូបក្តី ធ្វើបាដិហារ្យដូច្នេះ បាដិហារ្យរបស់ភិក្ខុទាំងឡាយទាំងមួយសែនរូបនោះ ក៏សម្រេចគ្រប់ប្រការដូចគ្នា ។ កិរិយាដែលព្រះចន្ទ ព្រះអាទិត្យទាំង ២ ដើរតាមវិថីក្តី ធ្វើអាការបំភ្លឺលោកឲ្យរុងរឿងក្តី ក៏តាំងនៅជាធម្មតាដូច្នោះ នឹងឧបមាប្រៀបដូចថាសទឹកប្រមាណ ១០០០ ពេញទៅដោយទឹកយកមកតម្កល់ទុក រូបព្រះចន្ទព្រះអាទិត្យទាំង ២ ក៏ចាំងចូលទៅ ប្រាកដក្នុងថាសទឹកទាំងអស់ ។ កិរិយាដែលព្រះចន្ទព្រះអាទិត្យដើមមានពន្លឺនោះ មិនមែនជាបាដិហារ្យតែម្យ៉ាងប៉ុណ្ណោះទេ វីបាដិហារ្យដូច្នោះ ក៏កើតមានដូច្នោះ មិនមែនជាបាដិហារ្យមួយប៉ុណ្ណោះឡើយ នឹងញុំាងទេវលោកឲ្យមកប្រាកដនៅក្នុងទីជិតៗ ក៏បាន លោកអ្នកមានឫទ្ធិចេញចាកចតុត្ថជ្ឈាន មានអភិញ្ញាជាបាទហើយ ធ្វើអាវជ្ជនៈពិចារណានូវស្ថានសួគ៌ទេវលោកនិងព្រហ្មលោកដែលនៅឆ្ងាយឲ្យមកប្រាកដក្នុងទីជិត បរិកម្មអធិដ្ឋានដូច្នេះហើយ ក៏ត្រឡប់ចូលកាន់ឈាន អធិដ្ឋានដោយឈាន ឲ្យស្ថានទេវលោក ព្រហ្មលោកដែលនៅឆ្ងាយ ក៏ឲ្យមកប្រាកដក្នុងទី

ជិត ព្រមគ្នានឹងអធិដ្ឋាន ។ បុគ្គលមានឫទ្ធិ ធ្វើនូវទីឆ្ងាយឲ្យមកនៅប្រាកដក្នុងទីជិតនោះ បុគ្គលណា គឺអគ្គបុគ្គលក្នុងលោក កាលទ្រង់ធ្វើយមកប្បាដិហារ្យ រួចហើយ ព្រះអង្គពុទ្ធដំណើរទៅកាន់ស្ថានតាវត្តិង្ស ធ្វើនូវភ្នំយុគន្ធរ និងភ្នំសិនេរុឲ្យមកនៅជិត ទើបដាក់ចុះនូវព្រះបាទម្ខាងជាន់លើកំពូលភ្នំយុគន្ធរ ដាក់ចុះនូវព្រះបាទម្ខាងទៀត ជាន់លើកំពូលភ្នំសិនេរុ ។

មួយទៀត ក្នុងលង្កាទ្វីប មានភិក្ខុ ៧០០ រូប និមន្តទៅកាន់សម្នាក់ព្រះមហាថេរៈ ។ ទើបព្រះមហាថេរៈរំពឹងគិតថា គ្រានេះ ក្រចង្អាន់ណាស់ ភិក្ខុទាំងឡាយនឹងនិមន្តបិណ្ឌបាត រកភិក្ខាចារនៅទីណាហ្ន៎ ទើបជ្រាបថា បាននូវអាហារបិណ្ឌបាតឆ្ងាយ រហូតដល់ក្រុងបាដលីបុត្រ ខាងត្រើយម្ខាងមហាសមុទ្រឯណោះ ។ ទើបប្រាប់ភិក្ខុទាំងឡាយឲ្យចាត់ចែងបាត្រ និងចីវរថា អាវុសោទាំងឡាយ ចូរលោកទៅបិណ្ឌបាតជាមួយនឹងខ្ញុំ ព្រះមហាថេរៈព្រះនាមចូឡសមុទ្ទត្ថេរ ក៏បង្រួញផែនដី នាំភិក្ខុទាំងឡាយមកកាន់ក្រុងបាដលីបុត្រ ។ ឯភិក្ខុទាំងឡាយមិនធ្លាប់ឃើញក្រុងបាដលីបុត្រ ក៏សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្រុងនេះ ឈ្មោះអ្វីដែរ ? ទើបព្រះមហាថេរៈប្រាប់ថា នេះជាក្រុងបាដលីបុត្រ ។ ទើបភិក្ខុ

ទាំងឡាយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្រុងបាដលីបុត្រ បានឮមកអំពីមុនថា នៅឆ្ងាយដល់ត្រើយម្ខាងមហាសមុទ្រឯណោះ ។ នែអាវុសោ ព្រះមហាថេរៈរបស់យើងនេះ ញ៉ាំងទីឆ្ងាយឲ្យជិតបាន ។ ភិក្ខុទាំងឡាយសង្ស័យទើបសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដូចម្តេចទើបមិនឃើញមហាសមុទ្រ ? អាវុសោ ក្នុងរវាងផ្លូវដែលមក លោកទាំងឡាយបានឃើញប្រឡាយតូចមួយនោះឬទេ ហ្នឹងមិនមែនមហាសមុទ្រទេឬ នុ៎ះឯងជាមហាសមុទ្រ កាលដែលលោកទាំងឡាយឆ្លងមកអម្បាញ់មិញនេះ ។ ទើបភិក្ខុទាំងឡាយសួរថា មហាសមុទ្រធំធេងណាស់ នេះគ្រាន់តែជាប្រឡាយទឹកតូចមួយប៉ុណ្ណោះ ។ អាវុសោ មហាថេរៈរបស់យើងធ្វើរបស់ធំ ឲ្យជាតូចបាន កិរិយាដែលធ្វើនូវបាដិហារ្យរបស់ធំ ឲ្យជាតូច និងទីឆ្ងាយឲ្យជិត ដូចព្រះមហាសមុទ្ទៈធ្វើដូច្នេះ ។

មួយទៀត គឺធ្វើទីឆ្ងាយឲ្យជិតនោះ បុគ្គលណាធ្វើ គឺព្រះភគវា កាលព្រះអង្គទ្រង់ទូន្មានព្រះអង្គុលិមាលនោះ ព្រះអង្គធ្វើបន្ទោះផ្លូវរវាងព្រះអង្គ និងអង្គុលិមាលនៅជិតគ្នានោះ ឲ្យឆ្ងាយក្រៃលែង ។ ព្រះ-

អង្គុលិមាលរត់ដេញតាមពេញទំហឹងហើយ រឹងរឹតតែរត់ រឹងរឹតតែឆ្ងាយ រហូតដល់អស់កម្លាំង បាននូវសេចក្តីលំបាក ។

**កោ ពហុកំ ថោកំ អកាសិ** បុគ្គលណាធ្វើរបស់ច្រើនឲ្យទៅជារបស់តិច គឺព្រះមហាកស្សបត្ថេរធ្វើ ។ បានឮមកថា គ្រាមួយក្រុងរាជគ្រឹះមហានគរលេងនក្ខត្តឫក្ស កុមារីទាំងឡាយ ៥០០ នាក់ កណ្តៀតកំប្រោងនំ ៥០០ ដើម្បីនឹងទៅលេងនក្ខត្តឫក្ស ជួបព្រះភគវា និងភិក្ខុសង្ឃទាំងឡាយជាច្រើនក៏មិនបានថ្វាយនំ ។ ព្រះមហាកស្សបៈ និមន្តមកតាមក្រោយម្នាក់ៗ ក៏ត្រេកអររីករាយថា ព្រះមហាថេរៈរបស់យើងនិមន្តមក មកយើងទាំងឡាយចូរកណ្តៀតនំចូលទៅកាន់សម្នាក់ព្រះមហាកស្សបៈ ថ្វាយទាំង ៥០០ កញ្ចប់ ។ ព្រះមហាកស្សបត្ថេរ ក៏អធិដ្ឋាននំទាំង ៥០០ កំប្រោងនោះ ដាក់ចូលក្នុងបាត្រពេញល្មម ។ កាលនំពេញបាត្រហើយ ក៏និមន្តចៀសចេញទៅ ។ ព្រះមានព្រះភាគចៀងចូលទៅគង់ក្រោមដើមឈើមួយដើម មួយអន្លើដោយភិក្ខុសង្ឃទាំងឡាយ ។ ព្រះមហាកស្សបត្ថេរក៏នាំយកនំបង្អែមចូលទៅដើម្បីថ្វាយចំពោះព្រះមានព្រះភាគ និងព្រះអរិយសាវកបរិវារ ៥០០ រូបឆាន់ឆ្អែតស្កប់ស្កល់ ។

ក្នុងរឿងនិទានអំពីឥលិសស្សសេដ្ឋីនោះ ព្រះមហាមោគ្គល្លាន គឺធ្វើតិចឲ្យច្រើន ។ ក្នុងរឿងកាកវឡិយបុរសនោះ ព្រះមហាកស្សបត្ថេរអាស្រ័យនៅដោយផលសមាបត្តិ ៧ ថ្ងៃ កាលបើលោកធ្វើនូវការសង្គ្រោះដល់មនុស្សទុគ៌ត ទើបនិមន្តទៅឈរទៀបទ្វារបេងផ្ទះរបស់មនុស្សទុគ៌តឈ្មោះកាកវឡិយបុរស នាងជាភរិយារបស់បុរសទុគ៌តនោះ បានដាក់យាគូក្នុងបាត្ររបស់ព្រះមហាកស្សបត្ថេរ ។ ព្រះមហាកស្សបត្ថេរនាំយកបិណ្ឌបាតទាននោះ នាំមកថ្វាយចំពោះព្រះសាស្តា គ្រានោះ ព្រះសម្ពុទ្ធទ្រង់អធិដ្ឋានឲ្យយាគូដល់ភិក្ខុជាច្រើនឆាន់ឆ្អែតស្កប់ស្កល់ ដោយយាគូដែលព្រះមហាកស្សបត្ថេរ នាំមកថ្វាយត្រឹមតែមួយបាត្រប៉ុណ្ណោះ ក៏ឆ្អែតគ្រប់ៗ រូប ។ លុះកាលកន្លងទៅបាន ៧ ថ្ងៃ កាកវឡិយបុរសទុគ៌តនោះ ក៏បានជាមហាសេដ្ឋី ដោយអានិសង្សយាគូ ដែលជាទិដ្ឋធម្មវេទនីយបុណ្យនោះ អ្នកទ្រទ្រង់នូវឫទ្ធានុភាពច្រើននេះ មិនមែនធ្វើត្រឹមតែរបស់តិចឲ្យច្រើននោះទេ នឹងធ្វើរបស់ដែលគ្មានរស ឲ្យកើតមានរសឆ្ងាញ់ក៏បានសម្រេចដូចសេចក្តីប្រាថ្នាគ្រប់យ៉ាង ។

គ្រាមួយ ព្រះអនុរុទ្ធត្ថេរ បានក្រឡេកឃើញភិក្ខុទាំងឡាយដ៏ច្រើនបាននូវបិណ្ឌបាតសុទ្ធតែជារបស់សៅហ្មង អគ្គុយឆាន់នៅក្បែរមាត់ទឹក

ក៏បានកើតសេចក្ដីអាណិតអាសូរ ទើបអធិដ្ឋានទឹកក្នុងស្ទឹងនោះ ឲ្យកើតជាសប្បិខាប់ដ៏មានរសឆ្ងាញ់ រួចហើយឲ្យសញ្ញាដល់សាមណេរទាំងឡាយៗ ក៏កាន់យកភាជនៈចុះទៅដងទឹក មកប្រគេនចំពោះភិក្ខុសង្ឃឲ្យឆាន់ជាមួយនឹងបិណ្ឌបាត ដែលជារបស់សៅហ្មងនោះ ភិក្ខុសង្ឃញ៉ាំងភត្តកិច្ចដោយសប្បិខាប់ព្រមគ្នាគ្រប់រូប ក្នុងពេលថ្ងៃនោះ ។

**តថា អស្សគុត្តត្ថេរោ** មួយទៀត ព្រះថេរៈព្រះនាមអស្សគុត្តត្ថេរ ឃើញភិក្ខុញ៉ាំងភត្តកិច្ចដ៏សៅហ្មង ក្នុងវត្តនិយសេនាសនៈនោះ ទើបអធិដ្ឋានទឹកក្នុងក្អម ឲ្យកើតជាទឹកដោះជូរក្នុងវេលាមុនភត្តរាល់ថ្ងៃ ទឹកក្នុងក្អមនោះក៏ប្រាកដជាទឹកដោះជូរក្នុងពេលមុនភត្ត លុះក្រោយភត្ត ក៏ជាទឹកធម្មតា បាដិហារ្យរបស់អ្នកទ្រទ្រង់នូវឫទ្ធិមានភាពអស្ចារ្យក្រៃលែងដូច្នេះ ។

មួយទៀត បុគ្គលទាំងឡាយដែលបានអភិញ្ញា គឺបញ្ញារឭកជាតិកន្លងមកហើយនោះ មាន ៦ ពួក គឺអន្យតិរ្ថិយ ១ បកតសាវក ១ អសីតមហាសាវក ១ ព្រះអគ្គមហាសាវក ១ ព្រះបច្ចេកពុទ្ធ ១ ព្រះពុទ្ធ ១ ។ កិរិយាដែលភពនោះៗ ចូលទៅជិតក្តី មិនបានចូលទៅជិតក្តី ដោយអំណាចលំដាប់នៃកិរិយានៅក្នុងភពនោះៗ ក្តី ដោយ

អំណាចចុតិបដិសន្ធិក្តី ហើយត្រាច់រង្គាត់ទៅក្នុងជាតិនោះ ឈ្មោះថា បុព្វេសន្និវាស ។ អន្យតិ្ថិយពួកខ្លះ មានបញ្ញាតិចនោះ រឭកជាតិបាន ១០០០ ជាតិយ៉ាងច្រើន ដែលមានបញ្ញាយ៉ាងកណ្តាលនោះ រឭកបាន ១០ សំវដ្តកប្ប ដែលមានបញ្ញាស្រួចស្រាល់នោះ រឭកបាន ៤០ កប្ប នឹងរឭកកើនឡើងទៅជាង ៤០ កប្បមិនមាន ព្រោះអ្វី ព្រោះថា អន្យតិ្ថិយទាំងឡាយនោះមានបញ្ញាទុព្វលភាព ហេតុអ្វីទើបមានបញ្ញា-ទុព្វលភាព ព្រោះអន្យតិ្ថិយទាំងឡាយប្រាសចាកបញ្ញាពិចារណា កំណត់នាមរូប មិនមានបញ្ញាកំណត់នាម និងរូបឡើយ ឯបញ្ញាកំណត់នាម និងរូបនោះ ជាបញ្ញាល្អិតសុខុមគម្ភីរភាព មានកម្លាំងខ្លាំងក្លា ។

ចំណែកបកតិសាវ័កទាំងឡាយ រឭកជាតិបាន ១០០ កប្បក្តី ១០០០ កប្បក្តី ច្រើនជាងអន្យតិ្ថិយ ព្រោះអ្វី ព្រោះថា បកតិ-សាវ័កទាំងឡាយមានបញ្ញាចាស់ក្លា ក្នុងការកំណត់នាមរូប ។

ចំណែកព្រះអសីតិមហាសាវ័ក មានបញ្ញាច្រើនជាងបកតិ-សាវ័កទាំងឡាយ ទើបរឭកជាតិបានមួយសែនកប្ប ។

ព្រះអគ្គសាវកទាំងពីររូប ដូចជាព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាននោះ រឭកជាតិបានមួយអសង្ខេយ្យ និងមួយសែនមហាកប្ប ។

ចំណែកព្រះបច្ចេកពុទ្ធ រឭកជាតិបានពីរអសង្ខេយ និងមួយសែនមហាកប្ប ។ សេចក្តីថា ព្រះអភិនីហាររបស់លោកទាំងឡាយជាដើម គឺបកតិសាវកនោះ កសាងបារមីច្រើនកំណត់ប្រមាណប៉ុនណា ក៏រឭកជាតិបានប្រមាណប៉ុណ្ណោះ ទើបយល់ច្បាស់ថា បកតិសាវកកសាងបារមីមករយកប្បក្តី ពាន់កប្បក្តី ក៏រឭកជាតិបានប៉ុនគ្នា ឬស្មើគ្នានឹងបារមី ។

**ពុទ្ធានំ បន** ព្រះពុទ្ធទាំងឡាយ ព្រះអង្គរឭកជាតិកំណត់មិនបាន គឺព្រះអង្គរឭកជាតិបានច្រើនសែនកោដិកប្ប ។

មួយទៀត អន្យតិត្ថិយរឭកជាតិបានដោយជាលំដាប់ គឺមិនរំលងជាតិបាន ។ ការពិត អន្យតិត្ថិយទាំងឡាយប្រៀបដូចមនុស្សខ្វាក់ទាំងឡាយ ដែលនឹងទៅកាន់ទីដែលខ្លួនប្រាថ្នានោះ នឹងទៅដោយខ្លួនឯងមិនបានទេ ត្រូវអាស្រ័យកាន់ឈើច្រត់ ទើបឈានដើរទៅបាន យ៉ាងណា អន្យតិត្ថិយទាំងឡាយនោះ ក៏មិនអាចលះបង់នូវលំដាប់ខន្ធ ប្រកាន់យក

លំដាប់ឲ្យមាំ ទើបរឮកជាតិទៅបាន មានឧបមេយ្យដូចមនុស្សខ្វាក់ទាំងឡាយកាន់ឈើច្រត់ដ៏មាំ ហើយក៏ឈានជើងដើរទៅបាន ។ បកតិសាវកទាំងឡាយ រឮកជាតិបានដោយលំដាប់ខន្ធក៏បាន នឹងរំលងទៅបានដោយអំណាចចុតិបដិសន្ធិក៏បាន ។ ព្រះអសីតិមហាសាវកទាំងឡាយក៏ដូចគ្នា ប៉ុន្តែព្រះអគ្គសាវកទាំងពីររូប កិច្ចដោយការរឮកតាមលំដាប់ខន្ធមិនមាន លោករឮកឆ្លងទៅដោយចុតិបដិសន្ធិតែម្តងគឺឃើញចុតិនៃអត្តភាពមួយហើយ ក៏ឃើញបដិសន្ធិក្នុងអត្តភាពដទៃតទៅ ឃើញអត្តភាពដទៃទៀតហើយ ក៏ឃើញបដិសន្ធិក្នុងអត្តភាពដទៃតទៅទៀត ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ដូចព្រះអគ្គសាវកទាំងពីរដែរ ។ **ពុទ្ធានំបិ** ប៉ុន្តែព្រះពុទ្ធទាំងឡាយ កិច្ចដែលជាលំដាប់ក៏មិនមាន កិច្ចដែលរំលងទៅដោយអំណាចចុតិ បដិសន្ធិក៏មិនមាន ។

អធិប្បាយថា ព្រះពុទ្ធទាំងឡាយ ប្រាថ្នានឹងរឮកជាតិកន្លងហើយ ឬរឮកជាតិទៅខាងមុខក្តី ក្នុងកោដិកប្បទាំងឡាយដ៏ច្រើនក្តី ទីនោះៗ ក៏ប្រាកដចំពោះព្រះអង្គ ។ **តស្មា** ព្រោះហេតុនោះ ព្រះអង្គនឹងបង្រួញនូវកោដិកប្បទាំងឡាយដ៏ច្រើន ប្រាថ្នារឮកជាតិណា ក្នុងជាតិទាំងឡាយនោះៗ ព្រះអង្គក៏រឮកនូវជាតិនោះៗ ប្រៀបដូចស្តេចកេសរសីហរាជ ។

ព្រោះហេតុនោះ ទើបព្រះអង្គប្រព្រឹត្តទៅដោយបុព្វេនិវាស ដោយអំណាច សីហោកន្តន័យ ប្រៀបដូចរាជសីហ៍លោត ។ មួយទៀត មានពាក្យ ឧបមាថា នាយខ្មាន់ធ្នូដ៏ស្ទាត់ជំនាញ ដូចសរភង្គអាចារ្យដែលជំនាញ ក្នុងសិល្បសាស្ត្រធ្នូ ដែលឈ្មោះថា **ពាលវេធី** អាចបាញ់ត្រូវចុងរោម ទ្រាយ ក្នុងចម្ងាយមួយយោជន៍ ហើយសរឈ្មោះថា **សរវេធី** អាចបាញ់ នូវសព្វសត្វ ត្រឹមតែបានឮសំឡេង ក៏អាចបាញ់ត្រូវ និងសរឈ្មោះ **វិជ្ជុវេធី** ពន្លឺរបស់ផ្លេកបន្ទោរមួយច្វាចនោះ ក៏លែងធ្នូបាញ់ទៅបាន ៧ ដង កាលលែងសរទៅនោះ មិនបានទើសទាក់ដោយរុក្ខជាតិ មាន វល្លិ៍ជាដើមនោះទេ ក្នុងចន្លោះសរធ្លាក់នោះ ក្នុងទីទំនេរជាកំណត់មិនបាន ឃ្លៀងឃ្លាត មិនបានខុសទិសដៅ យ៉ាងណា ព្រះញាណរបស់ព្រះ ពុទ្ធទាំងឡាយ ដែលពិចារណាទៅក្នុងជាតិទាំងឡាយ ដែលជា ចន្លោះៗ មិនបានឃ្លៀងឃ្លាត ក៏មានឧបមេយ្យដូច្នោះ ។ ព្រះញាណ ទៅចាប់យកនៅត្រង់ដែលព្រះអង្គប្រាថ្នាហើយនោះ មិនបានឃ្លៀង ឃ្លាត មិនខុស ។

បណ្តាបុគ្គលទាំងឡាយ ៦ ពួក ដែលរឭកបុព្វេនិវាសនេះ ពួកអន្យតិរ្ថិយឃើញនូវបុព្វេនិវាសក្លីប្រាកដ ដូចពន្លឺសត្វអំពិល

អំពេក ។ បកតិសាវ័កឃើញនូវបុព្វេនិវាសក្ខីប្រៀបដូចភ្លើងគប់ ។ ព្រះអគ្គសាវ័កទាំងពីរឃើញនូវបុព្វេនិវាសក្ខីប្រៀបដូចផ្កាយព្រឹក ។ ព្រះបច្ចេកពុទ្ធឃើញនូវបុព្វេនិវាសប្រៀបដូចពន្លឺព្រះចន្ទ ។ ព្រះពុទ្ធឃើញនូវបុព្វេនិវាសប្រៀបដូចពន្លឺព្រះអាទិត្យក្នុងសរទកាល ដែលប្រដាប់ទៅដោយពន្លឺខ្វាំងក្លា ។ ម្យ៉ាងទៀត ពួកអន្យតិរ្ថិយទាំងឡាយរឭកបុព្វេនិវាស ដូចមនុស្សខ្វាក់ទាំងឡាយកាន់ឈើច្រត់ ហើយទើបដើរទៅ ។ បកតិសាវ័កទាំងឡាយរឭកបុព្វេនិវាស ដូចដើរស្ពួលើស្ពានឈើមួយដើម ។ ព្រះអសីតិមហាសាវ័ករឭកនូវបុព្វេនិវាសដូចដើរទៅតាមផ្លូវបំបែក ។ ព្រះអគ្គសាវ័កទាំងពីររឭកនូវបុព្វេនិវាសដូចដើរទៅតាមស្ពានរទេះ ។ ព្រះបច្ចេកពុទ្ធដូចដើរតាមផ្លូវធំ ។ ព្រះពុទ្ធទាំងឡាយរឭកនូវបុព្វេនិវាស ដូចដើរទៅតាមផ្លូវធំដរាបស្មើជាផ្លូវបរវេ ត្រាច់ចរដោយពលពាហនៈជាអនេក សេចក្តីនេះអ្នកប្រាជ្ញទាំងឡាយគប្បីជ្រាបតាម **គម្ពីរវិសុទ្ធិមគ្គ** ។

បណ្តាឫទ្ធិទាំងឡាយដូចពោលមកនេះ ឫទ្ធិរបស់បុថុជ្ជននោះដែលបុគ្គលថែរក្សាបានដោយលំបាក ប្រៀបដូចទារកតូចនៅដេកផ្ងារក្នុងកន្ទុប ប៉ះពាល់តែបន្តិចក៏វិនាសភ្លាម ហេតុដូច្នោះ មនុស្សទាំង

ឡាយដែលបានឫទ្ធិរបស់បុថុជ្ជននោះ ហោះទៅខាងលើមហាសមុទ្រ និង ស្រះធំ កាលបើឫទ្ធិវិនាសសូន្យចាកសមាបត្តិ ក៏ភ្លាត់ធ្លាក់ចុះក្នុងទឹក អណ្ដែតត្រសែតប្រៀបដូចប៉ុយ-គ ឬប៉ុយសំឡី ធ្លាក់ចុះក្បែរមាត់ស្រះក្ដី ក្នុង **អដ្ឋកថាបរិវារញ្ជកវគ្គ មហាសកុលុទាយិសូត្រ** សម្ដែងថា បានឮ មកថា ព្រះថេរៈជាព្រះខីណាស្រពមួយរូបគិតថា យើងនឹងទៅថ្វាយបង្គំ ព្រះមហាចេតិយ និងព្រះមហាពោធិព្រឹក្ស ទើបមកកាន់មហាវិហារ ជាមួយនឹងសាមណេរមួយរូប ជាអ្នកកាន់នូវគ្រឿងបរិក្ខារ បាននូវ ឈានសមាបត្តិ ។ និមន្តចូលទៅកាន់មហាវិហារ ក្នុងវេលាល្ងាច ។ ភិក្ខុសង្ឃជាច្រើនរូបថ្វាយបង្គំព្រះមហាចេតិយ ព្រះខីណាស្រពនោះ ក៏បង្អង់សិន មិនទាន់នមស្ការព្រះចេតិយ ព្រោះហេតុអ្វី ? ព្រោះ ព្រះខីណាស្រពមានសេចក្ដីគោរព យ៉ាងខ្លាំងក្លាក្នុងព្រះរតនត្រ័យ ដូច្នោះ កាលបើភិក្ខុសង្ឃថ្វាយបង្គំ រួចហើយត្រឡប់ទៅវិញ ក្នុង វេលាដែលពួកមនុស្សបរិភោគអាហារពេលល្ងាច សូម្បីសាមណេរក៏ មិនឲ្យដឹង គិតថា អញនឹងទៅថ្វាយបង្គំព្រះមហាចេតិយ ទើបនិមន្ត ចេញទៅតែម្នាក់ឯងប៉ុណ្ណោះ ។ សាមណេរគិតថា វេលានេះ ជាវេលា មិនគួរ ហេតុអ្វី ព្រះថេរៈម្នាក់ឯង និមន្តទៅណា អាត្មាអញនឹងដឹងទី

ដែលលោកទៅ ទើបដើរតាមស្នាមជើងព្រះឧបជ្ឈាយ៍ទៅ ។ ព្រះថេរៈ មិនដឹងថា សាមណេរមកតាមទេ ព្រោះមិនគិត ទើបឡើងកាន់ទីលានព្រះមហាចេតិយតាមខ្លោងទ្វារខាងត្បូង ។ សាមណេរក៏ឡើងតាមស្នាមជើងនោះទៅ ។ ព្រះថេរៈសម្លឹងមើលព្រះមហាចេតិយបាននូវបីតិ មានពុទ្ធគុណជាអារម្មណ៍ សង្រួមចិត្តទាំងអស់ ត្រេកអរសោមនស្ស ថ្វាយបង្គំព្រះមហាចេតិយ សាមណេរឃើញអាការថ្វាយបង្គំរបស់ព្រះថេរៈ ទើបគិតថា ថ្ងៃនេះ ព្រះឧបជ្ឈាយ៍របស់អញមានចិត្តជ្រះថ្លាក្រៃលែង ថ្វាយបង្គំព្រះមហាចេតិយ ធ្វើដូចម្តេចទើបព្រះឧបជ្ឈាយ៍នឹងបានផ្កាដើម្បីធ្វើការបូជាហ្ន៎ ។ កាលព្រះថេរៈក្រោកឡើងថ្វាយបង្គំ លើកអញ្ជលីលើសិរសា ឈរសម្លឹងមើលព្រះចេតិយសាមណេរក៏គ្រហែមឲ្យព្រះថេរៈដឹងថា ខ្លួនមក ។ ព្រះថេរៈងាកមើលហើយ ហើយសួរថា លោកមកតាំងពីពេលណា ? សាមណេរតបថា ខ្ញុំព្រះករុណាមក កាលលោកម្ចាស់ថ្វាយបង្គំព្រះចេតិយ ហើយគិតថា ថ្ងៃនេះ ព្រះឧបជ្ឈាយ៍មានសេចក្តីជ្រះថ្លាក្រៃលែងណាស់ធ្វើដូចម្តេចហ្ន៎ ទើបព្រះឧបជ្ឈាយ៍នឹងបានផ្កាមកធ្វើសក្ការបូជា ។ ទើបព្រះថេរៈប្រាប់ថា ពិតហើយ លោកគិតត្រូវ ទីបញ្ចុះព្រះបរមធាតុ

ប្រមាណប៉ុណ្ណោះ ក្នុងទីដទៃៗ មិនមានឡើយ លើកលែងតែព្រះចេតិយក្នុងមហាវិហារនេះ បណ្តាមហាស្តូបដទៃ មិនស្មើមឹងមហាស្តូបនេះឡើយ ។ ដូចម្តេចហ្ន៎ ទើបបានផ្កាទាំងឡាយធ្វើសក្ការបូជាព្រះមហាចេតិយនេះ ។ សាមណេរក៏ជ្រាបអធ្យាស្រ័យរបស់ព្រះ-ឧបជ្ឈាយ៍ ទើបប្រាប់ថា សូមលោកម្ចាស់បង្អង់សិនចុះ ខ្ញុំព្រះករុណានឹងទៅបេះផ្កាយកមកប្រគេន ។ ក្នុងខណៈនោះ សាមណេរក៏ចូលឈានហោះទៅកាន់ព្រៃហិមពាន្ត បេះផ្កាបរិបូណ៌ដោយពណ៌ និងក្លិនដាក់ក្នុងធម្មក្រកទាល់តែពេញ ។ កាលព្រះថេរៈ មិនទាន់ងាកមុខចេញអំពីទិសខាងត្បូងផង សាមណេរក៏មកដល់វិញ ។ សាមណេរដាក់ធម្មក្រកក្នុងដៃព្រះថេរៈហើយ ពោលថា សូមលោកម្ចាស់បូជាព្រះចេតិយចុះ ។ ព្រះថេរៈពោលថា សាមណេរ ផ្ការបស់អ្នកតិចពេកណាស់ ។ សាមណេរពោលថា សូមលោកម្ចាស់ពិចារណារឭកដល់ព្រះពុទ្ធគុណហើយបូជាចុះ ។ ព្រះថេរៈឡើងកាន់ជណ្តើរទិសខាងលិចប្រារព្ធធ្វើការបូជាផ្កា ត្រង់ជើងវេទិកា ។ កាលនោះ ផ្កាទាំងឡាយក៏ពេញវេទិកា លិចវេទិកាដោយជុំវិញ ប្រមាណត្រឹមក្បាលជង្គង់ ហើយញ៉ាំងវល្ល័ង្គទាំងឡាយនោះឲ្យពេញបរិបូណ៌គ្រប់អន្លើ ទើបចុះមក

ជាន់ខាងក្រោម បាចសាចនូវផ្កាទាំងឡាយ ពេញលានព្រះចេតិយទាំងមូល ដោយអំណាចឫទ្ធិរបស់សាមណេរ ។ លំដាប់នោះ ទើបព្រះឧបជ្ឈាយ៍ពោលថា នែសាមណេរ ផ្ការបស់អ្នកមិនទាន់អស់ ។ សាមណេរតបថា សូមលោកម្ចាស់ ផ្កាប់ធម្មក្រកចុះក្រោម ហើយរលាស់ចេញផង ។ ព្រះថេរៈផ្កាប់ធម្មក្រក ហើយរលាស់ ។ ក្នុងកាលនោះផ្កាក៏អស់ទៅ ។ ព្រះថេរៈហុចធម្មក្រកដល់សាមណេរ ហើយធ្វើការប្រទក្សិណព្រះមហាចេតិយ អស់វារៈ ៣ ជុំ ថ្វាយបង្គំក្នុងទិសទាំង ៤ រួចហើយក៏ត្រឡប់ទៅកាន់បរិវេណ គិតថា **អយំ សាមណេរោ** សាមណេរនេះមានឫទ្ធិច្រើនណាស់ ក្នុងពេលក្រោយអាចរក្សានូវអានុភាពនេះទុកបាន ឬមិនបាន ក៏ពិចារណាឃើញថា មិនអាចរក្សាបាន ទើបពោលថា នែសាមណេរ ឥឡូវនេះអ្នកមានឫទ្ធិច្រើន តែអ្នកនឹងញ៉ាំងឫទ្ធិបែបនេះឲ្យវិនាសទៅ ក្នុងកាលជាខាងក្រោយ អ្នកនឹងបានបរិភោគបាយ ទឹក ដោយដៃរបស់ស្ត្រីតម្បាញក្អែកខ្វាក់ម្ខាង ដោយពិត ។ សាមណេរមិនបាននូវធម្មសង្វេគ មិនសូមនូវកម្មដ្ឋាន ដោយពាក្យរបស់ឧបជ្ឈាយ៍ ដែលគួរឲ្យកើតសង្វេគ នេះឈ្មោះថា ទោសរបស់សាមណេរដែលនៅក្មេង មិន

មែនជាការមិនស្តាប់ឱវាទ ។ កាលមហាថេរៈត្រឡប់មកហើយ ញ៉ាំង សាមណេរឲ្យកាន់នូវបាត្រ និងចីវរ ហើយទៅកាន់កុដេឡិតិស្សមហាវិហារដោយលំដាប់ សាមណេរក៏ដាប់តាមឧបជ្ឈាយ៍មក ។ លុះដល់ពេលត្រាច់បិណ្ឌបាត មិនបានទៅជាមួយឧបជ្ឈាយ៍ គិតថា ឧបជ្ឈាយ៍របស់អញទៅកាន់ទ្វារស្រុក ទើបកាន់បាត្រ និងចីវររបស់ខ្លួន និងរបស់ឧបជ្ឈាយ៍ហោះទៅតាមអាកាស ប្រគេនបាត្រ និងចីវរដល់ព្រះឧបជ្ឈាយ៍ ។

ព្រះថេរៈដាស់តឿនរឿយៗ ថា សាមរណេរ អ្នកកុំធ្វើដូច្នេះ ឈ្មោះថា ឫទ្ធិរបស់បុថុជ្ជនមិនរឹងមាំ មិនពិតប្រាកដ គ្រាបានអារម្មណ៍មានរូបជាដើម មិនជាទីសប្បាយត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ក៏បែកធ្លាយបាន ។ កាលបើវិនាសចាកសមាបត្តិហើយ មិនតាំងនៅក្នុងព្រហ្មចរិយៈបានឡើយ សាមណេរមិនប្រាថ្នានឹងឱវាទរបស់បជ្ឈាយ៍ឡើយ **តថេវ ករោតិ** ក៏នៅតែលេងឫទ្ធិនោះឯង ។

ថ្ងៃមួយ ធីតារបស់ជាងតម្បាញម្នាក់ មានរូបស្អាត នៅក្នុងបឋមវ័យ ចេញចាកស្រុកកម្ពពិន្ទុៈ ចូលទៅកាន់ស្រះឈូក ស្រែកច្រៀងបេះផ្កាឈូក ។ក្នុងសម័យនោះ សាមណេរហោះអំពីខាងលើ

ស្រះឈូកនោះ ជាប់ចិត្តនូវសំឡេងស្រែកច្រៀងរបស់កុលធីតា ប្រៀបដូចរុយខ្វាក់ភ្នែកហើរទៅជាប់សំណាញ់ពីងពាង ។ ក្នុងគ្រានោះ ឫទ្ធិរបស់សាមណេរក៏អន្តរាធាន ប្រាកដដូចក្អែកបាក់ស្លាប ។ តែដោយផលរបស់សមាបត្តិនៅមាន មិនធ្លាក់ទៅលើផ្ទៃទឹកនោះទេ ធ្លាក់ចុះដូចប៉ុយរកាដោយលំដាប់ ។ បានឈរនៅក្បែរមាត់ស្រះឈូក ។ សាមណេរប្រញាប់ទៅប្រគេនបាត្រ និងចីវរចំពោះព្រះឧបជ្ឈាយ៍ ហើយត្រឡប់មកវិញ ។ ព្រះថេរៈគិតថា អាត្មាយល់ហេតុការណ៍មកអំពីមុនហើយ សូម្បីហាមសាមណេរក៏គង់មិនវិលត្រឡប់មកវិញ ទើបមិននិយាយអ្វី បន្ទាប់មកក៏និមន្តទៅបិណ្ឌបាត ។ សាមណេរទៅឈរនៅត្រង់មាត់ស្រះឈូក រង់ចាំស្រីនោះឡើងមក ។ សូម្បីស្រីនោះ ក៏បានឃើញសាមណេរទាំងខណៈហោះ ទាំងខណៈមកឈរក៏ដឹងថា សាមណេរនេះស្រើបស្រាលព្រោះអាស្រ័យអញពិត ទើបពោលថា សូមគេចចេញទៅសាមណេរ ។ ទើបសាមណេរនោះគេចចេញទៅស្រីនោះឡើងមកផ្លាស់សំពត់ហើយ ចូលទៅរកសាមណេរសួរថា ហេតុអ្វី ទើបលោកមកទីនេះ ? សាមណេរប្រាប់ថា អាត្មាស្រឡាញ់ចំពោះនាងពន់ពេក ។ កុលធីតានោះមានបញ្ញា ក៏សម្តែង

ទោសក្នុងការគ្រប់គ្រងផ្ទះដោយហេតុច្រើនយ៉ាង និងអានិសង្ស ក្នុងការនៅប្រព្រឹត្តព្រហ្មចរិយៈ ។ សូម្បីអប់រំក្រើនរំលឹកយ៉ាងណា ក៏មិនសាមណេរមិនអាចបន្ទោបង់នូវសេចក្តីស្រឡាញ់នោះបាន ។ ទារិកានោះគិតថា សាមណេរនេះវិនាសបព្វជ្ជដូច្នេះ ព្រោះអញជាហេតុ ឥឡូវនេះ មិនគួរនឹងលះបង់ទេ ទើបពោលថា សាមណេរ សូម លោកនៅចាំទីនេះសិនចុះ រួចហើយ ធីតានោះទៅផ្ទះ ជម្រាបរឿង នោះដល់មាតាបិតា ។

សូម្បីមាតាបិតាមកហើយ ពោលអប់រំក្រើនរំលឹកច្រើនយ៉ាង ជាមួយនឹងសាមណេរ ។ សាមណេរមិនស្តាប់ មាតាបិតារបស់ កុលធីតានោះពោលថា លោកកុំយល់ថា ខ្ញុំមានត្រកូលខ្ពង់ខ្ពស់ ។ ពួកខ្ញុំត្រឹមតែជាជាងតម្បាញ តើលោកនឹងធ្វើអ្វីកើត សាមណេរ ប្រាប់ថា ការត្បាញក្តី ការធ្វើជាជាងផែងក្តី អាត្មាអាចធ្វើបាន អ្នកមិនចង់ឲ្យសាជកដល់អាត្មាទេដឹង ។គ្រានោះ បុរសជាងតម្បាញ ក៏ស្រាយសំពត់ក្រវាត់ចង្កេះហុចឲ្យដល់ធីតា កាលសាមណេរលាភេទ បព្វជិត ស្លៀកដណ្តប់សមគួរដល់ភេទគ្រហស្ថហើយ ក៏រៀនការងារ របស់ជាងតម្បាញ ធ្វើការងារនៅរោងជាងតម្បាញ ជាមួយនឹង

ពួកជាងត្បាញដទៃ ។ បណ្តាភរិយារបស់ជាងតម្បាញដទៃៗ ឯទៀត បានរៀបចំម្ហូបអាហារនាំមកតាំងអំពីព្រឹក ។ ភរិយារបស់បុរសនោះ នៅមិនទាន់មកដល់ បុរសនោះកាលអ្នកដទៃសម្រាកអំពីការងារ អង្គុយ បរិភោគអាហារ ក៏នៅអង្គុយបោះត្រល់ ។ ភរិយាបានទៅដល់ ក្រោយគេ ទើបបុរសនោះនិយាយគំហកដល់ភរិយាថា នាងមកយឺតយូរ ហួសវេលា ។ ធម្មតាមាតុគ្រាមដឹងថា សូម្បីស្វាមីជាក្សត្រក្តី ដែល មានចិត្តស្រឡាញ់ស៊ប់ចំពោះខ្លួន ក៏សម្គាល់កំណត់ស្វាមីដូចគ្នានឹងទាសៈ ព្រោះដូច្នោះ ទើបនាងពោលថា ក្នុងផ្ទះរបស់អ្នកដទៃគេសន្សំឧស បន្លែ អំបិលទុក ។ មួយទៀត ទៅធ្វើជំនួញ ( លក់ដូរ ) នាំមកនូវ ទាសកម្មករអ្នកបម្រើ ទើបបានធូរកម្លាំងភរិយា ឯខ្លួនខ្ញុំតែម្នាក់ឯង ប៉ុណ្ណោះ អ្នកមិនដឹងទេឬ ក្នុងផ្ទះរបស់យើង វត្ថុនេះមាន វត្ថុនេះ មិនមាន ។ ប្រសិនបើអ្នកត្រូវការ ក៏ចូរបរិភោគចុះ បើមិនត្រូវការទេ កុំបរិភោគអី ។ បុរសនោះនិយាយគំហកថា នាងមិនត្រឹមតែនាំអាហារ មកយូរប៉ុណ្ណោះទេ ថែមទាំងនិយាយបញ្ឆោះឲ្យយើងទៀត ។ បុរសនោះ ខឹងណាស់ កាលអ្វីមិនមាន ទើបទាញកញ្ចក់ត្រល់ រួចហើយគ្រវែង ទៅ ។ ភរិយាឃើញត្រល់ដែលស្វាមីគ្រវែងតម្រង់មក ទើបងាកចេញ

បន្តិច ចុងត្រល់នោះមុតត្រូវខាងចុងភ្នែកម្ខាង ។ ទើបនាងយកដៃទាំងពីរទៅខ្ទប់ភ្នែក ហើយរត់ទៅ ហូរឈាមចេញអំពីកន្ទែងរបួស ក្នុងកាលនោះ បុរសដែលជាស្វាមី ទើបរឭកដល់ពាក្យរបស់ព្រះឧបជ្ឈាយ៍ថា ព្រោះអាស្រ័យហេតុនេះពិតប្រាកដ ទើបពោលជាមួយនឹងអញថា ក្នុងអនាគតអ្នកនឹងត្រូវបរិភោគទឹកបាយ របស់ស្រីខ្វាក់ អហោ គួរអស្ចារ្យហ្ន៎ ឧបជ្ឈាយ៍របស់អញជាអ្នកឃើញកាលវែង ។ កាលបុរសនឹកដល់ពាក្យរបស់ឧបជ្ឈាយ៍ដូច្នោះ ក៏ស្រែកយំដោយសំឡេងខ្លាំង ។ ពួកជាងតម្បាញដទៃៗ បានពោលជាមួយនឹងបុរសនោះថា ល្មមឈប់យំប៉ុណ្ណឹងចុះអ្នក ចម្ងតាភ្នែកដែលខ្វាក់ហើយ មិនអាចធ្វើឲ្យដូចដើមវិញបានដោយការយំនោះទេ ។ បុរសនោះពោលថា ខ្ញុំមិនបានយំព្រោះរឿងនោះទេ ប៉ុន្តែខ្ញុំយំសំដៅដល់ហេតុនេះ ដូច្នេះហើយ និយាយប្រាប់រឿងទាំងអស់ តាមលំដាប់ ។

វិប្បដិសារ ដែលជារបស់បុថុជ្ជន រមែងញាប់ញ័រ ដូច្នេះឯប្បដិសារព្រះអរិយៈទាំងឡាយនោះ មិនមានការឃ្លៀងឃ្លាតឡើយ ។

ឥន្ទិកថា ចប់

# លោកសណ្ឋានកថា

*លំដាប់នេះនឹងឆ្លើយក្នុងអន្ទិមមាតិកា គឺលោកសណ្ឋាននោះតទៅ មានបញ្ហាចោទសួរក្នុងមាតិកានេះពិភាក្សាលោកវិនាស និងកើតឡើង ទើបឈ្មោះថា លោកសណ្ឋាន ។* **តត្ថ មហាន្តេសុ ចក្កវាឡេសុ** *បណ្តាចក្កវាឡជាច្រើន រឺចក្កវាឡមួយ* **អាយមតោ** *ចក្កវាឡមួយ បើវាស់ទទឹង ( វិជ្ឈមាត្រ ) មានប្រមាណ ១២ សែន ៣ ពាន់ ៤ រយ ៥០ យោជន៍ជាកំណត់ បើវាស់ទំហំជុំវិញ មានប្រមាណ ៣៦ សែន ១០ ពាន់ ៣ រយ ៤០ យោជន៍ជាកំណត់* **ពហាលត្តេន សង្ខាតា** *បើនឹងកំណត់រាប់ដោយកម្រាស់ បាន ២ សែន ៤ ម៉ឺន យោជន៍ ប្រតិស្ឋាននៅលើទឹកៗ ដែលទ្រផែនដីនោះ មានកម្រាស់ ៤ សែន ៨ ម៉ឺនយោជន៍ជាកំណត់ ប្រតិស្ឋាននៅលើខ្យល់ៗ ដែលទ្រទឹក មានកម្រាស់ ៩ សែន ៦ ម៉ឺនយោជន៍ជាកំណត់ ប្រាកដ មានគ្រប់ចក្រវាលដូចគ្នាទាំងអស់* **ឯវំ សណ្ឋិតេ** *ក្នុងកាលលោក សន្និវាស ពោល គឺចក្កវាឡនោះ បើប្រតិស្ឋានតាំងនៅដូច្នេះហើយៗ ក៏វិនាស ។ កាលបើវិនាសនោះ វិនាសដោយហេតុ ៣ ប្រការ*

មានភ្លើងជាដើម ។ **ចត្តារិ អសង្ខេយ្យានិ** មានអសង្ខេយកប្ប ៤ គឺសំវដ្តអសង្ខេយ្យ ១ សំវដ្តដ្ឋាយីអសង្ខេយ្យ ១ វិវដ្តអសង្ខេយ្យ ១ វិវដ្តដ្ឋាយីអសង្ខេយ្យ ១ ទើបជា ១ មហាកប្ប ។ សំវដ្តអសង្ខេយ នោះ មានអត្ថថា កាលដែលវិនាសនោះ ជាអសង្ខេយ្យដោយអត្តនោមត្យាធិប្បាយ សំវដ្តដ្ឋាយីនោះ មានអត្ថថា កាលដែលវិនាសនោះ តាំងនៅជាអសង្ខេយ្យ វិវដ្តនោះ ប្រែថា កើត ឬចម្រើន ។ វិវដ្តដ្ឋាយីនោះ ប្រែថា កាលដែលតាំងនៅនៃសេចក្តីចម្រើន **តត្ថ អសង្ខេយ្យេសុ** បណ្តាអសង្ខេយ្យទាំងឡាយ ៤ នោះ រីសំវដ្តអសង្ខេយ នោះ មាន ៣ យ៉ាង គឺតេជោសំវដ្តៈ ១ អាបោសំវដ្តៈ ១ វាយោសំវដ្តៈ ១ ។ **តិស្សោ សំវដ្តសីមាយោ** កាលលោកសន្និវាសសែនកោដិលោកធាតុទឹងវិនាសដោយភ្លើង ទឹក និងខ្យល់នោះ មានព្រំដែនជាទីកំណត់ **យទា កប្បោ តេជេន សំវដ្តតិ** ឯលោកធាតុវិនាសដោយភ្លើងនោះ ភ្លើងឆេះឡើងទៅទល់អាភស្សរាព្រហ្ម ទីទាំងនោះត្រូវសូន្យទទេ ។ បើវិនាសដោយទឹកៗ ក៏ជន់ឡើងទៅទល់ជាន់សុភកិណ្ហព្រហ្មចុះមក ។ បើវិនាសដោយខ្យល់ៗ បក់ឲ្យលោកវិនាសតាំងអំពីខាងក្រោមវេហប្ផលាព្រហ្មចុះមក ចំណែកចក្កវាឡជុំវិញ ក៏

វិនាសដោយភ្លើង ទឹក ខ្យល់ តាមពុទ្ធក្ខេត្ត គឺមួយសែនកោដិចក្កវាឡ ។ **តស្មឹ វិនស្សន្តេ** ក្នុងអាណាខេត្តសែនកោដិចក្កវាឡនោះវិនាសអស់ហើយ ជាតិខេត្តចក្កវាឡនោះក៏វិនាសទៅឯង ។ **ឯកតោ វិនស្សន្តិ** កាលទីងវិនាសក៏វិនាសព្រមគ្នា **អស្មិ សមយេ អគ្គិនា នស្សតិ** កាលលោកសន្និវាសវិនាសដោយភ្លើងនោះ កប្បវិនាសមហាមេឃតាំងឡើងមុន ភ្លៀងក៏ធ្លាក់ចុះទូទាំងសែនកោដិចក្កវាឡ អ្នកស្រុកនាំគ្នារីករាយសប្បាយក្នុងចិត្ត ចាត់ចែងនង្គ័ល រនាស់សាបព្រោះស្រូវព្រមគ្នា ។ ប៉ុន្តែកាល សាបព្រោះស្រូវដុះលូតលាស់ចម្រើនឡើង ល្មមគោក្របីស៊ីបាន កប្បវិនាស មហាមេឃនោះក៏មានសំឡេងលាន់ឮ ដូចសម្រែកសត្វលាយំ តាំងអំពីនោះមក សូម្បីភ្លៀងមួយតំណក់ក៏មិនមាន **ហោតិ ខោ ភិក្ខវេ សមយេ** អាស្រ័យមិនមានភ្លៀងដូច្នេះ ទើបព្រះសម្មាសម្ពុទ្ធត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ នាកាលមហាមេឃមានសំឡេង លាន់ឮឡើងដូចសម្រែកសត្វលាយំនោះ តាំងអំពីនោះមក ភ្លៀងក៏មិនធ្លាក់អស់រយសែនឆ្នាំជាច្រើន **វស្សូបជីវិនោ** បណ្តាសត្វទាំងឡាយដែលអាស្រ័យទឹកភ្លៀងចិញ្ចឹមជីវិតរបស់ខ្លួននោះ ក៏ធ្វើកាលកិរិយាទៅកើតក្នុងបរិត្តា

ព្រហ្មទាំងអស់ **បុប្ផជលូបជីវិនោ** សត្វទាំងឡាយដែលអាស្រ័យផ្កា និងផ្លែឈើចិញ្ចឹមជីវិត ក៏ស្លាប់ទៅកើតក្នុងព្រហ្មលោកទាំងអស់ ។ **ឯវំ ទីឃេ អទ្ធានេ** ការប្រព្រឹត្តទៅដូច្នេះ កន្លងជាយូរអង្វែងទៅ បណ្តាទឹកដែលមាននៅក្នុងប្រឡាយ អណ្តូង ស្រះ អូរ បឹង ក៏រីងស្ងួតទាំងអស់ ពួកត្រី អណ្តើកក៏ស្លាប់ ទៅកើតព្រហ្មលោកទាំងអស់ ។ **តត្ថ នេរយិកសត្តា** បណ្តាសត្វកើតក្នុងព្រហ្មលោក សត្វនរកទាំងឡាយ ដែលវិនាសព្រមគ្នានឹងកាល កើតឡើងនៃព្រះអាទិត្យរះ ៧ ដួងនោះ ក៏ទៅកើតព្រហ្មលោកដូចគ្នា ។

**ឈានំ បន វិនា នត្ថិ** ទើបមានពាក្យជាកថេតុកម្យតា-បុច្ឆាថា សត្វទាំងឡាយដែលកើតក្នុងព្រហ្មលោកនោះ ក៏អាស្រ័យបានចំពោះឈានសមាបត្តិ **កេសញ្ចិ** សត្វពួកខ្លះស្លាប់ដោយទុរ្ភិក្សក្តី សត្វពួកខ្លះជាអកុសលបុគ្គល មិនមានឈានសមាបត្តិក្តី ដូចម្តេចទើបទៅកើតក្នុងព្រហ្មលោកបាន ?

**ទេវលោកេ បដិលទ្ធឈានវសេន** ឆ្លើយថា សត្វលោកនេះ ស្លាប់អំពីមនុស្សហើយ ទៅកើតក្នុងជាន់ឥកាមាវចរ បាននូវឈានហើយ ទើបឡើងទៅកើតក្នុងព្រហ្មលោក **តថា ហិ** ពាក្យ

ធ្វើយនេះ ត្រូវពិតមែនហើយ សមគួរដល់ពាក្យខាងដើម **ជកា-មាវចរទេវា** វីទេវតាក្នុងឆកាមាវចរមានឈ្មោះថា លោកព្យុហៈ ជាសភាវៈលោកធម្មតា ដាស់តឿនជម្រុញចិត្តឲ្យដឹងពិតថា កន្លង ទៅមិនយូរ មួយសែនឆ្នាំទៀត នឹងកើតមានកប្បវិនាស **មុត្តសិរោ** ស្រាយចេញនូវផ្នួងសក់ **វិកិណ្ណកេសា** មានសក់រំសាយ មានក្អែក ទាំងពីរចម្រើនដោយទឹកភ្នែក យំរៀបរាប់ ដៃទាំងពីរជូតទឹកភ្នែក ដែលហូរមក **អត្តិវិយ វិរូបវេសធារិនោ** មានកាយវិកលគួរស្ដុត នាំគ្នាដើរទៅតាមផ្លូវមនុស្ស រួចហើយ ទើបបន្លឺកប្រកាសថា **មារិស** អ្នកទាំងឡាយនឹងដល់នូវសេចក្ដីវិនាសស្មើគ្នា តាំងអំពីនេះតទៅ មួយ សែនឆ្នាំទៀត នឹងកើតកប្បវិនាស មហាមេឃ និងលោកធាតុទាំង-ឡាយក៏នឹងសាបសូន្យទៅ ។ **អយញ្ច មហាបឋវី** ផែនដី និង ភ្នំសិនេរុ ភ្លើងនឹងដុត វិនាសរហូតដល់ព្រហ្មលោក **មេត្តំ ភាវេថ** យើងទាំងឡាយចូរកុំប្រមាទ ចូរនាំគ្នាចម្រើននូវព្រហ្មវិហារ មានមេត្តា ជាដើម ចូរបម្រើមាតា បិតា និងគោរពកោតក្រែងត្រកូលរៀមច្បង ។

បានឮមកថា គ្រានោះ ពពួកមនុស្សទាំងឡាយ ទាំងសែន កោដិលោកធាតុ បានស្ដាប់ពាក្យលោកព្យុហៈប្រកាស មនុស្សទាំង

នោះនូវធម្មសង្វេគ មានចិត្តទោរទន់ ផ្សាយមេត្តាដល់គ្នានិងគ្នា បំពេញនូវកុសល ស្លាប់ទៅកើតក្នុងកាមាវចរ ហើយចម្រើនវាយោកសិណ ញ៉ាំងឈានសមាបត្តិឲ្យកើត ហើយទៅកាន់ក្នុងព្រហ្មលោក ។ **តទញ្ញេ** សត្វដែលកើតក្នុងអបាយ ក្រៅអំពីទេវតា និងមនុស្ស ក៏ទៅកើតក្នុងកាមាវចរ ដោយអបរាបរិយវេទនីយកម្ម **សំសារេ សំសរន្តោ** ឈ្មោះថា សត្វទាំងឡាយដែលត្រាច់រន្ធាត់នៅក្នុងសង្សារវដ្តនេះ ដែលនឹងមិនមានអបរាបរិយវេទនីយកម្មនោះមិនមាន ។ **តេបិ តត្ថ ឈានំ** លុះសត្វទាំងឡាយស្លាប់ពីអបាយភូមិហើយ បានទៅកើតក្នុងស្ថានសួគ៌ បានឈានក្នុងទីនោះ ក៏ទៅកើតក្នុងព្រហ្មលោកទាំងអស់ **យេភុយ្យវសេន វុត្តំ** សម្តែងសេចក្តីដោយយេភុយ្យន័យ ព្រះអដ្ឋកថាចារ្យអធិប្បាយថា អបាយិកសត្វ គឺសត្វនរក ប្រេត អសុរកាយ និងតិរច្ឆាន ស្លាប់អំពីអបាយហើយ ក៏ទៅកើតក្នុងចក្រវាលដទៃ ដែលមិនវិនាសនោះមិនមាន **វស្សូបច្ឆេទតោ** តាំងអំពីលោកធាតុមិនមានភ្លៀងធ្លាក់មកអស់កាលកន្លះខែ ទើបកើតព្រះអាទិត្យ ២ ដួង **តស្មិំ នេវ រត្តិ បរិច្ឆេទោ** ក្នុងកាលព្រះអាទិត្យកើតឡើង ២ ដួងនោះ រីកិរិយាដែលកំណត់កាលថា ជាថ្ងៃ និងយប់

នោះមិនមាន ដោយព្រះអាទិត្យ ១ ដួងលិចទៅ ១ ដួង ទៀតក៏រះឡើង ភ្លឺរហូត ក្តៅរហូត **យថា ច កប្បវុដ្ឋានកាលេ** កាលអសង្ខេយ្យកប្បចម្រើននោះ មានព្រះសុរិយទេវបុត្រកើតប្រចាំនៅក្នុងសុរិយវិមាន អសង្ខេយ្យកប្បវិនាសនោះមិនមានទេវបុត្រប្រចាំទេ ។ **បភស្សរតោ តេជវន្តតរោ** ចំណែកសុរិយមណ្ឌលវិមានមាសនោះសោត ក៏មានតេជះផូរផង់រុងរឿង ដោយវិសេសក្រៃលែងជាងសុរិយវិមានធម្មតា ។ កាលបើសុរិយវិមាននោះ បំភ្លឺលោកជាប្រក្រតីនោះ ផ្ទៃមេឃមានមេឃវលាហកៈ និងផ្សែងខ្មួលខ្មាញ់ អណ្តែតត្រសែតទៅលើផ្ទៃមេឃ ប្រាសចាកពពក ពន្លឺរបស់សុរិយវិមាននោះប្រាសចាកមន្ទិលរុងរោចន៍ ហាក់បីដូចជាកញ្ចក់ **ឋបេត្វា បញ្ច-មហានទិយោ** អាស្រ័យហេតុដូច្នេះ ស្ទឹងតូចៗ ដ៏សេស លើកលែងតែស្ទឹងធំៗ ទាំង ៥ គឺគង្គា យមុនា អចិរវតី មហី មហាសរភូ ក្រៅអំពីនោះហើយ ក៏រីងស្ងួតហួតហែងគ្រប់កន្លែង **តតោ ទីឃស្ស អទ្ធុនោ** តាំងអំពីព្រះអាទិត្យកើតឡើង ២ ដួងហើយ កាលកន្លងយូរមក ទើបកើត ១ ដួងទៀតជាគម្រប់ ៣ ដួង ទឹកក្នុងស្ទឹងទាំង ៥ ក៏រីងស្ងួតអស់ **ចតុត្ថោ សុរិយោ** កាលកន្លងទៅបានកន្លះខែ

ទើបកើត ១ ដួងទៀតជាគម្រប់ ៤ ដួង **ហិមវតីមហានទីធំ បកវា** ស្រះធំទាំង ៧ មានអនោតត្តស្រះជាដើម ដែលជាប្រភពនៃស្ទឹងទាំង ៥ នោះ ក៏រីងស្ងួតអស់ **តតោបិ ទីឃសូរ្យ អច្ចយេន** តាំងអំពីព្រះអាទិត្យ ៤ ដួងកើតឡើងហើយ កន្លងមកយូរអង្វែង ទើបកើត ១ ដួងទៀតជាគម្រប់ ៥ ដួង ។ កាលបើព្រះអាទិត្យជាគម្រប់ ៥ ដួងកើតឡើងនោះ ទឹកក្នុងមហាសមុទ្រក៏រីងស្ងួតអស់ មិនទៅសល់ត្រឹមតែ ១ ទូកដៃ ចាប់តាំងអំពីព្រះអាទិត្យកើតឡើង ៥ ដួងនោះអស់កាលយូរទៅ ទើបកើត ១ ដួងទៀតជាគម្រប់ ៦ ដួង ។ កាលបើព្រះអាទិត្យជាគម្រប់ ៦ ដួងកើតឡើង លោកទាំងឡាយ ក៏ក្លាយជាដុំផ្សែងទាំងអស់ **បរិយាទិណ្ណសិនេហាំ** ផែនដី និងភ្នំទាំងឡាយក៏អស់ជាតិក៏អស់ជ័រ គ្មានទឹកខ្វែងណាសើមប៉ុន្តែចក្រវាលដទៃមានបរិមណ្ឌលរណបមណ្ឌលចក្កវាឡនេះប្រមាណសែនកោដិជាទីបំផុត ជាដុំផ្សែងដូច្នេះជាច្រើនរយឆ្នាំ ទើបកើត ១ ដួងទៀត ជាគម្រប់ ៧ ដួង ។ **យស្ស ធាតុភាវ** នាកាលព្រះអាទិត្យកើតឡើងជាគម្រប់ ៧ ដួងដូច្នោះ លោកធាតុមួយសែនកោដិ សន្ធោសន្ធៅដោយអណ្តាតភ្លើងព្រមគ្នាបន្លឺនូវសំឡេងលាន់ឮឡើង គួរតក់ស្លុត ។ **យោជនសតិកា-**

**ធិភេធា** កំពូលភ្នំសិនេរុរាជ កំពូលភ្នំកណ្តាប់ចក្រវាលផ្សេងៗក្នុងទី
១០០ យោជន៍ជាដើម ក៏បាក់រលំ ខ្ទាត់ខ្ទាយសាបសូន្យទៅក្នុងអាកាស
**សា ច អគ្គិជាលា** អណ្តាតភ្លើង ប្រល័យលោកផ្តើមអំពីមនុស្ស
នេះមុន ហើយក៏រាលដាលឡើងទៅ ចាប់យកនូវចាតុម្មហារាជិកា-
ទេវលោក ប្រហារនូវវិមានប្រាក់ វិមានមាស វិមានកែវឲ្យទ្រោម
វិនាសទៅ ហើយក៏រាលដាលទៅស្ថានតាវត្តិង្ស យាមា ហើយក៏
ចូលជាលំដាប់ទៅ ចាប់ឆេះប្រឹថពីមានប្រមាណដល់បឋមជ្ឈានភូមិ
ទាំង ៣ ទល់គ្នានឹងអាភស្សរព្រហ្មហើយ ក៏ឈប់ៗ **យាវ អនុ-
មត្តម្បិ សង្ខារគតំ** សព្វសង្ខារមានប្រមាណប៉ុនអាណូ នៅសល់
ដរាបណា ភ្លើងប្រល័យក៏នៅតែឆេះដរាបនោះ **សព្វសង្ខារ បរិក្ខយា
បង** កាលសព្វសង្ខារមានប្រមាណប៉ុនអាណូមិនមានហើយ រីភ្លើង
ដែលដុតលោកឲ្យវិនាសនោះក៏រលត់ៗ **ហេដ្ឋា អាកាសេង** អាកាស
ខាងក្រោម និងអជដាកាសខាងលើនោះក៏ចូលគ្នាតែមួយ មានភាព
ងងឹតអព្ទុសូន្យសុងទាំងអស់ **ឯកន្ធការំ ហុត្វា ឋិតេ** ឯលោក-
សន្និវាសដល់នូវសេចក្តីវិនាស អាកាសចូលគ្នាតែមួយហើយ ទើប
កើតលោកសណ្ឋាន មហាមេឃតាំងឡើងញាំងភ្លៀងឲ្យធ្លាក់ចុះគ្រប់

កន្លែង តំណក់គ្រាប់ភ្លៀងមិនធំ មានប្រមាណប៉ុនតំណក់ទឹកសន្សើម ក្នុងសរទកាល ដូចគ្នានឹងរដូវវស្សា គ្រាប់ភ្លៀងនោះក៏ធំឡើងៗ ជាលំដាប់ ។ មុនដំបូងប៉ុនតំណក់ទឹកសន្សើម បន្ទាប់មកប៉ុនទងផ្កាកម្ពុទ ប៉ុនអង្រែ ប៉ុនសសរ ប៉ុនដើមត្នោត ពេញអស់នៅក្នុងសែនកោដិចក្រវាល ដែលភ្លើងទៅដល់នោះ ។ **តំ ឧទកំ ហេដ្ឋា** ខាងក្រោមនោះក៏កើតខ្យល់បក់ទ្រទឹកភ្លៀង មិនឲ្យលិចចុះទៅខាងក្រោមបាន មានឧបមេយ្យដូចតំណក់ទឹកនៅលើស្លឹកឈូក អានុភាពដែលខ្យល់បក់នោះខ្លាំងក្លា បក់ទឹកឡើងមកធ្វើឲ្យកកជាដុំ **ហេដ្ឋា ឱតរតិ** ខាងក្រោមនោះកកដោយលំដាប់ៗ **ទេវលោកា ធាតុភវន្តិ** កាលបើទឹកកកដល់ស្ថានព្រហ្មលោកៗ ក៏កើតឡើង កាលទឹកស្រកមកដល់ស្ថានកាមាវចរទេវលោកៗ ទាំង ៤ ក៏កើតឡើង នៅតែជាន់តាវត្តិង្សនិងជាន់ចាតុម្មហារាជិកា ព្រោះហេតុអ្វី ព្រោះថា ទេវលោកទាំងពីរនេះ ជាផ្ទៃដែលជាប់គ្នានឹងផែនដីចក្រវាល **បុរិមបឋវិដ្ឋានំ ឱតិណ្ណោ** កាលទឹកភ្លៀងកកធ្លាក់ចុះមក ក៏កើតមានខ្យល់ ដែលមានកម្លាំងខ្លាំងក្លា **និរុស្សាលំ កត្វា រុន្ធន្តិ** មកបក់ក្រសោបទ្រទឹក **ធម្មករកេបិតឧទកំ វិយ** មានឧបមេយ្យដូចជាទឹកក្នុងធម្មក្រកក៏ដូច្នោះ **ឧបរិ–**

**រសបថវី** តាំងអំពីនោះទៅទឹកក៏ជ្រាបចូល ញុំាងរសផែនដីឲ្យកើតឡើង អណ្តែតនៅលើទឹក **ឧប្បលបត្តំ វិយ** ដូចស្លឹកឧប្បលអណ្តែតលើទឹក **សាចកណ្ណិការបុប្ផំ ឥវ** ផែនដីនោះមានសម្បុរលឿងដូចផ្កាកណិការ មានក្លិនក្រអូប មានរសផ្អែម ស្ថិតនៅលើផ្ទៃទឹក **ឯត្ថ បឋវិបទេសេសុ** បណ្តាដុំផែនដីទាំងឡាយនោះ រីផែនដីជាទីតាំងនៃពោធិបល្ល័ង្កនោះ កាលនឹងវិនាស ក៏វិនាសក្រោយគេបំផុត កាលកើតឡើងក៏កើតមុនគេ **តត្ថ បុព្វនិមិត្តំ** ទីនោះ ជាទីអស្ចារ្យ មានដុះផ្កាឈូកមួយគុម្ព ផុសឡើងមុនជាបុព្វនិមិត្ត បើអសង្ខេយ្យកប្បនោះមានព្រះពុទ្ធកើតឡើង ឈូកគុម្ពនោះក៏មានផ្កា ។ បើព្រះពុទ្ធកើតមួយព្រះអង្គ ឈូកក៏មានផ្កាមួយទង ព្រះពុទ្ធពីរព្រះអង្គ ឈូកក៏មានផ្កាពីរទង ព្រះពុទ្ធបីព្រះអង្គ ឈូកក៏មានផ្កាបីទង ព្រះពុទ្ធបួនព្រះអង្គ ឈូកក៏មានផ្កាបួនទង ព្រះពុទ្ធប្រាំព្រះអង្គ ឈូកក៏មានផ្កាប្រាំទង ។ **តទាមហាព្រហ្មា** គ្រានោះ មានតែមហាព្រហ្មមួយ ពួកទេបានដឹង បានឃើញ **សចេ បស្សន្តិ** បើមហាព្រហ្មបានឃើញផ្កាឈូក ក៏មានចិត្តរីករាយ បើមិនឃើញបានវិញ ក៏ស្ងួតចិត្ត បន្លឺនូវវាចាថា **ឆស្សតិ វត ភោ លោកោ** ពួកយើងអើយ លោកនឹងវិនាស

គ្មានទីពឹង រតនៈប្រហទីបមិនមានដើម្បីនឹងបំភ្លឺលោក ក៏ដល់នូវការសោកសៅរន្ធត់ចិត្ត **តទា ច អាភស្សរព្រហ្មលោកេ** ក្នុងគ្រានោះសត្វទាំងឡាយដែលបានកើតនៅក្នុងអាភស្សរពិភពនោះ ចុតិចុះមកដោយអស់បុណ្យអស់អាយុ ចុះមកកើតមុនគេ ជាឱបបាតិក-កំណើត មនុស្សទាំងនោះហោះហើរដើរទៅក្នុងអាកាសបាន មានពន្លឺភ្លឺចេញអំពីកាយរៀងៗ ខ្លួន **តំ រសបឋវី សាសយិត្វា** កាលកន្លងយូរទៅបានស្រូបលិទ្ធភ្លក្សនូវរសផែនដី **តណ្ហាភិភូតា** រសតណ្ហាបានគ្របសង្កត់ក៏ញុំាំងសេចក្តីព្យាយាម ដើម្បីនឹងបរិភោគនូវរសផែនដី ។ តាំងអំពីនោះមក រស្មីកាយក៏អស់ទៅ ភាពងងឹតក៏កើតឡើង ។ មនុស្សទាំងឡាយក៏ភ័យតក់ស្លុត មានភ័យជាកម្លាំង **តតោ តទនន្តរំ** លំដាប់នោះ ព្រះអាទិត្យក៏កើតប្រាកដឡើង មានបរិ-មណ្ឌលពេញ ៥០ យោជន៍ អណ្តែតទៅឰដ៏អាកាសគ្រប់លោកធាតុ

**តេ តំ ទិស្វា** ឯមនុស្សទាំងឡាយ បានឃើញព្រះអាទិត្យដែលបំភ្លឺលោកអណ្តែតនៅឰដ៏អាកាស ក៏កើតសោមនស្សរីករាយបន្លឺនូវវាចាដោយចិត្តរីករាយថា **អយំ ទេវបុត្តោ** ទេវតាអង្គនេះមានរស្មីដ៏ភ្លឺ ញុំាំងភាពក្លៀវក្លាឲ្យកើតដល់យើងទាំងឡាយ ។ **តស្មា សុរិយោ**

**ហោតុ** ព្រោះហេតុដូច្នោះ ទើបព្រះអាទិត្យ មានឈ្មោះថា ព្រះសុរិយា ដរាបដល់សព្វថ្ងៃនេះ ។ **ទិវសំ អាលោកំ កត្វា** ក្នុងកាលព្រះអាទិត្យ រះឡើងបំភ្លឺហើយក៏អស្តង្គតទៅ លោកក៏ត្រឡប់ងងឹតដូចដើម មនុស្ស ទាំងឡាយក៏ត្រឡប់ភ័យតក់ស្លុតសាជាថ្មីទៀត ក៏និយាយប្រាប់គ្នាទៅថា ពួកយើងទាំងឡាយអើយ នឹងធ្វើដូចម្តេចល្អ ព្រះអាទិត្យ ជាទីពឹងរបស់ ពួកយើងវិនាសហើយ ធ្វើដូចម្តេចទើបនឹងបាននូវទីពឹង ដែលនឹងបំភ្លឺ ឲ្យភ្លឺបន្តទៅទៀត **តេ តំ ចិត្តំ ញត្វា វិយ** ហាក់បីដូចជាដឹងចិត្ត របស់មនុស្សទាំងនោះ ព្រះចន្ទមានបរិមណ្ឌល ៤៩ យោជន៍ ក៏កើត ប្រាកដឡើងអណ្តែតនៅពួជ៍អាកាស **ហដ្ឋតុដ្ឋា ហុត្វា** មនុស្ស ទាំងឡាយ ក៏រីករាយសោមនស្ស បន្លឺនូវវាចាដោយចិត្តត្រេកអរ ថា **អម្ហាកំ ជន្ទំ ញត្វា** ទេវតាអង្គនេះហាក់បីដូចជាដឹងចិត្តយើងថា យើងនេះប្រាថ្នាឲ្យកើតមានពន្លឺ ក៏រីករាយសប្បាយចិត្ត ទើបតាំង ឈ្មោះថា ព្រះចន្ទ **ឯវំ ចន្ទិមសុរិយេសុ** ក្នុងកាលព្រះចន្ទ ព្រះអាទិត្យ ប្រាកដមានក្នុងលោកធាតុហើយ លំដាប់នោះ យប់ និងថ្ងៃក៏កើត ប្រាកដឡើង លុះយប់ និងថ្ងៃ កើតប្រាកដឡើងហើយ ខែឆ្នាំរដូវក៏ កើតប្រាកដឡើងតៗ គ្នាមក ។ **ចាតុទ្ទសទិវសេ** ក្នុងថ្ងៃដែលព្រះចន្ទ

ព្រះអាទិត្យកើតឡើងនោះ ភ្នំសិនេរុ ភ្នំកណ្តាប់ចក្រវាល ភ្នំហិមពាន្ត មហាសមុទ្រក៏កើតមានព្រមគ្នាទាំង ៦ យ៉ាង ក្នុងថ្ងៃពេញបូណ៌មីខែផល្គុន ។

ទើបមានពាក្យសួរថា លោក គឺផែនដី និងភ្នំ កាលកើតឡើង កើតឡើងដូចម្តេច ?

មានពាក្យឆ្លើយដោយឧបមាថា **យថា ឆាម កង្គុ ភត្តេ បច្ចមានេ** កាលបើកើតឡើងនោះ ប្រៀបដូចបុគ្គលដែលចម្អិននូវគ្រាប់ថ្ពៅ ធម្មតាគ្រាប់ថ្ពៅដែលចម្អិននោះ រមែងផុះឡើងព្រមគ្នា ពេលដែលផុះឡើងនោះ កន្លែងខ្លះខ្ពស់កំពង់ជាកញ្ចុំៗ កន្លែងខ្លះក៏ទ្រោមចុះទៅ កន្លែងខ្លះក៏រាបស្មើគ្នា **យថា** មានឧបមាយ៉ាងណា លោកធាតុដែលកើតឡើងនោះ ក៏មានឧបមេយ្យដូច្នោះ **ថូបថូថា** ស្ថានទីដែលខ្ពស់ៗ នោះ ក៏កើតជាភ្នំ **និន្ននិន្នា** ទីទំនាបនោះក៏ជាមហាសមុទ្រ ។ ទីដែលរាបស្មើៗ នោះ ក៏ជាទ្វីបធំ ទ្វីបតូចតាមលំដាប់ **តេសំ សត្តានំ** នាកាលសត្វទាំងឡាយ ដែលរសតណ្ហាគ្របសង្កត់ហើយ ក៏បបួលគ្នាស៊ីនូវរសផែនដីនោះ **ឯកច្ចេ** សត្វពួកខ្លះមានសម្បុរផូរផង់ សត្វពួកខ្លះក៏មានសម្បុរអាក្រក់ ជាទីតិះដៀលនៃ

មនុស្សដែលមានសម្បុរល្អ ។ **តេសំ អតិមានប្បច្ចយា** បាបធម៌ទាំងពីរ គឺសក្កាយទិដ្ឋិ និងអតិមានះនេះជាដើមជាដើមហេតុ ជាបច្ច័យញុំាងលោកឲ្យប្រែប្រួល ។ កាលបាបធម៌ទាំងពីរកើតឡើងខ្លាំងក្លា រសផែនដីដែលជាអាហារដ៏ឆ្ងាញ់នោះក៏សាបសូន្យអស់ទៅ ។ **ភូមិបប្បដកោ** ផែនដី ក៏ក្លាយទៅជាក្រមរ តែក្រមរផែនដីនោះ មានក្លិនក្រអូប មានរសផ្អែមឆ្ងាញ់ ជាអាហាររបស់មនុស្ស ។ លុះសន្តាននោះក្រាស់ទៅដោយបាបធម៌ ក្រមរផែនដីនោះក៏អន្តរធានអស់ទៅលំដាប់នោះ ទើបវល្លិ៍ដីកើតឡើង **បទាលតា** វល្លិ៍នោះ ក៏សាបសូន្យអស់ទៅ **អកដ្ឋបាកោ** រីស្រូវសាលីកើតឯង មិនបាច់ភ្ជួររាស់ ដុះទ្រុបទ្រុលឡើងឯង ជាស្រូវគ្មានកន្ទក់ គ្មានអង្កាម សស្អាត មានក្លិនក្រអូប មានផ្លែចេញមកជាអង្ករតែម្តង ក៏កើតប្រាកដឡើង ។ មនុស្សទាំងឡាយ ក៏ទៅច្បូតយកស្រូវសាលីមកចម្អិនបរិភោគតទៅ មនុស្សទាំងឡាយនាំគ្នាយកស្រូវសាលីត្រង់ទីណាក្នុងវេលាណា សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ។ មនុស្សទាំង-ឡាយនាំគ្នាយកស្រូវសាលីត្រង់ទីណា ក្នុងវេលាព្រឹក សម្រាប់

បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាច ទីនោះ ក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះក៏ប្រាកដហាក់បីដូចជាមិនបានច្បូតឡើយ ។ គ្រានោះ កិរិយាដែលចម្អិនបាយបរិភោគ ក៏មិនលំបាកលំបិនដែរ ។ យកស្រូវសាលីដាក់ក្នុងឆ្នាំងហើយ ក៏យកទៅតម្កល់ដាក់លើជុំថ្ម ហើយឆ្នាំងក៏ក្តៅ ក៏ឆ្អិនទៅឯង ។ **ឆ ហិ ការណិយំ** ម្យ៉ាងទៀត អាហាររបស់មនុស្សកាលនោះ មិនមានកិច្ចស្វែងរកម្ហូប និងសម្លនោះទេ កាលពេញចិត្តរសជាតិឯណា បាយនោះក៏មានរសដូច្នោះ **អាហារំ អាហារយតំ** ប្រការដែលមនុស្សបរិភោគអាហារយ៉ាងនោះ អាហារនោះក៏រលាយកើតជាមូត្រ និងលាមក **តថា ហិ តទមិនា សច្ចំ** ការពោលមកនេះ ជាការត្រឹមត្រូវព្រោះកាលមនុស្សបរិភោគផែនដី និងក្រមរផែនដី និងវល្លិ៍ដីនោះក៏ដូចគ្នានឹងសុទ្ធាហារ ព្រោះថា បានបន្ទោបង់នូវសេចក្តីលំបាកញុំាងរសតែម្យ៉ាងឲ្យកើតឡើង ព្រោះអ្វី ព្រោះថា សុខុមភាពរបស់វត្ថុ **ឱឡរោ បន បរិភុត្តោ** លុះកាលមកបរិភោគនូវរសអាហារជាបាយ ជាវត្ថុគ្រោតគ្រាត ឧច្ចារៈ បស្សាវៈក៏កើតឡើង ។ កាលបើឧច្ចារៈ បស្សាវៈកើតឡើងហើយ **វណមុខំ** មុខដំបៅដែលជា

ដែនហូរចេញរបស់មូត្រ និងលាមកនោះ បែកចេញជាភាវរូប ២ គឺឥត្ថីភាវរូប និងបុរិសភាវរូបក៏កើតឡើង អ្នកណាធ្លាប់ជាបុរសក៏ជាបុរស ធ្លាប់ជាស្ត្រីក៏ជាស្ត្រីទៅ ។

**បុរិមត្តភាវេសុ ហិ** ដើម្បីញ៉ាំងសេចក្តីនេះឲ្យច្បាស់ មនុស្សដើមកប្បទាំងឡាយ នៅមិនទាន់ដាច់ឧបចារជ្ឈានតជាប់មកក្នុងសន្តានអំពីគ្រានៅក្នុងព្រហ្មលោកនោះប្រាកដ គឺសង្កត់សង្កិននូវកាមរាគៈ មិនឲ្យកើតឡើងបាន អាស្រ័យនូវឥន្ទ្រិយរូប គឺឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយមានហើយ ទើបកើតជាកាមរាគៈៗ កើតហើយ ឧបចារជ្ឈាន ក៏ដាច់អំពីសន្តានរបស់សត្វទាំងឡាយ **ពហុលកាម–រាគោ លទ្ធាវកាសោ** កាលបើឧបចារជ្ឈានដាច់អំពីសន្តានហើយ ក៏ជាឱកាសរបស់ពហុលកាម **រាគតោ តទុបនិស្សយា** នាកាលឥត្ថី–ភាវៈ និងបុរិសភាវៈដែលជាឧបនិស្សយប្បច្ច័យនៃកាមរាគៈនោះកើតមានហើយ ទាំងប្រុស ទាំងស្រី ក៏សម្លឹងមើលគ្នាទៅវិញទៅមក **កាមបរិឡាហោ ឧប្បជ្ជតិ** ម្នាក់ៗ ក៏ខ្វល់ខ្វាយដោយអំណាចរាគៈតណ្ហា ក៏មានតម្រេកកើតឡើង តាំងអំពីនោះមកសត្វទាំងនោះក៏នាំគ្នាសេពមេថុន ព្រោះសេចក្តីពេលពាលជាបច្ច័យ **អសទ្ធម្ម–**

**បដិសេវនាបច្ចយាតិ** សេពនូវមេថុនធម្មជាហេតុ សត្វទាំងឡាយនោះ ក៏ត្រូវខ្វល់ខ្វាយស្វែងរកនូវជម្រក គឺផ្ទះ **អគារំ អជ្ឈាវ-សមានា** កាលមនុស្សទាំងឡាយគ្រប់គ្រងផ្ទះសម្បែង ដូច្នោះប្រកបដោយជាតិជាអ្នកខ្ជិលច្រអូសក៏កើតឡើង ធ្វើការសន្សំនូវស្រូវសាលី គឺខ្ជិលទៅច្បូត នាំយកស្រូវសាលីមកទុកម្តងៗ ច្រើនៗដាក់ក្នុងភាជនៈពេញៗ មនុស្សទាំងឡាយបានជាគំរូធ្វើតម្រាប់តាមគ្នាយ៉ាងច្រើន ស្រូវសាលីនោះ ក៏មានកន្ទក់ និងអង្កាម ស្រូវសាលីដែលច្បូតរួចហើយនោះក៏លែងដុះឡើងវិញ **តេ សន្និបតិត្វា អនុដ្ឋុនន្តិ** មនុស្សទាំងនោះ ម្នាក់ៗ ក៏ខកចិត្តធំ ពោលថា ពួកយើងអើយ បាបធម៌ដ៏អាក្រក់កើតឡើងដល់យើងរាល់គ្នាហើយ អំពីមុនយើងទាំង-ឡាយបាននូវសេចក្តីសុខសប្បាយ ព្រោះមានបីតិជាអាហារ **អន្តលិក្ខេ** ហោះទៅក្នុងអាកាសបានដូចចិត្តគិត បានភាពចម្រើន អស់កាលជាយូរអង្វែង **អនុក្កាមេ** ចំណេរតមក ក៏ស៊ីផែនដី ស៊ីក្រមរផែនដី ស៊ីវល្លិ៍ សេចក្តីចម្រើនក៏អស់ទៅបណ្តើរៗ រហូតដល់បានបរិភោគនូវស្រូវសាលីជាអាហារ អំពីមុនស្រូវសាលី ក៏មិនមានកន្ទក់ និងអង្កាម ច្បូតនាំយកអំពីពេលលាច ព្រឹកឡើង ក៏ដុះឡើងវិញទ្រុប

ទ្រុលដូចដើម **សោបិ ឥទានិ** ឥឡូវនេះ គ្រប់យ៉ាងប្រែប្រួលទាំងអស់ យូរទៅពួកយើងរកអ្វីបរិភោគបានដោយលំបាក **យន្នូន មយំ** កុំដូច្នោះឡើយ យើងទាំងឡាយអើយ មកយើង នឹងបែងចែកស្រូវសាលីឲ្យជាចំណែកបោះព្រំខណ្ឌ រៀងៗ ខ្លួន ។ **សមំ ឋបេសិ** ពេលនោះ ក៏ចាត់ចែងជាព្រំ **តតោ អញ្ញតរោ បុរិសោ** បន្ទាប់អំពីនោះទើបកើតបុរសជាតិជាអ្នកប្រវ័ញ្ច ប្រកបដោយអកុសលចិត្ត លួចយកចំណែករបស់អ្នកដទៃ ដែលម្ចាស់មិនបានឲ្យដោយកាយ និងវាចា **ទុតិយម្បិ** **បរិភាសេត្វា** ម្ចាស់របស់ចាប់បាន លុះចាប់បានហើយក៏ស្តីឲ្យដូច្នេះថា ឱ ! សត្វអើយ ឯងធ្វើអំពើអាក្រក់ ជេរស្តី ២-៣ ម៉ាត់ហើយក៏លែងទៅ **តតិយវារេ** ធ្វើការលួចយកចំណែកអ្នកដទៃដូច្នេះអស់កាលយូរអង្វែង ក្នុងតតិយវារៈគេចាប់បាន គេក៏ចោមរោមវាយតប់ទះសត្វនោះ ដោយដៃខ្លះ ដោយចោលដុំដីខ្លះ ពួកសត្វខ្លះវាយនឹងដំបងរួចហើយក៏លែងទៅ ។ តាំងអំពីនោះមក អទិន្នាទានក៏កើតមានការតិះដៀលគ្នាក៏កើតឡើង មុសាវាទក៏កើតឡើង របស់ពិន័យ និងអាជ្ញាក៏កើតឡើង សត្វទាំងនោះក៏ចង្អៀតចង្អល់ចិត្តក្រៃលែង ទើបប្រជុំប្រឹក្សាគ្នាថា **យត្រ ហិ នាម បាបកានិ** ឱ ! សត្វអើយ កាលឥឡូវ

នេះ សត្វទាំងឡាយដ៏លាមកថោកទាបនេះមានច្រើនឡើង យើងទាំងឡាយនេះនៅស្ងៀមមិនបាន នឹងរៀបចំសន្មតគ្នាទើបជាការគួរ **យោ នោ សម្មា ខីយតព្វំ** យើងទាំងអស់គ្នានេះយល់ថា អ្នកណាមានបញ្ញា គួរនឹងពោលសង្កត់សង្កិន បន្ទោសសត្វដែលគួរបន្ទោសតាមហេតុ តិះដៀលសត្វដែលយើងគួរតិះដៀល គួរចំពោះបព្វា-ជនីយកម្ម ក៏បណ្តេញ បំបរបង់ចេញទើបបានជាសុខ សឹមពួកយើងនឹងជូននូវចំណែកស្រូវសាលីទាំងឡាយដល់អ្នកនោះ ម្នាក់មួយតៅទើបគួរ ។ ក្នុងកាលសត្វទាំងឡាយ គិតប្រឹក្សាព្រមគ្នាដូច្នេះហើយ ក៏បានជ្រើសរើសសម្រិតសម្រាំងរកនូវបុគ្គលនោះ ។

**អយមេវ ភគវា** ក្នុងដើមកប្បអសង្ខេយ្យកប្បនោះ ព្រះសម្ពុទ្ធនៃយើងនេះ កើតជាព្រះពោធិសត្វប្រាកដដល់សត្វទាំងពួង ព្រមដោយរូប គឺសក្តិធំដ៏ក្រៃលែង ដោយកម្លាំងបញ្ញាជាងពួកសត្វទាំងនោះ អាចពោលពាក្យសង្កត់សង្កិន អប់រំប្រៀនប្រដៅមនុស្សទាំងឡាយបាន **តេសំ តំ ឧបសង្កមិត្វា** បណ្តាមនុស្សទាំងឡាយស្រុះស្រួលគ្នា ក៏នាំទៅកាន់សម្នាក់ព្រះពោធិសត្វ ហើយទើបសូមអញ្ជើញព្រះពោធិ-សត្វឲ្យទទួលតំណែង ទើបធ្វើរាជាភិសេកមហាសម្មតិ ឲ្យស្រង់

ឧទកទាំង ៣ ស្ថាន ថ្វាយព្រះនាមថា **មហាសម្មតិរាជ** ដោយអត្ថថា ញុំាងពួកមនុស្សជាច្រើននាក់ ឲ្យធ្វើជាម្ចាស់នៃទិស ញុំាងមហាជនឲ្យត្រេកអរដោយយុត្តិធម៌ និងមានកម្មដ៏ស្មើ **ខត្តិយបណ្ឌិតេ** ក្នុងកាលខត្តិយដែលមហាជនចាត់ចែងស្រេចហើយ មនុស្សទាំងឡាយពួកខ្លះគិតថា ពួកយើងអើយ បាបធម៌ អកុសលធម៌ដ៏លាមកនេះ កើតប្រាកដមានចំពោះសព្វសត្វជាច្រើនក្រៃលែង ទាំងមុសា អទិន្នាទានរបស់ពិន័យអាជ្ញា ការតិះដៀលគ្នាសព្វយ៉ាងកើតឡើង **យន្នូន មយំ** កុំដូច្នោះឡើយ ពួកយើងអើយ បើដូច្នោះ ពួកយើងគួរតែបន្សាត់នូវធម៌ជាអកុសលដ៏លាមកទាំងឡាយចេញ ។ **បណ្ណកុដិយោ កត្វា** គ្រានោះមនុស្សទាំងនោះយល់ព្រមគ្នាហើយ ក៏នាំគ្នាទៅកាន់ព្រៃ បានធ្វើបណ្ណសាលានៅអាស្រ័យ ។ មានប្រក្រតីត្រាច់ទៅកាន់ស្រុក និគម និងរាជធានី ដើម្បីសូមនូវអាហារ ។ ជនទាំងនោះ បានឈ្មោះថាព្រាហ្មណ៍ ដោយអត្ថថា គិតបន្សាត់ចេញនូវបាបមេថុនធម្ម **សម្មាន–យិត្វា** ពួកមនុស្សណាពេញចិត្តសេពនូវមេថុន ពួកមនុស្សនោះ ក៏ខ្វល់ខ្វាយទៅដោយកសិកម្ម ពាណិជ្ជកម្ម ចិញ្ចឹមគោក្របី ទើបហៅថាកសិករ ពាណិជ្ជករ បន្តរហូតដល់សព្វថ្ងៃនេះ ។ មនុស្សពួកណា

មិនពេញចិត្តនឹងការបៀតបៀនអ្នកដទៃជាដើម ប្រព្រឹត្តតែការងារបរិសុទ្ធ ជាមនុស្សបរិសុទ្ធ ទើបបានឈ្មោះថា មេត្រីសារ ក៏មានដោយប្រការដូច្នេះ ។

**ឃរំ សណ្ឋិតោ កប្បោ** នាកាលលោកសន្និវាសសែនលោកធាតុកើតឡើងដូច្នេះ បានឈ្មោះថា វិវដ្ដដ្ឋាយីអសង្ខេយ្យកប្ប ។ កប្បមាន ២ គឺសុញ្ញកប្ប និងអសុញ្ញកប្ប ។ កប្បនោះមាន ៥ គឺ សារកប្ប ១ មណ្ឌកប្ប ១ វរកប្ប ១ សារមណ្ឌកប្ប ១ ភទ្ទកប្ប ១ ជា ៥ ។ បណ្ដាកប្បទាំង ៥ នេះ កប្បដែលឈ្មោះថាសារកប្បនោះ ដោយអត្ថថា ទ្រទ្រង់នូវព្រះសម្មាសម្ពុទ្ធ ១ ព្រះអង្គ ដែលញ៉ាំងនូវគុណប្រយោជន៍ឲ្យកើតឡើង ។ កប្បដែលឈ្មោះថាមណ្ឌកប្បនោះ ដោយអត្ថថា ទ្រទ្រង់នូវព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ ។ កប្បដែលឈ្មោះថា វរកប្បនោះ ដោយអត្ថថា ទ្រទ្រង់នូវព្រះសម្មាសម្ពុទ្ធ ៣ ព្រះអង្គ ។ ដោយហេតុថា ព្រះសម្មាសម្ពុទ្ធព្រះអង្គនោះនឹងបានព្យាករព្រះពុទ្ធអង្គទី ២ ។ ព្រះពុទ្ធអង្គទី ២ នោះ បានព្យាករព្រះពុទ្ធអង្គទី ៣ ទើបឈ្មោះថា វរកប្ប ។ សារមណ្ឌកប្បនោះ ទ្រទ្រង់ព្រះសម្ពុទ្ធ ៤ ព្រះអង្គ សារមណ្ឌកប្បនោះ ដោយអត្ថថា ប្រសើរជាងកប្បមុនៗ ។

**យស្មឹ បន កប្បេ** សូម្បីក្នុងកប្បណានឹងទ្រទ្រង់ព្រះសម្ពុទ្ធបាន ៥ ព្រះអង្គ កប្បនោះឈ្មោះថា ភទ្ទកប្ប ដោយអត្ថថា **ចម្រើន ។ សោ បន ទុល្លភោ** ព្រោះអសង្ខេយ្យកប្បនេះ កម្រនឹងមាន លំបាកនឹងបានជួប សត្វពួកណាបានជួបហើយ នេះជាគុណានិសង្សដ៏ក្រៃលែង **កល្យាណសុខពហុលា** នឹងច្រើនទៅដោយកុសល និងសេចក្តីសុខនោះដោយពិត បើជាត្រៃហេតុសត្វក៏នឹងបានកាត់ផ្តាច់កិលេស បើជាទុហេតុក៏មានតែសុគតិភពជាខាងមុខ **ឥតិ តស្មា** ព្រោះហេតុដូច្នេះ ទើបមាននាមបញ្ញត្តិថា ភទ្ទអសង្ខេយ្យកប្ប ដូច្នេះ ។

**កប្បវិនាសមហាមេឃតោ** កិរិយាដែលកំណត់ដឹងនូវអសង្ខេយ្យទាំង ៤ នោះ កំណត់អំពីកប្បវិនាស ទល់គ្នានឹងអស់អណ្តាតភ្លើង ឈ្មោះថា **សំវដ្តអសង្ខេយ្យ** តាំងអំពីអស់អណ្តាភ្លើងដរាបដល់មហាមេឃញ៉ាំងភ្លៀងឲ្យធ្លាក់ ពេញក្នុងទីដែលភ្លើងឆេះនោះ ឈ្មោះថា **សំវដ្តដ្ឋាយីអសង្ខេយ្យ សម្បត្តិមហាមេឃតោ** តាំងអំពីភ្លៀងធ្លាក់ពេញសែនកោដិចក្រវាល នោះ ដរាបដល់ព្រះចន្ទព្រះអាទិត្យកើត ឈ្មោះថា **វិវដ្តកប្ប ចន្ទិមសុរិយបាតុភាវ** តាំងអំពីព្រះចន្ទព្រះអាទិត្យកើតមក ដរាបដល់កប្បវិនាស ឈ្មោះថា

*វិវដ្ដដ្ឋាយីអសង្ខេយ្យកប្ប អ្នកប្រាជ្ញគប្បីជ្រាបដោយប្រការ ដូច្នេះ ។*

**វិវដ្ដដ្ឋាយីអសង្ខេយ្យោ** *ការពិត វិវដ្ដដ្ឋាយីអសង្ខេយ្យនេះ ព្រះសង្គីតិកាចារ្យសង្គ្រោះយកនូវអន្តរកប្ប ៦៤ អាចារ្យខ្លះពោលថា ២០ អន្តរកប្ប* **សេសានិ** *រីអសង្ខេយ្យដ៏សេសនោះ មានកាលកន្លងយូរស្មើដោយវិវដ្ដដ្ឋាយីនោះទាំងអស់* **ឯកោ មហាកប្បោ** *អសង្ខេយ្យនេះជាមួយមហាកប្ប* **វិនាសោ ច សណ្ឋហានំ ច** *កិរិយាសម្ដែងនូវកប្បវិនាសអស់ដោយភ្លើង អ្នកប្រាជ្ញគប្បីជ្រាបដោយន័យប្រមាណប៉ុណ្ណេះ ។*

**យស្មឹ កប្បេ** *បើកប្បនឹងវិនាសដោយទឹកនោះ អ្នកប្រាជ្ញគប្បីសម្គាល់ដូចគ្នានឹងដោយភ្លើងនោះ* **អយំ បន វិសេសោ** *ក្នុងទីនេះនឹងពោលតែសេចក្ដីដែលប្លែកគ្នាប៉ុណ្ណោះ ។ កាលកប្បវិនាសដោយទឹកនោះ គ្រាលោកវិនាស មហាមេឃកើតឡើងហើយរហូតដល់ពេលកើតនៃព្រះអាទិត្យរះឡើង ២ ដួងនោះ ពេលនោះ ជាទីកើតរបស់ខារុទកមហាមេឃ* **សោ ខារុទកមហាមេឃោ** *រីមហាមេឃទឹកក្រុត កាលបើធ្លាក់ចុះនោះ ញាំងនូវតំណក់តូចៗ ឲ្យធ្លាក់ចុះមុនហើយក៏មានតំណក់ធំៗ កើតឡើងដោយលំដាប់ៗ ញាំងសែនកោដិ*

ចក្កវាឡឲ្យពេញ **បឋវីបត្តានយោ** ផែនពសុធាមហាបពិតទ្រាំមិនបាន ក៏ទ្រោមផុតរលួយវិនាសសាបសូន្យអស់ទៅ មានឧបមាយ៉ាងណា **បក្ខិត្តលោណសក្ខរា វិយ** ឧបមាដូចដុំអំបិលដែលបុគ្គលបោលទៅក្នុងទឹក **ឯក្កុឧកមេវ** ទឹកក្រុត និងទឹកទ្រផែនដីនោះ ក៏រលាយចូលគ្នាតែមួយ ។

**អបរេ វទន្តិ** អាចារ្យខ្លះពោលជំទាស់ពាក្យនោះ ទឹកក្រុតនិងទឹកដែលទ្រទ្រង់ផែនដីជាទម្រង់តែមួយ យើងឃើញដូចជាមិនសមតើអ្វីទៅទ្រាំនឹងទឹកក្រុតនោះបាន កុំថាតែទឹកទ្រទ្រង់ផែនដី សូម្បីខ្យល់ទ្រទឹកក៏ទ្រាំមិនបាន វិនាសទូទាំងចក្រវាលទាំងអស់ ។ **ឯកោឃនភូតោ** ជាដុំមួយគ្មានមនុស្សនៅលាយឡំ ដកបសង្ខារមានប្រមាណប៉ុនអាណូតាំងនៅមិនបាន ក៏សាបសូន្យអន្តរធានទៅឯង**ហេដ្ឋា អាកាសេ** អាកាសខាងក្រោម និងអាកាសខាងលើក៏ដូចគ្នា**សព្វត្ថសទិសំ** ដោយសេចក្តីដែលសម្តែងរួចមកហើយក្នុងពេលមុន **៩ឧ អាបោ សំវដ្តេ** ក្នុងអាបោសំវដ្តវិនាសដោយទឹកនោះវិនាសទៅដល់ព្រហ្មលោក ក្រោមជាន់សុភកិណ្ហាចុះមក **លោកោធាតុភវតិ** កាលលោកនឹងកើតឡើងអំពីជាន់អាភស្សរព្រហ្មចុះមក

**សុភកិណ្ហតោ** សត្វទាំងឡាយ ក៏ចុតិអំពីសុភកិណ្ហៈតៗ ចុះមកជាលំដាប់ **កប្បវិនាសមហាមេឃតោ** តាំងអំពីកប្បវិនាសមហាមេឃតាំងឡើងមកនោះ ដរាបដល់ខារុទក ជាអសង្ខេយ្យមួយ តាំងអំពីអស់ខារុទកហើយ ដរាបដល់កើតសម្បត្តិមហាមេឃនោះ ដរាបដល់កើតព្រះចន្ទព្រះអាទិត្យ ជាអសង្ខេយ្យមួយតាំងអំពីព្រះចន្ទព្រះអាទិត្យកើតដរាបដល់កើតកប្បមហាមេឃ ជាអសង្ខេយ្យមួយដូចគ្នាទាំងអស់ **ឯវំ ឧទកេន វិនាសោ** វីកិរិយាដែលលោកវិនាសដោយទឹក ហើយកើតឡើងវិញនោះ អ្នកប្រាជ្ញគប្បីជ្រាបដោយប្រការដូច្នេះ **យស្មិំ បន សមយេ** ក្នុងកាលកប្បវិនាសដោយខ្យល់នោះសោត កប្បវិនាសមហាមេឃកើតឡើងមុន ។ ក្នុងទីនេះប្លែកគ្នានៅត្រង់ព្រះអាទិត្យកើតឡើង ២ ដួង ជាពេលដែលកើតមានខ្យល់ **សោ វាតោ** វីវាយោសំវដ្តៈ ខ្យល់ដែលញុំាងកប្បឲ្យវិនាសនោះបក់បន្តែមមករឿយៗ បក់មករំភើយៗ ល្មមតែធូលីម៉ដ្តៗ ហុយឡើង ហើយនឹងញុំាងដុំថ្ម និងភ្នំតូចធំឲ្យអណ្តែតឰដ៏អាកាស និងមិនបានធ្លាក់ចុះ ។ **ចុណ្ណវិចុណ្ណា** ជាកម្ទេចវិនាសសូន្យឯងទៅក្នុងអាកាសនោះ **ហេដ្ឋា បថវិយា** ពេលក្រោយមក ទើបកើតមានខ្យល់ខាងក្រោមប្រឹថពីមាន

កម្លាំងខ្លាំងក្លាក្រៃលែង **ឧទ្ធំ មូលំ កត្វា** ញ៉ាំងផែនដីឲ្យរបើក ឡើង ហើយក៏រសាត់ឡើងទៅឰដ៏អាកាស **ឯកយោជនប្បមាណា** ផែនដីដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍នោះ ក៏បែកចេញ ជាដុំ ទំហំប្រមាណ ១០០ យោជន៍ខ្លះ ៤០០ យោជន៍ខ្លះ ដោយ កម្លាំងខ្យល់បក់យ៉ាងខ្លាំងក្លា ក៏សាបសូន្យអស់ទៅ **ចក្កវាឡបព្វតំបិ** សូម្បីកណ្តាប់ភ្នំចក្រវាល ភ្នំហិមពាន្ត ភ្នំសិនេរុទាំងសែនកោដិចក្រ-វាលទ្រាំមិនបាន ក៏អណ្តែតខ្ទាត់ខ្ទែងទៅក្នុងអាកាស ទង្គិចគ្នានិងគ្នា ក៏បែកជាកម្ទេចសូន្យបាត់ទៅឯង ភុម្មដ្ឋកវិមាន អាកាសដ្ឋវិមាន ទាំងសែនកោដិចក្រវាល តាំងអំពីមនុស្សលោកនេះឡើងទៅ ដរាប ដល់តតិយជ្ឈានភូមិវិនាសទៅដោយខ្យល់ទាំងអស់ **សោ វាតោ** ខ្យល់ប្រល័យលោកនេះ កាលបើប្រហារនូវលោក ខាងក្រោមតាំង អំពីអជដាកាសឡើងទៅ ដរាបដល់ព្រហ្មលោក ៩ ជាន់ បឋម-ជ្ឈានភូមិ ៣ គឺព្រហ្មបារិសជ្ជា ១ ព្រហ្មបុរោហិតា ១ មហាព្រហ្ម ១ ។ ទុតិយជ្ឈានភូមិ ៣ គឺបរិត្តាភា ១ អប្បមាណាភា ១ អាភស្សរា ១ ។ តតិយជ្ឈានភូមិ ៣ គឺបរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហា ១ ជា ៩ វិនាសទៅទាំងអស់ សង្ខារមានប្រមាណ

ប៉ុនលម្អិតតូចបំផុតវិនាសមិនមានសេសសល់ រួចហើយខ្យល់ក៏អន្តរាយស្ងប់ទៅឯងតាមធម្មតា **សព្វំ វុត្តសទិសំ** សេចក្តីដ៏សេសនោះ អ្នកប្រាជ្ញគប្បីជ្រាបដោយន័យដូចសម្តែងរួចមកហើយ ។

**កិំការណា** ក្នុងកប្បវិនាសនិទ្ទេសនេះមានពាក្យសួរថា **សង្ខារានំ គហេតុកោ** លោកទាំងអស់នេះ ជាអហេតុកសង្ខារ មិនមានលោភៈ ទោសៈ មោហៈ វិនាសដោយហេតុណា ហេតុណាជាហេតុឲ្យវិនាស ?

**អកុសលមូលំ** ឆ្លើយថា អកុសលមូលនោះឯងជាហេតុឲ្យវិនាស កម្លាំងបុណ្យនៃសត្វនោះឯងជាហេតុឲ្យកើត **អកុសលមូលេ** ក្នុងកាលអកុសល គឺលោភៈ ទោសៈ មោហៈក្រាស់ឡើងក្នុងសន្តានសត្វហើយ លោកក៏មានសេចក្តីវិនាស **តថា ហិ តទមិនា សច្ចំ** អធិប្បាយសេចក្តីនេះសមនឹងបាលីថា **រាគទោសមោហានំ** ក្នុងសភាពនៃសត្វទាំងឡាយមានសន្តានក្រាស់និងច្រើនទៅដោយអកុសលមូលកើតឡើងហើយ អន្តរកប្ប ៣ ប្រការគឺ **រោគន្តរកប្ប** រោគជាច្រើនកើតដល់សត្វ ១ **សត្ថន្តរកប្ប** កើតការកាប់សម្លាប់គ្នា ១ **ទុព្ភិក្ខន្តរកប្ប** ទុរ្ភិក្សក៏កើតឡើង ១ ។ អន្តរកប្បទាំង ៣ ប្រការនេះកើតមានក្នុងវិវដ្តដ្ឋាយីអសង្ខេយ្យយ៉ាងណាក្តី លោកសំវដ្តៈទាំង ៣

នេះក៏កើតដោយការៈនៃរាគៈច្រើនជាដើម ឧបមេយ្យដូចគ្នាដូច្នោះ **តត្ថ រាគា ឧស្សន្នេ** ក្នុងកាលសត្វក្រាស់ទៅដោយរាគៈ លោកវិនាសទៅដោយភ្លើង ក្នុងកាលសត្វក្រាស់ទៅដោយទោសៈ លោកវិនាសទៅដោយទឹក ក្នុងកាលសត្វក្រាស់ទៅដោយមោហៈ លោកវិនាសទៅដោយខ្យល់ ។

ព្រះចន្ទ និងព្រះអាទិត្យទាំង ២ នេះ មិនប្រាកដព្រមគ្នាទេ ។ ព្រះអាទិត្យប្រាកដមុន ។ កាលពន្លឺរបស់សត្វពួកនោះអស់ទៅ ភាពងងឹតសូន្យសុងក៏កើតមានឡើង ។ សត្វទាំងនេះភ័យតក់ស្លុត ទើបគិតគ្នាថា ប្រសិនបើមានពន្លឺកើតប្រាកដឡើងទើបល្អ ។ បន្ទាប់អំពីនោះព្រះអាទិត្យក៏កើតឡើងដល់ប្រជា ។ ដោយហេតុនោះ ព្រះអាទិត្យនោះទើបឈ្មោះថា **សុរិយោ** ដូច្នេះ ។ កាលបើព្រះអាទិត្យនោះញ៉ាំងពន្លឺឲ្យភ្លឺហើយ ក៏អស្តង្គតទៅ ភាពងងឹតសូន្យសុងក៏ត្រឡប់កើតម្តងទៀត ។ សត្វទាំងនោះនាំគ្នាគិតថា បើមានពន្លឺដទៃកើតឡើងដូច្នេះ ជាការល្អ ។ ពេលនោះ ព្រះចន្ទក៏កើតឡើង ។ ដោយហេតុនោះឯង ទើបព្រះចន្ទកើតមានឈ្មោះថា **ចន្ទោ** ដូច្នេះ ។

គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងពាក្យថា ព្រះអាទិត្យ និងព្រះចន្ទ

ញុាំងពន្លឺឲ្យភ្លឺក្នុងទីនេះប្រមាណប៉ុនណា ដូច្នេះ ព្រះចន្ទ និងព្រះអាទិត្យរមែងញុាំងពន្លឺឲ្យភ្លឺក្នុងទ្វីបទាំង ៣ ដោយព្រមគ្នា ។

ក្នុង គម្ពីរទីឃនិកាយ បញ្ចមភាគ អដ្ឋកថាអគ្គញ្ញសូត្រទី ៤ សម្តែងអំពីព្រះអាទិត្យ និងព្រះចន្ទ មានសេចក្តីថា ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថា ចន្ទិមសុរិយា ។ បទថា **ចាតុរហេសុំ** ប្រែថា ប្រាកដឡើង ។

**សោ ហិ អមាវសិយំ** ពិតហើយ ក្នុងកាឡបក្ខចន្ទវិមានគោចរទៅព្រមជាមួយព្រះអាទិត្យ ខាងខ្នើតក៏ឃ្លាតចេញមួយថ្ងៃបន្តិចៗ រហូតដល់ ១ ថ្ងៃ ១ សែនយោជន៍ ជាបដល់ ថ្ងៃ ១៥ កើត ក៏បានពាក់កណ្តាលផ្លូវ គឺកន្លះចក្កវាសី ។

ព្រះចន្ទ ជួនកាលប្រាកដទិសខាងត្បូង ជួនកាលប្រាកដទិសខាងជើង ព្រោះព្រះចន្ទតែងលះបង់គន្លងគោចររបស់ខ្លួន ជួនកាលខិតមករកភ្នំកណ្តាប់ចក្រវាល ជួនកាលខិតទៅរកភ្នំសិនេរុ កិរិយាបែបនេះ ហៅថា **តិរិយំគមន**។

**សុរិយស្ស បន** ឯព្រះអាទិត្យមាន **ឧជុគមន** កិរិយានោះរហ័ស **តិរិយំគមន** កិរិយានោះយឺត ។ ឈ្មោះថា **តិរិយំគមន** គឺ

ព្រះអាទិត្យរិតមកទិសខាងត្បូងជិតភ្នំកណ្តាប់ចក្រវាល និងរិតមកទិសខាងជើងជិតភ្នំព្រះសិនេរុ កិរិយារិតចេញ រិតចូល ដូច្នេះ ឈ្មោះថា **តិរិយំគមន ។ ឧជុំគមន** គឺគោចរទៅដោយត្រង់ គឺទៅអំពីទិសខាងកើត ទៅកាន់ទិសខាងលិចនោះឯង ។ **សុរិយោ ចន្ទេន គន្ត្វា** កាលដែលព្រះអាទិត្យមាន **ឧជុំគមន** គឺកិរិយារហ័សជាងព្រះចន្ទនោះ បើខាងរនោច ព្រះអាទិត្យគោចរទៅជាមួយព្រះចន្ទ បិទបាំងមណ្ឌលព្រះចន្ទមិនឲ្យប្រាកដ លុះចាប់ពីថ្ងៃ ១ កើត ព្រះអាទិត្យក៏គោចរឆ្ងាយអំពីព្រះចន្ទបន្តិចម្តងៗ គឺ ១ ថ្ងៃ ១ សែនយោជន៍ ឯចន្ទមណ្ឌលក៏ប្រាកដបន្តិចម្តងៗ រហូតដល់ថ្ងៃ ១៥ កើត ចន្ទមណ្ឌលក៏ពេញបរិបូណ៌ ។ **តត្ថ ចន្ទមណ្ឌលំ** ព្រះចន្ទ និងព្រះអាទិត្យទាំង ២ នោះ បើប្រមាណដោយយោជន៍ វិជ្ឈមាត្រមានប្រមាណ ៤៩ យោជន៍ **សុរិយមណ្ឌលំ បន** ឯព្រះអាទិត្យវាស់ដោយវិជ្ឈមាត្រមានប្រមាណ ៥០ យោជន៍ ។ ចន្ទមណ្ឌលនៅខាងក្រោម គឺទាបជាងព្រះអាទិត្យ សុរិយមណ្ឌលនៅខាងលើ គឺខ្ពស់ជាងព្រះចន្ទប្រមាណ ១ យោជន៍ បើវាស់អំពីផ្ទៃខាងក្រោមរបស់ព្រះចន្ទ ទៅទល់គ្នានឹងផ្ទៃខាងលើរបស់ព្រះអាទិត្យប្រវែង ១០០ យោជន៍ដោយ

កំណត់ ។ ខាងក្នុងនៃចន្ទវិមានជាវិការនៃកែវមណី ខាងក្រៅជាវិការនៃប្រាក់ មានសភាពត្រជាក់ទាំងខាងក្នុង និងខាងក្រៅ ។ ខាងក្នុងនៃសុរិយវិមាននោះជាវិការនៃមាស ខាងក្រៅជាវិការនៃកែវផលិក មានសភាពក្តៅទាំងខាងក្នុង និងខាងក្រៅ ។ ក្នុងវេលាច ព្រះអាទិត្យនៅចំពីលើព្រះចន្ទ ព្រះចន្ទក៏មិនបានប្រាកដពន្លឺ ឧបមេយ្យដូចភាជន៍តូច ដែលត្រូវភាជន៍ធំបិទបាំង ដូច្នោះ ។ ពោលដោយតិរិយំគមនគតិ ព្រះអាទិត្យយឺតជាងព្រះចន្ទ តិរិយគមនៈនោះមាន ២ ផ្លូវ គឺ ទក្ខិណាយនៈ ១ ឧត្តរាយនៈ ១។ ផ្លូវអំពីទិសខាងជើងទៅកាន់ទិសខាងត្បូង ឈ្មោះថា **ទក្ខិណាយនៈ** ផ្លូវអំពីទិសខាងត្បូង ទៅកាន់ទិសខាងជើងនោះ ឈ្មោះថា **ឧត្តរាយនៈ** ព្រះអាទិត្យទៅកាន់មាគ៌ាទាំង ២ ឈ្មោះតិរិយំគមនៈ យឺតជាងព្រះចន្ទ ។ **ឆ ហិ មាសេហិ** ផ្លូវទាំង ២ នោះ ព្រះអាទិត្យគោចរចូល ៦ ខែ គោចរចេញ ៦ ទើបសម្រេច ។

ក្នុងទីនេះ នឹងចែកតាមសុរិយគតិទីបនីថា **តថា ហិ** ភាពដែលព្រះអាទិត្យគោចរចូល ៦ ខែ គោចរចេញ ៦ ខែនោះពិត ។ ផ្លូវដែលឈ្មោះថា ទក្ខិណាយនៈនោះ មានខែ ៦ គឺកក្កដា ១

សីហា ១ កញ្ញា ១ តុលា ១ វិច្ឆិកា ១ ធ្នូ ១ បណ្ដាផ្លូវខាងជើងមានខែ ៦ គឺមករា ១ កុម្ភៈ ១ មេសា ១ ឧសភា ១ មិថុនា ១ ។ វីថិគោចរនៃព្រះចន្ទ និងព្រះអាទិត្យនោះ មាន ៣ ផ្លូវ គឺអជវិថី ១ នាគវិថី ១ គោណវិថី ១ **អជានំ ឧទកំ** ធម្មតាពពែទាំងឡាយមានសន្ដានមិនចូលចិត្តទឹក **ហត្ថីនំ មនាបំ** ដំរីទាំងឡាយមានសន្ដានចូលចិត្តទឹក ឯសត្វគោទាំងឡាយ ត្រូវការត្រជាក់ និងក្ដៅស្មើគ្នា ។ កាលព្រះចន្ទ និងព្រះអាទិត្យគោចរក្នុងអជវិថី គឺផ្លូវពពែ ភ្លៀងក៏រាំងមិនបានធ្លាក់ក្នុងកាលនោះ ( ព្រោះវស្សវលាហកទេវបុត្រ ខ្លាចអំណាចចន្ទទេវបុត្រ និងសុរិយទេវបុត្រ មិនហ៊ានចេញពីវិមាន ) ក្នុងកាលណាព្រះអាទិត្យ និងព្រះចន្ទគោចរក្នុងនាគវិថី គឺផ្លូវដំរីក្នុងកាលណា ភ្លៀងក៏ធ្លាក់ជោកជាំក្នុងកាលនោះ ព្រះអាទិត្យ និងព្រះចន្ទគោចរក្នុងគោណវិថីកាលណា ភ្លៀងធ្លាក់ខ្លះ មិនធ្លាក់ខ្លះ តែល្មមប្រមាណក្នុងកាលនោះ ។

**ឥមស្មិំ បន ទីបេ** កាលព្រះអាទិត្យរះឡើងក្នុងជម្ពូទ្វីបនេះ តែជាថ្ងៃត្រង់សម្រាប់បុព្វវិទេហទ្វីប ជាថ្ងៃលិចសម្រាប់ឧត្តរកុរុទ្វីបនិងកណ្ដាលអធ្រាត្រសម្រាប់អមរគោយានទ្វីប បើមនុស្សក្នុងបុព្វវិទេហ

ទ្វីបមើលឃើញថ្ងៃរះ ថ្ងៃត្រង់ក្នុងឧត្តរកុរុទ្វីប ថ្ងៃលិចក្នុងអមរគោយានទ្វីប និងកណ្តាលអធ្រាត្រសម្រាប់ជម្ពូទ្វីប ។ បើមនុស្សក្នុងឧត្តរកុរុទ្វីបឃើញថ្ងៃរះ មនុស្សក្នុងអមរគោយានទ្វីបក៏ឃើញថ្ងៃត្រង់ មនុស្សក្នុងជម្ពូទ្វីបក៏ឃើញថ្ងៃលិច មនុស្សក្នុងបុព្វវិទេហទ្វីបក៏ជាអធ្រាត្រ ។ បើមនុស្សក្នុងអមរគោយានទ្វីបឃើញថ្ងៃរះ គឺថ្ងៃត្រង់ក្នុងជម្ពូទ្វីប ថ្ងៃលិចក្នុងបុព្វវិទេហទ្វីប អធ្រាត្រក្នុងឧត្តរកុរុទ្វីប ។

ដើម្បីឲ្យជាក់ច្បាស់ សូមមើលតារាងខាងក្រោម ៖-

១- ជម្ពូទ្វីប រះ →
- បុព្វវិទេហទ្វីប - ត្រង់
- ឧត្តរកុរុទ្វីប - លិច
- អមរគោយានទ្វីប - អធ្រាត្រ

២- បុព្វវិទេហទ្វីប រះ →
- ឧត្តរកុរុទ្វីប - ត្រង់
- អមរគោយានទ្វីប - លិច
- ជម្ពូទ្វីប - អធ្រាត្រ

៣- ឧត្តរកុរុទ្វីប រះ →
- អមរគោយានទ្វីប - ត្រង់
- ជម្ពូទ្វីប - លិច
- បុព្វវិទេហទ្វីប - អធ្រាត្រ

ជម្ពូទ្វីប - ត្រង់

៤- អមរគោយានទ្វីបរះ → បុព្វវិទេហទ្វីប - លិច

ឧត្តរកុរុទ្វីប - អធ្រាត្រ

វិសជ្ជនាថា **ឥមស្មឹំ បន ទីបេ** រូបភាពទី ១ កាលព្រះអាទិត្យរះបញ្ចេញពន្លឺបំភ្លឺក្នុងជម្ពូទ្វីប ឧត្តរកុរុទ្វីបជាពេលព្រះអាទិត្យអស្តង្គត គឺលិច អមរគោយានទ្វីបជាវេលាអធ្រាត្រ បុព្វវិទេហទ្វីបជាពេល ថ្ងៃត្រង់ ។ល។ **តេនាហុ បោរាណា** អាស្រ័យហេតុដូច្នោះព្រះអដ្ឋកថាចារ្យសម្តែងថា **អាទិកប្បម្ហិ បជា** ជាដើមដូច្នោះ សេចក្តីនេះមានក្នុងព្រះ បាលីទីបនីក៏មានន័យដូចសម្តែងមកហើយ ។

តទៅនឹងសម្តែងនៅក្នុង **គម្ពីរទីឃនិកាយ តតិយភាគ មហាវគ្គ អដ្ឋកថាមហានិទានសូត្រ** មានសេចក្តីថា មួយទៀត រាហូអសុរិន្ទ្រ ពីចុងសក់ដល់ចុងជើង ៤៨០០ យោជន៍ ចន្លោះដៃទាំងពីរខាង ១២០០ យោជន៍ ដោយកម្រាស់ ៦០០ យោជន៍ បាតដៃបាតជើងកម្រាស់ ២០០ យោជន៍ ប្រមុះ និងមាត់ ៣០០ យោជន៍ ម្រាមដៃនីមួយៗ ៥០ យោជន៍ ចន្លោះចិញ្ចើម ៥០ យោជន៍ ថ្ងាស ៣០០ យោជន៍ ក្បាល ៩០០ យោជន៍ ។

សួរថា ព្រះចន្ទ និងព្រះអាទិត្យ មានឫទ្ធិតេជៈច្រើនដូច្នេះ ដូចម្ដេចទើបរាហូអសុរិន្ទលេបបាន អាស្រ័យហេតុដូចម្ដេច លេបដូចម្ដេច ?

ឆ្លើយថា លេបចូលទៅពិតមែន ព្រោះថា រាហូអសុរិន្ទនោះធំក្រៃលែង ។ រាហូអសុរិន្ទមានកាយធំក្រៃលែងដូច្នេះ កាលបើឃើញព្រះចន្ទ និងព្រះអាទិត្យមានរស្មីដ៏រុងរឿង មានចិត្តប្រណែនទឹងគ្របសង្កត់ ក៏ទៅកាន់ទីគោចររបស់ព្រះចន្ទ និងព្រះអាទិត្យ **មុខំ វិវរិត្វា** មកឈរហាមាត់រង់ចាំលេបព្រះចន្ទ និងព្រះអាទិត្យ ។ រីព្រះចន្ទ និងព្រះអាទិត្យក៏អណ្ដែតតាមទីគោចរចូលទៅក្នុងមាត់ របស់រាហូ-អសុរិន្ទ ហាក់បីដូចរអិលធ្លាក់ចុះ ក្នុងរណ្ដៅមហានរកដ៏ជ្រៅ ៣០០ យោជន៍ **វិមានេ អធិវត្ថា ទេវតា** ពពួកទេវតាដែលអាស្រ័យនៅក្នុងវិមាន ភ័យខ្លាចមហិមា ស្រែករំពង ជ្រួលច្របល់ទៅទាំងវិមាន **កទាចិ** ជួនកាលរាហូអសុរិន្ទយកដៃបាំងក៏មាន ជួនកាលយកចង្កាកៀបសង្កត់ ប្រសិនបើមិនលេប ក៏លៀនអណ្ដាតបាំង ជួនកាលក៏បៀមក្នុងថ្ពាល់ **វេគំ បន ធារេតុំ** ប្រសិនបើនឹងពោលដោយការពិត រាហូអសុរិន្ទនេះមិនអាចនឹងបញ្ឈប់នូវកម្លាំងរបស់ព្រះចន្ទព្រះ

អាទិត្យនោះបានឡើយ **សចេ មារេស្សាមិ** ប្រសិនបើរាហូអសុរិន្ទគិតថា អាត្មាអញនឹងសម្លាប់ព្រះចន្ទព្រះអាទិត្យ គិតដូច្នេះហើយ ក៏លេបចូលទៅ **មុទ្ធកំ រាហុស្ស ភិន្ទិត្វា** សុរិយវិមានមានអាការដូចទម្លាយនូវក្បាលរបស់រាហូអសុរិន្ទ រួចហើយក៏ចេញមក ជួនកាលហាក់បីដូចអូសរាហូអសុរិន្ទឲ្យឱនទៅឱនមក **តស្មា** ព្រោះហេតុដូច្នោះ រាហូអសុរិន្ទក៏ត្រូវទ្រេតទ្រោតទៅតាមវិមាន **ចន្ទិមសុរិយា** ពិតណាស់ ព្រះចន្ទព្រះអាទិត្យទាំងពីរនេះ មានប្រក្រតីប្រទក្សិណភ្នំសិនេរុរាជ សញ្ចរមិនដាច់ ស្មើទៅតាមធម្មតា ។

ក្នុង ខុទ្ទកនិកាយ មហានិទ្ទេស អដ្ឋមភាគ អដ្ឋកថាសុប្បារកជាតក សេចក្តីថា **មហាសមុទ្ទេ ឱតារេត្វា** ចំណែកភ្នំសុមេរុរាជដែលជាស្តេចភ្នំប្រចាំលោកនេះ តាំងនៅក្នុងមហាមុទ្រនោះ ៨៤០០០ យោជន៍ ខ្ពស់អំពីផ្ទៃទឹកមហាសមុទ្រក៏ ៨៤០០០ យោជន៍ **ឆ កោវលំ** មិនតែកម្ពស់នោះទេ បណ្តោយ និងទទឹងនោះក៏ ៨៤០០០ យោជន៍ ស្មើគ្នាទាំងអស់ដោយជុំវិញ **ចត្តារោ អាលិន្ទា** ស្តេចភ្នំសិនេរុនោះមាន ៤ ជាន់ មួយជាន់ៗ មានមុខ ៤ ទាំងទំហំ ទាំងកម្រាស់ ៥០០០ យោជន៍ ជាទីលំនៅរបស់នាគ គ្រុឌ កុម្ភណ្ឌ យក្ខទាំងឡាយសម្រាប់

ការពាររក្សា **តាវតឹសទេវលោកា ចាថិនបស្សំ** ទិសខាងកើតនៃភ្នំសិនេរុនោះសុទ្ធតែប្រាក់ ហេតុដូច្នោះ ទឹកក្នុងមហាសមុទ្រទិសខាងកើតនោះក៏មានពណ៌ដូចប្រាក់ ។ ខាងទិសទក្សិណ មានកែវឥន្ទនិល ទើបទឹកក្នុងមហាសមុទ្រនោះខៀវ ទិសខាងលិចនោះ ក៏ប្រាកដដូចកែវផលិក ទិសខាងឧត្តរនោះក៏ប្រាកដដូចមាស ។ ទឹកក្នុងមហាមុទ្រនោះ ក៏មានពណ៌ដូចកែវផលិក និងដូចមាស ។ អាស្រ័យនូវហេតុនោះ ទើបមហាសមុទ្រមាន ៤ ដោយរស្មីនៃភ្នំសិនេរុនោះឯង ចាំងចុះមក ទើបមានឈ្មោះផ្សេងៗ គ្នា ។ ក្នុងមហាសមុទ្រទាំង ៤ សម្បូណ៌ទៅដោយកែវ **យត្ថ វជិរំ** មហាសមុទ្រណាច្រើនទៅដោយកែវវជិរ ក្នុងមហាសមុទ្រនោះ មានត្រីដែលមានដើមទ្រូវ និងប្រមុះដូចមនុស្សមុជងើបហែលក្នុងសមុទ្រនោះ ទើបសមុទ្រនោះ ឈ្មោះថា **ខុរមាលី** ។ មហាសមុទ្រណាច្រើនទៅដោយមាសនព្វគុណ ភ្លឺរុងរឿង ហាក់បីដូចជាគំនរភ្លើង មហាសមុទ្រនោះ ឈ្មោះថា **អគ្គិមាលី** ។ មហាសមុទ្រណាច្រើនទៅដោយប្រាក់ មហាសមុទ្រនោះមានពន្លឺ-ស ហាក់បីដូចជាទឹកដោះជូរនិងទឹកដោះស្រស់មហាសមុទ្រនោះឈ្មោះថា **ទធិមាលី** ។ មហាសមុទ្រណាច្រើនទៅដោយនីលមណី ទឹកក្នុងមហាសមុទ្រមាន

ពន្ទីខៀវ ហាក់បីដូចជាស្បូវភ្លាំង និងស្គា មហាសមុទ្រនោះឈ្មោះថា កុសមាលី ។ **យោ ឧស្សនត្តា** មហាសមុទ្រណាច្រើន ដោយកែវវិទូរ្យដ៏វិចិត្រ **សិនេរុស ឧបឌ្ឍភាគប្បមាណោ** ភ្នំយុគន្ធរដែលនៅជុំវិញភ្នំសិនេរុនោះ ទាំងទំហំ ទាំងកម្ពស់ ៤២០០០ យោជន៍ ពាក់កណ្ដាលភ្នំសិនេរុ ភ្នំឥសិន្ធរនោះ ទាំងទំហំ និងកម្ពស់ស្មើពាក់កណ្ដាលភ្នំយុគន្ធរ នៅជុំវិញភ្នំសិនេរុ **អស្សកណ្ណា** ភ្នំសត្តភណ្ឌ (ភ្នំ ៧) គឺយុគន្ធរ ឥសិន្ធរ ករវិកៈ សុទស្សនៈ នេមិន្ធរ វិន្តកៈ អស្សកណ្ណៈ ថយតាមលំដាប់គ្នាជាជាន់ៗ ទាបជាងគ្នាចុះមកពាក់កណ្ដាលៗ **សិនេរុយុគន្ធារំ** ក្នុងចន្លោះនៃភ្នំសិនេរុ និងយុគន្ធរនោះក្ដី ចន្លោះភ្នំឥសិន្ធរ និងភ្នំករវិកៈ និងសុទស្សនៈៗ និងនេមិន្ធរៗ វិន្តកៈៗ និងអស្សកណ្ណៈ ចន្លោះនោះជាមហាសមុទ្រទាំងអស់ ឈ្មោះថា សីទន្តរមហាសមុទ្រទាំងអស់ ដូច្នេះ ព្រោះអ្វី ព្រោះទឹកក្នុងមហាសមុទ្រនោះសុខុមសូម្បីរោមនៃសត្វក្អែកធ្លាក់ក៏លិចចុះ **សិនេរុស្មឹ ហិ បដិច្ចឋានំ** មហាសមុទ្រទាំង ៤ នេះ ដែលទទួលរស្មីនៃភ្នំសិនេរុ ហាក់បីដូចជាព្រៃបបុស និងព្រៃឫស្សី មហាសមុទ្រនេះឈ្មោះថា **នឡមាលី** ។ សម្ដែងមកនេះ ជាឈ្មោះនៃមហាសមុទ្រ ។ មហាសមុទ្រមួយទៀត

ឈ្មោះពលវាមុខី មហាសមុទ្រនេះ មានខ្យល់មួយពួកសម្រាប់ក្រសោបបង្វិលទឹកឲ្យខ្ពស់ឡើងឰដ៏អាកាស គឺកួចយកទឹកអំពីមហាសមុទ្រឲ្យខ្ពស់ឡើងទៅដល់ក្នុងកណ្តាប់ចក្រវាល **បុន មហាសមុទ្ទេ បតតិ** ទឹកនោះក៏ត្រឡប់ធ្លាក់ចុះមកកាន់មហាសមុទ្រវិញ លាន់សំឡេងគ្រាំងៗ ខ្ទាំងៗ ហាក់បីដូចនឹងបែកត្រចៀក និងបេះដូង មហាសមុទ្រនេះហៅពលវាមុខី **ជលស្ស វឌ្ឍនំ ហាយនញ្ច** មួយទៀត ទឹកឡើងនិងទឹកស្រកនោះ ក៏អាស្រ័យពលវាមុខីនេះឯង **ឥតោ អវញ្ញាស្មឹបិ** ពលវាមុខីកន្លែងដទៃទៀតក៏មាន **តំ អាវត្តមុខំ** ពលវាមុខីនោះធំដែលជាឈូងនៃមហាសមុទ្រ **តថា ហិ** ពាក្យដែលសម្តែងមកនេះពិតណាស់ កាលបើសត្វនរកទាំងឡាយ សោយនូវទុក្ខវេទនានៅក្នុងអវីចីមហានរកនោះ ទ្វារនៃនរកនោះបើកបិទជានិច្ច ដូច្នោះ **អគ្គិ–ក្ខន្ធោ** គំនរភ្លើងធំក៏ឆេះសន្ធោសន្ធៅចេញមកតាមទ្វារនោះ ញ៉ាំងខាងក្រោមផ្ទៃនៃមហាសមុទ្រ ដែលធំធេងរាប់រយយោជន៍ឲ្យក្តៅខ្ទាំងក្លា **ឧបរិ ឧទកំ** ទឹកដែលនៅខាងលើនោះក៏ក្តៅ ហាក់បីដូចទឹកដាំ មានសំឡេងយ៉ាងចម្លែកគួរខ្លាច មហាសមុទ្រដែលសម្តែងមកនេះឈ្មោះថាពលវាមុខីដូចគ្នា **មហាសមុទ្ទោ បន** រីផ្ទៃនៃមហាសមុទ្រនេះ

មានប្រក្រតីរុញចេញទៅៗ ដោយលំដាប់ៗ ដរាបដល់កណ្ដាប់ចក្កវាឡ ចូលទៅខាងក្នុង ដរាបដល់ជើងភ្នំសិនេរុ ក្នុងទីជិតចក្កវាឡ និង ភ្នំចកវាឡនោះ ទឹកមានជម្រៅ ៨៤០០០ យោជន៍ ទឹកខាងក្រោម ៤០០០០ យោជន៍នោះ សម្បូណ៌ទៅដោយត្រី, ទឹកខាងលើ ៤០០០០ យោជន៍នោះ ផុកដោយខ្យល់, ទឹកក្នុងទីកណ្ដាល ៤០០០ យោជន៍ មិនកម្រើកញាប់ញ័រ នៅនឹងថ្កល់ជាប្រក្រតី ។ ក្នុងផ្ទៃនៃមហាសមុទ្រ នោះមានរលក ៣ ពួក រលកមួយពួកឈ្មោះថា **មហិន្ទវីចិ** រលកនោះ ធំមានកម្ពស់ ៦០ យោជន៍ ។ រលកមួយពួកឈ្មោះថា **គង្គាវីចិ** រលកនោះ ធំមានកម្ពស់ ៥០ យោជន៍ ។ រលកមួយពួកទៀតឈ្មោះថា **រោហណវីចិ** រលកនោះធំមានកម្ពស់ ៥ យោជន៍ ។ មួយទៀត ក្នុងផ្ទៃនៃមហាសមុទ្រ នោះ មិនមានសាកសពឯណានីមួយធ្លាក់ចុះ និងអណ្ដែតនៅទីនោះ ឡើយ ទីបំផុតសូម្បីតែខ្មោចដំរី ខ្មោចសេះជាដើមធ្លាក់ចុះអណ្ដែតនៅ ទីទឹកនោះហើយ រលកនោះក៏រសាត់នាំឡើងទៅលើច្រាំងទាំងអស់ ។ ក្នុង គម្ពីរទីឃនិកាយ មហាវគ្គ អដ្ឋកថាមហានិទានសូត្រ សម្ដែងថា **តស្មិំ តិមិ ឆាម មច្ឆា** ក្នុងផ្ទៃនៃមហាសមុទ្រនោះ មានត្រីធំៗ ជាច្រើន ត្រី ១ ឈ្មោះតិមិ ប្រវែង ២០០ យោជន៍ ត្រី ១

ឈ្មោះតិមិង្គល ប្រវែងធំ ៣០០ យោជន៍ ត្រី ១ ឈ្មោះតិមិរមិង្គល ប្រវែងធំ ៥០០ យោជន៍ ។ នៅមានត្រីធំ ៤ ទៀត ឈ្មោះត្រីអានន្ទ ១ តិមិន្ទៈ ១ អជ្ឈារោហៈ ១ មហាតិមិរៈ ១ **ឥមេ ចត្តារោ** ត្រីទាំង ៤ នេះ ត្រីនីមួយៗ ប្រវែង ១០០០ យោជន៍ **តស្មិំ បន មុត្តា វសន្តិ** ក្នុងមហាសមុទ្រនោះមានវត្ថុវិសេសៗ ដូចជាកែវនពរ័ត្ន ជារតនវត្ថុនៅក្នុងមហាសមុទ្រ គឺកែវមុក្តា កែវមណី កែវក្រហម កែវខៀវជាដើមគ្រប់យ៉ាង មានស័ង្ខទក្ខិណាវដ្ដ ស័ង្ខទង់ដែង ស័ង្ខមាស និងស័ង្ខសិលា ប្លែកៗ ច្រើនយ៉ាង មានថ្មខ្មៅ ថ្ម-ស ថ្មមុក្តាជាដើម ។ អ្នកប្រាជ្ញគប្បីជ្រាបសន្និដ្ឋានថា ផ្ទៃនៃមហាសមុទ្រនោះជាកន្លែងកើតនៃកែវច្រើនយ៉ាងដូច្នេះ កិរិយាពោលដោយមហាសមុទ្រសង្ខេប ចប់ត្រឹមតែប៉ុណ្ណេះ ។

លំដាប់នេះនឹងសម្ដែងនូវ សំយុត្តនិកាយ សគាថវគ្គ ទុតិយភាគ សក្កសំយុត្ត អដ្ឋកថាសុវីរសូត្រ តទៅ **សិនេរុ មុទ្ធនិ** កំពូលភ្នំសិនេរុរាជនោះ ជាពិភពតាវត្តិង្ស ទំហំប្រមាណមួយម៉ឺនយោជន៍ វិចិត្រទៅដោយសណ្ឋាន និងសួនឧទ្យាន គួរជាទីសប្បាយរីករាយក្រៃលែងព្រះឥន្ទ្រាធិរាជជាម្ចាស់ពិភពតាវត្តិង្សនោះ កាលពីដើមជាមយមាណព

នៅក្នុងស្រុកអចលគ្រាម ជិតដែនមគធៈ បបួលនូវបុរស ៣៣ នាក់ បំពេញនូវវត្តបទ ៧ ប្រការ ។ ចុតិចាកជាតិនោះ ទៅកើតក្នុងទេវលោកក្នុងស្ថានតាវត្តិង្សទាំងអស់គ្នា ។ បណ្តាទេវបុត្រដែលបានទៅកើតមុនកាលក្រឡេកឃើញព្រះឥន្ទ្រ និងបរិវារប្រកបទៅដោយឋានៈ ១០ ប្រការ ដោយអានុភាពនៃកម្មដ៏ខ្លាំងក្លា ទើបគិតថា ទេវបុត្រនេះជាអាគន្តុកៈមកហើយ ទើបត្រៀមទឹកគន្ធបានជាដើមដើម្បីនឹងផឹក ។ សក្កទេវរាជបានឲ្យពាក្យដាស់តឿនដល់បរិវាររបស់ខ្លួនថា នៃអ្នកនិទ្ទុក កុំផឹកទឹកគន្ធបាន ចូរសម្តែងត្រឹមតែអាការផឹកត្រឹមតែប៉ុណ្ណោះ ពួកគេបានធ្វើយ៉ាងនោះ ទេវបុត្រដ៏ដើមផឹកទឹកគន្ធបាន ដែលគេនាំមកឲ្យតាមសេចក្តីត្រូវការ ស្រវឹងដួលដេកនៅលើផែនដីមាសនោះៗ ។ ស្តេចសក្កៈពោលថា ចូរចាប់ទាំងមេទាំងកូន ដូច្នេះ ចាប់ត្រង់ជើងគ្រវែងទៅត្រង់ជើងភ្នំសិនេរុ ។ សូម្បីទេវបុត្រនោះមិនស្លាប់ ក៏ធ្លាក់ចុះនៅទីនោះ ដោយតេជះនៃបុណ្យរបស់ខ្លួន ។ ទេវបុត្រទាំងនោះមានសេចក្តីដឹងខ្លួនក្នុងវេលាធ្លាក់ចុះដល់ពាក់កណ្តាលភ្នំសិនេរុ ទើបពោលថា ពួកយើងកុំផឹកសុរាទៀតឡើយ ។ ចាប់តាំងអំពីនោះ ទើបបានឈ្មោះថា **អសុរ** ។ ការពិត កម្មប្បច្ច័យ គឺកុសលកម្មដែលអសុរ

ទាំងឡាយបានសន្សំមក គឺមិនទាន់ឲ្យផលសព្វគ្រប់ ។ រីកពអសុរធំទូលំទូលាយប្រមាណមួយម៉ឺនយោជន៍ មានឧតុជាសមុដ្ឋានកើតឡើងនៅពីខាងក្រោមភ្នំសិនេរុ ព្រោះបច្ច័យនៃកម្មរបស់ពួកគេ ដោយមានដើមច្រនៀងប្រចាំអសុរពិភព ។

ចំណែកសក្កទេវរាជក៏ចាត់ចែងការពាររក្សា ដើម្បីនឹងមិនឲ្យអសុរវិលត្រឡប់ឡើងមកបាន ។ ជួនកាលពួកអសុរមានកម្លាំងខ្លាំងក្លា ដេញពួកទេវតាឲ្យត្រឡប់ចូលទៅកាន់នគរវិញ ទេវតាទាំងឡាយក៏បិទទ្វារហើយជាការស្រេច ពួកអសុរពាន់សែននាក់ ក៏មិនអាចប្រានចូលបានឡើយ ។ ជួនកាលពួកទេវតាមានកម្លាំងខ្លាំងក្លា ដេញពួកអសុរទាំងឡាយឲ្យបែក រុញត្រឡប់ចូលក្រុងវិញ ពួកអសុរបិទទ្វារក្រុងហើយក៏ជាការស្រេច ។ សូម្បីពួកទេវតាពាន់ម៉ឺន ក៏ប្រានចូលទៅមិនបាន **ឥមានិ ទ្វេ នគរានិ** ព្រះនគរទាំងពីរនេះអំពីដំបូងឈ្មោះថា **អយុធបុរីនគរ** ហេតុសង្គ្រាមទេវតា និងអសុរ មិនមានអ្នកណាឈ្នះ មិនមានអ្នកណាចាញ់ **សក្កោន នគររក្ខា** សក្កទេវរាជព្រះអង្គចាត់ចែងពលយោធា ៥ ពួក ត្រង់ជើងភ្នំសិនេរុទាំង ៤ ជាន់ ។ នៅជើងភ្នំសិនេរុជាន់ទី ១ នោះ តែងតាំងពពួកនាគឲ្យនៅរក្សា ជាន់ទី

២ នោះ ពពួកគ្រុឌ ជាន់ទី ៣ នោះ ពពួកកុម្ភណ្ឌ ជាន់ទី ៤ ពពួកយក្ខ ជាន់ទី ៥ ពពួកមហារាជទាំង ៤ ។

**តេ បន អសុរា** ចំណែកពួកអសុរទាំងឡាយនោះ កាលខ្លួនសោយទិព្វសម្បត្តិនៅក្នុងអសុរពិភព បរិបូណ៌ដោយអាយុ វណ្ណៈ យស និងភាពជាធំ ដូចគ្នានឹងស្ថានតាវត្តិង្ស ហេតុដូច្នោះ សម្គាល់ថាខ្លួននោះគ្រប់គ្រាន់ហើយ ក៏ភ្លើតភ្លើនប្រមាទ ។ កាលដើមប្រទៀងមានផ្ការីកហើយ ក៏ដឹងខ្លួនថា នគរនេះមិនមែនទេវនគរ ។ នគររបស់យើងនោះមានដើមបារិច្ឆត្តកព្រឹក្សប្រចាំព្រះនគរ កាលបើរឭកដឹងឡើងតូចចិត្ត ក៏ខឹងចងគំនុំនឹងសក្កទេវរាជថា **ជរសក្កោ មហាសុរំ ចាបេត្វា** សក្កៈចាស់នេះបោកបញ្ឆោតអញឲ្យផឹកសុរាជាច្រើនរួចហើយ ក៏ដណ្ដើមយកទេវនគររបស់អញ មកពួកយើងនាំគ្នាទៅធ្វើសង្គ្រាមយកសម្បត្តិរបស់យើងមកវិញ គិតរួចហើយ ក៏ចាត់ចែងសព្វាវុធដែលវិចិត្រដោយកែវ និងមាស ឡើងជិះហត្ថិយាន និងអស្សយានទូងស្គរជ័យ ៣ ដង ហើយក៏ជ្រែកទឹក ផុសឡើងមកប្រារព្ធដើម្បីនឹងឡើងភ្នំសិនេរុ **អថ តេសា** កាលពួកអសុរឡើងកាន់ភ្នំសិនេរុនោះ វីនាគយោធាទាំងឡាយ ដែលនៅជាន់ទី ១ ក៏ចូលតយុទ្ធនឹងពួកអសុរ

ទាំងឡាយ **តស្មឹ ខោ បន យុទ្ធេ** អ្នកប្រាជ្ញគប្បីសន្និដ្ឋានក្នុងចម្បាំង នោះ កាលបើវាយចាក់គ្នាក្ដី អ្នកណាមួយនឹងត្រូវឈើចាប់ ឬរបួស ត្រឹមតែរលាត់ស្បែកតែម្នាក់មិនមាន ពពួកទេវតា និងពពួកអសុរ បានច្បាំងគ្នា ប្រៀបដូចកូនក្មេងតូចៗ ច្បាំងគ្នា ដូច្នោះ **កោដិ-សតាបិ** ហ្វូងនាគច្រើនជាងរយកោដិពាន់កោដិ ច្បាំងនឹងអសុរ ហ្វូងនាគឈ្នះ អសុរចាញ់ ។ **អសុរបុរំ យេវ បវេសេត្វា** ដេញ ពួកពលសេនាអសុរឲ្យត្រឡប់ចូលកាន់ពិភពអសុរ **សចេ បន អសុរា** ប្រសិនបើអសុរមានកម្លាំងខ្លាំងក្លា ញ៉ាំងហ្វូងនាគឲ្យចាល ចាញ់ ហើយក៏ឡើងទៅដល់ជើងភ្នំជាន់ ២ ច្បាំងជាមួយនឹងគ្រុឌ ពេលចាញ់គ្រុឌ ត្រឡប់ចូលក្រុងវិញ ។ ពេលឈ្នះរហូតឡើងទៅ ដល់ជាន់ទី ៥ ។ ស្ដេចចតុលោកបាលទាំង ៤ ឡើងទៅក្រាបទូល សក្កទេវរាជៗ ក៏យាងឡើងកាន់វេជយន្តរថ លើកពលទេពវាហនៈ ចេញចាកទេវនគរ ដើម្បីច្បាំងនឹងអសុរទាំងឡាយ **សោ បន រថោ** វេជយន្តរាជរថនោះ ប្រវែង ១៥០ យោជន៍ **តស្ស បច្ឆិមន្តោ** ចន្ទោលរថនោះប្រវែង ៥០ យោជន៍ តួរថ ៥០ យោជន៍ កន្ទុយរថ ៥០ យោជន៍ រតនបល្ល័ង្កតម្កល់នៅលើរថនោះកម្ពស់ ១ យោជន៍ មាន

ស្វេតច្ឆត្រកម្ពស់ ៣ យោជន៍ នឹមម្ខាងៗ ទឹមដោយសេះ ១០០០ គ្រឿងតាក់តែងគ្រៅអំពីនោះច្រើនក្រៃលែងហួសប្រមាណ ។ ទង់ជ័យដោតនៅត្រង់ចន្ទោលរថនោះ មានកម្ពស់ ២៥០ យោជន៍ ។ វេជយ័ន្តរាជរថនោះ កាលបើមានខ្យល់បក់ត្រូវ ចង្រ្កង់ក៏បន្លឺនូវសំឡេងដូចតូរ្យតន្ត្រី ចំណែកសំឡេងរថ សំឡេងសេះ និងសំឡេងទង់ ប្រសិនបើឲ្យសំឡេងព្រមគ្នាហើយ សំឡេងនោះ ហាក់បីដូចសំឡេងអសនីបាត **សោ បន រថោ** គួរនឹងពោលនូវ ភាពអស្ចារ្យនៃវេជយ័ន្តរាជរថនេះ មានភាពអស្ចារ្យក្រៃលែងណាស់ សូម្បីភ្នំសិនេរុ និងភ្នំកណ្តាប់ចក្រវាលនៅពាំងអំពីមុខក្តី ក៏គង់រុញទម្លុះធ្លាយអស់ទៅបានយ៉ាងលឿនរហ័ស ដូចទៅក្នុងអាកាស **កស្មា** ព្រោះហេតុអ្វី **តស្ស បុញ្ញ បច្ចយេន និព្វត្តត្តា** ព្រោះថា រថនេះកើតអំពីបច្ច័យគឺបុញ្ញាភិសម្ភាររបស់សក្កទេវរាជ ម្ចាស់ពិភពតាវត្តិង្ស **តេសំ វចនំ សុត្វា** សក្កទេវានមិន្ទ ព្រះអង្គទ្រង់ព្រះសណ្តាប់ស្តេចចតុលោកបាលក្រាបទូលហើយ ព្រះអង្គក៏ឡើងកាន់ព្រះវិជយរាជរថទៅដោយខ្លួនព្រះអង្គខ្លះ ជូនកាលក៏ប្រើឲ្យរាជឱរសលើកពលទៅច្បាំងខ្លះ **តស្មិំ បន ទិវសេ** ថ្ងៃមួយ សក្កទេវានមិន្ទ លើកពលសេនាចេញចាកទេវនគរ

**អត្តុគ្គន្ធា** ហោះមកតាមអាកាស ចាប់ជើងអសុរគ្រវែងចុះមកកាន់ផ្ទៃនៃមហាសមុទ្រនោះ ហើយត្រឡប់វិលចូលទៅនគរវិញ ទើបនិម្មិតរូបព្រះអគ្គ តាំងទុកត្រង់ខ្លោងទ្វារទាំង ៤ **តស្មា** ព្រោះហេតុដូច្នោះ នាកាលអសុរទាំងឡាយវាយទម្លាយពលសេនាការពារទាំង ៤ ផ្នែក រំលងរហូតឡើងមកហើយ ក្រឡេកឃើញរូបព្រះឥន្ទ្រក៏ថយត្រឡប់ទៅវិញ ដោយសម្គាល់ថា ព្រះឥន្ទ្រលើកកងទ័ពមក **ឃរំ អសុរសង្គាមេ** ក្នុងកាលអសុរធ្វើសង្គ្រាមដូច្នេះ វិវេបចិត្រាសុរជាធំទើបត្រាស់បញ្ជាអសុរទាំងឡាយថា **សចេ មារិសា** នៃពួកយើងទាំងឡាយ បើទេវតាចាញ់យើងហើយ ចូរយើងនាំគ្នាចាប់សក្កទេវានមិន្ទនោះឲ្យបាន ចាប់រួចហើយ ចូរចង ៥ ចំណង គឺដៃទាំង ២ ជើង ទាំង ២ ក ១ ហើយ ចូរនាំយកមកឲ្យយើង ។ ព្រះឥន្ទ្រសោតក៏បញ្ជាចំពោះទេវតាដូចគ្នាដែរ ។ **អជេកធិវសំ** គ្រាមួយ អសុរទាំងឡាយចាញ់ ទេវតាទាំងឡាយចាប់ខ្លួនវេបចិត្រាសុរបាន ចងទៅដោយប្រវាក់មាសគម្រប់ ៥ ប្រការ នាំយកទៅថ្វាយព្រះឥន្ទ្រ **ទេវសង្ខលិកាឆាម** ឈ្មោះថា ប្រវាក់ទិព្វនេះសោត មិនមែនធំទេ សរសៃតូចប៉ុនសរសៃឈូក ឬសរសៃសម្បុកពីងពាង តែអាចការពារឥរិយាបថបាន

គួរយល់ថា តូចៗ ប៉ុណ្ណោះ បើកាត់ដោយកាំបិត ឬពូថៅក៏មិនដាច់ ។ កាលនឹងចង ក៏ចងដោយចិត្ត កាលឲ្យរបូតទៅវិញ ក៏របូតទៅដោយចិត្ត គឺមិនមានអ្នកណា អាចស្រាយចេញបានឡើយ ។

**វេបចិត្តិ បន** ឯវេបចិត្រាសុរ កាលបើខ្លួនត្រូវជាប់ចំណង យ៉ាងនេះ ក៏នៅតែមិនខ្លាចព្រះឥន្ទ្រ ក៏ត្រឡប់ស្រែកជេរផ្តាសាព្រះ-ឥន្ទ្រដោយអក្កោសវត្ថុ ១០ យ៉ាង គឺ **ចោរោសិ** អាចោរ **ពាលោសិ** អាមនុស្សពាល អាល្ងើ អាអូដ្ឋ អាគោ អាក្របី អាឆ្កែ អានរក អាតិរច្ឆាន អាមនុស្សគ្មានសុគតិ ដោយវាចាជាអសប្បុរសដ៏អាក្រក់ ។ ហើយពោលដដែលៗ ដោយវាចាជាអសប្បុរសដ៏អាក្រក់ថា **ជរសក្ក** នែសក្កៈចាស់ ឯងឈ្នះយើងហើយ កាលបើចាញ់យើងវិញ យើងក៏ចាប់ឯងយកទៅចងឯកណ្តាលទ្វារក្រុងដូចគ្នា ហើយក៏នឹងបបួលគ្នាវាយឲ្យចាស់ដៃ ពោលដដែលៗ ដូច្នោះ ។ **សក្កោ បន** ឯព្រះឥន្ទ្រសូម្បីបានឮ ក៏មិនយកចិត្តទុកដាក់ ។ **អស្សមត្តកេ វិធនន្តោ** ដូចព្រះអង្គបន្សាត់បង់នូវពាក្យផ្តាសានោះឯង ទុកនៅលើសិរសារបស់វេបចិត្រាសុរនោះ ហើយព្រះអង្គក៏ឡើងកាន់សាលាធម្មសភា ។

**អថ មាតលិ សង្គាហកោ** លំដាប់នោះឯង ទើបមាតលី

ទេវបុត្ររំពឹងគិតថា **កិន្នុខោ** នេះមានហេតុដូចម្ដេចហ្ន៎ ទើបសម្ដេចអមរិន្ទព្រះអង្គអត់ធន់បាន តើព្រះអង្គទ្រង់ខ្លាច ឬព្រោះទ្រង់មានកម្លាំងខ្សោយ ទើបក្រាបបង្គំទូលសួរសេចក្ដីនោះដោយគាថាថា **ភយា នុ មឃវា សក្ក** ជាដើម ។ **អថ សក្កោ ទេវរាជា** សក្កទេវរាជព្រះអង្គទ្រង់សណ្ដាប់ហើយ ក៏ត្រាស់ប្រាប់កម្លាំងអត់ធន់របស់ព្រះអង្គ ក៏ពោលជាគាថាថា **នាហំ ភយា ន ទុព្ពល្យា ខមាមិ វេបចិត្តិនោ កថំ ហិ មាទិសោ វិញ្ញូ** ដូច្នេះជាដើម សេចក្ដីក្នុងគាថានោះថា ម្នាលមាតលី ខ្លួនយើងនេះ មិនមែនខ្លាចចំពោះវេបចិត្រាសុរនោះទេ **ន ទុព្ពល្យា** ម្យ៉ាងទៀត យើងមានកម្លាំងខ្សោយជាងវេបចិត្រាសុរនោះក៏មិនមែន **កថញ្ហិ មាទិសោ វិញ្ញូ** បុគ្គលជាអ្នកប្រាជ្ញ ឈ្លាសក្នុងគតិលោក និងគតិធម៌ដូចយើងនេះ នឹងតប-តជាមួយបុគ្គលពាលបានប្រយោជន៍អ្វី ។ **យោ ហវេ ពលវា សន្តោ** នៃមាតលី យើងនឹងពោលឲ្យអ្នកស្ដាប់ បើបុគ្គលណាមានកម្លាំងច្រើនជាង **តិក្ខតិ** បានអត់នូវទោសរបស់អ្នកមានកម្លាំងខ្សោយជាងខ្លួន បុគ្គលនោះក៏នឹងជាទីសរសើរនៃបណ្ឌិតទាំងឡាយថា **បរមំ ខន្តិ** ជាអ្នកមានអធិវាសនខន្តីដ៏ឧត្ដមដោយពិត **យោ កុទ្ធំ បដិកុជ្ឈតិ** ម្យ៉ាងទៀត

បើអ្នកណាឃើញថាគេក្រោធ ក៏ក្រោធតបគេវិញ **តេន ធាបិយោ** អ្នកដែលក្រោធតបគេនោះឈ្មោះថា ជាមនុស្សអាក្រក់ជាងអ្នកដែលក្រោធមុននោះទៅទៀត **កុទ្ធំ អប្បដិកុជ្ឈន្តោ** ប្រែថា ឃើញគេក្រោធខ្ញួនប្រឹងប្រែងអត់ធ្មត់ មិនក្រោធតបនឹងអ្នកដែលក្រោធ បុគ្គលពួកនោះឈ្មោះថា ឈ្នះនូវសង្គ្រាមដែលគេឈ្នះបានដោយកម្រ **ទុជ្ជយំ** សង្គ្រាម គឺក្រោធ និងក្រោធតប វាយទៅ វាយមក ជេរទៅជេរមក ទាំងនេះ ជាកំពូលសង្គ្រាម ប៉ុន្មាននាក់ នឹងឈ្នះបាន ? **ខន្តិពលំ វណ្ណេត្វា** អមរិន្ទ្រាធិរាជ ព្រះអង្គសម្ដែងនូវអានិសង្សនៃខន្តីថា មានផលច្រើន ដោយវិសេសសម្រេចហើយ ទើបមានទេវ-បញ្ជាក់ត្រាស់ចំពោះវេបចិត្តិអសុរថា នៃវេបចិត្តិអសុរ **សបថំ ករោហិ** លោកស្បថសិនចុះ ថាយើងមិនប្រទូស្តដល់គ្នា ខ្ញុំក៏នឹងដោះលែងក្នុងកាលឥឡូវនេះ **សបថំករោន្តោ** កាលដែលវេបចិត្រាសុរនឹងស្បថសច្ចា ទើបពោលគាថាថា **យំ មុសា ភណតោ ធាបំ យំ អរិយុបវាទិនោ មិត្តទ្ទុនោ ច យំ ធាបំ** ជាដើម ប្រែថា **សុជម្បតិ** បពិត្រសុជម្បតិ ខ្ញុំនិយាយឲ្យស្ដាប់ **យំ ធាបំ** វិបាបនៃមុសាវាទឯណា មានទោសច្រើន ដូចមុសាវាទរបស់ចេតិយរាជនោះ

ក្តី រីអរិយុបវាទកម្មឯណា មានទោសច្រើន ដូចអរិយុបវាទរបស់កោកាលិកនោះក្តី រីបាបនៃការប្រទូស្តចំពោះមិត្រឯណាមានទោសច្រើន ដូចនាយព្រានដែលប្រទូស្តចំពោះស្តេចពានរនោះក្តី រីបាបនៃអកតញ្ញូឯណាមានទោសច្រើន ដូចបាបអកតញ្ញូរបស់ទេវទត្តនោះក្តី បាបទាំង ៥ យ៉ាងនេះ ជាបាបយ៉ាងក្រៃលែង ។ ប្រសិនបើខ្ញុំនេះប្រទូស្តចំពោះលោកតទៅ បាបដែលធំៗ នោះ សូមឲ្យបានចំពោះខ្លួនខ្ញុំនេះចុះ ។ សម្តេចអមរិន្ទ្រកាលដែលបានឮពាក្យស្បថសច្ចាដូច្នេះហើយ ក៏ដោះលែងវេបចិត្រាសុរនោះទៅ សម្តែងមកត្រឹមប៉ុណ្ណេះជាសេចក្តីកន្លងមកហើយ ប៉ុន្តែនេះចាប់សម្តែងបន្ត ដែលទើរនៅពាក់កណ្តាលនោះតទៅ ។

ផ្តើមសេចក្តីវិសេសក្នុងអសុរសង្គ្រាមនោះដូចតទៅនេះ **ទេវាសុរសង្គាមោ** នាកាលសង្គ្រាមទេវតា និងអសុរប្រព្រឹត្តទៅនោះរមែងប្រព្រឹត្តទៅ នៅលើផ្ទៃនៃមហាសមុទ្រដោយច្រើន **ចក្កវាឡមហាសមុទ្ទបិដ្ឋិយញ្ច** ការពិត នៅលើផ្ទៃនៃមហាសមុទ្រមួយ ជិតគ្នានឹងភ្នំចក្កវាឡ មានតាបសសាងបណ្ណសាលា គង់នៅច្រើនអង្គមួយអង្គៗ មានសីលាចារវត្ត ឈានសមាបត្តិដ៏ល្អ **អសុរានញ្ច សព្វកាលំ** នាកាលអសុរទាំងឡាយធ្វើសង្គ្រាមនឹងទេវតា មានតែការ

ចាញ់ច្រើនជាងឈ្នះ កាលដែលខ្វាត់ខ្វាយរត់គេចទៅ ក៏រត់ទៅតាមបណ្ណសាលារបស់តាបសទាំងឡាយនោះ ។ អសុរទាំងឡាយក៏សម្គាល់ក្នុងចិត្តថា ព្រះឥន្រ្ទមកប្រឹក្សាជាមួយតាបសទាំងឡាយនេះ ទើបពួកយើងទាំងឡាយចាញ់ កាលបើខ្លួនឯងយល់ដូច្នេះហើយ ក៏មានសេចក្តីក្រោធចំពោះតាបសទាំងឡាយនោះ នាំគ្នាទាញអូសបណ្ណសាលា រួចហើយនាំគ្នាវាយកម្ទេចឆ្នាំងទឹកចោល និងបរិក្ខារទាំងឡាយ ហើយក៏ចៀសចេញទៅ **ឥសយោ** កាលបើតាបសទាំងឡាយមកអំពីស្វែងរកផ្លែឈើ ក៏មានសេចក្តីលំបាកដោយការជួសជុលអាស្រម **តេ ពុនប្បុនំ** អសុរទាំងឡាយនោះប្រទូស្តដូច្នេះច្រើនលើកច្រើនសា ទើបតាបសទាំងឡាយប្រឹក្សាគ្នាថា **អម្ហាកំ ភយំ** ភ័យអន្តរាយកើតដល់ពួកយើងទាំងឡាយច្រើនដង ដូច្នេះ ក៏ព្រោះសង្គ្រាមទេវតា និងអសុរ ពួកទេវតាគេប្រកបដោយធម៌ ទើបមានជ័យជម្នះ ពួកអសុរទាំងឡាយមិនតាំងនៅក្នុងធម៌ ទើបចាញ់ បើដូច្នោះ យើងទាំងឡាយត្រូវនាំគ្នាទៅកាន់សម្នាក់របស់សម្ពរអសុរ នឹងសូមអភ័យចំពោះសម្ពរអសុរ ទើបបាននូវសេចក្តីសុខ តាបសមានគំនិតព្រមគ្នាហើយ ក៏ទៅកាន់សម្នាក់របស់សម្ពរអសុរ តាបសទៅដល់ហើយ

ទើបសូមអភ័យដោយគាថាថា **កាមំ ករោហិ តេ ទាតុំ ភយស្ស វា អភយស្ស វា** ជាដើម មានសេចក្តីថា បពិត្រមហាភាជ អាត្មាភាពទាំងឡាយនេះនាំគ្នាមក ដើម្បីសូមនូវអភ័យ **កាមំ ករោហិ** តាមតែមហាបពិត្រនឹងប្រទានឲ្យ កាលបើប្រាថ្នាដើម្បីនឹងឲ្យនូវអភ័យ ឬនឹងមិនឲ្យនូវអភ័យ ក៏តាមតែព្រះទ័យ ។ សម្ពរអសុរបានស្តាប់ហើយ ទើបត្រាស់ថា បពិត្រតាបសទាំងឡាយ តាបសទាំងឡាយនេះពេញចិត្តសេពគប់ជាមួយនឹងព្រះឥន្ទ្រ ដែលជាមនុស្សមានកំហុស ហើយត្រឡប់មកសូមអភ័យ ខ្ញុំមិនឲ្យអភ័យឡើយ ។ តាបសទាំងឡាយនេះមានភ័យតែម្យ៉ាង **តេ ឥសយោ** តាបសទាំងឡាយនោះ បានស្តាប់ពាក្យសម្ពរអសុរដូច្នេះហើយ ក៏ពោលជាគាថាថា **អភយំ យាចមានំ ភយមេវ ទទាសិ នោ** ដូច្នេះជាដើម ប្រែថា នៃអសុរចិត្តបាប អាត្មាទាំងឡាយមកដោយប្រាថ្នានឹងសូមនូវអភ័យ មិនដឹងសោះថា ត្រឡប់បានមកនូវភ័យទៀត **បដិគ្គណ្ហាម តេ** អាត្មាទាំងឡាយក៏នឹងទទួលយកនូវអភ័យ ភ័យនោះក៏ធ្លាក់ទៅលើអ្នកវិញ **យាទិសំ វប្បតេ ពីជំ** នៃសម្ពរអសុរ **កល្យាណកា** ធម្មតាពូជទាំងឡាយដែលបុគ្គលសាបព្រោះដោយប្រការណា កាលបើនឹងឲ្យផលនោះ ក៏មិនខុសអំពី

ពូជដែរ **កល្យាណការី** បុគ្គលធ្វើនូវកុសលនោះ ក៏នឹងបាននូវផល ជាកុសល ។ **ចាបការី ច** ឯបុគ្គលដែលធ្វើបាប ក៏សោយនូវផល ជាអកុសលដ៏លាមក **ឃវំ តថា** ក៏មានឧបមេយ្យដូច្នោះ **អភិ-សប្បិត្វា** លុះផ្តាសាដូច្នេះហើយ តាបសទាំងឡាយ ក៏បាត់អំពីទី នោះ មកប្រាកដនៅក្នុងបណ្ណសាលារបស់ខ្លួនវិញ **អភិសប្បិត-កាលតោ** តាំងអំពីថ្ងៃដែលតាបសទាំងឡាយដាក់ផ្តាសាមក សម្ពរ អសុរសោយមិនបាន ផ្ទំមិនលក់ មានតែការភ័យតក់ស្លុតជានិច្ច មួយថ្ងៃ ៣ ដង។ **សាយមាសភត្តំ ភុញ្ជិត្វា** វេលាល្ងាចសោយព្រះ ក្រយាហាររួចហើយ ក៏យាងចូលទៅក្រឡាព្រះបន្ទំដើម្បីផ្ទំ **ឱនន្ត-មត្តាយ** គ្រាន់តែញ៉ាំងព្រះកាយឲ្យទ្រេតចុះដើម្បីនឹងផ្ទំ ក៏ឃើញមនុស្ស មកចោមរោមជុំវិញ ចាក់ដោយលំពែងដ៏ធំៗ បណ្តាលឲ្យភ័យខ្លាច ព្រួយចិត្តភ្លាមៗ ក៏ស្ទុះក្រោកឡើង **វិរវន្តោ** ស្រែកឡើងដោយ សំឡេងដ៏ខ្លាំងថា នរណានឹង មកធ្វើអ្វីដល់ខ្ញុំ សំឡេងនោះក៏លាន់ឮ ឡើងទូទាំងក្រុង រហូតដល់ម៉ឺនយោជន៍ ។ **អថ ធំ អាគន្ត្វា** ពេល នោះ ពួកអសុរទាំងឡាយក៏ភ្ញាក់ផ្អើល មកសួរសុខទុក្ខ ម្នាក់ៗសាក សួរអំពីហេតុការណ៍ទាំងឡាយ សម្ពរអសុរនោះ ក៏លាក់បិទបាំង មិន

បានប្រាប់ដល់នរណាម្នាក់ឡើយ **ទុតិយយាមាទីសុ** លុះមកដល់យាមទី ២-៣ ក៏ដូច្នោះដូចគ្នាទាំង ៣ យាម មានសេចក្តីលំបាកដរាបទល់ភ្លឺ ។ តាំងអំពីថ្ងៃនោះមក ក៏មានសេចក្តីទុក្ខរាល់ថ្ងៃ អាស្រ័យហេតុដូច្នេះ ទើបសម្ពរអសុរមានឈ្មោះថា **វេបចិត្តិ** ដែលជានេមិត្តកនាម ដោយអត្ថថា ញាប់ញ័រតក់ស្លុត ឯឈ្មោះថា **សម្ពរ** នោះ ជាឈ្មោះដើម **ឃរំ បន ពាឡ្ហគិលានំ** ស្តេចវេបចិត្តិអសុរមានជំងឺជាទម្ងន់ដូច្នោះ ទើបឯអមរិន្ទ្រម្ចាស់កពតាវត្តិង្ស **ឧបសង្កមតិ** ចូលទៅសួរសុខទុក្ខអសុរ **តតោ វេបចិត្តិ អសុរិន្ទោ** ស្តេចវេបចិត្តិគ្រាន់តែក្រឡេកឃើញព្រះឥន្ទ្រមកអំពីចម្ងាយ ក៏សប្បាយចិត្ត ហើយអង្វរថា **ទេវានមិន្ទ** បពិត្រទេវានមិន្ទជាម្ចាស់សួគ៌ សូមទ្រង់ព្រះករុណាអាណិតខ្ញុំផង ជួយព្យាបាលឲ្យខ្ញុំជាសះស្បើយនូវរោគាព្យាធិក្នុងកាលឥឡូវនេះ ។ ទើបកោសិយអមរិន្ទ្រត្រាស់ថា ហៃសម្ពរអសុរ បើលោកមិនបានលាក់បិទបាំងទុកនូវមាយារបស់ខ្លួន ហើយលោកសម្តែងចេញនូវមាយានោះដល់ខ្ញុំៗ នឹងព្យាបាលឲ្យជាសះស្បើយទាល់តែបាន ។ វេបចិត្តិបានស្តាប់ព្រះឥន្ទ្រពោលដូច្នោះ ទើបមានវាចាថា បពិត្រអមរិន្ទ សូមព្រះអង្គលើកទុកសិនចុះ ខ្ញុំប្រឹក្សាជាមួយ

នឹងអសុរទាំងឡាយសិន រួចហើយទើបប្រាប់ពេលខាងក្រោយ ពោលដូច្នេះហើយ ទើបត្រាស់ចំពោះអសុរទាំងឡាយ ដែលស្ថិតនៅក្នុងទីនោះថា នែពួកយើង ឥឡូវនេះ ស្តេចអមរិន្ទ្រឲ្យប្រាប់នូវមាយារបស់យើងជាមុនហើយ ទើបស្តេចព្យាបាលរោគាព្យាធិពេលជាខាងក្រោយ អសុរទាំងឡាយបានស្តាប់ហើយ ទើបទូលជំទាស់ថា បពិត្រព្រះអង្គ មិនបានបាន ។ ព្រះឥន្ទ្រមិនបានដឹងនូវមាយារបស់ពួកយើងយ៉ាងនេះ ញ៉ាំងនូវការបៀតបៀនចំពោះយើងត្រឹមប៉ុណ្ណេះ ប្រសិនបើដឹងហើយនោះ ខ្ញុំ ( ពួកអសុរ ) យល់ឃើញថា នឹងវិនាសដោយពិតលំដាប់នោះ ទើបវេបចិត្តិអសុរត្រាស់ទូលព្រះឥន្ទ្រដោយព្រះគាថាថា **មយាវី មឃវា សក្ក ទេវរាជា សុជម្បតិ ឧបេតិ និរយំ ឃោរំ** ជាដើម ប្រែថា បពិត្រសក្កទេវរាជ កាលអំពីមុនខ្លួនខ្ញុំឈ្មោះថាសម្ពរនេះ **មាយាវី** ជាអ្នកប្រកបដោយមាយាសាមាន្យ អកុសលចិត្តនេះបញ្ជូនឲ្យខ្ញុំធ្លាក់ទៅក្នុងនរកអស់កាលរយឆ្នាំ **តុម្ហេ បន ធម្មិកា** បពិត្រលោកដែលប្រកបដោយធម៌ ( សុចរិតកម្ម ) មិនគួរដើម្បីស្តាប់ និងដឹងនូវមាយានោះឡើយ ។

**សក្កោ បន តំ តិកិច្ឆន្តោ** ទើបមានពាក្យសួរថា ព្រះឥន្ទ្រ

នឹងព្យាបាលរោគាព្យាធិវេបចិត្តិអសុរនោះដូចម្តេច ?

ឆ្លើយថា ប្រសិនបើវេបចិត្តិអសុរមិនបានលាក់បិទបាំងនូវមាយានោះទេ បានប្រាប់នូវមាយារបស់ខ្លួន សក្កទេវរាជក៏នឹងនាំទៅកាន់សម្នាក់របស់តាបសទាំងឡាយ នឹងញ៉ាំងតាបសទាំងឡាយឲ្យអត់ទោសនោះរួចហើយ ក៏នឹងជាសះស្បើយ ។ **តថា អកត្វា** វេបចិត្តិអសុរមិនធ្វើយ៉ាងនោះ ។ គ្រានោះ ព្រះឥន្ទ្រក៏វិលត្រឡប់មកកាន់ស្ថានរបស់ព្រះអង្គវិញ ។

**ឥមំ បន អសុរភាវញ្ច** លំដាប់តទៅនេះ នឹងសម្តែងកពទាំង ៥ ដែលមានប្រមាណមួយម៉ឺនយោជន៍ប៉ុនគ្នា គឺអសុរ ១ តាវត្តិង្ស ១ ជម្ពូទ្វីប ១ អវិចី ១ និងឧស្សទនរក ១ ។ ប៉ុន្តែអមរគោយានទ្វីបនោះមាន ៧ ពាន់យោជន៍ បុព្វវិទេហទ្វីបក៏ ៧ ពាន់យោជន៍ ឧត្តរកុរុទ្វីប ៨ ពាន់ យោជន៍ជាកំណត់ **ឯកមេកោ** ទ្វីបធំទាំង ៤ ទ្វីបនីមួយៗមានទ្វីបតូចៗ ៥០០ ជាបរិវារ ។ បើនឹងសម្តែងដោយសណ្ឋាននៃទ្វីបជម្ពូទ្វីបនេះ **សកដសណ្ឋានោ** មានសណ្ឋានដូចទ្រុងរទេះ **អឌ្ឍចន្ទសណ្ឋានោ** បុព្វវិទេហទ្វីបមានសណ្ឋាន ដូចព្រះចន្ទពាក់កណ្តាលវង់ អមរគោយានទ្វីបនោះ **អាទាសសណ្ឋានោ** មានសណ្ឋាន

ដូចវង់ចិញ្ចៀន **ឧត្តរកុរូបីឋសណ្ឋានោ** ឧត្តរកុរុមានសណ្ឋានដូចតាំង **តំ តំ ទីបវាសីនំ** បណ្តាមនុស្សដែលនៅក្នុងទ្វីបណាៗ ក៏មានមុខដូចទ្វីបនោះៗ **តត្ថ ជម្ពុទីបោ** បណ្តាទ្វីបទាំង ៤ នោះ ក្នុងជម្ពូទ្វីបនេះ មានចំណតសំពៅដល់ ៩៦ សែនកោដិ ហើយក៏មានអណ្តូងកែវ ៥៦ អណ្តូង ។ ប្រកបដោយរាជធានី ៦៣០០០ បីដង ។ រួមចូលគ្នាជារាជធានីដល់មួយសែនប្រាំបីម៉ឺនប្រាំបួនពាន់នគរ មានក្រុងតូចៗ ៩៩ សែនជាចំណុះ ។

ក្នុង គម្ពីរទីឃនិកាយ បដិក្កវគ្គ ឆដ្ឋវគ្គ អដ្ឋកថាអាដានាដិយសូត្រ សម្តែងថា **ជម្ពុទីបេ បន** ក្នុងជម្ពូទ្វីប ដើមឡើយជម្ពូទ្វីបនេះមានមួយម៉ឺនយោជន៍ អស់បុណ្យវាសនានៃសត្វដែលមានបុណ្យហើយ ទឹកជន់លិច អស់ ៤ ពាន់យោជន៍ នៅជាទីតាំងនៃមនុស្ស ៣ ពាន់យោជន៍ ជាទីតាំងនៃភ្នំហិមពាន្ត ៣ ពាន់យោជន៍ ភ្នំហិមពាន្តនោះបើប្រមាណដោយកម្ពស់ ៥០០ យោជន៍ បណ្តោយ ៣ ពាន់យោជន៍ ហើយក៏ប្រដាប់ទៅដោយកំពូល ៤ ពាន់កំពូល ឈ្មោះថាសុទស្សនកូដជាដើម **បញ្ចមហានទីហិ វិចិត្តោ** ភ្នំហិមពាន្តនោះវិចិត្រប្រកបទៅដោយស្ទឹង ៥ ខ្សែ ហើយប្រដាប់ទៅដោយមហាស្រះ

៧ គឺអនោតត្តស្រះ ១ កណ្ណមុណ្ឌស្រះ ១ រថការស្រះ ១ ឆទ្ទន្តស្រះ ១ កុណាលទហស្រះ ១ មន្ទាកិនីទហស្រះ ១ សីហប្បាតទហស្រះ ១ ប៉ុន្តែមហាស្រះនីមួយៗ ជម្រៅ ៥០ យោជន៍ បើនឹងវាស់ដោយជុំវិញ ១៥០ យោជន៍ **តត្ថ អនោតត្តទហោ** បណ្តាមហាស្រះទាំង ៧ នោះ រីអនោតត្តស្រះ នៅចន្លោះនៃភ្នំទាំង ៥ គឺសុទស្សនកូដ ១ ចិត្រកូដ ១ កាឡកូដ ១ គន្ធមាទនកូដ ១ កៃលាសកូដ ១ តាំងនៅដោយជុំវិញ ។ បណ្តាភ្នំទាំង ៥ នោះ រីសុទស្សនៈនោះជាវិការនៃមាសកម្ពស់ ២ រយយោជន៍ មានសណ្ឋានដូចមាត់ក្អែក ភ្នំចិត្រកូដមានកែវ ៧ ប្រការ ភ្នំកាឡកូដនោះ ជេរដាសទៅដោយកែវពណ៌ខៀវ ។ គន្ធ-មាទនកូដនោះ ពាសពេញទៅដោយកែវធ្នូត ខាងក្នុងមានកែវពណ៌ដូចកែវមុក្តា ប្រដាប់ដោយដើមឈើក្រអូប ១០ ប្រការ ដែលមានគុណវិសេសផ្សេងៗ ពួកឈើខ្លះមានឫសក្រអូប ពួកឈើខ្លះមានខ្លឹមក្រអូប ពួកឈើខ្លះមានក្រមរក្រអូប ពួកឈើខ្លះមានស្រាយក្រអូប ពួកឈើខ្លះមានសម្បកក្រអូប ពួកឈើខ្លះមានជ័រក្រអូប **នានប្បការឱសថសញ្ចន្នំ** ហើយជេរដាសទៅដោយឱសថជាតិមានប្រការផ្សេងៗ ក្នុងភ្នំគន្ធមាទន៍នោះ មានជ្រោយ ( ញក )

មួយឈ្មោះនន្ទមូលៗ នេះជាទីនៅនៃព្រះបច្ចេកពុទ្ធទាំងឡាយ ។ **តិស្សោ គុហាយោ** ហើយក៏មានគុហា ៣ គឺ **សុវណ្ណគុហា** គុហាមាស ១ **មណិគុហា** គុហាកែវ ១ **រជតគុហា** គុហាប្រាក់ ១ ។ **មញ្ជុស្សកោ រុក្ខោ** មានដើមឱលោកមួយដើមដុះឡើងនៅក្បែរមាត់គុហាកែវ កម្ពស់ ១ យោជន៍ ហើយក៏មានសាលា ១ ឈ្មោះរតនមាឡកៈ ជាកន្លែងប្រជុំនៃព្រះបច្ចេកពុទ្ធទាំងឡាយ ។ មួយទៀតក្នុងរតនមាឡកៈនោះ មានខ្យល់ជាប្រចាំ ៦ ពួក **១- ឈ្មោះសម្មជ្ជនកវាត** សម្រាប់បក់សម្អាតនូវសាលានោះ **២- ឈ្មោះសមករណវាត** សម្រាប់កៀរដីឲ្យស្មើ **៣- ឈ្មោះសិញ្ចកតវាត** សម្រាប់បក់ក្រសោបយកទឹកអំពីអនោតត្តស្រះមកប្រោះព្រំ **៤- ឈ្មោះសុគន្ធករណវាត** សម្រាប់បក់យកគន្ធជាតិមកអប់ **៥-ឈ្មោះឱចិនវាត** សម្រាប់បក់ក្រសោបយកផ្កាឈើ មកទម្លាក់រោយរាយនៅក្នុងសាលានោះ **៦- ឈ្មោះសន្ថារកវាត** សម្រាប់បក់ក្រាលជាសេនាសនៈផ្កា ។ **សព្វេ បច្ចេកពុទ្ធា** ក្នុងរតនមាឡកៈនេះ ជាកន្លែងប្រជុំនៃព្រះបច្ចេកពុទ្ធទាំងឡាយ តែងតែមកប្រជុំព្រមគ្នា ក្នុងថ្ងៃដែលកើតនៃព្រះបច្ចេកពុទ្ធនិងថ្ងៃឧបោសថ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋាន ភ្នំគន្ធមាទន៍នេះ ថាជា

ទីនៅនៃព្រះបច្ចេកពុទ្ធដោយប្រការដូច្នេះ ។

**កេលាសកូដំ បន** ឥឡូវនេះ នឹងពណ៌នានូវភាពវិសេសនៃភ្នំកៃលាសជាដើមតទៅ **រជជមយំ** ភ្នំកៃលាសនោះពោរពេញទៅដោយប្រាក់ ភ្នំទស្សនៈនោះពោរពេញទៅដោយមាស ភ្នំកាឡកូដពោរពេញទៅកែវពណ៌ខៀវ ភ្នំចិត្រកូដពោរពេញទៅដោយកែវ ៧ ប្រការ ទាំងកម្ពស់ ទាំងសណ្ឋានស្មើៗ គ្នា ព័ទ្ធជុំវិញអនោតត្តស្រះ **ទេវានុ-ភាវេន នាគានុភាវេន** ដោយអានុភាពនៃទេវតា និងអានុភាពនៃនាគ ក៏ញុំាងភ្លៀងឲ្យធ្លាក់ចុះមិនដាច់ ទឹកទាំងអស់ហូរចុះអំពីអនោ-តត្តស្រះនោះឯង ។ **ចន្ទិមសុរិយា** ពេលខ្វះព្រះចន្ទ និងព្រះអាទិត្យគោចរតាមផ្លូវទក្ខិណាយនៈ និងឧត្តរាយនៈនោះ ពន្លឺនៃព្រះចន្ទ និងព្រះអាទិត្យភ្លឺទៅដល់ ។ ប្រសិនបើគោចរដោយឧជុគ្គមនមាគ៌ាហើយ ក៏មិនអាចចាំងត្រូវបាន អាស្រ័យហេតុដូច្នេះ ទើបឈ្មោះថា អនោតត្តស្រះដោយប្រការដូច្នេះ ។

**តត្ថ រតនមយមនុញ្ញំ** ក្នុងអនោតត្តស្រះនោះជាទីរីករាយនៃចិត្ត ប្រដាប់ទៅដោយជណ្ដើរកែវ និងមានកំពង់រាបស្មើ មានទឹកថ្លាដូចកញ្ចក់ ជាទីអាស្រ័យស្រង់ជម្រះព្រះកាយនៃលោកអ្នកទាំង-

ឡាយដែលមានបុណ្យ មានព្រះសម្មាសម្ពុទ្ធ និងព្រះបច្ចេកពុទ្ធជាប្រធាន ហើយក៏ជាកន្ទ្វែងហូរទៅនៃស្ទឹងទាំង ៤ ជាប្រកពទឹកចេញអំពីប្រកពទឹកទាំង ៤ គឺសីហមុខ ១ ហត្ថិមុខ ១ អស្សមុខ ១ ឧសភមុខ ១ៗ ទឹកណាដែលហូរចេញអំពីប្រកពទឹកឈ្មោះសីហមុខនោះ ប្រាំងស្ទឹងនោះដេរដាសទៅដោយរាជសីហ៍ ៗ ទឹកណាដែលហូរចេញអំពីប្រកពទឹកឈ្មោះហត្ថិមុខ ប្រាំងស្ទឹងនោះ ដេរដាសទៅដោយហ្វូងដំរីទាំងឡាយ ៗ ទឹកណាដែលហូរចេញអំពីប្រកពទឹកឈ្មោះអស្សមុខនោះ ប្រាំងស្ទឹងនោះដេរដាសទៅដោយហ្វូងសេះ ៗ ទឹកណាដែលហូរចេញអំពីប្រកពទឹកឈ្មោះឧសភមុខ ប្រាំងស្ទឹងនោះដេរដាសទៅដោយគោទាំងឡាយដើរទៅមក ៗ **បុរត្ថិមទិសតោ និក្ខន្តឧទី** រីទឹកដែលហូរចេញអំពីអនោតត្តស្រះ ប៉ែកទិសខាងកើតនៃភ្នំហិមពាន្តនោះ ហូរប្រទក្សិណនូវអនោតត្តស្រះ ៣ ជុំ ហើយឆ្ងងកាត់នូវស្ទឹង ៣ ខ្សែ ហើយក៏ហូរអំពីភ្នំហិមពាន្តទិសខាងកើតចេញទៅដែននៃមនុស្សតម្រង់ឆ្ពោះផ្ទៃនៃមហាសមុទ្រ ៗ **បច្ឆិមទិសតោ ច ឧត្តរទិសតោ ច** ញាំងទឹកឲ្យហូរចេញអំពីអនោតត្តស្រះអំពីទិសខាងលិច និងទិសខាងជើងនោះ ហូរប្រទក្សិណអនោតត្តស្រះ ៣ ជុំ ហើយក៏ទៅកាន់ទិស

ខាងលិច និងខាងជើងហើយ ក៏ហូរតម្រង់ឆ្ពោះផ្ទៃនៃមហាសមុទ្រដូចគ្នា **ឆិក្ខត្តុឆធី បឆ** ភាពវិសេសអំពីទឹកដែលហូរប្រទក្សិណនោះ កាលប្រទក្សិណអនោតត្តស្រះរួចហើយ ក៏ហូរចុះទៅខាងលើផ្ទៃថ្មរាបស្មើមួយ មានប្រវែង ៦០ យោជន៍ **បព្វតំ បហរិត្វា** ទើបទៅប៉ះទង្គិចនឹងភ្នំមួយ **ឧដ្ឋាយ បហារក្ខេ បឆ** ទីនោះ ទឹកក៏បាញ់ឡើងលើអាកាស ជាធារទឹកមានប្រមាណ ៣ គាវុត **តិយគ្គឡេ ចាសាណេ** ហើយក៏ធ្លាក់ចុះលើផ្ទៃថ្មមួយ ឈ្មោះថា តិយគ្គឡ ជាថ្ម ៣ ជ្រុង **ឧឆកធារវេគេឆ** ថ្មនោះធន់នឹងផ្ទៃទឹកនោះមិនបាន ក៏បែកខ្ទាត់ខ្ទាយកើតជាស្រះមួយ ឈ្មោះថា តិយគ្គឡបោក្ខរណី **ចោក្ខរណិយា កុលំ ភិន្ទិត្វា** ហើយទម្លាយនូវច្រាំងតិយគ្គឡបោក្ខរណី ហូរទៅមានរយៈផ្លូវ ៦០ យោជន៍ទៀត ។ **ឃឆបឋវិ ភិន្ទិត្វា** ហើយក៏ទម្លាយនូវឃនបឋវី ហូរចុះទៅក្រោមដីអស់រយៈផ្លូវ ៦០ យោជន៍ទៀត **តិរច្ឆានបព្វតំ** ទើបប៉ះនឹងតិរច្ឆានបព៌ត ទីនោះក៏ហូរបែកគ្នាចេញជា ៥ ខ្សែ **បញ្ចង្គុលីសធិសា** ដូចម្រាមដៃទាំង ៥ **អឆោតត្តំ បឆ បឆក្ខិណំ កត្វា** ការពិត ទឹកដែលហូរចេញអំពីអនោតត្ត-ស្រះនោះ ហើយហូរប្រទក្សិណនោះ ក៏ប្រាកដឈ្មោះថា **អាវដ្តគង្គា**

ដែលហូរចុះមក ហើយនឹងរសាត់ឡើងលើអាកាស ក៏មានឈ្មោះថា អាកាសគង្គា ។ ដែលធ្លាក់ចុះលើតិយគ្គឡសិលានោះ ឈ្មោះថា តិយគ្គឡបោក្ខរណី ដែលហូរចូលទៅក្នុងផ្ទាំងថ្មនោះ ឈ្មោះថា ពហឡគង្គា ។ ដែលហូរទៅក្នុងឧម្មង្គទ្ទ៌ះ ឈ្មោះថា **ឧម្មង្គគង្គា** ។ ដែលហូរមកអំពីតិរច្ឆានបពិតនោះ ហើយក៏បែកគ្នាចេញ ជា ៥ ខ្សែ នោះ ឈ្មោះថា គង្គានទី ១ ខ្សែ យមុនានទី ១ ខ្សែ អចិរវតី ១ ខ្សែ មហិនទី ១ ខ្សែ សរភូ ១ ខ្សែ ស្ទឹងទាំង ៥ ហូរមកកាន់ដែនដីមនុស្ស ។

**ជម្ពុទ្ទហោ បន** ឯធម្ពុទ្ទនោះសោតជំប្រវែង ៥០ យោជន៍ ក្នុងទីកណ្តាលស្រះនោះ មានទឹកដ៏ថ្លា ប្រាសចាកចក សារាយ មានប្រមាណ ១២ យោជន៍ ថ្លាបរិសុទ្ធ មានពណ៌សដូចពណ៌នៃដុំកែវមណី **តទនន្តរំ** បន្ទាប់អំពី ១២ យោជន៍នោះចេញមក ទើបមានព្រៃឈូក ៧ ប្រការព័ទ្ធជុំវិញ តអំពីព្រៃឈូក ៧ ប្រការនោះ **សុទ្ធកលាបហារ-វណ្ណំ** គឺព្រៃចង្កុលណី ទទឹង ១ យោជន៍ ។ បន្ទាប់អំពីព្រៃសុទ្ធនីលឧប្បល ទទឹង ១ យោជន៍ ព័ទ្ធជុំវិញតៗ គ្នា ចេញមកជាជាន់ៗ **តទនន្តរំ** បន្ទាប់អំពីព្រៃឈូក ៧ ប្រការនោះ ចេញមកទើបជាព្រៃចម្រុះ មានផ្កាឈូកគ្រប់បែប មានពណ៌ផ្សេងៗ ទទឹងក៏ ១ យោជន៍

ដូចគ្នា បន្ទាប់អំពីព្រៃចម្រុះចេញមក ដល់ផ្ទៃទឹកល្មមស្មើនឹងខ្នងដំរី ទើបជាព្រៃតេនសាលី ទទឹង ១ យោជន៍ស្មើគ្នា **តទនន្តរំ** បន្ទាប់អំពីនោះចេញមក ដល់ព្រៃខុទ្ទកគច្ឆ គឺគុម្ពនៃផ្កាឈើទឹកមានពណ៌ផ្សេងៗ ដូចជាពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌-ស ទទឹងក៏ ១ យោជន៍ស្មើគ្នាដែរ **តទនន្តរំ** បន្ទាប់អំពីនោះ នៅលើមាត់ប្រាំងមានសណ្តែកខៀវ សណ្តែកខ្មៅ សណ្តែករាជមាស តអំពីនោះមកដល់ព្រៃត្រឡាច ល្ពៅ មានផ្លែធំៗ តអំពីនោះទៀត ដល់ព្រៃអំពៅអំពៅដើមធំៗ ប៉ុនដើមស្លា ។ តមកទៀត មានព្រៃចេក មានផ្លែធំៗ ប៉ុនភ្លុកដំរី ។ តមកទៀត មកដល់ព្រៃរាំង ព្រៃខ្នុរ មានផ្លែធំៗប៉ុនពាងទឹក ហើយក៏មកដល់ព្រៃស្វាយ ហើយមកដល់ព្រៃអំពិលផ្អែម ហើយមកដល់ព្រៃខ្វិតជាប់តៗគ្នាមក ព្រៃទាំងនេះ ជាសុទ្ធវ័ន ។

**តតោ វោមិស្សកមហាវនំ** បន្ទាប់អំពីសុទ្ធវ័ន ទើបជាព្រៃចម្រុះ ហើយក៏មកដល់ព្រៃឫស្សី **ទុន្និក្ខមំ** សូម្បីតែពស់ក៏លូនចូលទៅបានដោយលំបាក **តំ បរិក្ខិបិត្វា ឋិតា** បន្ទាប់អំពីព្រៃឫស្សីចេញមក ទើបដល់ភ្នំព័ទ្ធជុំវិញ រហូតដល់ ៧ ភ្នំ ភ្នំទី ១ ឈ្មោះចូឡកាឡបព៌ត ភ្នំទី ២ ឈ្មោះមហាកាឡបព៌ត ភ្នំទី ៣ ឈ្មោះ

ឧទកបស្សប្បតិត ភ្នំទី ៤ ឈ្មោះចន្ទបស្សប្បតិត ភ្នំទី ៥ ឈ្មោះថា សុរិយបតិត ភ្នំទី ៦ ឈ្មោះមណិបស្សប្បតិត ភ្នំទី ៧ ឈ្មោះ សុវណ្ណបស្សប្បតិត ។ **បព្វតកណ្ណេ** ជ្រុងស្រះខាងទិសឦសាននោះ មានដើមជ្រៃមួយដើមធំ មានដើមមូលទំហំ ៥ យោជន៍ កម្ពស់អំពី ប្រគាបឡើងទៅ ៧ យោជន៍ មួយប្រគាបមានមែក ៤ មែកនីមួយៗ មានប្រវែង ៦ យោជន៍ ដើមជ្រៃនេះបើវាសអំពីគល់រហូតដល់ចុង មានកម្ពស់ ១២ យោជន៍ បរិមណ្ឌលក៏ ១២ យោជន៍ដូចគ្នា ។

**មុណ្ឌមណិបព្វតោ វិយ** ដើមជ្រៃនោះមានមណ្ឌល ដូច មណ្ឌលនៃមណិបតិត ។ **មណ្ឌាកិណិយា បឆ** ឯមណ្ឌាកិណីស្រះ នោះ ទទឹង ២៥ យោជន៍ មានទឹកថ្លាដូចកញ្ចក់ មិនមានចក និង សារាយឡើយ **ឆាតានំ បិដ្ឋិបមាណោ** ត្រង់មាត់ប្រាំងមានទឹកស្មើ ខ្នងដំរីនោះ មានព្រៃផ្កាឈូក-សត្វព័ទ្ធជុំវិញមួយជុំ **មុទ្ទាលំ មត្តល-សីស មត្តំ** ដើមឈូកប៉ុនគ្នានឹងចន្ទោលរទេះ ក្រអៅឈូកមួយ ក្រអៅៗ មានប្រមាណប៉ុនស្គរជ័យ **ឯកេកស្មឹ បព្វន្តរេ** ក្នុងប្រហោង នៃក្រអៅឈូកនោះ មានទឹកដោះពណ៌-សជក់នៅគ្រប់ៗ ប្រហោង នីមួយៗ វាល់បានច្រើននាឡិ ។ **កុសុមានំ បុប្ផសមយេ** ពេលផ្កា

ឈូករីកហើយ មានខ្យល់មួយពួកបក់រលាស់នូវកេសរឲ្យធ្លាក់ចុះលើស្លឹកឈូក ក៏មានលម្អង និងតំណក់ទឹកសនៀមស្រក់ធ្លាក់ចុះមកប្រោះព្រំលើកេសរ **អាទិច្ចាភេន បចិត្វា** លុះពន្លឺព្រះអាទិត្យពាល់ត្រូវក៏ស្ងួតកកជាដុំ មានឈ្មោះប្រាកដបោក្ខរមធុ **តទនន្តរំ** បន្ទាប់អំពីពួកឈូក-ស ក៏ដល់ពពួកឈូកក្រហម ហើយមកដល់ពពួកឈូក-សពពួកលំចង់ ផ្កាពណ៌ខៀវស្វាយ រហូតដល់សុគន្ធសាលិវ័ន គឺព្រៃស្រូវក្រអូប បន្ទាប់មកក៏ដល់ព្រៃត្រឡាច ព្រៃឃ្លោក សុទ្ធតែមានរសដ៏ផ្អែម **បូគរុក្ខប្បមាណំ** មកដល់ព្រៃអំពៅ ដើមអំពៅមួយដើមៗធំប៉ុនដើមស្លា **ហត្ថីនាគា** ពួកដំរីទាំងឡាយនាំគ្នាកាច់យកមកដាក់លើថ្មធ្មតមួយកន្លែង ហើយក៏នាំគ្នាពូត **រសោ បគ្ឃរិត្វា** ទឹកអំពៅនោះក៏ហូរធ្លាក់ដក់នៅពេញកន្ទុកតូចធំ **អទិច្ចាភេន បចិត្វា** កាលត្រូវពន្លឺព្រះអាទិត្យក៏កករឹងជាដុំពណ៌-ស ហាក់បីដូចថ្មទឹកដោះ **គេគហោត្វា** ពួកដំរីទាំងឡាយ ក៏នាំគ្នាយកទៅថ្វាយព្រះសម្មាសម្ពុទ្ធព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ដែលយាងមកដល់ **ឧច្ឆុ-វនស្ស អនន្តរំ** បន្ទាប់អំពីព្រៃអំពៅក៏ដល់ព្រៃចេក ផ្លែចេកសោតក៏ធំៗ សូម្បីកាលមនុស្សបរិភោគតែ ២ ផ្លែ ក៏ហល់ **តទនន្តរំ** បន្ត

អំពីព្រៃចេកក៏ដល់ព្រៃខ្នុរ ផ្លែធំៗ ប៉ុនពាង បន្ទាប់មកទៀតដល់ព្រៃស្វាយ ព្រៃទិត ជាប់បន្តបន្ទាប់គ្នាមក **សង្ខេបតោ វា** នឹងសង្ខេបសេចក្តីឲ្យសមគួរនោះ មណ្ឌាកិនីស្រះនេះ មានវត្ថុគ្រប់យ៉ាង **ហិមវតិ វសន្តេសុ** ក្នុងព្រៃហិមពាន្តនោះ បើនឹងពណ៌នាខាងសត្វចតុប្បាទទ្វេបាទសោតក៏ច្រើនក្រៃលែង ក្នុងទីនេះនឹងជ្រើសសម្តែងតែសត្វដែលពិសេសៗ ត្រង់ៗ តាមព្រះបាលី មានរាជសីហ៍ សត្វករវិកជាដើម **តត្ថ សីហា ចតុព្វិធា** បណ្តាសត្វទាំងឡាយនោះ រីសត្វរាជសីហ៍នេះមាន ៤ ត្រកូល គឺតិណសីហៈ ១ កាឡសីហៈ ១ បណ្ឌុសីហៈ ១ កេសរសីហៈ ១ ។ បណ្តារាជសីហ៍ទាំង ៤ នោះ តិណសីហៈជាសីហៈស៊ីស្មៅ **ករោធកាវីសទិសោ** មានរូបរាងដូចមេគោ មានសម្បុរដូចសត្វព្រាប កាឡសីហៈនោះមានសម្បុរខ្មៅដូចមេគោខ្មៅស៊ីស្មៅដូចគ្នា បណ្ឌុសីហៈសម្បុរលឿង រូបរាងក៏ដូចគោស៊ីនូវសាច់ជាអាហារ ប៉ុន្តែភាពវិសេស រាជសីហ៍នោះ មាត់ក្រហមហាក់ដូចលាបដោយទឹកលក្ក មានផ្ចិត-កក្រហម ដូចពន្លឺនៃសំពត់រត្តកម្ពល **អវសេសឋានំ** ក្រៅអំពីនោះ សម្បុរសសុទ្ធដូចស្រូវសាលីសុទ្ធ និងស័ង្ខ តាំងអំពីក្បាលរហូតមកដល់កន្ទុយ មានខ្សែឆ្នូត ៣ ខ្សែ សម្បុរ

លឿនដូចពណ៌លក្ខ ប្រៀបដូចអួសដោយបន្ទាត់ រាជសីហ៍មានប្រក្រតីនៅក្នុងល្អាងមាស ល្អាងប្រាក់ ល្អាងកែវ ។ កាលបើចេញអំពីល្អាងដែលរស់នៅនោះ **ឆេ្វ បច្ឆិមចាទេ** តាំងនូវជើងឲ្យស្មើ ទើបសន្ធឹងនូវជើងខាងមុខ រត់ពត់ខ្លួន បន្ទាបនូវខ្នង អើតក្បាល រួចហើយបន្លឺសីហនាទ សំឡេងសីហនាទនោះហាក់បីដូចសំឡេងផ្គរលាន់ **សរី–លគ្គរជ្ជំ វីធុនន្តោ** ទើបរលាស់នូវរោម ញ៉ាំងខ្លួនឲ្យប្រាសចាកធូលី ហើយក៏លោតតាមទំនើងចិត្ត គ្មានក្រែងរអែង **តរុណាវច្ឆកោ វិយ** ដូចកូនគោដែលក្លាលោតតាមទំនើងចិត្ត ហើយក៏បន្លឺនូវសំឡេង ៣ ដង **សោ សទ្ទោ** សំឡេងនោះក៏លាន់ឮខ្ទាំងឡើង បាន ៣ យោជន៍ជុំវិញ ។ **ទ្វិចាទចតុប្បាទគណា** ពួកសត្វទ្វេបាទ ចតុប្បាទ ក៏មិនអាចទ្រទ្រង់តាំងនៅបាន ដោយភ័យខ្លាចពីម្រឹគរាជ ហាក់បីដូចចាប់ខ្លួន ក៏នាំគ្នារត់ពួន ។ សត្វនៅរន្ធក៏រត់ចូលរន្ធ ។ សត្វណានៅក្នុងទឹកក៏ចុះទឹក សត្វនៅក្នុងព្រៃក៏រត់ចូលព្រៃ លាក់ពួនក្នុងព្រៃស៊ុមទ្រុមព្រៃរបោះ **អាកាសំ បក្ខិនោ** ហ្វូងបក្សាបក្សី ក៏ហើរឡើងទៅឰដ៏អាកាស ។ **គាមរាជធានីសុ** ពោលទៅថ្វីដល់សត្វនៅក្នុងព្រៃ សូម្បីតែដំរី សេះ គោ និងក្របីដែលចងក្នុងស្រុក និងភូមិ ក៏ធន់មិនបាន

ក៏កៀសខ្លួន ស្ទុះចេញទៅរហូតដាច់កន្ទុះ ដាច់បង្ហៀរដោយអំណាចនៃរាជសីហ៍ ។

**កេ បន អភីតា** ក៏នឹងចែកនូវសេចក្តីវិសេសក្នុងទីនេះដោយ សួរថា សព្វសត្វទាំងឡាយសុទ្ធតែខ្លាចនូវសំឡេងរាជសីហ៍ដូច្នេះឬ ?

ឆ្លើយថា មិនខ្លាចទាំងអស់ទេ **ជាតិសមសីហោ** រាជសីហ៍ស្មើជាតិ ១ ហត្ថាជានេយ្យ ១ អស្សាជានេយ្យ ១ ឧសភាជានេយ្យ ១ បុរិសាជានេយ្យ ១ ព្រះខីណាស្រព ១ សូម្បីបានឮក៏នៅស្ងៀមព្រងើយមិនខ្លាច ។ មានពាក្យអធិប្បាយថា រាជសីហ៍ដែលស្មើជាតិគ្នានោះមិនខ្លាចដោយគិតថា អាត្មាអញនេះមានជាតិ ត្រកូល គោត្រក្លៀវក្លាក៏ដូចគ្នានឹងសីហៈនោះ ហេតុដូច្នោះ ទើបមិនបានខ្លាច **ហត្ថាជា-និយានយោ** ហត្ថាជានេយ្យ អស្សាជានេយ្យ ឧសភាជានេយ្យ បុរិសាជានេយ្យ ទាំងនេះមិនខ្លាចនោះ ដោយហេតុថា រឹងត្អឹងដោយសក្កាយទិដ្ឋិ គឺប្រកាន់ខ្លួននោះខ្លាំងក្លាក្រៃលែង ។ ចំណែកព្រះខីណាស្រពវិញនោះ លោកលះបង់នូវសក្កាយទិដ្ឋិអស់ហើយ ទើបមិនខ្លាច **សោ បន** កាលបើស្តេចរាជសីហ៍បន្លឺនូវសំឡេង ៣ ដង

ហើយលោតចុះលោតឡើង បានចម្ងាយមួយឧសភៈ **ឧទ្ធំ ឧប្បតន្តោ** ហើយក៏លោតទៅខាងមុខទៀត បានចម្ងាយ ៤ ឧសភៈក៏មាន ៨ ឧសភៈក៏មាន **ឧបក្ខន្ទន្តោ** រាជសីហ៍ បើនឹងឈរនៅទីរាបស្មើ ក៏លោតទៅបានចម្ងាយ ១៦-២០ ឧសភៈខ្លះ ប្រសិនបើលោតអំពីទីទួលមកប្រាំងបោត ៦០-៨០ ឧសភៈ **ឯវំ សុរភា វាឌីហិ សេដ្ឋោ** រាជសីហ៍ត្រកូលប្រសើរជាងរាជសីហ៍ដទៃនោះដោយគុណ មានភាពក្លៀវក្លាជាដើម ដោយប្រការដូច្នេះ ។

**ករវិក សកុណោ** ក្នុងផ្ទៃព្រៃហិមពាន្តវិសេសដោយសត្វករវិក **មុខតុណ្ឌេន បហរិត្វា** ពេលខ្លួនទំចឹកស៊ីនូវផ្លែស្វាយ ហើយក៏ទទះស្លាបហើរទៅ សំឡេងនោះហាក់បីដូចប៉ីកែវ តើប៉ីកែវពីរោះដូចម្តេច ? ពីរោះចាប់ចិត្តទៅគ្រប់សត្វ **នាយ វេលាយ** ពេលនោះ បណ្តាសត្វទ្វេបាទ ចតុប្បាទដែលបានឮ **មធមត្តា វិយ** ហាក់បីដូចវង្វេងវង្វាន់ដោយសារសំឡេងនោះ **គោចរបសុតា** សត្វដែលពាំនូវចំណីៗ ក៏របូតធ្លាក់អំពីមាត់ ខ្លាកំពុងដេញម្រឹគ លើកជើងប្រុងនឹងលោត ក៏ងើបឈរទ្រឹង នៅស្ងៀមមួយកន្លែង **អនុពន្ធមិគា** ម្រឹគដែលត្រូវខ្លាដេញមកនោះ ក៏បាត់នូវការខ្លាច ឈរទ្រឹងស្តាប់សត្វ

ករវិក **បក្ខន្តបក្ខិនោ** ពួកបក្សាបក្សីដែលហើរក្នុងអាកាស ក៏សំកាំង ស្ងាបស្ងាប់ ពួកសត្វក្នុងទឹក ពពួកត្រីទាំងឡាយក៏មិនបានហែល ហើយ សំងិលខ្លួននៅសៀម នាំគ្នាប្រុងចាំស្តាប់ **ឯវំ មធុស្សរា** អាស្រ័យហេតុ នោះ ទើបលោកពោលសរសើរថា សំឡេងពីរោះដូចសំឡេង នៃសត្វករវិកដោយប្រការដូច្នេះ ។

**អយំ ធីរោ** មួយទៀត កោះនេះឈ្មោះថា ជម្ពូទ្វីប ជានេមិត្តកនាម អាស្រ័យដើមព្រីងប្រចាំទ្វីប ដើមឈើនោះនៅក្នុងហិមពាន្តនោះឯង **តំ បុរតោ យាវ** វាស់អំពីគល់រហូតទៅដល់ចុង បាន ១០០ យោជន៍ **បរិយន្តប្បមាណំ** បើវាស់អំពីគល់ទៅដល់ប្រគាបបាន ៥០ យោជន៍ អំពីប្រគាបទៅដល់ខាងចុងមែកបាន ៥០ យោជន៍ មែកធំៗ នីមួយៗ ៥០ យោជន៍ **តាសុ បន សាខាសុ** ក្នុងមែកព្រីងទាំង ៤ មែកនោះ មានស្ទឹងធំហូរឆ្លងកាត់ទៅក្នុងទិសទាំងឡាយ **ឧភយតីរេ** ច្រាំងស្ទឹង ទាំងពីខាងនោះ ជាទីធ្លាក់ចុះនៃផ្លែព្រីងទុំ ហើយផុសឡើងជាមាសៗ នោះ ហូរតាមទឹកទៅកាន់មហាសមុទ្រ **តស្មា** ព្រោះអាស្រ័យហេតុនោះ ពួកមាសធម្មជាតិនេះកើតអំពីជម្ពូទ្វីប ឈ្មោះថា **មាសជម្ពូនុទ** ដោយ ប្រការដូច្នេះ ។

**តេនាហុ បោរាណា** ទើបបោរាណដ្ឋកថា និពន្ធចងជាគាថាសម្តែងថា **តិបញ្ចយោជនក្ខន្ធបរិក្ខេបានគវ្ហយាបញ្ញាសយោជ-នក្ខន្ធសាខា** ជាដើម អធិប្បាយតាមសេចក្តីបាលីនិគមគាថាថា **ជម្ពូ-ទីបោ បក្កាសតោ** ទ្វីបនេះឈ្មោះថា ជម្ពូទ្វីប **យស្សានុភាវេន** ដោយអានុភាពនៃដើមព្រីងណា ដើមព្រីងនោះវាស់ដោយជុំវិញ គឺទំហំដើមបាន ៥ យោជន៍ ។ កម្ពស់ ១០០ យោជន៍ ។ បើវាស់ពីគល់ទៅខាងចុងមែក គឺទាំង ៤ ទិស ១០០ យោជន៍ ទាំងបរិមណ្ឌលនោះ មានប្រមាណស្មើគ្នា ។

**អញ្ញេ រុក្ខា** មានស្តេចឈើ ៦ ដើមដទៃទៀត **បាតលី** គឺប្រទៀង ប្រចាំពិភពអសុរ ១ **សិម្ពលី** ដើមរកាប្រចាំពិភពគ្រុឌ ១ **បារិច្ឆត្តកោ** ដើមរលួសផ្អុងប្រចាំភពតាវត្តិង្ស ១ **កទម្ពោ** ដើមក្ទម្ពប្រចាំអមរគោយានទ្វីប ១ **កប្បរុក្ខោ** ដើមកប្បព្រឹក្សប្រចាំឧត្តរកុរុទ្វីប ១ **សិរិសព្រឹក្ស** ដើមប្រេស ប្រចាំបុព្វវិទេហទ្វីប ១ ជា ៧ ទាំងដើមព្រីង ទាំងកម្ពស់ និងមណ្ឌល មានប្រមាណប៉ុនគ្នា ទាំង ៧ ដើមនេះ មានអាយុវែងតាំងនៅរហូតដល់អស់ភទ្ទកប្ប ។

**ឧត្តរកុរុកាមំ បន** ក្នុងទីនេះ នឹងលើកយកឧត្តរកុរុទ្វីបឡើង

ពោលសរសើរ ដែលជាទ្វីបដ៏វិសេស **តេ រុក្ខា** រីដើមកប្បព្រឹក្ស ទាំងឡាយ ដែលឲ្យសម្រេចនូវនិវេសនកិច្ច ពោល គឺជាទីនៅនៃ មនុស្សនោះមានមែកប្រកបទៅដោយប្រគាប និងស្លឹកជិតស្និទ្ធក្រាស់ ណែន ប៉ុន្តែមែកនីមួយៗ ប្រគាបនីមួយៗ នោះ ហាក់បីដូចជាប្រាសាទ ឬផ្ទះកំពូល ជាទីរហោស្ថាន ។ **អញ្ញេបិ រុក្ខា** សូម្បីដើមឈើដទៃ ក៏មានច្រើន ជាឈើមានផ្កា មានផ្លែ ជាទីរីករាយក្រៃលែង **ជលាសយា** ហើយក៏ប្រកបដោយស្រះទឹក និងអណ្តូងទឹក ។ ស្រះទឹក និងអណ្តូងទឹក ប្រដាប់ដោយបញ្ចុឧប្បល មានក្លិនដ៏ក្រអូបឈ្ងុយ **សរីរំបិ តេសំ** មួយទៀត មនុស្សម្នាក់ៗ ក៏ប្រាសចាកទោស គឺមិន ខ្ពស់ពេក និងមិនទាបពេក ហើយក៏មានកម្លាំង និងសេចក្តីព្យាយាម ហើយនឹងសុវត្ថិភាពមិនសាបសូន្យ មិនចាំបាច់ព្រោះពូជ មិន ចាំបាច់នាំនង្គ័លចេញទៅ ដោយគិតថា អាត្មាអញនឹងភ្ជួរក្នុងទី នោះៗ នឹងមិនលំបាកដោយពាណិជ្ជកម្ម ឬដោយការស្វែងរកនូវ អាហារចិញ្ចឹមជីវិតរបស់ខ្លួនឡើយ ។ **កាមការាធិ បរិគ្គហោ** មួយទៀត មិនមានការបោកបញ្ឆោតរវាងបុរស ឬស្ត្រី **ឆ ច តត្ថ** ប្រការមួយទៀត ក្នុងទ្វីបនោះមិនមានភយន្តរាយ ដូចជាពស់តូច ពស់ធំ របោម មូស ជន្លូវ ចៃ ខ្វា ក្រពើជាដើមឡើយ មិនក្តៅពេក

និងមិនត្រជាក់ពេក រដូវនោះស្មើជាប្រក្រតី **៩៨ តិម្ហានំ** រដូវក្នុងជម្ពូទ្វីបនេះស្មើគ្នា គឺខែ ៧ ខាងរនោច ខែ ៨ ខាងខ្នើត វេលាព្រឹកៗមានរដូវជាប្រក្រតី មិនក្តៅពេក មិនត្រជាក់ពេក ទាំងនេះមានយ៉ាងណា អ្នកឧត្តរកុរុទ្វីប គេនៅជាសុខដោយគ្រប់ៗ រដូវ គ្រប់ៗខែយ៉ាងនេះ **៩ ៥ នេសំ កោចិ** មិនមាននរណាម្នាក់បៀតបៀនវាយតប់ឈ្លោះប្រកែកគ្នានោះទេ **អកដ្ឋបាកមេវ** ស្រូវសាលីសោតក៏កើតឯងក្នុងព្រៃ ជាស្រូវមិនមានកន្ទក់ និងអង្កាម ស្អាតមានក្លិនក្រអូប ផ្លែចេញជាអង្ករ មនុស្សទាំងឡាយដាក់អង្ករនោះក្នុងឆ្នាំងចម្អិនដោយភ្លើងឥតផ្សែង មិនមានរងើក ។ មានសេចក្តីថា មនុស្សក្នុងស្រុកនោះតែងយកថ្ម ៣ ដុំ ឈ្មោះជោតិបាសាណធ្វើជាជុំជើងក្រានហើយយកឆ្នាំងតម្កល់លើជុំជើងក្រាននោះ ស្រាប់តែមានចំហាយភ្លើងក្តៅឡើងអំពីថ្មនោះ ធ្វើឲ្យឆ្អិនតែម្តង ។ **អញ្ញោ សូចោ វា** កាលទឹងបរិភោគនោះសោត មិនចាំបាច់ស្វែងរកម្ហូបសម្លជាដើម បើចង់បរិភោគនូវរសយ៉ាងណា រសនោះក៏ប្រព្រឹត្តទៅក្នុងភាជនៈតាមចិត្តប្រាថ្នានោះឯង **តំ បន ភុញ្ជន្តានំ** អាស្រ័យដោយអាហារនោះមានគុណដូច្នេះ រោគាព្យាធិក៏មិនមាន ។ ក្នុងទ្វីបនោះមិនមានមនុស្សកើតរោគស៊ើស្បែក ដូចជារោគរមាស់ រោគឃ្លង់ បូសជាដើមនោះទេ

**សមុបត្ថានំ** មួយទៀត បាយដែលបានចម្អិនឡើងនោះ នរណាមក ដល់ប្រាថ្នានឹងបរិភោគ ក៏បរិភោគតាមអធ្យាស្រ័យ មិនមានចិត្ត ហួងហែងកំណាញ់ឡើយ ។ **ពុទ្ធបច្ចេកពុទ្ធានំ យោ** ការពិត ព្រះ- អរិយៈអ្នកមានឥទ្ធិឫទ្ធិ មានព្រះសម្មាសម្ពុទ្ធ និងព្រះបច្ចេកពុទ្ធជាដើម ស្តេចតែងនិមន្តទៅទទួលបិណ្ឌបាតជារឿយៗ **ឥត្ថិយោ បិ** ក្នុងពេល នោះគួរនឹងពោលឲ្យវិសេសដោយស្ត្រីអ្នកឧត្តរកុរុទ្វីប ម្នាក់ៗ នោះ ដូចៗ គ្នា មិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិន-សពេក **សោភគ្គប្បត្តា** ម្នាក់ៗ ស្អាត ស្មើៗគ្នា **ទីឃង្គុលីតម្ពនខី** ម្រាមដៃ វែងៗ មានក្រចកពណ៌ក្រហម **អលម្ពថនា** មានស្តនមូលក្លំ មាន ត្រគាកសាយ មានចង្កេះរៀវ ។ **ចន្ទមុខី** មានវង់ភក្ត្រហាក់បីដូចដួងចន្ទ **មុទុគត្តា សឞិតោរុ** មានដៃជើងល្វតល្វន់ មានសម្ផស្សជាសុខគួរ ដល់រដូវ មានវាចាពីរោះផ្អែមល្ហែម **អយំ ធម្មតា** វីការសម្តែងមកនេះ ជាធម្មតារបស់អ្នកស្រុកឧត្តរកុរុទ្វីប មានយ៉ាងនេះឯង **កាមារតិយា** ប្រការមួយទៀត អ្នកស្រុកឧត្តរកុរុទ្វីបនោះ ស្ត្រីទាំងឡាយ បើនឹង មានតម្រេកដោយរាគៈ នឹងមាននោះក៏ត្រឹមតែ ៧ ថ្ងៃ **យថា កថំ** ផុត ៧ ថ្ងៃហើយ ក៏អស់តម្រេកត្រេកត្រអាល **៩៨ វិយ គច្ឆោកគ្គិក-**

**ម្ពលកាំ** ការពិត ស្ត្រីក្នុងទ្វីបនេះប្រកបគព្ភោកន្តិមូលកទុក្ខ និងគព្ភ-បរិហារណមូលកទុក្ខ គឺបាននូវសេចក្តីលំបាកខណៈមានគភ៌ ឲ្យឈឺចុកចាប់ ឬអាពាធមានប្រការផ្សេងៗ និងលំបាកដោយការរក្សាគភ៌មានប្រការផ្សេងៗ មិនមានដូច្នោះឡើយ មានគភ៌ក៏សប្បាយ មិនមានក៏សប្បាយ សូម្បីប្រសូតក៏មិនលំបាកៗ ទាំងម្តាយ ទាំងកូន **មាតុកុច្ឆិតោ អមក្ខិតា** ទារកដែលប្រសូតមកនោះប្រាសចាកមន្ទិល បរិសុទ្ធដូចដុំមាសដែលបុគ្គលដាក់លើសំពត់កម្ពល **អយំតត្ថ ធម្មតា** យ៉ាងនេះក៏ជាប្រពៃណីដូច្នោះទាំងអស់ ។ ចំណែកម្តាយកាលបើប្រសូតកូនរួចហើយ ក៏ដូចជាហីទៅ មិនអើពើរវល់អាល័យចង់ទៅណា ក៏ទៅតាមចិត្ត ទារកក៏ដេកនៅស្ងៀមទីនោះ **យេ បស្សន្តិ** ជាទារក ឬទារិកាក៏មិនគិតទេ ទីបំផុតនរណាមកឃើញ ក៏យកម្រាមដៃដាក់ចូលទៅក្នុងមាត់ហើយ ក៏សម្រេចកិច្ចជាអាហារ ជាទឹកដោះហូរចេញមក និងរស់នៅដូច្នេះមិនយូរ **កតិបយទិវសេហេវ** ពេញ ៣ ថ្ងៃក៏ក្រោកដើរបាន ជាស្ត្រីក៏ទៅកាន់ពួកស្រី ជាបុរសក៏ទៅកាន់ពួកបុរសមានតែភាពសុខសប្បាយ មិនលំបាកអ្វីបន្តិចឡើយ **កប្បរុក្ខោ និប្ប-ជន្តិ** មនុស្សទាំងឡាយក្នុងទ្វីបនោះ សម្រេចនូវវត្ថាភរណៈអំពីដើមកប្បព្រឹក្ស តាមចិត្តនឹកគិត មានសម្លៀកបំពាក់គ្រឿងអលង្ការនៅ

គ្រង់ដើម ឬមែកតូចធំ ជាទីរីករាយចិត្តវិសេសទៅក្រៃលែង រហូតដល់គ្រឿងតូរ្យតន្ត្រី មានរនាត ប៉ី ស្គរ សម្ភោរ ចំពោះអ្នកណាដែលប្រាថ្នាចង់បាន ស្ទឹងសោតក៏មានភាពពិសេស មានទឹកថ្លា មានកំពង់រាបស្អាតប្រាសចាកភក់ មិនត្រជាក់ពេក មិនក្តៅពេក មាត់ច្រាំងដេរដាសទៅដោយគន្ធជាតិ មានផ្កាសុរភីជាដើម **សុរភិវាយន្តិ** មានក្លិនក្រអូបសាយ **ឆហាយិតុកាមា បឆ** កាលពពួកមនុស្សនាំគ្នាចុះកាន់កំពង់ទឹក សម្លៀកបំពាក់ គ្រឿងប្រដាប់កាយទាំងឡាយនោះក៏ទុកជាគំនរ ៗ លុះមុជទឹករួចហើយ ឡើងមកផ្លាស់សម្លៀកបំពាក់និងពាក់គ្រឿងប្រដាប់កាយសោត ក៏មិនបានប្រកាន់ហួងហែងក្នុងសម្លៀក និងគ្រឿងប្រដាប់នោះឡើយ **សយិតុកាមា** កាលប្រាថ្នានឹងដេកក៏ចូលទៅកាន់ដើមឈើៗ នោះ ក៏សម្រេចកិច្ចជាពូក ខ្នើយ **មតេ ច** កាលស្លាប់ទៀតសោត ក៏មិនមានអ្នកណាយំ មិនអាល័យដល់គ្នា **តញ្ច មណ្ឌយិត្វា** ស្លាប់ហើយក៏នាំគ្នា រៀបចំយកសំពត់រុំសពហើយយកបោះចោល មានបក្សាបក្សីធំមួយពួក ហើរមកដល់ហើយ ក៏ចាបពាំយកសាកសពនោះទៅចោលឯកោះដទៃ ហេតុណា ហេតុនោះ ក្នុងឧត្តរកុរុទ្វីបនោះមិនមានព្រៃខ្មោច ទីស្មោកគ្រោក គឺសាកសព មូត្រនិងលាមកនោះមិនមាន **ឆ ច តតោ** ម្យ៉ាងទៀត អ្នកឧត្តរកុរុទ្វីប

ស្លាប់ហើយ មិនទៅកើតក្នុងអបាយភូមិឡើយ ដោយអំណាចនៃសេចក្ដីបរិសុទ្ធក្នុងបញ្ចសីល បានកើតក្នុងទេវលោកទាំងអស់ នេះក៏ជាវិស័យធម្មតានៃអ្នកឧត្តរកុរុទ្វីបនោះ **ឯវំ បវត្តមានំ** កាលលោកសន្និវាស លោកធាតុ ១ ប្រព្រឹត្តទៅដោយន័យសម្ដែងមកដោយសង្ខេបដូច្នេះ **ចក្កវាឡន្តិ វុច្ចន្តិ** ព្រះសម្មាសម្ពុទ្ធនៃយើង ព្រះអង្គត្រាស់ហៅថាចក្កវាឡដោយអត្ថថា មានភ្នំកណ្ដាប់ចក្កវាឡសូម្បីព័ទ្ធជុំវិញឲ្យមូលហាក់បីដូចកងចក្រ **សោ បន ទេ្វ** ចំណែកភ្នំកណ្ដាប់ចក្កវាឡ **អដ្ឋោគាឡ្ហោ** លិចនៅក្នុងទឹក ៨ ម៉ឺនយោជន៍ ផុតអំពីទឹក ៨ យោជន៍ ព័ទ្ធជុំវិញលោកធាតុ ហេតុដូច្នោះទើបឈ្មោះថា ចក្កវាឡដោយប្រការនេះ ។

វក្កវាឡនេះ វិនាសដោយភ្លើង ៧ ដង ទើបវិនាសដោយទឹកម្ដង វិនាសយ៉ាងនេះ ៧ ជុំ គឺ ៥៦ ដង ទើបវិនាសដោយខ្យល់ម្ដង ។ **កប្បស្ស វិនាសសណ្ឋាហានាការោ** ការពិតក្នុងលោកសណ្ឋិតិមាតិកានេះសម្ដែងនូវសេចក្ដីវិនាស និងការចម្រើនឡើងនៃលោកជាសំណួរក៏ចប់ត្រឹមតែប៉ុណ្ណេះ ។

អ្នកប្រាជ្ញគប្បីជ្រាបលថាពោលអំពីការវិនាស នៃលោកជាដើមតាមអដ្ឋកថាអគ្គញ្ញសូត្រ ក្នុងទីឃនិកាយ និងវិសុទ្ធិមគ្គ ការកើត

ឡើងនៃដើមឈើ មានពោធិព្រឹក្សជាដើមនោះ គប្បីជ្រាបក្នុងអដ្ឋកថា មហាបទានសូត្រ ការចែកនូវបរិមាណ និងគមនកិរិយានៃព្រះអាទិត្យ ព្រះចន្ទជាដើមនោះ ក្នុងអដ្ឋកថាអគ្គញ្ញសូត្រ គប្បីជ្រាបចន្ទគាថ និង សុរិយគាថនោះ ក្នុងអដ្ឋកថាទេវតាសំយុត្តសូត្រ ក្នុងសំយុត្តនិកាយ គប្បីជ្រាបទេវាសង្គ្រាម និងអសុរសង្គ្រាមនោះ ក្នុងអដ្ឋកថាសំយុត្ត-សូត្រ សំយុត្តនិកាយនោះឯង គប្បីជ្រាបជម្រៅ និងការតាំងនៅនៃ មហាសមុទ្រក្នុងអដ្ឋកថាមហារាជសូត្រ អង្គុត្តរនិកាយនោះឯង គប្បី ជ្រាបអាការញ្រាប់ញ្រ័រនៃទឹក និងរលកជាដើមតាមអដ្ឋកថាធម្មហទយ វិភង្គ ក្នុងវិភង្គប្បករណ៍នោះឯង គប្បីជ្រាបមហាសមុទ្រឈ្មោះខុរ-មាលីជាដើមតាមអដ្ឋកថាសុប្បារកជាតកនោះឯង គប្បីជ្រាបវឡវា-មុខនទីតាមអដ្ឋកថាថេរគាថាសុត្តបាលី និងអដ្ឋកថារបស់ព្រះ-គលបូជត្ថេរ គប្បីជ្រាបទំហំត្រីធំតាមអដ្ឋកថាមហានិទានសូត្រ ទីឃ និកាយ គប្បីជ្រាបព្រៃហិមពាន្តជាដើមតាមអដ្ឋកថាសំយុត្តនិកាយជា ដើម គប្បីជ្រាបសម្បត្តិអ្នកឧត្តរកុរុទ្វីបតាមអដ្ឋកថាអាដានាដិយសូត្រ នោះហោង ។

**ឯវមិមិស្សា លោកសណ្ឋិតិយា គហិតដ្ឋានដិយមោ**

កិរិយាដែលខ្ញុំឈ្មោះថានន្ទាចារ្យសម្តែងនូវលោកសណ្ឋាននេះ ដោយ

បំណងថា នឹងញ៉ាំងអ្នកប្រាជ្ញដែលឈ្លាស ក្នុងព្រះបរិយត្តិធម៌ឲ្យចាំ ឆាយទៅតាមគម្ពីរដែលអានទុក និងញ៉ាំងបសាទសទ្ធាជ្រះថ្លាឲ្យមាំទាំ តាមព្រះពុទ្ធដីកាដែលទ្រង់ប្រទាន ។

**សព្វសោ សារត្ថសង្គហោ** គម្ពីរសារត្ថសង្គហៈនេះ វិចិត្រ ទៅដោយសង្គហៈ ៤០ គត់ និង ២៦ ភាណវារ ក៏សន្មតចប់ត្រឹម តែប៉ុណ្ណេះហោង ៕

លោកសណ្ឋានកថា ចប់

សារត្ថសង្គហៈ ចប់

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែផល្គុន ព.ស.២៥៥៥

**ដោយសមាគមធម្មទានអរិយវង្សយង់ស្ទូផាត**

## ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានត្រាំព្យន័រជាដើម ក្នុងកិច្ចការខាងធម្មទាន

✵ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា ប៊ួរ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក ប៊ួរ ស៊ីផូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា ប៊ួរ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា ប៊ួរ ដាវី កញ្ញា អ៊ឹង មុយហៀក

✵លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទបូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សារ៉ឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ឹង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារេត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

✵ឧបាសក ឈុំ គឹម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

✵ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

✵ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមថៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងងិម និងស្វាមី ព្រមទាំងកូនចៅ

✵ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ជុះ ចំណាន

ឧបាសិកា វិញ ពូន

✵ឧបាសក ឡាំ ធៀន ឧបាសិកា ស៊ឹន ចន្ថា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់វារី

✵ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ួន ព្រមទាំងបុត្រ

ញោម ឥម្មន្ទីនិងជូ ញោម ហាន ញោម រ៉ែន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា

នា ញោម ឆាង ញោម ជឹង ឡេង ញោម អៀម ញោម កួង ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ធាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម ស៊ិន ញោម ភាព សាវឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា ។

❋ ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុនសេរី

លោក ដែង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ ឧបាសក អ៊ុង ហេ្គចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ

លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ុង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ុង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ុ ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ

❋ ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្តាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អឿន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ុ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ែ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នឿង+យាយ ធីង+គួង ភាង+សើន គា+សឿង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាវ៉ាឡែន+ ហ៊ុង+ ប៉ែ ង៉ា+ រី រុត្ន

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណេរ អ៊ុំ វីរៈ

ញោមប៉ែ ង៉ាថូគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត

ញោម ហ៊ុង+នាង មឿន+អូនប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+ តាំង វេន+ យុន+ យាយ ធុច + យាយ យន

ញោម ហ៊ិន  ស៊ិម ញោម អឿន ភី+វ៉ាន់  ស៊ុនឡាយ+ផល្លី+សវ៉ាមី
ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី
ញោម ណៅ ហ្គេចណៃ+វ៉ាន់ សុផានី+សា រឿន+សំ គី+ចាន់ ណារ៉ា
ញោម ធារ៉ា+យឿត និងស្វាមី+ហួត អេង+អារ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី
ញោម អៀប សានួន+ យាយ ហឿន+យាយ ឡាំ+ភេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

# នាមពុទ្ធបរិសទ្យនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា
# ឧបត្ថម្ភប្រាក់ប្រចាំខែ

| | |
|---|---|
| លោកម្ចាស់ សោម ហួន | |
| លោកគ្រូធម្មបណ្ឌិត | ( ទក្ខប្បញ្ញោ ) អឿ សៅ |
| ឧបាសិកា ធឹក ស្រ៊ិន | ព្រមទាំងកូនប្រុស អ៊ឹង រិទ្ធី និងភរិយា |
| ឧបាសក ប៊ូហោ នាង | ឧបាសិកា អ៊ុង រិទ្ធារី ព្រមទាំងបុត្រធីតា |
| ឧបាសក យេម សំណាង | ឧបាសិកា យេម ឡរ៉ា ព្រមទាំងបុត្រ |
| ឧបាសក សៅ ហ៊ាន | ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ |
| ឧបាសក ឈៀងសារឿន | ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា |
| ឧបាសក ម៉ៅ វង្ស | ឧបាសិកា ឆាន់ កាន់ជួង ព្រមទាំងបុត្រ |
| ឧបាសក និន ហាក់ | ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ |
| ឧបាសិកា ម៉ី ចាន់រ៉ាវី | ព្រមទាំងបុត្រធីតា |
| ឧបាសិកា យ៉ក់ ស៊ីមូរ៉ា | ព្រមទាំងបុត្រ |
| ឧបាសិកា វាន់ចាន់ | ព្រមទាំងបុត្រធីតា |
| ឧបាសិកា ខៀវ ណាត | ព្រមទាំងបុត្រធីតា |

## នាមពុទ្ធបរិសទ្យនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

*ឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គីមសែ កូន+ចៅ*

*ឧបាសិកា យូ ស៊ាងនួនលី ព្រមទាំងកូនចៅ*

## នាមពុទ្ធបរិសទ្យនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

*ឧបាសក ប៊ុន ហេង ឧបាសិកា ជុំ សុខុម*

*ឧបាសិកា ហេង ស្រីជា ឧបាសិកា ហេង ស្រីចន្ទ*

*ឧបាសិកា ហេង គន្ធា ឧបាសក ហេង សុកត្រ័*

## នាមពុទ្ធបរិសទ្យនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

*ឧបាសក ឈុំ គីមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ*

*ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន*

*ឧបាសក អ៊ឹង ហ្គិចឡេង ឧបាសិកា តាំង ប៉ោងជីង ព្រមទាំងកូនចៅ*

*ឧបាសក វៀម ឈើន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ*

ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក នាង រ៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ

ឧបាសក សៅ ស៊ីន្ធូរ៉ា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលៀម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធរី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ុម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡេា សាយហ៊ួច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិសទ្យនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងបុត្រធីតា និងចៅ

ឧបាសិកា ប៉ោ គីមស៊ុន ព្រមទាំងបុត្រធីតា និងចៅ

លោក លី ហុង លោកស្រី ជា ណារី ព្រមទាំងបុត្រធីតា និងចៅ

លោក ផូ ចាន់ថន លោកស្រី ជា ណាវី ព្រមទាំងបុត្រធីតា

លោក លឹម ចាន់ឌី លោកស្រី ទេព ចិន្តា+បុត្រធីតា និងចៅ

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា លោកស្រី លឹម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន+កូនចៅ

ឧបាសិកា ធុយ ឈីវអួន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន+កូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា លោកស្រី មុំ ដាន់ ព្រមទាំងបុត្រធីតា

លោក ចាប សោភ័គ លោកស្រី មុំ ដា ព្រមទាំងបុត្រធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រធីតា និងចៅ

លោក រស់ ប៊ុនឡេង លោកស្រី ឡេង ស៊ីនី+បុត្រធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀវ ងីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

លោក សំរិត សឿន លោកស្រី ជុន បូណ៌មី ព្រមទាំងបុត្រ

ឧបាសិកា ធា ព្រមទាំងកូនក្មួយ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជឹ សុខអៀម ឧបាសិកា តាំង ស៊ូអេង+កូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជឹ ញ៉េ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ំ ម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ជឹ ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង+កូនចៅ

ឧបាសិកា គី បួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ារិទ្ធ លោកស្រី រស់ ចិន្ដា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា ឃន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនក្មួយ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា ស៊ិន ឡាច ព្រមទាំងក្រុមគ្រួសារ

ឧបាសក ប៊ុន បួន ឧបាសិកា យុត សួរ ព្រមទាំងកូនចៅ

លោក ផាន សុបិន លោកស្រី សំ សុវណ្ណមល្លិកា+បុត្រ

បងស្រី ណៅ សុភី និង ប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី លោកស្រី អួន សារ៉េត ព្រមទាំងបុត្រធីតា

លោក ឱម ឡូត លោកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រធីតា

លោក ម៉ាន់ សារឿន លោកស្រី ម៉ម សុធា+បុត្រធីតា

លោក ស៊ឹម សារ៉ាន់ លោកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេង វណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គីមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧ.សិ ប៉េ សារ៉ា ឧ.ស ម៉ី ធារី ឧ.សិ ម៉ៅ ណារី+កូនចៅ

ឧបាសក ប៉ៃ ស៊ីថា ឧបាសិកា ង៉ួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ ព្រមទាំងក្រុមគ្រួសារ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃ្លោក ម៉ាន ឧបាសិកា ជូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា ម៉ៅ សុផានី ព្រមទាំងបុត្រធីតា

លោក លឹម លី លោកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រធីតា

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុធធារី ព្រមទាំងកូនចៅ

ឧបាសិកា មាស ជី ព្រមទាំងកូនចៅ

ឧបាសិកា ទេព ធុនណារី ព្រមទាំងកូនចៅ

ឧបាសិកា អៀវ គីមហេង យាយទ្រព្យ ព្រមទាំងកូនចៅ

លោក ទូច ថៃ លោកស្រី សុខ នី ព្រមទាំងកូនចៅ

លោក ផូ ប៊ុនធឿន លោកស្រី កង ស្រីអូន ព្រមទាំងកូនចៅ

លោក ពៅ វឌ្ឍា លោកស្រី ខិន សុផល ព្រមទាំងកូនចៅ

ឧបាសិកា ឈឺន សន ព្រមទាំងកូនចៅ

ឧបាសិកា ឡេង ស៊ីម ព្រមទាំងកូនចៅ

លោក ស៊ិន ឡោ លោកស្រី កុក សេងលី ព្រមទាំងកូនចៅ

លោក គិត សេដ្ឋ លោកស្រី ឃឹម សុភណា ព្រមទាំងបុត្រ

ឧបាសិកា ទូច គីមឃី ព្រមទាំងកូនចៅ

ឧបាសិកា កែ យ៉ុម ព្រមទាំងកូនចៅ

លោកស្រី អ៊ីង សុធារី ព្រមទាំងកូនក្មួយ

លោក សាន់ វ៉ុន លោកស្រី អ៊ីង ស្រីពៅ

លោក ជុំ ឌី លោកស្រី ជឹម ណារី ព្រមទាំងបុត្រ

ឧបាសិកា គាំ នួន ព្រមទាំងកូនចៅ

លោក ជឹម វុធី លោកស្រី គង់ ណាគ្រី ព្រមទាំងបុត្រ

ឧបាសិកា ទូច អ៊ឹមអ៊ីម ព្រមទាំងកូនចៅ

លោក ពេជ្រ វិសាល និងភរិយា

ឧបាសក រស់ ហុងអៀង ឧបាសិកា កា គឹមហេង+កូនចៅ

ឧបាសិកា អ៊ិត លៀងពិន ព្រមទាំងកូនចៅ

ឧបាសិកា ឆេង ម៉ែន យុន វឌ្ឍារ៉ា ហៅ ដារ៉េត ព្រមទាំងបុត្រ

លោកស្រី ម៉ៅ សុធារី និងស្វាមី ព្រមទាំងបុត្រ

លោកស្រី ចាន់ ម៉ាលី និងស្វាមី ព្រមទាំងបុត្រ

លោកស្រី ស៊ុន សុធារី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា មុត សំអុន ព្រមទាំងកូនចៅ

ឧបាសិកា ទុំ លាន ព្រមទាំងកូនចៅ

ឧបាសិកា ឡាយ មួយ និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ស្រអែម ផល្លា ព្រមទាំងកូនចៅ

ឧបាសិកា ចាន់ សុភី ព្រមទាំងកូនចៅ

ឧបាសិកា សួន សុខយាង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសក ធឹង ផាត់ ឧបាសិកា ណុប សៀងហេង+កូនចៅ

លោកស្រី សួង សុភាព និងស្វាមី ព្រមទាំងបុត្រ

លោកស្រី សួង សុភី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា សាយ សុខលីម ព្រមទាំងកូនចៅ

ឧបាសក ថៃ ប៊ុនលី ឧបាសិកា សាយ សុខហួត+កូនចៅ

លោកស្រី ហេង ម៉ានិត និងស្វាមី ព្រមទាំងបុត្រ

លោកស្រី យន់ សុភាវី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា តាំង សៀមគាវ ព្រមទាំងកូនចៅ

ឧបាសិកា ខ្នុរ សេរី និងស្វាមី ព្រមទាំងបុត្រ

លោក ឡឹង លោកស្រី ស្រីណា ព្រមទាំងបុត្រ

ឧបាសក ឃី គង់មា ឧបាសិកា សាម មុយខេង+កូនចៅ

ឧបាសិកា ជា ប៊ុច ព្រមទាំងកូនចៅ

ឧបាសិកា ឃឹម តុន ហៅយាយ ប្រាក់ ព្រមទាំងកូនចៅ

ឧបាសិកា បេអិច ស៊ាង ព្រមទាំងកូនចៅ

លោក សុខ បូរ៉ា និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា មុត សំអុន ព្រមទាំងកូនចៅ

លោក ឡេង ស្រេង់ លោកស្រី ហាក់ ស៊ីយឿន និងបុត្រធីតា

ឧបាសិកា ហាក់ សុគន្ធា ព្រមទាំងកូនចៅ

ឧបាសិកា ថៃ ស្រីមុំ ព្រមទាំងកូនចៅ

ឧ.សិ ទី ណារិន និងកូនចៅ ឧទ្ទិសជូន ឧ.ស ចាយ ថាន់

ឧបាសក ស៊ុម ប៊ុនសុង ឧបាសិកា ជួន វិបុល និងកូនចៅ

ឧបាសក ឌូ យឿន ឧបាសិកា អ៊ួន ស៊ុម ព្រមទាំងកូនចៅ

លោកស្រី ស៊ុយ សុខាលីន និងស្វាមី ព្រមទាំងបុត្រ

ឧបាសក អ៊ីវ ធុន ឧបាសិកា ទន់ នួវ ព្រមទាំងកូនចៅ

ឧបាសិកា យី ផល្លី ព្រមទាំងកូនចៅ

ឧបាសិកា យុត ណោត ព្រមទាំងកូនចៅ

ឧបាសិកា សួស ហៀង ព្រមទាំងកូនចៅ

ឧបាសិកា ហុង ហ៊ាន ឧបាសិកា លីសាន ព្រមទាំងកូនចៅ

លោកស្រី ព្រុំ នាង និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ពេជ្រ ស៊ុម ព្រមទាំងកូនចៅ

ឧបាសិកា ហៀង រី ព្រមទាំងកូនចៅ

ឧបាសក សុខ ផល្លា ឧបាសិកា នាក់ សុខុម និងបុត្រ

ឧបាសិកា ហេង ណឹប ព្រមទាំងកូនចៅ

លោក ចាន់ សុផល ឧបាសិកា ហ៊ៅ ចាន់ណារី

លោក ស៊ឹម សារឿន ឧបាសិកា លឹម ម៉ាលី និងកូនចៅ

លោក ឡុង ប៉េងហួរ

លោក អ៊ុន ប៉េង ឧបាសិកា ទិត្យ សំអឿន និងកូនចៅ

លោក ខៀវ សាមុត លោកស្រី ថោង សុគន្ធា និងកូនចៅ

លោក លាវ វិប៊ែល លោកស្រី ឡេង វន្ថា និងកូនចៅ

លោក ឡេង វណ្ណដា លោកស្រី ម៉េង ក័ក្រ្តណា និងបុត្រ

## នាមពុទ្ធបរិសទ្យនៅភ្នំពេញមានសទ្ធាជ្រះថ្លា
## ឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគីម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុធី +បុត្រ ហែម តុលា

## នាមពុទ្ធបរិសទ្យនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា ឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ុវទៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិសទ្យអ្នកមានឧបការៈក្នុងការខារធម្មទាន

១- សាមណេរ កែន សុធន

២- ឧបាសក ប៉េង តាំងហៃ ឧបាសិកា ហ៊ូ គីមហៀក

៣- ឧបាសក ស្រេង ស្រ៊ាង ឧបាសិកា គិម ចន្ថា

៤- ឧបាសក ឡាយ សុខុម ឧបាសិកា គី គីមហាប់

៥- ឧបាសិកា ប៊ួរ ម៉ាឡា កញ្ញា ប៊ួរ ដាវី

៦- ឧបាសិកា ង៉ែត យូអេង កញ្ញា អ៊ឹង មុយហៀក

៧- ឧបាសក លឹម ខូង ឧបាសិកា កែវ អុន

៨- ឧបាសិកា កែវ កល្យាណ ឧបាសិកា សុខ សុទ្ធី

៩- ឧបាសិកា សឺន ចន្ថា លោក ឡាំ ដាវណ្ណ

១០- ឧបាសិកា គួ ប៊ុនគាង ឧបាសិកា ឈុំ គីមហួយ

១១- ឧបាសិកា នេត្រ នរិន្ទ ឧបាសិកា ទន់
១២-ឧបាសិកា ឱម លក្ខណា ឧបាសិកា ហេង ច័ន្ទបុញ្ញវឌ្ឍី
១៣-ឧបាសិកា គី យក់បួយ ឧបាសិកា ឈុន ណាត
១៤-ឧបាសិកា អ៊ឹង រិទ្ធារី ឧបាសក អ៊ុន សេរី
១៥-ឧបាសិកា វៀម ថុល ឧបាសិកា ម៉ៅ នី
១៦-ឧបាសក សន ឈៀត ឧបាសក ឡាន សុខុម
១៧-ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ប៉ាន ណម
១៨-ឧបាសិកា សួន កល្យាណ ឧបាសិកា ភួង កក្តី
១៩-ឧបាសក អ៊ឹម វ៉ៃយ៉ា ឧបាសក កុយ សាមន
២០-ឧបាសក ហុង សុវណ្ណារិទ្ធ ឧបាសក ហុង សុវណ្ណារ៉េត

ខ្ញុំព្រះករុណា អាត្មាភាពមានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរសព្ទនេះ ០១២ ៣០៥ ៧៦៦, ០៨៨៨ ៧៧ ៩៩ ៦៦ ០៧៧ ៦៦ ៦៦ ៣៨ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសក** មាន ៥ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៥ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

**-វិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេចដែរ ដែលមាន ៣ ភាគ ។

**-គម្ពីរសារត្ថសង្គហៈ** ហើយសព្វថ្ងៃនេះ បានធ្វើរួចជាស្ថាពរ គឺវាយកុំព្យូទ័ររួចជាស្រេចអស់ហើយទាំង ២ ភាគ ដែលមានកម្រាស់រហូតទៅដល់ ៦០០ ទំព័រជាង ។

**-គម្ពីរអភិធម្មត្ថសង្គហៈ** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦៥០ ទំព័រជាង ។

**-អភិធម្មត្ថសង្គហៈ** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៩៨៩ ទំព័រជាង ។

**-គម្ពីរអភិធម្មាវតា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

**-មិលិន្ទបញ្ហា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

**-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន** បានធ្វើសម្រេចជាស្ថាពរហើយ ដែលមានចំនួន ៥ ភាគ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦០០-៧០០ ទំព័រជាងក៏មាន ។

**-ខ្ញុំព្រះករុណា អាត្មាភាព** មានបំណងនឹងរៀបចំធ្វើ **គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា** បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដក

ហើយដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានេះ ព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយកុំព្យូទ័រចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នា ដែលធ្វើសម្រេចជាស្ថាពរ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិនយបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ ភាគ
-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ
-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ
-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ
-គម្ពីរអង្គុត្តរនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១៣ ភាគ
-គម្ពីរខុទ្ទកនិកាយ ប្រែបាន ២៥ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នាសព្វថ្ងៃនេះ បានចំនួន ៧៨ ក្បាលជាងហើយ ។

## សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
## ខ្ញុំព្រះករុណា អាត្មាភាព
## ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក ១-៨

-ជីវប្រវត្តិព្រះពុទ្ធសាវិកា ១-៤

-ជីវប្រវត្តិព្រះពុទ្ធឧបាសក ១-៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ១-៤

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន ១-៥

-វិសុទ្ធិមគ្គ និងបរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស ១ ភាគ

-វិសុទ្ធិមគ្គ និងបរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស ១-៤

-វិសុទ្ធិមគ្គ និងបរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ១-៣

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-ពុទ្ធប្បវត្តិ

-គម្ពីរសារត្ថសង្គហៈ ពីភាគ ១-២ ។

# ឧបត្ថម្ភប្រាក់ទ្រទ្រង់សមាគមប្រចាំខែ

ឧ.សិ តាំង ប៉ោជីង ស្វាមី ព្រមទាំងកូនចៅ ........... ១០០ $

ឧ.សិ { អ៊ឹម ចាន់ណា និងកូនក្មួយ<br>អ៊ឹម ចាន់ណាក់ ស្វាមីនិងកូនចៅ } ........... ៣០ $

ឧ.សិ ជា នាង ព្រមទាំងជីតា .......................... ២០ $

ឧ.ស អ៊ឹង ប៊ុនហួរ ឧ.សិ ប៊ួរ ម៉ាឡា និងបុត្រ ....... ២០ $

ឧបាសិកា ហុក ជុន និងស្វាមី ព្រមទាំងកូនចៅ ....... ២០ $

ឧបាសិកា គី ពេញ ព្រមទាំងកូនចៅ ...................... ២០ $

ឧ.ស ហុង ជ្រិន ឧ.សិ ឡេង ចំរើន កូនចៅទួត ..... ១០ $

ឧបាសិកា ពៅ សូហ៉ាង ហៅសូយ៉ាង .................... ១០ $

ឧ.ស ង៉ូវ គា ឧ.សិ ឈុន គីមអេង +កូនចៅ ....... ១០ $

ឧបាសិកា ជា នាង និងកូនចៅ ............................ ១០ $

ឧបាសិកា ពូ ហ៊ាង និងកូនចៅ ........................... ១០ $

ឧបាសិកា ភ្លាត វណ្ណា និងកូនចៅ ...................... ១០ $

ឧបាសិកា ហោ ភាព ក្មួយចៅ ............................ ១០ $

ឧបាសិកា យក់ វ៉ាន់ថា កូនចៅ ............................ ១០ $

ឧបាសិកា ប៊ូ សៀកលីវ និងកូនចៅ ....................... ១០ $

ឧ.ស ឈុន ចន្ទា ឧ.សិ កត់ សុធន្នី និងកូន ......... ១០ $

ឧបាសិកា ស៊ី គឹមវួច ........................................ ១០ $

ឧបាសិកា អ៊ុំ សាវរី ........................................ ៥ $

ឧបាសិកា នួន ប៊ុនលី កូនចៅ ............................... ៥ $

ឧបាសិកា ឯម សុវណ្ណារា ........................................ ៥ $

ឧបាសិកា អៀម ខុន ព្រមទាំងកូនចៅ ................. ៥ $

ឧ.ស ថេត ប៊ុនថុល ភរិយា រស្មី និងកូន .............. ៥ $

ឧបាសិកា ញ៉ឹក សាអន ព្រមទាំងកូនចៅ ................. ៥ $

ឧបាសិកា សុខ នាង ព្រមទាំងកូនចៅ ...................... ៥ $

ឧ.ស ហុង ឆាយ ឧ.សិ ម៉ា សុភី និងកូនចៅ ........... ៥ $

ឧបាសិកា { តៀ សុខុម / សុប គាត / សុប សារុំ } .......................... ១៥០០០ ៛

ឧបាសិកា ជាម មួន និងកូនចៅ ........................ ១០០០០ ៛

ឧបាសិកា ចៅ យ៉ា និងកូនចៅ ........................ ១០០០០ ៛

ឧបាសិកា លី ម៉េង និងកូនចៅ ...................... ១០០០០ ៛

ឧបាសិកា ង៉ែត ពីន និងកូនចៅ ..................... ១០០០០ ៛

ឧបាសិកា វ៉ាន់ សុផាត និងក្មួយ ..................... ៥០០០ ៛

ឧបាសិកា ជា ស៊ីវវួច និងកូនចៅ ................... ៥០០០ ៛

## នាមពុទ្ធបរិសទ្យបរិច្ចាគប្រាក់បោះពុម្ពសៀវភៅ

ឧបាសិកា ឱម លក្ខិណា ........................... ១០០ $

ឧ.ស អ៊ឹង ប៊ុនហួរ ឧ.សិ ប៊ួរ ម៉ាឡា និងបុត្រ... ១០០ $

ឧបាសិកា ឃឹម តាន់ ............................. ៤០ $

ឧ.ស ជា ទិត ឧ.សិ ហុង ចិន .......................... ២០ $

ឧបាសិកា ពៅ សារ៉ាង .............................. ២០ $

ឧ.ស គីម សៀង ឧ.សិ ហេង វ៉ាន់ថា និងកូនចៅ. ៣០០០០+១០ $

ឧ.ស សេង យ៉ាន ឧ.សិ អុន ណារិន និងកូនចៅ... ១០ $

| | |
|---|---|
| ឧ.សិ ហង្ស ចន្ទី លោកលី មិញ អ្នកស្រី វឌ្ឍី..... | ១០ $ |
| ឧ.ស ទិត វីណា ឧ.សិ កែវ សុខា និងកូនចៅ....... | ៥ $ |
| ឧបាសិកា សោម ឡុង ព្រមទាំងកូនចៅ .......... | ៥ $ |
| ឧ.ស លី ហេង ឧ.សិ លី ឡេង ........................ | ១០០០០០ ៛ |
| ឧ.ស ហុង ឆាយ ឧ.សិ ម៉ា សុភី +កូនចៅ........... | ៥០០០០ ៛ |
| ឧបាសិកា លី ម៉េង និងកូនចៅ ........................ | ៣០០០០ ៛ |
| ឧ.ស ង៉ែត សៀកផេង ឧ.សិ ជួប សៀត+កូនចៅចៅទួត. | ៣០០០០ ៛ |
| លោកយាន វារៈ អ្នកស្រី ជៀង សាវង្ស ............. | ២០០០០ ៛ |
| ម៉ែ ពូអៀន ................................. | ២០០០០ ៛ |
| ឧ.សិ ផាត់ លី ឧ.សិ សៀក ឡាង ..................... | ២០០០០ ៛ |
| លោកអុក សារឿន អ្នកស្រី ស្រាង វណ្ណា ........... | ២០០០០ ៛ |
| ឧ.ស ហោ ឆាយ ឧ.សិ ហៃ ម៉ៅ និងកូនចៅ..... | ២០០០០ ៛ |
| លោកប្រាង ឡុន អ្នកស្រីរឿន គន្ធី និងកូន.......... | ២០០០០ ៛ |
| ឧបាសិកា តាំង វួចឡាង និងកូនចៅ ................ | ២០០០០ ៛ |
| ឧបាសិកា ទេព គីមហ៊ា .............................. | ១០០០០ ៛ |
| ឧបាសិកា មុយ យួម .............................. | ១០០០០ ៛ |

ឧ.ស លឹម យុន ឧ.សិ វង់ ស៊ាង និងកូន ......... ១០០០០៛

ឧ.ស តូច យន់ ឧ.សិ សឹង ផាន និងកូន ........... ១០០០០៛

ឧបាសិកា សន សុខុម ព្រមទាំងបុត្រ ......... ១០០០០៛

ឧ.ស ហេង ម៉ឹក ឧ.សិ ឌុប ច័នរតនៈ និងកូន .... ១០០០០៛

ឧ.ស វិន ឧ.សិ ផាត់ ព្រមទាំងបុត្រ ..................... ៥០០០៛

នី ស៊ើន ព្រមទាំងបុត្រ ..................... ៥០០០៛

អាត កៀត ព្រមទាំងបុត្រ ..................... ៥០០០៛

ឧបាសិកា ហួត សោភ័ណ និងក្ដួយ .................... ៥០០០៛

ឧ.ស ម៉ី យ៉ូន ឧ.សិ ប៉ូច ល័ក្ខ ព្រមទាំងបុត្រ .... ៥០០០៛

ឧ.ស លីយន ឧ.សិ អ៊ុច ចៅ ព្រមទាំងបុត្រ ...... ៤០០០៛

ឧបាសិកា វ៉ាន់ ធី ព្រមទាំងបុត្រ ..................... ៤០០០៛

ឧបាសិកា ឃុយ ហេង ព្រមទាំងបុត្រ .................. ៣០០០៛

ឧបាសិកា សន វ៉ិច ព្រមទាំងបុត្រ ................. ៣០០០៛

ឧបាសិកា ខ្ចៅ ឌី ព្រមទាំងបុត្រ ................. ២០០០៛

ឧបាសិកា អ៊ុន ជា ព្រមទាំងបុត្រ ................. ២០០០៛

ឧបាសិកា គឹម អោន ព្រមទាំងបុត្រ ................. ២០០០៛

| | | |
|---|---|---|
| ចិត្ត ធវី ព្រមទាំងបុត្រ | .................. | ២០០០ ៛ |
| ម៉ឹង ណាង ព្រមទាំងបុត្រ | .................. | ២០០០ ៛ |
| ហែម លន់ មទាំងបុត្រ | .................. | ១០០០ ៛ |




ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត